BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P-K - 1
1967 - 5

ក-213
ក-216

# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

ទស្សនាវដ្ដី ផ្សាយ ពុទ្ធសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ទំព័រ

ផ្នែកសាសនា

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . ៤៥៧
២– ព្រះពុទ្ធសាសនា និង ផ្លូវលោក ព្រះមហា អេង ខេមី រៀបរៀង . . . . . ៤៦៧

ផ្នែកអក្សរសាស្ត្រ

៣– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . ៤៨៣
៤– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . . . ៤៩៣
៥– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឧ. ពាម ស្រាវជ្រាវ (ត) . . . . . . ៤៩៧
៦– ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៥០៥
៧– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៥១១
៨– ឯកសារកម្ពុជសុរិយា លោក ឧ.ពាម ប្រមូលរៀបរៀង (ត) . . . . . . ៥១៩
៩– ចិត្តមិនព្រមចាស់ លោក ញូង-សឿង រៀបរៀង . . . . . . . . ៥២៥
១០– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . ៥៣០

## ផ្នែកកំណាត់ និង ប្រវត្តិការណ៍


១១ – ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ . . . . . . ៥៤០

– សុន្ទរកថា សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ. . . . ៥៤២

១២ – ពិធីបុណ្យរំឭកថ្ងៃកំណើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ . . . . ៥៤៩

១៣ – បុគហ្វាយនៃពុទ្ធសាសនបណ្ឌិត្យ . . . . . . . ៥៥៣


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជា៖ ២៣០៛០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុំសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

## បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ថាំង ប្រែ - រៀបរៀង

ប្បុ. បើដូច្នេះ ផ្លែនៃព្រះពុទ្ធសាសនា មិនគឺសំដៅថា ផលទាំងអស់សុទ្ធតែកើតឡើងអំពីហេតុហើយឬ?

វិ. ពិតដូច្នោះមែន ផលទាំងឡាយតែងអាស្រ័យនូវហេតុជាបច្ចុប្បន្ន ឬអំពីអតីត ។

ប្បុ. ឯពាក្យថា "ហេតុ" នោះ គេហៅថាអ្វីបានទៀត?

វិ. បើពោលសំដៅមនុស្សសត្វ គេហៅថាកម្ម ឬអំពើ គឺថា អំពើដែលយើងធ្វើហើយ អាចនាំមកនូវសេចក្ដីសុខ ឬទុក្ខទោស តាមដំណើរដែលយើងបានប្រព្រឹត្ត ។

ប្បុ. មនុស្សប្រព្រឹត្តទុច្ចរិត អាចគេចចៀសពន់អំពីផលនៃកម្មរបស់ខ្លួនបានឬទេ? ។

វិ. គម្ពីរធម្មបទសំដែងថា ទោះលើផែនដីក្ដី លើអាកាសក្ដី ក្នុងសមុទ្រក្ដី ក្នុងចន្លោះថ្មភ្នំក្ដី បុគ្គលបទុច្ចរិត ពុំអាចនឹងរកកន្លែងដើម្បីចៀសឲ្យផុតអំពីផលនៃកម្មរបស់ខ្លួនបានឡើយ ។

ប្ញ. មនុស្សសុចរិត ចៀសវាងមិនទទួលផលនៃកម្ម ដែលខ្លួនធ្វើហើយនោះបានឬទេ?

វិ. ដោយអំណាចផលកម្មជាកុសលដ៏ច្រើន បុគ្គលនោះ នឹងត្រូវបានទទួលការបរិបូណ៌ដោយគតិ គឺទីកើតរូបកាយ, ពេលវេលា និងចំណេះវិជ្ជាទៅអនាគត ដែលជាហេតុអាចឲ្យចៀសចេញឆ្ងាយពីផលនៃកម្មជាអកុសល ហើយជាជំនួយដល់ការប្រព្រឹត្តឲ្យបាននឹងរឹតតែប្រសើរខ្ពង់ខ្ពស់តទៅទៀតផង ។

ប្ញ. មនុស្សបែបនេះ គេហៅថាដូចម្ដេច ?

វិ. គេហៅថា ជាអ្នកមានគតិសម្បត្តិ, ឧបធិសម្បត្តិ, កាលសម្បត្តិ និងអាយោគសម្បត្តិ ។

ប្ញ. រឿងនេះ មានទំនងស្របគ្នានឹងការសិក្សា ខាងវិទ្យាសាស្ត្រសម័យនេះឬទេ ?

វិ. មានទំនងស្របគ្នាណាស់ មិនគួរសង្ស័យឡើយ ។

ប្ញ. មនុស្សទាំងអស់ អាចនឹងត្រាស់ដឹងជាព្រះពុទ្ធបានឬទេ ?

វិ. ការត្រាស់ដឹង ពុំមែនមានពល់មនុស្ស ក្នុងកល្បតែមួយទេ

ព្រោះថា ដែលនឹងបានជាព្រះពុទ្ធមួយព្រះអង្គ ៗ នោះ ត្រូវកសាងបារមីជាយូរអង្វែងឆ្នាំណាស់ ហើយសត្វលោកទៀត ក៏ត្រូវការនឹងព្រះសាស្តាជួបប្រទះផង ទើបមានព្រះពុទ្ធមួយព្រះអង្គទ្រង់ចុះមកចាប់បដិសន្ធិ ដើម្បីនឹងពន្យល់ផ្លូវទៅកាន់ព្រះនិព្វាន ដែលមនុស្សក្នុងលោក ភ្លេចបោះបង់ចោលហើយនោះ ជាថ្មីម្តងទៀត ។

ប្រ. ច្បាប់ព្រះពុទ្ធសាសនាសំដែងថា មនុស្សនឹងកើតតែលើផែនដីនេះទេ ឬដូចម្តេច ?

ឆ្លើ. តាមសភាវៈធម្មតា មនុស្សមិនមែនយកកំណើតតែលើផែនដីនេះទេ បុគ្គលទីមួយ ៗ អាចនឹងមានកំណើតខ្ពស់ឬទាប មានភាពល្អឬអាក្រក់លើសពីមនុស្សលោកនេះបានតាមកម្លាំងចិត្ត និងកុសលអកុសល ព្រោះភពដែលមនុស្សសត្វត្រូវយកបដិសន្ធិ និងទីតាំងនៃបដិសន្ធិ មានច្រើនជាអនេក ៗ ឯក្បួនវិទ្យាសាស្ត្រក៏មានថ្លែងថា បដិសន្ធិរបស់សត្វរមែងស្របទៅតាមកម្លាំងទឹកចិត្ត ឬកម្លាំងកម្ម ដូចគ្នានឹងសេចក្តីពន្យល់ក្នុងច្បាប់ព្រះពុទ្ធសាសនាដែរ ។

ប្រ. មានភពដទៃទៀត ដែលវិសេស ឬដែលថោកទាបជាងផែនដីយើងនេះដែរឬ ?

ឆ្លើ. ច្បាប់ព្រះពុទ្ធសាសនាពន្យល់ថា មានភពខ្ពស់ទាបល្អអាក្រក់ជាច្រើនបែប, ឯសេចក្តីចំរើនរបស់សត្វដែលស្ថិតនៅក្នុងភពនោះ ៗ ក៏

ប្រកបទៅតាមថ្នាក់តាមឋានខ្ពស់និងទាប តាមលំដាប់ សម្រាប់បុគ្គលនីមួយ ៗ

ប្ញ. ព្រះពុទ្ធជាម្ចាស់ ទ្រង់មានបង្រួញសេចក្តីក្នុងផ្លូវនៃធម៌ និងវិន័យទាំងមូលមកជាគាថា ជាដូចម្តេចឬទេ ?

វិ. មាន ៗ

ប្ញ. ចូរអ្នកពោលមកមើល ?

វិ. សព្វបាបស្ស អករណំ

កុសលស្សូបសម្បទា

សចិត្តបរិយោទបនំ

ឯតំ ពុទ្ធានសាសនំ

(ប្រែជាសេចក្តីថា) កិរិយាមិនធ្វើអំពើបាប ការសន្សំបំពេញនូវកុសល និងការធ្វើចិត្តរបស់ខ្លួនឲ្យផូរផង់ នេះហើយជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ។

ប្ញ. គាថា ៣ បាទខាងលើ មានអ្វីជាសេចក្តីប្លែកឬទេ ?

វិ. មាន, បាទទី១ រួមចូលក្នុងព្រះវិន័យបិដក, បាទទី២ រួមចូលក្នុងព្រះសូត្រ, បាទទី៣ រួមចូលក្នុងព្រះអភិធម្ម ។ គាថានេះ មានពាក្យបាលីតែ៨ម៉ាត់ទេ តែហាក់ដូចជាដំណក់ទឹកសន្សើមដែលអាចផ្ទុះយកពន្លឺនៃពួកផ្កាយទាំងអស់បាន គឺអាចបញ្ចាំងរស្មីនៃព្រះពុទ្ធសាសនាទាំងមូល ៗ

ប្រ. សិក្ខាវិន័យទាំងនេះ បង្ហាញឲ្យដឹងថា ព្រះពុទ្ធសាសនា ជាពាក្យប្រដៅនាំឲ្យខ្ជិលច្រអូស ឬក៏ឲ្យខំស្វាហាប់?

វិ. ត្រង់ “ហាមមិនឲ្យធ្វើបាប” ហាក់ដូចជានាំឲ្យខ្ជិល ក៏ប៉ុន្តែត្រង់ដែលថា ឲ្យសន្សំបំពេញកងការកុសល ហើយសំអាងចិត្តគំនិតឲ្យបរិសុទ្ធផូរផង់នេះ ត្រូវឲ្យមានកិរិយាប្រឹងប្រែងណាស់ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រដៅថា យើងមិនគប្បីពេញចិត្តនឹងភាវៈជាអ្នកគ្មានវឌ្ឍិនោះទេ ក៏ប៉ុន្តែ ត្រូវកាន់កិរិយាល្អជាដរាប ។

ប្រ. ទីពឹងទីរឭកទាំង៣ប្រការ ដែលអ្នកកាន់ព្រះពុទ្ធសាសនាត្រូវប្រតិបត្តិនោះ គឺអ្វីខ្លះ?

វិ. ទីពឹងទីរឭកទាំងនេះ ហៅថា “ត្រៃសរណៈ” គឺ ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធជាម្ចាស់ ទុកដូចជាមគ្គនាយក, ខ្ញុំព្រះករុណាសូមដល់នូវព្រះធម៌ បីដូចជាយាននាំផ្លូវ, ខ្ញុំព្រះករុណាសូមដល់នូវព្រះសង្ឃ បីដូចមគ្គនាយក, រតនវត្ថុទាំង៣ប្រការនេះ ជាពុទ្ធធម៌ ។

ប្រ. បុគ្គល ដែលសូត្រស្វាធ្យាយពាក្យវត្ថុទាំងនេះ មានការសំគាល់ក្នុងចិត្តដូចម្តេច?

វិ. គឺតាំងចិត្តថា យកព្រះពុទ្ធជាសាស្តាដ៏ក្រៃលែង ជាកល្យាណមិត្រ ជាគ្រូ ។ យកព្រះធម៌ដូចជាក្រឹត្យដ៏ឧត្តមគ្មានវិបល្លាស, ជាផ្លូវនៃសុចរិតនិងយុត្តិធម៌ ជាផ្លូវដ៏វិសេស អាចនាំទៅកាន់សន្តិសុខដ៏ឧត្តម ក្នុ

សាកលលោកនេះ ។ យកព្រះអរិយសង្ឃទាំងឡាយ ជាគ្រូអាចារ្យ ជាទិដ្ឋានុគតិ គួយ៉ាងដ៏ជាក់ស្តែង របស់ព្រះធម៌ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងទុកមក ។

បុ. ក្នុងពពួកព្រះភិក្ខុសង្ឃទាំងអម្បាលនេះ មានព្រះសង្ឃអង្គណាដែលទទ់តាបដោយបញ្ញាទិន៍ចិត្តឬទេ ?

វិ. មាន, តែព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ដែលទឹងទុកជាសង្ឃសាវ័ករបស់ព្រះអង្គដូច្នេះ គឺភិក្ខុសង្ឃឯណាដែលបានព្យាយាម ប្រតិបត្តិផ្លូវសីលសិក្ខា ធ្វើបញ្ញាឲ្យកើតឡើង ហើយបានសំរេច នូវអរិយមគ្គនិងអរិយផលទាំង៨ប្រការណាមួយ ។ ព្រះអង្គប្រកាសថា ព្រះសង្ឃដែលរាប់ចូលក្នុងត្រៃសរណៈនេះ គឺ "ព្រះអដ្ឋអរិយបុគ្គល" ក៏គឺសំដៅដល់បុគ្គលដែលបានដល់ហើយ នូវអរិយមគ្គអរិយផលទាំងប្រាំបីប្រការណាមួយ ។ កិរិយាដែលគ្រាន់តែទ្រទ្រង់នូវត្រៃចីវរពណ៌ទឹកអម្ពត់ បានចូលបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនានេះ ពុំមែនជាការគួរឲ្យស្គាល់បានថា ជាអ្នកអស់នូវកិលេសទាំងពួង ដល់នូវភាវៈជាអរហន្ត គួរជាទីគោរពឡើយ ។

បុ. បើដូច្នេះ ពុំមែនពួកភិក្ខុថោកទាបនោះទេឬ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ទទួលយកទៅជាទីពឹងជាមគ្គនាយកនោះ?

វិ. ពិតមែនណាស់ហើយ ។

បុ. សិក្ខាបទ៥យ៉ាង ហៅថា "បញ្ចសីល" ដែលគ្រហស្ថទាំងអស់គ្នាត្រូវសមាទាននោះ បានដល់អ្វីខ្លះ?

វិ. ត្រណាម "សិក្ខាបទ" ទាំងនោះ មាននៅក្នុងពាក្យប្ដេជ្ញាដែលពុទ្ធសាសនិកទាំងឡាយត្រូវស្បថប្រកាសក្នុងព្រះវិហារ គឺ

១- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាវៀរចាកការសម្លាប់សត្វមានជីវិត ។

២- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាវៀរចាកការលួចយកទ្រព្យរបស់អ្នកដទៃ ។

៣- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាវៀរចាកការខុសក្នុងកាមទាំងឡាយ គឺស្រីដែលគេហួងហែងគេ ។

៤- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយានិយាយពាក្យកុហក ។

៥- ខ្ញុំព្រះករុណាសូមសមាទាននូវសិក្ខាបទ គឺកិរិយាមិនផឹកនូវទឹកស្រវឹង ( គឺសុរានិងមេរ័យ ) ។

បុ. មនុស្សប្រកបដោយបញ្ញា កាលមើលប្រទះសិក្ខាបទទាំងនេះហើយ តើនឹងកើតការឃើញដូចម្ដេច?

វិ. នឹងគិតឃើញថា បុគ្គលណាបានប្រព្រឹត្តកាន់តាមដោយហ្មត់ចត់ នឹងអាចចៀសវាងទុក្ខទោសលំបាកក្នុងមនុស្សលោកនេះបាន ។

បើយើងពិចារណាតាមប្រវត្តិសាស្ត្រទៅ ក៏គង់ឃើញថា ទុក្ខលំបាកគ្រប់យ៉ាង កើតមកអំពីការប្រព្រឹត្តកន្លងនូវសិក្ខាបទខាងលើនេះ ណាមួយដោយពិត ។

បុ. បណ្តាសិក្ខាបទទាំងនេះ តើសិក្ខាបទណាខ្លះដែលសឲ្យឃើញថាពុទ្ធបញ្ញត្តិ ជាត្រឹមត្រូវពិត?

វិ. គឺសិក្ខាបទទី១,ទី៣,ទី៥ ព្រោះកិរិយាធ្វើមនុស្សឃាតក្តី ការសេពកាមក្តី និងវត្ថុជាគ្រឿងស្រវឹងក្តី សឹងនាំមកនូវទុក្ខលំបាកដល់អ្នកប្រព្រឹត្តចំនួន ៩៨ ភាគរយនៃសេចក្តីទុក្ខរបស់មនុស្សលោក ។

បុ. អ្នកដែលប្រព្រឹត្តកាន់ ធ្វើតាមសិក្ខាបទទាំងនេះ នឹងបានដល់ប្រយោជន៍អ្វីខ្លះ?

វិ. បានកុសលតិចច្រើនតាមកំឡាំង តាមលក្ខណៈនៃការប្រតិបត្តិតាមពេលវេលាដែលរក្សា និងតាមចំនួនសិក្ខាបទ គឺថាបើអ្នកណារក្សាតែសិក្ខាបទ ១ ហើយចោលសិក្ខាបទ ៤ ឯទៀតនោះ នឹងទទួលកុសលតែអំពីសិក្ខាបទដែលខ្លួនរក្សាប៉ុណ្ណោះ អ្នកដែលបានរក្សាខ្ជាប់ខ្ជួននូវសិក្ខាបទទាំង ៥ ។ ទៅអនាគតជាតិនឹងបានទៅកើតក្នុងភពខ្ពង់ខ្ពស់គួរជាទីរីករាយយ៉ាងក្រៃលែង ។

បុ. សិក្ខាបទណាខ្លះទៀត ដែលគ្រហស្ថគួរគប្បីកាន់យកហើយប្រតិបត្តិតាមសេចក្តីស្ម័គ្រ?

វិ. គឺអដ្ឋសីលឧបោសថសីល ៨ ដែលមានសិក្ខាបទពាក់ព័ន្ធដូចខាងលើ តែលុបពាក្យថា "ស្ត្រីដែលគេហួងហែងហេង" គឺ វៀរចាកការសេពមេថុនធម្មទៅ ហើយបន្ថែមសិក្ខាបទ ៣ ទៀត គឺ

– ខ្ញុំព្រះករុណា សូមសមាទានទូវសិក្ខាបទ គឺវៀរចាកការមិនបរិភោគអាហារក្នុងពេលវិកាល ។

– ខ្ញុំព្រះករុណា សូមសមាទានទូវសិក្ខាបទ គឺវៀរចាកការរាំច្រៀងដេញដំប្រគំតូរ្យតន្ត្រី ល្បែងរបាំនិងផ្កាកំរង គ្រឿងក្រអូបនិងគ្រឿងតាក់តែងកាយ ។

– ខ្ញុំព្រះករុណា សូមសមាទានទូវសិក្ខាបទ គឺវៀរចាកការដេកអង្គុយលើទីសេនាសនៈខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរ ។ បុគ្គលអ្នកវៀរចាកកាម ត្រូវចៀសពន់ទីដេកអង្គុយដែលនាំឲ្យសម្រេចក្នុងផ្លូវកាមគុណនេះ ។

ឬ. ពុទ្ធសាសនិកជនពន្យល់អំពីកុសលថាដូចម្តេច?

វិ. ថាគ្មានអំពើខាងក្រៅណាមួយ ដែលអាចនាំមកនូវកុសលបានទេ, កុសលទាំងអស់ សុទ្ធតែអាស្រ័យហេតុខាងក្នុងជីវិត ដែលនាំឲ្យធ្វើអំពើនោះឡើង ។

ឬ. ចូរអ្នកលើកឧទាហរណ៍មួយមកមើល?

វិ. អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ ទុកជាបានចំណាយទ្រព្យអស់

ច្រើន សង់វិហារសាលា សាងព្រះពុទ្ធរូប ធ្វើពិធីបុណ្យ, ទំនុកបំរុងព្រះភិក្ខុសង្ឃ ឲ្យទានដល់ស្មូមយាចក, ដាំដើមឈើ ជីកស្រះ សង់សាលាសំណាក់តាមផ្លូវសម្រាប់អ្នកដំណើរក៏ដោយ បើអ្នកនោះធ្វើអំពើទាំងនេះដើម្បីយកមុខឲ្យគេអួតសរសើរ ឬ ដោយប្រការណាចំពោះតែរូបខ្លួនមួយ អ្នកនោះឈ្មោះថា បានផលតិចស្តួចស្តើងទេ ។ បើគ្រាន់តែធ្វើបន្តិចបន្តួចក៏ពិតមែន តែធ្វើដោយចិត្តសប្បុរស ដោយចិត្តសទ្ធា ធ្វើអំពើល្អដល់អ្នកដទៃ ទើបបានបុណ្យកុសលច្រើនជាងដោយពិត ។ អំពើល្អណាមួយដែលកើតដោយចិត្តទុច្ចរិត ដោយបំណងអាក្រក់ អាចនាំមកនូវប្រយោជន៍ដល់តែអ្នកដទៃប៉ុណ្ណោះ ពុំមែនជាប្រយោជន៍ដល់អ្នកដែលធ្វើនោះឡើយ ។

បុគ្គលដែលគ្រាន់តែទទួលអនុមោទនា ត្រេកអរចំពោះអំពើល្អរបស់អ្នកដទៃ គង់បានទទួលចំណែកកុសលដូចគ្នាដែរ ឲ្យតែមានសមានចិត្តពិតប្រាកដ ពុំមែនដោយធ្វើកលមាយាធ្វើអំពើលាមកវិញ ។

បុ. អំពើកុសលណា ដែលលោកចាត់ថាមានផលច្រើនជាងអំពើកុសលទាំងពួង ?

វិ. ក្នុងគម្ពីរធម្មបទ លោកប្រាប់ថាការសំដែងធម៌ ប្រដៅចង្អុលបង្ហាញប្រាប់ច្បាស់ ប្រាប់ផ្លូវឲ្យអ្នកដទៃធ្វើល្អធ្វើត្រូវ មានផលច្រើនក្រៃលែងជាងការជាកុសលទាំងពួង ។

(នៅមានត)

# ព្រះពុទ្ធសាសនា និង ផ្សវិលោក

ព្រះមហា អេង·ខេមី

វត្តស្វាយពពែ សង្កាត់លេខ ៦ ក្រុងភ្នំពេញ

រៀបរៀង

---

## សេចក្តីផ្តើម

កាលពីសម័យបុរាណជាយូរយារណាស់មកហើយ មានមនុស្សមួយពួកដែលចូលចិត្តប្រៀនប្រដៅគេឲ្យបដិបត្តិធម៌ ដោយយល់ថាជាការធ្វើខ្លួនឯងមិនឲ្យសូន្យតាកប្រយោជន៍ ក្នុងការដែលបានកើតមកជាមនុស្ស និងជាការជួយសង្គ្រោះមហាជនឲ្យបានសម្រេចប្រយោជន៍ធំធេង ៗ មនុស្សពួកនេះ យ៉ាងជាន់ខ្ពស់ស៊ូលះសេចក្តីសុខផ្ទាល់ខ្លួន លះទ្រព្យសម្បត្តិសក្តិយសហើយចេញទៅទ្រទ្រង់ភេទជាអ្នកបួស ស្វែងរកផ្លូវបដិបត្តិដែលខ្លួនយល់ឃើញថា ត្រូវមានប្រយោជន៍ នាំយកមកទូន្មានដឹកនាំមហាជនឲ្យបដិបត្តិតាម ។

ក្នុងចំណោមមនុស្សពួកនេះ ព្រះបរមសាស្តារបស់យើងក៏មួយព្រះអង្គនិងគេដែរ ដែលពេញព្រះទ័យនឹងដឹកនាំគេឲ្យប្រព្រឹត្តធម៌ ដោយព្រះអង្គហ៊ានលះបង់គ្រប់បែបយ៉ាង ដើម្បីប្រយោជន៍ដល់មហាជន ។ សេចក្តីអស្ចារ្យរបស់ព្រះអង្គ ក្នុងការបំពេញប្រយោជន៍សាធារណៈ ដែលប្រជាពលលោកគួរគោរពស្ងប់ស្ងែង និងគួរកត់សំគាល់នោះ មាន ៣ ប្រការគឺ

១- ការចេញទ្រង់ព្រះផ្នួស ព្រះអង្គជាមកុដរាជកុមារ ដែលត្រូវបានទទួលរាជសម្បត្តិតព្រះវង្សពីព្រះវរបិតា ហើយតាមទំនាយថ្វាយថា ត្រូវបានជាស្តេចចក្រពត្តិដ៏ធំសម្បើមថែមទៀតផង ។ តែព្រះអង្គបានទ្រង់លះបង់ចោលអស់ ហើយចេញទ្រង់ព្រះផ្នួស ដោយឥតមានព្រះទ័យនឹកអាល័យស្តាយក្រោយទាល់តែសោះ ។

២- ទុក្ករកិរិយា ក្នុងការស្វែងរកមោក្ខធម៌ ព្រះអង្គទ្រង់បានបដិបត្តិយ៉ាងតឹងរ៉ឹងបំផុត គឺទ្រង់អត់ព្រះក្រយាស្ងោយ រហូតដល់ព្រះកាយស្គាំងស្គមទៀបនឹងអស់ព្រះជន្ម តែព្រះអង្គមិនរវល់នឹងព្រះជន្មជីវិតឡើយ ។

៣- ការប្រោសសត្វ ពេលដែលព្រះអង្គទ្រង់ត្រាស់ដឹងហើយ ព្រះអង្គមិនបានសម្ងំយកសុខតែមួយព្រះអង្គឯងប៉ុណ្ណោះ ទ្រង់ព្យាយាមសំដែងធម៌ទូន្មានប្រៀនប្រដៅសត្វ គ្មានសំរាកថ្ងៃណាមួយ រហូតទល់គ្នានឹងថ្ងៃដែលទ្រង់បរិនិព្វាន ។

ក្នុងការប្រោសសត្វនេះសោត ព្រះអង្គបានទ្រង់សំដែងបញ្ជាក់ថា ជនណាបូជាតថាគតដោយអាមិសបូជា អ្នកនោះមិនឈ្មោះថាស្រឡាញ់តថាគតទេ ជនណាបូជាតថាគតដោយការបដិបត្តិតាមពាក្យប្រដៅរបស់តថាគត អ្នកនោះទើបឈ្មោះថាស្រឡាញ់តថាគត ។ ព្រះពុទ្ធដីកានេះ សឲ្យឃើញច្បាស់ថា ព្រះអង្គគ្មានប្រាថ្នាលាភសក្ការៈប្ដូរប្រយោជន៍ផ្ទាល់ព្រះអង្គទាល់តែសោះ ដែលប្លែកពីគណាចារ្យមេលទ្ធិដទៃ ៗ ក្នុងសម័យនោះ ។

ពាក្យប្រៀនប្រដៅដែលព្រះអង្គទ្រង់សំដែងអស់រយៈពេល ៤៥ ឆ្នាំ គឺចាប់ពីពេលត្រាស់ដឹង រហូតដល់ពេលបរិនិព្វាននោះ ហៅថា ព្រះពុទ្ធ-សាសនា ។ ព្រះពុទ្ធសាសនាបានឋិតនៅក្នុងលោកនេះជាង ២៥០០ ឆ្នាំហើយ ។ មនុស្សជំនាន់ក្រោយខ្លះ ដែលបានសិក្សាវិជ្ជាការខាងផ្លូវលោកមកហើយ ច្រើនតែរិះគន់ថា ព្រះពុទ្ធសាសនា មានប្រយោជន៍សម្រាប់តែអ្នកបួស និងមនុស្សចាស់ ៗ ដែលកាន់ឈើច្រត់ហើយប៉ុណ្ណោះទេ គ្មានប្រយោជន៍អ្វីសម្រាប់ក្មេង ៗ និងមនុស្សអ្នកប្រកបការងារចិញ្ចឹមជីវិតទេ ។ តាមការពិត ព្រះពុទ្ធសាសនាមានប្រយោជន៍សម្រាប់មនុស្សគ្រប់ភេទគ្រប់វ័យ គ្រប់ជាន់ថ្នាក់ ។

គោលធម៌មួយខាងព្រះពុទ្ធសាសនា ដែលហៅថា ឥទ្ធិបាទធម៌ គឺជាវិធីការដែលមនុស្សប្រតិបត្តិតាមហើយ នឹងឲ្យសម្រេចប្រយោជន៍ដូចសេចក្តីប្រាថ្នា ហើយសម្រាប់មនុស្សគ្រប់គ្នា គ្មានរើសមុខឡើយ ។ ឥទ្ធិបាទធម៌នោះ មាន ៤ យ៉ាង គឺ

១– ឆន្ទៈ សេចក្តីពេញចិត្តក្នុងកិច្ចការដែលធ្វើ,

២ - វីរិយៈ សេចក្តីប្រឹងប្រែងព្យាយាមធ្វើកិច្ចការនោះ,

៣– ចិត្តៈ ការយកចិត្តទុកដាក់ក្នុងកិច្ចការនោះ,

៤ - វីមំសា ការពិនិត្យពិច័យកិច្ចការដែលធ្វើនោះ,

គប្បីសង្កេតមើលថា ក្មេង បើគ្មានឆន្ទៈ គឺសេចក្តីពេញចិត្តនឹងទៅ

រៀន តើក្មេងនោះទៅរៀនកើតឬទេ ? សូម្បីតែត្រូវមនុស្សចាស់បង្ខិតបង្ខំក៏ដោយចុះ បើក្មេងនោះមិនពេញចិត្តនឹងទៅទេ ក៏មិនអាចនឹងទៅបានឡើយ, យើងអាចឃើញបាន ដូចក្មេងដែលគេបវេះជាដើម ។ អ្នកធ្វើការពេជការ អ្នកធ្វើស្រែចំការ បើគ្មានឆន្ទៈគឺសេចក្តីពេញចិត្តក្នុងការងារនោះ តើនឹងទៅធ្វើកើតដែរឬទេ? ហើយបើមានតែឆន្ទៈពេញចិត្តនឹងធ្វើ តែខ្វះសេចក្តីប្រឹងប្រែង, បើមានសេចក្តីពេញចិត្តនិងការប្រឹងប្រែងហើយ តែខ្វះការយកចិត្តទុកដាក់ក្នុងកិច្ចការនោះ ឬបើមានគ្រប់តាំង ៣ ខាងដើមហើយ តែខ្វះខទី ៤ គឺពេញចិត្ត, ប្រឹងប្រែង និងយកចិត្តទុកដាក់ធ្វើហើយ តែមិនមានការត្រួតពិនិត្យមើល ធ្វើទៅដោយខ្ជីខ្ជា តើកិច្ចការនោះនឹងបានផលបរិបូណ៌ដែរឬទេ? តាមការពិត មិនបានផលឡើយ បើនឹងបានក៏បានបន្តិចបន្តួច មិនសមល្មមនឹងទំហំកិច្ចការ គឺសម្រេចផលតិចច្រើនទៅតាមលំដាប់អង្គនោះឯង បើខ្វះតាំង ៤ តែមួយនោះ ក៏នឹងមិនបានសម្រេចផលអ្វីសោះតែម្តង ។ មនុស្សដែលធ្វើការអ្វីទៅហើយ មិនបានទទួលលទ្ធផលអ្វីសោះនោះ បើពិនិត្យស្រាវជ្រាវទៅហើយ នឹងឃើញបានថា ខ្វះគោលណាមួយ ក្នុងបណ្តាគោលតាំង ៤ នោះ ឬក៏ខ្វះតាំងអស់តែម្តង ។ សេចក្តីអធិប្បាយយ៉ាងខ្លីប៉ុណ្ណេះ បញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាមានប្រយោជន៍ដល់មនុស្សគ្រប់ភេទ វ័យ និងគ្រប់ជាន់ថ្នាក់ មិនមែនសម្រាប់តែមនុស្ស

ពួកណាគេទណាទេ ។ អ្នកខ្លះទៀតទិទៀនថា ព្រះពុទ្ធសាសនាធ្វើឲ្យមនុស្សខ្ជិល មិនទាន់សម័យ ទាញផ្លូវលោកគេថយណាស់ អ្នកប្រាជ្ញខាងផ្លូវលោក គេបានរៀបចំឲ្យមានរបៀបបែបផែនក្បួនតម្រា ដែលមានផលប្រយោជន៍ដល់ជីវិតមនុស្ស តាមដែលមនុស្សត្រូវការ ជាចាំបាច់ ដូចរឿងសង្គមសាស្ត្រនិងសេដ្ឋកិច្ច ជាដើម ។ ឯព្រះពុទ្ធសាសនាគ្មានទូន្មានបង្ហាត់បង្រៀនអំពីវិជ្ជាទាំងនេះ ដែលជាប្រយោជន៍ដល់ជីវិតមនុស្ស ដូចគេសោះ ។ អ្នកដែលទិទៀនបែបនេះ មិនមកពីអ្វីទេ គឺមកពីអ្នកនោះឯងសិក្សារឿងព្រះពុទ្ធសាសនាតិចពេក ។ តាមការពិត វិជ្ជាទាំងនោះ ខាងព្រះពុទ្ធសាសនាមានទាំងអស់ ហើយមានមុនផ្លូវលោកទៀតផង គឺព្រះពុទ្ធជាម្ចាស់ បានទ្រង់ត្រាស់សំដែងទុកមកជាង ២៥០០ ឆ្នាំហើយ ឯអ្នកប្រាជ្ញខាងផ្លូវលោក ទើបនឹងបង្កើតវិជ្ជាទាំងនោះឡើង នៅពេលក្រោយនេះទេ ។

ដើម្បីនឹងដោះស្រាយរឿងនេះ អ្នកសរសេរទើបនាំយកគោលធម៌ខាងព្រះពុទ្ធសាសនាខ្លះមកធ្វើអត្ថាធិប្បាយ ប្រៀបធៀបនឹងហេតុការណ៍ដែលកើតមានឡើងក្នុងលោក ដើម្បីឲ្យលោកអ្នកអានបានស្គាល់នូវតម្លៃនិងគុណប្រយោជន៍នៃព្រះពុទ្ធសាសនា ។ ហេតុនោះ ទើបឲ្យឈ្មោះរឿង ព្រះពុទ្ធសាសនា និង ផ្លូវលោក ដោយអធិប្បាយប្រៀបធៀបគ្នាជាលំដាប់ ៗ តទៅ ។

# អំពីសន្តិភាព

មនុស្សក្នុងលោកទាំងមូលនេះ មិនថាជាតិណា សាសន៍ណា ប្រុសស្រី ក្មេងចាស់ទេ សុទ្ធតែចង់បានសេចក្តីសុខ ស្អប់ខ្លាចទុក្ខដូចគ្នាទាំងអស់ ។ តែតាំងពីបុរាណកាលមក ការស្វែងរកសេចក្តីសុខផ្លូវលោក ច្រើនតែជាការបៀតបៀនគ្នា ដែលជាហេតុឲ្យកើតសេចក្តីទុក្ខក្តៅក្រហាយដល់គ្នានិងគ្នាទៅវិញ ។ ពលរដ្ឋនៃប្រទេសមួយលើកទ័ពទៅច្បាំងកាប់សម្លាប់ពលរដ្ឋក្នុងប្រទេសមួយទៀត ដោយសង្ឃឹមថា កាលបើបង្ក្រាបបានហើយ ខ្លួនក៏នឹងបានសេចក្តីសុខ ព្រោះនឹងមានអំណាចលើប្រទេសនោះគ្រប់បែបយ៉ាង ។ តែតាមការពិត ប្រទេសដែលចាញ់គេនោះ ខាងផ្លូវចិត្ត ឥតព្រមចុះចាញ់ទាល់តែសោះ តែដោយខ្លួនទន់ខ្សោយខាងផ្លូវកម្លាំង មិនអាចតស៊ូនឹងគេបាន ក៏ត្រូវតែអត់ទ្រាំទទួលបរាជ័យទៅសិន ដោយមានគំនិតគិតបង្កើតគំនុំគុំគួនព្យាបាទ គិតរកឧបាយ ដើម្បីនឹងបំបាក់បំបែកគូសត្រូវរបស់ខ្លួនយកជ័យជំនះមកវិញជានិច្ច ។ លុះពេលដែលមានកម្លាំងល្មមនឹងតស៊ូបាន អ្នកចាញ់នោះ ក៏លើកទ័ពទៅធ្វើសង្គ្រាមកាប់សម្លាប់យកជ័យជំនះពីអ្នកដែលបំបាក់បំបែកខ្លួនពីកាលមុននោះ ជាហេតុឲ្យអ្នកដែលគិតថានឹងបានសុខស្រួលពីមុននោះ ត្រឡប់ទៅជាបានសេចក្តីទុក្ខក្តៅក្រហាយឡើងវិញ ។ ការស្វែងរកសេចក្តីសុខខាងផ្លូវលោកបែបនេះ មិនបានសេចក្តីសុខសមតាមប្រាថ្នាសោះ, ផ្ទុយទៅវិញ ត្រឡប់ជា

បានតែសេចក្តីទុក្ខក្តៅក្រហាយជានិច្ច ៗ ទើបអ្នកដែលចង់ស្វែងរកសេចក្តីសុខសន្តិភាពខាងផ្លូវលោក នេះតែងព្យាយាមផ្លាស់ប្តូរមធ្យោបាយ ជាលំដាប់ ៗ មក ៗ លុះមកដល់ពេលមុននឹងកើតសង្គ្រាមលោកលើកទី ១ ព្រះមហាក្សត្រនិកូឡាសទី ២ នៃប្រទេសរុស្ស៊ី ទ្រង់បានស្នើឲ្យមានការប្រជុំរវាងប្រជាជាតិនានាពិភាក្សាបញ្ហាបន្ថយសព្វាវុធ ដើម្បីចៀសវាងការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ៗ តែការស្នើរបស់ព្រះអង្គមិនបានសម្រេចផល ទើបនៅឆ្នាំ ១៩១៤ ក៏កើតសង្គ្រាមលោកលើកទី ១ ឡើង ៗ លុះមកដល់ឆ្នាំ ១៩១៨ ពេលដែលសង្គ្រាមលោកលើកទី១ ស្ងប់ហើយ ប្រជាជាតិនានាបានរួបរួមគ្នាផ្តើមចាត់តាំងអង្គការមួយឡើង ហៅថា "សន្និបាតជាតិ" សម្រាប់ជាទីប្រជុំពិភាក្សាបញ្ហាផ្សេង ៗ រវាងប្រទេស ៗ អង្គការនេះមានគោលបំណងធំបំផុត គឺដើម្បីរក្សាទុកនូវសុវត្ថិភាព និងសន្តិភាព នៃប្រជា-ពលរដ្ឋក្នុងប្រទេសនានា និងពួតដៃគ្នារវាងប្រទេស ដើម្បីជួយទំនុកបំរុងឲ្យសាកលលោកមានសេចក្តីចំរើនលូតលាស់ ដែលជាហេតុឲ្យកើតសេចក្តីសុខសន្តិភាព ៗ តែអង្គការនេះសោត ក៏មិនអាចផ្តល់នូវសន្តិភាពដ៏បរិបូណ៌ដល់ប្រជាពលលោកបាន ទើបនៅឆ្នាំ ១៩៣៦ សង្គ្រាមលោកលើកទី ២ ក៏បានផ្ទុះឡើងទៀត ៗ លុះសង្គ្រាមលោកលើកទី ២ នេះស្ងប់ចុះហើយ នៅឆ្នាំ ១៩៤៥ គឺ ចិន សហរដ្ឋអាមេរិក បារាំងសែស អង់គ្លេស និងរុស្ស៊ី ក៏បានប្រជុំព្រមព្រៀងគ្នាបង្កើតអង្គការមួយថ្មីទៀត

មានឈ្មោះថា អង្គការសហប្រជាជាតិ បានចាប់ផ្ដើមអនុវត្តកិច្ចការឡើងក្នុងឆ្នាំ ១៩៤៥ នោះឯង ។ គោលបំណងធំបំផុតនៃអង្គការនេះ គឺដើម្បីស្វែងរកសន្តិភាពឲ្យដល់សាកលលោក ដោយប្រើវិធីប្រជុំពិភាក្សាប្តូរយោបល់គ្នារវាងប្រជាជាតិនានាក្នុងសាកលលោក សំដែងគោលបំណងរៀងៗខ្លួនចំពោះទីប្រជុំ និងជួយដោះស្រាយបញ្ហាផ្សេងៗដែលកើតនៅប្រទេសនោះៗ ដើម្បីការពារកុំឲ្យកើតសង្គ្រាមកាប់សម្លាប់គ្នាបាន ហើយនឹងចាត់ឲ្យមានផ្នែកសម្រាប់ជួយសង្គ្រោះប្រទេសនានា ដែលខ្វះខាតជាដើម ។ តាំងនេះ ដោយយល់ឃើញថា មនុស្សយើង តែងចង់បានសេចក្ដីសុខដូចៗគ្នាតាំងអស់ កាលបើចូលមករួមប្រជុំសំដែងយោបល់ ឲ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក ហើយក៏មុខជានឹងមានសេចក្ដីមេត្តាករុណាអាណិតអាសូរគ្នានិងគ្នា លែងបៀតបៀនគ្នា ដែលជាហេតុឲ្យកើតសេចក្ដីស្ងប់សុខឡើង ហេតុនោះ ទើបព្រមព្រៀងគ្នាចាត់តាំងអង្គការនេះឡើង ដោយមានទីស្នាក់ការធំនៅក្រុងញូវយ៉ក សហរដ្ឋអាមេរិក ហើយនឹងប្រទេសនានាក៏បានជួយឧបត្ថម្ភគាំទ្រ ជាហេតុឲ្យបានគង់វង់នៅរហូតមកដល់បច្ចុប្បន្នកាលនេះ ។ តែទុកជាយ៉ាងនេះ ក៏សាកលលោកនៅតែមិនបានសេចក្ដីស្ងប់សុខ សមតាមសេចក្ដីប្រាថ្នារបស់មនុស្សទៅ, ការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ការបៀតបៀនគ្នា ក៏នៅតែមាន មិនបានសាបសូន្យឡើយ ។ នេះឯងគឺជាវិធីស្វែងរកសេចក្ដីសុខសន្តិភាពខាងផ្លូវ

លោក ដែលមានដំណើរជាការចងពៀរ ទើបប្រជាពលលោកមិនបាន សេចក្ដីសុខសមតាមសេចក្ដីប្រាថ្នា ។

ខាងផ្លូវព្រះពុទ្ធសាសនា ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់ប្រាប ច្បាស់ថា មនុស្សខ្លះទៅ ពេលដែលនឹងស្វែងរកសេចក្ដីសុខ ក៏គិតតែត្រឹម ខ្លួនឯងមួយប៉ុណ្ណោះ ត្រង់ការស្វែងរកសេចក្ដីសុខរបស់ខ្លួននោះប៉ះទង្គិច ទៅលើប្រយោជន៍អ្នកដទៃ ធ្វើឲ្យអ្នកដទៃកើតសេចក្ដីទុក្ខក្ដៅក្រហាយនោះ មិនបានគិតដល់សោះ ។ យើងអាចសង្កេតឃើញបានដូចអ្នកសម្លាប់សត្វ មាន់ទាជាដើម តែងតែគិតសប្បាយរីករាយក្នុងចិត្តថា នឹងបានឆ្ងាញ់ ពីសាដោយបានបរិភោគសាច់មាន់ទានោះ ត្រង់ដែលសត្វនោះបានទទួល សេចក្ដីទុក្ខភ័យស្ដាយជីវិតយ៉ាងណានោះ ខ្លួនគ្មានគិតទាល់តែសោះ ។ តែពេលដែលមានអ្នកណាមួយមានចិត្តក្លាហាន មិនចាំបាច់ដល់ទៅយក អាវុធមកកាប់សម្លាប់អ្នកដែលកាប់សម្លាប់សត្វ មានមាន់ជាដើមនោះឡើយ គ្រាន់តែយកដៃទៅទះតប់ ឬហៅអា-មឹងមួយម៉ាត់ប៉ុណ្ណោះ អ្នកនោះឯង រមែងប្រឡាតក្រោធខឹង កើតសេចក្ដីក្ដៅក្រហាយក្នុងចិត្ត ព្រោះប្រកាន់ ថាគេមើលងាយខ្លួន តែត្រង់ដែលខ្លួនយកសត្វមានជីវិត ស្រឡាញ់ជីវិត ទៅកាប់សម្លាប់ផ្ដាច់ជីវិតគេនោះ ខ្លួនគ្មានគិតដល់សេចក្ដីទុក្ខ របស់គេ សោះ ។ ម្យ៉ាងទៀត អ្នកដែលមានសេចក្ដីទុក្ខលំបាក ព្រោះការខ្វះអាហារ ទទួលទាន ខ្វះសំពត់ស្លៀកពាក់ ហើយមិនខំស្វែងរកដោយផ្លូវសុចរិត បែរ

ជាទំលួចប្លន់ឆក់ដណ្តើមទ្រព្យរបស់អ្នកដទៃ យកមកបំពេញសេចក្តីខ្វះខាតរបស់ខ្លួន ឲ្យខ្លួនបានសុខ ត្រង់ដែលគេបានទុក្ខក្តៅក្រហាយស្តាយទ្រព្យសម្បត្តិព្រោះតែខ្លួនទៅលួចប្លន់នោះ ខ្លួនគ្មានគិតបន្តិចបន្តួចសោះ សំឡឹងយកសេចក្តីសុខចំពោះតែខ្លួនឯងម្នាក់ប៉ុណ្ណោះ ។ ឯអ្នកម្ចាស់សោក ក៏មានការគុំគួន និងរកឱកាសព្យាបាទតបវិញដែរ ដែលជាហេតុនាំឲ្យមានការចងពៀរនឹងគ្នា បៀតបៀនគ្នាមិនចេះអស់មិនចេះហើយ ។ ព្រះពុទ្ធជាម្ចាស់ ទើបទ្រង់ត្រាស់សំដែងទុកថា " ពៀរមិនដែលស្ងប់ដោយការចងពៀរបានទេ " គឺថា បើនៅតែមានការចងចិត្តប្រទូសរ៉ាយគ្នាទៅវិញទៅមកនោះ មនុស្សមិនអាចនឹងស្រឡាញ់ សះស្រេលគ្នាបានទេ, សត្វទាំងឡាយតែងតក់ស្លុតចំពោះអាជ្ញា គឺការបៀតបៀនពីអ្នកដទៃ, ជីវិត ជាទីស្រឡាញ់របស់សត្វទាំងពួង, មនុស្សត្រូវយកខ្លួនឯងជាគ្រឿងប្រៀបធៀប ហើយកុំបៀតបៀន កុំសម្លាប់អ្នកដទៃ, " អ្នកណា ស្វែងរកសុខដល់ខ្លួន ហើយបៀតបៀនសត្វដទៃ ដែលគេប្រាថ្នាសុខដែរនោះ អ្នកនោះ មិនបានជួបប្រទះនឹងសេចក្តីសុខជាដាច់ខាត " ។ តាមន័យព្រះពុទ្ធភាសិតនេះ ឃើញថា មនុស្សយើងគ្រប់រូប ដែលស្រឡាញ់សុខ ត្រូវកុំបៀតបៀនគេ ព្រោះគេស្រឡាញ់សុខដូចយើងដែរ កាលបើយើងទៅបៀតបៀនគេ គេក៏ក្តៅក្រហាយ ហើយនឹងបៀតបៀនយើងវិញ ជាហេតុឲ្យយើងមិនបានសុខដែរ ដែលជាការចងពៀររកទីបំផុតគ្មាន ។ កាលបើការចងពៀរ

ការបៀតបៀនគ្នា មានផលប៉ុណា សេចក្ដីទុក្ខក្ដៅក្រហាយ ក៏មាននៅផលប៉ុនោះដែរ នឹងរកសេចក្ដីសុខស្ងប់ស្ងៀមមិនបានឡើយ លុះត្រាតែមនុស្សឈប់បៀតបៀនគ្នានោះ ទើបនឹងបានសេចក្ដីសុខសមតាមប្រាថ្នា សមនឹងព្រះពុទ្ធភាសិតមួយបទទៀតថា « ការមិនបៀតបៀនគ្នា ជាសុខក្នុងលោក » ។ ដោយអាស្រ័យហេតុនេះហើយ ទើបព្រះពុទ្ធជាម្ចាស់ ដែលជាសាស្ដាឯកក្នុងលោក ព្រះអង្គទ្រង់ត្រាស់សំដែងនូវវិធីបំបាត់ការបង្កៀតនឹងគ្នា ដើម្បីបំបាត់ការធ្វើសង្គ្រាម កាប់សម្លាប់គ្នានេះទុកមក ដោយទ្រង់សំដែងតាំងផ្លូវវិន័យ តាំងផ្លូវធម៌ ដែលហៅថា « សីលធម៌ » គឺសីល ៥ និងធម៌ ៥ ដូចតទៅនេះ ៖

## បញ្ចសីល

១ ទ្រង់ហាមមិនឲ្យសម្លាប់សត្វបំបាត់ជីវិតគេ តាំងអំពីសត្វជាន់ទាបរហូតដល់មនុស្ស ។

២– ទ្រង់ហាមមិនឲ្យលួចប្លន់ឆក់ដណ្ដើមទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ។

៣– ទ្រង់ហាមមិនឲ្យប្រព្រឹត្តខុសកាម គឺមិនឲ្យរំលោភលើប្រពន្ធគេ រំលោភលើបុត្រធីតាភរិយាគេ ។

៤– ទ្រង់ហាមមិនឲ្យនិយាយកុហកបញ្ឆោតអ្នកដទៃ ។

៥– ទ្រង់ហាមមិនឲ្យផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជា

ហេតុឲ្យកើតសេចក្ដីប្រមាទ ខូចសតិស្មារតី ហ៊ានធ្វើអំពើអាក្រក់ផ្សេងៗ ដោយឥតអៀនខ្មាស ។

## បញ្ចធម៌

១– ទ្រង់ប្រដៅឲ្យមានមេត្តា ករុណា អាណិតអាសូរដល់មនុស្សសត្វទូទៅ ។

២– ទ្រង់ប្រដៅឲ្យប្រកបការចិញ្ចឹមជីវិតតាមសម្មាជីវៈ គឺគេទទួលបានចិញ្ចឹមជីវិតដោយសុចរិតត្រឹមត្រូវ តាមគន្លងធម៌ ចៀសវាងការចិញ្ចឹមជីវិតដោយផ្លូវទុច្ចរិត ។

៣– ទ្រង់ប្រដៅឲ្យសង្រួមក្នុងកាម ឲ្យសន្ដោសត្រេកអរតែនឹងភរិយារបស់ខ្លួន ។

៤– ទ្រង់ទូន្មានឲ្យនិយាយតែសេចក្ដីពិត និយាយតែពាក្យផ្អែមល្ហែម មានផលមានប្រយោជន៍ ។

៥– ទ្រង់ប្រដៅឲ្យតាំងសតិសម្បជញ្ញៈ សង្រួមរាំងក្នុងអារម្មណ៍ផ្សេងៗ ជានិច្ច ។

សីល ៥ និង ធម៌ ៥ ដូចរៀបរាប់មកខាងលើនេះ គឺជាគុណវិធីដ៏វិសេសមួយសម្រាប់ឲ្យមនុស្សប្រតិបត្តិតាម ដើម្បីកុំឲ្យមានការបង់ពៀរនឹងគ្នា កុំឲ្យបៀតបៀនគ្នា ដោយឲ្យចេះគិតយកចិត្តអ្នកដទៃមកដាក់នឹងចិត្តខ្លួន គឺឲ្យចេះគិតពិចារណាប្រៀបធៀបថា ចិត្តរបស់យើងស្រឡាញ់សេចក្ដី

សុខ ស្រឡាញ់ជីវិត ស្អប់ខ្ចបទុក្ខលំបាកយ៉ាងនោះដែរ ។ គេបៀតបៀនយើងដោយកាយវាចា យើងបានសេចក្ដីទុក្ខក្ដៅក្រហាយយ៉ាងណា យើងបៀតបៀនគេវិញ គេក៏មានសេចក្ដីទុក្ខក្ដៅក្រហាយដូចយើងយ៉ាងនោះដែរ ។ កាលពិចារណាឃើញដូច្នោះហើយ ត្រូវបេះផ្សាយមេត្តាអាណិតអាសូរដល់គ្នានឹងគ្នា តាំងចិត្តចៀសវាង ការបៀតបៀនគ្នាប្រទូស-រ៉ាយគ្នាតរៀងទៅ ដែលជាហេតុឲ្យកើតសេចក្ដីសុខសន្តិភាពដល់មនុស្សគ្រប់ៗគ្នា ។ អាចនឹងមានសំនួរថា បើពិតដូច្នេះមែន ចុះហេតុអ្វីក៏ប្រទេសដែលកាន់ព្រះពុទ្ធសាសនាដូចគ្នានៅតែមានការទាស់ទែងខ្វែងគំនិតគ្នាមានការបៀតបៀនដែរ ? ឆ្លើយថា ព្រោះពលរដ្ឋនៃប្រទេសទាំងនោះល្មើសព្រះពុទ្ធដីកា គឺមិនបដិបត្តិតាមនូវពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ។ ពាក្យថា ពុទ្ធសាសនិកជន គឺអ្នកកាន់ព្រះពុទ្ធសាសនានោះ មិនមែនមានន័យថា ពលរដ្ឋទាំងនោះសុទ្ធតែគោរពបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងអស់ទេ, ជនពួកខ្លះ គ្រាន់តែជាពុទ្ធសាសនិកដោយកំណើតប៉ុណ្ណោះក៏មាន គឺថាមាតាបិតាជាពុទ្ធសាសនិកផងដែរ តែគ្មានបានសិក្សាព្រះពុទ្ធសាសនាសោះក៏មាន ខ្លះក៏បានសិក្សាខ្លះដែរ តែមិនបដិបត្តិតាម ប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិរបស់ព្រះពុទ្ធជាម្ចាស់ក៏មាន ។ ប្រៀបដូចជា ច្បាប់សម្រាប់ប្រទេសនីមួយ ៗ កើតឡើងអំពីឆន្ទៈរបស់ប្រ-ជាពលរដ្ឋ ហើយត្រូវតាំងឡើងដើម្បីការពារកុំឲ្យពលរដ្ឋប្រព្រឹត្តអាក្រក់មាន

លួចប្លន់ជាដើម ចុះហេតុដូចម្តេចបានជានៅតែមានមនុស្សលួចប្លន់មិនចេះអស់? ឆ្លើយថា ព្រោះពលរដ្ឋមិនគោរពច្បាប់, ច្បាប់មានក៏ពិតមែន តែបើពលរដ្ឋល្មើស មិនព្រមប្រតិបត្តិតាម ការលួចប្លន់ជាដើមក៏មិនអាចនឹងអស់ទៅបាន, ហេតុនោះ ការដែលមានច្បាប់ហើយ នៅតែមានចោរលួចប្លន់នោះ មិនមែនមកអំពីច្បាប់ទេ គឺមកអំពីមនុស្សមិនព្រមគោរពច្បាប់នោះឯង សេចក្តីនេះយ៉ាងណាមិញ ប្រទេសដែលកាន់ពុទ្ធសាសនានៅតែមានការឈ្លោះវិវាទគ្នានោះ ក៏មិនមែនមកអំពីព្រះពុទ្ធសាសនាទេ គឺមកអំពីពលរដ្ឋនៃប្រទេសនោះ ៗ មិនព្រមប្រតិបត្តិតាមព្រះពុទ្ធវាទយ៉ាងនោះដែរ ។ សរុបសេចក្តីថា ការដែលប្រទេសកាន់ព្រះពុទ្ធសាសនានៅតែមានការបៀតបៀនគ្នានោះ មិនមែនមកពីព្រះពុទ្ធសាសនាទេ ព្រះពុទ្ធសាសនា មានគោលការសុទ្ធតែនាំឲ្យកើតសេចក្តីសុខសប្បាយ ឲ្យចៀសវាងការបៀតបៀនប្រទូសរ៉ាយគ្នាទាំងអស់ ។ តាមគោលការបញ្ចសីល បញ្ចធម៌ដូចពោលមកនេះ ប្រសិនបើមនុស្សប្រតិបត្តិតាមឲ្យដិតដល់ហើយ រមែងបានទទួលលទ្ធផលគឺ សេចក្តីសុខសេចក្តីចំរើនសមដូចសេចក្តីប្រាថ្នាជាមិនខាន ។ ឧទាហរណ៍ដូច មនុស្ស ៣ នាក់នៅជាមួយគ្នា ហើយតាំងចិត្តរៀង ៗ ខ្លួន គឺថា អ្នកទី ១ តាំងចិត្តថា នឹងមិនបៀតបៀនអ្នកទី ២ និងអ្នកទី ៣ អ្នកទី ២ ក៏តាំងចិត្តថា នឹងមិនបៀតបៀនអ្នកទី ១ និងអ្នកទី ៣, ឯអ្នកទី ៣ ក៏តាំងចិត្តថា នឹងមិនប្រទូសរ៉ាយអ្នកទី ១ និង

អ្នកទី ២ ។ កាលបើតាំងចិត្តនិងបដិបត្តិយ៉ាងតឹងរ៉ឹងបានយ៉ាងនេះ អ្នកទាំង ៣ ក៏នឹងមិនមានការប៉ះទង្គិចគ្នា មិនមានការបៀតបៀនប្រទូសរ៉ាយគ្នានិងគ្នាឡើយ, បើគ្មានការបៀតបៀនគ្នាហើយ សេចក្ដីទុក្ខសេចក្ដីក្ដៅក្រហាយក៏គ្មាន, អ្នកទាំង ៣ នឹងមានតែសេចក្ដីសុខក្សេមក្សាន្តជាដរាប បើមនុស្ស ១០ នាក់ដែលនៅជាមួយគ្នា ធ្វើបានយ៉ាងនេះ មនុស្សទាំង ១០ នាក់នោះ ក៏នឹងមានសេចក្ដីសុខស្ងប់ស្ងៀម គ្មានសេចក្ដីទុក្ខឡើយ, បើពលរដ្ឋនៅក្នុងប្រទេសជាមួយគ្នា ធ្វើបានយ៉ាងនេះ ពលរដ្ឋទាំងនោះក៏នឹងបានសេចក្ដីសុខសេចក្ដីចំរើនគ្រប់ ៗ គ្នា, ហេតុនេះ ប្រសិនបើមនុស្សនៅក្នុងសាកលលោកទាំងមូលនេះ បដិបត្តិយ៉ាងនេះ សាកលលោកទាំង-មូលក៏នឹងមានតែសេចក្ដីស្ងប់រៀបរយ គ្មានការកាប់សម្លាប់គ្នា គ្មានការធ្វើសង្គ្រាមបង្ហូរឈាមឡើយ, មនុស្សក្នុងសាកលលោក ក៏នឹងមានតែសេចក្ដីសុខក្សេមក្សាន្ត ប្រាសចាកសេចក្ដីទុក្ខក្ដៅក្រហាយជាពិតប្រាកដ ។

នេះឯង គឺជាវិធីស្វែងរកសេចក្ដីសុខសន្តិភាព ខាងផ្លូវព្រះពុទ្ធសា-សនា ដែលមនុស្សអនុវត្តតាមហើយ នឹងបានសម្រេចផលតាមសេចក្ដីប្រាថ្នា គឺជាវិធីការដែលប្រសើរ មិនអន់ថយជាងវិជ្ជា ឬវិធីការខាងផ្លូវលោក ឬក៏អន់ថយជាងគោលការនៃសាសនាដទៃនោះទេ ហើយមិនមែនគ្រាន់តែជាសាសនាដែលមានគោលការទាន់សម័យប៉ុណ្ណោះទេ តែជាសាសនា

ដែលមានគោលការនាំមុខវិធីការខាងផ្លូវលោកថែមទៀតផង ព្រោះព្រះពុទ្ធជាម្ចាស់បានទ្រង់សំដែងពុទ្ធវិធីនេះទុកមកជាង ២៥០០ ឆ្នាំហើយ, ឯវិធីការផ្សេង ៗ ខាងផ្លូវលោក ទើបនឹងកើតមានឡើងនៅពេលក្រោយនេះឯង ៗ ហេតុនោះ អស់លោកអ្នកអានទាំងឡាយដែលជាពុទ្ធសាសនិកជនកុំគប្បីទើកតូចចិត្តនឹងព្រះពុទ្ធសាសនារបស់យើងថាជាសាសនាអន់ថយជាងវិជ្ជាការខាងផ្លូវលោកឡើយ គួរត្រិះរិះពិចារណាសាជាថ្មី ហើយសេចក្តីរីករាយពេញចិត្តចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់ជាតិជាយើងឈ្មោះថាជាអ្នកមានភ័ព្វវាសនាធំណាស់ ដែលបានកើតមកទាន់ព្រះឱវាទពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលជាព្រះឱវាទដ៏មានតម្លៃទាន់សម័យ និងមានសភាពស័ក្តិសិទ្ធិអាចធ្វើឲ្យយើងជាពុទ្ធសាសនិកអ្នកបដិបត្តិតាមយ៉ាងជិតដល់ បានសម្រេចប្រយោជន៍តាមសមគួរដល់ការបដិបត្តិរៀង ៗ ខ្លួន ពោលគឺ អាចជួយឲ្យមនុស្សអ្នកបដិបត្តិតាមបានផុតអំពីសេចក្តីទុក្ខភ័យ ហើយបានជួបប្រទះនឹងសេចក្តីសុខក្សេមក្សាន្តដូចសេចក្តីដែលបានធ្វើអត្ថាធិប្បាយមកដូច្នេះឯង ។

---

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ ពោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

## ពិចារណាដើម្បីយល់តក្កវិជ្ជា

(ត)

លោក ហ៊ុន គិមសៀ រៀបរៀង

តក្កសាស្ត្របភាព ជាវិទ្យាសាស្ត្រមួយបែបគ្មានប្រកាន់វណ្ណៈ គឺជាឧបករណ៍មួយយ៉ាងសម្រាប់មនុស្សទូទៅ ប៉ុន្តែក្នុងការសិក្សាដែលអាចឲ្យឆាប់យល់ច្បាស់ហើយត្រឹមត្រូវផងនោះ គេត្រូវប្រកាន់យកគំនិតវិទ្យា-សាស្ត្រ ដែលជាគំនិតជាក់ស្តែង គំនិតរកហេតុផលគ្រប់គ្រាន់ និងមានភស្តុតាង ។

### ការយល់ក្នុងគ្រាដំបូង

មនុស្សមានគំនិតវិទ្យាសាស្ត្រគេយល់ថា : ការចេះដឹងរបស់មនុស្សវាត្រូវឆ្លងកាត់រយៈពេលបីយ៉ាង ហើយរយៈពេលទាំង៣យ៉ាងនោះ វាទាក់ទងគ្នាយ៉ាងជិតស្និទ្ធ មានវិធានរបស់វា ។ ឥឡូវយើងយករយៈពេលនីមួយ ៗ មកពិចារណាសភាពការចេះដឹងរបស់មនុស្សយើងល្បងមើល ។

មុនដំបូងយើងនិយាយ អំពីការយល់គន្លងគ្រាដំបូង :

មនុស្សយើងមានបញ្ចេន្ទ្រិយ ( Cinq sens ) កាលណាសម្ភារៈ ឬ ធាតុក្លូតខាងក្រៅវាមកប៉ះទង្គិចនឹងបញ្ចេន្ទ្រិយ នាំឲ្យកើតមានជាវិញ្ញាណ ( Sensation ) ។ ភ្នែកមើលឃើញពន្លឺ, ឃើញពណ៌សម្បុរសខ្មៅ.. ត្រចៀកឮស្ងូរសម្លេងពីរោះ ឬ សម្លេងស្អុ ... ដៃកាន់វត្ថុដឹងថារបស់ទន់ របស់រឹង ... ។ល។ ហេតុដូច្នេះ ការចេះដឹងរបស់មនុស្ស ចាប់ផ្ដើមពីវិញ្ញាណ ពីព្រោះថា : វិញ្ញាណជាលទ្ធផលនៃការប៉ះទង្គិច រវាងបញ្ចេន្ទ្រិយ និងសម្ភារៈ គន្លងសាកលលោកខាងក្រៅ ។

ឧទាហរណ៍ : វិញ្ញាណយើងដឹងថា ភ្លើងវាក្ដៅ ពីព្រោះយើងនៅជិតភ្លើង វាមានចំហាយក្ដៅមែន ( មានយើង+ភ្លើង=ក្ដៅ ) តើមានវិញ្ញាណអ្នកណាខ្លះដែលដឹងថា ផ្កាយវាក្ដៅ បើយើងមិនដែលរៀនចក្រវាឡសាស្ត្រ ម្ដងណាសោះ? ។

សុំប្រាប់ថែមទៅទៀតថា : វិញ្ញាណអាចដឹងបានតែលក្ខណៈឬភាពមួយ ៗ នៃវត្ថុប៉ុណ្ណោះទេ ប៉ុន្តែផ្ទុយទៅវិញ វត្ថុមួយ ៗ មានលក្ខណៈនិងភាពរបស់វាច្រើនបែបច្រើនយ៉ាង ។ ឧទាហរណ៍ : យើងមើលគោ យើងឃើញភាពនិងលក្ខណៈវាច្រើនដូចជា : ពណ៌សម្បុរ ទំហំ, ចាស់ក្មេង, ស្គមធាត់ ... លក្ខណៈទាំងអស់នេះវាចូលមកគន្លងភ្នែកយើងទាំងអស់ ដូច្នេះ គន្លងពេលដែលយើងមើលឃើញវត្ថុឬព្រ

សម្លេងអ្វី រូបក៏ចូលមកក្នុងខួរក្បាលយើង ក៏មិនមែនចូលមកតែមួយ ឬពីរលក្ខណៈប៉ុណ្ណោះទេ គឺក៏ចូលមកព្រមគ្នាទាំងអស់ក្នុងមួយពេលតែម្ដង នាំឲ្យយើងមានវិញ្ញាណយ៉ាងសទ្ទឹក ( គឺដឹងថា គោបាស, គោស្គម, គោក្រហម, គោខូចត្រូវលក់ឲ្យគេប្រញាប់ ) វិញ្ញាណទាំងនោះ ក៏ទាក់ទងគ្នាមានឯកភាពយ៉ាងស្រុះស្រួលគ្នា ដែលនាំឲ្យកើតទៅជាបញ្ញាញាណ ឬ ជាការដឹងច្បាស់ ។

ក្រៅអំពីវិញ្ញាណនិងបញ្ញាញាណ មនុស្សនៅមានទស្សនៈមួយទៀត (Concept) គឺថា : នៅចំពោះមុខយើងមានវត្ថុមួយ វត្ថុនោះនាំឲ្យយើងមានជាវិញ្ញាណនិងបញ្ញាញាណដោយផ្ទាល់ ។ ដល់យើងយកវត្ថុនោះទុកបាត់ទៅ ក៏នៅមានរូបភាពនឹងបែបផែននៅក្នុងខួរក្បាលយើងនៅឡើយ នេះហៅថា ទស្សនៈ ។

ឧទាហរណ៍ : បងឯងមើលឃើញខ្ញុំ ខ្ញុំឃើញបងឯង យើងមានវិញ្ញាណ និង បញ្ញាញាណចំពោះគ្នាទៅវិញទៅមក ។ បងឯងត្រូវទៅស្រុកឆ្ងាយ យើងទាំងពីរនាក់នឹករឭកគ្នា នៅចាំរូបរាងគ្នា ចាំសម្ដីនិយាយគ្នា ចាំសំឡេងសើច របស់គ្នា នេះហើយហៅថាទស្សនៈ ។

កន្លងមកយើងទាំងអស់គ្នាបានយល់ហើយអំពីវិញ្ញាណ, បញ្ញាញាណ និង ទស្សនៈ ។ ប្រការទាំង ៣ នេះក៏ខុសគ្នា ប៉ុន្តែយើងត្រូវយល់អំពីលក្ខណៈដូចគ្នានៃប្រការទាំង ៣ ខាងលើនេះ ។ គឺកើតឡើងមកតែអំពីការប៉ះទង្គិចរវាងសម្ភារៈ និង បញ្ចិន្ទ្រីយ៍ទាំងអស់ ។

យើងទាំងអស់គ្នាបានយល់ថែមទៀតថា ការចេះដឹងរបស់មនុស្ស មិនមែននៅនឹងថ្កល់មួយកន្លែងទេ វាអាចឡើងពីទាបទៅខ្ពស់ ៗ មុនដំបូង សម្ភារៈ វាមកប៉ះនឹងឥន្ទ្រិយនាំចូលទៅក្នុងខួរក្បាល កើតបានជាវិញ្ញាណ កើតជាការដឹង ហើយបន្តទៅទៀត វានាំឲ្យមនុស្ស មានការពិចារណា; ការត្រិះរិះរកហេតុរកផល, ការពិនិត្យដើម្បីឲ្យយល់អស់នូវបាតុភូតនីមួយៗទៀត ។ ល ។

## ការយល់ដៅលើកទី២ និង ទី៣

សម្ភារៈទាំងអស់នៅក្នុងលោក សុទ្ធតែមានចលនារបស់វា, ហើយ ខួរក្បាលរបស់មនុស្សយើង ក៏មានចលនារបស់វាដែរ ។ ចលនារបស់ខួរក្បាលយើង ហៅថា „ ការពិចារណា " ឬ " ការគិត " ។

ឧទាហរណ៍: យើងនៅក្នុងផ្ទះ, ឮស្នូរឆ្កែព្រុស យើងគិតភ្លាមថា: នៅខាងក្រៅមានមនុស្សឬមានបាតុភូតអ្វីចំឡែក ។ ហេតុនេះចលនានៃខួរក្បាលវាចាប់ផ្តើមពីវិញ្ញាណ, ចាប់ផ្តើមពីសម្ភារៈប៉ះទង្គិចនឹងបញ្ចេន្ទ្រិយ, ចាប់ផ្តើមពីទស្សនៈ ។

វិញ្ញាណ និង បញ្ញាញាណផ្តល់ឲ្យខួរក្បាលនូវឧបករណ៍ ដើម្បីគិតដែលបញ្ចេន្ទ្រិយ ទទួលបានមក ហើយទស្សនៈជាអ្នករក្សាទុកនូវឧបករណ៍ទាំងនោះក្នុងខួរក្បាល ។ បន្ទាប់មក ខួរក្បាលវាចាប់ផ្តើមត្រិះរិះពិចារណា នូវឧបករណ៍ទាំងនោះ តាមរបៀបតក្កវិជ្ជា រួមមានរបៀប :

· ពិចារណាប្រៀបធៀប

· ពិចារណាវែកញែក និង ចងក្រង

ពិចារណាសន្និដ្ឋាន និង ការប្រមាណស្ទង់ហេតុ

បន្ទាប់ពីការពិចារណាបាតុភូត តាមរបៀបតក្កវិជ្ជាហើយ ទើបខួរក្បាលមនុស្សមានការចេះដឹង មានការយល់កាន់តែទូលាយឡើងថែមទៀត ។

ឧទាហរណ៍: មូសកើតពីទឹកស្អុយ ហើយមកខាំមនុស្ស, មនុស្សត្រាំមិនបានគិតរកមធ្យោបាយការពារ ។ មុនដំបូង មនុស្សដុតភ្លើងផ្សែងការពារ បន្ទាប់មកយកមុង ដល់យូរៗទៅ មនុស្សកាន់តែជឿនលឿន មនុស្សចេះប្រើថ្នាំការពារ ទៅអនាគតមនុស្សនឹងបំបាត់មូសឲ្យអស់ពីផែនដីតែម្ដង កាលណាមនុស្សមានសមត្ថភាពវិទ្យាសាស្ត្រគ្រប់គ្រាន់ ។ នេះហើយហៅថាការយល់ឬការចេះរបស់មនុស្ស គឺវាមានកំរិតកាន់តែយល់ឡើងបែបនេះឯង ។

យើងសុំបញ្ជាក់ឧទាហរណ៍មួយទៀត ដូចជាពេជ្រ :

មុនដំបូង មនុស្សដឹងថា ពេជ្រជារតនវត្ថុមួយភ្លឺថ្លាឆ្លាំងចែងចាំងស្រស់ល្អ, ហេតុនេះគេយកវាមកធ្វើជាគ្រឿងអលង្ការ, តមកទៀត គេដឹងថាវារឹងជាងលោហធាតុឯទៀតទាំងអស់, ហេតុនេះ មនុស្សគេយកវាមកធ្វើជាម្ជុល ឬ ធ្វើជាប្រដាប់សំរាប់កាត់កញ្ចក់ ។ល។

មិនមែនដូចអាជ័យ ម្ដាយប្រើឲ្យទៅរកឈើ "ដំពាម" ក្នុងព្រៃយក មកធ្វើជើងក្ដារនៀ ទៅរកមួយថ្ងៃទល់ល្ងាច ត្រឡប់មកផ្ទះវិញហើយឆ្លើយ ប្រាប់ម្ដាយថា: គ្មានដំពាមក្បាលចុះក្រោមទេ មានតែ "ដំពាម" ក្បាលឡើងទៅលើ ។ នេះបានចំជាអាជ័យ ក្បាលទៅលើឬចុះក្រោមស្រេចតែគេបង្កិលទេតើ ! ។

ដើម្បីរើសអើងនឹងវែកញែក រវាងប្រការចាំបាច់និងមិនសូវចាំបាច់ ប្រការជាធម្មជាតិក្នុងសម្ភារៈ និងការដែលប្រែប្រួលនៅក្នុងធម្មជាតិ តក្កវិជ្ជា គេប្រើវិធី "ទូទៅ" និង វិធីពិចារណាខាងគំនិតនិយម ។

សមត្ថភាពខាងពិចារណា គឺជាសមត្ថភាពរបស់មនុស្ស ពីព្រោះ មនុស្សមានការពិចារណាខាងខួរក្បាល (សត្វដទៃគ្មានការពិចារណាទេ)។

នៅក្នុងដំណើរជីវភាពរាល់ថ្ងៃ មនុស្សប្រើការពិចារណា ខាងគំនិត ឧទាហរណ៍ ដូចថា "នៅក្នុងផ្ទះនេះ មានមនុស្ស ១៥ នាក់" ។ ស្ដាប់តាមយើងអាចយល់ថា ឃ្លានេះហាក់ជាក់លាក់ពេក ប៉ុន្តែផ្ទុយទៅវិញ ឃ្លានេះមិនទាន់ជាក់លាក់ប្រាកដប្រជានៅឡើយទេ ។ ពីព្រោះ ១៥ នាក់ ក៏នៅជាអរូបី ។ មនុស្សគឺជា នាមនាមទូទៅ ។ ១៥ នាក់គឺជាបកតិសំខ្យាទូទៅ ។

យើងយកឧទាហរណ៍ ១៥ នាក់នេះ មកនិយាយចុះ ។ ម្នាក់ៗ សុទ្ធតែមានអាយុខុសគ្នា, ពណ៌សម្បុរខុសគ្នា, ពង់ពៅសំដីសំដៅខុស

គ្នា !... នេះយើងមិនទាន់និយាយអំពីចិត្តថ្លើម ទឹងអញ្ញាស្រ័យខុសគ្នាថែមទៀតផង ដែលជាគុណសព្ទរបស់លក្ខណៈមនុស្ស ៗ ដូច្នេះ ១៥ នាក់យើងនិយាយអំពីបញ្ហាដូចគ្នាគឺ "មនុស្ស" គឺចំនួនប៉ុណ្ណោះ ៗ

ហេតុនេះ "មនុស្ស" គឺជាសព្ទ នាមមិនជាក់លាក់ (និយាយរួម) មានតែមនុស្សទូទៅ ចំណែកមនុស្សជាក់លាក់ គឺមនុស្សណាឆាត់ ឬ ស្គម ធំ ឬ តូច ... ៗល ៗ ហេតុដូច្នេះហើយ បានជាយើងនិយាយថា ការយល់របស់មនុស្សក៏មានពីរ ការយល់ខាងគំនិត នៅការយល់ខាងសម្ភារៈ រួចពីការយល់ខាងសម្ភារៈ ត្រឡប់មកការយល់ខាងគំនិតវិញ គឺការពិចារណាខាងខួរក្បាល ដើម្បីយល់បាតុភូតនៃសម្ភារៈ ៗ ពីព្រោះសម្ភារៈក៏មានគុណលក្ខណៈច្រើន ដូចជាមនុស្សម្នាក់ក៏មានគុណលក្ខណៈ ខ្មៅ, ស, ក្រហម, ចាស់, ឆាត់, ស្គម, ស្ងួត, កាច ៗល ៗ

និយាយសង្ខេបមក គួរឲ្យបញ្ហានៃការពិចារណានេះ មនុស្សយើងក៏មានការចេះដឹង ឬជាការយល់ច្រើនលើកច្រើនគ្រា ៗ ការយល់លើកទី ១ ក៏ខុសនឹងការយល់លើកទី ២ ពីព្រោះការយល់លើកក្រោយ ក៏ច្បាស់លាស់ ហើយជ្រាលជ្រៅជាងលើកទី ១ ៗ

# ទស្សននិយម ( CONCEPT )

ក– ធម្មជាតិនៃទស្សនៈ

ខ– ទស្សននិយម និង ភាសា

គ– លក្ខណៈផ្ទាល់ និង លក្ខណៈទូទៅនៃទស្សនៈ

ឃ– ការទាក់ទងរវាងលក្ខណៈទូទៅ និង លក្ខណៈផ្ទាល់

ង– ទស្សនៈប្រភេទ និង ទស្សនៈតូច (ចំពូក)

ច– ការទាក់ទងរវាងទស្សនៈ

## ក_ ធម្មជាតិនៃទស្សនៈ

យើងទាំងអស់គ្នាបានតាមដានអំពីការពិចារណារួចហើយ ឥឡូវ យើងមកដល់ ទស្សននិយមហើយ ( Concept ) ។ ទស្សននិយម គឺជាអត្ថសំខាន់នៅក្នុងតក្កវិជ្ជា ។

មុនដំបូងបង្អស់យើងត្រូវយល់ជាមុនសិន នូវពាក្យថា " ទស្សន-និយម " ។

វិញ្ញាណរបស់មនុស្ស ឬ ជាបញ្ចេន្ទ្រីយរបស់មនុស្ស ក៏ប៉ះពាល់នឹង សម្ភារៈនិងបាតុភូត(Phénomène)ខាងក្រៅ នាំឲ្យមានការចាប់អារម្មណ៍ នៅក្នុងវិញ្ញាណ ការចាប់អារម្មណ៍នៅក្នុងវិញ្ញាណនោះហើយ ដែលហៅ ថា: ទស្សននិយម ។

ឧទាហរណ៍ ៖ យើងយកថ្ងៃជាកម្មវត្ថុ ។ ថ្ងៃក៏មនុស្សប៉ះនឹងកម្មវត្ថុខាងក្រៅ គឺ (ថ្ងៃ) នាំឲ្យអារម្មណ៍របស់យើងមានទស្សនៈនិយមមួយ គឺ សត្វថ្ងៃ ។ និយាយមួយបែបទៀតថា ទស្សនៈនិយម គឺជាការចាប់អារម្មណ៍នៃខួរក្បាលដែលកើតឡើងមកអំពីវត្ថុជាសម្ភារៈខាងក្រៅ(កម្មវត្ថុ) មកប៉ះទង្គិចនឹងបញ្ចេន្ទ្រិយរបស់មនុស្ស ។ ទស្សនៈគឺជាលទ្ធផលខ្ពស់បំផុតនៃខួរក្បាល ក៏មិនមែនគ្រាន់តែជាការយល់ធម្មតា ការឃើញធម្មតា ការដឹងធម្មតា គឺក៏រួមទាំងការ និងឃើញ-យល់ហើយមានការពិចារណាជ្រាលជ្រៅច្បាស់លាស់បូកថែមទៅទៀតផង គឺថា ទស្សនៈមិនមែនគ្រាន់តែជា ការយល់ឃើញសើៗ ខាងក្រៅនៃសម្ភារៈប៉ុណ្ណោះទេ ផ្ទុយទៅវិញ គឺក៏ជាការយល់យ៉ាងជ្រាលជ្រៅគ្រប់ហេតុ ផល បច្ច័យ ទាំងអស់នៃសម្ភារៈ ។

នៅក្នុងសង្គមមនុស្សទូទៅ ក៏មានទស្សនៈពីរផ្ទុយគ្នា គឺទស្សនៈមួយកើតគំនិត ឬ អារម្មណ៍របស់មនុស្ស ដែលយើងហៅថា ទស្សនៈ (គំនិតនិយម) ឬ ទស្សនៈយល់សប្តិនិយម ទស្សនៈដែលមានតែនៅក្នុងគំនិត ទស្សនៈមិនពិត និងទស្សនៈមួយទៀត គឺពិតប្រាកដ មានការជាក់លាក់ ដែលយើងហៅថា ទស្សនៈសម្ភារនិយម ។

ឧទាហរណ៍ ៖ ដូចជាអង្គុយសំកុកមើលមេឃ ហើយចង់ឡើង

ឋានសួគ៌ ។ នេះជាទស្សនៈគំនិតនិយម ។

ចង់ចេះឲ្យសម្លាប់អាចារ្យ ចង់បានផ្លែផ្កាឲ្យយកភ្លើងដុតគល់ ។ល។ នេះជាទស្សនៈសម្ភារៈនិយម ។

យើងនិយាយកាន់គ្នាទៅវិញទៅមករាល់ថ្ងៃ បានសេចក្ដីថា យើងប្រើទស្សនៈ ដើម្បីប្ដូរអារម្មណ៍របស់យើង ។ បណ្ដាទស្សនៈដែលយើងប្រើរាល់ថ្ងៃ គឺជាការចេះដឹងរបស់មនុស្ស ឆ្លងកាត់ច្រើនសតវត្សមកហើយ ដែលពពួកមនុស្សខំប្រឹងប្រមែប្រមូលបានមកគ្រប់វិស័យ ។

នៅក្នុងទំព័រប្រវត្តិសាស្ត្រនៃដំណើរលូតលាស់របស់ (ការគិត) វាមានពីរយ៉ាងគឺ ការគិតម្យ៉ាងពិត ជាប្រាកដនិយម ការគិតម្យ៉ាងទៀតវាមិនពិត ដូចជាការគិតអំពីខ្មោចព្រាយ ជឿអារក្សអ្នកតា ជាដើម ។ គំនិតមិនពិត គេមិនអាចបញ្ជាក់បានតាមរបៀបសម្ភារៈ ឬ តាមសង្គមមនុស្សជាក់ស្ដែងបានទេ ហើយសំដីនិយាយដែលគេចង់គ្រង់ទៅជាទ្រឹស្ដីក៏មិនរឹងប៉ុងដែរ ពីព្រោះគ្មានមូលដ្ឋានជាក់ណាក់ ។

## ១_ ទស្សនិយម និង ភាសា

សតិអារម្មណ៍និងភាសា វាមានការទាក់ទងគ្នាជិតដិតណាស់ ។ ភាសា, ពាក្យ, សំដី, អក្សរ . . . គឺជាសញ្ញាដើម្បីសម្ភារភាវូបនីយកម្ម (Matérialiser) សតិអារម្មណ៍ ដើម្បីលាតត្រដាងគំនិតឲ្យចេញមកក្រៅ ។

(នៅមានត)

—ជាតិតា ស្ត្រី. ភាវនៃអ្នកដែលកើតក្នុងវណ្ណៈចុងបំផុត ។ —អន្ត្យាជិ បុំ. ភាគខាងចុង ។

អន្ត្យាវសាយិន៑ បុំ. អ្នកនៅក្នុងវណ្ណៈចុងបំផុត ។

អន្ត្រ នបុំ. ពោះវៀន ។ —ឝិលា ស្ត្រី. តាមស៊ឹង ។

អន្ត្រាបីឌប្រកាឝិន៑ គុ. ដែលប្រាប់ថាមានពោះឈឺខ្លាំង ។

អន្ទុ-ន្ទូ ស្ត្រី. ខ្សែប្រវាក់តូច (សម្រាប់ស្ត្រីពាក់កជើង) ។

អន្ទោលន នបុំ. កិរិយាយោល (ទោង) ។

អន្ធ គុ ខ្វាក់, ងងឹត, ល្ងង់ខ្លៅ ។ —តា ស្ត្រី. អន្ធការភាព ភាពខ្វាក់ ។ —ការ បុំ. នបុំ. អន្ធការ ។ គុ. ដែលអន្ធការ, តា ស្ត្រី. អន្ធការភាព; អន្ធការិត គុ. ដែល

ធ្វើឲ្យខ្វាក់ ឬ ឲ្យងងឹត, អន្ធការិន គុ. ដែលងងឹត,

ខ្មៅ ។ –មយ គុ. ដែលងងឹត ។ –រូប បុំ.

អណ្ដូងងងឹត, នាមនរក ។ –តមស៍ ឬ –តមស

នបុំ. កិរិយាងងឹតក្រៃលែង ។ –តមិស្រ នបុំ. ភាព

ងងឹត, នាមនរក ។

អន្ធក គុ. ខ្វាក់, ល្ងង់, ខ្មៅ ។ បុំ. នាមអសុរ និងអ្នកដទៃទៀត ។

នាមប្រទេស ។ –ឃាតិន៍ ឬ –រិបុ បុំ. ឥវ ។

អន្ធកាន្តក បុំ. ឥវ ។

អន្ធស៍ នបុំ. ចំណីអាហារ ។

អន្ធ្រ បុំ. ពហុ. នាមវណ្ណៈថោកទាប ។ នាមប្រជាជន នៅប្រទេសតេលុគុ ។

អន្ន នបុំ. ចំណី អាហារ បាយ ។ –វន្ត គុ. ដែលមានអាហារ ។

ទ ឬ ទាត្រ គុ. អ្នកឲ្យអាហារ ។ –ទោស បុំ.

អន្នទោស ។ –បត្តិ ស្ត្រី. កិរិយាចំអិនអាហារ ។

បតិ បុំ. សវិតរ៍ ។ –ប្រាសន នបុំ. អន្នប្រាសន៍

អាហារដែលឲ្យទារកមុនដំបូង, នាមរីតិ ។ –មល នបុំ. អន្នមល, មេរ៍យ ។ –រស បុំ. អន្នរស, អន្ននិងបាន; បុំ. រសនៃអាហារ ។ –វិការត្ត នបុំ. ការនៃកិរិយាធ្វើឲ្យក្លាយជាអាហារ ។ –វិក្ឫតិ ស្រ្តី. –សំស្ការ បុំ. កិរិយាចំអិនអាហារ ។ អន្នាទ គុ. ដែលស៊ីអាហារ; បុំ បុត្រនៃក្ឫស្ណ ។ អន្នាទិន គុ អន្នាទិន ដែលស៊ីអាហារ ។ អន្នាទ្យ នបុំ. ចំណីអាហារ, គ្រឿងបរិភោគ ។ ភាពមាំមួន ។ អន្នាយុ គុ. អន្នាយុ, ដែលចង់បរិភោគអាហារ ។

អន្នមយ គុ. ដែលជាវិការនៃអាហារ ។

អន្យ គុ. ដទៃ ផ្សេង មួយទៀត ដទៃទៀត ។ –កក្ឫត គុ. ដែលមានអ្នកធ្វើការមួយទៀត ។ –កាម គុ. ដែលស្រឡាញ់អ្នកមួយទៀត ។ –គ គុ. ដែលទៅកាន់អ្នកមួយទៀត, ដែលមិនស្មោះត្រង់, –គាមិន ដូចគ្នា ។

-ចិត្ត គុ. ដែលមានចិត្តបញ្ជូនទៅកាន់អារម្មណ៍ដទៃ ។

-ចេតស គុ ដែលមានចិត្តបែកចេញ, ភយមាយ ។

-ជ គុ ដែលកើតអំពីអ្នកដទៃ ។ -ជន្ម នបុំ

អន្យជន្ម, កំណើតក្នុងអនាគត ។ -ជាត បុំ. អន្យ-

ជាត, អ្នកកើតអំពីមាតាបិតាឥតខាន់ស្លា ។ -បរ គុ. ដែល

ទាក់ទងដោយអ្នកដទៃ ។ -បុព្វ ឬ -ភូតា

ស្ត្រី. នាមលលកញ ។ -បូវា ស្ត្រី. អន្យបូវា ស្ត្រីជា

ដែលគេដណ្ដឹង ឬ ការហើយដោយប្រុលដទៃមុនរៀបការ

ទៀត ។ -មនស គុ. ដែលមានចិត្តទៅកាន់អារម្មណ៍

ដទៃ, សាភ ។ មាតុក គុ ដែលមានមាតាមួយ

ទៀត ។ -យុក្ត គុ ដែលជាប់ដោយអ្នកដទៃ ។

-រាជក គុ ដែលមានព្រះរាជាមួយទៀត, ដែល

ជាភស្ត្រនៃព្រះរាជាមួយទៀត ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១២

(ត)

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

កាលនោះ ព្រះភិរុទព្រះសត្រុតទាំងពីរព្រះអង្គ ទ្រង់បានស្ដាប់ព្រះបិតុរេសធិបតី ក៏លើកដៃអញ្ជលីទទួលព្រះបញ្ជា ទើបថ្វាយបង្គំលាព្រះជនកព្រះជននី លាទាំងព្រះលក្សណ៍ និងអង្គសម្ដេចព្រះរាមាធិបតី និងព្រះអគ្គពជសីតាស្រេចហើយ ព្រះអង្គក៏យាងមកឡើងគង់លើរាជរថ ឲ្យលើកកងទ័ពយោធាពលករ ចេញមកនគរអយុធ្យាធានី ក៏ស្រូតរូតទៅតាមផ្លូវពនាលីហោង ៗ ស្ដេចលើកនិករយោធីឈប់សម្រាកក្នុងអរញ្ញវេសមករៀង ៗ ក៏បានដល់ក្រុងកៃកេសបុរី ព្រះចក្រីក៏យាងឡើងទៅកាន់ប្រាសាទកៃកេសនា ជាសុខក្សេមក្សាន្តហោង ៗ

យើងបញ្ឈប់ទុកស្ទះ ឥឡូវនេះនឹងនិយាយពីទូរគីទ្ធីគ្នាហាន មានទេវបុត្រទៅថែរក្សាមកជាយូរអង្វែង គុហាកែវសូរ្យកាន្តដូចបានទៅដោះមាតាតែសព្វថ្ងៃ ក៏មានកម្លាំងពលបុត្តាក្លាហាននោះ ដោយសារបានទេវរក្ខជួយទំនុកបំរុងរក្សា លុះចម្រើនវឌ្ឍនាការធំឡើងគ្រប់ថ្ងៃខែ ពូកែមានឫទ្ធិ ក៏គេចចរយាត្រាចេញមកល្បងដើររត់លេងស្រែកកងរំពងព្រៃ វៃស្ទុះវ៉ៃបុកសិលាធំ ៗ ហើយដើរតាមគន្លងដានខ្លាកា ហើយមហិង្សា

ក៏តាំងត្រាវស្វែងរកបែបប្រេបជិតខាងគន្លងស្នាមជើងបិតា ល្បងលងមើលទៅ ឃើញគន្លងស្នាមស្វែងរែតនោះ ក៏រើកបានធំ ៗ ប៉ុនគន្លងជានបិតាដែរ ដូច្នេះហើយក៏គិតថា អញនេះល្មមនឹងដល់តស៊ូបាន ទុរភីគិតហើយ ប៉ិនក្នុងចិត្តថា សត្រូវនឹងបិតាមិនក្លួចឡើយ ហើយថា ថ្ងៃហ្នឹងខ្លួនអញនឹងបិតា នឹងបានល្បងប្តូចគ្នា ដល់មើលឲ្យបានដឹងកម្លាំងប្តូច គិតហើយ ទុរភីក៏អែបខ្លួនពួនកាយា ក្រោមម្លប់មែកឈើធំចាំហិតក្លិន ស៊ីស្មៅនៅរម ខាងជ្រោះ ៗ

គ្រានោះ ទុរភាបុត្តាក្លាហាន ដេកនៅនឹងហ្វូងបរិវារចាំដល្ងួច ហើយ ក៏ក្រោកឡើងនាំអស់ហ្វូងបរិវារ ត្រាច់ដើរដោយព្រៃពនាវ័ន ទៅតាមមគ្គមាគ៌ា សប្បាយតាមទំនើងចិត្តឥតទើសទាល់ ៗ គ្រានោះទុរភីបុត្តាក្លានោះ លុះឃើញទុរភាបិតាដើរមកហើយ ក៏មានចិត្តនោះក្រេកអរសាទរណាស់ ចង់ដល់ឈ្នះចាញ់ហើយ ក៏ស្ទុះលោតទៅដោយកម្លាំងកំពុងពេញពាល ចូលទៅជិតបើកកន្ទុយកន្លើកឡើងលើហើយ ក៏ស្កាត់ផ្លូវនៅចំមុខ ស្រែកទៅថា ស្គាល់អញឬទេទុរភា ខ្លួនអ្នកនេះចិត្តអាក្រក់ឫស្យា មិច្ឆាធន្ទា ព្យាបាទ សម្លាប់តែកូនឯងស្លាប់ច្រើនមកណាស់ហើយ យើងនេះ ក៏ជាកូនបង្កើតរបស់អ្នកដែរ តែក្នុងវេលានេះ យើងប៉ងបំណងមកបំផ្លាញជីវិតអ្នកហោង ៗ

កាលនោះ ទុរភាបានស្ដាប់ហើយ ក៏ក្រេវក្រោធប្រឡាតនេះដូច

ភ្លើងប្រល័យកល្ប ហើយក៏រលាស់ស្នែងលើកកន្ទុយកងឡើងលើ ហើយស្រែកទៅថា ខ្លួនឯងនេះ ជាកូនអញ គួរឬមកមាក់ងាយ និយាយមិនគប្បី ព្រោះហើន ហ៊ានប្រមាថអញជាបិតា ដ៏មានបុណ្យក្រៃ ឮល្បីខ្ចរខ្ចាយសាយសព្វគ្រប់ទីអរញ្ញក ទោះតាំងស្តេចគជសារចុះប្រេង ក៏មិនហ៊ានទទឹងរឹងនៅពីមុខអញ ឯងចង់តស៊ូរឹទ្ធិនឹងអញជាបិតា អញនឹងជល់សម្លាប់អាឯងឲ្យស្លាប់ក្នុងគ្រានេះហោង ។

គ្រានោះ កំហែងទូរគីបានស្តាប់ទូរគាពោលពាក្យអហង្ការហើយ ក៏លោតចូលទៅ ចំអកឡុកឡុយ ហើយឆ្លើយតបទៅវិញថា ខ្លួនអ្នកធ្ងន់ទុច្ចរិត ហើយមកអាងអួតឫទ្ធិនឹងអញដូចម្តេចបាន ទេពក៏លោកមិនជួយឲ្យពរជ័យអ្នកទេ ធ្វើម្តេចនឹងបានរួចដីក៏មរណក្ស័យនឹងអញពុំខាន ។

គ្រានោះ ទូរគានោះ បានស្តាប់ហើយ ក៏ក្រេវក្រោធពិរោធក្រៃពេក ភ្នែកទាំងពីរនោះ ក្រហមច្រាលដូចភ្លើង ក៏កងកន្ទុយគ្រវីស្នែងគ្រវែងខ្លួន ស្ទុះបោលចូលទៅវាធវៃជល់ដីរបើកលើកឡើង រលាស់រហ័សលោតហក់ ហើយបំណងប៉ងក្នុងចិត្តនោះ នឹងផ្តាច់ជីវិតជីវីហោង ។

គ្រានោះ ទូរគីក៏បែងហៅហានមហិមា ឧនក ប្រុងកាយឈរចាំបម្រុងនឹងជល់ ហើយក៏បែរប្រមុខមក គ្រវីស្នែង គ្រលែងដាក់ ប៉ះស្នែងនឹងស្នែងគ្នា ពថយរៀងខ្លួន រួចក៏ស្ទុះបោលចូលជិត ជល់គ្នាទៀតទៅស្នែងនិងស្នែងគ្រលែងរលាស់ប៉ះគ្នា ឮស័ព្ទសន្ធឹកដូចរន្ទះទាំង ៧ យូរបន្តិច

ទៅ ទូរគាក្ខាត់ថយព ទូរគ៏ក៏រុញផល់ដិតកិតកៀករំលៀករ៉ធទៅត្រូវត្រង់ កទូរគា មរណាស្លាប់ទៅហោង ៗ រីទូរគ៏នោះ លុះបានឈ្នះមានជ័យ ជំនះលើបិតាហើយ មហិន្ទ្រាក៏គេកអរក្រៃ ត្រអាលអួតអរងើយង រត់ ល្បងលងដើង តាមទំនើងដោយចិត្តស្រើបស្រួល លោក្កុលក្នុងចិន្តា ទឹកដល់ហ្វូងពួកបរិវារមហិន្ទ្រាញីនោះ ហើយក៏ស្ទុះបោលបោះផ្លោះតម្រង់ មករកក្របីញី ៗ លុះបានមកដល់ហើយ ក៏តាំងស្របស្រង់ក្លិនហិតបោ មាត់លិទ្ធមុខលេងដោយស្នេហា ហើយក៏រួមរសតណ្ហាមេត្រីនឹងហ្វូងក្របី ញីរួចស្រេចកាលណា មហិន្ទ្រាទូរគ៏ សែនសប្បាយកាយសប្បាយចិត្ត រឹតរឹងតែរួមរក្សស្នេហា តាមដោយកាសាសត្វ សែនត្រេកាលត្រអាលអង្គ ក្នុងហិមវ័ន ប្រឡែងលេងនឹងហ្វូងបរិវារមហិន្ទ្រាញី ជាទីសម្រាន្តកាយ សប្បាយចិត្តហោង ៗ លុះយូរបន្តិចទៅ ក៏ត្រេចយាត្រាត្រង់ ចង់ល្បង ដើងរត់ចាកហោលពីហ្វូងបរិវារធំហើយ ក៏ត្រេចដើរដោយផងមាគ៌ាស្ពាន មានចិត្តនោះអហង្ការក្អេងក្អាហាន លុះបានដើរមកដល់ពនាលីហិមវ័ន ក៏ តាំងដល់ក្នុងសិលា ហើយក៏ស្រែកថា រឺយពួកទេវតាទេវៈណា មានសក្តា អានុភាពក្រៃ ចូលមកជាញជ័យតវិទ្ធិគ្នាឲ្យបានដឹងឈ្នះចាញ់ ៗ

កាលនោះ រីអស់ហ្វូងទេវរុក្ខជាធំនៅក្នុងហិមវាពនាលី បានស្តាប់ ពាក្យមហិន្ទ្រាទូរគ៏ទុច្ចរិតចិត្តបាប ហើយទេវតាក៏ដញ្ជឹងរំពឹងគិតទៅថា ខ្ទួន វាជាសត្វតិរច្ឆាន សន្តានពាល ជាចិត្តវាក៏ទុច្ចរិតឫស្យា ថាបើអញនឹង

ចេញទៅជាញជ័យល្បែង ប្រឡងឫទ្ធា សម្លាប់ជីវិតបាន ក៏គិតមើល ទៅដូចជាក់មិនល្អ ថាបើអញនេះទៅតឫទ្ធិនឹង ចាញ់ឫទ្ធិ ក៏នឹងអាប់ អស់កេរ្តិ៍ឈ្មោះទេវគ្រប់កសីហោង ៗ គិតហើយទើបតបវាចាទៅថា អញនេះ មិនមានឫទ្ធានុភាពនឹងជាញជ័យ នោះយើងមិនហ៊ាននឹងអ្នកទេ បើអ្នកចង់តតាំងឫទ្ធិដូច្នេះ ចូរអ្នកទៅញ៉ាំងកាឧបញ្ចពិត ៗ

គ្រានោះ ទូរគីទុច្ចរិតឫស្យា ឃើញពួកទេវតា ក៏ខ្លាចក្រែងស្ញែងឫទ្ធិ មិនហ៊ានដូច្នោះហើយ ក៏រឹតរឹងទ្រើសទ្រនង់ក្នុងចិត្ត មិនគិតខ្លាចអំណាចអ្នកណាឡើយ ទើបមហិទ្ធិក្រាប់គ្រង់តម្រង់ដើរទៅទៀតហោង ៗ លុះក្រាប់មកដល់បញ្ចគិរីបពិត ក៏ចូលទៅរែកភ្នំដំជុំ ៗ ក៏របើកបែកខ្ចាយព្រាយភ្លឺព្រោងដូចផ្កាភ្លើង ហើយក៏ស្រែកទៅថាដោយពាក្យអហង្ការ ពុំមានគោរពញញើតឡើយ រុយនៃ ពួកទេវតាទាំងពួងអើយ ទេវៈណាដែលមានឫទ្ធិបារមីខ្លាំងក្លាហាន ជាងអស់ទេពទេវតា ដែលឋិតនៅក្នុងព្រៃហិមវ ចូរអ្នកមកតតាំងឫទ្ធិនឹងអញដ៏មានឫទ្ធិក្លាហាន ៗ កាលណោះទេវតាដែលនៅនឹងគិរី ៥ អង្គនោះ ស្តាប់ពាក្យទូរគីពោលហើយ ក៏ឆ្លើយតបទៅវិញថា វីអាត្មាខ្ញុំអញទាំងឡាយនេះ នឹងតតាំងឫទ្ធិនឹងអ្នកពុំបានទេ ឃើញទេវតាដែលនៅរក្សាសមុទ្រនោះ គេមានកម្លាំងឫទ្ធានុភាពក្រៃលើសលុបលោកា អញ្ជើញអ្នកចូលទៅជាញជ័យនឹងគេឯង ឯណោះចុះ យើងចាញ់អ្នកហើយ ៗ នឹងអង្គព្រះសមុទ្រទៅ ទើបនឹងមានឫទ្ធាតទល់

ទឹងអ្នកបាន ។ ថាហើយទេវបុត្រក៏លើកដៃចង្អុលបង្ហាញមាគ៌ា ។ គ្រា
នោះ ទូរគីកំហែងក្លាហានបានស្តាប់វាចាទេវបុត្រនោះប្រាប់ដូច្នោះហើយ ក៏
ហោះទៅដោយកម្លាំងឫទ្ធិហោង ៗ លុះដល់ហើយ ក៏ចុះហែលក្នុងមហា
សាគរ មហាឥន្ទ្រក៏គាំងវែងរកវិតវរបែកពពុះសំពោងក្នុងជលសា ហើយ
ស្រែកប្រកាសទៅថា វ៉ុយ ៗ ពួកទេពទេវ ដែលនៅក្រោមមហាសមុទ្រ
ធំ ល្បីពួកឡីមានឫទ្ធិតបៈតូកខ្លាំង ចូលមកច្បាំងទឹងអញឲ្យដឹងគេជដៃ
ហោង ៗ កាលណោះ ព្រះសមុទ្រទេវាធិបតី បានស្តាប់សំដីកំហែង
ទូរគី មានវាចាអួតអាងអំណាចអហង្ការដូច្នោះហើយ ទើបឆ្លើយទៅវិញថា
រីខ្លួនយើងនេះគ្មានឫទ្ធានុភាពទេ យើងនេះសព្វថ្ងៃតាំងចិត្តកាន់ឧបេក្ខា-
ញាណ អ្នកណាហើយនឹងចង់ច្បាំងនឹងអ្នកឲ្យសប្បាយកាយាហឫទ័យ ។
រីខ្លួនអញឯនេះ ចំជាទុច្ចរិតចិត្តឈ្លានពាន មិនដឹងគុណអញសោះឡើយ
ហើយបើអ្នកចង់ជាញជ័យ ចូរអ្នកអញ្ជើញទៅកៃលាសគិរី ។ កាល
ណោះ កំហែងទូរគី បានស្តាប់ទេវបុត្រសមុទ្រទេវាថាដូច្នោះហើយ ក៏
ត្រេកអរសោទរក្រៃ មិនគិតខ្លាចអំណាចព្រះបរមលោកា មហាឥន្ទ្រក៏ស្ទុះ
ឡើងចាកសមុទ្រគម្ភីរ ដោយកម្លាំងឫទ្ធាពលាកាយរំសាយកន្ទុយ បើក
ត្រចៀក ដើរមកតាមដោយមគ្គមាគ៌ាពនាលីហោង ៗ លុះមកដល់
អរញ្ញបពិតកៃលាសហើយក៏ឃើញព្រះត្រៃគូនាថបរមលោកា ក៏ឈប់ឈរ
ហើយពោលវាចាថា ម្នាលព្រះឥស្សរជ័មានឫទ្ធា ខ្លួនអ្នកជាអគ្គទេវនៃអ្នក

បង្ក្រាបកបបានដល់ឋានតុសិត ជាធំនៅក្នុងកំឡុងទិសទាំង ១០ ចូរអ្នក
មកល្បងវិទ្ធទីងអញ ជាអ្នកមានវិទ្ធលីទ្ធសក្តា ។ កាលណោះ ព្រះ
ឥស្សូរលោកា ព្រះអង្គបានស្តាប់ពាក្យមហាទ័ព្វអហង្ការដូច្នេះហើយ ព្រះ
បរមលោកា ក៏មានទេវវង្គ្ការថា យើ ! មើលមើល អាទូរគីឯហ៊ានមក
អួតអាងកាងក្រេវថាវានេះមានវិទ្ធក្លាហាន រំប្រាណអាឯងនេះថាមានវិទ្ធ
ក្លាហានណាស់, នៃអាឯងនេះ ពេញហៅទុច្ចរិតគាក្រក់ក្រៃ បរៃស្រ
ពាលពាលា ហើយអាហ៊ានយកកមកលទីងបក្រពេជ្រ អាឯងជាតិជាសត្វ
តិរច្ឆានអប្រិយ សម្មាប់បិតាហើយបង់មកតវិទ្ធទីងអញទៀត អាឯងនេះ
មិនមែន . . . . ហើយមិនសមជាគូដៃទីងអញទេ, អើ បើអាឯងចង់
ច្បាំងណាស់ អាឯងចូរទៅច្បាំងនឹងពាលីជាបុត្រទេវិន្ទឥន្ទ្រា ឲ្យអាឯង
អស់ជីវិតដោយវិទ្ធញាណពានរ នៅនគរទិតទិនបុរីឯណោះ បើអាឯងស្លាប់
ទៅហើយ ចូរអាឯងទៅកើតជាកូនពញាខរ ឈ្មោះមុន្ទកេណ្ឌ ដ៏មានវិទ្ធ
ពូកែ តែឯងនេះមុខជាស្លាប់ទីងសរជ័យទីងដៃនាពយណ៍បែងភាគ ចុះទៅ
នោះហោង ។ គ្រានោះទូរគីវិទ្ធក្លាហាននោះ លុះត្រូវពាក្យបណ្តាសា
ព្រះឥស្សូរធិបតីឃុនក្របី គឺបណ្តាលចិត្តនោះមោហោតោសោ ធ្គត់ធ្វើង
ក៏យកស្នែងវែងដល់គិរីកៃលាសបន្តិចហើយ ក៏សម្តែងវិទ្ធញាប់ញ័រកក្រើក
ដី ស្រេចហើយឃុនក្របី ក៏ត្រឡប់វិលមកក្នុងព្រៃពពនាលី តម្រង់ទៅ
ជាទីបុរីទិតទិនគត ។ លុះដល់ហើយ ទូរគីនោះ ក៏ចូលទៅវែងស្នួន

ឧទ្យានរបស់ក្រុងពាលី រលំរលើងបាក់បែកដើមវិនាស មិនតែប៉ុណ្ណោះ ក៏ដេញផល់ពួកពានរវេរ៉ក ។

គ្រានោះ វេបណ្ណាពួកពលពានរតូចធំនោះ ឃើញមហិង្សាដេញផល់វឹកវរ ក៏ភ័យភិតតក់ស្លុតរន្ធត់ពល់គ្នា មិនមានពលណាហ៊ានតដៃ ក៏ភ័យនាំគ្នាខ្លាចខ្លួនញ័រជើងដៃ ហើយក៏ស្រែកហៅគ្នាគ្នាជាកោលាហល ខ្លះក៏រត់ជ្រួលស្រងល់ទល់ប្អូកនៅប្អូះ ។ ខ្លះក៏ខំរត់គេចវេះទៅ ត្រឡប់ត្រឡិនកិនប៉ះគ្នាទៅវិញទៅមក ។

កាលណោះ កំហែងទូរគីនោះ លុះឃើញពួកពលស្វាមិនហ៊ានតដៃឡើយ ហើយក៏ស្ទុះដើរមកដល់មុខព្រះលានជ័យហោង ៗ ហើយក៏ស្រែកហៅថា អុយ! ពានរខ្ទុជាចៅមឿងខិតខិនបុរី ល្បីឮថាមានរិទ្ធិពូកែវិសេស ដ្បិតអង្គអញគ្មានមុខអ្នកណាហើយអាចក្លាហានហ៊ានចូលជាញជ័យតដៃនឹងអញ ។ រីអង្គអញនេះ ទីលំនៅអញសំណាក់ ក្នុងទីពនាលីហិមពាន្តមានឫទ្ធាក្លាហានណាស់ អស់ពួកទេវរ័ក្ខទេព្រ័ក្ស ព្រមទាំងចក្រវាឡមិនហ៊ានតបេស្គាអានុភាពនឹងអញបានឡើយ ហើយបើឯងពូកែមានរិទ្ធិវិសេសជាចំបង ចូលមកប្រឡងល្បងរិទ្ធានឹងគ្នា ឲ្យឃើញគេជដៃក្នុងគ្រានេះ, អម្បាលតែព្រះឥស្សរបរមគិរី ក៏មិនហ៊ានតរិទ្ធិបេស្គានឹងអញឡើយ ។

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិជ្ជាឋាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញឹក-ថែម រៀបរៀង

( ក )

បំណងជើង " សាស្ត្រា សុគន្ធជោង "

អ្នកនិពន្ធ *ព្រហ្មបវរគត្ត ឬ បវរគត្ត "ព្រហ្ម" ។*

កាលបរិច្ឆេទ *ថ្ងៃអាទិត្យ ៨ កើត ខែស្រាពណ៍ ឆ្នាំចអដ្ឋស័ក ព.ស. ២៤២៩ ច.ស. ១២៤៨ ( គ.ស. ១៨៨៦ ) ។*

របៀបនិពន្ធន៍ *ពាក្យកាព្យ ( បទកាកគតិ – ពំនោល – ព្រហ្មគីតិ – កុជគ្គលីលា ) ។*

ប្រភពរឿង *ហាសិបជាតក៍ ឬ បញ្ញាសជាតក ។*

លក្ខណៈឯកសារ *សាស្ត្រាស្លឹករឹត ៨ ខ្សែចប់ ជុំជាតក៍ ។ ខ្សែទី ១ មានសន្លឹក ៣៣, ទី ២ មានសន្លឹក ៣៤, ទី ៣ មានសន្លឹក ៣៤, ទី ៤ មានសន្លឹក ៣៦, ទី ៥ មានសន្លឹក ៣៤, ទី ៦ មានសន្លឹក ៣៦,*

ទី ៧ មានសន្លឹក ៣៦ ទី ៨ មានសន្លឹក ៣៨ ។

បូករួម ២៨១ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានច្បាប់ដើមអំពី

វត្តហារ ខេត្តកណ្តាល យកមកចារ ចម្លងកាលពី

ព.ស. ២៤៨៦ ចុះលេខសាស្ត្រា ១៣៦៩ ។

អត្ថបទផ្តើម ៖ កាទុនៃខ្ញុំ នេះនាមឈ្មោះព្រហ្ម បរិភក្តី គិតកាព្យ

និទាន ផ្សិតមានសេចក្តី និទានរឿងនៃ សុគន្ធជោងណា ។

មានគុណទិបាត ហៅហាសិបជាតក អតិក្កន្តា កន្លងឆ្ងាយហើយ

កាលណោះព្រះមហា ពោធិសាត្ត សាងព្រះបារមី ។ . . .

ពុទ្ធសាសនំ អតិក្កន្តំ កន្លងហើយណា ពីរពាន់បួនរយ

ម្ភៃប្រាំបួនវស្សា ចុល្លសករាជត្រូវជា មួយពាន់ពីររយ សែសិប

ប្រាំបី កាលខ្ញុំគិតនៃ ចងជាកាព្យដោយ អតីតនិទាន មាន

មកមិនឲ្យ លើសលស់តាមដោយ សេចក្តីពាក្យកាព្យ ។

វិភរ ប្រាំបីកេចខែ ស្រាពណ៍នៃឆ្នាំ នក្សត្រអដ្ឋស័ក

ជៀងជាក់កាលក កាព្យគិតតាំងត ទុកក្នុងសាសនា. . .។ល។

អត្ថបទបញ្ចប់ ៖ រីឯព្រះឥន្ទ្រ ហោមហៅទេវិន្ទ្រ នោះឯងតែងមាន គុណ

និងពោធិ នោះជាប្រធាន ជាសាវកញាណ អនុរុទ្ធាចារ្យ ។

ឯអាជានេយ្យ បេរិលវិនៃវៃ ជួបជុំជាគា ជាអង្គព្រះធម្មន្ទថេក
សាវ័កសាស្តា សារពេជ្ញញាណញោយ្យ ។ ព្រះជ័យសុរវង្ស
អន្ទោលជាតិទ្រង់ សន្សំបារមី ដល់ជុំជាតកខ្ញី ត្រាស់ធម៌
ប្រាំបី ហ៊ឹនបួនពាន់ហោង ។ គឺអង្គព្រះពុទ្ធ ប្រសើរវិសុទ្ធ
វិសេសកន្ទុង ទេសនាទូន្មាន មនុស្សសត្វនោះផង គិតដ៏ចម្ងង
ជាក់ដល់និញ្វាន ។ និពាននេះស្រេច គិតការព្យកែគេច លើក
ខុសក្រែងមាន លោកណាចាំជាក់ សេចក្តីនិពាន ខ្វះខាត
ក្រែងមាន ជួយតម្រង់ផង ។

+

បំណងជើង " សាស្ត្រា អាចុះអាសាញ់ "

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាយ (បទកាកគតិ - មណ្ឌាគាគ - ពំនោល -ព្រហ្មគីតិ - កុជង្គលីលា ) ។

ប្រភពរឿង រឿងព្រេងខ្មែរ

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែចប់ ចំនួនសន្លឹក ២១ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តស្តៅ
ខេត្តកំពង់ចាម ចុះលេខសាស្ត្រា ៦៨៣ ។

អត្ថបទផ្ដើម : បវកាកគតិ ។ បពិត្រអញខ្ញុំ ហត្ថាបង្គំ ប្រណម្យ សូមពរ សូមមានតេជះ ដូចព្រះរាមា សូមមានប្រាជ្ញា ដូចព្រះមហោសថ ។ ខ្ញុំថ្វាយបង្គំ ព្រះពុទ្ធុត្តម ប្រាជ្ញា មុះមុត តែងនាំសត្វផង ឆ្លះឆ្លងសមុទ្រ សង្សារចំហុត ដាក់ដល់សួគ៌ា . . . ។ល។

អត្ថបទបញ្ចប់ : ចៅសាញ់សោយរាជ្យ មែនមានអំណាច លើព្រះបិតា សឹងតែបានសុខ ឥតទុក្ខភយា ទោះរាស្ត្រប្រជា ឥតមានទុក្ខសោក ។ ខ្ញុំលក់ទំនិញ ដូចពីមុនមិញ ទិញគ្នាទៅមក អឹកធឹកក្រៃ រអែករអាក ទិញគ្នាទៅមក រកស៊ីទៅហោង ។ ឥតទុក្ខឥតភ័យ រកស៊ីសព្វថ្ងៃ សប្បាយឥតហ្មង ចៅសាញ់សោយរាជ្យ យូរក្រៃកន្លង ពុំផ្អើលដល់ម្ដង សឹងសុខឥតក្រែង ។

រីឯពាក្យខ្ញុំ សេចក្ដីសុខុម ផុតប៉ុណ្ណោះឯង នេះតាមទំនង រឿងគេថ្លាថ្លែង តែប៉ុណ្ណោះឯង សូរេចហើយហោង ។

បំណងរឿង “ សាស្ត្រា ទេវទត្ត(១) ”

អ្នកនិពន្ធ លោក អម្មតក្សត្រី “ម៉ុក” (២) ។

កាលបរិច្ឆេទ ថ្ងៃព្រហស្បតិ ៣ កើត ខែអស្សុជ ឆ្នាំមមែ ព.ស. ២៤០២ (គ.ស ១៨៥៩) ។

របៀបនិពន្ធ ពាក្យកាយ (មានតែបទកាកគតិ តែមួយបទ ហូតដល់ចប់) ។

ប្រភេទរឿង ហាសិបជាតក៍ ឬបញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ៦ ខ្សែចប់ដុំជាតក៍ ។ ខ្សែទី ១ មាន ២៩ សន្លឹក ខ្សែទី ២ មាន ៣៦ សន្លឹក ខ្សែទី ៣ មាន ៣៣ សន្លឹក ខ្សែទី៤ មាន២៧ សន្លឹក ខ្សែទី ៥ មាន ៣៤ សន្លឹក ខ្សែទី ៦ មាន ៣២ សន្លឹក ។

---

១ – រឿងទេវទត្តពាក្យកាព្យនេះ និពន្ធដោយលោក អម្មតក្សត្រី “ម៉ុក” ខ្ញុំស្រង់ចម្លងអំពីច្បាប់សាស្ត្រាស្លឹករឹតជាដំបូង កាលពីឆ្នាំ ១៩៤៤ ។ តមកក្នុងឆ្នាំ ១៩៤៧–៤៨ ទើបឃើញមានចុះផ្សាយអត្ថបទនេះ ក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ។

២ – កវីនេះ មានគោរម្យងារជា អម្មតក្សត្រី នាមដើម “ម៉ុក” បាននិពន្ធរឿងនេះកាលពី ព.ស ២៤០២ ចុងសម័យឧដុង្គ ។ ប្រហែលជាកវីនេះទេដឹង? នៅខាងដើមសម័យដើមក្រុងភ្នំពេញ លោកមានគោរម្យងារជា ឧកញ៉ាសុន្ទរវោហារ “ម៉ុក,, ជាកវីមានកិត្តិនាមល្បីល្បាញក្នុងរជ្ជកាលព្រះករុណា ព្រះសុវណ្ណកោដ្ឋ មានមុខងារជា ចាងហ្វាងកឹង ព្រះអាលក្ខណ៍ ដូចខ្ញុំបានសរសេរជីវប្រវត្តិយ៉ាងខ្លី នៅខាងដើមរឿងទេវទត្ត ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ឆ្នាំ ១៩៤៧ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពី
វត្តសម្បូរ ខេត្តកណ្ដាល យកមកចារចម្លងចុះ
លេខសាស្ត្រា ១៣៨៣ ។

អត្ថបទផ្ដើម: ឋទាកគតិ ។ អហំវន្ទា អញ្ជលិយា បគ្គយ្ហ សិសបណេ
ពុទ្ធេក វិញ្ញាណា ញាណសេដ្ឋា ។ អហំនមោ នមស្សិត្វា
ធម្មគុណា សង្ឃគុណំ អហំនមោ នមស្សមានោ វត្តិខ្ញុំ ។ ...
សកពជគ្រប់គ្រាន់ បួនយេពីរពាន់ ទិងពីវស្សា គនគិត
គ្នាគាន់ បច្ចុប្បន្នសាសនា មមែងឡា អស្សុជមាសី ។
សុក្កប្បក្ខេ តេត្តិយេ គរុកទី បីកើតគត់ច្បាស់ ព្រហស្បតិ៍
តិរកាលអង្គត-សូរសមសក្កា ។ល។ . . .

អត្ថបទបញ្ចប់: វេវន្ទនវិន្ទា នរុត្តមោ វិសេសចេក្កង្កាន ចេក្កង្កល់
ប្រាជ្ញប្រុះ វិញ្ញាញេយ្យញាណ ពុំគិតក្រក្សាន្ត ព្រះថេរដៃ ។
គឺអង្គព្រះពុទ្ធ ប្រិតៃបរិសុទ្ធ ខ្ទាំងកពៃគ្រ ស្មោះស្មើទីនេស
វិសេសថ្លៃថ្លៃ គ្រូគ្រប់សុវណ្ណ សុវណ្ណនាគារ ។ ទាំង
កុក្កណ្ឌាយក្ខ មនុស្សទេពសឹងពាក់ សឹងពឹងបេក្កា បញ្ចង់
ប្រតិស្ឋ នមស្សការ លុះត្រៃសរណា សរណគមគាប់ ។
វរទេវន្ទា គឺជាជាតកោ ទិដ្ឋកំបែងចប់ ដោយកាព្យកបកិច្ច
សេចក្ដីគ្រប់លុះសព្វ បរិបូណ៌គ្រាន់គ្រប់ ប្រការម៉្លេះហោង ៕

( នៅមានត )

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ញូ · គាន ជ

ប្រែ · រៀបរៀង

( គ )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលចំណាន ទាំងមានសន្តានស្នេហជាតិ
យូរ—អ៊ុន

លុះនាយទាហានជាបំរើ កាន់តម្រាស់ចូលទៅហើយ ក៏អង្គុយព្រងើយធ្វើបែបមិនដឹងខ្លួន គ្មានគំនាប់តាមគួរសមសោះ, តេងអ៊ីក៏និយាយនឹងអ្នកកាន់សំបុត្រតម្រាស់នោះថា កាលគ្រាព្រះចៅវុយអងគង់ព្រះជន្មនៅ បានតាំងចៅហ្វាយយើងឲ្យធ្វើធំហើយ តែព្រោះមានមនុស្សញុះញង់ ទើបកើតជារឿងហេតុមកដល់សព្វថ្ងៃនេះ, ឥឡូវព្រះចៅវុយអង ទើបតែនឹងសុគតមិនទាន់បានប៉ុន្មានថ្ងៃ ស្រាប់តែមានតម្រាស់មកកាត់ទោសបងប្អូនឯង ៗ តេងអ៊ីថា ចៅហ្វាយស្រុកយើងនេះ មានសតិបញ្ញាឈ្លៀវឈ្លាត ទីងរកនរណាស្មើគ្មាន គួរតែបានធ្វើធំជំនួសបិតា តែមានមនុស្សញុះញង់បានជាមិនបានវិញ ។ •

ឯចូស៊ុត ក៏បង្គាប់ទាហាន ឲ្យទាក់កបំរើកាន់ត្រាបង្គាប់នោះឲ្យជាប់ ហើយឲ្យយកដំបងដេញវាយបំរើនោះឲ្យចេញទៅ, បំរើនោះ ក៏វិលទៅ

ទូលចូភីតាមដំណើរ ។ ចូភីខឹងណាស់ ទើបប្រើខៅផូឲ្យនាំទាហាន ៣.០០០ លើកប្រញាប់ទៅដល់ស្រុកលិមឈី ។ ឯពួកទាហានដែលយាមទ្វារស្រុកលិមឈី មិនព្រមបើកទ្វារឲ្យខៅផូចូលទៅ, ខៅផូក៏សម្លាប់ទាហានយាមទ្វារនោះស្លាប់ លើកកងទ័ពចូលទៅដល់លំនៅចូស៊ុត ឃើញចូស៊ុតនឹងគេងងី គេងអ៊ី កំពុងផឹកស្រាស្រវឹងដេកទាំងអស់គ្នា ខៅផូក៏ឲ្យទាហានចាប់ចងទាំងខ្លួនដាក់លើរទេះទាំង ៣ នាក់ ហើយបង្គាប់ទាហានឲ្យចាប់យកកិរិយាបុត្រប្រពន្ធក្នុងផ្ទះចូស៊ុត, លុះទៅដល់ស្រុកស៊ៀបកុនហើយ ក៏នាំខ្លួនចូស៊ុតនឹងគេងងី គេងអ៊ុ ចូលទៅថ្វាយចូភី ។ ក៏បង្គាប់ឲ្យយកខ្លួនគេងងី គេងអ៊ី ទៅប្រហារជីវិតបង់ ហើយឲ្យយកចូស៊ុតទៅដាក់គុកទុក ។ មាតាចូភីដឹងដំណឹងថា ចូហ៊ុមចងកស្លាប់ទៅហើយ ឥឡូវចូភីចាប់ចងខ្លួនចូស៊ុតមកសម្លាប់ទាំងស្រគប់ក្ខពួកពេញទៀត. ឯខ្លួនចូស៊ុតឲ្យដាក់គុកទុកដូច្នោះ, មាតាក៏សោកាពិលាបអាណិតកូនណាស់ ហើយឲ្យហៅចូភីចូលទៅ, ចូភីក៏ក្រាបសំពះមាតា ។ ទួញយំអង្វរកូនសុំទោសថា ប្អូនប្រុសរបស់ចៅម្នាក់នេះ រមែងចូលចិត្តផឹកស្រា វាអួតថាខ្លួនវាល្អត្រឹមត្រូវ វេលានេះ ជីវិតម្ដាយនៅរស់ នៅឲ្យកូនយល់មុខម្ដាយម្ដងចុះ ព្រោះវាជាប្អូនប្រុសរួមឧទរជាមួយគ្នានឹងកូន ។ កុំសម្លាប់វាឡើយ បើទៅទុកជីវិតវាហើយ ទោះបីម៉ែស្លាប់ក៏ធ្មេចភ្នែកជិតទៅបាន ។

ចូភីជំរាបមាតាថា ប្អូនខ្ញុំបាទនេះ វាជាអ្នកឆ្លៀវឆ្លាតណាស់ ខ្ញុំបាទ

ក៏មានចិត្តស្រឡាញ់ពប្រាកដ ដែលខ្ញុំបាទធ្វើទោសពយ៉ាងនេះ ប្រយោជន៍ពងតាល កុំឲ្យពធ្វើអាក្រក់តទៅមុខទៀត ខ្ញុំបាទមិនមែនចង់សម្លាប់ពទេ អ្នកម្តាយកុំព្រួយបារម្ភឡើយ ។ មាតាពុកទូលថាដូច្នោះហើយ ក៏មានអំណរណាស់ ត្រឡប់ចូលទៅក្នុងវិញ, ចូកក៏ត្រឡប់ទៅកាន់ទីនិយាយការ ហើយឲ្យយកខ្លួនចូស៊ិតចេញទៅសួរ, ហ៊ូហ៊ុមក៏ទូលសួរចូកថា មាតាទ្រង់បានសុំទោសចូស៊ិតថា ចូកប្រាប់ថាមាតាខ្ញុំសុំទោសចូស៊ិត ខ្ញុំលើកជូនទៅហើយ, ហ៊ូហ៊ុមថា ចូស៊ិតនោះ ជាមនុស្សប៉ិនប្រសប់ណាស់ បើនឹងទុកជីវិតទៅមិនបានទេ ក្រែងយូរទៅនឹងកើតអន្តរាយ ។ ចូកថា នឹងទទឹងប្រសាសន៍មាតាម្តេចបាន ។ ហ៊ូហ៊ុមថា ទូលបង្គំបានឮគេនិយាយល្បីថា, ចូស៊ិតនោះចេះតែងឃ្លោងចំណាប់ណាស់ សូមទ្រង់ឲ្យហៅខ្លួនមកតែងឃ្លោងល្បងមើល បើចេះល្អមែន ក៏មិនគួរនឹងសម្លាប់ទេ ។ ចូកក៏ឲ្យហៅខ្លួនចូស៊ិតចូលមក, ចូស៊ិតភ័យណាស់ ចូលទៅដល់ហើយ ក៏ក្រាបសំពះបងអង្វរសុំទោស ។

ចូកថា បងនឹងចៅឯងជាបងប្អូននឹងគ្នាពោះមួយ ឥឡូវបងបានជាម្ចាស់ផែនដីហើយ គឺដំនួសបិតាយើង, បណ្តានាម៉ឺនមុខមន្ត្រីធំ - តូចក៏គោរពខ្លាចបងទាំងអស់, ហេតុអ្វីចៅឯងមិនក្រែងខ្លាចយើងបន្តិចសោះ, កាលបិតានៅរស់ តែងប្រើចៅឲ្យតែងឃ្លោងស្តាប់, បងនៅសង្ស័យថាក្រែងអ្នកដទៃធ្វើឲ្យចៅទេដឹង ? បើធ្វើបានមែនពិត ត្រូវដើរចេញទៅ

៧ ដំហាន ហើយថាពាក្យឃ្លោងឲ្យបានសេចក្តី ឲ្យបងស្តាប់ល្បងមើល ត្រូវពណ៌នាពីយើងបងប្អូន តែត្រូវឲ្យយកសេចក្តីដទៃមកប្រៀបក្នុងបងប្អូនយើង កុំឲ្យចេញឈ្មោះបងប្អូន, បើធ្វើបាន បងនឹងលើកទោសចោល បើធ្វើមិនបាន បងនឹងចុះទោសប្រហារជីវិត ។ ចូស៊ុតថា សូមទ្រង់ឲ្យហាមកុំឲ្យឮមាត់មនុស្សទាំងពួងនិយាយគ្នា រួចចាំស្តាប់ចុះ ហើយដើរគិតថាពាក្យឃ្លោងនោះថាឲ្យល្មមតែ ៧ ដំហានឲ្យចប់សេចក្តី ។

ក្នុងសេចក្តីនោះថា :

"ទឹងលីងសណ្តែកនៅក្នុងឆ្នាំង ត្រូវដុតភ្លើងខ្លាំងតាំងឲ្យស៊ុស
យកទងសណ្តែកដុតធ្វើអុស គ្រាប់លីងឆ្អិនស្រុសព្រោះទងវា ។
ដើម ទង និង ឫសដុះជាគ្រាប់ កើតជាប់ជាមួយដោយពូជជារ
ភ្លើងឆេះព្រោះទងឆាងផ្គុំគ្នា ធ្វើឲ្យគ្រាប់វាឆ្អិនខ្លោចទៅ" ។

ចូភីបានស្តាប់ឃ្លោងដូច្នេះ ក៏នឹករឭកដល់សេចក្តីស្រឡាញ់បងប្អូនដែលជាប់ជាតិលោហិតជាមួយគ្នា ឲ្យកើតសេចក្តីខ្សឹកខ្សួល អាណិតមេត្តា ក៏សោកាពិលាប មាតាក៏ទូលដើរមកត្រូ ទើបមកនិយាយថា ទៅជាបងគេ ហេតុម្តេចមកធ្វើញាំញី ឲ្យប្អូនបានសេចក្តីទុក្ខលំបាកក្តៅក្រហាយដូច្នេះ ? ចូភីបានឮមាតាថាដូច្នេះ ក៏ក្រោកឡើងគំនាប់ហើយដកបថា នេះឯងជាទំនៀមផែនដីនៃអ្នកធំ បើឃើញថា អ្នកឯណាធ្វើខុសហើយ ក៏ត្រូវតែធ្វើទោសតាមទោសានុទោស បើមានសេចក្តីយោក

យល់ត្រាប្រណី ច្បាប់ផែនដីក៏ទឹងសាបរលាបខុសអំពីបុរាណរាជប្រវេណី ទៅ ហើយចូគីចាត់ឲ្យចូស៊ុតទៅឈររក្សាស្រុកអានហៀង ជាចុងស្រុក ឆ្ងាយពីទីក្រុងចេញទៅ, ចូស៊ុតក៏ព្រមទទួលបង្គាប់ គំនាប់លាចេញទៅ នៅអានហៀង, ឯចូគីក៏តាំងកើងយសខ្ពស់លើសជាងបិតា ប្រើអាការសង្កត់សង្កិនព្រះចៅហៀនតេ លើសជាងអំណាចចូចូ មួយសាទៅទៀត ។ សម័យនោះ មានមនុស្សដែលស៊ើបការណ៍ នាំយកការពិតមានទៅទូលព្រះចៅឡេវពី ឯស្រុកសែឈួន ។

ព្រះចៅឡេវពី លុះទ្រង់ជ្រាបនូវព្រឹត្តិការណ៍សព្វប្រការដូច្នោះ ក៏ព្រួយព្រះទ័យណាស់ ត្រាស់ឲ្យប្រជុំអស់នាម៉ឺនមុខមន្ត្រី ដែលជាទីប្រឹក្សាទាំងពួងមកព្រមហើយថា ចូចូស្លាប់ទៅ ឥឡូវបានចូគីជាកូនឈរនិយាយការជំនួស ហើយចេះតែសង្កត់សង្កិនព្រះចៅហៀនតេ លើសជាងចូចូទៅទៀត ឯចំណែកខាងស៊ុនគួន ក៏បន្ទាបខ្លួនទៅចំណុះចុះចូលធ្វើជាខ្ញុំចូគីហើយ, វេលានេះ យើងគិតនឹងចង់លើកទ័ពទៅច្បាំងយកស្រុកកាំងតាំង សងសឹកគួនអ៊ូឲ្យបានរួចសម្រេចនោះលើកទៅវាយកំចាត់អាសត្រូវពាលសម្បត្តិក្នុងផែនដីទាំងអម្បាលនេះ ឲ្យរាបទាបឲ្យបានទៀត លៀវហួបានឮដូច្នោះក៏យំ ហើយទូលថា គួនអ៊ូ, គួនប៉េង ស្លាប់បង់ត្រានេះ ក៏ព្រោះតែឡេវហង និង បេងតាត់ មិនលើកទ័ពទៅជួយ ឯ២នាក់នេះ មានទោសដល់ស្លាប់ គួរតែទ្រង់នឹងសម្លាប់ចេញទើបត្រូវ

ព្រះចៅឡៅពីយល់ឃើញត្រូវ ក៏ឲ្យទៅយកខ្ទួនឡៅហង និង បេងគាត់ មកដើម្បីសម្លាប់ចេញ ។

ខ្ទួនបេង ឮដូច្នោះ ក៏ទូលតាស់ឃាត់ថា សូមឲ្យទ្រង់បង្អង់ឈប់សិនបុះ ព្រោះយើងគិតធ្វើការសង្គ្រាមជាធំណាស់ និងស្រួលត្រូវធ្វើការប៉ុណ្ណោះ ក្រែងឡៅហង, បេងគាត់ និង ទៅជាសត្រូវឡើង, សូមទ្រង់តាំងឲ្យអ្នកទាំង ២ នេះញែកគ្នាចេញទៅឈរក្សាស្រុកម្នាក់ស្រុក១ ប្រសិមយើងធ្វើការជាក្រោយឲ្យបានស្រួល ។ ព្រះចៅឡៅពីយល់ឃើញត្រូវ ទើបចាត់ឲ្យនាំត្រាតាំង ទៅតាំងឡៅហងជាចៅហ្វាយស្រុកបិតុក តាំងបេងគាត់ជាចៅហ្វាយស្រុកយុង ។

ឯផែអៀវ ជាពួកប័ក្ខ ត្រូវអធ្យាស្រ័យគ្នា នឹងបេងគាត់ កំពុងគាល់ព្រះចៅឡៅពីនៅទីនោះ លុះឮព្រះរាជតម្រាស់ ដូច្នោះ ក៏លបធ្វើសំបុត្រចាត់បម្រើជាសម្ងាត់ទៅប្រាប់បេងគាត់ឲ្យដឹងខ្លួន, បម្រើក៏កាន់សំបុត្រចេញទៅតាមផ្លូវទក្សិណស្រុកសែឈួន ។

ម៉ាឈៀវ ទៅតយល្បាតចាប់បានបម្រើរបស់ផែអៀវ បានឃើញមានសំបុត្រ ក៏ស្រាយយកទៅមើល ដឹងសេចក្ដីនោះហើយ ម៉ាឈៀវក៏ទៅជួបនឹងផែអៀវក្នុងផ្ទះ, ផែអៀវក៏ឲ្យរៀបតុលៀងអាហារ ផឹកស្រាជោកកាលណា ម៉ាឈៀវក៏ល្បងសួរយកការណ៍ថា អ្នកជាមនុស្សមានសតិបញ្ញា ពីដើមមកព្រះចៅឡៅពីបានជប់លៀងអ្នកច្រើនណាស់ មក

ដល់សម័យនេះ ខ្ញុំឃើញមិនដូចពីដើម ដូចជាគ្មានសេចក្ដីប្រោសប្រាណអ្វីសោះ ។

ផែអៀវ ស្រវឹងស្រាខ្លាំងណាស់ឆ្លើយថា អាឡៅពីកញ្ញាស់នេះ ក៏ជាមនុស្សត្រឡប់ត្រឡិន មិនទឹងខ្លួនត្រង់ណាសោះ បើកាលណាមានឱកាស ខ្ញុំនឹងសងសឹកពុំបាន ។ ម៉ាឈៀវក្លែងថា ខ្លួនខ្ញុំក៏មានសេចក្ដីគាន់គ្នាញ់ក្នុងចិត្តមកជាយូរណាស់ហើយដែរ ។ ផែអៀវបានឮដូច្នោះ ក៏ឆ្លើយថា បើដូច្នោះ ចូរអ្នកលើកទាហានរបស់អ្នកទៅគិតគ្នានឹងបេងគាត់ឲ្យវាយចូលមកចុះ ខ្លួនខ្ញុំនិងទាហានរបស់ខ្ញុំ នឹងចាំរះគិតធ្វើកលខាងក្នុង មុខជានឹងកើតការដោយស្រួលមិនខាន ។ ម៉ាឈៀវថា អ្នកគិតការយ៉ាងនេះស្រួលណាស់ ចាំថ្ងៃក្រោយយើងនឹងប្រឹក្សាគ្នាទៀត នឹងបានសងសឹកតាមគំនិតយើងគិត និយាយគ្នាហើយ ម៉ាឈៀវក៏លាចេញទៅ ហើយយកមនុស្សបំរើផែអៀវ និងសំបុត្រគាងនោះ ចូលទៅថ្វាយព្រះចៅឡៅពី ហើយចូលទៅរៀបទូលសេចក្ដីតាមសំដីដែលផែអៀវនិយាយនឹងខ្លួននោះ ថ្វាយព្រះចៅឡៅពីទ្រង់ព្រះសណ្ដាប់, ព្រះចៅឡៅពីទ្រង់ខ្ញាល់ខ្លាំងណាស់ ត្រាស់បង្គាប់ឲ្យទៅចាប់ខ្លួនផែអៀវ មកកាយពីតារណាសួរយកចម្លើយ, នោះផែអៀវក៏ឆ្លើយទទួលតាមស័ត្យ ហើយក៏ត្រាស់បង្គាប់ឲ្យយកខ្លួនផែអៀវទៅដាក់គុក ។ ព្រះចៅឡៅពី ក៏ទ្រង់ប្រឹក្សានឹងខុងបេងថា ផែអៀវកាគិតក្បត់នឹង

យើងដូច្នេះហើយ បើយើងនឹងចិញ្ចឹមរក្សាទុកក៏ពុំបាន ប្អូនឹងគិតប្រការម្តេច ?

ខ្ញុំបេងទូលថា: អាផៃអៀវនេះ វាជាមនុស្សព្រើលចំពួតសោះ បើនឹងចិញ្ចឹមរក្សាទុកក៏ពុំបាន គង់មានពេលទៅថ្ងៃមុខ ៗ ជានឹងប្រទុស-ក៏យើងវិញពុំខាន ។ ព្រះចៅឡៀតក៏ត្រាស់ឲ្យដាក់គុកផៃអៀវទុកឲ្យស្លាប់ក្នុងគុកនោះ, ឯការនោះមិនស្ងាត់ មានមនុស្សនាំដំណឹងទៅប្រាប់បេងគាត់ ៗ ដឹងដូច្នោះក៏ភ័យខ្លាំងណាស់ ព្រោះដឹងថាខ្លួនមានទោសខុសមកស្រាប់ផង ថែមទាំងឃើញត្រាតាំងបំបែកឡៀតហងទៅឈរស្រុកប៉ីតុក ឯខ្លួនឯងក៏ពាល់គំនិត ព្រោះឥតមានចំប្រឹក្សាការសោះ ទើបឲ្យអញ្ជើញ សិន-តាំ ជានាយទាហាយធំក្នុងស្រុកសុងយ៉ុង ហើយនឹងស៊ុន-នី ជានាយទាហាននៅស្រុកហងឡុង, ទាំង ២ នាក់នេះបងប្អូននឹងគ្នា ត្រូវអធ្យាស្រ័យគ្នានឹងបេងគាត់ លុះនាយទាហានទាំង ២ មកដល់ហើយ បេងគាត់និយាយថា ហ្លួងបេងនិងខ្ញុំ បានធ្វើសេចក្តីគាប់ប្រសើរទុកដល់ព្រះចៅឡៀតមកពីថ្ងៃមុនច្រើនណាស់; វេលានេះ ហ្លួងបេងក៏ស្លាប់ទៅហើយ ឡៀតភ្លេចអស់សេចក្តីគាប់ប្រសើរនោះ ត្រឡប់គិតប្រទូសក៏យខ្ញុំវិញ ខ្ញុំមិនដឹងនឹងគិតគំនិតយ៉ាងណា ទើបនឹងបានឲ្យរួចពីសេចក្តីស្លាប់នោះបាន ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ស)

លោក ឌឹក-គាម ប្រមូលរៀបរៀង

សាស្ត្រាចចក : ទ.ក. ១១, ទំព័រ ១០៦៩, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

សិប្បកថា : ព្រះឧបាលិវង្ស មឹង-សែស ទ.ក. ៩, ទំព័រ ៨៧៤, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។ ទ ក ៨, ទំព័រ ៥៦៣, ឆ្នាំ ១៩៥៥, (ម.៥២/១៧) ។

សិវិជាតក : លោកមហា ប៉ុណ្ណ-សម្កាជ ទ.ក. ១១, ទំព័រ ៥៩៩, ឆ្នាំ ១៩៤៦, (ម ៥២/១៨) ។

សិរីវិបុលកិត្តិជាតក : ព្រះឧត្តមមុនី អ៊ុំ ស៊ូ ទ.ក. ១-៦, ទំព័រ ៩៤, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

សិល្បៈនៃអតីតព្រះរាជអាណាចក្រខ្មែរ : លោក ក៏យ-ប៊ុក ទ.ក. ៧, ទំព័រ ៦៥៤ ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សិល្បៈពុទ្ធសាសនា : ព្រះឧបាលិវង្ស សូ-ហាយ ទ.ក. ៥, ទំព័រ ៤១១, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

សិល្បរបាំ : ផេង-ជ្រៅ ទ.ក. ៨, ទំព័រ ៥៤៧, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សិលាចារឹកជ័យ-នន្ទ : លោក ឌីក-គាម ទ.ក. ៥, ទំព័រ ៥១៥ ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

សិលាចារឹកត្រពាំងរុង : លោក ឌីក-គាម ទ.ក. ៨, ទំព័រ ៨៣២, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

សិលាចារឹកនគរវត្ត : ព្រះមហាពិទូរក្រសេម ទ.ក. ៤-៥-៦, ទំព័រ ៣, ឆ្នាំ ១៩៣៨, (ម.៥២/១០) ។

សិលាចារឹកប្រាសាទវិមានអាកាស : ព្រះភិក្ខុ ប៉ាង-ខាត់ ទ.ក. ៨, ទំព័រ ៩១៥, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សិលាចារឹកក្ដីស្វរ : លោក ឌីក-គាម ទ.ក. ១១, ទំព័រ ១១៩៤ (ម.៥២/៣៦) ។

សិលាចារឹកស៊ុម៉ង់រឿងព្រះពុទ្ធសាសនា : ទ.ក. ១-២-៣ ទំព័រ ១៣, ឆ្នាំ ១៩៣៧, (ម.៥២/៣២) ។

សីលធម៌ : ឃុនបណ្ណាទុរក្ស ប៊ូ-ប៉ូ ទ.ក. ១, ទំព័រ ២២, ឆ្នាំ ១៩៥៥ (ម.៥២/២៧) ។

សីលធម៌ និង សិល្បសាស្ត្រ : ឃុនបណ្ណាទុរក្ស ប៊ូ ប៉ូ ទ.ក. ៧ ទំព័រ ៦៣៦, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

សុខកថា : ព្រះមហា ផៃ-មុល ទ.ក. ១១, ទំព័រ ៨១០, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។ ព្រះមហា សុខ-ទេ ទ.ក. ៣,

ទំព័រ ១៦៣, ឆ្នាំ ១៩៥៤ (ម.៥២/៤៦) ។ ព្រះបាឡាត់ បទុមវង្ស ហ៊ុន-កេង ទ.ក. ៤, ទំព័រ ៣៥៩, ឆ្នាំ ១៩៥៩ (ម៥២/៣១) ។

សុខមូលតាឌមិ : ភិក្ខុបសេនោ ញ៉ែម-នី ទ.ក. ៤, ទំព័រ ១៥៤, ឆ្នាំ ១៩៣៦, (ម.៥២/៣៧) ។

សុខុប្បត្តិមូលគាថា : ព្រះមហា ទៅ-ជា ទ.ក. ៦, ទំព័រ ៥៨៣, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សុទោទាយកគាថា : ព្រះអាចារ្យ ទូច-ឡេង ទ.ក. ២, ទំព័រ ៨៣, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

សុចរិត និង ទុច្ចរិត (រឿងព្រេងរុស្ស៊ី) : អ្នកស្រី ស-សក ទ.ក. ៨, ទំព័រ ៩០៧, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

សុជាតាជាតក : លោកអាចារ្យ មុញ ណាគ្រី ទ.ក ១១, ទំព័រ ៦៥៧, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

សុទ្ធិគាថា : ព្រះមហា មូល-អ៊ូ ទ.ក. ៦, ទំព័រ ៥៤៥, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុខក្ខត្តលិច្ចវិមុត្ត : យុវបណ្ណានុរក្ស ប៊ូ.ប៉ូ ទ.ក. ១១, ទំព័រ ៨១១, ឆ្នាំ ១៩៤៥ (ម.៥២/២៥) ។

ស៊ុនយ៉ាតសេន អ្នកនយោបាយឯកជាតិចិន : លោក
ប៉ាយ ប៊ុក ទ.ក. ១, ទំព័រ ៣៨, ឆ្នាំ ១៩៤៨, (ម.៥២/២០) ។

សុន្ទរកថា : រដ្ឋលេខាធិការក្រសួងធម្មការ ទ.ក. ៩, ទំព័រ ១០៦១
ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សុន្ទរកថា និង សារលិខិត : លោក ប៉ាយ-ប៊ុក ទ.ក. ៧,
ទំព័រ ៦៦៣, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុន្ទរកថាអំពីដង្ហែព្រះសារីរិកធាតុនៅខេត្តសៀមរាប:
លោក សុខ-សាវឿន ទ.ក. ៥, ទំព័រ ៤៦៧, ឆ្នាំ ១៩៤៦
(ម.៥២/៣៦) ។

សុភានឡ្បាយ : ទ.ក. ៤ ៥ ៦, ទំព័រ ២៥៩, ឆ្នាំ ១៩៣៨,
(ម.៥២/១០) ។

សុភាសិត : លោក ប៉ាយ ប៊ុក ស៊ីរ និង លីបង់ ទ.ក. ១, ទំព័រ ៦៦,
ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។ យួន-ចិន ទ.ក. ៤, ទំព័រ
៤៤៧, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

សុភាសិត (កាព្យ) : ព្រះគ្រូសុខុវិទូ ពាន-សុខ ទ.ក. ៧, ទំព័រ
៣៣៩, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

សុភាសិតច្បាប់ស្រី : ឧកញ៉ាសុគន្ធប្រីជាឥន្ទ ទ.ក. ៤–៥–៦,
ទំព័រ ៤៦, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

សុភាសិត ជាតិប៉ុល និង ទូត្តលៀរ : លោក ក៉យ-ប៊ុក ទ.ក. ១, ទំព័រ ៦៥, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

សុភាសិតចាកំងសែស : ទ.ក.៤, ទំព័រ ២៤៣, ឆ្នាំ ១៩៤៨ (ម.៥២/២០) ។

សុភាសិតបាលី (ប្រែកាព្យ) : ព្រះគ្រូសុវណ្ណវិទូ ពាង-សុខ ទ.ក. ៤, ទំព័រ ១៨២, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

សុភាសិតប្រកាបនិធាន : ទ.ក. ១-២-៣, ទំព័រ ១៥៣, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

សុភាសិតប្រដៅជនប្រុសស្រី : ព្រះឃោសធម្ម ម៉ុង-សែស ទ.ក.១, ទំព័រ ៥០, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុភាសិតប្រឆិតរឿង : ព្រះមហា អ៊ុម-សុខ ទ.ក. ១,២ ទំព័រ ៩១១, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

សុភាសិតភាគទី ១ : លោក ក៉យ-ប៊ុក ទ.ក. ៣, ទំព័រ ១៨១, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។ ភាគទី ២ ទ.ក. ៧, ទំព័រ ៤៩៧, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

សុភាសិតនិង ធារកោភាន : មហា សៅ-ល័រ ទ.ក. ៨, ទំព័រ ៤៣០, ឆ្នាំ ១៩៤៧ (ម.៥២/១៩) ។

សុភាសិតកាជធីតិ (កាព្យ) : អ្នកឧកញ៉ា នៅ ទ.ក. ២,
ទំព័រ ១៤៧, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

សុភាសិតណារ៍ : លោក ក៉យ-ប៊ុក ទ.ក. ១១, ទំព័រ ៩៨៣,
ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សុភាសិតវាចាកថា : ព្រះគ្រូញាណសំវរ ញាណ-ឈឹន ទ.ក.
១-២-៣, ទំព័រ ៨៣, ឆ្នាំ ១៩៣៨ (ម.៥២/១០) ។
ទ.ក. ១-២-៣, ទំព័រ ១៣១, ឆ្នាំ ១៩៣៨ (ម.៥២/១១) ។

សុភាសិតសារៈដ៏ប៉ៃឬ : លោក ក៉យ-ប៊ុក ទ.ក. ៦, ទំព័រ
៥៦០, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

សុភាសិតបាណ្ណ : លោក ក៉យ-ប៊ុក ទ.ក. ១២, ទំព័រ ១១១៨,
ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

សុភាសិតអង់គ្លេស : លោក ក៉យ-ប៊ុក ទ.ក. ២, ទំព័រ ៨១,
ឆ្នាំ ១៩៥០ (ម.៥២/២២) ។

សុភាសិតអាកប់ : លោក ក៉យ-ប៊ុក ទ.ក. ៩, ទំព័រ ៨២៣;
ឆ្នាំ ១៩៥៧ (ម.៥២/៣០) ។

(នៅមានត)

# ចិត្តមិនព្រមចាស់

និយាយពីចិត្តមិនព្រមចាស់ ចិត្តនេះខូចណាស់ក្រាស់មុខរឹង
សម្ដែងឫកពួនក្នុងខ្លួនហ្មង យកជាទីពឹងអាស្រ័យនៅ ។
ខ្លួនធ្លាក់ក្នុងភ័យវ័យជរា ស្រុះស្រោមគ្រាំគ្រាយ៉ាប់យ៉ឺនទៅ
សាច់ស្បែកជ្រួញជ្រីអ៊ីវជាតិចៅ ភ្នែករូងខូងជ្រៅដូចរន្ធឡ្យ ។
ធ្មេញបាក់សក់ស្កូវថ្ងូរអើទៀត តែចិត្តមានស្នៀតខ្ទៀតកក្កូរ
នៅខ្ទៀតកកាយស្ដាយបាយចូ ចង់ណាស់បោះឡូដូចក្មេងក្មាង ។
ខ្ញុំមិននិយាយតាមចិត្តស្រី មិនកើតទេវីអស់ទីអាង
តែស្រីៗ ទឹងប្ដឹងតឹងតាង អីរ៉ាន់ទេងខាងចាក់សោគ្រឹប ។
និយាយតែចិត្តប្រុសគ្នាយើង មិនសូវនាំគ្នើងដើងដើរឡើប
កិច្ចការជ្រៅពក់ណាក់លបឡឹប ឡូកលេងកេងកិបគ្នាយើងស្រាប់ ។
ធម្មតាចិត្តប្រុសមានខុសគ្នា មានខូចមានជាក្រៅក្នុងច្បាប់
ប៉ុន្តែរឿង "ចាស់" ចិត្តមិនស្ដាប់ លុះតែរូបស្លាប់ទើបអស់ផ្លូវ ។
សមស្រុកសព្វថ្ងៃខ្នៃយ៉ាងណា ផុនតាមប្រាថ្នារឿងសក់ស្កូវ
មានថ្នាំក្រូមើរកែតម្រូវ លាបលនលុបផ្លូវខ្មៅរលោង ។
ឲ្យខ្មៅរលង់គង់ភាពដើម ប្រេងផ្សើមប្រោះផ្សំខ្ញំយីតយោង
ពោះធ្មេញបាក់ទៀតធ្មៀតលៃឈោង មានគ្រឿងផ្សែងជ្រោងគ្រប់សណ្ឋាន ។
ឧបករណ៍ជំនួយជួយវ័យចាស់ មានច្រើនម៉ាកណាស់ផ្លាស់ប្ដូរបាន

សម្រាប់គុបតែងលំអប្រាណ ឲ្យតែលុយមានគ្មានក្រអ៊ី ។
តែទុកជាចិត្តឥតគ្រឿងអាង តាំងប៉ុន្មានយ៉ាងដូចពោលស្តី
ក៏ចិត្តប្រុសឃើញក្នុងលោកិយ ឥតបីព្រមបាស់ក្រឡាស់ប្រែ ។
មានតាខ្ញុំម្នាក់ធ្លាក់វ័យចាស់ ចិតសិបប្លាយច្បាស់ក៏ប៉ុន្តែ
ក្មេង ៗ ហៅតាដេរដល់ម៉ែ ចូនពឹតហូរហៃតាមតែថា ។
អាចោរខ្មោចក្មេងលេងមើលងាយ តើអញយកយាយឯងកាលណា
ក៏មកហៅអញថា តា.តា អាចោរមោហាប្រយ័ត្នក្មេង ។
ពាក្យសល់ឯទៀតមិនធ្មៀតហៅ ម៉េចនាំកំដៅអាតែហោង
អាចោរតែហឹតក្រអឹតកោង ក្រោយ ៗ ឯងគោងជីងឲ្យច្បាស់ ។
តាខ្ញុំគាត់វិលវៀងមួយទៀត គាត់ខំប្រឹងធ្មៀតតែងខ្លួនណាស់
ចូលចិត្តតែលេងល្បែងផ្តាំចាស់ បរផ្កាស់គិតតែលៃវៀងហ៊ង ។
មានស្រីខូចវិលគឹលគ្រង់ណា ពោះនៅចីផ្សារប្តូក្រៅក្រុង
គាត់ញៀនញឹកញាប់ជាប់ចិត្តស្លុង វិលក្បែងផុងខ្លួនពួនគ្រង់នោះ ។
ស្រីវិលឃើញតាពីចម្ងាយ ស្រស់ស្រាយពក់ពាក់ហាក់ចិត្តស្មោះ
ហ៊ឺះទុះមកហើយបងកំឡោះ ខ្ញុំអរដូចពោះបានជួបបង ។
នាំគ្នាស្ទុះចុះទៅទទួល បបួលគ្នីគ្នាគ្រាហ៍អែបអង
អួសដាក់លើតូកលូកកេះខ្នង ផ្អៀងផ្អង់ផ្ដេកផ្ដិតកិតកៀកកាយ ។
ខ្ទះគក់ប្រហាច់កាច់ដើងដៃ ខ្ទះបាច់សរសៃស្អាបនាយអាយ

បញ្ចោរបញ្ចេចសើចក្អាកក្អាយ    តាខ្ញុំសប្បាយព្រឺបេះដូង ៗ
យកអីយកទៅពៅបងអើយ    ដល់ថ្នាក់ហ្នឹងហើយតាយល់សួង
យល់សប្តយើញគាត់ធ្លាក់អណ្តូង    ជ្រោះជ្រៅស្រឡូនខ្វូងក្អែកស៊ឹង ៗ
មិនមែនតែតាខ្ញុំមួយទេ    ទោះទាំងតាគេរឿងត្រង់ហ្នឹង
យាយដេរម្តេចក៏មិនខ្វីទឹង    តាប្រឹងលែងព្រួយពួយអស់ដៃ ៗ
គាត់ថាដូចជារបស់ទ្រព្យ    កាលណាគាត់ឆាប់ជីវិតក្ស័យ
កូនចៅផ្ទង់ឲ្យដោយច្រើនក្រៃ    ចង្រៃរឿងហ្នឹងផ្ទង់មិនបាន ៗ
ដូច្នេះទើបតាគាត់ខំប្រឹង    បំពេញកិច្ចហ្នឹងកុំឲ្យខាន
ទោះអស់សោហ៊ុយលុយប៉ុន្មាន    ប្រថុយប្រថានប្រាណផ្ដាំចាស់ ៗ
ចួនកាលតាខ្ញុំចួបមិត្តភក្តិ    បើគេកក់តាក់គាត់ដោរណាស់
ពួកពាក្យថា «ឃើ! ម្តេចក្រចាស់?    ដូចជាអត់ផ្លាស់នៅដដែល ៗ
ខានបានចួបគ្នាប៉ុន្មានឆ្នាំ    សាច់នេះហៅចាំអាយុក្រែល
តែដូចកំឡោះស្ទោះដដែល    រកមនុស្សប្រហែលពីនេះក្រ» ៗ
ពាក្យគេបញ្ចោរលើកបញ្ចេច    តាខ្ញុំគាត់សើចមាត់ប្រហ
ញញឹមបីថ្ងៃជាប់បន្ត    អរអើយសែនអរនេះតាខ្ញុំ ៗ
ឲ្យតែអ្នកណាចេះបញ្ចោរ    គុយទាវពោះគោចាយលុយជុំ
បើទៅទីណាមានក្រមុំ    ញ៉េះញ៉ោះចេះសុំតាឲ្យម៉ត់ ៗ
ការមីធាស្រោបដ្ឋម    ទៅពីតតែក្លែមតាស៊ូអត់

យាយនៅឯផ្ទះធ្វើការហត់ តាខ្ញុំគាត់ក្បត់អត់បានឆ្ងាញ់ ។
កាលយាយខ្ញុំដឹងខឹងប្រឡោត "កញ្ជាស់នៅនោតឯងក្បត់អញ
ឃើញមុខកាលណាផ្សាក្តៅក្តាញ់ ឲ្យគេបំពញ់ចាញ់បោកគេ ។
ចាស់ឡើងព្រើលឡើងដូចឆៃយ៉ុំ ក្មេងនេះបានផ្តាំចាំឬទេ ?
មរណៈចូលជិតតែខ្ចប់ខ្វេ ចាស់ចើកខុសគេចាស់បំភ្លត់" ។
តាខ្ញុំខំអត់អំណត់ដែរ ប៉ុន្តែយាយខ្ញុំផ្តុំរឿងត្រួត
តាទឹកខឹងខ្ទាំងតាំងប្រកួត "មេពោរក្រកួតអួតពូកែ ។
ឃើញអញស្ងៀមឈឹងរឹងរឹតណាស់ ខ្មោចមេកញ្ជាស់មិនមែនម៉ែ
គិចអត់មិនបានចាននៅក្បែរ បោកក្បាលបែកបែរចេញឈាមភ័រ" ។
យាយខឹងឆ្លួលចេះស្ទើរប្រញាប់ ស្ទុះក្តួតលេងផ្ទាប់ចាប់កអាវ
កញ្ជាក់បោកក្តោបឧបក្រសាវ តារើចំប្រាវលោតឡើងឆាក់ ។
យាយគេចរួចខ្លួនពួនក្បែរពាង តាដួលចង្ក្រានភាំងដូចយក្ស
ស្មារតីយាយរឹងប្រឹងឥតពាក់ យាយស្ទុះក្តួតពាក់ដៈលើតា ។
តារើខ្វៃ-ខ្វៃដៃប្រឡេះ យាយប្រឹងកកេះខ្ទេះក្តិចខ្វារ
តាដួលក្រឡាប់វិលផ្ងាប់ផ្ងារ យាយសាក្រឡប់គប់តាម៉ាំង ។
តារើខ្លួនរួចក្ពួចប្អូនដៃ "ខ្មោចមេចង្រៃចេះចោរខ្លាំង"
តាក្តួតទៅទៀតធ្វៀតតតាំង យាយយឺតប្រឆាំងកាំងទទួល ។
តាចាប់យាយបានប្រានត្រឡត់ ហើយស្ទុះទៅទាត់ក្តាត់ដើងដួល

យាយមានទំនងវង់យ៉ាងស្រួល ដែលអៀវចាប់មួលពងតាដាប់ ។
តាខ្ញុំខំស្រែកភ្ញកស្ដោស្ដឹង កុំលេងធមិតឹងមេត្រូវគ្រាប់
ឮយ៉ះប៉ះបំកន្ទេងឆាប់ ហាងធ្លាប់ដឹងទេមេចង្រៃ ។
លែងអញឲ្យចាប់ប្រញាប់ក្លាម តិចអញពួយផ្គាមហាងមួយដៃ
យាយថាកុំបាច់គិតសង្ស័យ បានដៃប៉ុណ្ណេះកេះមិនបាន ។
អញមួលប្រពាច់ផ្ដាច់អាយ៉ូស ឲ្យផុតខ្យល់ស្រូសប្រូសបែកហាន
ឲ្យអស់ពុតខូចដូចតិរច្ឆាន ម៉េចនៅក្លាហានយ៉ាងណាទៀត ?
តាវើយាយតែមឹតមួលខ្វាំង តាឈប់តតាំងច្បាំងអស់ស្មៀត
រិះ ៗ ដាច់ខ្យល់ខ្វល់ចង្អៀត បែរបៀតសុំចុះចំណុះយាយ ។
រឿងយើងប្រុស ៗ ឈ្មោះទីងស្រី មិនស្រួលទេវ៉ីកុំមើលងាយ
ប្រយ័ត្នប្រយែងស្មែងមួយឆ្ងាយ កុំទុកពត់កយយាយលេងម៉ត់ ។
ដំណាលពីចិត្តមិនព្រមចាស់ កាវេងធ្លាយណាស់សរសេរហត់
បែកដល់រឿងតាសង្ហាក្បត់ យាយអៀវសង្កត់តាវិះឆាប់ ។
ខ្ញុំសូមសន្មតកំណត់ស្ទុះ បញ្ចប់ត្រឹមណេះឈប់រៀបកប់
ចាំមានដំណើរប្រសើរគាប់ ទីងលែងគ្លាប់រឿងទៅទៀត ! ។

ញ៉ូច-សឿម

# ជីវប្រវត្តិរបស់ខ្ញុំ

## ឈ្មោះ អៀង-សាយ

(ត)

ដោយឃើញសេចក្ដីកន្សំបុត្រដូចនេះ ទើបចៅហ្វាយនាយខ្ញុំញញឹម ខ្ញុំក៏ខានញញឹមមិនបាន ដោយលោកដឹងថាខ្ញុំមិនសូវចេះបារាំង ដោយនិយាយបារាំងជាមួយលោកមិនច្បាស់ ម្ដេចក៏គេថា ខ្ញុំចេះអាចកែចាប់ខុសត្រូវបាន ។

ខ្ញុំក៏នឹកហួសចិត្ត ដោយយល់ថា លោកអ្នកដែលបកប្រែសៀវភៅនោះ យ៉ាងអន់ណាស់ក៏ថ្នាក់ឌិប្លូមដែរ ឯខ្លួនខ្ញុំមិនដែលមានឈ្មោះនៅក្នុងថ្នាក់កុមារដ្ឋាននៅសាលាណាសោះ មិនគួរមានកិត្តិយសដល់ទៅជាអ្នកចាប់ខុសគេបានទេ តែដោយចង់បង្អាក់ ចៅហ្វាយនាយខ្ញុំក៏ឲ្យលោកញញឹមទៀត ខ្ញុំទទួលយកសៀវភៅទាំងពីរទៅ និងជំរាបលោកថា ចាំខ្ញុំយកទៅមើល ក្រែងមានខុសត្រង់ណា ។

ក្រោយពីនោះ ៤ ថ្ងៃមក ខ្ញុំយកសៀវភៅបារាំងនិងសៀវភៅខ្មែរ មានក្រដាសគៀតភ្ជាប់គ្នាបួនដប់សន្លឹករបស់ខ្ញុំយកមកជាមួយផង ខ្ញុំបង្ហាញចៅហ្វាយនាយខ្ញុំបានទាំងអានអក្សរខ្មែរ ប្រែជាបារាំង ឲ្យលោកស្ដាប់ផងថា : អៀង-សាយ ខ្ញុំបានមើលពិនិត្យសៀវភៅដែលប្រែពីភាសាបារាំងមកជាខ្មែរនោះ ឃើញល្អមយកជាការបានហើយ តែ

មនុស្សពីរនាក់មិនដែលយល់ស្របគ្នាទាំងអស់ទេ បើគេឲ្យខ្ញុំបកប្រែមានយល់ផ្សេងពីគ្នាដោយអន្លើខ្លះ ដូចខ្ញុំបានសរសេរនៅលើក្រដាស ជូនដប់ សន្ទឹកនេះ ខ្ញុំកត់លេខទំព័រនិងចំនួនបន្ទាត់ពីលើទៅដល់ត្រង់សេចក្តីនោះ ហើយខ្ញុំចម្លងសេចក្តីអក្សរបារាំងដាក់ម្ខាង ខ្ញុំសរសេរបកប្រែជាខ្មែរម្ខាង តាមខ្ញុំយល់ផ្សេងពីលោកអ្នកបកមុន មានតែប៉ុន្មានអន្លើនេះ ។

ទៅហ្វាយនាយខ្ញុំបើកមើលក្រដាសដែលខ្ញុំសរសេរជូនដប់សន្ទឹករួចហៅស្មៀនមកប្រើឲ្យចាត់ការបញ្ជូនត្រឡប់ទៅវិញ ។

ខ្ញុំមិនមែនបង្រៀនតែសិស្សនៅសាលាឧស្សាហកម្ម, វិទ្យាល័យ-ស៊ីសុវត្ថិ, សាលាគរុវិជ្ជា ប៉ុណ្ណោះទេ ខ្ញុំមានទៅបង្រៀនសិស្សនៅអនុ-វិទ្យាល័យនារី ដែលជាអនុវិទ្យាល័យនរោត្តមសត្វថ្ងៃនេះផងទៀត ដោយគេគិតថ្លៃពេលម៉ោងខាងណោះខាងណោះ ឲ្យល្មមខ្ញុំទៅមកបង្រៀន ១ ម៉ោងក្ដី ១ ជាក់ត្រង់ជាក់ទាំងអស់ ។

បានជាខ្ញុំរត់ទៅណោះទៅណោះខ្វែងជើងយ៉ាងនេះ មកពីគ្មានគ្រូឯទៀតក្រៅពីខ្ញុំ សូមជ្រាបថា តាមកម្មវិធីដែលគេតម្រូវ ឲ្យបង្រៀនសិស្សនៅមធ្យមសិក្សា មានគំនូរទេសនាការ (ដេស្សាំង អាវ៉ុយ) គំនូរវេចនា ( ដេស្សាំងឌ៉ីដេគ័រ៉ាស៊ីយ៉ុង ) គំនូរធរណីមាណសាស្ត្រ ( ដេស្សាំងសឺអូមេទ្រិក ) និងគំនូរសិប្បយការ ( ដេស្សាំងអាំងឌុស-ទ្រីយ៉ែល ) ទាំង ៤ មុខនេះ ។

ពួកសិស្សដែលមានឌីប្លូមចេញពីសាលារចនាមក ចេះតែគំនូរពីរមុខខាងដើម មិនចេះគំនូរពីរមុខទៀត ទៅធ្វើជាគ្រូបង្រៀនមិនបាន ។

បើឲ្យសិស្សដែលមានសញ្ញាបត្រចេញពីសាលាបច្ចេកទេសមកធ្វើគ្រូ ចេះតែពីគំនូរពីរមុខខាងចុង គំនូរពីរមុខខាងដើមមិនចេះបង្រៀនវាមិនកើតទៀត ទើបបានជាខ្ញុំធ្វើការដល់កំណត់ឆ្នាំ ដល់អាយុគេមិនទាន់ឲ្យនិវត្ត ទៅធ្វើការហួសកំណត់ឆ្នាំនោះមក ៧ ឆ្នាំទៀត ទើបបានឈប់ ឈប់ហើយ ទៅសាលារចនាដែលឡើងជាមហាវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ខ្វះគ្រូដែលចេះគំនូរធរណីមាណសាស្ត្រ គេដឹងថាខ្ញុំចេះ គេហៅឲ្យទៅបង្រៀន ឲ្យឈ្នួលគិតតាមម៉ោងទៅទៀត ។

ខ្ញុំសរសេរភ្លេចមុខភ្លេចក្រោយ ដោយមិនបានព្រាង នឹកឃើញត្រង់ណាសរសេរត្រង់ហ្នឹង ខ្ញុំត្រូវសរសេររឿង ១ ថែមឲ្យស៊ីសេចក្តីខាងដើម តែមិនមែនចង់ធ្វើឲ្យដូចពាក្យហោរឬពាក្យគ្រូទាយនោះទេ គឺខ្ញុំជ្រុលខ្លួនហួសទៅហើយ ទើបនឹកឃើញពាក្យហោរដែលទាយថា ខ្ញុំត្រូវមានប្រពន្ធដល់ទៅបីនោះជាក្រោយ គឺជាព្រហ្មលិខិតរបស់ខ្ញុំយ៉ាងនេះ ។

ខ្ញុំចាស់អាយុ ៥៨ ឆ្នាំទៅហើយ មានកូន ៤ ចៅ ១៧ នាក់ ខ្ញុំឃើញស្រីម្នាក់អាយុ ១៤ ឬ ១៥ ឆ្នាំ នៅស៊ីឈ្នួលបំរើគេ ដោយខ្ញុំធ្លាប់ខិលខូចនឹងស្រី តាំងពីក្មេងរៀងរាបមករតលះបង់ចោលល្បែងនេះមិនបាន តាំងល្បែងបរបាញ់សត្វក៏ខ្ញុំធ្លាប់លេង ដោយមានកាំភ្លើងបាញ់សត្វ

ដល់ទៅពីរដើម មានច្បាប់អនុញ្ញាតឲ្យកាន់ ខ្ញុំចៀសវាងបានតែល្បែង ស៊ីសង និងល្បែងស្រា អាភៀន កញ្ឆា ខ្ញុំមិនជាប់ចិត្តសោះ តែត្រង់ល្បែងស្រី ជាប់ចិត្តលង់លួចលាក់ជានិច្ច ដោយខ្ញុំសប្បាយណាស់ ទៅជាមានជម្ងឺ គិតកុំឲ្យឈឺ លុះតែរកស្រីស្អាតស្អំ ដល់មកឃើញក្មេងដែលនៅស៊ីឈ្នួលគេនេះមានភាពជាក្មេងល្អត្រឹមត្រូវហើយ នៅតូចផង ទើបនិយាយនឹងឪពុក ម្តាយឲ្យយកប្រាក់ខ្ញុំពីរពាន់រៀលទៅសងគេហើយ យកនាងនោះ ដែលជាកូនមកនៅជាមួយគាត់ឲ្យឈប់លែងទៅបម្រើគេ ។ ដោយគាត់ជាអ្នកទីទាល់ហើយមានកូន ៤ នាក់នៅក្នុងបន្ទុក ខ្វះស្បៀកពាក់ស៊ីចាយ ខ្ញុំជួយឲ្យប្រាក់ចាយ ជួយប្អូននាងនោះពីរនាក់ឲ្យមានសំ. បុត្រកំណើត បានចូលរៀនជាសិស្សសាលា ឪពុកម្តាយនាងនោះ. ឃើញខ្ញុំមានគុណលើកូនគាត់ នឹងលើខ្លួនគាត់ផង ក៏រៀបសែនមេបាឲ្យនាងនោះមកខ្ញុំ ។ ទៅដេកនៅ ១ ដង ១ កាល មិនបានទៅជាប់ជានិច្ចទេ ដោយខ្លាចអ្នកមេផ្ទះខ្ញុំនិងកូនខ្ញុំគេដឹង តែដល់នាងនោះមានផ្ទៃពោះ ខ្ញុំទៅជាទន់ទោរទៅមកញឹក លុះបានកូនស្រីមួយនឹងនាងនោះ ខ្ញុំប្រាប់ប្រពន្ធតាមត្រង់ ដោយមិនចង់មានរឿងតាស់តែងគ្នា រវាងកូនដើមនឹងកូនចុង ពីរឿងកេរ្តិ៍មរតក ខ្ញុំធ្វើសំបុត្រប្រគល់ផ្ទះថែកដីកាត់ឈ្មោះខ្ញុំ ឲ្យទៅឈ្មោះកូនស្រីម្នាក់ជាកូនដើម ។ ដល់មកពេលនេះ ខ្ញុំមានកូននឹងនាងក្រោយនេះដល់ទៅពីរបី ខ្ញុំរកដីសង់ផ្ទះបានមួយឲ្យនៅ

ខាងត្បូងផ្សារទួលទំពូង ដោយក្រែងអត់អំពីខ្ញុំទៅពិបាកវេទនា ទីងគ្នាច្រើនហើយគ្មានបេរគេទទួលទាន ខ្ញុំបង្រៀននាងនោះឲ្យចេះអក្សរ ឲ្យចេះធ្វើការជាងវេចនា ឥឡូវចេះធ្វើការលក់ដូរបានប្រាក់ចាយខ្លះហើយ ។

ខ្ញុំមិនមែនបានថ្មីហោលចាប់ទេ ខ្ញុំនៅជានិច្ចជាមួយអ្នកមេផ្ទះរបស់ខ្ញុំ ៗ គ្រាន់តែទៅមកផ្ទះក្រោយនេះ ១ ថ្ងៃ ២ ថ្ងៃម្ដង របស់ទ្រព្យ ប្រាក់ខែ ខ្ញុំមិនយកទៅទេខ្ញុំប្រគល់ឲ្យអ្នកមេផ្ទះខ្ញុំទាំងអស់ ខ្ញុំសុំយកទៅចាយខ្លះ ដែលគេព្រមល្មមឲ្យខ្ញុំ ៗ ធ្វើការរកប្រាក់ក្រៅបាន ខ្ញុំយកទៅឯណោះ ដូចជាបានមកអំពីលក់គំនូរ ឬលក់សិទ្ធិ ដែលបាននិពន្ធរឿងផ្សេង ៗ ។

ដល់មកនិយាយអំពីរឿងលក់សិទ្ធិ ខ្ញុំនឹកឃើញរឿងផ្ការីកផ្កាពោយដែលជាប់លេខ ក្នុងការប្រឡងបានរង្វាន់ ឃើញគេចុះផ្សាយក្នុងកាសែតកម្ពុជាបន្តិចម្ដង ៗ រហូតដល់ចប់ ហើយបណ្ណាគារគីម-សេង ទិញយកទៅបោះពុម្ពជាសៀវភៅលក់ ។

មានទស្សនាវដ្ដីបារាំងឈ្មោះ ហ្វ្រង់ អាស៊ី កំបានយករឿងនេះទៅចុះផ្សាយជាអក្សរបារាំងដែរ ។

ដល់មកពេលខាងក្រោយនេះ ក្រុមហ៊ុនភាពយន្តមានជ័យ បានទិញសិទ្ធិយករឿងផ្ការីកផ្កាពោយរបស់ខ្ញុំនេះថតជាខ្សែភាពយន្ត ។

ដល់និយាយពីរឿងភាពយន្ត ខ្ញុំបានចូលជាសមាជិកក្រុមហ៊ុនភាព-

យន្តនាពយន៍ ជាមួយលោក រឹម គិន, លោក ម៉ាំង-ម៉ូរ៉ា, លោក ហុក-ភ៉ែត ។ល។ ខ្ញុំបានទិញសៀវភៅច្បាប់ក្បួនថតភាពយន្ត ថតសម្លេងនិងផ្ទះបញ្ចាំង យកមករៀន ។ ខ្ញុំជាអ្នកផ្ញើទៅមកសួរគេទិញប្រដាប់ថតភាពយន្ត ថតសម្លេង និងប្រដាប់ផ្ទះបញ្ចាំង ។

ពេលដែលបានប្រដាប់ថតភាពយន្តមក លោក ហុក-ភ៉ែត គិតរកឲ្យគេមកបង្រៀនពន្យល់អំពីការប្រើប្រដាប់ទាំងអស់នោះ តែខ្ញុំមិនព្រម ដោយអួតអាងថាខ្ញុំចេះ ខ្ញុំទៅរកខ្សែហ្វីលដែលគេថតខូចគេចោលបាន ១ ដុំមក រកមើលរបៀបបើកប្រដាប់ថត ដាក់ខ្សែហ្វីលបានហើយ ខ្ញុំតួនទៅកន្ទុំបន្ទប់បិទទ្វារឲ្យស្ងាត់ ខ្ញុំរកបើកបិទគិតធ្វើជាថត ត្រូវមួលមើលតាមណា បើចង់បានរូបតូចរូបធំ ឆ្ងាយជិតឲ្យច្បាស់ តើធ្វើយ៉ាងម៉េច ឃើញថាត្រូវផ្លាស់ប្តូរកែវយឺតគិតតាមលេខតូច-ធំ រួចរកពីបើកបិទឲ្យល្មិត-ភ្លឺ ។ ខ្ញុំតួនមើលពិនិត្យគិតដល់យល់ការទាំងអស់ បើបានហ្វីលថ្មី ១ ដុំមក ខ្ញុំថតបានភ្លាម ទើបខ្ញុំទៅជួបនឹងលោក ហុក-ភ៉ែត ពន្យល់អំពីរបៀបប្រើប្រាស់ថតនោះទៅ លោកជឿទុកចិត្តតាមខ្ញុំអាចថតបាន ទើបបណ្តោយឲ្យខ្ញុំចាត់ការថតខ្សែកុន ១ ខ្សែ ។ ខ្ញុំយក រឿងការសង់សឹក ពីលោក រិម-គិន មកគិតបែងចែងរឿងនោះជាភាគ ១ សង្កាត់ ។ ដែលគេហៅថា ដេគុបប៉ាស ។

រៀបរឿងរួចហើយ ខ្ញុំហៅគេបង់ប្អូនក្មួយនិងញាតិមិត្តជិតខាងខ្ញុំ

មក នាំគ្នាហាត់លេងតាមរឿង ៗ បានធ្វើប្រដាប់ដាវ-ខែល-ធ្នូ-ស្នា-លំពែង និងសំលៀកបំពាក់ មិនចង់ឲ្យបង់ខាតអស់ប្រាក់ច្រើនទៅលើសំលៀកបំពាក់តាមរឿងជាន់ដើម ខ្ញុំយកសំលៀកបំពាក់ធម្មតាមក រកក្រដាសពណ៌ក្រដាសមាស កាត់បិទបាយម៉ាន ធ្វើឲ្យបានល្អសមរម្យ រួចខ្ញុំចាត់ការថតផ្ទាល់ខ្លួនខ្ញុំ ពីដើមរហូតដល់ចប់ ៗ ថតបណ្ដើរផ្ញើទៅឲ្យគេលាងឯស្រុកបារាំងបណ្ដើរ ដោយខ្សែកុនពណ៌លាងនៅស្រុកយើងមិនទាន់បាន ដល់បានមកខ្ញុំសរសេរអក្សរចំណងជើងថតកាត់បិទតភ្ជាប់គ្នាកើតបានជាខ្សែកុន ១ យ៉ាងវែង ល្មមចុះបញ្ចាំងឲ្យគេមើលយកប្រាក់បាន ៗ

ដោយចង់បង្អួតគេឲ្យឃើញថា ខ្ញុំចេះល្បិចថតភាពយន្ត ខ្ញុំថតខ្សែកុនមិតប្រាយ ១ ខ្សែខ្លី នាំឲ្យគេឆ្ងល់នឹងពពុះទឹកអណ្ដែតចេញពីកែវដែលមានទឹកពណ៌ស, ខៀវ, ក្រហម ទៅតម្រៀបជាអក្សរហើយក្លាយទៅជាទង់ជាតិ ៗ គេឆ្ងល់នឹងផ្កាយរេដំរៀបគ្នាជាអក្សរហើយឃើញព្រះច័ន្ទពេញវង់ ថែមទាំងឃើញព្រះភក្ត្រព្រះករុណា នៅក្នុងព្រះចន្ទនោះ ៗ មានមេអំបៅហើរដំរៀបគ្នាជាអក្សរ និងមានរូបគំនូរចេះដើរ គឺរូបរឿងអាចាក់ស្លុក ១ ចប់ ៗ

ខ្សែភាពយន្តវែង ១ ខ្សែខ្លី ១ ខ្សែនេះបានចុះបញ្ចាំងឲ្យគេមើលរោងកុនជិតវាលមេរុ មានសម្ដេចដែលខ្ញុំថតបញ្ចេញមុខក្នុងពេលចុះបញ្ចាំងនោះផង ៗ

ក្នុងវេង ១ អាទិត្យ បានប្រាក់ចំណូល ៩០ ពាន់ ។

ដោយជិតអស់ក្រដាសនៅសៀវភៅនេះ ខ្ញុំមិនអាចសរសេរឲ្យពិស្តារបាន សូមសរសេរខ្លី ៗ ត្រង់នេះបន្តិច ត្រង់នោះបន្តិច តាមដែលនឹកឃើញ ។

ខ្ញុំមានបានរួមគំនិតជាមួយឈ្មោះ អៀង សឿង ប្អូនខ្ញុំ ចេញទស្សនាវដ្តីមួយឲ្យឈ្មោះថា ទស្សនាវដ្តីកំសាន្តចិត្ត ។ ប្អូនខ្ញុំនិពន្ធរឿងព្រេងជារឿងកំប្លែងខ្លី ៗ ចំណែកខ្ញុំ ៗ និពន្ធរឿងកំប្លែងសម័យថ្មីខ្លី ៗ ជាង ៣០ រឿង និងរឿងបញ្ហាព្រមទាំងរូបចំណោទឯទៀត ។ ចេញក្នុង ១ ខែ ១ លេខ ចេញបាន ១២ លេខឈប់ ។

ដល់មកសម្តេចព្រះបិតាអក្សរសាស្ត្រទ្រង់បានបង្កើតសារពត៌មានអ្នកជាតិនិយម ក្រុមជំនុំបានពាក់ឈ្មោះខ្ញុំចូលជាអ្នកនិពន្ធអ្នកជាតិនិយម ដោយឃើញមានបញ្ជីរាយនាមខ្ញុំ និងនាមអស់លោកធំ ៗ ដើមកខ្ញុំហើយ យករូបថតខ្ញុំទៅធ្វើពុម្ព ១ និងយក ១ ទៀតទៅបិទធ្វើជាកាត ឲ្យខ្ញុំកាន់ចេញចូលទៅក្នុងព្រះរាជដំណាក់សម្តេចព្រះប្រមុខរដ្ឋនៅចំការមន ខ្ញុំបានជួយគូររូបអប់រំដាក់ចំណងជើងជាពាក្យកាព្យចុះក្នុងសារពត៌មាន អ្នកជាតិ-និយមហូរហែមក ។ បានទទួលប្រោសព្រះរាជទានការជប់លៀងនៅក្នុងព្រះបរមរាជវាំង និងបានទទួលព្រះរាជទានគ្រឿងឥស្សរិយយសមេ-ដាយអស្សរិទ្ធិសុវត្ថាភ ដោយការនិពន្ធនេះ ។

អំពីការដែលមានឈ្មោះជួយមើលការប្រឡង រៀងរាល់ឆ្នាំដែលប្រឡងចេញ ប្រឡងចូល មានឈ្មោះគ្រូជួយមើល ។ ឯវិញ្ញាសាការប្រឡងគំនូរ ខ្ញុំជាអ្នកជ្រើសរើសគេជូនទៅលោកប្រធាននៃការប្រឡងដល់បេក្ខជនគូរហើយ គ្រូខ្ញុំជាអ្នកមើលឲ្យពិន្ទុ ។

ឯកម្មវិធីដែលបង្រៀនគំនូរនៅមធ្យមសិក្សា គឺខ្ញុំជាអ្នករៀបចំ តាំងពីថ្នាក់ទី ៦ ដល់ថ្នាក់ទី ៣ ។ ឯថ្នាក់ទី ២ និងទី ១ រៀបចំដោយគណៈកម្មការសាស្ត្រាចារ្យខាងគំនូរ ដែលមានឈ្មោះខ្ញុំជាប្រធាន ប្រជុំគ្នារៀបចំនៅមន្ទីររដ្ឋមន្ត្រីក្រសួងអប់រំជាតិ ។

តាំងពីមានថ្នាក់បង្រៀនខាងវិជ្ជាជីវៈគ្រូបង្រៀនប្រុសស្រី នៅវិទ្យាស្ថានជាតិគរុកោសល្យមក ខ្ញុំជាអ្នកបង្ហាត់បង្រៀនខាងមុខគំនូរ ខ្ញុំយកកម្មវិធីបង្រៀនគំនូរ នៅសាលាបឋមសិក្សាមកបង្ហាញឲ្យសិស្សទាំងអស់មើល ដោយកម្មវិធីនោះជាអក្សរបារាំង ខ្ញុំក្រែងពួកអស់នោះមិនយល់សេចក្តីមកជាភាសាខ្មែរ សូម្បីខ្ញុំដឹងថាពួកសិស្សដែលប្រឡងជាប់បានចូលទៅរៀនហាត់ធ្វើគ្រូនោះខ្លះមានឌីប្លូម ខ្លះមានបាស្សក្តី គឺខ្ញុំនៅតែមិនទាន់ជឿថា អាចយកកម្មវិធីអក្សរបារាំងនោះទៅមើលហើយយល់អាចបង្រៀនទៅតាមកម្មវិធីនោះបាន ទើបខ្ញុំហៅរកអ្នកនាងណាដែលថាខ្លួនចេះអក្សរបារាំង អាចការានបានដឹងសេចក្តីឲ្យមកមើលកម្មវិធី ១ ឃ្លា ឬ

១ ភាគ រួចខ្ញុំសួរថាអ្នក នាងយល់សេចក្ដីនេះថា គេឲ្យយើងទៅបង្រៀន យ៉ាងម៉េចខ្លះ? តាមគោលការគេ ។ ឲ្យយើងធ្វើម្ដេចខ្លះ ឲ្យត្រូវតាមវិធីនោះ ។ មានខ្លះថាគ្រាន់តែយល់មិនចេះនិយាយ មានខ្លះចេះនិយាយដែរ តែនិយាយមិនត្រូវតាមគោលការ ដោយមានប្រឡំខ្លះ ។ មិនចេះពាក្យបច្ចេកទេស ម៉្លោះហើយខ្ញុំមិនព្រមឲ្យគ្រូ ខ្ញុំដណ្ដើមមើល ១ ឃ្លា ឬ ១ ភាគ ខ្ញុំនិយាយបកប្រែតាមសេចក្ដី តាមគោលការហើយថែមពាំងគួរពន្យល់ទៅក្ដារខៀនទៀត ។

ដោយខ្ញុំបង្ហាញឲ្យពួកសិស្សឃើញអំពីការចេះដឹងយល់ការរបស់ខ្ញុំជាងខ្លួនគេ ។ ក៏នាំគ្នាចង់ដឹងថាខ្ញុំ រៀនបារាំងដល់ទៅថ្នាក់ណាទៅ បានជាចេះដឹងបកប្រែ " ខេមតិចនិក ,, ពាក្យបច្ចេកទេសជ្រៅជ្រះម៉្លេះ ។ ខ្ញុំថា ខ្ញុំមិនដែលមានឈ្មោះជាសិស្សរៀនអក្សរបារាំងនៅគ្រូអង់ហ្វង់តាំងសាលាណាសោះផង ។ និយាយតាមត្រង់ដូច្នេះ គ្មានអ្នកណាជឿសោះ ។

ខ្ញុំសរសេររឿងត្រង់នេះមិនមែនខ្ញុំអួតទេ គឺខ្ញុំចង់បំភ្លឺគេឲ្យយល់ថា ចំណេះរបស់ខ្ញុំមិនមែនកើតឡើងដោយបានរៀននៅថ្នាក់នេះថ្នាក់នោះ ឬដោយមានសញ្ញាប័ត្រនេះ សញ្ញាបត្រនោះទេ គឺសំខាន់ត្រង់ការព្យាយាមដូចមានខ្លួនខ្ញុំជាគួយ៉ាង ។

(នៅមានត)

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## ពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ

ឆ្នាំនេះ ក៏ដូចឆ្នាំមុនៗដែរ រាជរដ្ឋាភិបាល បានរៀបចំ ធ្វើពិធីបុណ្យនមស្ការព្រះសក្យមុនីចេតិយ យ៉ាងឱឡារិក នៅក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

ពិធីនេះ បានចាត់ចែងឡើងជាពីរលើក គឺពេលល្ងាចថ្ងៃ ១៥ កើត ខែពិសាខ គឺថ្ងៃទី ២៣ មេសា ១៩៦៧ ប្រារព្ធធ្វើពិធីនមស្ការព្រះចេតិយដែលមានតម្កល់ព្រះបរមសារីរិកធាតុនៃព្រះសម្ពុទ្ធបរមគ្រូ ដែលតាំងនៅមុខស្ថានីយរាជអយស្ម័យយាន នាក្រុងភ្នំពេញ ។ សម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ក្រោយដែលបានទទួលគារវកិច្ចអំពីសំណាក់ឥស្សរជនគ្រប់ដំណែងនៃព្រះរាជាណាចក្រ ដែលមកជួបជុំក្នុងព្រះពន្លា ហើយ ព្រះអង្គទ្រង់គោរពព្រះសង្ឃ ៥០ អង្គ ដែលមាន សម្តេចព្រះសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះពោធិវង្ស ជាអាទិ៍ ។ បន្ទាប់មកក៏មានប្រារព្ធពិធីគោរពទង់ជាតិ ទង់សាសនា ដោយមានចម្រៀងបទនគររាជ និងបទសរភញ្ញ អង់ផង ។ សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា ក្នុងនាមរាជរដ្ឋា-

ភិបាល សំដែងសេចក្ដីគោរពចំពោះព្រះសក្យមុនីចេតិយ ដែលបន្តមកសម្ដេចព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ថ្លែងតបវិញនូវព្រះសង្កថា យ៉ាងក្បោះក្បាយ មានន័យទូលំទូលាយក្រៃលែង ដែលពុទ្ធបរិស័ទ និងបណ្ដាជនទាំងអស់បានស្ដាប់តាមវិទ្យុជាតិ ដែលបានផ្សាយជាច្រើនលើកមកហើយ គួរឲ្យជាប់ចិត្តពន់ពេកណាស់ ។

ចប់ព្រះសង្កថាហើយ សម្ដេចព្រះបិតាជាតិ ទ្រង់បានយាងមួយអន្ទើងនឹងនាម៉ឺនសព្វមុខមន្ត្រី តាមដង្ហែព្រះអង្គផង យាងប្រទក្សិណនិងធ្វើសក្ការបូជាចំពោះព្រះសក្យមុនីចេតិយ ។ តមកព្រះសង្ឃ ៨០ អង្គក៏ចំរើនពុទ្ធជយមង្គលគាថា លាន់ឮគឹកកងផង ។

លុះព្រឹកឡើងថ្ងៃ ១ រោច ត្រូវនឹងថ្ងៃទី ២៤ មេសា ១៩៦៧ មានរៀបពិធីដាក់បាត្រព្រះសង្ឃ ៨០ អង្គ ជាផ្លូវការ នៅក្រោមព្រះរាជាធិបតីភាពនៃសម្ដេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលតមកមានពិធីទំលាក់ទង់ជាតិ ទង់សាសនា និងមានពិធីដាក់បាត្រព្រះសង្ឃ ១.៥០០ អង្គដោយឡែកទៀត ដែលពុទ្ធិកសមាគមបានរៀបចំឡើង ព្រមទាំងមានពុទ្ធបរិស័ទច្រើនកុះករមកចូលរួមផង ។

# សុន្ទរកថា

សហជីវិន **គុយ-ពៅ** អនុរដ្ឋលេខាធិការ

ក្រសួងធម្មការ និង សាសនសិក្សាធិការ

ថ្លែងក្នុងឱកាសបុណ្យនមស្ការព្រះសក្យមុនីចេតិយ

សូមព្រះតេជៈតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ

នៃសម្តេច សហជីវិន ព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ថ្ងៃនេះ ជានក្ខត្តឫក្ស ពេញបូណ៌មី ខែពិសាខ គឺជាឱកាសប្រសើរបំផុតរបស់ពុទ្ធសាសនិកជនទាំងឡាយ សម្រាប់រំលឹកដល់មហាទិពរាត្រី ដែលព្រះសមណគោតម ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រសូតជាបច្ឆិមជាតិផង ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញាណទាំងបី គឺ បុព្វេនិវាសានុស្សតិញាណ ទ្រង់រំលឹកឃើញជាតិកំណើតព្រះអង្គ ក្នុងអតីតជាតិ ដែលធ្លាប់អន្ទោលទៅមកក្នុងវដ្តសង្សារ, ចុតូបបាតញាណ ទ្រង់ជ្រាបដល់សត្វដែលច្យុត និងបដិសន្ធិ, អាសវក្ខយញាណ ទ្រង់ជ្រាបនូវផ្លូវសម្រាប់ទៅកាន់ទីរលត់ទុក្ខ និង ថ្ងៃបរិនិព្វានផង ។

ពុទ្ធសាសនិកជនទូទាំងប្រទេស ជាពិសេស អ្នកនៅក្នុងព្រះរាជធានីភ្នំពេញ តែងត្រេកអរផុតឧបមា និងបានហែតាមពីក្រោយព្រះប្រស្ថាននៃសម្ដេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិតលើត្បូង និងសម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ ជាទីស្នេហា និងគោរពស្មើជីវិតរបស់ខ្ញុំ ក្នុងការបូជាគ្រឿងទិព្វទេសពិសេសគន្ធរស ប្រទក្សិណព្រះសក្យ-មុនីចេតិយ ដែលតម្កល់ព្រះបរមសារីរិកធាតុ ។

ទូលព្រះបង្គំជាខ្ញុំ ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល ក្នុងនាមនៃពុទ្ធបរិស័ទទាំងអស់ ក្នុងប្រទេសកម្ពុជាទាំងមូល និងក្នុងនាមនៃគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំពិធីបុណ្យ, សូមព្រះបរមរាជានុញ្ញាតសំដែងនូវអំណរព្រះគុណ និង កតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះវត្តមាននៃសម្ដេចព្រះប្រមុខរដ្ឋ ជាទីគោរព·សក្ការៈ ស្មើដោយជីវិត នៃបណ្ដាជនខ្មែរ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្ដេចយាងមកជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់ ដើម្បីញ៉ាំងពិធីនេះ ឲ្យបានរុងរឿងជាកិយេក្រាភាព ហើយជាសក្ខីភាព បញ្ជាក់នូវព្រះរាជូបត្ថម្ភដ៏ខ្លាំងក្លា ចំពោះព្រះពុទ្ធសា-សនា ដែលជាសាសនារបស់ព្រះអង្គ ។

សូមព្រះតេជៈតម្កល់លើត្បូង

ព្រះសក្យមុនីចេតិយនេះ ជាអនុស្សរណដ្ឋានដ៏ធំក្រៃលែង របស់ពុទ្ធសាសនិកជនខ្មែរទូទៅ ដែលតែងតែនាំគ្នាធ្វើសក្ការៈបូជាដោយទឹក

ចិត្តជ្រះថ្លាជាបំផុត ៗ រីឯព្រះបរមសារីរិកធាតុ ដែលដំកល់នៅទីនេះ គឺដោយសារសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ដែលព្រះអង្គទ្រង់គង់នៅលើកដបល្ល័ង្កនៅឡើយ ព្រះអង្គទ្រង់បានទទួលផ្ទាល់ពីលោកអ្នកដែលថែរក្សាព្រះធាតុ នៅក្រុងកេណ្ឌី នៅឱកាសដែលទ្រង់យាងទៅបំពេញបេសកកម្ម ឯប្រទេសសេរីលង្កា ៗ នៅពេលដែលប្រទេសយើងរៀបធ្វើពិធីបុណ្យពាក់កណ្ដាលសាសនា ពី គ.ស ១៩៥៧ នោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានប្រោសព្រះរាជទានឲ្យដង្ហែព្រះបរមសារីរិកធាតុ មកប្រតិស្ឋាននៅក្នុងអង្គព្រះចេតិយនេះ ទុកជាទីគោរពសក្ការៈតរៀងមក ៗ បន្ទាប់ពីបុណ្យដ៏ធំនេះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះករុណាព្រះមហាកាញូនកោដ្ឋ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ កំណត់យកថ្ងៃ ១៥ កើត ទិន ១ រោច ខែពិសាខ ទុកជាថ្ងៃបុណ្យសម្រាប់ធ្វើពិធីនមស្ការព្រះសក្យមុនីចេតិយជាផ្លូវការ ហើយទ្រង់ចាត់ឲ្យក្រសួងធម្មការរៀបចំធ្វើពិធីនេះ ដោយរួបរួមជាមួយក្រសួងនានា ប្រារព្ធធ្វើមកជារៀងរាល់ឆ្នាំ ជាគំរប់ឆ្នាំទី ១០ ហើយ ៗ

ព្រះសកម្មភាព ដ៏ធំៗ ក្នុងការឧបត្ថម្ភព្រះពុទ្ធសាសនា ដូចបានរៀបរាប់មកនេះ បន្ថែមទៅលើព្រះមហាករុណាធិគុណជាច្រើនអនេកផ្សេង ៗ ទៀត ដែលព្រះមហាក្សត្រគ្រប់ព្រះអង្គ ទ្រង់តែងតាក់ព្រះទ័យក្នុងការកសាងឲ្យមានអគារវិហារនាការ ខាងពុទ្ធចក្រ គឺដូចជាខាងអាណា-

បក្រដែរ ជាឧទាហរណ៍ ឲ្យយល់ប្រត្យក្សថា ព្រះរាជបល្ល័ង្កខ្មែរ តែងតែសន្តោសឧបត្ថម្ភព្រះពុទ្ធសាសនាគ្រប់ពេលវេលា ពុំមានខ្វះ ៗ

សូមទ្រង់ព្រះមេត្តាប្រោស

លំដាប់តពីនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជវរោកាស ថ្លែងអភិវន្ទនកិច្ច ចំពោះព្រះបរមសារីរិកធាតុដូចតទៅ :

បពិត្រព្រះបរមសារីរិកធាតុ ព្រះសម្មាសម្ពុទ្ធ បរមគ្រូជាអម្ចាស់

ពិតមែនតែព្រះអង្គទ្រង់ចូលព្រះបរិនិព្វានផុតទៅហើយ ប៉ុន្តែព្រះបរមធាតុ និង សាសនាគឺពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដែលទ្រង់ប្រតិស្ឋានទុកឲ្យគ្រប់ ៥.០០០ ព្រះវស្សានោះ បានឋិតនៅសេរើកដូចទិដ្ឋភាព កាលព្រះអង្គ គង់ព្រះជន្មនៅ ដូច្នោះដែរ ៗ ព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម ដែលជាមូលដ្ឋាននៃព្រះពុទ្ធដីកា ក៏ត្រូវពួកពុទ្ធសាសនិកជនត្រង់ត្រាប់ គោរពប្រតិបត្តិ មកទល់សព្វថ្ងៃនេះបាន ២៥១០ វស្សាហើយ រហូតទៅដល់អង្គព្រះសិអារ្យមេត្រី ដែលនឹងត្រាស់ដឹងនៅចុងភទ្ទកប្បនេះ មានព្រះជន្មវស្សាដល់ទៅប្រាំបីម៉ឺនព្រះវស្សា ៗ កម្ពុជរដ្ឋ ដែលក្នុងបច្ចុប្បន្ននេះ បានសន្តិភាពជាជាងប្រទេសនានា ដោយអាស្រ័យសម្តេចព្រះមហាក្សត្រិយានី និង សម្តេចព្រះអគ្គប្រមុខរដ្ឋ ព្រះអង្គទ្រង់ឧបត្ថម្ភពេញព្រះសមត្ថភាព លើកសាសនាព្រះអង្គឲ្យរុងរឿងជាអតិបរមា ព្រមជាមួយអង្គការចលនាសង្គមរាស្ត្រនិយម ដែល

មានមនោគមន៍វិជ្ជាដូចនេះបិទ ទីនិសង្គមនិយមព្រះពុទ្ធសាសនាដែរ ។ ខ្ញុំព្រះអង្គទាំងឡាយ មានសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះប្រមុខរដ្ឋ ជាប្រធាន, ព្រះសង្ឃទាំងឡាយ មានសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក, សម្តេចព្រះពោធិវង្ស, រដ្ឋសភា, ក្រុមប្រឹក្សាព្រះរាជាណាចក្រ, ព្រះរាជរដ្ឋាភិបាល, នាម៉ឺនសព្វមុខមន្ត្រី គ្រប់ក្រសួង ទាំងទាហាន, ទាំងស៊ីវិល, យុវជន - យុវតី, ឧបាសក - ឧបាសិកា ព្រមទាំងប្រជាពលរដ្ឋ បានស្តេចយាង និង អញ្ជើញមកជួបជុំក្នុងបរិវេណនេះ ដើម្បីគោរពនមស្ការចំពោះព្រះសារីរិកធាតុនៃព្រះអង្គ ដែលប្រតិស្ឋានទៅទីនេះ និងសូមរំលឹកព្រះមហាករុណាធិគុណនៃព្រះអង្គផង ព្រមទាំងបានបូជាដោយគ្រឿងសក្ការៈទាំងឡាយ មានទៀន - ធូប - ផ្កាភ្ញីប្រទីបផ្កាលា ជាដើមផង ។ សូមព្រះអង្គ ទ្រង់ព្រះមេត្តាប្រោសទទួលនូវអភិវន្ទនកិច្ច និង គ្រឿងសក្ការៈទាំងឡាយ ដែលខ្ញុំព្រះអង្គទាំងអស់បាននាំមកថ្វាយនៅវេលានេះ ។

សូមទ្រង់ព្រះមេត្តាប្រោស

ដោយអានុភាពនៃកិច្ចនមស្ការនេះ ខ្ញុំព្រះអង្គទាំងឡាយ សូមគោរពបួងសួងចំពោះគុណព្រះបរមសារីរិកធាតុ គុណព្រះរតនត្រ័យ និងទេវតាទូទាំងសកលចក្រវាឡ សូមជួយបីបាច់ថែរក្សាអង្គសម្តេចព្រះមហា

ក្សត្រិយានី ព្រះមាតាជាតិ, សម្ដេចព្រះប្រមុខរដ្ឋ ព្រះបិតាឯករាជ្យជាតិ ជាទីគោរព និង ស្នេហា ស្មើជីវិតនៃប្រជាពលរដ្ឋទាំងឡាយ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ សូមព្រះអង្គប្រកបដោយព្រះបរមសុខ មានព្រះជន្មាទីឃាយុយឺនយូររាប់រយព្រះវស្សា ឈ្នះអស់មារសត្រូវគ្រប់ទិសទី ដែលកំពុងឃោរឃៅសព្វថ្ងៃ ឲ្យវិនាសខ្ទាត់ខ្ទាយអន្តរាយបាត់បង់យ៉ាងដុតដាប់ និងទ្រង់គង់ជាម្លប់ដ៏ត្រជាក់សុខសាន្តនៃកូនចៅរបស់ព្រះអង្គ នៅក្នុងកម្ពុជរដ្ឋទាំងមូល ជាអង្វែងតរៀងទៅ ។

មួយចំណែកទៀត សូមបុញ្ញកុសលនេះ ជួយទ្រទ្រង់សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃរាជ, សម្ដេចព្រះសុគន្ធាធិបតី ព្រះសង្ឃនាយក, សម្ដេចព្រះពោធិវង្ស និង សម្ដេចគ្រប់ព្រះអង្គ សូមទ្រង់បានប្រកបជួបប្រទះតែនឹងបរមសុខ ផុតចាករោគាពាធទាំងឡាយ ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា បានថ្កុំថ្កើងរុងរឿងឋិតថេរថេរកាលតរៀងទៅ ។

ទីបំផុត សូមគុណានុភាព ជួយអភិបាលពុទ្ធបរិស័ទ ទាំងគ្រហស្ថប្រជាពលរដ្ឋរួមជាតិគ្រប់ឋានៈ ទាំងទាហាន - ទាំងស៊ីវិល - កងរាជតម្រួត - យុវជនរាជសង្គមនិយមខ្មែរ និង ប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រទាំងមូល ឲ្យបានជួបតែនឹងសេចក្ដីសុខចំរើនគ្រប់ប្រការ ព្រមទាំងមានការព្រមព្រៀងគ្នាជាឯកភាព ក្នុងការកសាងប្រទេសជាតិ និង

ព្រះពុទ្ធសាសនា ក្រោមព្រះរាជូបត្ថម្ភនៃព្រះរាជបល្ល័ង្ក ឲ្យរឹងរឹតតែមាន
សាមគ្គីរឹងប៉ឹងឡើងទៀត ដង្ហែតាមព្រះមាគ៌ានយោបាយដ៏ភ្លឺស្វាង នៃ
សម្តេចព្រះអគ្គមគ្គុទ្ទេសក៍ជាតិ ដើម្បីជោគជ័យ និងសុខុមាលភាពគ្រប់
ពេលវេលាតរៀងទៅកុំបីឃ្លៀងឃ្លាត ។

សូមព្រះតេជៈតំកល់លើត្បូង

# ពិធីបុណ្យរំឭកខួបកំណើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

កាលពីថ្ងៃសុក្រ ទី ១២ ខែឧសភា ១៩៦៧ វេលាម៉ោង ៨ ព្រឹក នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ មានប្រារព្ធធ្វើពិធីបុណ្យខួបឆ្នាំទី ៣៧ នៃការបង្កើតវិជ្ជាឋាននេះ ហើយនិងពិធីថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គសាសនូបត្ថម្ភក៍ ។ ពិធីនេះប្រារព្ធធ្វើក្រោមអធិបតីភាពនៃសម្តេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាកម្ពុជរដ្ឋ អធិបតីនៃក្រុមជំនុំព្រះត្រៃបិដក និងព្រះតេជព្រះគុណ អ៊ុក-ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនសិក្សាធិការ ដែលមានបុគ្គលិកទាំងព្រះសង្ឃទាំងគ្រហស្ថនិងពុទ្ធបរិស័ទធ្វើការក្នុងក្រសួងធម្មការ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ អគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹតជួបជុំផង ។ មុនការប្រារព្ធដាក់បាត្រព្រះសង្ឃចំនួន ៣៧អង្គ និងការចំរើនសត្តប្បករណាភិធម្ម កត្តានុមោទនា សហជីវិន លាង-ហ័ប-អាន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្នុងនាមព្រះសង្ឃ គ្រហស្ថជាបុគ្គលិកនៃវិជ្ជាឋាន បានថ្លែងសុន្ទរកថាស្តីអំពីប្រវត្តិវិជ្ជាឋាន គោលបំណងនៃពិធីបុណ្យ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# សន្ទរកថា

សូមនមស្ការ សម្ដេចព្រះពោធិវង្ស ជាអម្ចាស់

សូមប្រណិប័តន៍ ឯកឧត្ដម ទេសរដ្ឋមន្ត្រី

សូមជំរាបព្រះតេជព្រះគុណអនុរដ្ឋលេខាធិការ

សូមជំរាបសហជីវិន សហជីវិនីទាំងឡាយ

ខ្ញុំព្រះករុណា ខ្ញុំបាទមានបីតិសោមនស្សក្រៃលែង និងសូមថ្លែងអំណរព្រះគុណ-អំណរគុណចំពោះសម្ដេចជាអម្ចាស់ ឯកឧត្ដម ព្រះតេជព្រះគុណ និងសហជីវិន សហជីវិនីទាំងអស់ ដែលទ្រង់បាននិងបានភ្ញៀតឱកាសយ៉ាងមមាញឹក និមន្តនិងអញ្ជើញមកជាកិត្តិយស ក្នុងពិធីបុណ្យខួបលើកទី ៣៧ នៃការបង្កើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលយើងខ្ញុំព្រះករុណា ខ្ញុំបាទ ប្រារព្ធធ្វើឡើងក្នុងពេលនេះ ។ ការនិមន្ត និងអញ្ជើញមកនេះ បញ្ជាក់នូវព្រះហឫទ័យ នូវចិត្តសន្ដោសមេត្តារបស់សម្ដេច ឯកឧត្ដម ព្រះតេជព្រះគុណ សហជីវិន-សហជីវិនី ចំពោះវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ នាំឲ្យយើងខ្ញុំព្រះករុណា-ខ្ញុំបាទ រឹងរឹតតែមានកម្លាំងប្រឹងប្រែង បំរើមុខងាររក្នុងវិជ្ជាឋាននេះ ខ្លាំងក្លាថែមឡើងទៀត ។

បន្ទាប់ពីនេះ សូមមេត្តាអនុញ្ញាត ដើម្បីខ្ញុំព្រះករុណា ខ្ញុំបាទ ថ្លែងបន្តិចអំពីប្រវត្តិដើមនៃវិជ្ជាឋាននេះ :

ដូចជាសម្តេច ឯកឧត្តម ព្រះតេជព្រះគុណ និងសហជីវិនទាំងអស់ ជ្រាបស្រាប់មកហើយ មន្ទីរពុទ្ធសាសនបណ្ឌិត្យនេះ កាលដើមឡើយហៅថា " ព្រះរាជបណ្ណាល័យ " ដែលរាជការបានបង្កើតឡើងតាំងពីឆ្នាំ ១៩២១ ហើយដែលបានធ្វើពិធីសម្ពោធនៅថ្ងៃ ១៣ សីហា ១៩២៥ ក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ។ តាំងពីចាប់ប្រកបដំណើរការមក ព្រះរាជបណ្ណាល័យក៏បានលេចឮឈ្មោះទៅគ្រប់ទិសទីទាំងក្នុងប្រទេស ទាំងក្រៅប្រទេស រហូតមកដល់គ្រាសព្វថ្ងៃ ហើយក៏នៅតែមានអង្គការបរទេសសសេរសំបុត្រសួរមកទាក់ទង តាមសំបុត្រថា " ព្រះរាជបណ្ណាល័យ " នោះដែរ ។ កាលកើតឡើងជាដំបូងនោះ ព្រះរាជបណ្ណាល័យមានមុខងារជាអ្នកថែរក្សាគម្ពីរ - ក្រាំង - សាស្ត្រា និងសៀវភៅឯកសារប្រភេទដូចគ្នានេះ មកតម្កល់ថែរក្សាទុកផង ៗ ម្ល៉ោះហើយ ចំនួនឯកសារក៏កាន់តែមានច្រាស់ក្រែលឡើងជាលំដាប់ ឯសៀវភៅភាសាបារាំង និងភាសាដទៃ ៗ ទៀតសោត ក៏កាន់តែកើនច្រើនឡើង ។ ព្រោះមានការទាក់ទងជាមួយអង្គការបរទេសកាន់តែសាយភាយឡើងដែរ ធ្វើឲ្យបណ្ណាល័យនេះ ទៅជាមជ្ឈមណ្ឌលវប្បធម៌មួយ ដែលគេស្គាល់ជាង

គេនៅក្នុងប្រទេសឥណ្ឌាចិន កាលសម័យនោះ ។ មិនតែប៉ុណ្ណោះ ព្រះរាជបណ្ណាល័យបានចាត់ការបោះពុម្ពផ្សាយសៀវភៅធម៌អាថ៌ ដែលចាត់ជាការបោះពុម្ពផ្សាយជាគ្រាដំបូងបំផុតនៅប្រទេសកម្ពុជាយើង ជាពិសេសគឺការបោះពុម្ពព្រះត្រៃបិដក ដែលជាការងារយ៉ាងធំ ហើយយ៉ាងពិនិត្យពិច័យបំផុតរបស់ក្រុមជំនុំព្រះត្រៃបិដក ។

លុះមកដល់ គ.ស. ១៩៣០ ព្រះបាទសម្តេចព្រះមុនីវង្ស ព្រះអង្គទ្រង់មាន ព្រះរាជបំណងចង់ពង្រីកព្រះពុទ្ធសាសនាក្នុងប្រទេសយើង ព្រះអង្គទ្រង់គ្រាស់បង្កើតឲ្យមានវិជ្ជាឋានមួយ ហៅថា " ពុទ្ធសាសនបណ្ឌិត្យ " តាំងនៅជាមួយគ្រឹះស្ថានព្រះរាជបណ្ណាល័យ ដើម្បីទទួលភារៈសិក្សាស្រាវជ្រាវ និងតម្រឹមតម្រង់ការប្រតិបត្តិព្រះពុទ្ធសាសនាឲ្យកាន់តែបានហ្មត់ចត់ឡើង នៅក្នុងប្រទេសយើង ។ ដូច្នេះកិច្ចការខាងបោះពុម្ពផ្សាយ និងការស្រាវជ្រាវគ្រប់បែបយ៉ាង ត្រូវផ្ទេរបន្តទៅឲ្យជាភារៈរបស់ពុទ្ធសាសនបណ្ឌិត្យ ឯព្រះរាជបណ្ណាល័យគ្រាន់តែជាអ្នកថែរក្សាប៉ុណ្ណោះ ។

វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យបានសម្ពោធជាផ្លូវការកាលពីថ្ងៃទី ១២ ឧសភា គ.ស. ១៩៣០ នៅក្រោមព្រះរាជាធិបតីភាពនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស បើគិតមកដល់ថ្ងៃនេះ ត្រូវជា ៣៧ ឆ្នាំ គត់ ។

លុះមកដល់ គ.ស. ១៩៤៣ ព្រះរាជបណ្ណាល័យត្រូវផ្ទេរសម្បត្តិ ដើមដែលជា គម្ពីរ សាស្ត្រាទិងក្រាំងយកពីក្នុងព្រះរាជវាំងមកនោះ ប្រគល់ជូនទៅបណ្ណាល័យក្នុងព្រះបរមរាជវាំងវិញ ដូច្នេះឈ្មោះដើមដែលជា " ព្រះរាជបណ្ណាល័យ " នោះ ត្រូវអស់តាំងពីនោះមក ។ បណ្ណាល័យដែលសេសសល់ឯកសារទាំងប៉ុន្មាន ក៏ទៅជាសម្បត្តិផ្ទាល់របស់ពុទ្ធសាសនបណ្ឌិត្យរហូតមក ។

ចំណែកអ្នកកាន់កាប់គ្រប់គ្រងមន្ទីរនេះ ដើមឡើយសុទ្ធសឹងតែជាជនជាតិបារាំង តែអ្នកទាំងនេះបានទទួលយកចិត្តទុកដាក់ណាស់ ដោយធ្វើសហប្រតិបត្តិការជាមួយសម្តេចព្រះវរបគ្រណពុទ្ធ ទេពគម-សុធារស, សម្តេចព្រះធម្មលិខិត ល្វី-ឯម កាលនៅជាព្រះញាណបវរវិជ្ជា, សម្តេចព្រះសង្ឃរាជជាក់ទី ១ កាលនៅជាព្រះសំសត្តា, សម្តេចព្រះពោធិវង្ស កាលនៅជាព្រះគ្រូសំវិជ្ជា និង ព្រះឧត្តមមុនី អ៊ុំ-ស៊ូ កាលនៅជាព្រះវិមលបញ្ញា ។ ដូច្នេះ គឺព្រះអង្គដែលមានរាប់ព្រះនាមមកនេះហើយដែលបានផ្តើមត្រួសត្រាយផ្លូវដឹកនាំក្រសួងឲ្យបានល្អគួរសមចំរើន សឹងមានកេរ្តិ៍ឈ្មោះល្អថ្កុំថ្កើងរហូតដល់មកសព្វថ្ងៃនេះ ។

នៅ គ.ស. ១៩៥០ រាជការបារាំង ក៏បានផ្ទេរវិជ្ជាបាទពុទ្ធសាសនបណ្ឌិត្យជូនមករាជការខ្មែរ ពេលនោះ សហ. យៀន-ចឹម ដែលធ្លាប់ធ្វើជាគ្រូឈ្មួយ អគ្គលេខាធិការ ជាតិបារាំងជាច្រើននាក់មកហើយនោះ

ទទួលកាន់កាប់ជាអគ្គលេខាធិការបន្ទការផ្ការយ៉ានម៉ិនម៉ាត់ រហូតដល់ គ.ស. ១៩៦៥ ទើបលោកត្រូវដល់កំណត់អាយុចូលនិវត្តន៍ ។ ភារៈនេះ ក៏ធ្លាក់មកលើសហជីវិន ពៃយ-ប៊ុក បន្តមកទៀតបានមួយឆ្នាំ ក៏ដល់ អាយុនិវត្តន៍ទៅទៀត ទើបភារៈនេះ ត្រូវធ្លាក់មកលើខ្ញុំករុណា - ខ្ញុំបាទ ទទួលបន្តកិច្ចការដ៏ប្រសើរជាដំណអំពីរៀមច្បងទាំងនោះមក ។

សម្តេចជាអម្ចាស់ ឯកឧត្តម ព្រះតេជព្រះគុណ សហជីវិន សហជីវិនីទាំងឡាយ ។

គោលបំណងនៃពិធីបុណ្យពេលនេះ គ្មានអ្វីក្រៅពីការបង់រំឭក ថ្ងៃកំណើតនៃវិជ្ជាឋាននេះ ដោយលើកយកកិត្តិគុណ អស់លោកអ្នក ប្រាជ្ញទាំងអស់ ដែលលោកបានជួយឧបត្ថម្ភវិជ្ជាឋាន ឲ្យមានដំណើរល្អ ណាស់ ជាមធ្យោបាយផ្សាយ ពង្រីកវប្បធម៌ជាតិ ឲ្យសាយភាយទូលាយ ក្នុងព្រះរាជាណាចក្រផង ជាហេតុនាំឲ្យយើងខ្ញុំព្រះករុណា ខ្ញុំបាទ ពុំអាចបំភ្លេចលោកបានឡើយ ។ ព្រះនាមនិងនាមនៃអស់លោកអ្នក ប្រាជ្ញ និងជាអ្នកឧបត្ថម្ភរនោះមាន :

ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ថោង, សម្តេចព្រះធម្មលិខិត ល្វី-ឯម, សម្តេចព្រះសង្ឃរាជជោតញាណ ជួន - ណាត, សម្តេច ព្រះរាជអគ្គមហេសី រាជក្រណារិទ្ធិ នរោត្តម-សុត្ថារស, សម្តេចព្រះពោធិវង្ស ហួត-តាត ដែលព្រះអង្គគង់ជាប្រធានក្នុងទីនេះ, ព្រះឧត្តមមុនី អ៊ុំ-ស៊ូ,

ព្រះមហាព្រហ្មមុនី ទេព - អ៊ុ, ព្រះមុនីកោសល សោម - ឈុន, ព្រះធម្មលិខិត ម៉ឹង - សែស, ព្រះវិតក្កញ្ញាណ សោម - ឡុច, ព្រះមុនីកោសល សួរ-ហាយ, ព្រះញាណកោសល ញាណ-ឈឹន, ព្រះបិដកសោភ័ណ ប៉ែន - សុខ, ព្រះមហា ប៉ាង-ខាត់, ព្រះសិរីសម្មតិ-វង្ស ប៉ុណ្ណ-សម្ភាជ, លោក ជុំ-ម៉ៅ, គិម្យ-ង៉ុយ, លោក សោ-ភ័ណមន្ត្រី ជួន-នុត, លោកឧកញ៉ា ឈឹម-ក្រសេម, ព្រះសាសនមុនី គឹម-តូ, ព្រះធម្មឧត្តម ហ៊ុ-ជា, លោក អ៊ុច-រស់, លោក អ៊ុក-ម៉ូត, លោកយឿន ចឹម, លោកក៉យ-ប៊ុក, លោក ទិន-ហួត, លោក ញ៉ុក-ថែម, លោក តាប-ពិន, លោក យូរ-អ៊ុន, លោក ប៊ូ-ប៉ូ, លោក ឈឹម-ស៊ុម, ឯកឧត្តម ឃឹម-ទិត, លោក ផេង-ជ្រីវ, លោក ស៊ិន-ហ៊ិន, លោក មាឃ-ស៊ុន, លោក ម៉ាង-នាង លោក សឹង-ផន, លោក ញូង-សៀង និងអស់លោកច្រើនទៀតដែលពុំបានកប់អស់ ព្រោះពេលវេលាខ្វះពេក ។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមបួងសួងឧទ្ទិសបុញ្ញរាសី ដែលកើតឡើងក្នុងពិធីបុណ្យនេះ :

ជាបឋមថ្វាយជាព្រះរាជកុសលចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គបានប្រកបនិងបរមសុខក្នុងសិរីរាជ-សម្បត្តិ មានព្រះជន្មាទីឃាជាងរយព្រះវស្សា និងសូមថ្វាយចំពោះសម្តេចឪព្រះប្រមុខរដ្ឋជាទីគោរពស្នេហាបំផុត សូមព្រះអង្គបានប្រកប

នឹងជោគជ័យគ្រប់ប្រការ កុំបីមានសត្រូវណា មកបៀតបៀនព្រះអង្គបានឡើយ ។

ជាបន្ទាប់មកសូមឧទ្ទិស ចំពោះព្រះវិញ្ញាណក្ខន្ធ នៃព្រះអតីតព្រះមហាក្សត្រទាំងឡាយ មានព្រះករុណាព្រះបាទសម្តេចព្រះអង្គ-ឌួង ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះបាទសម្តេចព្រះមុនីវង្ស ព្រះបាទសម្តេចព្រះសុរាម្រឹត សូមព្រះអង្គទ្រង់អនុមោទនានិងសូមទ្រង់ប្រកបដោយព្រះបរមសុខកុំបីឃ្លៀងឃ្លាតឡើយ ។

មួយចំណែកទៀត សូមឧទ្ទិសផ្សាយកុសល ជូនដល់វិញ្ញាណ-ក្ខន្ធអស់លោក ដែលមានគុណលើមន្ទីរពុទ្ធសាសនបណ្ឌិត្យ ហើយដែលបែកស្លាប់ទៅហើយនោះ សូមឲ្យបានស្ថិតនៅក្នុងសុគតិភពជាភិយ្យោភាព ៗ ទីបំផុត សូមផ្សាយកុសលចំពោះសម្តេច ជូនឯក-ឧត្តម ព្រះតេជព្រះគុណ សហជីវិន សហជីវិនីទាំងអស់ សូមឲ្យបានសម្រេចសមបំណង ដូចចិត្តប៉ងប្រាថ្នាកុំបីឃ្លៀងឃ្លាតឡើយ ។

# បុតហ្វាយនៃពុទ្ធសាសនាបណ្ឌិត្យ

បន្ទាប់ពីពិធីបុណ្យរំឭកថ្ងៃកំណើតនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យមក សហជីវិននាយកនៃវិទ្យាស្ថាននេះ ក៏បានធ្វើជាបុតហ្វាយ ថ្វាយព្រះពរចំពោះ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង, សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ និង សម្ដេចព្រះសង្ឃរាជ ដ៏ចមានសេចក្ដីចម្លង ចុះថ្ងៃនទាំងស្រុង តទៅនេះ :

*សូមព្រះតេជៈតំកល់លើត្បូង*

*សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ*

*នៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត*

*សូមទ្រង់ជ្រាប ។*

*ទូលព្រះបង្គំជាខ្ញុំ ព្រមទាំងបុគ្គលិក ព្រះសង្ឃ និង គ្រហស្ថ ជាសហការីទាំងអស់ នៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ ក្រោយដែលបាន ទទួលព្រះរាជទ នៃសម្ដេចព្រះពោធិវង្ស ហួត តាត អគ្គាធិការ នៃពុទ្ធិកសិក្សាកម្ពុជរដ្ឋ និងជាអធិបតី នៃក្រុមជំនុំព្រះត្រៃបិដក ហើយនិងដោយបានទទួលការណែនាំផ្ទាល់ ប្រកបដោយសេចក្ដីអបអរសាទរនៃឯកឧត្តម ស៊ឹង ហ៊ុនសាងទេសរដ្ឋមន្ត្រីក្រសួងធម្មការ និង ព្រះតេជព្រះគុណ អ៊ុក - ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការ បាន ប្រមូលគ្នា ប្រារព្ធធ្វើពិធីបុណ្យរាប់បាត្រ ព្រះសង្ឃរាជាគណៈ ឋានានុក្រម ទាំងពីរគណៈចំនួន ៣៧ អង្គ ក្រោមព្រះអធិបតីភាព នៃសម្ដេចព្រះ*

ពោធិវង្ស កាលពីព្រឹកថ្ងៃសុក្រ ទី ១២ ឧសភា ១៩៦៧ នៅនាបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។ ពិធីបុណ្យនេះមានគោលបំណងសំខាន់ដូចតទៅ គឺ :

- រំលឹកដល់ខួបទី ៣៧ នៃឆ្នាំកំណើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលបានកើតឡើងពីខែមករា គ.ស. ១៩៣០ ដោយស្នាព្រះហស្ថដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ហើយដែលទ្រង់បានសព្វព្រះរាជហឫទ័យបើកពិធីសម្ពោធជាផ្លូវការ យ៉ាងឧឡារិកនៅថ្ងៃទី ១២ ឧសភា ១៩៣០ ។

– ថ្វាយព្រះរាជកុសល ចំពោះព្រះវិញ្ញាណក្ខន្ធ នៃព្រះអតីតមហាក្សត្រគ្រប់ព្រះអង្គ ដែលទ្រង់មានព្រះមហាករុណាធិគុណដ៏ធ្ងន់ ចំពោះប្រទេសជាតិ ក្នុងវិស័យវប្បធម៌–អក្សរសាស្ត្រ ព្រមទាំងទ្រង់មានព្រះគុណបំណាច់ឧបត្ថម្ភផ្ទាល់ព្រះអង្គ នូវមជ្ឈមណ្ឌលព្រះពុទ្ធសាសនា និងវប្បធម៌ជាតិ គឺមានព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រឹត និងសម្តេចក្រុមព្រះវរចក្ររណារិទ្ធ នរោត្តម-សុធារស ជាដើម ។

–ថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ និងជាព្រះមាតានៃវប្បធម៌ សិល្បៈ និងអារ្យធម៌ជាតិ ព្រមទាំងចំពោះសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ ។

– ថ្វាយព្រះរាជកុសល : ជូនកុសល ចំពោះគរ៍ អ្នកប្រាជ្ញ រាជបណ្ឌិត្យ ទាំងបព្វជិត ទាំងគ្រហស្ថ ទោះធ្វើមរណកាលទៅហើយ ឬ មានជន្មាយុនៅឡើយ ដែលបានខិតខំបំរើវិស័យព្រះពុទ្ធសាសនា វប្បធម៌ និងអក្សរសាស្ត្រជាតិ មានសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ និងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ជាប្រធាន ។

សូមទ្រង់ព្រះមេត្តាប្រោស

ពិធីបុណ្យនេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ បានសម្រេចកំណត់ទុកជាប្រពៃណីរបស់វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលនឹងត្រូវធ្វើរៀងរាល់ឆ្នាំតទៅ នៅថ្ងៃទី ១២ ឧសភា នៃសុរិយគតិដើម្បីជាសក្ខីភាពនៃកតញ្ញូតា ចំពោះព្រះមហាករុណាទិគុណរបស់ព្រះមហាក្សត្រ និង បុព្វបុរស ដែលមានសគុណចំពោះជាតិ សាសនា ព្រះរាជបល្ល័ង្ក ព្រមទាំងជាសញ្ញានៃសាមគ្គីភាព របស់បុគ្គលិកក្នុងក្រសួង ។

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមលំឱនកាយក្រាបបង្គំថ្វាយ នូវបុញ្ញរាសីដ៏ឧត្តម ដែលកើតអំពីពិធីបុណ្យរាប់បាត្រព្រះសង្ឃពេលនេះ ចំពោះសម្តេចជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គទ្រង់គង់នៅក្នុងព្រះបរមសុខសួស្តី ជោគជ័យមង្គល មហាប្រសើរ មានជន្មាទីឃាយុជាងរយព្រះវស្សា មានព្រះសុខភាពបរិបូណ៌ ដើម្បីទ្រង់គង់នៅជាមហាម្លប់ដ៏

ត្រជាក់ត្រជុំពំនាក់ទងជ្រករោគ នៃបណ្ដាកូនចៅព្រះអង្គ អស់កាលជាអង្វែងគ្រប់ ៗ កាលជានិរន្ដរ៍ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជតានក្រោបបង្គំទូលថ្វាយ នៅថ្ងៃទី ១៣ ធ្នូ ១៩៦៧

ទូលព្រះបង្គំជាខ្ញុំ ឈាង-ហ៊ាបអាន

នាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

---

២– បុគ្គលិកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យថ្វាយសម្ដេចសហជីវិន. –

សូមក្រាបបង្គំទូល

សម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាប ។

ទូលព្រះបង្គំ ព្រមទាំងបុគ្គលិក ព្រះសង្ឃនិងគ្រហស្ថ ជាសហការីទាំងអស់ នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ ក្រោយដែលបានទទួលព្រះទានទៃសម្ដេចព្រះពោធិវង្ស ហួត តាត អគ្គាធិការនៃពុទ្ធិកសិក្សាកម្ពុជ្ជ និងជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក និងក្រោយដែលបានទទួលការណែនាំផ្ទាល់ ដោយសេចក្ដីអបអរសាទរនៃឯកឧត្ដម អ៊ុង-ហ៊ុងសាន ទេសរដ្ឋមន្ត្រីក្រសួងធម្មការ និងព្រះតេជព្រះគុណ អ៊ុក-ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការ បានរួបរួមគ្នាប្រារព្

ធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃរាជាគណៈ ឋានានុក្រម រួមទាំងពីរគណៈ ចំនួន ៣៧ អង្គ ក្រោយព្រះអធិបតីភាពនៃសម្តេចព្រះពោធិវង្ស កាលពីព្រឹកថ្ងៃ សុក្រទី ១២ ឧសភា ១៩៦៧ នៅសាលបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។ ពិធីបុណ្យនេះ មានគោលបំណងសំខាន់ ដូចតទៅ គឺ :

— រំលឹកខួបទី ៣៧ នៃឆ្នាំកំណើតវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលបានកើតឡើងពីខែ មករា ១៩៣០ ដោយស្នាព្រះហស្តដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះករុណាព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ មុនីវង្ស ហើយដែលទ្រង់សព្វព្រះរាជហឫទ័យ បើកពិធីសម្ពោធជាផ្លូវការយ៉ាងឧឡារិក នៅថ្ងៃទី ១២ ឧសភា ១៩៣០ ។

— ថ្វាយព្រះរាជកុសល ចំពោះព្រះអតីតមហាក្សត្រគ្រប់ព្រះអង្គ ដែលទ្រង់មានព្រះមហាករុណាធិគុណ ចំពោះប្រទេសជាតិ ក្នុងវិស័យវប្បធម៌-អក្សរសាស្ត្រ ព្រមទាំងទ្រង់មានព្រះគុណចំណាច់ឧបត្ថម្ភផ្ទាល់ព្រះអង្គនូវមជ្ឈមណ្ឌលព្រះពុទ្ធសាសនា និង វប្បធម៌ជាតិ គឺមានព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ-មុនីវង្ស ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រឹត និងសម្តេចព្រះរាជអយ្យកោ វរចក្រណារិទ្ធិ នរោត្តម-សុធារស ជាដើម ។

— ថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានី ជា

អម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក ទាំងជាព្រះមាតានៃវប្បធម៌ សិល្បៈ និងអារ្យធម៌ជាតិ ព្រមទាំងចំពោះសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ ។

-ថ្វាយព្រះរាជកុសល - ជូនកុសលចំពោះគរុ អ្នកប្រាជ្ញ រាជបណ្ឌិតជាបព្វជិត និងគ្រហស្ថ ដោះទទួលមរណភាពទៅហើយក្តី ឬ មានជន្មាយុនៅឡើយក្តី ដែលបានខិតខំបំរើវិស័យព្រះពុទ្ធសាសនា វប្បធម៌ និងអក្សរសាស្ត្រជាតិ មានសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ និង សម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ជាប្រធាន ។

សូមទ្រង់ព្រះមេត្តាប្រោស

ពិធីបុណ្យនេះ ទូលបង្គំទាំងឡាយ បានសម្រេចកំណត់ទុកជាបុណ្យប្រពៃណីរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលនឹងត្រូវធ្វើនៅថ្ងៃទី ១២ ធ្នូ រៀងរាល់ឆ្នាំតទៅ ដើម្បីជាសក្ខីភាពនៃកតញ្ញូតាធម៌ ចំពោះព្រះមហាករុណាធិគុណរបស់ព្រះមហាក្សត្រ និងបុព្វបុរសដែលមានសគុណចំពោះជាតិ – សាសនា – ព្រះរាជបល្ល័ង្ក ព្រមទាំងជាសញ្ញានៃសាមគ្គីភាពរបស់បុគ្គលិកក្នុងក្រសួង ។

ទូលព្រះបង្គំទាំងឡាយ សូមលំអុតលំឱនក្រាបបង្គំថ្វាយ នូវបុញ្ញាភិសង្ខារឧត្តម ដែលកើតអំពីពិធីបុណ្យរាប់បាត្រព្រះសង្ឃពេលនេះ ចំពោះសម្តេចសហជីវិនជាអម្ចាស់ សូមព្រះអង្គគង់នៅក្នុងព្រះបរមសុខសួស្តី

ជោគជ័យមង្គល មហាប្រសើរ មានព្រះជន្មាទីឃាយុជានរយព្រះវស្សា មានព្រះសុខភាពបរិបូណ៌ ដើម្បីទ្រង់គង់នៅជាម្លប់ដ៏ត្រជាក់ត្រជុំ ជាទីពំនឹងពំនាក់ជ្រកកោន នៃកូនចៅព្រះអង្គគ្រប់ៗកាល ជានិរន្តរ៍តទៅ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមក្រាបបង្គំទូលថ្វាយ នៅភ្នំពេញ ថ្ងៃទី ១៣ មេសា ១៩៦៧

ទូលព្រះបង្គំ ឈាង-ហ៊ាបអាង

នាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

---

៣– ចុតហ្មាយថ្វាយសម្ដេចព្រះសង្ឃរាជ –

សូមព្រះតេជៈតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ

នៃសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ គណៈមហានិកាយ

សូមទ្រង់ជ្រាប ។

ទូលព្រះបង្គំជាខ្ញុំ ព្រមទាំងបុគ្គលិក ព្រះសង្ឃ និង គ្រហស្ថ ជាសហការីទាំងអស់នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រោយដែលបានទទួលព្រះឱវាទនៃសម្ដេចព្រះពោធិវង្ស និងក្រោយដែលបានទទួលការណែនាំផ្ទាល់របស់ព្រះតេជៈព្រះគុណ អ៊ុក-ម៉ូត អនុរដ្ឋលេខាធិការ ក្រសួងធម្មការ បានប្រារព្ធធ្វើពិធីបុណ្យខួប ទី ៣៧ រំលឹកដល់ឆ្នាំកំណើតនៃ

ពុទ្ធសាសនបណ្ឌិត្យ ដែលបានកើតឡើងក្នុងឆ្នាំ ១៩៣០ កាលពីព្រឹក ថ្ងៃ សុក្រ ទី ១២ ឧសភា ១៩៦៧ នៅបណ្ណាល័យនៃវិជ្ជាឋាននេះ ក្រោមអធិបតីភាពនៃសម្ដេចព្រះពោធិវង្ស ព្រមទាំងរំលឹកដល់គុណូបការ នៃកវី អ្នកប្រាជ្ញ រាជបណ្ឌិតទាំងឡាយ ដែលបានខិតខំយកព្រះទ័យ· ចិត្តទុកដាក់ពុះពារឧបសគ្គគ្រប់បែបគ្រប់យ៉ាង ក្នុងវិស័យពុទ្ធសាសនា និង អក្សរសាស្ត្រជាតិ ដោយបានទុកកេរ្តិ៍មរតកគឺស្នាព្រះហស្ត ស្នាដៃ ជាសៀវភៅធម៌អាថ៌ ជាសៀវភៅវេយ្យាករណ៍ ជាក្បួនខ្នាតសំខាន់ ៗ ដ៏ច្រើនមហិមា សម្រាប់កូនចៅជាន់ក្រោយ ពិសេសគឺសម្ដេចជាម្ចាស់ និងសម្ដេចព្រះពោធិវង្ស ដែលជាអាទិកម្មិកបុគ្គលនៃព្រះរាជបណ្ណាល័យ និង ពុទ្ធសាសនបណ្ឌិត្យ នេះឯង ។

ក្នុងពិធីដ៏តូចនេះ មានការរាប់បាត្រព្រះសង្ឃចំនួន ៣៧ អង្គ ដោយតម្រូវនឹងអាយុកាលនៃពុទ្ធសាសនបណ្ឌិត្យ ដើម្បីសំដែងនូវកត·ញ្ញូតា និង គារវភាព ឧទ្ទិសកុសលថ្វាយ-ជូន ចំពោះកវី អ្នកប្រាជ្ញ រាជបណ្ឌិត ជាបុព្វបុរសទាំងឡាយនោះផង ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ បានសម្រេចកំណត់យកពិធីបុណ្យខួបនេះ ទុកជាបុណ្យប្រពៃណីរបស់វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលតទៅមុខនឹងត្រូវធ្វើនៅថ្ងៃទី ១២ ឧសភា រៀងរាល់ឆ្នាំ ដើម្បីតម្រូវនឹង

ថ្ងៃបុណ្យសម្ពោធនៃវិជ្ជាឋាននេះ ដែលបានធ្វើកាលពីថ្ងៃទី ១២ មេសា ១៩.៣០ ។

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមព្រះករុណាទ្រាបបង្គំក្រោមល្អងធូលីព្រះបាទ ថ្វាយនូវភាគផលកុសលកសិដ៏ឧត្តម ដែលកើតអំពីបុណ្យកប់បាត្រព្រះសង្ឃនោះបំពោះសម្តេចជាអម្ចាស់ សូមព្រះអង្គទ្រង់គង់នៅក្នុងព្រះបរមសុខ មានព្រះសុខភាពបរិបូណ៌ មានព្រះជន្មាស្សាយឺនយូរជានិរយព្រះវស្សា ដើម្បីទ្រង់គង់ជាម្លប់ត្រជាក់ត្រជុំ ជាទីជ្រកកោននៃពុទ្ធបរិស័ទទាំងឡាយអស់កាលជាអង្វែងតទៅ ។

គួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះករុណាទ្រាបបង្គំទូលថ្វាយ នៅភ្នំពេញថ្ងៃទី ១៣ មេសា ១៩៦៧

ទូលព្រះបង្គំជាខ្ញុំ ឈាង-ហ៊ាប អាង

នាយកនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

BIBLIOTHÈQUE NATIONALE DU CAMBODGE
P. K. 1
1967 _ 6

K. 213

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . . ៥៦៩

២– ករណីយកិច្ចរបស់ពុទ្ធបរិស័ទ លោក ប៊ូ-ប៉ូ រៀបរៀង . . . . . . . . ៥៧៩

៣– ការគប់មិត្ត លោក គ្រួច-ភុម រៀបរៀង . . . . . . . . . . . . ៦០៩

*ផ្នែកអក្សរសាស្ត្រ*

៤– ហេតុដូចម្តេចក៏សុំឲ្យទេព្ដាជួយ? លោក ផេង-ជ្រីវ រៀបរៀង . . . . . . . ៦២០

៥– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . ៦៣០

៦– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . . . . ៦៣៨

៧– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឌ. គាម ស្រាវជ្រាវ (ត) . . . . . . . . ៦៤២

៨– ឯកសារ សាស្ត្រស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៦៤៤

៩– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៦៤៩

១០– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . . ៦៥៧

១១– ឯកសារកម្ពុជសុរិយា លោក ឌ.គាម ប្រមូលរៀបរៀង (ត) . . . . . . . . ៦៦៧

*ផ្នែកកំណត់ និង ប្រវត្តិការណ៍*

១២– ពុទ្ធសាសនបណ្ឌិត្យ បានទទួលព្រះរាជបុត្តហ្មាយ . . . . . ៦៦៩
១៣– សកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ ក្នុងខែឧសភា ១៩៦៧ . . . . ៦៧៤

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០,០០ ៛

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក, ឲ្យធ្វើល្អទៅ,
ឲ្យផុសខាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ក.ព.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ចាំង ប្រែ - រៀបរៀង

ប្រ. គម្ពីរណា ដែលមានចារឹកព្រះពុទ្ធដីកាដ៏ប្រសើរ របស់ព្រះសម្មាសម្ពុទ្ធ ?

វិ. គឺគម្ពីរ ៣ ផ្នែកដែលហៅថា ព្រះត្រៃបិដក ឬល្អី ឬកំកាដទៈ ៣ ។

ប្រ. គម្ពីរព្រះត្រៃបិដកនោះ មានឈ្មោះអ្វីខ្លះ ?

វិ. វិនយបិដក, សុត្តន្តបិដក និងអភិធម្មបិដក ។

ប្រ. ក្នុងគម្ពីរទាំងនោះ មាននិយាយពីអ្វីខ្លះ ?

វិ. ក្នុងគម្ពីរវិនយបិដក ព្រះអង្គសំដែងអំពីសិក្ខាបទ សណ្តាប់ធ្នាប់ ច្បាប់របស់ព្រះសង្ឃ, ក្នុងសុត្តន្តបិដក ព្រះអង្គសំដែងអំពីនិទានរឿងរ៉ាវ ដែលនាំឲ្យកើតបញ្ញា អំពីសម្មាប្រតិបត្តិទូទៅគ្រប់គ្នាទាំងអស់,

ក្នុងអភិធម្មបិដក ព្រះអង្គសំដែងអំពីផ្លូវបរមត្ថរបស់ព្រះពុទ្ធជាម្ចាស់ មាន ២៤ គម្ពីរ ពន្យល់អំពីចិត្ត, ចេតសិក, រូប និង និព្វាន ។

ប្រ. ពុទ្ធសាសនិកជនទាំងឡាយ នឹងគិតស្មានថា គម្ពីរទាំងឡាយនេះ គឺវិសេសទេពណាមួយបានទ្រទ្រង់ទុក ឬប្រកាសប្រាប់ ឬ ?

វិ. ទេ, ដែលគេជឿគោរពដូច្នេះ មកពីក្នុងគម្ពីរទាំងនេះ មានសំដែងអំពីធម៌វិន័យ ដែលបុគ្គលរៀនសូត្រចេះចាំប្រតិបត្តិតាម ហើយអាចផ្ដាច់បង់នូវសង្សារទុក្ខបាន ។

ប្រ. នៅក្នុងផ្លូវគម្ពីរព្រះត្រៃបិដកទាំងមូលនេះ មានពាក្យប៉ុន្មានម៉ាត់?

វិ. តាមលោកបណ្ឌិតឈ្មោះ ( de DR. Rhys Davids ) រីសដាវិឌស៍ ថាមាន ១៧៥២.០០ ម៉ាត់ ។

ប្រ. គម្ពីរទាំងនេះ លោករៀបរៀងឡើងពីកាលណា ?

វិ. ពីក្នុងរវាង ៨០ ឆ្នាំមុនគ្រិស្តសករាជ ក្នុងរាជព្រះចៅលង្កាទ្វីប ព្រះនាមវដ្ដគាមិនី, ៣៣០ ឆ្នាំក្រោយព្រះពុទ្ធជាម្ចាស់បរិនិព្វាន ។

ប្រ. គេនឹងអាចជឿបានថា ធម៌ទេសនារបស់ព្រះពុទ្ធជាម្ចាស់នៅគង់ទ្រង់មកដល់យើងទាំងអស់ ឬ ?

វិ. ទេ, ព្រោះថា ប្រហែលជារវាង ៤៥ ឆ្នាំ ដែលព្រះអង្គត្រាស់ទេសនា ព្រះអង្គបានសំដែង ជាច្រើនរយដងណាស់ហើយ

ប្រហែលត្រូវការរឹបជាន់បំផ្លាញ កាលគ្រាចម្បាំង និងសេចក្ដីផ្លាញផ្លាល
របស់សត្រូវ ធ្វើឲ្យវិនាសអស់ជាច្រើនហើយ ។

ប្រ. ពពួកពុទ្ធមាមកៈទាំងឡាយនឹងសំគាល់ថា ព្រះពុទ្ធជាម្ចាស់
ជាបុគ្គលប្រកបព្រមដោយឥទ្ធិឫទ្ធិ និងគុណធម៌អាចជួយដោះទុក្ខទោស
របស់យើងបាន ឬដូចម្ដេច ?

វិ: ពុំមែនដូច្នោះឡើយ, បុគ្គលនីមួយ ៗ ត្រូវតែរកឧបាយ
ដោះទោសទុក្ខខ្លួនឯង ព្រោះត្រូវតែវិលកើតវិលស្លាប់រាប់គ្រាពុំបាន ហើយ
ត្រូវជាចំណីនៃអវិជ្ជា និងជាខ្ញុំនៃតណ្ហារហូតទាល់តែបានសម្រេចមគ្គផល
ដល់នូវទីបំផុតជាតិ ។

ប្រ. ចុះព្រះពុទ្ធជាម្ចាស់ មានឧបការគុណដូចម្ដេច ចំពោះយើង
រាល់គ្នា ?

វិ. ព្រះអង្គជាព្រះអគ្គនាយក យ៉ាងចំណានវិសេសបំផុត ដែល
រកឃើញផ្លូវនាំឲ្យរលាស់រួចស្រឡះចាកទុក្ខ ហើយបានបង្ហាញពន្យល់
ដល់សត្វលោក, ទ្រង់បានចង្អុលប្រាប់ហេតុដែលបង្កើតទុក្ខ ដល់សត្វ
លោក និងនូវផ្លូវឯកតែមួយ, ដែលអាចឲ្យជាសះស្បើយបាន ព្រះអង្គ
ជាមគ្គនាយក បង្ហាញផ្លូវ ត្រាស់ប្រាប់ឧបាយស្រោចស្រង់ ឲ្យចៀស
វាងគ្រោះថ្នាក់ ឧបទ្រពអន្តរាយទាំងពួង ដូចបុគ្គលដែលជួយយកអាយុ
ជីវិតមនុស្សម្នាក់ ដោយដឹកនាំចម្លងតាមស្ពានតូចចង្អៀតនៃជ្រោះជ្រៅមួយ
យ៉ាងនោះ ។

បុ. បើយើងល្បងឲ្យឈ្មោះធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ជាពាក្យមួយម៉ាត់ តើនឹងជាដូចម្តេច ទើបសម ?

វិ. ជា "យត្តិធម៌"

បុ. ហេតុដូចម្តេច ?

វិ. ព្រោះធម៌វិន័យនេះ ប្រដៅថា បុគ្គលនីមួយ ៗ ត្រូវទទួលកម្រៃផលល្អឬអាក្រក់ ដែលខ្លួនត្រូវបាន មិនលើសមិនខ្វះអំពីយថាកម្មរបស់ខ្លួន ។ ការធ្វើល្អឬអាក្រក់ ទោះបីតិចតួចក្តី ស្ងាត់កំបាំងក្តី ក៏ពុំអាចគេចចៀសឲ្យផុតពីតុល្យភាពនៃកម្មឡើយ ។

បុ. កម្មនោះ ជាអ្វី ? (១)

វិ. ជាហេតុដែលគេធ្វើ ដោយមានពាក់ទងដល់មនោទ្វារ និងកាយទ្វារឬទ្វារដទៃ ៗ ពុទ្ធមាមកជនទាំងឡាយ តែងមិនពោលសរសើរចំពោះកិច្ចរបស់មនុស្ស ថាជាអស្ចារ្យទេ, បុគ្គលសាបព្រោះបែបណា ត្រូវបានផលបែបនោះវិញ ជាដាច់ខាត ។

បុ. អ្វីជាអត្ថរសរបស់ព្រះពុទ្ធសាសនា ?

វិ. គឺការបណ្តុះសេចក្តីល្អផ្ទាល់ខ្លួន និងមេត្រីចិត្តស្នេហាសត្វលោកទូទៅ ។

---

១ កម្មគឺអំពើល្អអាក្រក់គ្រប់យ៉ាងនៃបុគ្គលនីមួយៗ, ព្រះធម៌ដែលសំដែងអំពីហេតុនិងផល ហៅថា បដិច្ចសមុប្បាទធម៌ មានក្នុងគម្ពីរអង្គុត្តរនិកាយ ព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា "សត្វលោកមានកម្មជារបស់ខ្លួន ជាកេរ្តិ៍មរតក ជាដែនកើត ជាផៅពង្ស ជាទីជ្រកប្រាស្រ័យ" ។

ប្រ. ធម៌វិន័យត្រង់ណាដែលស្ទួយតំកើងព្រះពុទ្ធសាសនា ឲ្យបានខ្ពង់ខ្ពស់ ជាងសាសនាទាំងអស់ ក្នុងលោកនេះ ?

ឆ្លើ. គឺធម៌ មេត្តា "សេចក្ដីមេត្រីរាប់អាន", ឯពាក្យដ៏សំខាន់ជាគ្រឿងបង្ហាញឲ្យឃើញជាក់ស្ដែងនោះគឺ ( មេត្តិយ ) ដែលជានាមរបស់ព្រះពុទ្ធមួយអង្គក្នុងអនាគតកាល ។

ប្រ. គឺកាលព្រះអង្គគង់នៅក្រោមដើមពោធិព្រឹក្ស ឬ ដែលទ្រង់បានត្រាស់ដឹងនូវធម៌ដែលអ្នកទើបនឹងអធិប្បាយមកនេះឬ ?

ឆ្លើ. មែនពិតហើយ គឺព្រះអង្គពិចារណាតាមផ្លូវនេះ ដូចគេឃើញមាននៅក្នុងគម្ពីរព្រះពុទ្ធសាសនាជាច្រើនកន្លែង ។ ព្រះអង្គបានត្រាស់ដឹងនូវព្រះធម៌ទាំងពួង ដែលរាប់ថា ជាព្រះពុទ្ធសាសនា ដោយប្រពៃចំពោះព្រះអង្គក្នុងពេលនោះ ។

ប្រ. ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅនាទីដើមពោធិព្រឹក្សចំនួនប៉ុន្មានថ្ងៃ ?

ឆ្លើ. សែសិបប្រាំបួនថ្ងៃ ។

ប្រ. ធម្មទេសនា ដែលព្រះអង្គត្រាស់សំដែងជាដំបូងបង្អស់ ចំពោះបញ្ចវគ្គិយភិក្ខុ មាននាមថាដូចម្ដេច ?

ឆ្លើ. ថា "ធម្មចក្កប្បវត្តនសូត្រ" គឺ "សូត្រដែលសំដែងពន្យល់អំពីផ្លូវប្រតិបត្តិក្នុងព្រះពុទ្ធសាសនា" ។

ប្រ. សូត្រនេះ មានសេចក្ដីអធិប្បាយដូចម្ដេចខ្លះ ?

វិ. មានអធិប្បាយអំពីអរិយសច្ចទាំង ៤ និងអដ្ឋង្គិកមគ្គ, ព្រះអង្គត្រិះរិះរៀលការប្រព្រឹត្តរបស់ពួកតាបស ដែលជាអត្តកិលមថានុយោគ (ធ្វើឲ្យលំបាកខ្លួនហួសប្រមាណ) និងការស្វែងរកត្រេកត្រអាលក្នុងកាមទាំងឡាយដែលហៅថា "កាមសុខល្លិកានុយោគ", ព្រះអង្គត្រាស់សរសើរអំពីមគ្គប្រកបដោយអង្គប្រាំបី ថាជា "មជ្ឈិមាបដិបទា" គឺផ្លូវនៃសេចក្ដីប្រតិបត្តិជាកណ្ដាល ។

បុ. ព្រះបរមគ្រូ ទ្រង់ទទួលយល់ព្រម នូវការបូជាចំពោះទេវរូបទាំងឡាយឬទេ ?

វិ. ទេ, ព្រះអង្គបញ្ញត្តិហាមដោយដាច់ខាត ទ្រង់ត្រិះរិះរៀលការគោរពទេវរូប, អារក្ស, អ្នកតា និងដើមពោធិ៍ជាដើម, ការគោរពជាខាងក្រៅព្រះពុទ្ធសាសនា មិននាំមកនូវសេចក្ដីក្សេមឡើយ, បុគ្គលដែលបានដឹងហើយ ត្រូវតែលះបង់ ។

បុ. បើដូច្នោះ ពួកពុទ្ធសាសនិកជន មិនធ្វើការសំពះគោរពព្រះបដិមា ព្រះពុទ្ធរូប ព្រះសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ ឬស្តូបព្រះចេតិយដែលតម្កល់នូវវត្ថុទាំងនោះទេ ឬ ?

វិ. ធ្វើដែរ, ប៉ុន្តែមិនមែនសំពះដោយតាំងចិត្តគោរព ចំពោះតែរូបនោះទេ ។

បុ. ចុះខុសគ្នាដូចម្ដេច ?

វិ. មនុស្សក្រៅព្រះពុទ្ធសាសនា តែងសំគាល់កាន់យកនូវរូបទាំងនេះ ជាជាតំណាងអង្គទេវតាឥន្ទ្រព្រហ្មទាំងឡាយ ៗ អ្នកបូជាតែងកំណត់ទុកក្នុងចិត្ត ជារូបដែលខ្លួនគោរពនេះ ជាការបែងភាគនៃទេវរូបដោយជាក់ស្តែង ។

បុ. ចុះអ្នកកាន់ព្រះពុទ្ធសាសនា គិតដូចម្តេចវិញ ?

វិ. អ្នកកាន់ព្រះពុទ្ធសាសនា គោរពបូជាព្រះពុទ្ធរូបនិងវត្ថុឯទៀតនោះ គ្រាន់តែជាទីរលឹកដល់ព្រះបរមសម្មាសម្ពុទ្ធ ដែលជាមហាបុរសប្រកបព្រម ដោយសេចក្តីករុណាអាណិតសត្វក្នុងកប្បនេះ, មនុស្សគ្រប់ជាតិគ្រប់សាសន៍ ដែលថែរក្សាបូជាធាតុឬវត្ថុដែលគួរគោរពទាំងនោះ ព្រោះមានសេចក្តីសម្គាល់ទុកដូចជារបស់ដ៏ថ្លៃថ្លាប្រពៃ ដោយប្រការផ្សេង ៗ ។ បុគ្គលទាំងពួងដែលបានជួបប្រទះនឹងទុក្ខលំបាក គប្បីស្រឡាញ់ហើយគោរពកោតខ្លាចព្រះបរមសម្ពុទ្ធជាងសាស្តាឯទៀត ។

បុ. ចុះព្រះអង្គបានប្រទានពុទ្ធានុញ្ញាតក្នុងរឿងនេះឬទេ ។

វិ. បានប្រទានពិតប្រាកដ, ក្នុងមហាបរិនិព្វានសូត្រ ព្រះអង្គទ្រង់ត្រាស់សំដែងថា បុគ្គលលោះសះចេញចាកទុក្ខបានតែដោយការដើរតាមផ្លូវអដ្ឋង្គិកមគ្គដែលហៅថា «បដិបត្តិបូជា» ពុំមែនដោយការបូជាខាងក្រៅគឺអាមិសបូជា ឬដោយការគោរពកោតក្រែងចំពោះព្រះអង្គឬសាស្តារូបដទៃណាមួយទេ ។

ប្ុ. ព្រះពុទ្ធជាម្ចាស់ព្រះអង្គទុកដាក់ការបូជាដូចម្តេច ?

វិ. ព្រះអង្គតិះតិះដៀលតាំងអំពីដំបូង នូវពិធីបូជានិងពិធីដទៃក្រៅទៀត ដែលជាហេតុនាំឲ្យងងឹតវង្វេង និងនាំឲ្យជំពាក់ចិត្តចំពោះរូបដែលគ្មានវិញ្ញាណ ។

ប្ុ. ព្រះអង្គយល់ព្រមតាមអំពើទាំងនេះឬទេ ?

វិ. ទ្រង់ត្រាស់បដិសេធរឿងទម្លាប់នេះ ដោយធម៌ទេសនាជាច្រើនកន្លែង, ព្រះអង្គបានបញ្ញត្តសិក្ខាបទ ហាមប្រាមភិក្ខុទាំងឡាយដែលធ្វើឲ្យខាតពេលវេលា ដោយការពិគ្រោះជជែកគ្នាពីរឿងកិច្ចការឥតប្រយោជន៍ និងពីល្បិចឧបាយផ្លូវបរមត្ថនាំឲ្យថយកម្លាំងសតិបញ្ញា ។

ប្ុ. មន្ត ស្នេហ៍ អាគម ជោគជ័យ ឫក្សពារពេលាល្អ និងការលៀងអារក្ស ទាំងនេះ មានក្នុងព្រះពុទ្ធសាសនាឬទេ ?

វិ. ទេ, ជាទំនាស់នឹងព្រះពុទ្ធសាសនាធំណាស់ គឺជាលទ្ធិដទៃខាងក្រៅទេ ។ ក្នុងព្រហ្មជាលសូត្រ ព្រះអង្គបានត្រាស់ពន្យល់ដោយពិស្តារអំពីការជឿលទ្ធិទាំងនេះ និងជំនឿដទៃបែបនេះថា ជាជំនឿក្រៅសាសនា ជាជំនឿដ៏ថោកទាបប្រាសចាកសេចក្ដីពិត (១) ។

---

១ សេចក្ដីប្រឫកប្រឫបល់លទ្ធិនិងទំនៀមទម្លាប់ទាំងនេះ នាំឲ្យសៅហ្មងដល់ព្រះពុទ្ធសាសនាខ្លាំងណាស់ ។ មានកិច្ចខ្លះ ជាការពិតមែនហើយ អាចនឹងពន្យល់ដោយផ្លូវវិជ្ជាសាស្ត្របាន, ការកាន់បែបនេះ កាលបើប្រព្រឹត្តធ្វើដោយអសប្បុរស អាចនឹងនាំមកនូវអកុសលចិត្ត តែបើប្រើវេទមន្តនេះ ជាប្រយោជន៍ដល់អ្នកដទៃ មានការមើលជម្ងឺនិងជួយជីវិតជាដើម ព្រះសម្មាសម្ពុទ្ធក៏ទ្រង់អនុញ្ញាតឲ្យប្រើបានខ្លះដែរ ។

ប្រ. ព្រះពុទ្ធសាសនា មានសេចក្តីប្លែក ជាទំនាស់នឹងសាសនាឬលទ្ធិដទៃ ដូចម្តេចខ្លះ ? ចូរអ្នកអធិប្បាយមកមើល !

ឆ្លើ. ព្រះពុទ្ធសាសនាប្រដៅប្លែក អំពីសាសនាដទៃ គឺឲ្យធ្វើចិត្តសុភាពសប្បុរសបំផុត ឥតមានព្រះជាម្ចាស់សួគ៌អ្នកកសាងលោកទេ មានការយកជាតិកំណើតជាលំដាប់លំដោយ, មិនទទួលជឿលទ្ធិដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន, ពុំជឿថា មានតួវិញ្ញាណដទៃឋិតនៅក្រៅអំពីខ្លួនជានិច្ចនោះទេ. សេចក្តីល្អអាក្រក់មានសម្រាប់បុគ្គលអ្នកប្រព្រឹត្តពល់រូប, ធ្វើការពិចារណាឲ្យរួចចាកទុក្ខទាំងពួង ដោយឥតមាននរណាទទួលជួស, សេចក្តីបរិសុទ្ធិនិងមិនបរិសុទ្ធិ មានចំពោះខ្លួនឯង ៗ គ្មានពិធីបូជាបន់ស្រន់អង្វរសូមពរ ឬក៏សូមឲ្យជ្រះបាបទេ, គ្មានអ្នកដែលជួយអង្វររំដោះបាបឡើយ ។ បុគ្គលអាចបានដល់នូវព្រះនិព្វាន ក្នុងលោកនេះ និងក្នុងបច្ចុប្បន្នជាតិនេះ ដោយការចិញ្ចឹមជីវិតជាបរិសុទ្ធផ្លូវផងប្រកបព្រមដោយបញ្ញា ប្រាជ្ញាប្រយោជន៍និងសេចក្តីសុខចំរើន ដើម្បីអ្នកដទៃផង ដើម្បីខ្លួនផង ផ្សាយមេត្តាចិត្តចំពោះសត្វទាំងអស់ ។

ប្រ. ចូរអ្នកញែកពិធីនៃវិបស្សនាធុរៈទាំងពីរប្រការ ដែលជាផ្លូវនាំឲ្យកំចាត់បង់នូវតណ្ហា ហើយដល់នូវវិជ្ជានោះមកមើល ?

ឆ្លើ គឺសមថ: និងវិបស្សនា, ដែលអាចនឹងបន្ថយនូវតណ្ហាបានដោយបួសជាបព្វជិត ហើយខំព្យាយាមសង្រួមនូវឥន្ទ្រិយទាំងឡាយ

ដោយយកកម្មដ្ឋានណាមួយមកជាអារម្មណ៍, ដល់ភាពជាបុគ្គលវិសេសនោះ ដោយការរំពឹងពិចារណា ។ របៀបចំរើនវិធីទាំងពីរប្រការនេះមាន ៤ យ៉ាង តែពុំបាននាំមកអធិប្បាយក្នុងទីនេះទេ ព្រោះជាការឥតប្រយោជន៍ (បើចង់ច្បាស់សូមមើលក្នុងសមាធិនិទ្ទេស) ។

ប្ញ. មគ្គទាំង ៤ ប្រការ ដែលព្រះអរិយបុគ្គលបានសំរេចជាលំដាប់នោះ គឺអ្វីខ្លះ ?

វិ. ១. សោតាបត្តិមគ្គ គឺការឃើញច្បាស់នូវអរិយសច្ចទាំង ៤ ជាផ្លូវនាំទៅកាន់ព្រះនិព្វាន ។

២- សកិទាគាមិមគ្គ ជាផ្លូវបង្ក្រាបនូវសេចក្ដីស្រើបស្រាល, សេចក្ដីព្យាបាទ និងសេចក្ដីវង្វេង ។ អ្នកបាននូវមគ្គនេះ នឹងមកកាន់ភពនេះតែមួយជាតិទៀតប៉ុណ្ណោះ ។

៣- អនាគាមិមគ្គ ជាថ្នាក់ដែលបុគ្គលអាចឈ្នះសឹកសត្រូវ គឺកិលេសគ្រប់យ៉ាង រហូតដល់គ្មានត្រឡប់មកកាន់ភពនេះទៀតឡើយ ។

៤- អរហត្តមគ្គ ជាថ្នាក់លោកុត្តរចិត្ត ពុំដែលគ្រាន់តែរួចផុតពាក កិរិយាកើតក្នុងភពទេ គឺដល់នូវថ្នាក់ជាន់ខ្ពស់បំផុត មានកិរិយាស្ងត់ស្ងប់ អស់កិលេសតណ្ហា មានមេត្តាទៅគ្មានទីបំផុត ចំពោះមនុស្សល្ងង់ខ្លៅ ក្រីក្រដល់នូវទុក្ខលំបាក គឺមានតែសេចក្ដីករុណា ស្រឡាញ់ អាណិតសត្វទាំងអស់ ឥតរើសមុខ ។ (តមានត)

# ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

## ពាក្យរបស់អ្នករៀបរៀង

ករណីយកិច្ចរបស់ពុទ្ធបរិស័ទនេះ មិនមែនជាយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំអ្នករៀបរៀងទេ គឺជាយោបល់របស់លោកអ្នកប្រាជ្ញពុទ្ធសាសនា ដែលលោកបានរៀបរៀងទុកជាយូរឆ្នាំហើយ ៗ ខ្ញុំបានដកស្រង់យកចំពោះតែត្រង់គោលធម៌ជាសារៈសំខាន់បំផុតអំពីច្បាប់របស់លោកនោះ គឺច្បាប់ពុទ្ធសាសនាថៃ, ច្បាប់អរិយសច្ចកថាខ្មែរ និងច្បាប់ពោធិបក្ខិយធម៌ខ្មែរ មករៀបរៀងបញ្ចូលគ្នាជាសៀវភៅ ១ ក្បាលនេះ សន្មតឈ្មោះថា ករណីយកិច្ចរបស់ពុទ្ធបរិស័ទ លុះរៀបរៀងចប់ហើយ ខ្ញុំបានប្រគេនព្រះពុទ្ធាចារ្យ កុល-ទេស ពជាគណៈវត្តបទុមវតី សូមជួយពិនិត្យផង លោកក៏យកព្រះទ័យទុកដាក់ជួយពិនិត្យដោយហ្មត់ចត់ យល់ឃើញត្រឹមត្រូវល្មមយកជាផ្លូវប្រតិបត្តិបានហើយ ៗ

សូមលោកអ្នកប្រាជ្ញពុទ្ធសាសនាទាំងឡាយ អភ័យទោសចំពោះខ្លួនខ្ញុំ ក្រែងមានសេចក្ដីភ្លាត់ខុសឆ្គាំឆ្គង ឬប្រើពាក្យពេចន៍មិនសមរម្យ សូមមេត្តាប្រណីជួយកែតម្រង់ឲ្យបានផង ព្រោះខ្ញុំគ្មានចេតនាប៉ុនប៉ងនឹង

បង្ខុសទេ ចង់ឲ្យតែបានត្រឹមត្រូវណាស់ ប៉ុន្តែគង់នៅមានក្លាត់ខុសខ្លះ ជាមិនខាន ព្រោះតាមធម្មតាសតិបញ្ញារបស់ខ្ញុំជាបុថុជ្ជន នឹងចៀសវាងឲ្យផុតពីការភ្លាំងភ្លេចឬកាន់ប្រឡំមិនបានឡើយ ។

ប៊ូ ប៉ូ បុគ្គលិកក្នុងក្រុមពុទ្ធសាសនបណ្ឌិត្យ

ក្រសួងធម្មការ ក្រុងភ្នំពេញ

ព.ស. ២៤៩៨ គ.ស ១៩៥៥

# ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

## ពាក្យបរិយាយខាងដើម

មនុស្សយើងកើតមកហើយ មិនថាអ្នកមានឬអ្នកក្រ អ្នកខ្ពង់ខ្ពស់ ឬអ្នកថោកទាបទេ សុទ្ធតែស្អប់ខ្ពើមទុក្ខ ចង់បានសុខដូចគ្នាទាំងអស់ គ្មានអ្នកណាចង់បានទុក្ខស្រឡាញ់ទុក្ខសោះ កុំថាដល់ទៅខ្លួនឯងទុក្ខ សូម្បីគ្រាន់តែពាក្យថាទុក្ខ ៗ ក៏មិនចង់ឲ្យឮផង ៗ ហេតុនេះ បានជាមនុស្សគ្រប់រូបខំគិតរកឧបាយ ដើម្បីធ្វើឲ្យខ្លួនផុតពីទុក្ខទោស ឲ្យខ្លួនបានសុខដោយវិធីផ្សេង ៗ គ្នា, អ្នកខ្លះខំធ្វើការងារចិញ្ចឹមជីវិតត្រឹមត្រូវតាមផ្លូវលោកផ្លូវធម៌ក៏មាន អ្នកខ្លះខំធ្វើការងារទុច្ចរិត ខុសផ្លូវលោកផ្លូវធម៌ក៏មាន សូម្បីនឿយហត់យ៉ាងណាក៏មិនរួញរាក ទាំងនេះ ក៏ព្រោះតែគេចង់ឲ្យខ្លួនបានសុខតែម្យ៉ាងប៉ុណ្ណោះ ៗ ប៉ុន្តែអ្នកស្វែងរកសុខនោះ មិនមែនចេះតែបានសុខគ្រប់រូបទេ ៗ បើអ្នកណាធ្វើត្រូវតាមផ្លូវឲ្យកើតសុខ អ្នកនោះទើបបានសុខដូចចិត្តប្រាថ្នា ៗ បើអ្នកណាធ្វើខុសផ្លូវឲ្យកើតសុខ អ្នកនោះមិនបានសុខទេ ត្រឡប់ជាបានទុក្ខផ្ទុយនឹងចំណង់ខ្លួនទៅវិញ ព្រោះខ្លួនមិនដឹងដើមហេតុដែលឲ្យកើតសុខទុក្ខសោះ ៗ

តាមពិត សុខទុក្ខ ជាផលរបស់កម្ម ៗ ជាហេតុ ៗ បើកម្មល្អជាហេតុ តែងបានសុខជាផល, បើកម្មអាក្រក់ជាហេតុ តែងបានទុក្ខជាផល ៗ សុខទុក្ខនឹងកើតមានឡើងដោយសារតែខ្លួនឯងជាអ្នក

ធ្វើ អ្នកណាធ្វើល្អ អ្នកនោះបានសុខ អ្នកណាធ្វើអាក្រក់ អ្នកនោះបានទុក្ខ ។ សុខទុក្ខនេះបែករំលែកឲ្យគ្នាមិនបានទេ បើគ្រាន់តែពន្យល់ប្រាប់ដើមហេតុឲ្យកើតសុខទុក្ខដល់គ្នាបាន ដូចជាប្រាប់គ្នាថា បើអ្នកចង់ដឹងត្រជាក់ត្រូវអ្នកងូតទឹក បើអ្នកចង់ដឹងក្តៅ ត្រូវអ្នកហាលថ្ងៃឬអាំងភ្លើងជាដើម ។ ត្រជាក់និងក្តៅមានចំពោះតែខ្លួនអ្នកងូតទឹកឬហាលថ្ងៃប៉ុណ្ណោះ ចំណែកអ្នកប្រាប់មិនត្រជាក់ឬក្តៅទេ, សុខទុក្ខក៏ដូចជាត្រជាក់និងក្តៅនេះដែរ ។

លទ្ធិសាសនាទាំងពួង ដែលកើតមានឡើងក្នុងលោក ក៏កើតមកអំពីគំនិតរបស់លោកជាសាស្តានោះ ៗ គិតចៀសវាងទុក្ខទោសហើយស្វែងរកសុខតែម្យ៉ាងប៉ុណ្ណោះ ។ ប៉ុន្តែសាសនាទាំងនោះ មានពាក្យប្រៀនប្រដៅប្លែក ៗ គ្នា ទៅតាមគំនិតយោបល់សាស្តានោះ ៗ ។

ចំពោះព្រះពុទ្ធសាសនា មានពាក្យប្រៀនប្រដៅ អំពីផ្លូវចៀសវាងទុក្ខទោសនិងផ្លូវធ្វើឲ្យកើតសុខ ក្នុងលោកនេះនិងលោកខាងមុខ ដោយបរិយាយដ៏ជ្រាលជ្រៅល្អិតសុខុមណាស់ ដូចកាលព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងថ្មី ៗ ជាដំបូងបំផុត ទ្រង់ប្រដៅសាវ័កឲ្យស្គាល់ទុក្ខ, ឲ្យស្គាល់ហេតុកើតទុក្ខ, ឲ្យស្គាល់ទីរលត់ទុក្ខ និងឲ្យស្គាល់ផ្លូវប្រតិបត្តិឲ្យដល់ទីរលត់ទុក្ខ ។ រួមឲ្យខ្លីថា ព្រះពុទ្ធអង្គទ្រង់ប្រាប់ឲ្យស្គាល់ហេតុឲ្យកើតសុខទុក្ខមុនរឿងផ្សេង ៗ ។

ហេតុនេះមនុស្សគ្រប់រូបទើបត្រូវកាន់សាសនាទុកជាគោលសម្រាប់

គ្រប់គ្រងជីវិតរបស់ខ្លួនឲ្យប្រាសចាកទុក្ខ ឲ្យបានសុខស្រួលពល់ថ្ងៃ ដូចជាកាន់ច្បាប់សម្រាប់ស្រុកទេសដែរ ។ ប៉ុន្តែ អ្នកណាកាន់សាសនាអ្វី អ្នកនោះត្រូវតែខំគិតជ្រេញជ្រាលរកហេតុផលក្នុងសាសនានោះ ឲ្យឃើញពិតប្រាកដដោយប្រាជ្ញារបស់ខ្លួន កុំចេះតែកាន់សាសនាដោយសារគេបង្ខំ, ដោយខ្លាចគេ ឬក៏ដោយអៀនខ្មាស់គេ ។

ក្នុងសៀវភៅនេះ ខ្ញុំអធិប្បាយចំពោះតែវិធីប្រតិបត្តិធម៌ក្នុងព្រះពុទ្ធ-សាសនាមួយប៉ុណ្ណោះ, សាសនាឯទៀតលើកទុក ។

សូមលោកអ្នកប្រាជ្ញពុទ្ធសាសនាជួយវិនិច្ឆ័យប្រស្នា ៥ ប្រការតទៅនេះផង :

១ ព្រះពុទ្ធអង្គជាអ្នកបង្កើតលោកឬទេ ?

២- ព្រះពុទ្ធអង្គជាអ្នកដាក់ទោសទណ្ឌកម្ម ដល់ពួកសាវ័កដែលល្មើសពុទ្ធបញ្ញត្តិឬទេ ?

៣ ព្រះពុទ្ធអង្គជាអ្នកទទួលទុក្ខទោសជួសពួកសាវ័កឬទេ ?

៤- ព្រះពុទ្ធអង្គជាអ្នកទទួលពាក្យអង្វរករបន់ស្រន់របស់ពួកសាវ័កឬទេ ?

៥- ព្រះពុទ្ធអង្គជាម្ចាស់កម្មផលវែនឬទេ ?

ប្រស្នាទាំង ៥ ប្រការនេះ សូមអស់លោកអ្នកសង្កេតមើលសេចក្តីក្នុងផ្ទៃរឿងនេះចុះ កាលបើមើលចប់ហើយ មុខជានឹងបានយល់ពាក្យឆ្លើយប្រស្នាទាំង ៥ ប្រការនោះដោយច្បាស់លាស់មិនខាន ។

# ពុទ្ធបរិស័ទ

ពាក្យ " ពុទ្ធបរិស័ទ " ចែកជា ២ បទគឺ ពុទ្ធៈ ១ បរិស័ទ ១ ពុទ្ធៈ ជាព្រះនាមនៃព្រះសមណគោតម ដែលជាម្ចាស់អ្នកបង្កើតសាសនា (១) ។ បរិស័ទ ជាឈ្មោះពួកជនដែលកាន់សាសនាត្រូវគ្នា ដូចជាពួកពុទ្ធបរិស័ទ, ពួកគ្រិស្តបរិស័ទ, ពួកឥស្លាមបរិស័ទជាដើម ។ ពុទ្ធៈ និង បរិស័ទ ភ្ជាប់គ្នាជា ពុទ្ធបរិស័ទ ប្រែថា " បរិស័ទរបស់ព្រះពុទ្ធ " ឬថា " ពួកជនអ្នកកាន់ពុទ្ធសាសនា គឺជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅនៃព្រះពុទ្ធ " ។ ពួកពុទ្ធបរិស័ទទាំងអស់នឹងផ្លាស់ឈ្មោះហៅថា " ពុទ្ធសាសនិកជន " ឬ " ពុទ្ធមាមកៈ " ឬ " ពុទ្ធសាវក " យ៉ាងនេះវិញ ក៏បាន គឺសំដៅយកពួកជនអ្នកកាន់ពុទ្ធសាសនាដូចគ្នា បើហៅឲ្យខ្លីថា " ពួកពុទ្ធសាសន៍ " ។

មនុស្សដែលបាននាមថា ពុទ្ធបរិស័ទ នោះគេមិនបានកំណត់ថាជាជាតិអ្វីទេ មិនកំណត់ថា ប្រុស ឬ ស្រី ក្មេង ឬ ចាស់ទេ ឲ្យតែអ្នកណាប្រព្រឹត្តត្រឹមត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធហើយ អ្នកនោះក៏បាននាមថា " ពុទ្ធបរិស័ទ " ដូចគ្នាទាំងអស់ ។ ពុទ្ធបរិស័ទមាន ២ ពួក គឺគ្រហស្ថ ១ ពួក បព្វជិត ១ ពួក ។

---

១ មានសេចក្តីពិស្តារក្នុងច្បាប់ពុទ្ធប្រវត្តិ ឬគម្ពីរបឋមសម្ពោធិ ។

អ្នកដែលមានចិត្តចង់តាំងខ្លួនជាពុទ្ធបរិស័ទ ត្រូវតែសិក្សាឲ្យចេះដឹងនូវ :

## ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

ខាងពួកគ្រហស្ថ (១) មុនដំបូងត្រូវតាំងចិត្តជឿកម្មផល និងជឿគុណព្រះរតនត្រ័យ ហើយបន្ទឹកាចាស្កាលាទោសរួចប្រកាសប្តេជ្ញាខ្លួនថាជាអ្នកគោរពបអាងកាន់ពុទ្ធសាសនា នៅទីចំពោះព្រះភក្ត្រព្រះពុទ្ធរូប ឬចំពោះព្រះភក្ត្រភិក្ខុ ១ រូប ២ រូបឡើងទៅ នៅទីកន្លែងណាក៏បាន ។ លុះធ្វើកិច្ចទាំង ២ យ៉ាងខាងដើមនេះស្រេចហើយ ត្រូវសមាទានសីល៥ ឬសីល ៨ និងប្រព្រឹត្តតាមធម៌វិន័យសម្រាប់គ្រហស្ថជាច្រើនប្រការទៀត ។ ពុទ្ធបរិស័ទខាងពួកគ្រហស្ថ បើប្រុសហៅ "ឧបាសក" បើស្រីហៅ "ឧបាសិកា" គឺអ្នកតាំងចិត្តយកព្រះរតនត្រ័យជាទីពឹងជាទីរលឹក ។

ករណីយកិច្ចខាងពួកបព្វជិត(២) មុនដំបូង អ្នកដែលចង់បួស ត្រូវចូលទៅរកលោកគ្រូអាចារ្យ ឬព្រះឧបជ្ឈាយ៍ សូមរៀនសូត្រធម៌វិន័យសម្រាប់អ្នកបួស, បានចេះដឹងល្មមបមគួរហើយ ក៏រកត្រៃចីវរបរិក្ខារសម្រាប់អ្នកបួស, លុះរកបានសព្វគ្រប់ហើយ ចូលទៅសូមបួសក្នុងសំណាក់លោកគ្រូអាចារ្យ, កាលបួសរួចហើយបើប្រុសហៅ "សាមណេរ" ឬ "ភិក្ខុ" បើស្រីហៅ "សាមណេរី" ឬ "ភិក្ខុនី" ។

---

១ ករណីយកិច្ចខាងគ្រហស្ថ មានសេចក្ដីពិស្ដារក្នុងច្បាប់ឧបោសថកថា ឬគិហិបដិបត្តិ ។

២ ករណីយកិច្ចខាងអ្នកបួសមានសេចក្ដីពិស្ដារក្នុងច្បាប់បុព្វសិក្ខាឬវិនយវណ្ណនាឬបព្វជ្ជាខន្ធក។

អ្នកដែលបានទាមបញ្ញត្តិថា ជា " ពុទ្ធបរិស័ទ " ហើយ គួរណាស់តែខំសិក្សារឿងរ៉ាវ នៃព្រះពុទ្ធជាម្ចាស់យ៉ាងល្អិតតទៅទៀតដើម្បីឲ្យបានយល់ច្បាស់លាស់អំពី ៖

## ដើមកំណើតនៃព្រះពុទ្ធជាអ្នកបង្កើតសាសនា

ព្រះពុទ្ធជាបរមគ្រូនៃយើង ជាមនុស្សអស្ចារ្យ ទ្រង់សម្ភពក្នុងសក្យត្រកូល ព្រះជាតិជាក្សត្រ បានឡើងសោយរាជសម្បត្តិក្នុងព្រះជន្ម ១៦ វស្សា ទ្រង់ពិចារណាឃើញសេចក្ដីទុក្ខព្រួយរបស់ព្រះអង្គនិងមនុស្សសត្វដទៃ ទើបលះបង់ចោលរាជសម្បត្តិចេញ ទ្រង់ព្រះផ្នួសក្នុងព្រះជន្ម ២៩ ឆ្នាំ គង់ក្នុងព្រៃខំត្រិះរិះរកធម៌ជាគ្រឿងរំលត់ទុក្ខព្រួយនោះ, ក្នុងព្រះជន្ម ៣៥ ឆ្នាំ មានព្រះនាមថ្មីថា " ពុទ្ធៈ មានព្រះនាមតាម ព្រះគោត្រថា " ព្រះពុទ្ធសមណគោតម " ឬ " ព្រះពុទ្ធសក្យមុនីគោតម " ព្រះអង្គបរិនិព្វានក្នុងព្រះជន្ម ៨០ គត់ (១) ។

ពួកពុទ្ធបរិស័ទ កាលបើបានចេះដឹងរឿងរ៉ាវនៃព្រះពុទ្ធហើយ គ្រូវតែសិក្សាឲ្យយល់ច្បាស់លាស់អំពី ៖

## រូបរាងរបស់ពុទ្ធសាសនា

ពាក្យថា " ពុទ្ធសាសនា " ចែកជា ២ បទ គឺពុទ្ធៈ ១ សាសនា ១ ។ ពុទ្ធៈ ជាព្រះនាមនៃព្រះបរមសាស្ដាអ្នកផ្ដើម

១ រឿងរ៉ាវនៃព្រះពុទ្ធមានសេចក្ដីពិស្ដារក្នុងច្បាប់ពុទ្ធប្រវត្តិ ឬក្នុងគម្ពីរបឋមសម្ពោធិ ។

បង្កើតសាសនា ដូចជាមកហើយ ។ សាសនា ប្រែថា " ពាក្យប្រៀនប្រដៅ" រួមចូលគ្នាថា ពុទ្ធសាសនា ប្រែថា " ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ " ។

ពាក្យប្រៀនប្រដៅទាំងអស់ ដែលព្រះបរមសាស្ដាទ្រង់ត្រាស់ទេសនាទូន្មានពួកពុទ្ធបរិស័ទ តាំងពីបានត្រាស់ដឹងជាព្រះពុទ្ធរហូតដល់បរិនិព្វាន ក្នុងកំឡុង ៤៥ ឆ្នាំ សូម្បីព្រះអង្គសំដែងបែកខ្ញែកទៅជាប៉ុន្មានផ្នែកក៏ដោយ ក៏គង់តែហៅដោយសរុបថា " ពុទ្ធសាសនា " តែម្យ៉ាងប៉ុណ្ណោះ សឹងមានជាប់រហូតមកដល់សព្វថ្ងៃនេះ រាប់ជា " រូបរាងរបស់ពុទ្ធសាសនា " កើតមកបានអាយុ ២៤៩៨ ឆ្នាំ ហើយ ( គិតត្រឹមឆ្នាំដែលបោះពុម្ពសៀវភៅនេះ ( គ.ស. ១.៩៥៥ ) ។

ពុទ្ធបរិស័ទ កាលបើបានស្គាល់រូបរាងរបស់ពុទ្ធសាសនាហើយ ត្រូវតែត្រិះរិះដេញដោលរកផ្លូវ ៖

## វត្ថុបំណងរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាទាំងមូល ទោះបីព្រះបរមសាស្ដាទ្រង់ត្រាស់ទេសនាទូន្មានពួកពុទ្ធបរិស័ទ ដោយព្រះវិនយបិដកក្ដី ព្រះសុត្តន្តបិដកក្ដី ព្រះអភិធម្មបិដកក្ដី ក៏មានវត្ថុបំណងតែមួយ គឺទ្រង់ដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិឈមមុខទៅរកព្រះនិព្វាន ដែលជាទីរលត់ទុក្ខតែម្យ៉ាងប៉ុណ្ណោះ ។

ប៉ុន្តែ មានន័យថាអនេកប្រការ.(១) ដែលព្រះអង្គដឹកនាំពួកពុទ្ធបរិស័ទឲ្យប្រតិបត្តិយកផលប្រយោជន៍នៅនាលោកិយ ដែលជាអ្នកមិនទាន់បានដល់ព្រះនិព្វាន ដូចជាព្រះអង្គត្រាស់ប្រាប់ប្រយោជន៍ ៣ យ៉ាង គឺ ប្រយោជន៍ ក្នុងជាតិនេះ ១ ក្នុងជាតិខាងមុខ ១ និងប្រយោជន៍ប្រសើរបំផុតគឺព្រះនិព្វាន ១ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់នូវវត្ថុបំណងរបស់ពុទ្ធសាសនាហើយ ត្រូវតែខំពិចារណាឲ្យល្អិតជ្រាលជ្រៅស្រាវជ្រាវរកនូវ ៖

## គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនា

ព្រះពុទ្ធសាសនាទាំងមូល មានចតុរារិយសច្ច ( របស់ពិតដ៏ប្រសើរ ៤ យ៉ាង ) ជាកំពូល, ធម៌គ្រប់យ៉ាងសុទ្ធតែសង្គ្រោះរួមចុះក្នុងវង់ចតុរារិយសច្ចទាំងអស់ ។ សេចក្តីប្រតិបត្តិគ្រប់បែបដែលមានប្រាកដក្នុងគម្ពីរទាំងឡាយ ក៏តែងកើតមានឡើង ដើម្បីសេចក្តីចេះដឹងនូវចតុរារិយសច្ចដោយប្រាជ្ញា, ចតុរារិយសច្ច ជាកំពូលធម៌; ការចេះដឹងចតុរារិយសច្ច ជាកំពូលនៃព្រហ្មចរិយៈ, ការប្រតិបត្តិដើម្បីឲ្យត្រាស់ដឹងនូវចតុរារិយសច្ចដោយប្រាជ្ញា ជាកំពូលនៃការប្រតិបត្តិទាំងមូល ។

## ចតុរារិយសច្ច

ពាក្យថា “ ចតុរារិយសច្ច ” ប្រែថា “ របស់ពិតដ៏ប្រសើរមាន ៤ យ៉ាង ” គឺ

---

១ មានសេចក្តីពិស្តារក្នុងច្បាប់សិង្គាលោវាទសូត្រ ។

១ ទុក្ខអរិយសច្ច របស់ពិតដ៏ប្រសើរ គឺទុក្ខ ។

២ សមុទយអរិយសច្ច របស់ពិតដ៏ប្រសើរ គឺហេតុប្រជុំកើតឡើងនៃទុក្ខ ។

៣ និរោធអរិយសច្ច របស់ពិតដ៏ប្រសើរ គឺធម៌រលត់ទុក្ខ ។

៤ មគ្គអរិយសច្ច របស់ពិតដ៏ប្រសើរ គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

## សេចក្ដីអធិប្បាយអំពីអរិយសច្ច ដោយសង្ខេប[១]

១ ទុក្ខអរិយសច្ច គោលដោយខ្លី សំដៅយកឧបាទានក្ខន្ធទាំង ៥ គឺ សេចក្ដីប្រកាន់មាំថា រូប ១ វេទនា ១ សញ្ញា ១ សង្ខារ ១ វិញ្ញាណ ១ ជារបស់ខ្លួន ។

២ សមុទយអរិយសច្ច សំដៅយកតណ្ហា, តណ្ហា ប្រែថា "សេចក្ដីប្រាថ្នា" ។ តណ្ហានេះ ជាដើមហេតុធ្វើឲ្យមនុស្សសត្វកើតហើយស្លាប់ ៗ ហើយកើតទៀត មិនចេះផុត, ធ្វើឲ្យមនុស្សជាបុថុជ្ជន គឺឲ្យជាអ្នកក្រាស់ដោយកិលេស ។ មនុស្សដែលនៅមានតណ្ហាសេចក្ដីប្រាថ្នា ដរាបណា ក៏មិនដល់នូវទីរលត់ទុក្ខ ដរាបនោះ ប្រៀបដូចជាដៅមានភ្លើងគឺហេតុ ដរាបណា ផលគឺការក្ដៅ ក៏នៅមាន ដរាបនោះ ។ តណ្ហាមាន ៣ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។

---

១ មានសេចក្ដីពិស្ដារក្នុងច្បាប់អរិយសច្ចកថា ខ្មែរនិងសៀម ។

៣ និរោធអរិយសច្ច សំដៅយកការរលត់តណ្ហាអស់គឺបាន
ដល់ព្រះនិព្វាន ។

៤ មគ្គអរិយសច្ច សំដៅយកមគ្គមានអង្គ ៨ (អដ្ឋង្គិកមគ្គ)
ជាផ្លូវប្រតិបត្តិឲ្យបានដល់នូវរំលត់ទុក្ខគឺព្រះនិព្វាន ។

## ហេតុផលរបស់អរិយសច្ច

ទុក្ខ ជាផលរបស់ សមុទយៈ ។ ជាហេតុរបស់ ទុក្ខ ។
និរោធ ជាផលរបស់ មគ្គ ។ ជាហេតុរបស់ និរោធ ។

## កិច្ចដែលត្រូវធ្វើក្នុងអរិយសច្ច មាន ៤ (១)

១ ទុក្ខ ជាបរិញ្ញាតព្វកិច្ច គឺត្រូវកំណត់ដឹង ។

២ សមុទយៈ ជាបហាតព្វកិច្ច គឺត្រូវលះបង់ចេញ ។

៣ និរោធ ជាសច្ឆិកាតព្វកិច្ច គឺត្រូវធ្វើឲ្យជាក់ច្បាស់ ។

៤ មគ្គ ជាភាវេតព្វកិច្ច គឺត្រូវធ្វើឲ្យកើតមានឡើង ។

កិច្ចក្នុងអរិយសច្ចទាំង ៤ នេះ រួមឲ្យខ្លីមក នៅតែត្រឹម ២ យ៉ាង
គឺ លះបង់សមុទយៈ ១ ចំរើនមគ្គ ១ ។

## បរិវដ្តក្នុងអរិយសច្ច

បរិវដ្ត ប្រែថា « ញាណជាគ្រឿងវិលទៅ » សំដៅយក
ញាណទាំង ៣ គឺសច្ចញ្ញាណ ១ កិច្ចញ្ញាណ ១ កតញ្ញាណ ១ ។

---

១ កិច្ច ៤ នេះ គុណនឹងមគ្គ ៤ ទៅជា ១៦ ហៅថា សោឡសកិច្ច ។

១– ប្រាជ្ញាដឹងថា នេះទុក្ខ, នេះហេតុឲ្យកើតទុក្ខ, នេះសេចក្ដីរលត់ទុក្ខ, នេះផ្លូវឲ្យដល់នូវសេចក្ដីរលត់ទុក្ខ ហៅថា សច្ចញាណ ប្រែថា ប្រាជ្ញាដឹងរបស់ពិត ។

២– ប្រាជ្ញាដឹងថា ទុក្ខនេះគួរកំណត់ដឹង, សមុទយៈនេះគួរលះបង់, និរោធនេះគួរធ្វើឲ្យច្បាស់, មគ្គនេះគួរធ្វើឲ្យកើតមាន ហៅថា កិច្ចញាណ ប្រែថា ប្រាជ្ញាដឹងកិច្ចដែលគួរធ្វើ ។

៣– ប្រាជ្ញាដឹងថា ទុក្ខនេះអាត្មាកំណត់ដឹងហើយ, សមុទយៈនេះអាត្មាលះបង់ហើយ, និរោធនេះអាត្មាធ្វើឲ្យច្បាស់ហើយ, មគ្គនេះអាត្មាធ្វើឲ្យកើតមានហើយ ហៅថា កតញាណ ប្រែថា ប្រាជ្ញាដឹងកិច្ចដែលធ្វើស្រេចហើយ ។

ញាណទាំង ៣ នេះ ប្រព្រឹត្តទៅក្នុងអរិយសច្ចទាំង ៤ ត្រូវជាអាការៈ ១២ ( ៤ × ៣ = ១២ ) ។

## អត្ថក្នុងអរិយសច្ច ១៦

ទុក្ខ មានអត្ថ ៤

១– បីឡនត្ថៈ ប្រែថា បៀតបៀន,

២– សង្ខតត្ថៈ " ត្រូវបច្ច័យប្រជុំតាក់តែង,

៣– សន្តាបត្ថៈ " ក្ដៅក្រហាយ,

៤– វិបរិណាមត្ថៈ " ប្រែប្រួល ។

### សមុទយៈ មានអត្ថ ៤

១ អាយូហនត្ថៈ ប្រែថា ឲ្យកើតកងទុក្ខ

២ និទានត្ថៈ " ជាហេតុនៃទុក្ខ,

៣ សំយោគត្ថៈ " ប្រកបសត្វទុកក្នុងសង្សារទុក្ខ,

៤ បលិពោធត្ថៈ " ឃុំឃាំងសត្វទុកក្នុងគុកគឺសង្សារទុក្ខ ។

### និរោធ មានអត្ថ ៤

១ និស្សរណត្ថៈ ប្រែថា ជួយឲ្យចេញចាកឧបធិ (កិលេស),

២ វិវេកត្ថៈ(១) " ស្ងាត់ចាកកិលេស,

៣ អសង្ខតត្ថៈ " បច្ច័យតាក់តែងមិនបាន,

៤ អមតត្ថៈ " ជាអម្រឹតរស (មិនចេះស្លាប់) ។

### មគ្គ មានអត្ថ ៤

១ និយ្យានត្ថៈ ប្រែថា បញ្ជូនសត្វចេញចាកវដ្តសង្សារ,

២ ហេតុត្ថៈ " ជាហេតុនៃព្រះនិព្វាន,

៣ ទស្សនត្ថៈ(២) " ឃើញព្រះនិព្វាន,

៤ អធិបតេយ្យត្ថៈ " ជាអធិបតីក្នុងវិមុត្តិញាណទស្សនៈ ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់ច្បាស់ថា ចតុរារិយសច្ច ជា

---

១ ច្បាប់អរិយសច្ចកថា ថា អបលិពោធត្ថោ មានអត្ថថា រកកង្វល់រវល់មិនបាន ។

២ ក្នុងច្បាប់អរិយសច្ចកថា ថា ទស្សនត្ថោ អធិប្បាយថា សំដែងចេញ ។

គោលធម៌យ៉ាងសំខាន់បំផុតរបស់ពុទ្ធសាសនាហើយ ត្រូវតែត្រិះរិះរើសរកផ្លូវប្រតិបត្តិឲ្យឃើញថាផ្លូវណាជា ៖

## គោលនៃការប្រតិបត្តិធម៌យ៉ាងប្រសើរ បំផុតក្នុងពុទ្ធសាសនា

កាលពីជំនាន់បូរាណ ដែលមិនទាន់មានព្រះពុទ្ធជាម្ចាស់ក្នុងលោក បណ្ដាមនុស្សទាំងអស់ដែលធ្លាប់ស្គាល់សុខទុក្ខមកហើយ គេតែងស្អប់ខ្ពើមទុក្ខណាស់ មិនចង់បានទុក្ខសោះ ស្រឡាញ់តែសុខ ចង់បានតែសុខម្យ៉ាងប៉ុណ្ណោះ, ម្ល៉ោះហើយក៏កើតគំនិតរិះគិតរកផ្លូវប្រតិបត្តិ ដើម្បីចៀសវាងឲ្យផុតពីទុក្ខ ធ្វើឲ្យកើតសុខដល់ខ្លួន ៗ ប៉ុន្តែ ប្រតិបត្តិមិនត្រូវត្រង់ផ្លូវរំលត់ទុក្ខ ក៏គ្រាន់តែបានស្រាកស្រាន្តស្ងប់ទុក្ខក្នុងកាលខ្លះ, លុះអស់អំណាចកម្លាំងធម៌នោះហើយ ក៏ត្រឡប់ជាកើតទុក្ខឡើងវិញដដែល ទទួលសោយទុក្ខអស់កាលវែងឆ្ងាយតទៅមុខទៀត មិនរួចផុត ព្រោះតែមិនបានដឹងនូវអរិយសច្ច ៤ ដូចជាអាឡារតាបស និងឧទកតាបស ខំចំរើនឈានឲ្យបានផលទៅកើតនៅនាស្ថានព្រហ្ម ដោយសំគាល់ខុសថា ស្ថានព្រហ្ម ជាទីបំផុតទុក្ខ ជាទីរលត់ទុក្ខ ។ ព្រះពុទ្ធជាម្ចាស់នៃយើង កាលព្រះអង្គកំពុងតែស្វែងរកធម៌ជាគ្រឿងរំលត់ទុក្ខ មុនបានត្រាស់ដឹងជាព្រះពុទ្ធ ទ្រង់ធ្លាប់បានចូលទៅនៅសិក្សាលទ្ធិធម៌ ក្នុងសំណាក់តាបសទាំង ២ រូបនោះដែរ ប៉ុន្តែ ទ្រង់ជ្រាបថា

ធម៌នេះមិនមែនជាផ្លូវប្រតិបត្តិឲ្យផុតទុក្ខទេ ទើបទ្រង់យាងចេញពីសំណាក់តាបសទាំង ២ រូបនេះ ទៅស្វែងរកផ្លូវប្រតិបត្តិដោយវិធីផ្សេងៗទៀត ។

កាលដែលព្រះបរមសាស្តាបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។ ផុតពី ៤៩ ថ្ងៃមក ព្រះអង្គទ្រង់ត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រ ( អរិយសច្ច ៤ ) និងអនត្តលក្ខណសូត្រ ( ព្រះត្រៃលក្ខណ៍ ) មុនធម៌ទាំងអស់ ប្រោសភិក្ខុបញ្ចវគ្គីយ៍ ( ភិក្ខុ ៥ រូប ) មុនពុទ្ធ-បរិស័ទទាំងពួង នៅនាព្រៃឥសិបតនមិគទាយវ័នក្បែរក្រុងពារាណសី ។

សេចក្តីខាងដើមនៃព្រះធម្មចក្កប្បវត្តនសូត្រនោះ ទ្រង់ត្រាស់ប្រារព្ធអំពីផ្លូវប្រតិបត្តិ ៣ ប្រការថា ម្នាលភិក្ខុទាំងឡាយ! ផ្លូវប្រតិបត្តិ ១ ធូរថយពេក ហៅ " កាមសុខល្លិកានុយោគ " ប្រែថា " ការប្រកបខ្លួនឲ្យទឹកជោកទៅដោយសេចក្តីសុខក្នុងកាម " , ផ្លូវប្រតិបត្តិ ១ ទៀតតឹងរឹងហួសពេក ហៅ " អត្តកិលមថានុយោគ " ប្រែថា " ការប្រកបខ្លួនទុកក្នុងសេចក្តីលំបាក " សំដៅយកការប្រតិបត្តិ ដែលពួកជនខ្លះខំព្យាយាមទម្មានខ្លួនដោយវិធីផ្សេងៗ មានអាំងភ្លើង, ហាលថ្ងៃជាដើម ដើម្បីឲ្យផុតពីទុក្ខព្រួយ និងដើម្បីឲ្យបានសម្រេចនូវសេចក្តីប្រាថ្នា ។ ផ្លូវធូរពេក និងផ្លូវតឹងពេក ទាំង ២ ប្រការនេះ តថាគតបានប្រតិបត្តិរួចមកហើយ ដឹងថាជាផ្លូវឥតផលប្រយោជន៍ ជាផ្លូវអាក្រក់លាមក ថោកទាប, អ្នកទាំងឡាយ មិនត្រូវប្រតិបត្តិតាមផ្លូវទាំង ២ យ៉ាងនេះទេ ។

ម្នាលភិក្ខុទាំងឡាយ នៅមានផ្លូវប្រតិបត្តិ ១ ទៀត ជាផ្លូវប្រតិបត្តិយ៉ាងកណ្ដាល មិនធូរពេក មិនតឹងពេក ជាផ្លូវប្រតិបត្តិឲ្យដល់នូវទីរលត់ទុក្ខពិតប្រាកដ ជាផ្លូវដ៏ប្រសើរ មានអង្គ ៨ ( អដ្ឋង្គិកមគ្គ ) ជាផ្លូវដែលតថាគតបានប្រតិបត្តិរួចមកហើយ, តថាគតបានត្រាស់ដឹងនូវអរិយសច្ច ៤ ( របស់ពិតដ៏ប្រសើរ ៤ យ៉ាង ) ដោយសារតែផ្លូវនេះឯង, អ្នកទាំង-ឡាយ ត្រូវតែប្រតិបត្តិតាមផ្លូវកណ្ដាលនេះចុះ ដែលជាផ្លូវមានឈ្មោះថា មជ្ឈិមាបដិបទា ប្រែថា "សេចក្ដីប្រតិបត្តិជាយ៉ាងកណ្ដាល" សំដៅយកការធ្វើដំណើរទៅតាមគន្លងផ្លូវយ៉ាងកណ្ដាល ជាផ្លូវទៅកាន់ទីរលត់ទុក្ខ ។

ផ្លូវកណ្ដាលដែលឈ្មោះថា មជ្ឈិមាបដិបទា នេះ មានអង្គ ៨ ( អដ្ឋង្គិកមគ្គ[១] ) គឺ

១– សម្មាទិដ្ឋិ សេចក្ដីយល់ឃើញត្រូវ,

២– សម្មាសង្កប្បៈ សេចក្ដីត្រិះរិះត្រូវ,

៣– សម្មាវាចា វាចាត្រូវ,

៤– សម្មាកម្មន្តៈ ការងារត្រូវ,

៥– សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រូវ,

៦– សម្មាវាយាមៈ ព្យាយាមត្រូវ,

---

១ មានសេចក្ដីពិស្ដារក្នុងច្បាប់អរិយសច្ចកថា ។

៧- សម្មាសតិ រលឹកត្រូវ,

៨- សម្មាសមាធិ តាំងចិត្តមាំត្រូវ ។

អង្គទាំង ៨ នេះ លុះតែមានព្រមជាមួយគ្នាគ្រប់ទាំង ៨ រួមចូលគ្នាជាកំឡាំងតែមួយ ទើបហៅថា មគ្គ ឬ អរិយមគ្គ ឬ មជ្ឈិមាបដិបទា, បើញែកចេញឲ្យដាច់ពីគ្នា តែអង្គមួយៗវិញ មិនហៅថា មគ្គ ទេ គ្រាន់តែហៅត្រឹមចំណែកអង្គមួយៗ តាមឈ្មោះអង្គនោះ ៗ ប៉ុណ្ណោះ ។

មគ្គ មានឈ្មោះ ៤ យ៉ាង តាមកំឡាំងដែលអាចលះកិលេសបាន(១) គឺ

១ សោតាបត្តិមគ្គ ជាគូនឹង សោតាបត្តិផល

២ សកទាគាមិមគ្គ " សកទាគាមិផល

៣ អនាគាមិមគ្គ " អនាគាមិផល

៤ អរហត្តមគ្គ " អរហត្តផល

មគ្គ ៤ ផល ៤ នេះ ជាឈ្មោះរបស់ចិត្ត ។

អ្នកមានមគ្គចិត្តនិងផលចិត្តយ៉ាងនេះ ហៅថា " អ្នកបានសម្រេចមគ្គផល " ។

ការប្រតិបត្តិធម៌គ្រប់ជាន់ មានមជ្ឈិមាបដិបទាជាបង្គោល ។

---

១ មគ្គ ៤ លះកិលេសបានប្លែក ៗ គ្នា មានសេចក្តីពិស្តារក្នុងច្បាប់ពោធិបក្ខិយធម៌និងច្បាប់អរិយសច្ចកថា ។

មជ្ឈិមាបដិបទា ជាទីប្រជុំចុះនៃការប្រតិបត្តិធម៌ទាំងអស់ ក្នុងព្រះពុទ្ធសាសនាទាំងមូល ។ មជ្ឈិមាបដិបទាជាក្រសែនៃព្រះនិព្វាន, ជាផ្លូវដំណើរនៃចិត្ត មិនមែនជាផ្លូវសម្រាប់ដើរដោយជើងទេ ។

មជ្ឈិមាបដិបទា ជាធម៌សម្រាប់មនុស្សគ្រប់រូប មិនមែនជាធម៌ខ្ពស់ហួសផុតវិស័យរបស់មនុស្សឡើយ, មិនមែនជាធម៌ធ្វើឲ្យមនុស្សទន់ខ្សោយ ឬធ្វើឲ្យខ្ជិលច្រអូស, ឲ្យតាលតាញ់សេចក្តីទុក្ខដែលខ្លួនត្រូវអត់ធន់នោះទេ, ជាធម៌សម្រាប់មនុស្សអ្នកស្អប់ខ្ពើមទុក្ខហើយចង់បានសុខពិតប្រាកដ, ជាធម៌យ៉ាងកណ្តាល មានថ្នាក់ខ្ពស់ទាប តាមភាពរបស់មនុស្សបុថុជ្ជនគ្រប់រូប ក្នុងលោកនេះ មិនមែនជាធម៌សម្រាប់តែព្រះអរិយបុគ្គលមួយចំពួកប្រតិបត្តិប៉ុណ្ណោះទេ, ដ្បិតថា បើមនុស្សបុថុជ្ជន មិនប្រតិបត្តិតាមមជ្ឈិមាបដិបទានេះហើយ ធ្វើម្តេចនឹងក្លាយខ្លួនទៅជាព្រះអរិយបុគ្គល គឺអ្នកបានសម្រេចមគ្គ ៤ ផល ៤ កើត, ហេតុនេះ បានជាចាត់មជ្ឈិមាបដិបទាថា "ជាគោលនៃការប្រតិបត្តិធម៌យ៉ាងប្រសើរបំផុតក្នុងព្រះពុទ្ធសាសនា" ។

ពួកពុទ្ធបរិស័ទ កាលបើបានយល់នូវមជ្ឈិមាបដិបទា ថា "ជាគោលដ៏សំខាន់បំផុតនៃការប្រតិបត្តិធម៌" ហើយ ត្រូវតែពិចារណាដេញដោលរកឲ្យឃើញ នូវផលប្រយោជន៍នៃការប្រតិបត្តិធម៌ថា ផលដូចម្តេចដែលជា ៖

# ផលប្រយោជន៍យ៉ាងខ្ពស់បំផុតនៃការប្រតិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា (១)

ក្បួនច្បាប់ក្នុងព្រះពុទ្ធសាសនា បានសំដែងបញ្ជាក់អំពីផលប្រយោជន៍នៃការប្រតិបត្តិធម៌ ដោយអនេកបរិយាយ ប៉ុន្តែ ផលទាំងអស់នោះបើបំព្រួញឲ្យតិចមក នៅមានតែត្រឹម ២ យ៉ាង គឺ ផលជាលោកិយ ១ ផលជាលោកុត្តរៈ ១ ។

## ផលជាលោកិយ

ក្នុងទីនេះ សូមបរិយាយអំពីផលជាលោកិយមុន : អ្នកប្រតិបត្តិធម៌តាមក្រសែនៃមជ្ឈិមាបដិបទា ដូចបានរៀបរាប់ខាងដើមហើយនោះរមែងបានប្រយោជន៍យ៉ាងវិសេស ក្នុងលោកពុំនៃប្រតិបត្តិធម៌ មិនបង្អង់ចាំពេលណាទើបបានផលទេ ( អកាលិកោ ) ជាធម៌ឲ្យផលពុំមានកាលខាន់ គឺថា មជ្ឈិមាបដិបទា ធ្វើអ្នកប្រតិបត្តិតាមឲ្យបានទៅជាមនុស្សមានហេតុផលជាគោលការ, ធ្វើឲ្យបានទៅជាអ្នកដាច់ស្រេចក្នុងចិត្ត, ធ្វើឲ្យបានទៅជាអ្នកឈ្នះខ្លួនឯង, ធ្វើឲ្យបានទៅជាអ្នកបង្កាប់បញ្ហាខ្លួនឯងកើត, ធ្វើឲ្យបានទៅជាអ្នកមានសេចក្តីប្រាជ្ញាត្រឹមត្រូវ, ធ្វើឲ្យបានទៅជាអ្នកចៀសវាងគ្រោះថ្នាំ, ធ្វើឲ្យបានទៅជា

---

១ ស្រង់ចាកច្បាប់ពុទ្ធសាសនាសៀម លេខ ម. ៤៣៥ ទំព័រ ៥១៨ . . . របស់ក្រសួងពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ ។

អ្នកមានកាយកម្ម, វចីកម្ម និងការចិញ្ចឹមជីវិត ប្រាសចាកទុក្ខក្តៅក្រហាយគ្រប់ប្រការ; ធ្វើឲ្យបានទៅជាអ្នកមានព្យាយាមត្រូវ មានសេចក្តីក្លាហាន, មានសេចក្តីចេះដឹង និងឲ្យមានសេចក្តីទៀងទាត់ក្នុងចិត្ត ល្មមឲ្យជីវិតរបស់ខ្លួនមានរបៀបរៀបរយ គួរដល់ឋានៈរបស់ធម៌ដែលខ្លួនប្រតិបត្តិ ។

កាលមនុស្សបានប្រតិបត្តិធម៌ត្រឹមត្រូវតាមមជ្ឈិមាបដិបទា ដែលមាន សម្មាទិដ្ឋិ ជាប្រធាន ជាមេនាំមុខហើយ ក៏រមែងបានផលអាចឲ្យកើតអង្គមគ្គ ៧ ខាងចុង ក ៗ គ្នាតាមលំដាប់គ្នា ៗ មិនរង់ចាំកាលណាទេ ដូចជាអ្នកមាន :

១– សេចក្តីយល់ឃើញត្រូវ (សម្មាទិដ្ឋិ) ការចូលចិត្តត្រឹមត្រូវតាមហេតុផលហើយ ជាផ្លូវឲ្យកើត :

២– សេចក្តីត្រិះរិះត្រូវ (សម្មាសង្កប្បៈ) ។ សេចក្តីត្រិះរិះត្រូវធ្វើឲ្យកើត :

៣– វាចាត្រូវ (សម្មាវាចា)

៤– ការងារត្រូវ (សម្មាកម្មន្តៈ)

៥– ការចិញ្ចឹមជីវិតត្រូវ (សម្មាអាជីវៈ)

៦– ព្យាយាមត្រូវ (សម្មាវាយាមៈ)

៧– រលឹកត្រូវ (សម្មាសតិ)

៨– តាំងចិត្តមាំត្រូវ ( សម្មាសមាធិ ) ។

កាលបើអដ្ឋង្គិកមគ្គជាហេតុ កើតមានយ៉ាងនេះហើយ ការលះបង់កិលេសនោះ ៗ បានជាប់ស្រឡះជាផល ក៏កើតមានឡើងក្នុងខណៈនៃមគ្គនោះដែរ ក៏ប៉ុន្តែ ជាមគ្គនៅទន់ខ្សោយនៅស្តើងស្តួច; មិនទាន់រឹងប៉ឹងខ្លាំងក្លា, មិនទាន់ពេញលេញ ទើបហៅថា អរិយមគ្គមិនទាន់បានទេ គ្រាន់តែអាចលះបង់កិលេស បំពួកខ្លះ បានតាមកំឡាំងនៃមគ្គជាលោកិយ ឲ្យបានផលជាលោកិយប៉ុណ្ណោះ ។

បណ្តាផលជាលោកិយទាំងអស់ សំដៅយកត្រង់ការអស់កិលេសបំពួកខ្លះនោះ(១) ថាជាផលប្រសើរបំផុត លើសផលជាលោកិយនានា មានផលឲ្យបានសោយសុខសម្បត្តិក្នុងស្ថានមនុស្សនិងស្ថានសួគ៌ជាដើម ។

## ផលជាលោកុត្តរៈ

មគ្គជាលោកិយដូចបាននិយាយរួចមកហើយនោះ ជាគោលនៃការគ្រប់គ្រងជីវិតរបស់អ្នកប្រតិបត្តិធម៌ឲ្យប្រព្រឹត្តទៅរៀបរយ ។ ឲ្យបានសុខសប្បាយកល់ៗថ្ងៃ ហៅថា អ្នកបានផលជាលោកិយ ។ ផលជាលោកិយនេះ កាលបើគេអប់រំអដ្ឋង្គិកមគ្គឲ្យចាស់ក្លាដល់កំរិតហើយ អាចក្លាយទៅជា **អរិយផល** ដែលកើតពី **អរិយមគ្គ** ដូចសេចក្តីអធិប្បាយដោយសង្ខេបតទៅនេះ :

---

១ សេចក្តីសៅហ្មងអាក្រក់ដោយកាយ, វាចា, ចិត្ត ហៅថា កិលេស ។ នេះ មាន ៣ យ៉ាងគឺ យ៉ាងគ្រោកគ្រាកក៏មាន យ៉ាងកណ្តាលក៏មាន យ៉ាងល្អិតសុខុមក៏មាន ។

អ្នកប្រតិបត្តិធម៌តាមលំអាន នៃមជ្ឈិមាបដិបទាជាលោកិយ ហើយបានព្យាយាមអប់រំអង្គមគ្គទាំង ៨ ឲ្យមានកំឡាំងពេញទីតាមវិធីនៃការប្រតិបត្តិធម៌ ឲ្យព្រមព្រៀងគ្នាជាកម្លាំងតែ ១ ហើយ ហៅថា **អរិយមគ្គ** ។ នេះ អាចកំចាត់បង់កិលេស ឬ សំយោជន៍ (១) យ៉ាងល្អិតបំផុតដែលត្រាំជាប់ស្អិតនៅក្នុងសន្តានចិត្ត ឲ្យរលត់ទៅតាមចំណែកនៃកម្លាំងអរិយមគ្គ ដែលខ្លួនបានអប់រំមកហើយ ។ ផលដែលកើតមានឡើងអំពីកិរិយាលះបង់កិលេសបាននេះ ហៅថា **អរិយផល** ។

**អរិយមគ្គ** ដែលចាស់ក្លាផល់កំរិត អាចកំចាត់បង់កិលេសក្នុងសន្តានចិត្តបានត្រឹមណា ក៏មានឈ្មោះហៅតាមជាន់នៃការលះបង់កិលេសរបស់ខ្លួនបានត្រឹមណោះថា សោតាបត្តិមគ្គ, សកទាគាមិមគ្គ, អនាគាមិមគ្គ, អរហត្តមគ្គ ។ អរិយផល ក៏បានជាគូនឹងអរិយមគ្គគ្រប់ៗមគ្គដែរ គឺសោតាបត្តិផល, សកទាគាមិផល, អនាគាមិផល និង អរហត្តផល ។ ហេតុនោះទើបកើតបានជាមគ្គ ៤ ផល ៤ ហៅកាត់ឲ្យខ្លីថា **មគ្គផល** ។ អរិយមគ្គជាហេតុ អរិយផលជាផល, អរិយមគ្គដែលមានឈ្មោះផ្សេងគ្នាជា ៤ យ៉ាងនោះ ក៏ព្រោះកំចាត់បង់កិលេសបានច្រើនតិចជាងគ្នា(២) ។ ឱកាសបើកឲ្យអង្គមគ្គប្រជុំគ្នាជាអរិយមគ្គបានកាលណា ការកាត់ផ្តាច់សំយោជន៍ក៏កើត

---

១ កិលេសជាគ្រឿងប្រកបចិត្ត ហៅថា សំយោជនៈមាន ១០ យ៉ាង គឺសក្កាយទិដ្ឋិ ១, វិចិកិច្ឆា ១, សីលព្វតបរាមាស ១, កាមច្ឆន្ទ ១, ព្យាបាទ ១, រូបរាគ ១, អរូបរាគ ១, មានៈ ១, ឧទ្ធច្ចៈ ១, អវិជ្ជា ១ ។

២ អរិយមគ្គណា កំចាត់បង់កិលេសអ្វីខ្លះ មានសេចក្តីពិស្តារក្នុងច្បាប់អរិយសច្ចកថា ។

មានឡើងក្នុងកាលណាមួយរំពេច ។ ឧកាសនេះមិនកំណត់កាលទេ ( អកាលិកោ ) កើតមានឡើងក្នុងខណៈដែលចិត្តមូលជាអារម្មណ៍តែមួយ ដោយឆាប់រហ័ស ដូចអ្នកខ្លះស្ដាប់ទេសនាបានសម្រេចមគ្គផលនៅទីនោះភ្លាមក៏មាន(ខិប្បាភិញ្ញា) , ដោយសេចក្ដីព្យាយាមដ៏ខ្លាំងក្លា ដូចព្រះយោគាវចរខំចំរើនភាវនារឿយ ៗ រាល់ថ្ងៃ ទាល់តែបានសម្រេចមគ្គផលក៏មាន ( ទន្ធាភិញ្ញា ) ។

អ្នកប្រតិបត្តិធម៌ ហើយបានសម្រេចលោកុត្តរផល ជាផលជាន់ខ្ពស់បំផុតយ៉ាងនេះហើយ ឈ្មោះថា ជាអ្នកបានដល់ព្រះនិព្វាន ជាស្ថានរលត់ទុក្ខទាំងអស់ ឈ្មោះថា ជាអ្នកប្រតិបត្តិធម៌ត្រឹមត្រូវតាមវត្ថុបំណងនៃព្រះពុទ្ធសាសនាពិតប្រាកដ ព្រោះព្រះពុទ្ធសាសនាទាំងមូលមានចំណុចជាទីបំផុតត្រង់ មគ្គ ៤ ផល ៤ និព្វាន ១ រួមជា៩ ដែលហៅថា ព្រះនពលោកុត្តរធម៌ (១) ។

## សេចក្ដីបញ្ចប់

មនុស្សជាជាតិអ្វីក៏ដោយ ប្រុសឬស្រី ក្មេងឬចាស់ ដែលជាអ្នកកាន់ពុទ្ធសាសនា បាននាមបញ្ញត្តិថា ពុទ្ធបរិស័ទ ហើយត្រូវខំពិចារណាឲ្យយល់ច្បាស់ដោយគំនិតប្រាជ្ញារបស់ខ្លួនថា :

ព្រះពុទ្ធសាសនា ជាសាសនាទៀងទាត់ណាស់ គ្មានសាវ៉ែណា

១ ធម៌ចម្លងសត្វឲ្យឆ្លងផុតចាកលោក ហៅថា លោកុត្តរធម៌ ។

អាចលុបលាង ឬ កែប្រែ ដូចជាច្បាប់សម្រាប់ប្រទេសមួយ ៗ បានទេ, ជាសាសនាមិនទទួលពាក្យអង្វរករបន់ស្រន់ របស់អ្នកណាសោះឡើយ; ជាសាសនាមិនទទួលរ៉ាប់រងទុក្ខទោសជួសអ្នកណាឡើយ, ជាសាសនាបង្អុលហេតុផលយ៉ាងជាប់ខាត ។

ព្រះពុទ្ធសាសនាប្រៀបដូចទូក ពួកពុទ្ធបរិស័ទប្រៀបដូចអ្នកជិះ ។ ទូកល្បឿនក្តី មិនល្បឿនក្តី ទៅត្រង់ឬវៀចវេរក្តី ក៏ស្រេចតែលើខ្លួនអ្នកជិះ ។ បើទូកធ្លុះធ្លាយ ត្រូវតែអ្នកជិះជួសជុលបិទធ្លុះដោយខ្លួនឯង បើមិនបិទទេ ទូកក៏លិច ខ្លួនអ្នកជិះលើទូកក៏លង់ទឹកស្លាប់កណ្តាលទន្លេ ព្រោះនឹងស្រែកហៅរកអ្នកណាឲ្យជួយស្រង់ខ្លួនពុំបានឡើយ ។

ពួកពុទ្ធបរិស័ទ មិនត្រូវតាំងចិត្តផ្អែកវេរទៅលើព្រះពុទ្ធអង្គ ដោយនឹកអាងថា « ព្រះពុទ្ធ នឹងមកជួយដឹកដៃ យកយោងខ្លួន ឲ្យរួចពីទុក្ខទោសបាន» ដូច្នេះឡើយ ត្រូវតែតាំងចិត្តជឿកម្ម និងជឿផលរបស់កម្មយ៉ាងជាប់ខាតថា កម្មល្អឲ្យផលជាសុខ កម្មអាក្រក់ឲ្យផលជាទុក្ខ, អ្នកណាបានសុខឬបានទុក្ខ ក៏ព្រោះតែអ្នកនោះបានធ្វើកម្មល្អឬអាក្រក់រួចមកហើយ, គ្មានអ្នកណាអាចទទួលសុខទុក្ខជួសអ្នកណាបានទេ ប្រៀបដូចចោរលួចប្រាក់គេ ។ ចាប់បានដាក់គុក គ្មានអ្នកណាទទួលទោសគុកជួសចោរនោះបានឡើយ សូម្បីតែឪពុកបង្កើត ក៏ទទួលទោសគុកជួសកូនមិនបានដែរ ។ ម្យ៉ាងទៀត ដូចជម្ងឺ ឬសេចក្តីស្លាប់

នឹងទទួលផលជួសគ្នាមិនបានសោះឡើយ ។ សេចក្ដីបរិសុទ្ធិនិងមិនបរិសុទ្ធិ មានចំពោះតែរូបមនុស្សម្នាក់ ៗ ឥតអ្នកណាបរិសុទ្ធជួសអ្នកណាបានទេ ( សុទ្ធិ អសុទ្ធិ បច្ចត្តំ ខុ. ធ. ), អ្នកដទៃធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបានទេ ( នាញ្ញោ អញ្ញំ វិសោធយេ ខុ.ធ ); សេចក្ដីនេះប្រៀបដូចអ្នករៀនចំណេះវិជ្ជាផងទាំងពួង អ្នកណារៀន អ្នកនោះចេះ នឹងរៀនជួសគ្នាឬនឹងចេះជួសគ្នាមិនកើត ។ ការរៀនជាកម្មគឺហេតុ ការចេះដឹងជាផល ។ ហេតុនិងផល តែងអាស្រ័យគ្នាជានិច្ច ដូចសុភាសិតបុរាណថា « ចេះពីរៀនមានពីរក » ។

ពុទ្ធបរិស័ទ បើបានជឿកម្មផលដូច្នេះហើយ ទើបបានប្រតិបត្តិធម៌ត្រឹមត្រូវតាមវត្តបំណងរបស់ព្រះពុទ្ធសាសនា ។ បើមិនជឿកម្មផលទេ ហើយចេះតែធ្វើបុណ្យឲ្យទានរក្សាសីលទាំងខ្វាក់ទាំងថ្លង់ទៅ ព្រោះតែចិត្តចង់ឲ្យបានសុខនោះ លុះមិនបានសុខដូចបំណងហើយ ដៀតខ្លួនប្រតិបត្តិខុសគន្លងធម៌ ក៏ទៅជាខំបន់ស្រន់ព្រះសំពះទេវតាឲ្យជួយខ្លួន, កាលបើមិនឃើញព្រះ ឬ ទេវតាណាជួយ ក៏ត្រឡប់ជាខឹងស្អប់បន្ទោសព្រះ ឬ ទេវតា ថាមិនជួយខ្លួន ទៅវិញ ។

បណ្ដាយថាសភាវៈទាំងឡាយ(១) ដូចជាគេយកទឹកស្រោចភ្លើង ៗ តែងរលត់អស់ទៅ, នេះ ជាទំនៀមទម្លាប់យ៉ាងទៀងទាត់របស់ធម្មតា

---

១ របស់ដែលកើតមានឡើងឯងៗតាមធម្មតាលោកហៅថា យថាសភាវៈ ឬហៅថា វត្ថុធម្មជាតិ ។

គ្មានមនុស្សណាជាអ្នកសាងភ្លើង ឬ ទឹក ដែលជាវត្ថុធម្មជាតិនោះឡើយ មានតែមនុស្សជាអ្នកដឹងទំនៀមនេះថា « បើគេយកទឹកស្រោចភ្លើង ។ មុខជារលត់ » អ្នកដែលដឹងយ៉ាងនេះ ចាត់ថា ជាមនុស្សដឹងមុនគេ ហើយប្រាប់គ្នាតៗមក ។ ព្រះពុទ្ធអង្គក៏ដូច្នោះដែរ គឺព្រះអង្គបានជ្រាបរបស់ពិត ( អរិយសច្ច ) មុនគេ ។ ព្រះអង្គមិនបានកសាងអង្គមគ្គទាំង ៨ ឡើងទេ ។ ព្រះអង្គគ្រាន់តែជាអ្នកបានស្វែងរកមគ្គឃើញមុនគេ ហើយប្រកាសប្រាប់អ្នកដែលចង់បានសុខឱ្យធ្វើដំណើរទៅតាមអង្គមគ្គទាំង ៨ នោះប៉ុណ្ណោះ ( អក្ខាតារោ តថាគតា=ព្រះតថាគតទាំងឡាយ គ្រាន់តែជាអ្នកប្រាប់ផ្លូវ ខុ.ធ. ) ។

អង្គមគ្គទាំង ៨ ប្រៀបដូចជាផ្លូវថ្នល់ ១ ប្រកបដោយអង្គគុណ ៨ យ៉ាង គឺ មានក្តារបិទប្រកាសប្រាប់ដំណើរការសព្វគ្រប់ឱ្យដឹងផែនទីភូមិសាស្ត្រច្បាស់លាស់ កុំឱ្យវង្វេងផ្លូវបាន ( សម្មាទិដ្ឋិ ), . មិនវៀចវេរខុសផ្លូវ សំដៅត្រង់ទៅកាន់ទីតាមប្រាថ្នា ( សម្មាសង្កប្បៈ ), មានគូស្នាមគ្រោះល្អប្រពៃ ( សម្មាវាចា ). មានម្លប់រុក្ខាត្រជាក់ត្រជុំ ( សម្មាកម្មន្តៈ ), មានទីកន្លែងសម្រាប់ជ្រកសំណាក់អាស្រ័យយ៉ាងសុខស្រួល ( សម្មាអាជីវៈ ), មានទីកន្លែងសម្រាប់ស្វះស្វែងរកអាហារបំណាច់បានដោយងាយ ៗ មិនក្រ មិនលំបាក ( សម្មាវាយាមៈ ), មានការគ្រប់គ្រងថែរក្សាអ្នកដំណើរឱ្យបានសុខសប្បាយ មិនឱ្យមាន

អ្នកយកណ្តាលផ្លូវ (សម្មាសតិ), មានសេចក្តីសុខស្ងប់ស្ងាត់ត្រជាក់ត្រជុំដល់អ្នកដំណើរ (សម្មាសមាធិ) ។ អរិយមគ្គក៏មានអង្គនាំល្មមសមគួរឲ្យបានសម្រេចសេចក្តីប្រាថ្នារបស់អ្នកប្រតិបត្តិដូចជាផ្លូវនោះដែរ ។

អង្គមគ្គទាំង ៨ នឹងដើរជួសគ្នាមិនបានទេ ព្រោះជាចំណែកចិត្ត មិនមែនជាចំណែកវត្ថុដូចការលត់ភ្លើង ដែលអាចជួយស្រោចជួសគ្នាបានទេ ។ ភ្លើងប្រៀបដូចសេចក្តីទុក្ខក៏មែនហើយ ប៉ុន្តែ ភ្លើងជាចំណែកវត្ថុ ការលត់ជាចំណែកកាយ ទើបអាចជួយលត់ជួសគ្នាបាន ។ ទុក្ខក្នុងទីនេះ ជាចំណែកចិត្ត ដែលមនុស្សគ្រប់រូបដឹងឃើញដោយខ្លួនឯង (សន្ទិដ្ឋិកោ) ទើបធ្វើជួសគ្នាមិនបាន ប្រៀបដូចជាអ្នករៀន មិនអាចរៀនសូត្រចំណេះវិជ្ជាជួសគ្នាបានដូច្នោះដែរ ។

ព្រះពុទ្ធអង្គគ្រាន់តែជាអ្នកជ្រាបរបស់ពិតដ៏ប្រសើរ (អរិយសច្ច ៤) មុនគេ ហើយទ្រង់បានចង្អុលប្រាប់គេថា នេះហៅថា ទុក្ខ (ទុក្ខអរិយ-សច្ច) នេះជាហេតុឲ្យកើតទុក្ខ (ទុក្ខសមុទយសច្ច) នេះជាសេចក្តីរលត់ទុក្ខ (ទុក្ខនិរោធអរិយសច្ច) នេះជាផ្លូវដែលនឹងធ្វើអ្នកដំណើរឲ្យដល់នូវសេចក្តីរលត់ទុក្ខ (ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច) ជាផ្លូវដែលធ្វើឲ្យមារនិងសេនាមារតាមមិនទាន់. ជាផ្លូវដែលអ្នកទាំងឡាយ ត្រូវព្យាយាមដើរទៅដោយខ្លួនឯង, ព្រះតថាគតទាំងឡាយគ្រាន់តែជាអ្នកប្រាប់ផ្លូវប៉ុណ្ណោះទេ (អក្ខាតារោ តថាគតា) ។ មួយទៀត ព្រះតថាគតទាំងឡាយ មិនដែល

ទទួលពាក្យអង្វរករបន់ស្រន់របស់អ្នកណាឡើយ ( សុទ្ធិ អសុទ្ធិ បច្ចត្តំ “ សេចក្ដីបរិសុទ្ធិ និងមិនបរិសុទ្ធិ មានចំពោះខ្លួន ” នាញ្ញោ អញ្ញំ វិសោធយេ “ អ្នកដទៃធ្វើអ្នកដទៃឲ្យបរិសុទ្ធមិនបានទេ ” ខុ.ធ. ) ។

សេចក្ដីដែលបានអធិប្បាយអំពីករណីយកិច្ចរបស់ពួកពុទ្ធបរិស័ទតាំងពីដើមរហូតដល់ចប់ នេះជាពាក្យឆ្លើយដោះស្រាយប្រស្នា ៥ ប្រការខាងដើមនោះថា :

១– ព្រះពុទ្ធអង្គមិនមែនជាអ្នកបង្កើតលោកទេ ។

២– ព្រះពុទ្ធអង្គមិនមែនជាអ្នកដាក់ទោសទណ្ឌកម្ម ដល់ពួកសាវ័កដែលល្មើសពុទ្ធបញ្ញត្តិទេ ។

៣– ព្រះពុទ្ធអង្គមិនមែនជាអ្នកទទួលទោសជួសពួកសាវ័កទេ ។

៤– ព្រះពុទ្ធអង្គមិនមែនជាអ្នកទទួលអង្វរករពាក្យបន់ស្រន់ របស់ពួកសាវ័កទេ ។

៥– ព្រះពុទ្ធអង្គមិនមែនជាម្ចាស់កម្មផលទេ ។

## មេរៀន

ការប្រតិបត្តិធម៌ គឺជា ៖

១– ការផ្លាស់ចិត្តអាក្រក់ចេញឲ្យក្លាយទៅជាចិត្តល្អវិញ,

២– ការធ្វើជីវិតឲ្យបានសុខស្រួល,

៣– ការបំបាត់សេចក្តីល្ងង់ខ្លៅ,

៤– ការចេញចាកទុក្ខ ឈានទៅរកសុខ, សឹងមានជាទីដៅ ។

៥– ពុទ្ធបរិស័ទត្រូវប្រតិបត្តិតាមសាសនា ទើបហៅថា "ជាអ្នកកាន់សាសនាពិត", ទាំងត្រូវចាំពុទ្ធប្រវត្តិដោយល្អិតល្អ ហើយត្រូវផ្តិតនិស្ស័យព្រះមកដាក់ខ្លួន ។

# ករណីយកិច្ចរបស់ពុទ្ធបរិស័ទ

សង្ខេបប៉ុណ្ណោះ

—o—

# ការគប់មិត្ត

តាំងពីព្រេងនាយ មកដល់សព្វថ្ងៃនេះ ជីវិតមនុស្ស ត្រូវការមិត្តជានិច្ចជាតុទាំងអស់ ។ នេះក៏គឺជាចំណោទសំខាន់ ហោទរួចហើយ បង្ហាញន័យ ថា៖

បុគ្គលដទៃ ក្រៅពីមាតាបិតា ស្វាមីភរិយា បុត្រធីតា និង ញាតិសន្តាន របស់ខ្លួនចេញ គ្មានបុគ្គលណា ជាទីស្រឡាញ់ស្និទ្ធស្នាលទុកចិត្ត ជួយផ្តល់ប្រយោជន៍ទៅវិញទៅមក ជាងមិត្តសម្លាញ់ខ្លួនទេ មានតែមិត្តនេះហើយ ដែលអាចជួយគាំទ្រដំណើរជីវិតយើង ឲ្យបានប្រព្រឹត្តទៅស្រួល ប្រកបដោយជោគជ័យ ក្នុងលោកនេះ ។

មនុស្សគ្មានមិត្ត ទុកដូចជាមនុស្សដកពិការគ្រប់យ៉ាង គឺ មានតែភ្នែកក្តី ប៉ុន្តែមើលអ្វីៗមិនឃើញ, មានតែត្រចៀកស្តាប់ក្តី តែគ្មានស្តាប់ការអ្វីឲ្យបានសព្វគ្រប់, មានដៃមាំមួន តែធ្វើការងារមិនបានល្បីឈ្មោះ និងមានជើងល្អជា តែធ្វើដំណើរទៅឆ្ងាយមិនរួច សូម្បីសួស្តី រត់មកចំខ្លួនហើយ បែរជាត្រឡប់ទៅរកអ្នកដទៃវិញ ។

ចំណុចយ៉ាងសំខាន់នេះហើយ ដែលបណ្តាលឲ្យជីវិតសត្វ ក្នុងលោកទាំងមូលសព្វថ្ងៃស្រេកឃ្លានមិត្ត ជាងចំណីអាហារទាំងពួង ហើយជាពិសេស មានដល់ទៅសុខចិត្តស៊ូបន្ថយចំណីអាហារពេលរដ្ឋខ្លួន ឲ្យថយតិចបុះ ទុកនៅត្រឹមតែទទួលទានរស់ ដើម្បីសំចៃឲ្យសល់លុយកាក់

ប្រាក់កាស ដើម្បីយកទៅចងមិត្តនឹងអ្នកប្រទេសនានាផងក៏មាន ។

ដូច្នេះ រដ្ឋក្តី មនុស្សម្នាក់ៗក្តី ត្រូវតែមានមិត្តជាចាំបាច់ ខានមិនបាន ប៉ុន្តែត្រូវស្គាល់មិត្តឲ្យច្បាស់ តាមសណ្តាប់ធ្នាប់ ច្បាប់ការគប់មិត្ត, បើមិនបានច្រើន ក៏ឲ្យល្មមនឹងធ្វើការពិចារណាខ្លះ ៗ ជាមុនសិនដែរ ទើបការគប់រក នឹងអាចប្រព្រឹត្តទៅបាន ដោយប្រពៃ ។ ក្នុងករណីនេះ អ្នកប្រាជ្ញបុរាណកាល លោកធ្លាប់បានធ្វើការត្រិះរិះពិចារណា យ៉ាងល្អិតល្អន់ ព្រមទាំងធ្លាប់ជួបប្រទះនូវអស់ទាំងសព្វហេតុការណ៍ជាពិតប្រាកដណាស់ហើយ ទើបមានគតិជាច្រើន ដែលលោកបានចារឹកទុកសម្រាប់កូនចៅជាន់ក្រោយតៗមក ។

ដូចនៅនេះ ចូរពិចារណាឲ្យវែងឆ្ងាយចំពោះ " ច្បាប់បណ្តាំឪពុក " ដែលលោកអ្នកប្រាជ្ញពីបុរាណចងទុកមក ថា៖

មិត្តមួយសោកណា ទៅមកការគ្នា បង្កើតឲ្យសុខ
មិត្តមួយឲ្យទោស បង្កើតជាទុក្ខ មិត្តមួយឲ្យធុក
ឲ្យបង់ទ្រព្យ ។

ចាស់ព្រឹទ្ធាចារ្យ បានចង្អុលបង្ហាញថា ក្លើម្រាក់ មិត្តភក្តិ បក្សពួក មានច្រើនស្ថាន ច្រើនបែបណាស់ គឺ អ្នកខ្លះ មានចិត្តសប្បុរស ខ្លះក៏អសប្បុរស ខ្លះស្លូត ខ្លះកាចជាដើម; តែទោះបីច្រើនម្តេចម្តាក៏ដោយ គង់រួមឲ្យខ្លីមក នៅត្រឹមតែពីរពួក គឺ

មិត្តណា ដែលសេពគប់ទៅមកការគ្នា កើតសេចក្ដីសុខ សេចក្ដីចម្រើន ទាំងផ្លូវលោកផ្លូវធម៌ ជាមិត្តប្រកបដោយសុជីវធម៌ មានការគួរសម ចេះយោគយល់គ្នា ជួយយកអាសាគ្នា ស្មោះត្រង់នឹងគ្នា មិនក្បត់ចិត្តគ្នា ប្រព្រឹត្តធ្វើតែអំពើជាប្រយោជន៍ដល់គ្នានឹងគ្នា, មិត្តនោះ ហៅថា "កល្យាណមិត្ត" ។

មិត្តណា នាំឲ្យកើតទុក្ខទោស ឬ នាំឲ្យមានគ្រោះថ្នាក់ បង់ទ្រព្យសម្បត្តិ អេចរិល អាប់អន់ទុនថយ សាបសូន្យពាក់សេចក្ដីចម្រើន សេចក្ដីសុខ ឬ ប្រយោជន៍គ្រប់យ៉ាង ជាមិត្តគ្មានសុជីវធម៌នៅក្នុងខ្លួន រាប់អានស្គាល់អ្នកណា យកអ្នកណាធ្វើមិត្ត មានគំនិតអាក្រក់ គិតតែបឺតជញ្ជាក់ យកប្រយោជន៍ពីអ្នកនោះ និងយកអ្នកនោះធ្វើខ្ញុំកញ្ជះខ្លួន, មិត្តនោះ ហៅថា "បាបមិត្ត" ។

១- កល្យាណមិត្ត= មិត្តល្អសប្បុរស គឺមិត្តដែលមានកុសលធម៌នៅក្នុងសន្តាន ជាអ្នកលះបាបសន្សំបុណ្យ លះគុណវិបត្តិ សន្សំគុណសម្បត្តិ, ជាមិត្តគួរសេពគប់រាប់រក គួរយកជាសម្ព័ន្ធមេត្រី ជាសាច់ឈាម ជាទំនុកទុកចិត្តឥតសង្ស័យ ។ ដូចថា :

### មិត្តដែលគួរផ្ដេកផ្ដិតស្និទ្ធស្នាលរាប់បញ្ចូលជាកល្យាណមិត្ត មាន ៤ យ៉ាង គឺ

ក- មិត្តអ្នកធ្វើឧបការគុណ អ្នកជួយឈឺឆ្អាល ។

ខ- មិត្តអ្នករួមសុខរួមទុក្ខជាមួយ ។

គ- មិត្តអ្នកបង្ហាញប្រយោជន៍ ប្រាប់ផ្លូវចម្រើន ។

ឃ- មិត្តអ្នកជួយអនុគ្រោះស្រោចស្រង់ ជួយយឹតជួយយោង ជួយ សណ្តោងអន្ទង ។

ន័យមួយបែបទៀតថា មិត្តល្អគួរសេពគប់ លោកទុកជាក់ជា កល្យាណមិត្ត តែងប្រកបដោយអង្គ ៧ យ៉ាង គឺ

ក- តែងឲ្យរបស់ដែលកម្រក្រៃលែង ដែលមិនងាយនរណាឲ្យគ្នា កើត គឺចែករំលែកឲ្យមិត្តបាននូវរបស់កម្រ ។

ខ តែងតែធ្វើនូវករណីយ ដែលលំបាក គឺជួយឈឺឆ្អាល ធ្វើឲ្យ កើតនូវកិច្ចការដ៏ធ្ងន់ ។

គ- តែងតែអត់ធ្មត់នឹងហេតុការណ៍ ដែលកម្រនរណាប្តូរស៊ូទ្រាំបាន គឺមានខន្តិធម៌ យ៉ាងចំណាប់ចំនួនល្អល្អះ ។

ឃ- តែងតែបង្ហើបបង្ហាញ ដោយច្បាស់លាស់ នូវរបស់កំបិទកំបាំង របស់ខ្លួនដល់មិត្ត ។

ង- តែងតែជួយលាក់លៀម បំបិទបំបាំងនូវអាថ៌កំបាំងរបស់មិត្ត ។

ច- កាលបើមិត្តមានគ្រោះភាព អន្តរាយ ចុះឆ្ងាយ ដោយហេតុ អ្វីមួយ, ស៊ូប្តូរក្រាញនៅជាមួយមិត្ត មិនបោះបង់ចោលមិត្ត ។

ឆ- បើមិត្តទៅជាក្រតោកយ៉ាក ខ្វះខាត ប៉ប៉ះប៉ប៉ុន, មិនប្រមាថ

មើលឆ្ងាយ មើលជាកមិត្ត ដល់តិចតួចឡើយ ។

មិត្តដែលមានកល្យាណធម៌ ដូចបានពណ៌នាមកនេះ ហៅថា កល្យាណមិត្ត; បើនរជនណា បានសេពគប់មិត្តបែបនេះ, នរជននោះ តែងបានសេចក្ដីសុខសួស្ដីសិរីមង្គលជានិរន្ដរ៍; សមដូចបុរាណកាសិត ថា "មិត្តមួយសោតណា ទៅមកកាន់គ្នា បង្កើតឲ្យសុខ" ដូច្នេះ ។ តែ ថា មិត្តបែបនេះ កម្រនឹងរកបានដោយងាយនោះណាស់ ត្រូវគ្នានឹង កាសិតថា "មិត្តល្អត្រូវសេពគប់" តែ "មិត្តល្អក្ររកបាន" គឺមិត្តកាពរក ពិញតាមផ្សារពុំបានឡើយ ហើយអ្នកប្រាជ្ញខ្លះ បានពោលបញ្ជាក់សង្កត់ លើទ្រឹស្ដីនៃការគប់មិត្តថា "មនុស្សដែលមានមេត្តាករុណា ជាមាតាដែល នាំមកនូវមិត្តភាព" ។ បើរកមិត្តជាកល្យាណ ដូចប្រាប់លក្ខណៈមក ខាងលើនេះបានហើយ អ្នកចូរសេពគប់ចុះ មិនខុសឃ្លាងផ្លូវល្អ ផ្លូវសុខ ចម្រើនឡើយ ។ ប៉ុន្តែ កុំប្រវាយកធ្វើជានាយទៅហ្វាយ ឬ ជា ទាសកម្មកររបស់ខ្លួន ព្រោះបើដូច្នោះ នឹងខានបានធ្វើជាមិត្តសម្លាញ់នឹង គ្នាទៅហើយ ។

មិនត្រឹមតែប៉ុណ្ណោះសោត ការសេពគប់កល្យាណមិត្ត តែងបាន អានិសង្សខ្ពង់ខ្ពស់ជាងនេះទៅទៀត ដូចជាព្រះពគ្គលិ ដែលបានសេព គប់នឹងព្រះសារីបុត្រ ជាកំពូលកល្យាណមិត្ត, មិនយូរប៉ុន្មាន ព្រះពគ្គលិ បានសម្រេចព្រះអរហត្ត កំចាត់កិលេស ឥតសេសសល់ឡើយ ។

៤- បាបមិត្ត= មិត្តអាក្រក់ មិត្តផ្សផ្ដាក់ មិត្តមានបាបធម៌នៅក្នុងខ្លួនសន្ដាន; មិត្តនេះ បុរសបុគ្គលមិនគប្បីសេពគប់ឡើយ; ព្រោះថាបាបមិត្ត តែងតែនាំបុរសបុគ្គលឲ្យលិចលង់ ឲ្យធ្លាក់ចុះក្នុងផ្លូវលាមកអាក្រក់គ្រប់ជំពូក ។ បណ្ឌិតផ្ដាំទុក ថា៖

## មិត្តមិនគួរសេពគប់ មិនគួរយកខ្លួនបៀត មាន ៤ យ៉ាង គឺ

១-មិត្តគិតតែប្រយោជន៍ខ្លួន, មិត្តដែលកោនកាញ់ចង់បានប្រយោជន៍តែម្នាក់ឯង ដែលចង់បានញ័រទទត់ ដូចគេទទាក់ ឬថា ញ័រទទេក្រេក គិតតែពីការក្រសោរក្រោវយកពីមុខគេឯង; សមដូចច្បាប់ពាក្យចាស់ថា

បានហើយចង់បានទៀត ធ្មៀតហើយធ្មៀតពុំគិតឈ្មោះ
មើលយល់តែមុខឯង មិនឃើញគេឯទៀតផង ។

មិត្តនេះ តែងធ្វើមុខក្រញូវ កញ្ចុបកញ្ចូវ សម្ងំសម្ងក់អួកដៃ ដែលគេបានលាភលើសខ្លួន ច្បួនទៅជាខ្វារខ្វាចដើមទ្រូងខ្លួនឯងក៏មានសមដូចសុភាសិត " ហៃអស់មហាជន " ថា

" ឃើញគេបានទ្រព្យល្អ ស្ទើរខ្វារគខ្វាចគេលើស " ។

២- មិត្តល្អតែវាចា ផ្អែមល្ហែមតែសំដី មិត្តនេះ មានសំដីសំដៅរៀបរយល្អ និយាយពាក្យ បាទ ចាស ជានិច្ច មិនដែលគ្គងពាក្យពេចន៍ម្ដងណាឡើយ តាមនុស្សពេះប្រចុប ពេះអែបអប ពេះផ្សំ ។

មិត្តដែលចាស់ទុំបរមបុរាណសន្មតថា "មនុស្សធ្មិនក្រៅនៅក្នុង" ចាត់ជាមនុស្សមិនបានការ យកជាគ្នីគ្នាមិនកើត ។

តាមច្បាប់ពង្សាវតារថា "កុំទុកចិត្តអភិប្រាយ" គឺកុំទុកចិត្តមនុស្សដែលចុះតែខាងប្រាជ្ញពោរក ដែលនិយាយឲ្យផុតតែពីមាត់ ដែលច្រើនតែសំដី ដូចសំដីស្រូវ ជារបស់ឥតប្រយោជន៍សោះ, ជាមនុស្សធ្មិនក្បាលស៊ីក្បាល ធ្មិនកន្ទុយស៊ីកន្ទុយ ។ មិត្តបែបនេះ មិនចេះយកអាសាទណាទេ, មិនចេះជួយទុក្ខធុរៈទណាទេ; បើទុកជាសន្ទានពឹងពាក់ផ្តេកផ្តួល ឱបដៃ ឱបជើង សូមឲ្យជួយដោះស្រាយរឿងទុក្ខលំបាកអ្វីមួយ ក៏ពុំសម្រេចការណ៍ ព្រោះថា មិត្តរបៀបនេះបានតែមាត់ ពាក្យចេះតែថា កើត! បាន! មិនជាអ្វីទេ! កុំព្រួយ! ចាំមើលបន្តិចទៅ! យើះ! ទៅភ័យអី!

របៀបមមិត្តនេះជាមិត្តមានសំដីក្រៅផ្អែម មានចិត្តខាងក្នុងល្វីងជូរចត់ មានទំនងត្រូវគ្នានឹងសុភាសិត "ច្បាប់ពាក្យចាស់" ថា៖

ចូលព្រៃសត្វសាហាវ ស្រែកអំពាវនាមកជុំ
ដល់បានស្លាទឹកឃ្មុំ ពួនសម្ងំស៊ីម្នាក់ឯង ។

៣. មិត្តនិយាយចាក់បណ្តោយ និយាយតម្រូវអធ្យាស្រ័យ តម្រូវចំណុច, មិនទទឹង មិនប្រឆាំង មិនជំទាស់ ។ មិត្តនេះ បើមានកិច្ចការអ្វី គួរពិគ្រោះប្រឹក្សាជាមួយ ចេះតែអុំអើ ចេះតែពីហាអើ, ទោះ

ត្រូវក៏ដោយ ខុសក៏ដោយ, មិនកាត់ទទឹងគាត់ឡើយ, ជាមិត្តផ្សំ យកអាមិស សម្ដីស្អៀក ៗ រកប្រយោជន៍ មិត្តលះពាក្យសត្យជាពាក្យអ្នកប្រាជ្ញ បែរជាទៅកាន់យកពាក្យចាក់បណ្ដោយ ជាពាក្យជម្រុញឲ្យគេដើរផ្លូវអាក្រក់ ជាសំដីពាលគេខ្ពើមសារគ្មាន ៗ

៤- មិត្តស្រឡាញ់តែផ្លូវវិនាស គឺមិត្តដែលចូលចិត្តប្រព្រឹត្តអបាយមុខ តាំង ៨ ប្រការគឺ

ក- ជាអ្នកប្រព្រឹត្តល្បែងស្រី= ជាប់ដៃនឹងស្រីអាក្រក់ (ស្រីពេស្យាផ្កាមាស) មួយហើយមួយទៀតមិនចេះស្កប់ ទាល់តែហិនហោចខ្លួន ៗ

ខ- ជាអ្នកប្រព្រឹត្តល្បែងសុរា= អ្នកស្រវឹងខ្លួន ផឹកស៊ី ៗ ទាល់តែរលាយខ្លួន ៗ

គ- ជាអ្នកប្រព្រឹត្តល្បែងស៊ីទំ = អ្នកដើរប្រមូលពួកម៉ាក ចៅទំចំណីស៊ីលេងសប្បាយ, ស៊ីទាល់តែអន្តរាយខ្លួន ៗ

ឃ- ជាអ្នកប្រព្រឹត្តល្បែងស៊ីសង= អ្នកលេងល្បែងភ្នាល់ ល្បែងស៊ីសងគ្រប់ប្រភេទ លេងទាល់តែរុះរោយអស់ទ្រព្យសម្បត្តិ ៗ

ង- ជាអ្នកយកបាបមិត្តជាគ្នា= ជាអ្នកស្រឡាញ់មនុស្សខូចកាច យកតែមនុស្សខូចកាចជាពួកម៉ាក, ទាល់តែវានាំទៅធ្លាក់រណ្ដៅលាមក ៗ

ច- ជាអ្នកខ្ជិលច្រអូស= កំដិលផេះ, ខ្ជិលស្លើររលួយខ្លួន, ខ្ជិលទាល់តែហូតរហូតទាប ៗ

គ- ជាអ្នកដើរលេងយប់= ដើរពីភូមិមួយទៅភូមិមួយ ដើរពីទីស្ថានមួយទៅទីស្ថានមួយ ដើរទាល់តែអន្តរាយខ្លួន ឬអន្តរាយដល់ប្រពន្ធ ទ្រព្យរបស់មានវិញ្ញាណឥតវិញ្ញាណឯផ្ទះ ។

ឃ- ជាអ្នកដើរមើលមហោស្រព= ដើរស្តាប់ច្រៀង មើលរបាំ មើលល្បែងផ្សេងៗ ដែលនាំឲ្យខូចសុខភាព ឲ្យខាតទ្រព្យរបស់ ឲ្យខូចអាជីវប្បវត្តិ ។

មិត្ត ៤ ពួក ដែលរៀបរាប់មកនេះ ជាមិត្តមិនត្រូវសេពគប់ មិនត្រូវរាប់អាន, លោករាប់បញ្ចូលក្នុងបាបមិត្ត ព្រោះជាមិត្តនាំឲ្យកើតទោសទុក្ខ, នាំឲ្យខូចខាតទ្រព្យសម្បត្តិ ដូចសុភាសិត ថា៖

មិត្តមួយឲ្យទោស បង្កើតជាទុក្ខ
មិត្តមួយឲ្យទុក្ខ ឲ្យបង់ទ្រព្យ ។

បុគ្គលណា ដែលប្រកបដោយលក្ខណៈអាក្រក់ មិត្តខុសសុជីវធម៌ លោកហាមមិនឲ្យសេពគប់រាប់រកឡើយ ។ ប៉ុន្តែ កុំយកវាជាសត្រូវ ព្រោះនាំឲ្យមានឧបសគ្គ ក្នុងដំណើរជីវិត, គ្រាន់តែស្គាល់ធម្មតា ក្នុងនេះជាមនុស្សដូចគ្នាបានហើយ កុំសេពគប់ស្និទ្ធស្នាលតទៅទៀត ។ បើអ្នករកមិត្តល្អមិនបានទេ សុខចិត្តនៅម្នាក់ឯងទៅល្អជាង ព្រោះមានសុភាសិតផ្តាំថា " មិត្តអាក្រក់មិនត្រូវសេពគប់ " ហើយផ្តាំបន្ថែមទៀត ថា

« សូវនៅម្នាក់ឯងល្អជាង គួរជៀសវាងបាបមិត្ត » ។

ក្នុងការគប់មិត្តនេះ បើបង្រួមសេចក្តីឲ្យខ្លីបន្តិចមកទៀត នឹងស្រប ទៅតាមសេចក្តីមួយវគ្គ ក្នុងស្រីហិតោបទេស ត្រង់វគ្គនៃការគប់មិត្ត នោះ មានសេចក្តី ថា

មនុស្ស គប្បីស្រឡាញ់មនុស្សដូចគ្នា គប្បីជួយយកអាសាគ្នា ក្នុង គ្រាដែលមានអាសន្នអន្ទ្រក គប្បីចែកសុខគ្នាឲ្យស្មើ កុំគប្បីក្រសោបសុខ ដើម្បីខ្លួន ហើយទម្លាក់សេចក្តីទុក្ខទៅលើអ្នកដទៃឡើយ ។ អ្នកណា ប្រកាន់ថា ជននេះជាពួកយើង ជននោះជាពួកគេ អ្នកនោះឈ្មោះថាជា មនុស្សឃើញកាលខ្លី ។ ឯអ្នកដែលមានការសិក្សាច្រើន មានចិត្ត គំនិតល្អ តែងនិយាយថា មនុស្សនៅលើផែនពសុធានេះ សុទ្ធតែជា ផៅពង្សនឹងគ្នាទាំងអស់ ។

មនុស្សធម៌នេះ ប្រពៃពិតហើយ ក៏ប៉ុន្តែ មានមនុស្សខ្លះ នៅ មុខអ្នក វាសំពះលុតក្រាបជិតបាតជើងអ្នក វានិយាយដោយសំដីទន់ផ្អែម ល្ហែមល្អូកល្អិន, នៅក្រោយអ្នក វាបេះសាច់ឆ្អឹងជំនីរអ្នកស៊ី(១), បើវា មានចន្លោះល្អ វាលូកដៃចូលទៅមូលបេះយកថ្លើមប្រមាត់អ្នកមួយរំពេច(២) ឥតបើកោតញញើតឡើយ ។ ទុជ្ជនបែបនេះ ទោះបីនិយាយពាក្យពីរោះ គួរជាទីពេញចិត្ត ក៏ដោយ អ្នកមិនត្រូវយកពាក្យនោះជាហេតុ ដើម្បីធ្វើ សេចក្តីស្និទ្ធស្នាលទេ ព្រោះសំដីនោះប្រៀបដូចជាទឹកឃ្មុំដែលជាប់នៅចុង

១-២ មនុស្សពាលនៅកំបាំងភ្នែកវាហ៊ានប្រមាថមើលងាយ ។

អណ្តាត ហើយចិត្តពេញដោយពិសពុល ដ៏ក្តៅក្រហាយពេលកល ។ ខណៈណាទៅស្និទ្ធស្នាលនឹងសត្រូវ នឹងកិរិយា ដែលមិនមានចិត្តប្រតិព័ទ្ធនឹងខ្លួន ដោយគាំងថា ខ្លួនមានទ្រព្យសម្បត្តិច្រើន, នាពេលនោះ ឈ្មោះថា មានជីវិតចូលទៅដល់ទីបំផុតនៃទុក្ខហើយ ( ជីវិតដែលចូលទៅដល់សេចក្តីស្លាប់ហើយ ) ។

ដូច្នេះ ការថែករំលែកមនុស្សជាមិត្តនិងសត្រូវ ជាការមួយចាំបាច់បំផុត ខានមិនបាន ។ អ្នកណា មិនលះបង់អ្នក ក្នុងគ្រាមានទុក្ខ ក្នុងគ្រាអត្តកាយ ក្នុងគ្រាទុរ្ភិក្ស ក្នុងគ្រាកស្តួចលាចល ក្នុងទ្វារព្រះរាជា និងក្នុងព្រៃស្មសាន, អ្នកនោះហើយ ជាមិត្តដ៏ល្អរបស់អ្នក ។ ចូរអ្នកយកអ្នកនោះជាមិត្តចុះ ។ (ស្រីហិតោបទេស)

ខ្ញុំពណ៌នា អំពីការគប់មិត្តសម្លាញ់នេះ ដោយមានបំណង ចង់នាំមនុស្សឲ្យដើរត្រង់ផ្លូវ រកសុខចម្រើន កុំឲ្យវង្វេងក្នុងផ្លូវខុស មានបាបគ្រោះ ព្រោះគេដឹកនាំ ។

ឯមិត្តនាំឲ្យសុខ ហៅថា កល្យាណមិត្ត និងមិត្តឲ្យទុក្ខ ហៅថា បាបមិត្ត ដែលបានពោលសង្ខេបមកនេះ សូមសាធុជនជ្រើសរើសសេពគប់ពប់គេមិត្ត ដែលនាំផ្លូវទៅកាន់សេចក្តីសុខនោះចុះ ។

ភ្នំពេញ ថ្ងៃ ៩ កើត ខែផល្គុន ឆ្នាំរោង ឆស័ក ត្រូវនឹង
ថ្ងៃ ១១ មីនា ព.ស. ២៥០៧ គ.ស. ១៩៦៤

ព្រួច-ក្រុម

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

# ហេតុដូចម្តេចក៏សុំឲ្យទេព្តាជួយ ?

(វិចារណកថា)

លោក ជេង-ជ្រីវ រៀបរៀង

មនុស្សក្នុងលោក មិនថាជាតិណាជាជាតិណាឡើយ តែកាលណាមានភ័យ មានអាសន្ន មានគ្រោះកាច មានទុក្ខព្រួយ ឬចង់សម្រេចបំណងអ្វីច្រើន តែងអំពាវនាវ សុំឲ្យទេព្តាជួយជាធម្មតា ។ ហេតុអ្វីក៏ចេះតែមានការបួងសួង – សំបូងសង្រួង – បន់ស្រន់ – អំពាវនាវ – ទទូចអង្វរយ៉ាងនេះ ? តាមការពិចារណា និងការត្រិះរិះឃើញថា ការណ៍នេះបណ្តាលមកពីទម្លាប់ ។ ចុះកូនក្មេងគេឲ្យទេព្តាជួយដែរ និងថាមកពីទម្លាប់ដូចម្តេចកើត ។ សូមជ្រាបថា គឺជាទម្លាប់ក្តើមគេក មានក្នុងឈាម តពីដូនតាមក មិនមែនទម្លាប់នៃជនម្នាក់ ១ ក្នុងបច្ចុប្បន្នឡើយ ចំពោះការសុំឲ្យទេព្តាជួយនេះ ។

សួរថា : ការសុំឲ្យទេព្តាជួយ មានដើមកំណើតពីណា ?

ឆ្លើយថា : ការសុំឲ្យទេព្តាជួយ បើតាមការពិចារណាដ៏ជ្រាលជ្រៅ បើតាមការសិក្សា ហើយពិនិត្យរកហេតុផល មានដើមកំណើតពីសាសនា ។

សួរថា : ក្នុងលោក សាសនាណាខ្លះពឹងផ្អែកទៅលើទេព្តា ?

ឆ្លើយថា : ក្រៅពីព្រះពុទ្ធសាសនា សាសនាទាំងអស់មែនពឹងផ្អែកទៅលើទេព្តា ទុកទេព្តាជាធំបំផុត ។

សួរថា : ព្រះពុទ្ធសាសនា ហេតុអ្វីក៏ខុសពីគេ មិនពឹងផ្អែកទៅលើទេព្តា ?

ឆ្លើយថា : ព្រះពុទ្ធសាសនា ជាសាសនាប្រាកដនិយមតែមួយក្នុងលោក ព្រោះមេសាសនានេះ ជាមនុស្សសុទ្ធសាធ ។ មនុស្សដ៏អស្ចារ្យនេះ និយមយក " កម្ម " ( ការធ្វើ ) ទុកជាមូលដ្ឋានធំនៃសាសនា ។ ចំណែកសាសនាដទៃ ជាអាទិ៍ គឺសាសនាព្រាហ្មណ៍ គ្រិស្តសាសនា និងសាសនាឥស្លាម មិនមែននិយមយក " កម្ម " ទុកជាមូលដ្ឋានធំ នៃសាសនាឡើយ គឺនិយមយកព្រះអាទិទេពទុកជាមូលដ្ឋានធំនៃសាសនា ។ គឺថា បើខ្លួនធ្វើអំពើអកុសលហើយ ហើយដឹងខ្លួនខុស ទៅសូមលន់តួទោសទីងព្រះអាទិទេព នោះខ្លួនត្រូវជ្រះស្រឡះចាកផលអកុសល រួចបានជាមនុស្សល្អត្រឹមត្រូវដូច

ដើមវិញពិតប្រាកដ បានសេចក្តីថា អំពើអាក្រក់អាចលុបលាងបាន ឲ្យតែខ្លួនព្រមទទួលសារភាព យកព្រះអាទិទេព ជាទីពឹង ។ ចំណែកព្រះពុទ្ធសាសនាវិញ មានសភាពផ្ទុយពីនេះស្រឡះ គឺថាបើខ្លួនធ្វើ "កម្ម" អាក្រក់ ត្រូវតែទទួលផលនៃ "កម្ម" នោះ គ្មានព្រះណាមកជួយបានឡើយ ព្រះពុទ្ធគ្រាន់តែជាអ្នកចែកផ្លូវ ជាអ្នកប្រាប់ផ្លូវ ប៉ុណ្ណោះ ឧបមាដូចជាចង្កៀងអុជបំភ្លឺក្នុងរាត្រីកាល សម្រាប់គ្រាន់តែឲ្យយល់ច្បាស់នូវទីដែលគួរទៅ និងទីដែលមិនគួរទៅ បើខ្លួនគោរព ឬ មិនគោរព តាមការណ៍នេះស្រេចនៅលើខ្លួនជាអ្នកធ្វើ ។

សួរថា : បើដូច្នេះ ហេតុដូចម្តេចក៏មានអ្នកព្រះពុទ្ធសាសនារកទេព្តាឲ្យជួយដែរ ក្នុងពេលមានអាសន្ន ?

ឆ្លើយថា: អ្នកព្រះពុទ្ធសាសនា រកទេព្តាឲ្យជួយ ដោយហេតុពីរប្រការគឺ ម្យ៉ាងដោយពួកនេះយល់ជម្រៅគោលពុទ្ធសាសនាមិនបានច្បាស់លាស់ ម្យ៉ាងដោយពួកនេះមានឈាមតពូជពីដូនតា ជាអ្នកកាន់ពាហិរសាសនា មកពីសម័យដើមយូរយារណាស់ហើយ មានសាសនាព្រាហ្មណ៍ជាដើម ដែលនិយមយកព្រះអាទិទេពបីព្រះអង្គ គឺ ព្រះព្រហ្ម ព្រះឥសូរ និងព្រះនារាយណ៍ ទុកជាមូលដ្ឋាននៃសាសនា ។

សូមបញ្ជាក់ថា : នៅពេលដែលព្រះសិទ្ធត្ថតាបស គង់លើរតនបល្ល័ង្ក ខាងក្រោមទុក្ករកិរិយាអស់ ៦ ព្រះវស្សា វេលាព្រលប់ក្រោម

ដើមមហាពោធិព្រឹក្ស ថ្ងៃ ១៥ កើត ខែវិសាខ . . . . . . ដើម្បីការត្រាស់ដឹង ក្រុងមារាធិរាជបានមករំខានព្រះអង្គ ដោយមធ្យោបាយផ្សេង ៗ ។ ពេលនោះព្រះសិទ្ធត្ថតាបស មិនបានអំពាវនាវសុំឲ្យទេព្តាជួយឡើយ ព្រះអង្គអំពាវនាវចំពោះតែបារមីទាំង ៣០ ប៉ុណ្ណោះ មារាធិរាជក៏ត្រូវអន្តរាយឯង ៗ ករណីនេះ សឲ្យឃើញថា ក្រុមគ្រួសារព្រះពុទ្ធមិនត្រូវការពឹងផ្អែកលើទេព្តាឡើយ គឺត្រូវពឹងផ្អែកតែទៅលើ " កម្ម " របស់ខ្លួនតែម្យ៉ាង ៗ អើ ! បើមេត្តាករុណាចំពោះទេព្តា គឺប្រាកដជាមានមែន ព្រោះព្រះពុទ្ធសាសនា ប្រដៅឲ្យមានធម៌មេត្តាករុណាជាធំ ៗ ដូច្នេះហើយ បានជានៅពេលបំពេញកុសលម្តង ៗ ព្រះពុទ្ធទ្រង់ប្រដៅអ្នកពុទ្ធសាសនា ឲ្យឧទ្ទិសផលកុសលកម្ម ដល់ទេព្តាផង ព្រោះនៅស្រុកភូមិទេព្តា គ្មានកន្លែងធ្វើបុណ្យទេ ៗ ចុះបើទេព្តាទទួលសេចក្តីសុខតែពីយើងដែលផ្សាយទៅឲ្យ តើទេព្តាមានសមត្ថភាពឯណា នឹងអាចមកជួយយើងបាន ?

ចំពោះការណ៍នេះ មានចំណោទមួយកើតឡើងថា : បើទេព្តាគ្មានសមត្ថភាពនឹងមកជួយមនុស្សបាន ហេតុអ្វី កាលកិច្ចចក្ខុបាលវង្វេងក្នុងព្រៃ ព្រោះតែសាមណេរជាក្មួយតែលោលដោយបណ្តាស្នេហា បានទេវមន្តមកដល់ក្រុងសាវត្ថីបានម៉្លេះ ? តាមក្នុងរឿងថា ទេព្តាជាអ្នកដឹកនាំលោកមក ដ្បិតលោកងងឹតភ្នែកទាំងពីរ ៗ

មែនពិត ចក្ខុបាលភិក្ខុបានត្រូវទេព្ដាជូនដំណើរមកមែន តែលោកឥតបានអំពាវនាវសុំឲ្យទេព្ដាជួយឡើយ គឺទេព្ដាជួយខ្លួនឯងទេតើ ដោយភ័យខ្លួន ខ្លាចមានទោស អត់ទ្រាំនៅស្ងៀមមិនបាន ក៏មកជួយលោក ព្រោះលោកជាអ្នកមានសីលបរិសុទ្ធ គឺតេជះសីលនេះហើយ ដែលទៅដេញទេព្ដាឲ្យមកជួយ ។

តទៅនេះ សូមរកញែកនូវហេតុដែលបណ្ដាលឲ្យមនុស្សស្ទើរគ្រប់រូប កាលណាមានទុក្ខព្រួយ តែងអំពាវនាវរកទេព្ដាឲ្យជួយ ។ ទម្លាប់នេះ បើតាមការសង្កេត មានមកច្រើនរយសតវត្សហើយ ។ ក្នុងលទ្ធិកតុទ្ធសាសនា មនុស្សតែងតែរកអ៊ីជាទីពំនឹងចិត្តរបស់ខ្លួន ម្ល៉ោះហើយ តែងយកវត្ថុផ្សេង ៗ មានទឹក ដី ភ្លើង ខ្យល់ ភ្នំ ជាដើម ទុកជាសរណៈនៃអាត្មា ។ បន្ទាប់មក មានមនុស្សខ្លះឈ្លាសវៃប៉ុនប្រសប់ខាងពាក្យសំដីខាងវោហារ ក៏តាំងខ្លួនដោយមធ្យោបាយផ្សេងៗ ជាមេធំជាជើងព្រះ ក្នុងតំបន់នីមួយ ៗ ហើយប្រកាសយកនេះយកនោះ ទុកជាសរណៈ អាចទុកជាអ្នកខ្លាំងពូកែ អាចផ្ដល់សុខទុក្ខដល់ខ្លួន ដល់មនុស្សទាំងឡាយ ដូច្នេះហើយ ទើបមនុស្សនិយមហៅនេះហៅនោះ ដែលតាមការណ៍ពិតជារបស់ធម្មតាសោះ ថាជា " ព្រះ " មានជាអាទិ គឺព្រះអគ្គី ព្រះគង្គា ព្រះពាយ ព្រះពៃស្រព ។ មិនតែប៉ុណ្ណោះ ដូចជាសាសនាព្រាហ្មណ៍នេះ ដែលជាសាសនាចាស់ជាងគេបំផុតក្នុងលោក បានប្រដៅមនុស្ស

ឲ្យគោពេសគោ ប្រដៅឲ្យទៅមុជទឹកលាងបាប ហើយទឹកសក្តិសិទ្ធិ ដែលអាចជម្រះបាបបាន បានតែទឹកក្នុងទន្លេគង្គា ក្នុងប្រទេសឥណ្ឌា ។ ក្នុងមួយឆ្នាំ ៗ ដល់រដូវលាងបាបម្តង ៗ មានមនុស្សពពាក់ពពួនចុះទៅក្នុងទន្លេ ជួនកាលដោយមានមនុស្សច្រើនពេក មានជាន់គ្នាស្លាប់ក៏សឹងមាន ។ ខ្ញុំសូមបើកវង់ក្រចកបន្តិច : យើងអាចទុកមនុស្សអស់នេះ ជាអ្នកមានការពិចារណាខ្វះឬទេ? បើទឹកសក្តិសិទ្ធិមែន ម្តេចក៏អ្នកមកលាងបាបត្រូវស្លាប់ទៅវិញ ? ព្រោះតែបង់រស់បង់សុខ ទើបបានមករកទឹកនេះ ។ គួរតែមេសាសនាព្រាហ្មណ៍ សើរើពិនិត្យគិតឡើងវិញនូវរឿងនេះ ការជឿអ្វីទាំងងងឹត នឹងជាគ្រោះភ័យដល់អាត្មា ។

ឥឡូវ ខ្ញុំបែរមកបន្តការដោះស្រាយរឿងទេវតាទៀត ។ ខ្ញុំមិនពោលទេអំពីអ្នកពាហិរសាសនា ដែលមានការអាសន្ន តែងអំពាវនាវរកទេវតាឲ្យជួយ ព្រោះគេជាអ្នកគោរពទេវតាទៅហើយ ខ្ញុំសូមលើកយកអ្នកពុទ្ធសាសនា មកធ្វើការដោះស្រាយ ។

អ្នកពុទ្ធសាសនាទាំងឡាយ គួរតែសើរើគំនិតថ្មី ស្តីពីការអំពាវនាវរកទេវតាឲ្យជួយ នៅពេលមានទុក្ខព្រួយ ។ ហេតុអ្វីបានជាថាយ៉ាងនេះ? ថាព្រោះព្រះពុទ្ធសាសនា គ្មានកន្លែងត្រង់ណា ដែលសំដែងថា កាលបើមានទុក្ខព្រួយ ត្រូវអំពាវនាវរកទេវតាឲ្យជួយឡើយ ។ ព្រះពុទ្ធសាសនាបញ្ជាក់ថា បើមានទុក្ខព្រួយ គួរតែអំពាវនាវរក " កម្ម "

របស់ខ្លួន មានតែផលកម្មនេះហើយ ទើបអាចជួយខ្លួនបាន ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោក ។ បើអ្នកពុទ្ធសាសនា បានជាមានជាប់ឈាមខាងបន់ទេព្ដា ខាងអំពាវនាវរកទេព្ដាឲ្យជួយ តពីដូនតាមក ក្នុងពេលនេះ គួរតែធ្វើការអប់រំជម្រះឈាមមិនបរិសុទ្ធនេះចេញ ។ ការធ្វើបែបនេះឈ្មោះថាយើងញុំាងពុទ្ធសាសនា ជាសរណៈស្មើដោយជីវិតរបស់យើង ឲ្យភ្លឺថ្លាឲ្យរុងរឿង ឲ្យមានរស្មីចិញ្ចាចចិញ្ចែងជាកិរិយាភាព ហើយនិងបាននាមដ៏ប្រសើរ ថាជាអ្នកពុទ្ធសាសនិក យល់ច្បាស់នូវជម្រៅដ៏ពិតប្រាកដ នូវគោលមូលដ្ឋានធំ នៃសាសនាព្រះសក្យមុនី ដែលយើងតែងតែគោរពរាល់ថ្ងៃនោះ ។ ព្រះពុទ្ធបរមគ្រូ ទ្រង់សំដែងថា “ កម្មំ សត្តេ វិភជតិ ” ប្រែសេចក្ដីថា “ កម្ម ( ការងារ ) បែងចែក សត្វទាំងឡាយ ” គឺជាមានតែ “ កម្ម ” ទេ ដែលអាចប្រែងមនុស្សឲ្យក្លាយទៅជានេះ ទៅជានោះបាន ដូចជាងដែកអាចច្នៃដែក ឲ្យទៅជាវត្ថុសមតាមសេចក្ដីត្រូវការបាន ។ យើងឃើញច្បាស់ហើយ សព្វថ្ងៃនេះទេព្ដាឯណាជួយមនុស្សកើត មានតែមនុស្សជួយខ្លួនឯង ដោយនិយមយក “ កម្ម ” ជាប្រមាណ ទើបបានកើត ។ ព្រោះទេព្ដា តាមការណ៍ពិតជាលទ្ធផលនៃកុសលកម្មរបស់មនុស្សទេ បាយទឹក ត្រីសាច់ សំពត់អាវ ផ្ទះសំបែង ។ល។ មិនដែលកើតពីទេព្ដាឡើយ គឺកើតឡើងតែពីមនុស្សធ្វើទាំងអស់ គួរដែរឬ កាលណាមានទុក្ខព្រួយ បែរទៅអំពាវនាវរកទេព្ដាឲ្យជួយវិញ ។

មួយកន្លែងទៀត ព្រះពុទ្ធបរមគ្រូ ទ្រង់ត្រាស់យ៉ាងច្បាស់ថា ៖

អត្តា ហិ អត្តនោ នាថោ
កោ ហិ នាថោ បរោ សិយា
អត្តា ហិ សុទន្តេន
នាថំ លភតិ ទុល្លភំ

ប្រែថា : ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃ នឹងជាទីពឹងដូចម្តេចកើត បើយើងមានខ្លួនទូន្មានល្អហើយ ឈ្មោះថាបាននូវទីពឹង ដែលអ្នកដទៃរកបានដោយលំបាក ។ បណ្តាគាថាទាំងបួនបទនេះ ខ្ញុំយកតែពីរបទខាងចុងមកធ្វើអត្ថាធិប្បាយ ។ ពាក្យថា " បើយើងមានខ្លួនទូន្មានប្រពៃហើយ ឈ្មោះថាបាននូវទីពឹង ដែលអ្នកដទៃរកបានដោយលំបាក " បានសេចក្តីថា បើយើងយល់ត្រូវហើយ គឺថាដឹងផ្លូវល្អ ផ្លូវចំរើនដែលគួរដើរតាម នឹងផ្លូវអាក្រក់ ផ្លូវប្រាសចាកអត្ថប្រយោជន៍ ដែលមិនគួរដើរតាមហើយ ឈ្មោះថាយើងមានទីពំនាក់ដ៏កម្រ ដែលអាចផ្តល់សេចក្តីត្រូវការមកយើង បានគ្រប់ពេលវេលា ឧបមាដូចអ្នកលង់ទឹករមែងត្រូវការទូកជាទីពឹង ដូចសត្វហើរកណ្តាលទីវាលកន្តារៈ រមែងត្រូវការដើមឈើជាទីពឹង ដូចបក្សីហើរឆ្លងសមុទ្រ រមែងត្រូវការកោះជាទីពឹង ។

សួរថា : យ៉ាងដូចម្តេច ហៅថា " យល់ត្រូវ " ?

ឆ្លើយថា: "យល់ត្រូវ" នោះគឺយល់ថា ព្រះពុទ្ធសាសនា ប្រាកដជា

និយមយក " កម្មផល " ទុកជាគោលមូលដ្ឋាន ជាសាសនាប្រាកដនិយមតែមួយគត់លោក នេះហៅថា " យល់ត្រូវ " ។ បើយើងតាំងខ្លួនថា ស្រឡាញ់រាប់អានព្រះពុទ្ធ តែយើងមិនគោរពព្រះទ័យរបស់ព្រះអង្គ តើការស្រឡាញ់រាប់អាននោះនឹងមានលទ្ធផលម្ដេចកើត ? បើយើងប្រកាសថា អ្នកនេះអ្នកនោះជាមាតាបិតារបស់យើង តែយើងមិនស្ដាប់ពាក្យប្រៀនប្រដៅដ៏ល្អរបស់លោក តើសេចក្ដីប្រកាសនេះ មានន័យដូចម្ដេច ? បើយើងពោលថា អ្នកនេះឬអ្នកនោះជាទីពឹង ជាមគ្គុទ្ទេសក៍របស់យើង តែបើយើងមិនព្រមអនុវត្តយ៉ាងម៉ត់ចត់នូវបទបញ្ញារបស់អ្នកនោះ តើការពោលនេះ នឹងមានខ្លឹមសារឬទេ ?

សូមបញ្ជាក់បន្ថែមថា " កម្ម ,, ជាគោលមូលដ្ឋាននៃព្រះពុទ្ធសាសនា ។ ចុះបើអ្នកពុទ្ធសាសនា កាលណាមានទុក្ខព្រួយ កាលណាមានភ័យ មិនរក " កម្ម ,, បែរទៅរក " ទេវតា ,, វិញ តើនឹងអាចទុកអ្នកទាំងនេះ ថាជាអ្នកពុទ្ធសាសនាត្រឹមត្រូវដូចម្ដេចបាន? បើតាមសច្ចៈយុត្តិធម៌ នឹងអាចរាប់បញ្ចូលអ្នកទាំងអស់នេះ ទៅក្នុងស្បៀងក្រុមអ្នកក្បត់នឹងពុទ្ធសាសនា ក៏សឹងបានទៅវិញ ។ តែក្នុងលោកនេះតែងមានអ្នកយល់ខុស យល់ភន្តច្រឡំពុំខាន មិនដែលថាមិនមានការភន្តច្រឡំនេះនោះទេ ។

ដូច្នេះហើយ គួរតែអស់លោកអ្នកយល់ភន្តច្រឡំក្នុងរឿងព្រះពុទ្ធ-

សាសនាកែប្រែចិត្តគំនិតដោយការចំរៀនចម្លាប់ចិត្តបែរមករកផ្លូវត្រូវ ផ្លូវពិតផ្លូវមែនឡើងវិញ ព្រោះការគោរពទេព្តា ជាសាសនាក្រៅដទៃ មិនមែនកប់ចូលក្នុងព្រះពុទ្ធសាសនាឡើយ ៗ ព្រះពុទ្ធសាសនាប្រដៅឲ្យគោរព " កម្ម " ព្រោះ " កម្ម " នេះ មានមហិទ្ធិរិទ្ធិអាចញុំាងអ្វី ៗ ឲ្យសម្រេចបានទាំងអស់ : វឌ្ឍនភាព ការរុងរឿង និង សន្តិភាព សុទ្ធសឹងជាលទ្ធផលនៃ " កម្ម " ៗ អន្តរាយគ្រប់បែបយ៉ាង មានអសន្តិសុខ សង្គ្រាម ការធ្លាក់ទៅអបាយភូមិ សុទ្ធសឹងជាលទ្ធផលនៃ " កម្ម " នេះដែរ ៗ មិនតែប៉ុណ្ណោះ តាមសង្កេតដ៏ម៉ត់ចត់ មានវិហារពុទ្ធសាសនាខ្លះ មានកុដិភិក្ខុសង្ឃខ្លះ ទុកជាអាស្រមនៃទេវរូបក៏មាន ៗ ការប្រព្រឹត្តិបែបនេះនៃអ្នកពុទ្ធសាសនា ជាអំពើធ្ងន់ធ្ងរក្រៃលែង ជាសេចក្ដីប្រមាថដ៏ឥតសមហេតុផល ៗ ព្រះពុទ្ធសាសនាដែលគួរតែពុទ្ធបរិស័ទសើរើពិនិត្យកែសម្រួលឲ្យសមនឹងត្រឹមត្រូវតាមព្រះពុទ្ធទុកទ ទើបប្រសើរ ៗ

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(ត)

លោក ហ៊ុន គិមសៀ រៀបរៀង

អ្នកប្រាជ្ញអក្សរសាស្ត្របានអះអាងថា : " ភាសាគឺជាបាតុភូតជាក់ស្តែងនៃសតិអារម្មណ៍ " ពីព្រោះសតិអារម្មនិងភាសារបស់មនុស្ស វាលូតលាស់ទៅជាមួយគ្នា ៗ ក្នុងដំណើរនៃការចលនាវិវត្តន៍របស់គំនិត ភាសាវាមានសារៈសំខាន់ណាស់ ក្នុងការបញ្ចេញគំនិតឲ្យឃើញជាក់ស្តែងមកក្រៅ ៗ យើងទាំងអស់គ្នាល្បងគិតនៅក្នុងខួរយើងរាល់គ្នាមើលហើយ, យើងអាចយល់បានភ្លាមថា : ក្នុងសតិអារម្មណ៍ ដែលយើងកំពុងគិតនោះក៏មានខ្លីភាសាយកទៅពិចារណាដែរ ដែលយើងហៅថា : កម្មវត្ថុរឿង ៗ

ខ្ញុំគិតថា : កសិកម្មនៅក្នុងប្រទេសយើង បើមិនឆាប់ក៏យូរ មុខតែបានរីកចំរើន ៗ ខ្ញុំគិតក្នុងខួរក៏ដូចជាខ្ញុំនិយាយ ឬសរសេរដែរ ៗ ដូច្នេះ យើងទាំងអស់គ្នាយល់បានថា : សតិអារម្មណ៍យើង វាទៅដល់ណា ភាសាយើងក៏អាចទៅដល់នោះ បានដែរ ៗ ហេតុនេះហើយបានជាជីវភាពរបស់យើងទាំងអស់ ផ្នែកខាងស្មារតី ទោះបីជ្រាលជ្រៅយ៉ាងណា ក៏សំដីនិយាយឬភាសា វាអាចបកស្រាយបានទាំងអស់ ៗ

ភាសា គឺជាសំដីនិយាយដែលអាចកត់ត្រាបាន ៗ សំដីនិយាយ

មួយម៉ាត់ ៗ គឺជាសញ្ញាសំរាប់សំគាល់ទស្សនៈ ខាងផ្នែកតក្កវិជ្ជា គេហៅថា : " ទស្សនៈ " ចំណែកខាងភាសា ហៅថា : " ពាក្យ " ។

ឧទាហរណ៍ : ផ្កាម្លិះ ។ ផ្កាម្លិះគឺជាទស្សនៈមួយ នៃប្រភេទផ្កាមួយយ៉ាង ។ ផ្កាម្លិះគឺជា " ពាក្យហៅ " ផ្កាសំដៅរូបភាពខាងក្រៅ ចំណែកឯទស្សនៈ គឺជាអត្ថសេចក្តីខាងក្នុង ។ ពីព្រោះហេតុនេះហើយ បានជាយើងយល់ថា : ទស្សនៈនិងភាសាវាមានការទាក់ទងគ្នាជិតជិតណាស់ ហើយវាវិវត្តទៅតាមគ្នាថែមទៀតផង ។ ប៉ុន្តែមិនមែនពីព្រោះតែដូច្នេះ ហើយទៅថាប្រឡំបល់ រវាង ទស្សនៈនិងភាសា បានទេ ។ ការពិតទស្សនៈនិងភាសាខុសប្លែកគ្នាឆ្ងាយណាស់ ។ ទស្សនៈ គឺជាការដឹង ឬការយល់ចំពោះវត្ថុមួយ; ចំណែកឯភាសាគ្រាន់តែជាការយល់ព្រម សុខចិត្តប្រើតាមទាំងអស់គ្នា ដែលទៅជាទម្លាប់ប៉ុណ្ណោះទេ ។

ឧទាហរណ៍ ដូចជា: ទស្សនៈ "មនុស្ស" គឺគេនិយាយដល់មនុស្ស បើប្រសិនចាស់ពីដើម ប្រើពាក្យថា "កុយ" សម្រាប់ហៅថាមនុស្ស ក៏យើងមិនដឹងធ្វើម្តេចដែរ យើងត្រូវតែហៅតាម " កុយ " ជំនួសពាក្យថាមនុស្សដែរ ប៉ុន្តែចំណែកទស្សនៈវិញ គឺមិនប្រែប្រួលទេ គឺនៅតែមនុស្សដដែល ទោះហៅ " កុយ " ឬហៅ មនុស្ស ក៏ដោយ ។

ដូចរឿង : លោកគ្រូធំនាំសិស្សពីលើភ្នំចុះមកទីក្រុង ( សិស្សទាំងនោះ មិនដែលចុះមកម្តងសោះតាំងពីកើតមក ) មកដល់ខាងក្រោម

ឃើញស្រីៗល្អ សិស្សសួរលោកគ្រូថា : ស្អីហ្នឹងច្រើនម៉្លេះ ? ។ គ្រូឆ្លើយថា : ខ្ញា ។ គំនិតលោកគ្រូចង់ឆ្លើយថាដូច្នេះ ពីព្រោះចង់ឲ្យសិស្សខ្លាច ។ ដល់ត្រឡប់ឡើងទៅលើភ្នំវិញ លោកគ្រូសួរសិស្សថា : កាលចុះទៅក្រោម ឯងទាំងអស់គ្នាចូលចិត្តអ្វី? ។ សិស្សឆ្លើយថា: ខ្ញុំចូលចិត្តខ្លាណាស់ ។ ហេតុនេះបានជាយើងយល់ថា : ពាក្យសំដីគ្រាន់តែជារូបភាពផ្លាស់ប្តូរបាន តែមិនអាចដូចទស្សនៈបានទេ ហើយជាងនេះទៅទៀត ពាក្យសំដីច្រើនបែប អាចឲ្យទ្រូសនាមបានតែទស្សនៈមួយប៉ុណ្ណោះទេ ឧទាហរណ៍ដូចជា : ទស្សនៈ " ភ្នំពេញ " ។ គេអាចហៅថា : កងតានីក៏បាន គឺភ្នំពេញហ្នឹងហើយ គេអាចហៅថា " ភ្នំពេញ " ក៏បាន ។ ចាស់ពីដើមមានប្រើពាក្យច្រើនណាស់ ដូចជា គិតគា, ផ្ទះសម្បែង . . . ។ល។ ផ្ទុយទៅវិញ ក្នុងករណីខ្លះ ក៏មានពាក្យមួយម៉ាត់ ហើយឲ្យទ្រូសនាមទស្សនៈបានច្រើនដូច្នេះដែរ ពីព្រោះពាក្យយើងមួយម៉ាត់មានន័យច្រើនយ៉ាង ។

ដល់មកត្រង់នេះទើបយើងទាំងអស់គ្នាយល់ថា : ការនិយាយពាក្យសំដីខុសគ្នាបន្តិចបន្តួច : អ្នកខ្លះហៅ " ខ្ទរ " អ្នកខ្លះហៅ " ខ្ទា " ( ចំពោះពាក្យសំដីនិយាយ ) ពុំមិនខុសត្រូវអ្វីប៉ុន្មានទេ ឲ្យតែគេសរសេរអក្សរត្រូវ មានទស្សនៈត្រូវ ទុកជាការហើយ កុំប្រកាន់ច្រើនពេក ព្រោះបើប្រកែកឃើញថាប្រែត្រូវហើយ មានទស្សនៈត្រូវគ្នាគឺទុកជាបានការ ។

## គ_ លក្ខណៈឯកឯង និង លក្ខណៈទូទៅ

និយាយដល់លក្ខណៈឯកឯង និង លក្ខណៈទូទៅ មានមិត្តអ្នកអានភាគខ្លះឆ្ងល់ថា : តើគេចង់និយាយអំពីរឿងអ្វី ។ ការពិត នៅក្នុងរឿងតក្កវិជ្ជាមានគំនិតបែបនេះ ដែលគេហៅថា " ពាក្យសម្រាប់ប្រើនៅក្នុងតក្កវិជ្ជា " ។

លក្ខណៈឯកឯងគឺយ៉ាងណា ?

ទស្សនទិយមនីមួយ ៗ ( Concepts ) វាមានលក្ខណៈពីរយ៉ាង ។ លក្ខណៈទី ១ យើងហៅថា " លក្ខណៈឯកឯង ", លក្ខណៈទី ២ ហៅថា " លក្ខណៈទូទៅ " ។ លក្ខណៈឯកឯង គឺវត្ថុនោះជាអ្វី ? ជាវត្ថុយ៉ាងដូចម្តេច ? ។

លក្ខណៈទូទៅគឺយ៉ាងណា ?

គឺជាវត្ថុនោះ មានលក្ខណៈដូចគ្នានិងវត្ថុដទៃច្រើនទៀត ។

ឧទាហរណ៍ : សត្វឆ្កែ ។ លក្ខណៈឯកឯង គឺជាសត្វឆ្កែតែមួយយ៉ាង មិនមែនជាសត្វណាដទៃទៀត ។ ចំណែកឯលក្ខណៈទូទៅ គឺសត្វឆ្កែមានជើងបួន មានចង្កូម. . . ដូចជាសត្វជាច្រើនឯទៀត ។

ឧទាហរណ៍មួយទៀត : ដូចជាមនុស្ស ។ លក្ខណៈឯកឯងរបស់វាគឺជាសត្វចេះពិចារណា ចេះបង្កើត ឧបករណ៍ដើម្បីប្រើប្រាស់ ។ល។ លក្ខណៈទូទៅរបស់វា គឺមនុស្សចេះដើរ ចេះដេក ចេះស៊ី ដូចជា

សត្វដទៃ ៗ ដូចជាផ្លែចេក, ផ្លែស្វាយ, ផ្លែល្មុត, ផ្លែប៉េងប៉ោះ ។ល។ លក្ខណៈទូទៅ គឺផលទាំងអស់នេះសុទ្ធតែជា "ផ្លែ" ដូចគ្នា ប៉ុន្តែ លក្ខណៈឯកឯងគឺផ្លែល្មុតខុសពីផ្លែស្វាយ ផ្លែប៉េងប៉ោះក៏ផ្សេងពីផ្លែចេក គឺថាវាមិនដូចគ្នាទេ ។

និយាយសង្ខេបមកយើងយល់ថា : វត្ថុ សម្ភារៈ នីមួយ ៗ ដែល មនុស្សយើងយល់ថាមានលក្ខណៈពីរយ៉ាងគឺ : លក្ខណៈឯកឯងនិង លក្ខណៈទូទៅ ដូចយើងបានអធិប្បាយខាងលើ ។

## ឃ-ការទាក់ទងរវាងលក្ខណៈទូទៅនិងលក្ខណៈឯកឯង

លក្ខណៈទូទៅ និង លក្ខណៈឯកឯង ក៏មានការទាក់ទងគ្នាជិតជិត ណាស់ គឺវាទាក់ទងគ្នាតាមមាត្រដ្ឋាន (échelle) ផ្សេង ៗ ឧបមា: មនុស្ស ១០ នាក់ស្ទូងស្រូវ កន្លង ១០ ថ្ងៃហើយបានស្រែមួយ, ចុះ បើមនុស្សតែ ៥ នាក់វិញ តើស្ទូងកន្លងប៉ុន្មានថ្ងៃបានហើយ ? មនុស្ស ស្ទូងកាន់តែច្រើន ពេលវេលាហើយ កាន់តែខ្លី, មនុស្សស្ទូងកាន់តែតិច ពេលវេលាហើយ កាន់តែវែង ។ ឥឡូវយើងត្រឡប់មកបញ្ហាយើងវិញ ដើម្បីឲ្យយល់អំពីការទាក់ទងរវាងលក្ខណៈទូទៅនិងលក្ខណៈឯកឯង យើង សូមលើកឧទាហរណ៍ : ទស្សនទិយម " សត្វលោក " ។ សត្វលោក រួម មាន មនុស្ស, ឆ្កែ, ឆ្មា, ជ្រូក, មាន់ . . . ។ល។ ហេតុអ្វី

ក៏សត្វលោករាប់រួមមានច្រើនម៉្លេះ ? ពីព្រោះលក្ខណៈទូទៅវាធំទូលាយពេក ។ ហេតុអ្វីក៏លក្ខណៈទូទៅវាធំទូលាយពេកដូច្នេះ ?

ពីព្រោះលក្ខណៈឯកឯងវារួមមានតិចពេក ។ សត្វលោក គឺជាសត្វឡែតមានជីវិតចេះមានចលនាទៅលើផែនដី គេហៅថា: សត្វលោក ហើយដើរក៏បាន, លូនក៏បាន, លោតក៏បាន, ស៊ីបាយក៏បាន, ស៊ីស្មៅក៏បាន, ស៊ីសាច់ក៏បាន, កើតជាកូនក៏បាន, កើតជាពងក៏បាន ...

ប៉ុន្តែ ផ្ទុយទៅវិញ បើយើងថែមលក្ខណៈមួយដូចជា « មានដោះ » ទៅលើលក្ខណៈទូទៅទាំងនោះ គឺថា « សត្វលោកមានដោះ » ដូច្នេះ ចំនួនលក្ខណៈទូទៅវារួញតូចមកវិញ គឺថា មានតែមនុស្ស, ឆ្កែ, ជ្រូក... ទេ ចំណែកពស់ ឬ មាន់ ... មិនអាចរាប់បញ្ចូលផងបានឡើយ ។ ផ្ទុយទៅវិញ មើលលក្ខណៈឯកឯងវាកាន់តែច្រើនឡើង ដូចជាយើងបន្ថែមលក្ខណៈត្រង់ « ចេះពិចារណា » ។ គឺថា : ទស្សនទិយម « សត្វលោក » តែសត្វលោកមានដោះ និង ចេះពិចារណា » គឺមានតែមនុស្សមួយគត់ប៉ុណ្ណោះ ។

## ង. ទស្សនៈពូជ និង ទស្សនៈបំពូក

ក្នុងពេលពិចារណាប្រធាន គំនិតរបស់មនុស្ស មានទទួលទស្សនៈមួយគឺប្រធាននោះឯង ។ ប៉ុន្តែនៅក្នុងចក្រវាឡ វត្ថុនេះវាមានការ

ទាក់ទងនឹងវត្ថុនោះ សម្ភារៈនេះក៏មានការទាក់ទងនឹងវត្ថុនោះ ។ ការចេះដឹងរបស់មនុស្សក្នុងមួយថ្ងៃ ៗ ក៏ចេះតែរីកធំឡើង ព្រោះហេតុនេះហើយ បានជា ចំពោះទស្សនៈមួយមនុស្សមានការពិចារណាឲ្យធំទូលាយហើយយល់ទៅដល់វត្ថុផ្សេងដទៃទៀត ដែលមានសភាពប្រហាក់ប្រហែលគ្នា ។ បានសេចក្តីថា : ការពិចារណារបស់មនុស្សចំពោះវត្ថុមួយៗក៏អាចនាំឲ្យយើងយល់បានវត្ថុទូទៅ ប៉ុន្តែផ្ទុយទៅវិញ បើយើងពិចារណាយល់វត្ថុទូទៅបានហើយ យើងក៏អាចយល់បាននូវវត្ថុរៀង ៗ នីមួយ ៗ បានដែរ ។ និយាយយ៉ាងនេះ គឺយើងចង់និយាយអំពីការលូតលាស់នៃការពិចារណារបស់មនុស្ស ។ ក្នុងការចលនាពិចារណាលូតលាស់របស់មនុស្សមានទស្សនៈខ្លះក៏ទូទៅ និងមានទស្សនៈខ្លះក៏មិនទូទៅទេ ។ និយាយពាក្យថា : ទស្សនៈទូទៅ និងទស្សនៈមិនទូទៅ យើងនិយាយតែអំពីទស្សនៈ ដែលមានលក្ខណៈទូទៅណាដែលក៏ដូចគ្នា ។ បើលក្ខណៈទូទៅនោះមិនដូចគ្នា គឺយើងមិននិយាយដល់ទស្សនៈទូទៅឡើយ យើងហៅថា « ទស្សនៈពូជ », ទស្សនៈមិនទូទៅ យើងហៅថា « ទស្សនៈចំពូក » ។

ឧទាហរណ៍ :— « ទីក្រុង » — « រាជធានី » — « ភ្នំពេញ » « ភ្នំពេញ » — « រាជធានី » — « ទីក្រុង » ទាំង ៣ នេះ គឺជាទស្សនៈ ដែលមានលក្ខណៈទូទៅ គឺពាក្យថា « ទីក្រុង » ពីព្រោះទីក្រុង ក៏អាចរួមលក្ខណៈទាំងភ្នំពេញ ទាំងរាជធានី បាន ។

ទីក្រុងក៏ទូលាយជាងរាជធានី ពីព្រោះទីក្រុងទាំងអស់មិនមែនសុទ្ធតែរាជធានីទេ ។ ស្វាយរៀង, ព្រៃវែង, ក្រចេះ ក៏ជាទីក្រុងដែរ ។ រាជធានីទាំងអស់គឺជាទីក្រុង ភ្នំពេញគឺជាទីក្រុង ។ ដូច្នេះ យើងយល់ថា : ទស្សនៈ " ទីក្រុង " ក៏ទូលាយជាង " ធានី " ព្រោះហេតុនេះ យើងត្រូវហៅថា " ទស្សនៈពូជ ", ចំណែកឯ " ធានី " ក៏ចង្អៀតជាង " ទីក្រុង " យើងហៅថា : " ទស្សនៈចំពូក " ។

ឥឡូវយើងនិយាយដល់ " រាជធានី " និង " ភ្នំពេញ " ម្ដង ។ ទស្សនៈ "រាជធានី" ក៏ទូលាយជាងទស្សនៈ "ភ្នំពេញ" ។ ហ្លួងប្រាបាងជារាជធានី, ឡុងដ្រ៍ជារាជធានី, បាងកកជារាជធានី, ភ្នំពេញជារាជធានី, ប៉ុន្តែបើត្រឹមតែភ្នំពេញ គឺបានន័យតែមួយប៉ុណ្ណោះ ។ ដូច្នេះនិយាយសង្ខេបមក យើងយល់ថា " ទស្សនៈពូជ " ក៏ទូលាយជាងទស្សនៈចំពូក ។ ទស្សនៈពូជ ដូចគ្នានឹងលក្ខណៈទូទៅ ទស្សៈចំពូក ដូចគ្នានឹង លក្ខណៈឯកឯង ។

(នៅមានត)

អ្នកធ្វើ តែងតែមានខុស, មានតែអ្នក
ឱបដៃចាំតែថាគេ ដែលមិនចេះខុស ។

ល.ហ.អ.

–រូប បុ. អន្យរូប កិរិយាក្លែងខ្លួន, ប្រដាប់សម្រាប់ក្លែងខ្លួន, គុ. ដែលមានរូបមួយទៀត ដែលបន្លំ; អន្យរូបិន ដូចគ្នា ។ –លោក្យ គុ. ដែលជាអន្យលោក ។ –វណ៌តា ស្ត្រី. ភាវនៃ...មានពណ៌ ឬ វណ្ណមួយទៀត ។ –ស្ត្រីគ ស្ត្រី អន្យស្ត្រីគ អ្នកលួចប្រពន្ធអ្នកដទៃ ។ អន្យាទ្ឫឝ៑ គុ. ដែលយល់ឃើញផ្សេង, ប្លែក; –ទ្ឫឝ៑ ដូចគ្នា ។ អន្យេទ្យុស ក្រ.វិ ថ្ងៃតទៅ, ថ្ងៃមួយ ។

អន្យតស្ដ្យ បុំ សត្រូវ ។

អន្យតា ស្ត្រី. ភាពផ្សេងគ្នា ។

អន្យត្រ ក្រ.វិ. វៀរតែ, លើកលែងតែ, មួយទៀត ។ –មនស៑ គុ. ដែលមានចិត្តមួយទៀត ។

អញ្ញថា ក្រ.វិ ដោយប្រការផ្សេង ផ្សេងពី, ដោយខុស, ពុំនោះទេ ។ អញ្ញថ-ភូ ផ្លាស់ប្តូរ, អញ្ញថ-ក្ឫ ធ្វើដោយខុស កែប្រែ បន្ថុស ។ -ពុទ្ធិ ស្ត្រី. អនយពុទ្ធិ គំនិតខុស, យោបល់ខុស ។ -ភាវ បុំ អន្យភាព កិរិយាផ្លាស់ប្តូរ ។ -ភាវិត្វ នបុំ. ភាវនៃកិរិយាប្តូរដោយប្រការដទៃទៀត ។ -វ្ឫត្តិ ស្ត្រី. អញ្ញព្រឹត្តិ គុ. ដែលប្រព្រឹត្តទៅផ្សេង ។ -វ្ឫត្តិចេតស៍ គុ. ដែលមានចិត្តប្រព្រឹត្តទៅផ្សេង ។ -សំភាវិន៍ គុ. ដែលមានក្តីសង្ស័យ ។

អញ្ញទា ក្រ.វិ. ក្នុងខណៈដទៃ, ថ្ងៃមួយ ។

អញ្ញទីយ គុ. អន្យទីយ ដែលជារបស់អ្នកដទៃ ។

អញ្ញាយ បុំ. វិធីមិនទៀងទាត់ ។ -តស៍ ដោយមិនទៀងទាត់ ។ -វ្ឫត្តិ ស្ត្រី. កិរិយាប្រព្រឹត្តមិនទៀងទាត់, គុ. ដែលប្រព្រឹត្តមិនទៀងទាត់ ។ អញ្ញាយិន៍ គុ. ដូចគ្នា ។

អញ្ញាយ្យ គុ. ដែលមិនស្មើគ្នា ។

អនូន គុ. ដែលមិនបន្ថយ, គ្រប់គ្រាន់ ។ –អនូនាធិក គុ. ដែលមិនតិចមិនច្រើន ។

អញ្ញោញ្ញ គុ. ទៅវិញទៅមក ។ –កិច្ច នប៉ុ. អញ្ញោញ្ញកិច្ច, សេវាទៅវិញទៅមក ។ –គត គុ. ដែលផល់គ្នាទៅវិញទៅមក។ –ធម្មិ គុ. ដែលមានធម៌ទៅវិញទៅមក ។ –ប្រេមន៍ នប៉ុ. អញ្ញោញ្ញប្រេម ប្រេមទៅវិញទៅមក ។ –ភាវ ប៉ុ. អញ្ញោញ្ញភាព, កិរិយាប្តូរទៅវិញទៅមក ។

អន្វក ក្រិ.វិ. ពីខាងក្រោយ, ដោយខាងក្រោយ ។

អន្វក្ស គុ. ដែលដើរតាមក្រោយ ។ អន្វក្សម៌ ដោយប្រក្រតី ។

អន្វធិវតិ ក្រិ.វិ. ដោយបណ្តោយតាមដងស្ទឹងអធិវតី ។

អន្វញ្ចុ ធាតុ ដើរតាមក្រោយ, ហែហម ។

អន្វបជា ធាតុ បាត់ទៅតាមគ្នា ។

អន្វភិឞិច ធាតុ ប្រោសព្រំដោយ ។

អន្វយ ប៉ុ. អន្វយ៍, កិរិយាតគ្នា, កូនចៅ, គ្រួសារ ។ ចំណង ។

សម្ពន្ធពាក្យ ។ _វត្តិ គុ. ដែលសម្ពន្ធគ្នា, ដែលកើតមកតគ្នា ។ _អន្វយោគត គុ. ដែលត្រូវមានមតិក ។

អន្វយិ គុ. ដែលមានសេចក្តីតាមលំដាប់ ។ ដែលត្រឹមត្រូវតាមន័យ ។ _តស៏ ដោយន័យរបស់សព្វ ។ –សំជ្ញ គុ. ដែលដឹងច្បាស់តាមន័យរបស់សព្វ ។

អន្វរក្ខ ធាតុ សាបព្រោះទូទៅ ។

អន្វក្រម៏ ធាតុ ចុះតាមលំដាប់ ។

អន្វរុហ៏ ធាតុ ទៅដល់, ឡើងកាន់តាមគ្នា ។

អន្វសោ ធាតុ ស្អិត, ជាប់នៅ ។

អន្វាយ បុ. អន្វាយ, ពូជ, កូនចៅ ។

អន្វាជ៏ ធាតុ ធ្វើឲ្យឈឺចាប់ ។

អន្វេ (ឥ) ធាតុ ចូល, សន្យា, ធ្លាក់ក្នុង ។

អន្វេក្ស (ឦ) ធាតុ សំឡឹងមើល, ពិចារណា ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១២

(ក)

លោក ឌិក-គាម

ស្រាវជ្រាវ និង រៀបរៀង

កាលណោះ ព្រះបាទក្រុងពាលីរឹទ្ធិក្រៃក្រូវន័យគង់នៅទីសីហបញ្ជរ នោះ លុះបានឮទូតភីឃុខក្របីស្តីពាក្យថាដូច្នោះហើយ ពុំលង់ឡើយ ក៏ក្រេវក្រោធច្រឡោតខ្លាំងណាស់ ក៏ស្ទុះយ៉ាងរហ័សចាប់យកព្រះខ័នជ័យ ដ៏មុតថ្លា យាត្រាចុះតាកប្រាសាទកែវមណី សម្តែងរឫទ្ធិចូលជាញជ័យ ហោង ។

កាលណោះ កំហែងទូតភីរឹទ្ធិក្លា ក៏លោតចូលទៅតតាំងច្បាំងទប់ ទល់មួយរំពេចខ្ញី យុទ្ធក្របីក៏សម្តែងរឫទ្ធិច្បាំងគ្នាទៅវិញទៅមក ទាំងពីរ នាក់សុទ្ធតែពូកែមានរឫទ្ធិចំណាប់ អ្នកមួយកាប់ អ្នកមួយការ គេចវៃ វិលវល់ មិនគិតដល់ជីវិតទាំងសងខាងឡើយ ។ ហើយកាលណោះ ពាលីមានរឫទ្ធិក្លាហាន បានតរឫទ្ធិនឹងទូតភី តាំងតែពីវេលាព្រឹក លុះដល់ វេលាថ្ងៃរសៀលល្ងាច ទើបគិតថា ការសេះ មានរឫទ្ធិក្លាហានមហិមា ជាជាងអាខសគ្គណាអសុរ ឥឡូវនេះ អញនឹងកាប់សម្លាប់វាកណ្តាលវាល ឃើញមិនបាន ណ្ហើយចុះ មានតែអញនេះនឹងគិតល្បងល្បួងបញ្ឆោត

ពចូលទៅច្បាំងគ្នាក្នុងគុហាថ្មវិញ   ប្រហែលឃើញជាក់ទាល់ទីនឹងតេច ការ កំអញនេះនឹងឆាយកាប់សម្លាប់ឲ្យស្លាប់ហោង ៗ គិតហើយពាលី ក៏មានពាក្យទៅថា ម្នាលទូរពីរិទ្ធិក្លាហាន ព្រោះណាយើងទាំងពីរនាក់នេះ ច្បាំងគ្នាមក មិនឃើញចាញ់ឈ្នះគ្នា អ្នកក៏មានរិទ្ធា យើងក៏មានរិទ្ធិ ល្មម យើងទាំងពីរនេះជំនឹងគ្នាបាន ប្រមាណកម្លាំងរិទ្ធិប្រហែលគ្នា បើមិនទូរពី ឯង ក៏អញ គង់នឹងចាញ់ឈ្នះគ្នាដល់មរណាមួយៗ ពុំលែងឡើយ ដែល នឹងរួចរស់ជីវិតនោះគ្មានទេ កុំសង្ស័យ... ឥឡូវនេះ ថ្ងៃក៏អស្តង្គតផុត សែនស្មើ ចូលរាត្រីដល់ពេលងងឹតហើយ ណ្ហើយចុះ ឯងចូរត្រឡប់វិល ទៅផ្ដាំអស់ហ្វូងបរិវារឯងចុះ ខាងអញនោះ ក៏នឹងវិលទៅផ្ដាំអស់ពួកបរិវារ ពល នូវស្រីស្នំក្រមការអញហោង, ព្រឹកឡើង សឹមយើងទាំងពីរនាក់ មកច្បាំងគ្នាទៀត ក្នុងទីគុហាកែវស្របក្រាន្ត ឲ្យបានកំបាំងភ្នែកមនុស្ស និងគ្រុឌនាគវិជ្ជាធរកិន្នរនាគ អារក្សទេព្រក្សទាំងឡាយ ថាបើអ្នកណាអន្តរាយ ក្ស័យជីវិត ក៏មិនសូវខ្មាសគេផង ទាំងពលបរិវារទាំងពួងហោង ៗ

## សូមជំរាបអ្នកអាន

ដោយហេតុរឿងរាមកេរ្តិ៍វែងពន់ពេក មានរហូតទៅ ១១៧ ភាគ ដែលយើងចុះផ្សាយមក អស់បីឆ្នាំហើយ បានត្រឹមតែ ១២ ភាគនោះ, អ្នកស្រាវជ្រាវបានសុំយករឿងនេះ ទៅចុះផ្សាយ ក្នុងសារពត៌មានប្រចាំថ្ងៃវិញ ។

ដូច្នេះ យើងសុំបញ្ឈប់តែត្រឹមនេះ ហើយយើងសូមអភ័យទោសចំពោះសំណាក់អ្នកអាន ·

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

ដែលមាននៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

លោក ញ៉ុក-ថែម រៀបរៀង

( គ )

បំណងជើង: " សាស្ត្រា ផាវគុន "(១)

អ្នកនិពន្ធ: សែតាន់ នាមខ្លួចហុកកៀន ក្រោយមកត្រូវឲ្យឈ្មោះ

អ៊ិន វ៉ាត់ ( ឬ អ៊ិន-វ៉ត ) ។

កាលបរិច្ឆេទ: ថ្ងៃសៅរ៍ ខែចេត្រ ឆ្នាំរកានព្វស័ក ព.ស. ២៤៤០ ។

របៀបនិពន្ធ: ពាក្យកាព្យ ៧ និង ពាក្យ ៨ ។

---

● រឿងនេះ កវីមិនបានចាប់ផ្ដើមអត្ថបទរបស់ខ្លួន ដោយពោលសរសើរ ឬនមស្សការព្រះរតនត្រៃ ដូចកវីដទៃៗទេ បែរជាផ្ដើមអត្ថបទដោយថ្លែងសេចក្ដីស្នេហាផ្ទាល់ខ្លួនទៅវិញ ។ តបន្ទាប់មកទើបកវីនេះថ្លែងបទនមស្សការព្រះរតនត្រៃ រំលឹកគុណមាតាបិតាគ្រូអាចារ្យជាដើម បញ្ជាក់កាលបរិច្ឆេទ និងជីវប្រវត្តិខ្លះរបស់ខ្លួន និងបុព្វហេតុខ្លះ ដែលនិពន្ធរឿងចិនមកជាខ្មែរ ។

គួរឲ្យឆ្ងល់ណាស់ចំពោះរឿងកវីនេះ ដែលជារឿងព្រេងចិនឥតទាក់ទិននឹងស្រុកខ្មែរសោះ ប៉ុន្តែកវីបានភ្ជាប់រឿងស្នេហាមួយ រវាងក្សត្រស្រុកចិននិងក្សត្រស្រុកខ្មែរ ត្រាតែកើតចម្បាំងរាំងផល់យ៉ាងឃោរឃៅ ដោយចង់បានស្ត្រីមានឆោមឆើត ១ ឈ្មោះនាង ផាវ គុន ប៉ុណ្ណោះ ។ ប្រសិនបើគេពិនិត្យមើលឈ្មោះ តួអង្គក្ដី ឈ្មោះស្រុកក្ដី ឈ្មោះភ្នំ ស្ទឹង បឹងបួរក្ដី ឈ្មោះតួអង្គយក្សក្ដី ឥសីក្ដី ទេពតាក្ដី សុទ្ធតែជាឈ្មោះចិនទាំងអស់ ឥតមានឈ្មោះខ្មែរសោះ វៀរលែងតែការរៀបរាប់ពីទេសភាព ធម្មជាតិនានា ដូចព្រៃ បក្សី ម្រឹគ និងមច្ឆាជាដើម ទើបមានបែបជាខ្មែរ ។

ប្រភពរឿង: រឿងព្រេងរបស់ចិន ។

លក្ខណៈឯកសារ: សាស្ត្រាស្លឹករឹត ៩ ខ្សែចប់ ។

ខ្សែទី ១ មានសន្លឹក ៦៨, ទី ២ មានសន្លឹក ៥៣,
ទី ៣ មានសន្លឹក ៤០, ទី ៤ មានសន្លឹក ៤៨,
ទី ៥ មានសន្លឹក ៥០, ទី ៦ មានសន្លឹក ៤៤,
ទី ៧ មានសន្លឹក ៤៨, ទី ៨ មានសន្លឹក ៥១,
ទី ៩ មានសន្លឹក ៥៤ បូករួម ៤៥៦ សន្លឹក ។

ឯកសារនេះ គួរចាត់ទុកជាមហាកាព្យមួយ ចំពោះំណាព្យ កាព្យ ៧ ៨ ដែលពុទ្ធសាសនបណ្ឌិត្យបានចារចម្លង កាលពី ព.ស. ២៤៨៦ ចុះលេខសាស្ត្រា ១៣៨១ ។

អត្ថបទផ្ដើម: ។ ៧ ។ តាំងពីរៀមយល់ទិមិលមាស ទិលោមទិលាស
ឆោមឆើតឆាយ រៀមរេងគិតដល់សល់សែនឆ្ងាយ រូបស្ងួន
សែនស្ដាយថ្កើងលោកអើយ ។ ដូចកាលសេកសោមកជបណ្ឌិត
ឃើញអង្គជួបជិតកជបក្សី សារិកាកែវសត្វបាត់ស្មារតី ចាប់ចិត្ត
បេតិស្និទ្ធស្នេហា ។ . . .

ព្រះបាទសម្ដេចនរោត្តម គ្រប់គ្រងរៀបចំរាជសម្បត្តិ
ក្រុងកម្ពុជាប្រសើរក្រាត់ សម្បូរសម្បត្តិមាសកែវកង ។

ប្រទេសយើតុនចិនតាមផ្ចាំ  កូឡាភូមាសៀមលាវហោង
ចាំពាំងម៉ាទិលនិងយួនផង  មូលដកអឹងកង់គ្រប់ភាសា ៗ
ផ្ញៀប្រែលលក់ក្នុងភាព  ក្រុងកម្ពុជាពងរដ្ឋ
ប្រាកដប្រកបដោយប្រការ  ពាំងបុណ្យក្សត្រាប្រកបសុខ ៗ
ថ្ងៃសៅរ៍ខែចេត្រឆ្នាំរកា  ខ្ញុំណានទុកដូចថែនថុក
ឆីចាយពុំបានដេកពុំលក់  ព្រួយចិត្តគិតស្រុករលឹកស្រី ៗ
រងីរងំបែងវែងបេក្ខា  ពុំបានធ្វើការរកឆីអី
នៅផ្ទះហ៊ាគាតថៃវរស្ដី  ឲ្យលើករឿងចិនឈ្មោះដាវគុន ៗ
តាមអ៊ុមប្រាប់ប្រាយស្រាយជាខ្មែរ  ឆ្នាំមមែខែផល្គុណមុន
រឿងនេះពិពេះពន់ពេកស៊ុន  ជាជាងរឿងមុនឈ្មោះតិកឆេង ៗ

. . . . . ៗលៗ

អត្ថបទបញ្ចប់: ពាក្យនេះខ្ញុំលើកតាមរឿងចិន បើមិនសូវប៉ុនរៀន លើកល ជាក់ជាប្រាកដខ្ញុំប៉ុនរក៍មិនលកមិនលមិនលេងឡើយ ៗ បើអស់អ្នកផងយកទៅមើល កុំថាខ្ញុំព្រើលបងប្អូនអើយ ពាក្យនេះមិនសូវចួនកំឡើយ បើបាទះហើយជួយតម្រង់ផង ៗ មួយទៀតក្រែងប្រៀតជ្រួសអក្សរ តួមិនសូវល្អរៀនលើកម្ដង កុំសើចកុំដៀលខ្ញុំឡើយហោង ថែមពាក្យឲ្យផងកុំមោសា ៗ ដ្បិតរឿង

ជាគុណអម្បូរបិន  បើមិនស្រួលប៉ិនថែមពេលហោរ  មិនធ្អិនកុំឲ្យថែម
ទៀតណា  លើសពាក្យកុំថាលេងផ្តេសផ្តាស ៗ ពាក្យណាបើ
មើលមិនស្រួលបំ  កុំឲ្យបន្ទុំថាចាក់ប្រាស  រឿងចិនមានឈ្មោះគេ
ច្រើនណាស់ ចូរអានឲ្យច្បាស់តាមសេចក្តី ៗ លើកចប់ ១០ កើត
ថ្ងៃចន្ទសុទ្ធ ខែអស្សុជចំហុតពេលម៉ោង ៣ រសៀលសុំយោជ្រ
ទុទ័យ  ជួបចប់សេចក្តីបរិបូណ៌ហោង ៗ

×××

បំណងជើង: "សាស្ត្រា លិនថោង[១]"

អ្នកនិពន្ធ: រកពុំទាន់ឃើញ ៗ

កាលបរិច្ឆេទ: គ្មានបញ្ជាក់ក្នុងអត្ថបទ ៗ

របៀបនិពន្ធ: កាព្យ ពាក្យ ៧

ប្រភេទរឿង: រឿងព្រេងខ្មែរ

---

១ រឿងនេះ ប្រហែលកើតឡើងដោយឥទ្ធិពលនៃរឿងរាមកេរ្តិ៍ដែរ? ព្រោះវិបត្តិផ្សេងៗ ដែលកើតដល់គ្រួ ឬ សង្គម ច្រើនតែចេញពីប្រភពស្នេហា ៗ នាំឲ្យកើតចម្បាំងយ៉ាងឃោរឃៅ ប៉ុន្តែក៏បានទុកដាក់ជារឿងកតញ្ញូកតវេទីរបស់បុត្រ ចំពោះមាតាបិតា ហើយទុកដាក់ជារឿងជាតក១ ដោយបញ្ជាក់ថា លិវថោង ជាតួអង្គព្រះពោធិសត្វ ។ ការពិតតួអង្គនេះ គ្មានបានកសាងអ្វីទេ ថែមទាំងពោរពេញទៅដោយតណ្ហា ស្នេហ រាគៈ មានគំនុំគុំគួនព្យាបាទ បោកបញ្ឆោត សម្លាប់ យក្ខយក់ឥតខ្លាចពៀរវេរា ។

**លក្ខណៈឯកសារៈ** ច្បាប់សាស្ត្រាស្លឹករឹត ។ ឯកសារនេះមាន ៣ ខ្សែ មិនទាន់ចប់ទេ ។ ខ្សែទី ១ មានសន្លឹក ៣៥, ទី ២ មាន សន្លឹក ៣៥, ទី ៣ មានសន្លឹក ៣៨ ។ លេខសាស្ត្រា.. ។

**អត្ថបទផ្ដើម:** នេះនឹងពណ៌នាពោលថ្វាថ្លៃ ជាបទពាក្យល្បងតែងកាព្យ ប្រាំពីរពាក្យពិតគិតបួនឃ្លា តាមអដ្ឋកថាលោកនិទាន ។ ខ្ញុំលុតលើកករអញ្ជលីផ្គង់ បង្គំដល់អង្គព្រះទ្រង់ញាណ ក្រាបក្រោមគន់ចក្កលាយលក្ខណ៍មានសារពេជ្រគាញាណព្រះជិនស្រី ។

. . . . . . ។ល។

**អត្ថបទបញ្ចប់:** នាងស្ដាប់ពាក្យយក្ខយង់នោះ បន្ទូលទ្រគោះទៅវិញស្នង មិនបាច់អ្នកសួរខ្ញុំច្រើនផង ខ្ញុំគ្មានទំនង់អ្វីនឹងប្រាប់ ។ ខ្លួនខ្ញុំនេះឯងខ្ញុំថាជា ឥឡូវនេះណាអ្នកដឹងស្រាប់ បើអ្នកស្គាល់ហើយចូរអ្នកចាប់ ប្រាប់មកឲ្យដឹងឥឡូវនៃ ។ កាលយក្ខសើចចំអកទៅថា វៃហនាងពីតាសួនចើមថ្ងៃ ឥឡូវនាងឯងទុកក្នុងស្បៃ តើធ្វើម្ដេចនៃនឹងចាប់បាន ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ - ភា ឆ

ប្រែ-រៀបរៀង

( ៣ )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ—អ៊ិន

ស៊ុន គាំ ថា ខ្ញុំមានឧបាយ ១ មិនឲ្យព្រះចៅឡៅពីធ្វើអន្តរាយដល់លោកបានឡើយ ។ បេងគាត់មានអំណាចណាស់ សួរថា ឧបាយរបស់អ្នកនោះ គិតប្រការម្តេច? ស៊ុនគាំ ថា បងប្អូនខ្ញុំ ២ នាក់នេះ បានគិតគ្នាទុកជាយូរណាស់មកហើយថា នឹងចូលទៅនៅខាងចូកី បើលោកនឹងចង់រួចអំពីសេចក្តីស្លាប់ ត្រូវធ្វើសំបុត្រ ១ ច្បាប់ទៅលាព្រះចៅឡៅពី អធិប្បាយអំពីគុណនិងទោសឲ្យឃើញហើយ សឹមលោករត់ចេញទៅនៅនឹងចូកី ។ បានលោកហើយ ក៏គង់នឹងជប់លៀង ឲ្យបានធ្វើជានាម៉ឺនធំ សឹមយើង ២ នាក់បងប្អូននឹងរត់ទៅតាមក្រោយ ។ បេងគាត់យល់ឃើញត្រូវ ក៏តែងសំបុត្រ ១ ច្បាប់សេចក្តីថា ទូលបង្គំបេងគាត់ មានសេចក្តីខុស ពីព្រោះមិនបានលើកទ័ពទៅជួយស្រុកកេងជីវ ។ ក៏ខូច ស្លាប់ទាំងគួនអ៊ូទៅទៀត ។ បើទ្រង់

អត់ទោសទុកអាយុជីវិតទូលបង្គំ នឹងបាននៅធ្វើជាការកែខ្លួនតទៅ តែឥឡូវទូលបង្គំជាខ្ញុំងងឹត ថា ទ្រង់មិនប្រោសប្រណីឲ្យរួចពីសេចក្ដីស្លាប់ ហើយនឹងត្រាំនៅក៏ពុំបាន ហេតុនេះ ទូលបង្គំសូមក្រាបបង្គំលាទៅនៅខាងព្រះចៅប៉ូគីហើយ ដែលទូលបង្គំទៅតាំងនេះ នឹងបានប្រែចិត្តទៅគិតប្រទូសរ៉ាយទ្រង់វិញក៏ទេ ទៅដើម្បីតែប្រាថ្នានឹងឲ្យរួចពាកសេចក្ដីស្លាប់ប៉ុណ្ណោះ លុះធ្វើរួចហើយ ក៏ឲ្យបម្រើនាំទៅថ្វាយព្រះចៅឡៅតី ឯចំណែកខ្លួនក៏នាំទាហាន ៥០ នាក់រត់ចូលទៅនៅនឹងប៉ូគី តាំងពីពេលអធ្រាត្រក្នុងថ្ងៃនោះ ។

ព្រះចៅឡៅតី បានទទួលសំបុត្រ ទតឃើញសេចក្ដីសព្វគ្រប់ ក៏ទ្រង់ព្រះក្រោធខ្លាំងណាស់ត្រាស់ថា : អាសត្រូវវាគិតក្បត់នឹងអញហើយ ថែមតាំងឲ្យសំបុត្រមកឲ្យកបញ្ឈឺចិត្តឯងទៀត អញនឹងលើកទ័ពទៅតាមចាប់ខ្លួនវាឲ្យបាន ។ ខុនបេង ទូលទាស់ឃាត់ថា ទ្រង់កុំអាលឲ្យលើកទ័ពទៅ ឲ្យព្រួយលំបាកពលទាហានឡើយ សុំឲ្យមានសំបុត្រទៅដល់ឡៅហង ឲ្យលើកទ័ពតាមទៅចាប់បេងគាត់វិញស្រួលជាង បើឡៅហងចាប់បេងគាត់បាន ក៏នាំខ្លួនមកយើង បើចាប់មិនបានក៏គង់តែឡៅហងនឹងមាររកយើង ។ ក៏នឹងចាប់ខ្លួនសម្លាប់ចេញ បានដោយងាយណាស់ ។ ព្រះចៅឡៅតីយល់ឃើញត្រូវ ក៏ចាត់បំរើឲ្យនាំព្រះតម្រាស់ទៅដល់ឡៅហង ក្នុងសេចក្ដីព្រះតម្រាស់នោះថា បេងគាត់ប្រែចិត្តក្បត់រត់ទៅ

ចូលចូគី ឡេវឡៅហានលើកកងទ័ពទៅចាប់ខ្លួននាំមកថ្វាយឲ្យខានតែបាន ។

ខណៈនោះ ព្រះចៅចូគី ចេញទីយាយពងការផែនដី បណ្ដានាម៉ឺនមុខមន្ត្រីខ្ញុំពងការ ក៏គង់គាល់គ្រៀបគ្រា មានបំរើចូលទៅទូលថា បេងតាត់នាយទាហានឡេវតី ចូលមកសុំធ្វើពងការថ្វាយ ។ ចូគីក៏ឲ្យហៅខ្លួនចូលទៅ ហើយត្រាស់សួរថា ឯងចូលមកនេះ អញយល់ឃើញថា មិនមែនចូលមកដោយត្រង់សុចរិតទេ គឺមកជាកលឧបាយបញ្ឆោតយើង ។ បេងតាត់ទូលថា ទូលបង្គំជាមនុស្សមានទោស ព្រោះមិនបានលើកទ័ពទៅជួយគួនអ៊ូឯស្រុងកេងជីវ ។ ក៏ខូច គួនអ៊ូក៏ស្លាប់ ព្រះចៅឡេវតីនឹងសម្លាប់ទូលបង្គំចេញ បានជាទូលបង្គំមានសេចក្ដីភ័យខ្លាច ពុំអាចនឹងនៅបានដោះប្រាណតែចូលមកជ្រកក្រោមម្លប់ព្រះបរមពោធិសម្ភារជាទីត្រជាក់ដើម្បីនឹងបានផុតធុរៈពីសេចក្ដីស្លាប់ នឹងបានមកប្រែក្រឡាប់ជាឧបាយ ដោយចិត្តទុច្ចរិតដល់លួងចូគីក៏ទេ គឺជាសេចក្ដីពិតត្រង់ប្រាកដណាស់ ប៉ុន្តែចូគីក៏មិនអស់មន្ទិលសង្ស័យ មិនមានសេចក្ដីជឿ ។

ឯឡេវហាង បានឃើញព្រះតម្រាស់ព្រះឡេវភី ក៏ស្រូតលើកទ័ពចំនួន ៥ ម៉ឺន ទៅតាមបេងតាត់ ដល់ស្រុកយ៉ាំងយ៉ុង ទើបឲ្យទាហានទៅស្រែកហៅបេងតាត់ឲ្យចេញមកពីក្នុង មកតស៊ូគ្នា ។ ខណៈនោះ មានមនុស្សនាំសេចក្ដីទៅទូលព្រះចៅចូគី នៅចំពោះមុខបេងតាត់ថា ឡេវហាង បានលើកទ័ពជិតតាមបេងតាត់ មកដល់ស្រុកយ៉ាំង

យ៉ុង ៗ ចូគីក៏ត្រាស់នឹងបេងតាត់ថា បើអ្នកឯងមកស្វាមីភក្តិត្រង់នឹងយើងដោយសុចរិតពិតមែន ចូរលើកទាហានចេញទៅតច្បាំងនឹងឡៀវហង យកក្បាលឡៀវហងមកឲ្យយើងចុះ យើងនឹងបានឃើញសេចក្តីពិតត្រង់របស់អ្នកឯង ។

បេងតាត់ទូលថា : ឡៀវហងនោះក៏មានទោសខុសដូចទូលបង្គំដែរ មិនត្រូវទៅច្បាំងនឹងគ្នាទេ បើប្រសិនទូលបង្គំចេញទៅប្រាប់ឲ្យដឹងខ្លួនជាមានទោសហើយ ក៏គង់នឹងសរសើរទ្រង់ថា ចេះលើកតម្កើងពួកទាហាន ដែលមានថ្វីដៃ ។ ឡៀវហងក៏អស់សង្ស័យ គង់នឹងចូលមកនៅជាខ្ញុំទ្រង់ទៀត ។

ចូគីឮដូច្នោះ ក៏មានអំណរណាស់ ត្រាស់តាំងបេងតាត់ជានាយទាហានធំឲ្យឈរឆ្មើទៅហួយស្រុកអ៊ួនសៀងង ៗ គ្រានោះ ហៃហៅសៀង និង ស៊ីឡុង នាយទាហានចូគី ដែលចូគីប្រើឲ្យនៅស្រុកយ៉ាំងយ៉ុង ដើម្បីទៅបញ្ចុះបញ្ចូលមនុស្សក្នុងស្រុកសៀងយ៉ុង; លុះឃើញបេងតាត់ទៅនៅស្រុកយ៉ាំងយ៉ុង, ហៃហៅសៀង និង ស៊ីឡុង ក៏ចេញទៅទទួលគំនាប់ដោយបដិសណ្ឋារៈ ហើយក៏នាំចូលទៅស្រុកនោះ ថ្ងៃពណ៌នាប្រាប់បេងតាត់ថា ឡៀវហងលើកទ័ពមកតាំងបន្ទាយនៅជិតស្រុកយ៉ាំងយ៉ុង ចម្ងាយផ្លូវប្រហែល ៥០០ សិន ( ២០ គ.ម ) បេងតាត់ក៏សរសេរសំបុត្រ ១ ច្បាប់ ឲ្យបម្រើកាន់ទៅបញ្ចុះបញ្ចូលឡៀវហង ៗ

ឃើញសំបុត្រហើយក៏ ខឹងណាស់ថា  អាក្បត់កបង់ធ្វើឲ្យអញខុសជាមួយផង  ពាជាមនុស្សមិនត្រង់នឹងម្ចាស់  ស៊ីបាយក្រហាម  ថែមទាំងឲ្យយើងបានសេចក្តីខុសទៀត  ថាហើយក៏ហែកសំបុត្រនោះចោលទៅហើយបង្គាប់ឲ្យចាប់ខ្លួនបំរើដែលកាន់សំបុត្រនោះទៅសម្លាប់បង់ ។

ចេងគាត់ បានដឹងដូច្នោះ ខឹងណាស់ ប្រឹក្សានឹងហៃហៅសៀងស៊ីឡុងថា ពេលព្រឹកស្អែក ចូរឲ្យអ្នកទាំង ២ លើកទាហានទៅបង្កប់នៅសងខាងផ្លូវ ឯខ្លួនខ្ញុំនឹងលើកទាហានចេញទៅច្បាំងនឹងឡៅហង់ហើយនឹងធ្វើជាថយមកតាមផ្លូវនោះ  បើឡៅហង់ដេញតាមផ្លូវនោះមក  អ្នកទាំង ២ ចូរលើកទាហាន  ចេញវាយប្រសព្វគ្នាចាប់យកខ្លួនឡៅហង់ឲ្យបាន  ហៃហៅសៀង នឹងស៊ីឡុងយល់ឃើញត្រូវ  ក៏លើកទាហានទៅពួនបង្កប់សងខាងផ្លូវដែលគិតទុកនោះ  ។

លុះវេលាព្រឹកឡើង  ឡៅហង់  លើកទាហានចេញពីបន្ទាយ  ឲ្យទាហានចូលទៅស្រែកដេរចេងគាត់  ហៅឲ្យចេញមកតស៊ូគ្នា ចេងគាត់ក៏ជិះសេះកាន់លំពែងចេញមុខទាហាន ឡៅហង់ក្រឡេកឃើញ  ក៏បន្តុលមុខហើយស្រែកថា  អាចោរចិត្តក្បត់ម្ចាស់  ផ្លាស់ស៊ីបាយក្រហាម ហេតុម្តេចបានជាមកលួងលោមអញឲ្យអាក្រក់តាមឯងទៀត  ។  ចេងគាត់ស្រែកថា ឯងជាមនុស្សទោស  នឹងដល់នូវសេចក្តីស្លាប់ឆាប់ហើយ ម្តេចក៏មិនទាន់ដឹងថា សេចក្តីស្លាប់នោះនឹងមានមកដល់ឡើយដូច្នោះ អាចោរ

ដកទ័ព ម្តេចក៏នៅលើកតម្កើងថាខ្លួនឯងល្អវិញ ៗ ឡៅហង់ខឹងណាស់ បំបោលសេះកំផ្ទាវចូលទៅប្រយុទ្ធគ្នានឹងបេងគាត់បាន ៣ ក្បួន បេងគាត់ក៏ធ្វើជាថយរត់ទៅក្រោយ ឡៅហង់ក៏ដេញបណ្តោយតាមទៅបានចម្ងាយប្រហែល ២០០ សិន ( ៨ .គ.ម ) នោះ វៃហៅសៀងនិងស៊ីឡុង ដែលពួនបង្កប់ ក៏លើកទាហានចេញទៅវាយប្រសព្វទាំងសងខាង បេងគាត់ក៏ស្ទាក់កាត់ពីមុខចូលមកទៀត ឡៅហង់ឃើញកងទ័ពវាយផ្ទប់ទាំង ៣ ផ្លូវ នឹងបំពារទៅមិនរួច ក៏នាំទាហានពារចំណាយរត់ទៅតាមផ្លូវ ត្រង់លើស្រុកសុងយ៉ុង បេងគាត់និងវៃហ-ហៅសៀង, ស៊ីឡុង ក៏លើកទាហានដេញតាមទៅ ៗ

ស៊ីឡុងនិយាយថា ឥឡូវកងទ័ពឡៅហង់ខ្ទេចខ្ទីអស់ហើយ បើអ្នកទាំង ២ លើកតាមទៅទៀត ក៏គង់នឹងបានជ័យជំនះមិនខាន ឯស្រុកសុងយ៉ុង ដែលឡៅហង់រត់តម្រង់ទៅនោះ ជាទីមាំមួនណាស់ ក្រែងតែស្រុកហាងឡេង ជាទីកន្លែងមិនសូវមាំមួន ខ្ញុំនឹងសុំលើកទាហានទៅចាំរក្សាទីនោះ បេងគាត់និងវៃហៅសៀង ក៏យល់ឃើញត្រូវ ស៊ីឡុងក៏លើកទាហានតម្រង់ស្រូតទៅនៅដល់ស្រុកហាងឡេង ឯឡៅហង់នោះលុះរត់ទៅដល់ស្រុកសុងយ៉ុងក្នុងវេលាកណ្តាលយប់ស្ងាត់ ក៏ចូលទៅគោះទ្វារឱ្យអ្នកយាមបើកទទួល ៗ

ខណៈនោះ ស៊ុនគាំ ដែលនៅរក្សាស្រុកសុងយ៉ុង ក៏ចូល

ទៅចំណុះខាងចូកអស់ហើយ លុះដឹងថា ទៀវហានទៅហៅឱ្យបើក ទ្វារ គឺម្នីម្នាដេញទាហានឱ្យឡើងរក្សាស៊ុនបន្ទាយ ហើយឱ្យពយ ទាហានបាញ់ធ្នូបម្រុះទៅត្រូវទាហានទៀវហានស្លាប់ច្រើនណាស់ ស៊ុនតាំ ក៏ឡើងទៅលើស៊ើន ពីខាងមុខហើយស្រែកថា យើងស្ម័គ្រទៅចំណុះ ជាខ្ញុំព្រះចៅចូកហើយ ទៀវហានឮដូច្នោះ ក៏រឹតតែខឹងណាស់គិតនឹង ឱ្យទាហានទម្លាយយកស្រុកស៊ុងយ៉ុងឱ្យបានវិញនោះស្រាប់តែកងទ័ពហៃ-ហៅសៀង លើកទៅដល់វាយខ្ទប់ពីក្រោយ ទៀវហានក៏នាំទាហាន រត់បណ្ដាយតម្រង់ទៅស្រុកហាន់ឡេង ក្រឡេកទៅឃើញទង់ដោតនៅ លើស៊ើន មានអក្សរក្នុងទង់នោះថា ស្រុកនេះ ជាចំណុះព្រះចៅចូក ។

ស៊ុនងី ដែលនៅរក្សាស្រុកនោះ ឡើងឈរពីលើស៊ើនគ្រវីទង់ ជ័យ សញ្ញាហៅទាហានឱ្យទៅជម្រាបស៊ុយឡុង ។ ក៏លើកកងទ័ពចេញ ទៅតាមវាយកងទ័ពទៀវហាន ។ តទល់ពុំបាន ក៏នាំទាហានរត់ទៅ ស៊ុយឡុង ក៏បរពលដេញសំដៅពីក្រៅកាប់សម្លាប់ទាហានទៀវហានស្លាប់ ច្រើនណាស់ ទៀវហានក៏នាំទាហាន ដែលសល់ខ្លះ រត់ទៅដល់ស្រុក សែឈួន ហើយចូលទៅគាល់ព្រះចៅទៀវពី ក្រាបទូលហើយក៏យំទូល រាប់រៀប តាមដំណើរការណ៍ ដែលបានលើកទ័ពទៅតាមចាប់បេងគាត់ តាំងពីដើមដល់ចុងអស់សេចក្ដី ។

ព្រះចៅទៀវពីទ្រង់ខ្ញាល់ខ្លាំងណាស់ ស្រែកដេរថា អាកូនចោល

មឿត កើតមកឲ្យបង់ជាតិ នៅធ្វើមុខថ្លៃបែរមករកអញធ្វើអ្វី ឡៅហាង ទូលថា កាលពីគ្រាគួនអ៊ី ទូលព្រះបង្គំឲ្យមានសំបុត្រមកសុំកងទ័ព ទៅជួយស្រុកកេងដីវ៉នោះ ទូលព្រះបង្គំបានឲ្យបម្រុងពលទាហានត្រៀម ទុកជាស្រេចហើយ ប្រុងនឹងលើកទៅជួយជាប្រាកដ តែបេងតាត់ ឃាត់ហាម មិនព្រមឲ្យលើកទៅ បានជាថយស្គាយដោយហេតុនោះ ។

ព្រះចៅឡៅពីត្រាស់ថា អញខាតកម្លាំងបង់ចិត្ត ដែលអាណិត ស្រឡាញ់ឯង ប្រឹ ស្បែងចិញ្ចឹមឯងមក ហាក់ដូចគេយកដុំឈើឬដុំដីមក រក្សា វាគ្មានដឹងការខុសត្រូវបន្តិចសោះ គួរអ៊ីវាទៅជឿស្តាប់ពាក្យសំដីអា បេងតាត់នោះ វាជាសត្រូវក្បត់ បានជាវាមិនព្រមឲ្យលើកកងទ័ពទៅជួយ គួនអ៊ីជាប្អូនអញ ឲ្យតាញ់ស្លាប់អសារ ត្រាស់ហើយក៏បង្គាប់ឲ្យយកខ្នុង ឡៅហាងទៅប្រហារជីវិត កាលព្រះចៅឡៅពីឲ្យសម្លាប់ឡៅហាងនោះ លុះ ក្រោយក៏ទ្រង់នឹករឭកឃើញសំដីដែលឡៅហាងទូលរាប់រៀបថា បេងតាត់ មានសំបុត្រមកបញ្ចុះបញ្ចូលឡៅហាងៗហែកសំបុត្រចោល ហើយសម្លាប់ អ្នកកាន់សំបុត្រនោះចេញ ក៏ឃើញថាចិត្តឡៅហាងនោះមិញ ជាមនុស្ស ត្រង់សុចរិត នឹងព្រះអង្គប្រាកដណាស់ ទ្រង់នឹកឃើញច្បាស់ ក៏គិត អាណិតស្តាយពន់ប្រមាណមានព្រះទ័យអាល័យស្តាយទៅដល់គួនអ៊ីទៀត ក៏រឹតតែចង្អៀតព្រះទ័យសព្វគ្រប់ ព្រះពេកកបណ្តាលឈឺខ្លាំងខ្ទប់សព្វមំសា ការដែលគិតនឹងលើកពលយោធាទៅច្បាំង ក៏បង្អង់ខានវិញ ។

ចប់ខ្សែ ៦៣ សូមរង់ចាំអានខ្សែទី ៦៤ ទៀត

# ជីវប្រវត្តិរបស់ខ្ញុំ

## ឈ្មោះ អៀង-សាយ

(ត)

មានរឿងបែបនេះ ១ ទៀត ខ្ញុំមានប្រកាសតែងតាំងតែត្រឹម ត្រូវបង្ហាត់ការតិចនិក ( ម៉ូនីទ័រ ទេ ឡង់សែញ៉េមង់ តិចនិច ) តែដោយបង្រៀននៅវិទ្យាល័យ គេសំគាល់ថាជាសាស្ត្រាចារ្យ ( ប្រូហ្វេស័រ ) ដោយខ្ញុំជាគ្រូថ្នាក់ផុតលេខ ចូលទៅថ្នាក់ពិសេសទៀត គេសំគាល់ថាខ្ញុំ មានឋានន្តរសក្តិខ្ពស់ជាងគេនៅសាលានេះ រឿងកល់ពិធីបុណ្យទាំងសមាសដែលគេប្រារព្ធធ្វើក្នុងវាំង, នៅកំពង់ផែឬកលមេរុ គ្រប់ក្រសួងទាំងអស់ ត្រូវចាត់ម្នាក់ ឬពីរ បីនាក់ឲ្យទៅរួមក្នុងពិធីនោះ ដោយដាក់ឈ្មោះក្នុងបញ្ជីបញ្ជូនទៅឲ្យគេមុន គេតែងតែតម្រូវមកឈ្មោះខ្ញុំឲ្យទៅរួមក្នុងពិធីនោះ ចំពោះព្រះករុណាជាអម្ចាស់ ចំពោះព្រះកត្រៃសម្តេចព្រះមហាក្សត្រិយានី ឬចំពោះព្រះកត្រៃសម្តេចព្រះប្រមុខរដ្ឋ ។

កាលនោះឋានន្តរសក្តិខ្ញុំ គេដាក់ថា សក្តិ៧ហ៊ូពាន់ ខ្ញុំត្រូវមានសំពត់ផាមួង ៧ ពណ៌ខុសគ្នា ស្លៀកចង្កេះរើសយកពណ៌តាមថ្ងៃ ពាក់អាវកុតសកត្រង់ មានសក្តិនៅលើស្មា និង នៅចុងដៃអាវ ហើយត្រូវមានខ្សែក្រវាត់ពុំព័ទ្ធពីលើអាវត្រង់ចង្កេះទៀត ដោយខ្ញុំមានមេដាយប្រាំ-ប្រាំមួយពាក់ព្យួរពេញ ១ ចំហៀងទ្រូងខាងឆ្វេង ។ មានពេល ១ ខ្ញុំ

ចូលទៅក្នុងទេការិទិច្ឆ័យមុនពេលម៉ោងបន្តិច មានលោកម្នាក់ងាកមក ឃើញខ្ញុំខំសម្លឹងបែបពិនិត្យ ហើយខ្សឹបសួរលោកម្នាក់ដែលឈរនៅជិតនោះ ខ្ញុំមិនឮទេ តែខ្ញុំដឹងមកពេលក្រោយ ដោយលោកដែលឈរជិតនោះប្រាប់ខ្ញុំថា គេសួរថា ខ្ញុំនេះធ្វើជាស្អីក៏សម្លៀមម៉្លេះ គេប្រាប់ថា ខ្ញុំធ្វើជា ប្រូហ្វេស័រ ។ លោកដែលសម្លឹងមើលខ្ញុំនោះងាកទៅខាងណោះ ងាកទៅខាងណេះ សសៀរមកដល់ជិតខ្ញុំ សួរខ្ញុំដោយញញឹមថា លោកជាន់ណាឯចេះ? មុនខ្ញុំឬក្រោយខ្ញុំ? ។ ខ្ញុំឮពាក្យនេះខ្ញុំយល់ថា លោកដែលសួរខ្ញុំនេះ លោកនឹកថា ខ្ញុំមានមេដាយសក្តិយសយ៉ាងនេះ ហើយធ្វើជាប្រូហ្វេស័រ ច្បាស់ជាមានឌិប្លូម ឬ បាស្យូ បើតិតដូចនេះ ម្តេចក៏មិនប្រហាក់ប្រហែលមុខសោះ ពីព្រោះកាលនោះគ្មានលិសេ គ្មានកូឡែសឯណា ក្រៅពីកូឡែសស៊ីសុវត្ថិទេ មុននឹងបានឌិប្លូម បាស្យូត្រូវរៀនតាំងពីថ្នាក់ទី ៦ ឡើងមកដល់ថ្នាក់ទី ៣ ទី ២ ទី ១ ដែលក្នុងរវាងប្រាំឆ្នាំ ទោះបីរៀននៅថ្នាក់ណា ក៏គង់តែស្គាល់មុខគ្នាដែរ ដោយគ្មានប្រហាក់ប្រហែលខ្ញុំសោះ ទើបបានជាគេសួរថា ខ្ញុំរៀនជាន់ណាពីឆ្នាំណា មុនគេឬក្រោយគេ បានសេចក្តីថា ក្រែងខ្ញុំរៀនមុនប្រឡងជាប់ចេញមុនមក គេចូលមករៀនក្រោយ ឬថា គេរៀនមុនខ្ញុំ គេចេញមុនបាត់មក ទើបបានខ្ញុំចូលទៅរៀនក្រោយ ។ គេឆ្ងល់ទើបគេសួរថា "លោកមុនខ្ញុំ ឬក្រោយខ្ញុំ"

ខ្ញុំតបយ៉ាងខ្លីថា រឿងកវែងណាស់ លោកសួរខ្ញុំពេកឆ្លើយមិនបានទេ ចាំមានពេលវែង សឹមខ្ញុំដំណាលពីរឿងនេះនៅឯណាពីឆ្នាំណា ។

ខ្ញុំជាសមាជិកចាស់ម្នាក់នៃសមាគមអ្នកនិពន្ធខ្មែរ បានជាប់ឈ្មោះជាសមាជិកក្រុមអភិបាលប៉ុន្មានឆ្នាំដែរ ហើយមានបានជាប់ឈ្មោះជាប្រធាននៃគណៈកម្មការសិល្បៈផង ថែមទាំងបានធ្វើជាមេប្រយោគក្នុងការប្រឡងអក្សរសាស្ត្រឥន្ទ្រទេវីលើកទី ១ ទៀត ។

កាលខ្ញុំនៅក្នុងឋានៈ ជាប្រធាននៃគណៈកម្មការសិល្បៈ ខ្ញុំបានគូរប្រចំណោទ ដាក់ចំណងជើងជាពាក្យកាព្យ និងបានសរសេរអត្ថបទដែលពន្យល់អំពីការសរសេរ ការអានសំបុត្រតារបុស ព្រមទាំងបរិហារការស្មាត់គំប៉ាំងល្បែងលេងកល់ថ្នូនក្នុងខ្ទះ និងសរសេរអត្ថបទរៀបរាប់ពីល្បែង ដែលគេលេងក្នុងឱកាសចូលឆ្នាំថ្មីពីដើម ដាក់ក្នុងទស្សនាវដ្តីអក្សរសាស្ត្រ គ្រាន់តែឈ្មោះទស្សនាវដ្តីនេះ ក៏ខ្ញុំដាក់ស្នើសូមឲ្យយកឈ្មោះនេះដែរ ។

នៅភាគខាងដើមខ្ញុំមាននិយាយអំពីគំនិត ដែលខ្ញុំគិតអប់រំកូនយ៉ាងនោះ ខ្ញុំយល់ថា ត្រូវបញ្ជាក់អំពីលទ្ធផលឲ្យឃើញថា បំណាច់នឹងអ្នកជាខ្ញុំនេះអប់រំកូន តើកូនទាំងអស់នោះបានទៅជាស្អីទៅ?

១– ឈ្មោះ អៀង-សាតុប៉ុន មានឧបួមហើយខ្ញុំមិនឲ្យធ្វើការទេ ឲ្យរៀនខាងពេទ្យទៀត បានសញ្ញាបត្រខាងមន្ត្រីសុខាភិបាល

ហើយបានបន្តវិជ្ជា យកហាំងទន្ទជាវេជ្ជបណ្ឌិតទៀត គ្រូពេទ្យនេះ ខ្ញុំឲ្យមានប្រពន្ធ តាំងពីកាលប្រឡងបានឌីប្លូម មានប្រពន្ធកូនហើយក៏នៅតែរៀន ។

២– អៀង គុនសាគី រៀនបានឌីប្លូម-ព្រេវេនៅស្រុកខ្មែរ ទៅរៀនយកបាស្ស៊ី និង លិស្សង់ឯស្រុកបារាំង បានបាស្ស៊ីហើយជិតនឹងដល់បានប្រឡងយកលិស្សង់ មានរឿងពីធ្វើនយោបាយគេបញ្ឈប់លែងឲ្យរៀន មកធ្វើជាសាស្ត្រាចារ្យ មានប្រពន្ធកូនហើយ ឥឡូវនៅធ្វើការឯប្រទេសបារាំងជាអ្នកចាត់ចែងអគ្គការយូណេស្កូ ហើយនឹងក្រសួងអប់រំជាតិ នៃព្រះរាជរដ្ឋាភិបាលយើង ។

៣– អៀង-ស៊ីសាគីម កូនស្រី រៀនបានវិញ្ញាបនប័ត្របឋមសិក្សាប្រឡងជាប់ចូលរៀននៅអនុវិទ្យាល័យនារី ( អនុវិទ្យាល័យព្រះនរោត្តម ) តែមិនទាន់បានប្រឡងឌីប្លូម ដោយមិនចង់ឲ្យរៀនយូរ ចង់ឲ្យបានធ្វើការឆាប់ ដ្បិតជាស្រីចេះប៉ុណ្ណឹងបានហើយ ឲ្យមករៀនធ្វើគ្រូបង្រៀនវិញ ឥឡូវធ្វើការនៅមណ្ឌលអប់រំគរុវិជ្ជា ឯកំពង់កន្ទួត មានប្ដីធ្វើគ្រូ ធ្វើការនៅជាមួយគ្នា ។

៤– អៀង-ស៊ុមសាគូ ប្រឡងបានព្រេវេ ហើយទៅរៀនខាងវិជ្ជាបសុពេទ្យ ជាប់បានឌីប្លូមខាងវិជ្ជានេះ សព្វថ្ងៃធ្វើការជាអគ្គិបាលការពារដម្ងៃនិងចិញ្ចឹមសត្វ នៅមណ្ឌលស្ទឹងមានជ័យ មានប្រពន្ធធ្វើគ្រូបង្រៀន ។

ប្រវត្តិរបស់ខ្ញុំ មិនមែនសុទ្ធតែមានរឿងល្អទេ រឿងអាក្រក់ក៏មានច្រើនណាស់ដែរ តែគ្មានប្រយោជន៍ទាំងអស់ទេ មានតែពីរ ដែលខ្ញុំយល់ថា មានប្រយោជន៍ ដោយចង់ឲ្យគេជឿហើយជៀសវាងកុំធ្វើតាមខ្ញុំ សូមសុំត្រឡប់ទៅមើលសេចក្តីខាងដើមមួយភាគ ដែលខ្ញុំនិយាយអំពីអុចធូប ៣ សរសៃថ្វាយព្រះពុទ្ធរូប ហើយនិយាយប្រកាសចំពោះព្រះពុទ្ធរូបយ៉ាងណានោះ ខ្ញុំនិយាយយ៉ាងនេះ ដូចជាខ្ញុំស្បថចំពោះព្រះភក្ត្រព្រះហើយ ខ្ញុំភ្លេចពាក្យដែលខ្ញុំប្រកាស ដូចជាខ្ញុំភ្លេចពាក្យសំបថរបស់ខ្ញុំ ។ យល់ហើយជឿជាក់ថា ពាក្យសំបថដែលយើងស្បថយ៉ាងណា ហើយយើងមិនបានកាន់ខ្ជាប់ មិនបានប្រតិបត្តិតាមពាក្យយើងនោះ គឺទៀងតែពិមានហេតុ មានផលមិនបាត់សាបសូន្យទេ ( សូមត្រឡប់ទៅបើកមើលត្រង់ទំព័រដែលនិយាយរឿងនេះមួយទំព័រ រួចវិលមកអានបន្តទៅទៀត ) ។

ដោយខ្ញុំប្រហែសមិនបានយកប្រាក់ ២ រៀល ទៅប្រគេនលោកគ្រូខ្ញុំ ដោយអៀនខ្មាសលោក មួយទៀតលោកមិនជ្រាបពីរឿងលួចលាក់ប្រាក់លោកទុកនោះផង ម្លោះហើយក៏បំភ្លេចចោលតែម្តងទៅ ។

លុះដល់មកធ្វើការរកប្រាក់បានដល់ហ្នឹង ហើយគ្មានប្រាក់ទុក នៅតែក្រ នៅតែមានការខ្វះខាត ទើបនឹកឃើញដល់ពាក្យ ដែលប្រកាសដូចជាបានស្បថចំពោះព្រះពុទ្ធរូប ខ្ញុំយល់ហើយជឿជាក់ថា ប្រាកដជាបាបកម្ម ដែលខ្ញុំមិនបានសងប្រាក់ ២ រៀលនោះហើយ ទើបនាំឲ្យខ្ញុំនៅ

តែក្រ នៅតែមានការខ្វះខាតដូច្នេះ ខ្ញុំចង់យកប្រាក់ពីរពាន់ ជំនួសប្រាក់ពីររៀលទៅសងលោកគ្រូខ្ញុំ ដើម្បីឲ្យរួចកម្មពៀរ ឲ្យអស់បាបកម្ម ដោយចង់មានចង់បានដូចគេ កុំឲ្យនៅតក្រល់បាកនិងការខ្វះមុខខ្វះក្រោយដូច្នេះ តែលោកគ្រូខ្ញុំ លោកផ្លាស់ភេទទៅជាឃរាវាស មានប្រពន្ធកូននៅឯស្រុកបាកាន ខេត្តពោធិ៍សាត់ លោកអនិច្ចកម្មបាត់ទៅហើយ ព្រមទាំងប្រពន្ធកូនលោក ក៏មិនដឹងជានៅឯណា ។

ជំនឿរបស់ខ្ញុំត្រង់នេះ បើមានលោកអ្នកណាមិនជឿដូចខ្ញុំ ដោយយល់ហេតុផលផ្សេងទៅវិញ ប្រហែលជាលោកអ្នកនោះ មិនជឿពាក្យចាស់ ៧ ឃ្លា ដែលថា: រីបុណ្យនិងបាប អំពើជាកទាប នោះវាគង់តាម បីដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលជៀសបាន ត្រង់ក្តីវិលវល់ ។

សូមបញ្ជាក់បញ្ចប់១ភាគនេះថា ខ្ញុំមិនសំគាល់ថា ការស្បថចំពោះព្រះពុទ្ធរូប ហើយព្រះពុទ្ធរូបទៅធ្វើគេឲ្យទៅជាយ៉ាងនេះយ៉ាងនោះ ៗ ទេ ដ្បិតព្រះពុទ្ធរូបគ្មានវិញ្ញាណ គ្មានទៅធ្វើអ្វីកើតទេ គ្រាន់តែស្តាប់ពាក្យយើងស្បថ ក៏គ្មានប្រដាប់និងឲ្យឮថាដូចម្តេចដែរ បើមិនឮក៏មិនដឹង បើមិនដឹងហើយ ទៅបណ្តាលឲ្យគេទៅជាមាន ជាក្រម្តេចនឹងបាន ។

បើគេចង់ដឹងអំពីគំនិតដែលខ្ញុំគិតយល់ឃើញថា អ្វីដែលនាំឲ្យមានបាបកម្ម ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់នោះ? បើនិយាយដោយ

ចំពោះ ថាយើងស្បថចំពោះព្រះភក្ត្រព្រះ ដល់យើងបំពានសំបថ តើអ្វី ដែលទៅធ្វើទោសយើង? តាមខ្ញុំយល់ ខ្ញុំឆ្លើយថា គឺ "ធម្មជាតិ" ពុំមែនតែបណ្តាលឲ្យមានហេតុ មានផលជាធម្មតាយ៉ាងនេះ គ្មានតួអង្គណាទៅធ្វើឲ្យទឹកសមុទ្រប្រៃ ទឹកភ្លៀងសាប ឬក៏ថា គ្មានតួអង្គណាធ្វើឲ្យទឹកក្រូចឆ្មាជូរ ធ្វើទឹកអំពៅផ្អែមនោះទេ គឺធម្មជាតិបណ្តាលឲ្យទៅជាយ៉ាងនោះ ទាំងពាក្យសំបថដែលស្បថហើយ មិនប្រតិបត្តិតាម ធម្មជាតិទឹងនាំបណ្តាលឲ្យទៅជាយ៉ាងនេះយ៉ាងនោះ តាមតែពាក្យដែលយើងស្បថ បើយើងមិនស្បថ ក៏គ្មានហេតុផលអ្វីដែរ ដូចជាថាតែពន្លឺមកប៉ះទីងយើង ៗ តែងតែមានស្រមោល បើគ្មានពន្លឺមកប៉ះទីងយើង ៗ ក៏គ្មានស្រមោលដែរ ។

មានរឿងមិនល្អរបស់ខ្ញុំមួយទៀត ដែលខ្ញុំមិនចង់លាក់ ដោយមានពន្ធុទុកគ្រាន់បំភ្លឺកុលបុត្រខ្មែរនៅខាងក្រោយ ឲ្យដើរចៀសវាងផ្លូវដែលមានសត្វពស់មានពិសជាច្រើននៅព្រៃសងខាងផ្លូវ ដែលខ្ញុំបានដើរម្តងរួចមកហើយ ហើយបានជួបប្រទះនឹងគ្រោះថ្នាក់យ៉ាងធំ ទើបខ្ញុំលើកយករឿងនេះមកធ្វើបន្ទាស្រាស់ផ្លូវនោះ កុំឲ្យក្មេងជាន់ក្រោយដើរទៅទៀត ។

ខ្ញុំជាមនុស្សគ្រេកគ្រេអាល ស្រើបស្រាលនឹងស្រីញញួល ហួសពេក តាំងពីក្មេងមកមានរឿងកប់មិនអស់ ។ កាលនាំនាងម្នាក់ទៅនៅខេត្តកំពង់ឆ្នាំង ដែលទៅធ្វើគ្រូបង្រៀនគន្ធូរនោះ នាងនេះមានផ្ទៃពោះគ្រប់ខែ

ត្រឡប់មកឆ្លងទន្លេឯភ្នំពេញ ដោយមានម្ដាយជាចាស់ទុំជួយមើលនៅឯណោះ ៗ

ចំណែកខ្ញុំជាប្រុសខិលខូច ក្នុងពេលដែលគ្មានស្រីនៅផ្ទះ ពេលយប់ទៅលេងផ្សារក្រោម ដោយរដូវទឹកទន្លេឡើងទីដីផ្សារក្រោមទឹកលិចទាំងអស់ ផ្ទះផ្សារទាំងប៉ុន្មាន នៅជាអណ្ដែតលើទឹកដោយមានក្បូនឬស្សីទ្រ ទាំងពេលល្ងាចក៏នៅលើទឹកដែរ សប្បាយបែកពីទីក្រុងឯទៀត ទៅមកតាមច្រកល្ហកផ្ទះផ្សារអណ្ដែតទឹក មានទូកតូច ៗ ជាច្រើន ក្មេងស៊ីឈ្នួលអុំឲ្យយើងជិះចង់ឈប់ត្រង់ណា ចង់ទៅណាស្រួលណាស់ ៗ ពេលយប់មួយនោះ ខ្ញុំអង្គុយមើលល្ខោនឃើញស្រីយួនម្នាក់ រូបល្អស្អាតអង្គុយជិតខ្ញុំ ដោយខ្ញុំចេះភាសាយួន ខ្ញុំនិយាយលេងនឹងវា ៗ ក៏និយាយឆ្លងឆ្លើយមករកខ្ញុំ លុះល្ខោនឈប់លេង ខ្ញុំឃើញវាគ្មានគ្នីគ្នា ខ្ញុំសូមជូនវាទៅផ្ទះ ហើយនាំគ្នាជិះទូក ១ ពីរនាក់មកដល់ផ្លូវដីគោក នាំគ្នាជិះរទេះសេះមកផ្សារលើ ខ្ញុំតាមតែវា ដោយចង់ដឹងផ្ទះវានៅឯណា លុះមកដល់ផ្ទះថ្មមួយធំ វាបញ្ឈប់រទេះ ខ្ញុំដឹងថាផ្ទះនេះជាផ្ទះលោកមេក្លូរួយលោករ៉េស៊ីដង់ត៍ វានាំខ្ញុំចូលទៅខាងក្រោយ ដល់បន្ទប់ដំណេកវា ខ្ញុំនៅមួយយប់ជាមួយវា ដល់ម៉ោង ៥ ជិតភ្លឺ ទើបបានខ្ញុំទៅផ្ទះខ្ញុំ ៗ ទៅមករកវា ជួនកាលខ្ញុំនាំវាទៅលេងនៅផ្ទះខ្ញុំ លុះតែប្រពន្ធដែលមកឆ្លងទន្លេបានកូនប្រុស ១ ត្រឡប់ទៅវិញ ទើបកំបុតការទាក់ទងនឹង

មីយួនស្រីបំរើប្រពន្ធបារាំងនោះ ហើយខ្ញុំក៏មានជម្ងឺក្នុងពេលនោះដោយកាមរោគ ដោយមានការអៀនខ្មាសលោកវេជ្ជបណ្ឌិត ខ្ញុំមិនបានព្យាបាលរោគតាមពេទ្យបារាំងទេ ខ្ញុំឲ្យគ្រូខ្មែរមើលវិញជាហេតុឲ្យរោគនោះកាន់តែដុនដាបទៅ ដោយមានហើមប្រចេទអន្ទើ នាំឲ្យក្តៅខ្លួនហួតដល់បាត់ស្មារតី លុះបានដឹងខ្លួនបន្តិច ដឹងថាមានឈឺនៅក្រលៀន មានឈឺត្រង់សៀតផ្កា ឈឺក្នុងក្បាលម្ខាងត្រចៀក ពេលនោះភ្នែកប្រវាំង ត្រចៀកហ៊ឹង មើលមិនច្បាស់ ស្ដាប់មិនឮ ៗ តែសូរសព្ទក្នុងក្បាល លុះបានងើបពីឈឺមក ខ្ញុំជាមនុស្សថ្លង់ចង់ទៅជាមនុស្សខ្វាក់ផង តែដោយត្រឡប់មករកគ្រូពេទ្យបារាំងវិញ ភ្នែកខ្ញុំគ្រាន់តែស្រវាំង មើលឃើញតែមិនសូវច្បាស់ ឯត្រចៀកខ្លួនហួតកែមិនបាន គ្រាន់តែឮ តែមិនឮដូចពីដើមទេ ខ្ញុំទៅជាមនុស្សធ្ងន់ត្រចៀកតាំងពីអាយុបាន ២០ ឆ្នាំមកដល់ឥឡូវនេះ ។

មានរឿងមានរោគតែហូរហែមក រកលះបង់ល្បែងស្រីញីនេះមិនបានសោះ អស់ពីក្រមុំព្រហ្មចារី ស្រីប្រពន្ធគេ ស្រីខិលខូច ស្រីពេស្យា ។

បើមានគេ ឬអ្នកណាបន្ទោសខ្ញុំថា ខ្ញុំជាមនុស្សចេះដឹងគ្រាន់បើដែរ ម្ដេចក៏ទៅខិលខូចដូចជាមនុស្សពាលទៅវិញ ៗ ខ្ញុំនឹងឆ្លើយថា គឺក្រឡាក្រយៅ ដែលព្រហ្មលិខិតរបស់ខ្ញុំពីនាយមក ។

ខ្ញុំសូមផ្ដាំផ្ដាច់ថា ល្បែងស្រីជាល្បែងហិនហោច ខ្ញុំមានការពិសោធន៍ផ្ទាល់ខ្លួនច្រើន មានរឿងទាស់ទែងកាប់ចាក់គ្នា, មានរឿង

ជាប់ពោធកាមផ្លូវច្បាប់, មានរឿងខុសអាប់កិត្តិយស, មានរឿងបាប ព្រោះដោយកាមភេគ និងមានរឿងទុក្ខសោកក្នុងគ្រួសារ ។

ប្រវត្តិខ្ញុំបានវិវឌ្ឍក្លាយទៅជារឿងរ៉ាវពុកផាសស្មុគស្មាញ ទៅជាអ្វីទៅហើយ តាមតែលោកកាត់ទោលត្រង់ណាដែលឥតប្រយោជន៍នោះទៅផងចុះ ។

ខ្ញុំបញ្ចប់ប្រវត្តិខ្ញុំ ដោយមានបញ្ញើឈ្មោះមេជាយ ដែលខ្ញុំបានទទួល នៅខាងខ្នងទំព័រនេះ ។

សរសេរដោយឥតព្រាងពីថ្ងៃ១៩ មិថុនា ដល់ ២៦ កក្កដា ១៩៦៦ ចប់

# ជឿ ក្បួន ហោរ ឬ ទេ ?

តាមពាក្យហោរថា ខ្ញុំនេះ លេខ ថ្ងៃ – ខែ – ឆ្នាំ ល្អណាស់ ថ្នាក់ទៅហ្វាយស្រុក ទៅហ្វាយខេត្ត ។

ឥឡូវនេះខ្ញុំបានធ្វើជាគ្រូបង្ហាត់ការតិចនិកថ្នាក់ផុតលេខ តាមឋានន្តរសក្តិមន្ត្រីអប់រំជាតិ គឺថ្នាក់ទីកញ្ញា សក្តិ ៧ ហូពាន់ ខ្ញុំមានគ្រឿងឥស្សរិយយសប្រាំមួយគឺ ៖

១– មេដាយប្រាក់រដ្ឋកាល

២– មេដាយប្រាក់អនុស្សាវរីយ៍

៣– មេដាយប្រាក់វិជ្ជានាការណ៍

៤– មេដាយអស្សប្ញទ្ធិមុនីសារគណ៍

៥– មេដាយអស្សប្ញទ្ធិសុវត្ថារា

៦– មេដាយអស្សប្ញទ្ធិព្រះរាជាណាចក្រកម្ពុជា ។

# ឯកសារ កម្ពុជសុរិយា

(ត)

លោក ឌឹក-គាម ប្រមូលរៀបរៀង

សុតជនុជាតកា : ព្រះញាណវិរយោ ឡុង ទ.ក. ១២ ,ទំព័រ ២៨២, ឆ្នាំ ១៩៣១, (ម.៥២/៤) ។

សុមនមាណការ : ខកញ៉ាកក្ដីសាទេពកៃ-នេត ទ.ក. ៩, ទំព័រ ៤៥១, ឆ្នាំ ១៩៤៥, (ម.៥២/១៧) ។

សុវណ្ណសាមជាតក (កាព្យ) : ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៊ុណ ទ.ក ៤, ទំព័រ ១៧០, ឆ្នាំ ១៩៤៤, (ម.៥២/១៦) ។

សុរិដ្ឋា : ចី ឆ.គិមហាក់ ទ.ក. ៨, ទំព័រ ២៧, ឆ្នាំ ១៩២៧, (ម.៥២/២) ។

សួរឆ្លើយក្នុងរឿងបតាសភាពជ : លោក ប៊ូ-ប៉ូ ទ.ក. ១២, ទំព័រ ៩០១, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

សួរឆ្លើយអំពីជម្ងឺដើមឈើប្រភេទខ្លះ : ទ.ក. ១៩, ទំព័រ ១៥, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សួស្ដី និង អពមង្គល : ព្រះអគ្គលេខា ណុប ទ.ក. ១-២-៣, ទំព័រ ១៧៤, ឆ្នាំ ១៩៣៣, (ម.៥២/៦) ។

សេចក្តីកត់សំគាល់របស់អ្នកប្រែ : លោក ក៉ឃ-ប៊ុក ក.ក. ៩, ទំព័រ ៣២៦, ឆ្នាំ ១៩៤៨, (ម.៥២/៤០) ។

សេចក្តីកត់ហេតុប្លែកៗ : ក.ក. ២៤, ទំព័រ ២៣, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។ ខេមរវង្ស ក.ក. ១៦, ទំព័រ ៥៤, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។ ក.ក. ២១-២២, ទំព័រ ៣២, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

សេចក្តីកត់ហេតុព្រះអង្គម្ចាស់សាវ៉ង់ធនមន្ត្រីពុទ្ធសាសនបណ្ឌិត្យ : ក.ក. ១០-១១-១២, ទំព័រ ១៩, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

សេចក្តីកត់ហេតុ អំពីព្រាងការណ៍ បុណ្យពាក់កណ្តាលព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជា : ក.ក ៤, ទំព័រ ៣៧០, ឆ្នាំ ១.៥៦, (ម.៥២/២៨) ។

សេចក្តីក្រាបបង្គំទូលព្រះករុណា សូមសាងវត្តកំចាង នៅខេត្តពោធិសាត់ជាថ្មីឡើងវិញ : ក.ក. ១០ ១១-១២, ទំព័រ ៨៧, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

សេចក្តីខ្ទះនិយាយអំពីអក្សរសាស្ត្រព្រះពុទ្ធសាសនា : ក.ក. ១៣, ទំព័រ ៣, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

(នៅមានត)

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## ពុទ្ធសាសនបណ្ឌិត្យ បានទទួលព្រះរាជចុតហ្មាយ

ក្រោយអំពីការរៀបចំពិធីបុណ្យរំឭកថ្ងៃកំណើតនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ហើយនិងពិធីថ្វាយកុសល ចំពោះព្រះមហាក្សត្រិយានី និង សម្ដេចសហជីវិនជាអម្ចាស់ រួចមក សហជីវិននាយកនៃវិទ្យាស្ថាន បានថ្វាយព្រះចុតហ្មាយក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទអំពីដំណឹងនេះ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់ថ្លែងព្រះចុតហ្មាយឆ្លើយតប រួមទាំងព្រះបរមនាម នៃព្រះមាតាជាតិផង មានសេចក្ដីដូចតទៅនេះ :

ព្រះរាជាណាចក្រកម្ពុជា

លេខ ៣៤៨ SPU

សម្ដេចព្រះ នរោត្តម សីហនុ

*សហជីវិន នាយកវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាទីស្នេហា*

*សម្ដេចព្រះមហាក្សត្រិយានី និង ខ្ញុំមានចិត្តសោមនស្សឥតឧបមា នៅពេលដែលបានទទួលពត៌មានថា សហជីវិន ដោយរួមជាមួយនឹងបុគ្គលិកទាំងអស់ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ បានប្រារព្ធធ្វើពិធីបុណ្យខួបទី ៣៧ នៃឆ្នាំកំណើតវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ក្រោមព្រះកិច្ចដឹកនាំដ៏ឧត្ដមនៃសម្ដេចព្រះពោធិវង្ស ដើម្បីឧទ្ទិសបុណ្យកុសលដល់ដួងវិញ្ញាណក្ខន្ធនៃបុព្វបុរសយើងគ្រប់រូប ដែលបានបំរើព្រះពុទ្ធសាសនា វប្បធម៌ និងអក្សរសាស្ត្រជាតិ ជាអាទិ៍ ថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធនៃព្រះករុណាព្រះបាទ សម្ដេចព្រះ ស៊ីសុវត្ថិ-មុនីវង្ស ដែលទ្រង់សព្វព្រះរាជហឫទ័យ*

បើកពិធីសម្ពោធជាផ្លូវការនៃវិទ្យាស្ថាននេះកាលពីថ្ងៃទី១២ ឧសភា ១៩៣០ ។

ដូចសហជីវិនមានប្រសាសន៍ត្រូវណាស់ ពិធីបុណ្យនេះជាសក្ខីភាពនៃកតញ្ញូតាធម៌ ចំពោះព្រះមហាករុណាទិគុណរបស់ព្រះមហាក្សត្រ និងបុព្វបុរស ដែលមានគុណចំពោះជាតិ - សាសនា · ព្រះរាជបល្ល័ង្ក ព្រមទាំងជាសញ្ញានៃសាមគ្គីភាព រវាងបុគ្គលិកក្នុងក្រសួងធម្មការ ដែលជាកម្លាំងយ៉ាងមាំនៃកម្ពុជរដ្ឋក្នុងសម័យនេះ និងតទៅអនាគត ។

ហេតុនេះ ខ្ញុំសូមថ្លែងសេចក្ដីអំណរគុណ និង សេចក្ដីសរសើរ ប្រកបដោយសេចក្ដីស្នេហាយ៉ាងជ្រាលជ្រៅរបស់ខ្ញុំ ប្រគេនព្រះតេជៈព្រះគុណគ្រប់ព្រះអង្គ និងជូនកូនចៅជាទីពំនឹងយ៉ាងមាំគ្រប់រូបរបស់ខ្ញុំ, សូមឲ្យបានប្រកបតែនឹងពុទ្ធពរទាំង ៤ ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។

ភ្នំពេញ ថ្ងៃទី ២៨ ឧសភា ១៩៦៧

សម្ដេចទ្រង់ឡាយព្រះហស្តលេខា : នរោត្តម - សីហនុ

បន្ទាប់ពីទ្រង់បានទទួលព្រះតង្វាយជាសៀវភៅរបស់ពុទ្ធសាសនបណ្ឌិត្យមក សម្ដេចព្រះមហាក្សត្រិយានី បរមបពិត្រ និង សម្ដេចសហជីវិនព្រះប្រមុខរដ្ឋជាអម្ចាស់ ទ្រង់ប្រោសប្រទានព្រាស់បញ្ជា អ្នកអង្គម្ចាស់ អគ្គនាយកនៃក្រសួងនានាក្នុងព្រះបរមរាជវាំង និង សហជីវិន នាយកពុទ្ធកាល័យ ថ្លែងចុតហ្មាយឆ្លើយតប ដោយមានសេចក្ដីដូចតទៅ :

អគ្គនាយក

នៃ

ក្រសួងនានាក្នុងព្រះបរមរាជវាំង

លេខ ៣៣៨ sdt

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ១៦ ឧសភា ១៩៦៧

អ្នកអង្គម្ចាស់ អគ្គនាយកក្រសួងនានា នៃព្រះបរមរាជវាំង

ជំរាបសហជីវិន ឈាង-ហ៊ាបអាន នាយក វិជ្ជាឋាន

ពុទ្ធសាសនបណ្ឌិត្យ បានជ្រាប ។

សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ដោយព្រះអង្គទ្រង់បានទទួលនូវសៀវភៅ ៤ ក្បាលគឺ : សៀវភៅ កាតាឡុកភាគ ២ មួយក្បាល, កាតាឡុករបស់សមាគមអ្នកនិពន្ធខ្មែរ ១ ក្បាល, ពិធីប្រចាំដប់ពីរខែ ១ ក្បាល, ភិក្ខុបាតិមោក្ខបាលី ១ ក្បាល ដែលសហជីវិនបានផ្ញើទៅថ្វាយតាមលិខិតលេខ ៨០៧ ពប ចុះថ្ងៃទី ៩ ឧសភា ១៩៦៧ នោះហើយ ។

សម្តេចជាអម្ចាស់ ទ្រង់ត្រាស់បង្គាប់ឲ្យខ្ញុំថ្វាយនូវព្រះរាជអំណរគុណដ៏ជ្រាលជ្រៅ ជាទីបំផុតចំពោះសហជីវិន ។

សូមសហជីវិន ទទួលនូវសេចក្តីរាប់អានដ៏ស្មោះចំពោះ អំពីខ្ញុំ ។

ព្រះហស្តលេខា : ជាកេង្គូម ភាគុល

---

ខុទ្ទកាល័យនៃសម្តេច សហជីវិន

ព្រះប្រមុខរដ្ឋ ភ្នំពេញ ថ្ងៃទី ២២ ឧសភា ១៩៦៧

លេខ ៨៨៩ SPU

ទទួលព្រះបរមរាជនុញ្ញាតដ៏កល់លើត្បូង

នាយកខុទ្ទកាល័យសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ

ជំរាបមក សហជីវិន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ក្រុងភ្នំពេញ ។

យោង : តាមលិខិតលេខ ៨០៦ ពប ចុះថ្ងៃទី ៩ ៥-៦៧ ។

ខ្ញុំបានទទួលកិត្តិយសដ៏ខ្ពង់ខ្ពស់ពីសម្តេចព្រះប្រមុខរដ្ឋ ទ្រង់ត្រាស់បញ្ជាឲ្យខ្ញុំឆ្លើយតបសហជីវិនវិញថា ព្រះអង្គមានព្រះរាជហឫទ័យរីករាយសោមនស្សជាអតិបរមា ចំពោះជង្វាយជាសៀវភៅ ៦ ក្បាល ដែលវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានថ្វាយចំពោះព្រះអង្គ ។

សម្តេចទ្រង់ថ្លែងសរសើរយ៉ាងខ្លាំងក្លា ចំពោះក្រុមអ្នកនិពន្ធ

សៀវភៅទាំងនេះ ដែលទុកជាអត្ថប្រយោជន៍យ៉ាងសំខាន់សំរាប់ជាតិ និងកុលបុត្រ ក្នុងព្រះពុទ្ធសាសនា នៃប្រទេសយើង ។

ទីបំផុតព្រះអង្គទ្រង់សង្ឃឹមថា បុគ្គលិកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ដែលជាពន្លឺសំរាប់ត្រាលបំភ្លឺជាតិយើងនេះ នឹងបញ្ចេញឧត្តមវិជ្ជាដល់ជាតិយើងឲ្យបានចំរើនរុងរឿងតទៅអនាគតជាពុំខាន ។

សូមសហជីវិនទទួលនូវសេចក្តីរាប់អាន ជាភាតរភាព អំពីខ្ញុំ ។

ហត្ថលេខា : អ៊ឹង-ហ៊ុងសាង

# សកម្មភាព នៃ ពុទ្ធសាសនបណ្ឌិត្យ

## ក្នុងខែ ឧសភា ១៩៦៧

១-ផ្នែករដ្ឋបាល

### ក-ចលនានៃបុគ្គលិក

– សហជីវិន ពេជ-សល់ នាយការិយាល័យទំនៀមទម្លាប់បានច្បាប់ឈប់សំរាកដោយមានបៀវត្សចំនួន ៦ ខែ ចាប់ពីថ្ងៃទី ៦ ឧសភា ទៅហើយ (ប្រកាសក្រសួងមហាផ្ទៃលេខ ១១៥៦ ចុះថ្ងៃទី២.៥-៦៧) ។

–តាមដីកាចាត់នៃក្រសួងធម្មការលេខ ៩៨/ប ចុះថ្ងៃ ទី ១០-៥-៦៧ សហជីវិន លឹម-លាងជិន និង លី-ឈាមគេង ត្រូវបានចាត់តាំងឲ្យកាន់មុខងារបន្ថែមជានាយការិយាល័យ និង ជានាយផ្នែកនៃការិយាល័យ ទំនៀមទម្លាប់ ជំនួសសហជីវិន ពេជ-សល់ ។

– តាម លិខិតក្រសួងមហាផ្ទៃលេខ ៦៧៦ ប.ក. ចុះថ្ងៃ ១០-៥-៦៧ សហជីវិន គុយ-សូត្រ អ្នកនិពន្ធតែងសេចក្ដី ថ្នាក់លេខ ៣ មាននាទីជាអ្នក កាន់ហិបចំណូល អំពីការជាវសៀវភៅ របស់ក្រសួង ត្រូវចូលនិវត្តន៍ចាប់ពីថ្ងៃទី ២១ មិថុនា ១៩៦៧ តទៅ ។

– ដើម្បីរៀបចំបុគ្គលិកជំនួស សហ. គុយ សូត្រ ដែលត្រូវចូលនិវត្តន៍នេះ តាមការសំរេចនៃកិច្ចប្រជុំការងារ ពីថ្ងៃទី ១-៣-៦៧ សហ. ខឹម-សួរ អ្នកនិពន្ធតែងសេចក្ដីថ្នាក់លេខ ៦ ធ្វើការនៅ

បណ្ណាល័យ ត្រូវចាត់ឲ្យទៅរៀនការអំពីសហជីវិនរូបនេះ តាំងពីដើមខែមេសាម៉្លេះ, ក្រសួង នឹងធ្វើសេចក្ដីសុំតែងតាំង សហ. ខឹម-សួរនេះ ជាបេឡាធិការជំនួស សហ. គុយ-សូត្រ ទៅក្រសួងហិរញ្ញវត្ថុ ។

ខ–លិខិតឆ្លងឆ្លើយ

ក្នុងខែឧសភានេះ រដ្ឋបាលបានចាត់ចែងធ្វើ និងទទួលលិខិតផ្សេង ៗ ពីគ្រប់អង្គការនានា គឺ :

– លិខិតចូលចំនួន ១០០ ច្បាប់ ពីលេខបញ្ជី ២៣៦ ដល់ ៣៣៦ ។

– លិខិតចេញចំនួន ១៧៦ ច្បាប់ ពីលេខបញ្ជី ៧៩០ ដល់ ៦៩៩ ។

២–ការិយាល័យបណ្ណាល័យ

– ចំនួនអ្នកចូលមកអានក្នុងខែឧសភានេះ មាន ២៨៥ នាក់ ។

– ចំនួនអ្នកខ្ចីសៀវភៅផ្សេង ៗ យកទៅស្រាវជ្រាវនៅផ្ទះក្នុងខែឧសភា នេះ មាន ៦៧ នាក់ ។

– ក្នុងខែឧសភានេះ បណ្ណាល័យបានទទួលអំណោយជាសៀវភៅភាសាជាតិ ភាសាបរទេស ៦៤ ក្បាល និងទស្សនាវដ្ដីសរុប ១៣៥ ក្បាល ( គឺសៀវភៅខ្មែរ ៦ ក្បាល ជាភាសាបរទេស ៦៤ ក្បាល និង ទស្សនាវដ្ដីនានា ៦៥ ក្បាល ) ។

មកដល់ថ្ងៃទី ៣១ ឧសភា នេះ បណ្ណាល័យមានសៀវភៅទាំងអស់ ៥២.២៣៤ ក្បាលហើយ ។

៣ ការិយាល័យទំនៀមទម្លាប់ :

— ក្នុងខែមេសានេះ ការិយាល័យបានទទួលឯកសារសំរាប់ប្រឡង ផ្នែកទំនៀមទម្លាប់ និងរក្សាទុក ចំនួន ៣៣ មុខ ។ រួមឯកសារប្រឡង បានទទួលរហូតមកដល់ពេលនេះមាន ៦៣ មុខហើយ ។

— មានអ្នកមកស្រាវជ្រាវ ចំនួន ៣៥ នាក់ ដែលមានជនបរទេស ១២ នាក់ផង ។

— បានឆ្លើយចំពោះសំនួរផ្សេងៗ ទាក់ទងនឹងទំនៀមទម្លាប់ខ្មែរ ដែលក្រសួងនានាផ្ញើមកសួរ បានចំនួន ៨ រឿង ។

៤-ការទទួលភ្ញៀវបរទេស :

ក្នុងខែមេសានេះ វិជ្ជាឋានបានទទួល ៖

— អ្នកនិពន្ធជាតិកាមីរូណម្នាក់ ជាភ្ញៀវរបស់សមាគមអ្នកនិពន្ធខ្មែរ ឈ្មោះលោក ហ្សែរហ្សៀ·ម៉ារសែល ( កាលពីថ្ងៃ ២៩ មេសា ១៩៦៧ វេលាម៉ោង ៩ ព្រឹក ) ។

— លោក លីង · តាវយាន់ ជាលេខាធិការទី ២ នៃស្ថានទូតចិន ទទួលភារៈខាងវប្បធម៌ ដែលបាននាំទស្សនាវដ្ដីអក្សរសាស្ត្រ ចំនួន ៦ ក្បាល មកជាមួយអ្នកបកប្រែភាសាម្នាក់ ( ថ្ងៃទី ២៩-៥·៦៧ ម៉ោង ១១ ព្រឹក ) ។

៥- ពិធីបុណ្យរំលឹកខួបទី ៣៧ :

ក្រោមអធិបតីភាពនៃសម្តេចព្រះពោធិវង្ស ហួត-តាត និងការណែនាំរបស់ ឯ.ឧ. ទេសរដ្ឋមន្ត្រី និងសហជីវិន អនុរដ្ឋលេខាធិការក្រសួងធម្មការ វិជ្ជាឋានបានធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ៣៧ អង្គ ដើម្បីរំលឹកខួបទី ៣៧ នៃការបង្កើតវិជ្ជាឋាននេះ ព្រមទាំងថ្វាយព្រះរាជកុសលចំពោះព្រះវិញ្ញាណក្ខន្ធ ព្រះមហាក្សត្រដែលទ្រង់មានព្រះគុណចំពោះវប្បធម៌ជាតិ-អារ្យធម៌ជាតិ ថ្វាយព្រះរាជកុសលចំពោះ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ, សម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក ព្រមទាំងជូនកុសលដល់បុព្វបុរសអ្នកមានគុណចំពោះក្រសួង កាលពីថ្ងៃទី ១២ ធ្នូ ១៩៦៧ ម៉ោង ៩ ព្រឹក ។

ចំពោះបុញ្ញកុសលនេះ វិជ្ជាឋានបានធ្វើបុគ្គលព្រោយថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានី លេខ ៨១៣-ពប សម្តេចព្រះប្រមុខរដ្ឋលេខ ០១៤ ព.ប និងសម្តេចព្រះសង្ឃរាជលេខ ៨១៥ ពប ចុះថ្ងៃ ១៣-៥-៦៧ ។

៦- ការធ្វើអំណោយសៀវភៅ និង ពិធីផ្សេងៗ :

- ក្នុងខែធ្នូនេះ វិជ្ជាឋានបានទទួលបង្គាប់ពីក្រសួងធម្មការ បញ្ជូនគណៈប្រតិភូមួយទៅធ្វើពិធីប្រគល់សៀវភៅចំនួន ៤៦៣ ក្បាល

ជូនឯ.ឧ.ប្រតិភូរាជរដ្ឋាភិបាលប្រចាំបូរីកែប ដើម្បីតំកល់ទុកក្នុងបណ្ណាល័យនៃមជ្ឈមណ្ឌលយុវជនរាជសង្គមនិយមខ្មែរ ( កាលពីថ្ងៃទី ២៦.៥.៦៧ ម៉ោង ៩ ព្រឹក ) ។

ក្នុងក្របខ័ណ្ឌផ្សាយ និងប្តូរវប្បធម៌ជាមួយអង្គការនានា វិជ្ជាឋានបាន:

– ធ្វើអំណោយសៀវភៅ ៣ ក្បាលទៅទីភ្នាក់ងារសារពតិមានខ្មែរ សំរាប់ជាឯកសារខាងទំនៀមទម្លាប់ ។

– ប្រគេនព្រះតេជព្រះគុណឥន្ទមុនី សេក - នាង ចំនួន រាមកេរ្តិ៍ខ្មែរ ១២ ក្បាល ដើម្បីជាឯកសារ បង្រៀនវិជ្ជាខ្មែរ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ។

– ជូនគណៈប្រតិភូខាងពុទ្ធសាសនាខ្មែរ ដែលដឹកនាំដោយព្រះសិរីសម្មតិវង្ស ប៉ុណ្ណ-សុម្ភាជ និងមានសហជីវិន អេង-សុទ្ធ ជាសមាជិក ទៅកាន់ក្រុងមូស្គូ នូវសៀវភៅ ឯកសារពុទ្ធសាសនាចំនួន ៤០ ក្បាល ។

---

BIBLIOTHÈQUE NATIONALE DU CAMBODGE
P.K-1
1967-7

ក-២៤២-ក

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ផ្នែកសាសនា ............ ទំព័រ

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . . ៦៨១

២ – សម្ដែងអំពីសុខនិងទុក្ខ ដែលកើតអំពីកម្ម ព្រះសាសនមុនី កិម-ទូ រៀបរៀង. . . . ៦៩១

៣–យោបល់ឯកឧត្ដម យឹម-ទិត ផ្ញើជូនសហ. សម-ថាំង . . . . . . . . ៧០៤

ផ្នែកអក្សរសាស្ត្រ

៤– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . . ៧១០

៥– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង–ខាត់ រៀបរៀង (ត) . . . . . ៧១៦

៦– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៧២០

៧– ឯកសារ សាស្ត្រាស៊ីករីតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៧៣២

៨– ឯកសារកម្ពុជសុរិយា លោក ឱ.គាម ប្រមូលរៀបរៀង (ត) . . . . . . ៧៤៥

៩– សេចក្ដីជូនដំណឹងអំពីលទ្ធផលនៃប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ
(ឆមាសទី ១ ឆ្នាំ ១៩៦៧) . . . . . . . . . . . . ៧៥៦

១០– ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ (ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៧) . . . ៧៥៩

## ផ្នែកកំណាព្យ និង ប្រវត្តិការណ៍


១១– ព្រះរាជបុគហ្លាយ សម្ដេចព្រះសង្ឃរាជ . . . . . . . ៧៦៦

១២– ព្រះរាជសុន្ទរកថានៃសម្ដេចព្រះប្រមុខរដ្ឋក្នុងឱកាសពិធីថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ បំពោះសម្ដេចព្រះសង្ឃរាជ ថ្នាក់ទី ១ ជួន-ណាត . . . . . ៧៦៨


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០៛០០ ។

## ផ្នែកសាសនា

> ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
> ជាការណាមក, ឲ្យធ្វើល្អទៅ,
> ឲ្យជ្រះស្វាត់ចិត្ត កុំឲ្យហ្មងសៅ,
> បីនេះលោកហៅ ពុទ្ធសាសនា ។
>
> ប.ព.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ថាំង ប្រែ - រៀបរៀង

*ប្ញ. ព្រះពុទ្ធសាសនា មានតែសេចក្តីពិតម្យ៉ាង ហើយស្របគ្នានឹងក្បួនវិទ្យាសាស្ត្រឬ ?*

*វិ. ព្រះពុទ្ធសាសនាសព្វថ្ងៃនេះ មានលាយឡំដោយសេចក្តីបន្ថែមខុសចាកការណ៍ពិត ដូចគ្នានឹងសាសនាបុរាណដទៃដែរ ។ មរនាគតិរបស់ពួកកវី, ជំនឿនិងការចង់លើកតំកើង របស់អ្នកប្រាជ្ញក្នុងព្រះពុទ្ធសាសនា ក្នុងជំនាន់នោះ ៗ សុទ្ធនាំឲ្យមានសៅហ្មងដល់ព្រះពុទ្ធសាសនាខ្លះដោយអន្លើ ៗ ដែលត្រូវតែកែលុបបំបាត់ចោលចេញ ទើបគួរ ។*

*ប្ញ.ចុះពុទ្ធមាមកជនពិតប្រាកដ ត្រូវមានបំណងយ៉ាងណា កាលបើគេឃើញសេចក្តីបន្ថែមចូលមកលុកលុយក្នុងសាសនាដូច្នេះ ?*

វិ. ពុទ្ធសាសនិកជន គប្បីខ្វល់ខ្វាយស្រាវជ្រាវរកសេចក្ដីបួមនេះ ហើយបើល្មមធ្វើបាន គេងតែជួយបំបាត់ឲ្យអស់ចេញ, បានធ្វើសង្គាយនា យ៉ាងធំបីគ្រាហើយ ដើម្បីជ្រើសស្រាវជ្រាវសម្រាំងព្រះពុទ្ធសាសនាហើយ បំបាត់សេចក្ដីបួមនេះចេញ ។

ប្. សង្គាយនានេះ ធ្វើពីកាលណាខ្លះ ?

វិ. លើកដំបូង ធ្វើក្នុងគុហាសត្តបណ្ណិ ពេលក្រោយព្រះបរមគ្រូចូលបរិនិព្វានទៅបន្តិច, លើកទី ២ នៅវាលុការាម ក្នុងក្រុងវេសាលី, លើកទី ៣ នៅអសោការាម ក្នុងបាតលិបុត្ត រវាង ២៣៥ ឆ្នាំក្រោយព្រះអង្គបរិនិព្វាន ។

ប្. ព្រះពុទ្ធជាម្ចាស់ បានផ្ដែផ្ដាំប្រយ័ត្នអំពីហេតុដែលនាំឲ្យព្រះពុទ្ធសាសនាអាប់ឱន នៅក្នុងគម្ពីរណា ?

វិ. នៅក្នុងគម្ពីរសំយុត្តនិកាយ ។

ប្. ព្រះសម្មាសម្ពុទ្ធ មានប្រៀនប្រដៅអំពីការជឿដែរឬទេ ?

វិ. មាន, ព្រះអង្គបានប្រកាសហាមប្រាមថា យើងមិនត្រូវជឿពាក្យដោយគ្រាន់តែគេនិយាយប្រាប់នោះទេ មិនត្រូវប្រកបតាមទំនៀមទម្លាប់ ជាតំណអំពីបុរាណនោះទេ មិនត្រូវជឿពាក្យបរម្បរាបែបនេះទេ តាំងក្បួនច្បាប់តាំងពួង ក៏មិនត្រូវជឿ ដោយគិតស្មានថាបានសរសេរទុកហើយដែរ មនោគតិដែលយើងគិតស្មានថា ជារបស់ទេវតា ។ មតិដែលយើងយល់ឃើញដោយការស្មានខុសទំនង ឬក៏សេចក្ដីប្រដូច ឬ

សំដី ដែលប្រកបដោយអំណាចនៃគ្រូបាធ្យាយរបស់យើង ក៏យើងមិនត្រូវជឿដោយឥតពិចារណាទាំងអស់ ។

ប្ញ. ក្នុងព្រះពុទ្ធសាសនា មានបញ្ញត្តិត្រង់ណា ដែលតម្រូវឲ្យជឿដោយឥតពិចារណាឬទេ ?

វិ. ទេ, មានតែពុទ្ធនុកាទហាមដោយដាច់ខាតថា កុំជឿដោយឥតត្រិះរិះនោះ(១) ។

ប្ញ. បើដូច្នោះ យើងត្រូវជឿដូចម្តេចវិញ ?

វិ. លុះតែគម្ពីរពាក្យប្រៀនប្រដៅ ឬពាក្យសំដីនោះ សមប្រកបស្របគ្នានឹងសេចក្តីត្រិះរិះពិចារណារបស់យើង ៗ យល់ថា ត្រឹមត្រូវហើយ សឹមជឿ; ការជឿនេះ ព្រះអង្គបានបញ្ជាក់ថា តថាគតបានប្រដៅប្រាប់អ្នកហើយថា មិនត្រូវជឿដោយព្រោះគេថានោះទេ តែបើអ្នកត្រិះរិះក្នុងចិត្តទៅ ហើយយល់ព្រមថាគួរជឿ អ្នកធ្វើតាមប្រាថ្នាចុះ ( មើលក្នុងកាឡាមសូត្រគម្ពីរអង្គុត្តរនិកាយ និងមហាបរិនិព្វានសូត្រ ) ។

ប្ញ. ព្រះសម្មាសម្ពុទ្ធ ទ្រង់ទុកដាក់ព្រះអង្គថាជាបុគ្គលបែបណា ?

វិ. ទ្រង់ត្រាស់ថាព្រះអង្គនិងព្រះពុទ្ធដទៃទៀតគ្រាន់តែជាអ្នកប្រដៅប្រាប់សេចក្តីពិត ( សច្ចៈ ) ជាអ្នកនាំឬបង្ហាញផ្លូវប៉ុណ្ណោះទេ ឯសេចក្តីល្អគ្រប់យ៉ាងស្រេចនៅលើយើងគ្រប់គ្នាខំប្រឹងប្រែងសន្សំបំពេញខ្លួនឯងចុះ ។

---

១ ត្រង់នេះ ក្នុងច្បាប់ដើមមានដោះស្រាយពិស្តារជាងនេះ តែលោកអ្នកជួយកែសម្រួលលុបឆូតចោលវិញ យើងនៅទុកសេចក្តីដោះស្រាយនេះខ្លះ ។

បុ. ព្រះពុទ្ធដីកានេះ មាននៅក្នុងទីណា ?

វិ. មាននៅក្នុងគម្ពីរធម្មបទ ត្រង់វគ្គទី ២០ ។

បុ. ព្រះពុទ្ធសាសនា ពោលសរសើរកិច្ចកលមាយា ឬអ្វី?

វិ. គម្ពីរធម្មបទមានសំដែងថា ផ្កាមានតែពណ៌សម្បុរ ក៏មិនមានប្រយោជន៍ យ៉ាងណា វាចាជាសុភាសិត មិនមានផលប្រយោជន៍ដល់អ្នកដែលមិនប្រតិបត្តិតាម យ៉ាងនោះដែរ ។

បុ. ព្រះពុទ្ធសាសនា ប្រដៅឲ្យធ្វើអំពើអាក្រក់ដល់គ្នានឹងគ្នាទៅវិញទៅមកឬទេ ?

វិ. ក្នុងគម្ពីរធម្មបទ ព្រះបរមគ្រូសំដែងថា “ បើបុគ្គលណាប្រព្រឹត្តលើសខុសឆ្គងនឹងតថាគត ក៏តថាគត នៅតែសង្គ្រោះសន្តោសដោយមេត្តាចិត្ត ទៅរកបុគ្គលនោះវិញដែរ បើទោសកំហុសនោះធ្ងន់ប៉ុន្មានក៏ដោយ តថាគតក៏នៅតែសង្គ្រោះដោយសេចក្ដីល្អជាដរាប, នេះជាផ្លូវនៃព្រះអរហត្ត ។ ការចងពៀរព្យាបាទដល់គ្នាទៅវិញទៅមកនោះច្បាប់ព្រះពុទ្ធសាសនាបានបញ្ញត្តហាមប្រាមដាច់ខាត ។

បុ. ព្រះពុទ្ធសាសនា និយមការកាចសាហាវឃោរឃៅឬទេ ?

វិ. ទេ, ក្នុងបញ្ចសីល និងក្នុងព្រះសូត្រជាច្រើនអន្លើ ព្រះអង្គបានប្រដៅឲ្យផ្សាយមេត្តាចិត្ត ចំពោះសត្វទាំងអស់ គឺត្រូវតែស្រឡាញ់រាប់អាន និងរកឧបាយឲ្យបានសេចក្ដីសុខ ដល់គ្នានឹងគ្នាជាដរាប ។

ព្រះអង្គបានសំដែងសូត្រថែមទៀតថា កុំឲ្យបំផ្លាញ ផ្តាច់បង់ជីវិតសត្វ ហេតុដល់ការធ្វើមនុស្សឃាត ឬក៏ជួយទំនុកបំរុងដល់អំពើនេះ ។

ប្រ. ព្រះអង្គត្រាស់សំដែងក្នុងសូត្រណា ?

វិ. ក្នុងធម្មិកសូត្រ ព្រះអង្គត្រាស់សំដែងថា បុគ្គលពុំគប្បីផ្តាច់បង់ជីវិត ឬយល់ព្រមដល់ការបំផ្លាញជីវិត ឬក៏មានចិត្តសោមនស្ស ចំពោះអំពើបាណាតិបាតនោះឡើយ ។ ត្រូវតែវៀរចាកការបៀតបៀនសត្វទាំងពួង ។

ប្រ. ព្រះពុទ្ធសាសនាបានអនុលោមដល់ការផឹកនូវទឹកស្រវឹងឬទេ?

វិ. ក្នុងធម្មិកសូត្រ ព្រះអង្គបានក្រើនរំលឹកហាមយើងកុំឲ្យផឹកទឹកស្រវឹង ហើយមិនត្រូវកំឡាឬសោមនស្សនឹងមនុស្សអ្នកផឹកនោះឡើយ ។

ប្រ. សេចក្តីស្រវឹង នាំមកនូវទោសដូចម្តេច ?

វិ. នាំឲ្យគេមិនពប់គាន, នាំឲ្យហ៊ានប្រព្រឹត្តបទឧក្រិដ្ឋ, នាំឲ្យខូចសតិ (វិកលចរិត) ព្រមទាំងនាំមកនូវសេចក្តីងងឹត (អវិជ្ជា) ដែលជាហេតុនាំមកនូវជាតិទុក្ខជាដើម ។

ប្រ. ព្រះពុទ្ធសាសនា សំដែងដូចម្តេចអំពីផ្លូវកាម ?

វិ. ការប្រព្រឹត្តិនូវព្រហ្មចរិយធម៌ ជាហេតុនាំឲ្យចំរើនផ្លូវចិត្តវិសេសណាស់, តែបើមានស្វាមីភរិយាតែមួយហើយមិនប្រព្រឹត្តកន្លងចិត្តគ្នាក៏ជាការប្រសើរដែរ ។ ឯការដែលមានភរិយាច្រើន ព្រះពុទ្ធជាម្ចាស់

ទ្រព្យទ្រព្យធ្វើជាហេតុនាំឲ្យដេកត្រាំនៅក្នុងសេចក្តីងងឹត ហើយនាំឲ្យខូចចិត្តគំនិតផង ។

បុ. ពាក្យប្រដៅនេះ មាននៅទីណា ?

វិ. ក្នុងគម្ពីរអង្គុត្តរនិកាយ ។

បុ. ព្រះពុទ្ធសាសនា ប្រដៅឲ្យមាតាបិតាសង្គ្រោះកូនដូចម្តេច ?

វិ. មាតាបិតាត្រូវទំនុកបំរុងហ្វឹកហ្វឺនប្រដៅបុត្រ ការពារកុំឲ្យប្រព្រឹត្តអំពើអាក្រក់ ឲ្យប្រព្រឹត្តអំពើល្អសុចរិតស្លូតត្រង់ ឲ្យរៀនសិល្បវិជ្ជាផ្សេងៗ រៀបចំកូនឲ្យមានស្វាមីភរិយាតាមសមគួរដល់វង្សត្រកូល ហើយចែកសម្បត្តិទ្រព្យឲ្យក្នុងកាលគួរ ។

បុ. បុត្រ ត្រូវទំនុកបំរុងមាតាបិតាដូចម្តេច ?

វិ. ត្រូវទំនុកបំរុងប៉ាច់រក្សាមាតាបិតាជាស់ជរា ក្នុងពេលដែលមាតាបិតាត្រូវការ ត្រូវថែរក្សាវង្សត្រកូលទ្រព្យសម្បត្តិឲ្យសមគួរជាអ្នកទទួលកេរ្តិ៍មរតក កាលបើមាតាបិតាទទួលអនិច្ចកម្មទៅហើយ ត្រូវធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសផលជូនគាត់ ។

បុ. ករណីយកិច្ចរបស់សិស្សចំពោះគ្រូបាធ្យាយ ដូចម្តេចខ្លះ ?

វិ. សិស្សត្រូវគោរពកោតខ្លាចបំរើ ស្តាប់បង្គាប់, បំពេញសេចក្តីត្រូវការ ហើយស្តាប់ពាក្យទូន្មានទំនៀមទូន្មានរបស់គ្រូបាធ្យាយ ។

បុ. ករណីយកិច្ច ដូចម្តេច ដែលស្វាមីត្រូវធ្វើចំពោះភរិយា ?

វិ. ត្រូវថ្នាក់ថ្នមនិយាយទៅកាន់ភរិយាដោយសំដីល្អ មិនកន្ទួងចិត្តភរិយា ប្រគល់ឥស្សរិយយស ហើយទំនុកបំរុងដោយគ្រឿងស្លៀកពាក់ និងតុបតែងកាយតាមការគួរ ។

ប្ញ. ចុះភរិយា ត្រូវធ្វើចំពោះស្វាមីដូចម្តេច?

វិ. ត្រូវសម្តែងឫកពាឲ្យឃើញថា ខ្លួនមានសេចក្តីស្រឡាញ់ពិត ត្រូវគ្រប់គ្រងផ្ទះសម្បែងឲ្យល្អ ត្រូវទទួលរាក់ទាក់ចំពោះញាតិរបស់ស្វាមី និងភ្ញៀវ ត្រូវមានចិត្តត្រង់នឹងស្វាមី ថែរក្សាសន្សំទ្រព្យ ហើយត្រូវជាអ្នកប៉ិនប្រសប់ និងមិនខ្ជិលច្រអូសក្នុងការងារ ។

ប្ញ. ដំបូន្មានទាំងនេះ មាននៅក្នុងសូត្រណា?

វិ. ក្នុងសិង្គាលោវាទសូត្រ ។

ប្ញ. ទ្រព្យសម្បត្តិជាជំនួយដល់ការស្វែងរកទីដ៏ប្រសើរ ក្នុងអនាគតរបស់មនុស្សដែរឬទេ?

វិ. គម្ពីរធម្មបទសំដែងថា ផ្លូវដែលនាំទៅកាន់ព្រះនិព្វាន ដទៃអំពីផ្លូវដែលនាំឲ្យបានទ្រព្យសម្បត្តិ ។

ប្ញ. បើដូច្នេះ អ្នកដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ នឹងប្រាថ្នានូវព្រះនិព្វានពុំបានទេ ឬដូចម្តេច?

វិ. ស្រេចតែនឹងបំណង របស់បុគ្គលនោះ, បើបុគ្គលនោះ បរិច្ចាគទ្រព្យសម្បត្តិដល់មហាជន ដើម្បីសង្គ្រោះមនុស្សអ្នកមាន

ជម្ងឺ ត្រូវគេសង្កត់សង្កិន និងមនុស្សល្ងង់ខ្លៅ, បុគ្គលនោះ នឹងបានទទួលផលនៃបុណ្យដោយពិត ។

ប្ញ. ចុះបើពុំបរិច្ចាគសម្បត្តិទ្រព្យដូច្នេះទេ តើដូចម្ដេចវិញ ?

វិ. បើអ្នកមានសម្បត្តិនោះកំណាញ់ប្ញស្សា ស្រឡាញ់លោភទុកទ្រព្យសម្បត្តិនោះ ដោយគិតតែពីបង់បាន, អកុសលចិត្តនឹងកើតមានដល់បុគ្គលនោះ ហើយនាំឲ្យប្រព្រឹត្តអំពើអាក្រក់, បុគ្គលនោះ នឹងសោយសោក ត្រូវគេនិន្ទាក្នុងលោកនេះផង ត្រូវទទួលផលនៃអំពើអាក្រក់នោះក្នុងបរលោកផង ។

ប្ញ. គម្ពីរធម្មបទសំដែងអំពីអវិជ្ជា ដូចម្ដេច?

វិ. ថាជាកំពូលនៃអកុសលគ្រប់យ៉ាងរបស់សត្វ ។

ប្ញ. គម្ពីរធម្មបទសំដែងពីការឃើញទោសរបស់អ្នកដទៃដូចម្ដេច?

វិ. ទោសរបស់អ្នកដទៃ បុគ្គលឃើញដោយងាយណាស់, ឯទោសរបស់ខ្លួន បុគ្គលពិបាកមើលយល់ណាស់, មនុស្សច្រើនតែបរិហារពីទោសរបស់គេ តាមខ្យល់ ដូចជាកំទេចអង្កាម ហើយលាក់បំបាំងទោសរបស់ខ្លួន ប្រៀបដូចជាអ្នកលេងខ្លាច់ ដែលបំបាត់នូវខ្លាច់របស់ខ្លួនមិនឲ្យអ្នកលេងផងគ្នាដឹង ។

ប្ញ. ព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានឲ្យសង្គ្រោះអ្នកក្រីក្រកំសត់ទុគ៌តដូចម្ដេចខ្លះ?

វិ. ព្រះអង្គត្រាស់សំដែងឲ្យចែកទ្រព្យសម្បត្តិ ដែលខ្លួនរកបានមក ជា ៤ ចំណែក មួយចំណែកត្រូវទុកធ្វើជាទានដល់ស្មូមយាចក ។

ប្រ. ជំនួញ ៥ ប្រការដែលចាត់ថាជាជំនួញដ៏ថោកទាបនោះគឺអ្វីខ្លះ?

វិ. គឺលក់គ្រឿងស្រវឹង, លក់សត្វដែលសម្រាប់ពិឃាតយកសាច់, លក់ថ្នាំពិសពុល លក់គ្រឿងសស្ត្រាវុធ និងធ្វើជំនួញមនុស្សដូចគ្នា ។

ប្រ. បុគ្គលណាខ្លះ ដែលលែងបានទទួលសេចក្ដីចំរើនដោយមគ្គនិងផល ក្នុងព្រះពុទ្ធសាសនា?

វិ គឺបុគ្គល អ្នកធ្វើបិតុឃាតកម្ម មាតុឃាតកម្ម អរហន្តឃាតកម្ម ភិក្ខុដែលបំបែកសង្ឃ បុគ្គលអ្នកបៀតបៀនដល់កាយព្រះពុទ្ធ និងបុគ្គលដែលយល់ឃ្លាង យល់ខុស គឺ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។

ប្រ. ព្រះពុទ្ធសាសនា មានសំដែងអំពីទីកន្លែងសម្រាប់បុគ្គលអ្នកធ្វើអំពើលាមកទុច្ចរិត ដែលទំលាយពងកាយលះបង់លោកនេះហើយ ត្រូវទៅកើតរងទុក្ខវេទនាឬទេ?

វិ. មាន, គឺសញ្ជីវៈ, កាលសុត្រ, សង្ឃាត, រោរុវៈ, មហារោរុវៈ, តាបៈ, ប្រតាបៈ, អវិចិ ។

ប្រ. ទុក្ខវេទនាទាំងមានដល់បុគ្គលនោះជានិច្ចគ្មានទីបំផុតទេឬ?

វិ. ទេ! ពុំមែនទេ, គឺកំណត់កាលទៅតាមសមគួរដល់កម្លាំងកម្ម របស់អ្នកធ្វើ ។

ប្ញ. ព្រះពុទ្ធសាសនាមានប្រកាសថា បុគ្គលណាមិនជឿព្រះបរម-សម្ពុទ្ធ ត្រូវមានបាបឬទេ?

វិ. ពុំមែនដូច្នោះទេ ដោយការធ្វើអំពើល្អ បុគ្គលនោះនឹងបាន ទទួលផលជាសុខ តាមកាលកំណត់ តែត្រូវមានជាតិកំណើតតទៅទៀត ព្រោះលះកាមតណ្ហាពុំទាន់អស់ស្រឡះ, ដើម្បីចៀសវាងការអន្ទោលទៅមកក្នុងភព ត្រូវប្រតិបត្តិតាមគន្លងព្រះអរិយមគ្គ ៨ ប្រការ ។

ប្ញ. ស្ត្រីនឹងបានសម្រេចផលដូចម្តេចតាមច្បាប់ព្រះពុទ្ធសាសនា ?

វិ. ស្ត្រីមានឧបនិស្ស័យស្មើគ្នានឹងបុរសគ្មានខុសគ្នាទេ, ព្រះពុទ្ធជាម្ចាស់ព្រះអង្គសំដែងក្នុងចុល្លវេទល្លសូត្រថា ស្ត្រីមានសម្រេចផលជាន់ខ្ពស់ថ្នាក់អរហត្តបានដូចជាបុរសដែរ ។

ប្ញ. ចុះមានយោបល់នៃអ្នកប្រាជ្ញទំនើបថាដូចម្តេច អំពីអានុភាពនៃព្រះពុទ្ធសាសនាចំពោះស្ត្រី ?

វិ. លោក ឡឺប៉ែលគ្រីហ្វ៊ីន (Sir Lepelqriffin) ថា : ព្រះពុទ្ធសាសនាអនុគ្រោះដល់ស្ត្រីក្នុងផ្លូវសុគតិច្រើនលើសលែងសាសនាទាំងពួង ។

ប្ញ. ព្រះពុទ្ធជាម្ចាស់ សំដែងអំពីរឿងវណ្ណៈថាដូចម្តេច?

វិ. មនុស្សគ្មានចូលក្នុងវណ្ណៈណាមួយជាចណ្ឌាល ឬជាព្រាហ្មណ៍ ដោយជាតិទេ ស្រេចហើយតែអំពើអាក្រក់ល្អ ។ ព្រះអង្គសំដែងថា អំពើអាក្រក់ល្អនេះ អាចធ្វើបុគ្គលឲ្យជាចណ្ឌាល ឬជាព្រាហ្មណ៍ ។ (មើលក្នុងវសលសូត្រ) ។

(នៅមានត)

# សម្តែងអំពី

# សុខ និង ទុក្ខ

ដែលកើតអំពី

# កម្ម

ព្រះសាសនមុនី ហ៊ិម-ហួរ ក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

នមត្ថុ រតនត្តយស្ស

សូមនមស្ការ ចំពោះព្រះរតនត្រ័យ ដោយគោរព!

មនុស្សសត្វទាំងឡាយ ដែលកើតមកក្នុងលោក សុទ្ធសឹងតែមាន គោលបំណងតែមួយដូច ៗ គ្នា គឺចង់បានសេចក្តីសុខតែម្យ៉ាង ហើយ ស្អប់ខ្ពើមសេចក្តីទុក្ខ ពុំចង់ជួបប្រទះសោះឡើយ ។ សេចក្តីសុខ ជា ឥដ្ឋារម្មណ៍ គឺអារម្មណ៍ជាទីប្រាថ្នា, ឯសេចក្តីទុក្ខ ជាអនិដ្ឋារម្មណ៍ គឺ អារម្មណ៍មិនជាទីប្រាថ្នា របស់មនុស្សសត្វទូទៅគ្រប់ប្រភេទ ។ សេចក្តី សុខនិងសេចក្តីទុក្ខ ជាផលដែលកើតចេញមកពី កម្ម ឬថា កម្ម ជាមូលហេតុដែលនាំបង្កបង្កើតសេចក្តីសុខនិងសេចក្តីទុក្ខគ្រប់យ៉ាង ។

ពាក្យថា កម្ម ជាពាក្យកណ្តាល ពុំទាន់ប្រាកដថា ល្អ ឬ អាក្រក់ នៅឡើយទេ ព្រោះធ្វើល្អ ក៏ហៅថា កម្ម ធ្វើអាក្រក់ ក៏ហៅថា កម្ម ។ បើលុះតែគេដាក់ កុសល ឬ អកុសល នាំមុខទៅជា កុសល-

កម្ម ឬជា អកុសលកម្ម ទើបអាចដឹងថា កម្មល្អ ឬកម្មអាក្រក់ ៗ សេចក្ដីសុខនិងសេចក្ដីទុក្ខ, បុណ្យនិងបាប, គុណនិងទោស, ល្អនិងអាក្រក់ ជាដើម ទាំងអស់នេះ កើតចេញពីកម្មហ្នឹងឯងជាប្រាកដ, ព្រោះហេតុនោះ មនុស្សទាំងឡាយ ដែលកើតមកក្នុងលោកសុទ្ធតែមានកម្ម គឺកុសលនិងអកុសល ជាប់មកជារបស់ខ្លួន គ្មាននរណាគេចចៀសវាងផុតពីកម្មបានឡើយ ៗ សេចក្ដីនេះ សមនឹងព្រះពុទ្ធដីកាក្នុងចូឡកម្មវិភង្គសូត្រ គម្ពីរមជ្ឈិមនិកាយថា : សព្វេ សត្តា កម្មស្សកា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា យំ កម្មំ ករិស្សន្តិ កល្យាណំ វា បាបកំ វា តស្ស ទាយាទា ភវិស្សន្តិ កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ សេចក្ដីថា សត្វសត្វទាំងអស់ សុទ្ធតែមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ (មត៌ក) មានកម្មជាកំណើត មានកម្មជាផៅពង្ស ឬ ជាញាតិសន្ដាន មានកម្មជាគ្រឿងរលឹក ឬជា ទីពឹងពំនាក់ បើនឹងធ្វើនូវកម្មណា ទោះល្អក្ដី អាក្រក់ក្ដី នឹងជាអ្នកទទួលយកនូវផលនៃកម្មនោះ កម្ម តែងបែងចែកសត្វទាំងឡាយដើម្បីឲ្យមានឋានៈថោកទាប និង ខ្ពង់ខ្ពស់ ៗ សេចក្ដីនៃពុទ្ធភាសិតនេះបញ្ជាក់ឲ្យឃើញច្បាស់ថា ពួកសត្វដែលមានឋានៈដ៏ខ្ពង់ខ្ពស់ ប្រកបដោយសេចក្ដីសុខ-ចម្រើនគ្រប់យ៉ាង អាស្រ័យដោយសារកុសលកម្ម, ពួកសត្វ

ដែលមានឋានៈដ៏ថោកទាប ប្រកបដោយសេចក្ដីទុក្ខលំបាកគ្រប់យ៉ាង អាស្រ័យដោយសារអកុសលកម្ម ។

## សេចក្ដីសុខ-ចំរើនគ្រប់យ៉ាង កើតអំពីកុសលកម្ម

ការប្រព្រឹត្តិធ្វើអ្វីខ្លះ ទើបហៅថា កុសលកម្ម ? ការលះបង់ទុច្ចរិត ៣ យ៉ាង មានកាយទុច្ចរិតជាដើមចេញ ហើយប្រព្រឹត្តសុចរិត ៣ យ៉ាង មានកាយសុចរិតជាដើមក្ដី ការប្រព្រឹត្តិធ្វើបុញ្ញកិរិយាវត្ថុ ១០ យ៉ាង មានការឲ្យទាន និងការរក្សាសីលជាដើមក្ដី ។ល។ ទាំងអស់នេះហៅថា កុសលកម្ម ប្រែថា អំពើជាកុសល ឬអំពើល្អ ដែលជាហេតុនាំឲ្យកើតសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់យ៉ាងដល់អ្នកធ្វើ ។

លំដាប់តទៅនេះ សូមពណ៌នាចំពោះតែកុសលកម្មរបស់អស់លោកអ្នកសប្បុរសទាំងឡាយដែលបានកសាងសេនាសនៈឧទ្ទិសចំពោះព្រះពុទ្ធសាសនា ។ ផ្នែកខាង អកុសលកម្ម ដែលជាអំពើអកុសលផ្ទុយនឹងកុសលកម្ម ពុំបានលើកយកមកពណ៌នាក្នុងអត្ថបទនេះផងឡើយ ។

ការកសាងទីសម្រាប់ដេក និងទីសម្រាប់អង្គុយ មានកុដិ សាលា វិហារជាដើម តំកល់ទុកក្នុងព្រះពុទ្ធសាសនា ច្រើនហៅថា សេនាសនទាន ។ ទីកន្លែងមានរោង ឬសាលាជាដើម ដែលគេកសាងបិតនៅក្បែរផ្លូវ តូចធំសម្រាប់ជ្រកស្នាក់សម្រាកអាស្រ័យមួយដងមួយកាល នៃជនអ្នកធ្វើដំណើរទូទៅគ្រប់ប្រភេទ ច្រើនហៅថា ឧបស្សយដ្ឋាន ឬអាវសថទាន ។

## ការកសាងសេនាសនៈ

សេនាសនៈ បើចែកទៅតាមប្រភេទនៃវត្ថុសម្រាប់ប្រើប្រាស់ មាន ៤ យ៉ាង គឺ

១– វត្ថុ គឺទីកន្លែងជាសំណាក់សម្រាប់ដេក-អង្គុយនៃបព្វជិត មាន កុដិ សាលា វិហារ អឌ្ឍយោគ គុហ ថែវ ជាដើម ហៅថា វិហារសេនាសនៈ ។

២– វត្ថុ ជារបស់សម្រាប់ប្រើប្រាស់ មានគ្រែ តាំង តុ កៅអី ជាដើម ហៅថា មញ្ចបីឋសេនាសនៈ ។

៣– វត្ថុ គឺគ្រឿងកម្រាលសម្រាប់ក្រាលដេក-អង្គុយ មានកន្ទេល ខ្នើយ ពូក ព្រំ ចៀមចំ ជាដើម ហៅថា សន្ថតសេនាសនៈ ។

៤– ទីកន្លែងណាមួយ មានទីសម្រាប់ចង្ក្រម ឬទីលាន បរិវេណ ជិតកុដិ សាលា វិហារ ជាដើម ឬក៏ទីសួនច្បារ ដីស្រែចំការ ដែលគេវេរទុកជូនសង្ឃ ដាក់ទុកជារបស់សម្រាប់វត្ត ហៅថា ឱកាសសេនាសនៈ ។

## សេនាសនៈដែលកើតឡើងជាដំបូងក្នុងព្រះពុទ្ធសាសនា

កាលដែលព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទើបនឹងត្រាស់ដឹងឡើងជាដំបូង ពុំទាន់មានវត្តនិងសេនាសនៈ ដូចសម័យសព្វថ្ងៃនេះនៅឡើយទេ, ពួកបព្វជិតជាសាវ័ករបស់ព្រះអង្គដែលបួសហើយ ច្រើននៅក្នុងព្រៃ

យកម្ទប់ឈើ ឬយកគល់ឈើធ្វើជាវត្ត ឬជាសេនាសនៈ ៗ ខាងក្រោយមក ព្រះមហាសម្ពុទ្ធ ដោយមានភិក្ខុសង្ឃជាព្រះអរហន្តតាមហែហោមជាបរិវារ ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីសំដែងធម៌ប្រោសព្រះបាទពិម្ពិសាររាជ តាមសេចក្តីប្តេជ្ញាក្នុងកាលមុនដែលព្រះអង្គពុំទាន់បានត្រាស់ដឹង ៗ លុះព្រះអង្គព្រមទាំងភិក្ខុសង្ឃ ទ្រង់យាងចូលទៅដល់ព្រះរាជនិវេសនដ្ឋាននៃព្រះបាទពិម្ពិសារហើយ ព្រះរាជាក៏ទ្រង់មានព្រះរាជហឫទ័យសោមនស្សជ្រះថ្លាដ៏ក្រៃលែង ទើបអារាធនានិមន្តព្រះអង្គព្រមទាំងភិក្ខុសង្ឃ ទទួលភត្តក្នុងវេលាព្រឹកស្អែក ៗ

គ្រានោះ ព្រះបាទពិម្ពិសារទ្រង់ព្រះតម្រិះថា ឥឡូវព្រះមានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃ ពុំទាន់មានវត្ត ឬសេនាសនៈដ៏សមគួរសម្រាប់គង់នៅឡើយ បើដូច្នោះ តើព្រះអង្គគួរគង់នៅក្នុងទីណាហ្ន៎ ដែលជាទីមិនឆ្ងាយពេក មិនជិតពេក អំពីទីក្រុង ជាទីងាយស្រួលល្មមទៅមកនៃមនុស្សទាំងឡាយដែលត្រូវការផង ជាទីមិនច្របូកច្របល់ក្នុងវេលាថ្ងៃ មានសម្លេងតិចមិនគ្រស្បូវគឹកកងក្នុងវេលាយប់ផង មានខ្យល់បក់ស្រួល គួរដល់ការពួនសម្ងំនៅនៃមនុស្សទាំងឡាយផង ៗ ព្រះរាជតម្រិះនៃព្រះបាទពិម្ពិសាររាជក្នុងខណៈនោះថា អើ! យើងមានឧទ្យានវេឡុវ័នមួយ, ឧទ្យាននេះ មិនឆ្ងាយពេក មិនជិតពេក អំពីទីក្រុង ជាទីស្រួលល្មមទៅមកបានដោយងាយនៃមនុស្សទាំងឡាយដែលត្រូវការ បើដូច្នេះ គួរអាត្មាអញវេរថ្វាយឧទ្យានវេឡុវ័ននុ៎ះ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ៗ ក្នុង

ពេលនោះ ព្រះបាទពិម្ពិសាររាជ ទ្រង់កាន់កុណ្ឌីមាសដ៏ពេញដោយទឹក ប្រោះដាក់លើព្រះហស្តនៃព្រះសម្មាសម្ពុទ្ធ ហើយក៏ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន! ខ្ញុំព្រះអង្គសូមវេរថ្វាយនូវវេឡុវ័ននុ៎ះ ជាអារាមដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រោះនិទាននេះឯង ទើបព្រះភគវ័តទ្រង់ធ្វើធម្មីកថាចំពោះព្រះបាទពិម្ពិសាររាជ មួយអន្លើដោយភិក្ខុសង្ឃទាំងឡាយ អនុញ្ញាតអារាមក្នុងពេលនោះថា អនុជានាមិ ភិក្ខវេ អារាមំ បដិគ្គហេតុំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុទាំងឡាយទទួលនូវអារាមបាន ។ អារាមឈ្មោះវេឡុវ័ននេះ កើតមានឡើងជាដំបូងបំផុតក្នុងព្រះពុទ្ធសាសនា ដែលព្រះបាទពិម្ពិសាររាជ ក្រុងរាជគ្រឹះ បានវេរថ្វាយព្រះអង្គ ។ ខាងក្រោយមក ទើបព្រះរាជាទ្រង់ចាត់ការឲ្យកសាងសេនាសនៈផ្សេងៗទៀត ជានិវាសនដ្ឋាន ថ្វាយព្រះសម្មាសម្ពុទ្ធនិងភិក្ខុទាំងឡាយសម្រាប់គង់នៅជាប្រក្រតី ។

តាមសេចក្តីដំណាលក្នុងគម្ពីរបរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ ថា វត្តវេឡុវ័ននោះ មានកំពែងកំពស់ ១៨ ហត្ថព័ទ្ធជុំវិញ មានគន្ធកុដិមួយសម្រាប់ជាទីគង់នៅ នៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ មានសេនាសនៈដទៃទៀតជាច្រើន គឺ កុដិ អឌ្ឍយោគ ប្រាសាទ គុហា មណ្ឌល ទីចង្ក្រម និងក្លោងទ្វារជាដើម ជាសេនាសនៈសម្រាប់ភិក្ខុសង្ឃជាសាវ័ក

នៅជាប្រក្រតី ៗ នៅខាងក្រៅកំពែង មានដើមគុម្ពឫស្សីជាច្រើនព័ទ្ធជុំវិញ បញ្ចេញពន្លឺពណ៌ខៀវស្រងាត់ គួរជាទីគយចាប់ចិត្តយ៉ាងក្រៃលែង ព្រោះហេតុនោះ បានជាគេហៅថា វត្តវេឡុវ័ន ដរាបមក ៗ មួយយ៉ាងទៀត គេហៅឈ្មោះវត្តនេះពេញបទថា វេឡុវ័នកលន្ទកា-និកាបដ្ឋាន ប្រែថា ព្រៃឫស្សីជាទីដែលគេតែងឲ្យនូវចំណីដល់សត្វកន្ធែន ព្រោះមានរឿងតំណាលថា កាលពីដើម ព្រៃឫស្សីនេះ ជាសួនឧទ្យាន មានស្ដេចមួយអង្គតែងយាងទៅក្រសាលក្នុងឧទ្យាននោះ ៗ ថ្ងៃមួយ ព្រះរាជាទ្រង់សោយសុរាស្រវឹង ផ្ទំលក់ក្នុងវេលាថ្ងៃ ៗ ចំណែកខាងព្រះរាជបរិពារទាំងប៉ុន្មាន ដែលតាមហែហមព្រះអង្គទៅផងនោះ ដោយបានដឹងថាព្រះរាជាផ្ទំលក់ហើយ ក៏នាំគ្នាចេញទៅដើរលេងកំសាន្តក្នុងទីខាងណេះខាងណោះអស់ទៅ ៗ គ្រានោះ មានពស់វែកមួយនៅក្នុងរន្ធឈើ ធុំក្លិនសុរា ហើយក៏លូនចេញតម្រង់មករកស្ដេចដោយបំណងនឹងចឹក ប៉ុន្តែរុក្ខទេវតា បានឃើញពស់នោះ ហើយគិតថា អញនឹងជួយសង្គ្រោះឲ្យជីវិតដល់ស្ដេចនេះចុះ ហើយក៏តំណែងភេទជាសត្វកន្ធែនទៅស្រែកជិតព្រះកណ្ណនៃស្ដេច ស្ដេចក៏ទ្រង់តើនឡើង ឯពស់វែកនោះក៏លូនត្រឡប់ទៅវិញ ៗ ព្រះរាជាទតទៅឃើញដូច្នោះ ក៏ទ្រង់ព្រះតម្រិះថា សត្វកន្ធែននេះ មកស្រែកជួយសង្គ្រោះឲ្យជីវិតដល់អញ បើកុំអី អញមុខជាត្រូវស្លាប់ក្នុងទីនេះពុំខាន ដោយព្រះតម្រិះដូច្នេះហើយ

ក៏ទ្រង់តាំងផ្ដើមឲ្យគេឲ្យចំណីដល់ពួកសត្វកែន្ហទក្នុងទីនោះផង ទ្រង់ឃោ-សនាបញ្ញត្តច្បាប់ឲ្យអភ័យដល់ពួកសត្វកែន្ហទក្នុងទីនោះផង, ព្រោះហេតុនោះ ចាប់ដើមតាំងពីថ្ងៃនោះមក ទីព្រៃនោះឯង គេហៅថា វេឡុវ័ន-កាលន្ទកនិវាបដ្ឋាន ដរាបមក ។

× × ×

# រាជគហសេដ្ឋីកសាងវិហារ

ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់នៅវត្តវេឡុវ័នកលន្ទក-និវាបដ្ឋាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះភគវ័ត មិនទាន់បាន អនុញ្ញាតសេនាសនៈដល់ពួកភិក្ខុនៅឡើយ ម៉្លោះហើយភិក្ខុទាំងឡាយនោះ ក៏នាំគ្នានៅក្នុងព្រៃខ្លះ នៅក្បែរគល់ឈើខ្លះ នៅជើងភ្នំខ្លះ នៅក្នុងព្រៃ ស្មសានខ្លះ នៅក្នុងទីកណ្ដាលវាលខ្លះ នៅទឹងគំនរចំបើងខ្លះ ។ លុះដល់ពេលព្រឹកឡើង ភិក្ខុទាំងនោះ ក៏ដើរចេញអំពីទីនោះៗ សឹងមានចក្ខុ សម្លឹងចុះ បរិបូណ៌ដោយឥរិយាបថស្រគត់ស្រគំរមទម្យគួរឲ្យកើតសេចក្ដី ជ្រះថ្លា ។ គ្រានោះឯង រាជគហសេដ្ឋី ធ្វើដំណើរចេញពីផ្ទះទៅកាន់ ឧទ្យានអំពីព្រលឹម បានឃើញភិក្ខុទាំងឡាយនោះ ក៏កើតមានសេចក្ដីជ្រះ ថ្លា នឹកគិតថា ភិក្ខុទាំងឡាយ មិនទាន់មានវិហារ (កុដិ) សម្រាប់គង់ ស្រួលបួលនៅឡើយទេ បើដូច្នោះ គួរអាត្មាអញចូលសួរមើល បើលោក ព្រមនៅ អាត្មាអញនឹងធ្វើវិហារប្រគេន ។ លំដាប់នោះ រាជគហសេដ្ឋី

ចូលទៅរកភិក្ខុទាំងឡាយ ហើយនិយាយនឹងភិក្ខុទាំងនោះថា បពិត្រលោកម្ចាស់ទាំងឡាយ ប្រសិនបើខ្ញុំព្រះករុណាឲ្យគេធ្វើវិហារប្រគេន តើលោកម្ចាស់ទាំងឡាយ នឹងគង់នៅក្នុងវិហាររបស់ខ្ញុំព្រះករុណាឬទេ? ភិក្ខុទាំងនោះឆ្លើយថា ម្នាលគហបតី ព្រះមានព្រះភាគ មិនទាន់បានអនុញ្ញាតវិហារដល់ភិក្ខុទាំងឡាយទេ ។ រាជគហសេដ្ឋីទូលថា បើដូច្នោះ សូមលោកម្ចាស់ទាំងឡាយ ក្រាបបង្គំទូលសួរព្រះមានព្រះភាគ អំពីរឿងវិហារនោះ បើបានការណ៍យ៉ាងណា សូមមេត្តាប្រាប់ដល់ខ្ញុំព្រះករុណាផង ។ ភិក្ខុទាំងនោះ ទទួលពាក្យរាជគហសេដ្ឋីហើយ ក៏នាំគ្នាចូលទៅក្រាបបង្គំគាល់ព្រះសម្មាសម្ពុទ្ធ ហើយទូលថា បពិត្រព្រះអង្គដ៏ចំរើន, រាជគហសេដ្ឋីមានបំណងនឹងឲ្យគេធ្វើវិហារដើម្បីយើងខ្ញុំទាំងឡាយ តើយើងខ្ញុំទាំងឡាយគប្បីប្រតិបត្តិដូចម្តេច? ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះភគវ័ត ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកជួបជុំ ហើយទ្រង់អនុញ្ញាតថា អនុជានាមិ ភិក្ខវេ បញ្ចសេនាសនានិ វិហារំ អឌ្ឍយោគំ បាសាទំ ហម្មិយំ គុហំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសេនាសនៈ ៥ យ៉ាងគឺ វិហារ ១ អឌ្ឍយោគ ១ ប្រាសាទ ១ ហម្មិយៈ ១ គុហា ១ ។

កាលបើព្រះមានព្រះភាគទ្រង់អនុញ្ញាតដូច្នេះហើយ ភិក្ខុទាំងឡាយនោះចូលទៅរករាជគហសេដ្ឋី ហើយនិយាយយ៉ាងនេះថា ម្នាលគហបតី

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់អនុញ្ញាតវិហារហើយ បើអ្នកយល់ថា កាលណាគួរ ក៏គប្បីធ្វើចុះ ។ គ្រានោះ រាជគហសេដ្ឋី ចាត់ការឲ្យគេសាងវិហារបានចំនួន ៦០[១] តែមួយថ្ងៃក៏ហើយទាំងអស់ ។ លុះសាងវិហាររួចហើយ រាជគហសេដ្ឋី ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន! សូមព្រះមានព្រះភាគ មួយអន្លើដោយភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គក្នុងវេលាថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ រាជគហសេដ្ឋី កាលបើបានដឹងច្បាស់ថា ព្រះមានព្រះភាគទ្រង់ទទួលនិមន្តហើយ ក៏ថ្វាយបង្គំលាព្រះមានព្រះភាគ ក្រោកចាកអាសនៈហើយចៀសចេញទៅ ។ គ្រាកាលកន្លងរាត្រីនោះទៅ រាជគហសេដ្ឋី ក៏ឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ប្រណីតផ្ចិតផ្ចង់រួចហើយ ឲ្យគេទៅក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន! ភត្តកាលសម្រេចហើយ ។

ក្នុងវេលាបុព្វណ្ហសម័យ ព្រះមានព្រះភាគ ទ្រង់យាងទៅកាន់និវេសនដ្ឋាននៃរាជគហសេដ្ឋី លុះយាងទៅដល់ហើយ ទ្រង់គង់លើពុទ្ធាសនៈដែលគេតាក់តែងបំរុងទុក មួយអន្លើដោយភិក្ខុសង្ឃ ។ ឯរាជគហសេដ្ឋី បានអង្គាសខាទនីយភោជនីយាហារដ៏ឆ្ងាញ់ពិសា ដោយដៃខ្លួនឯង ថ្វាយចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់, លុះព្រះអង្គទ្រង់

---

១ វិហារទាំង ៦០ នោះ មានទំហំតូចៗ ធ្វើដោយគ្រឿងឈើប្រក់ស្លឹក សម្រាប់នៅមួយអង្គៗ ។

សោយហើយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រទៀតហើយ, ទើបភផគហសេដ្ឋី ក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គជាអ្នកត្រូវការដោយបុណ្យនិងបានសួគ៌ បានសាងវិហារចំនួន ៦០ នេះ រួចស្រេចអស់ហើយ, បពិត្រព្រះអង្គដ៏ចំរើន! ខ្ញុំព្រះអង្គនឹងគប្បីប្រតិបត្តិចំពោះវិហារទាំងនោះដូចម្តេច? ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតី! បើដូច្នោះ អ្នកចូលប្រតិស្ឋានវិហារទាំង ៦០ នោះ សំរាប់សង្ឃដែលមកហើយ និងមិនទាន់មក អំពីទិសទាំង ៤ ចុះ ។ ភផគហសេដ្ឋីទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ! រួចក៏ប្រតិស្ឋានវិហារទាំង ៦០ នោះ សម្រាប់សង្ឃដែលមកហើយនិងមិនទាន់មក អំពីទិសទាំង ៤ ។ ទើបព្រះមានព្រះភាគទ្រង់ធ្វើអនុមោទនា ចំពោះភផគហសេដ្ឋី ដោយគាថាទាំងឡាយនេះថា :

សីតំ ឧណ្ហំ បដិហន្តិ តតោ វាឡមិគានិ ច
សរីសបេ ច មកសេ សិសិរេ ចាបិ វុដ្ឋិយោ
តតោ វាតាតបោ ឃោរោ សញ្ជាតោ បដិហញ្ញតិ
លេណត្ថញ្ច សុខត្ថញ្ច ឈាយិតុញ្ច វិបស្សិតុំ
វិហារទានំ សង្ឃស្ស អគ្គំ ពុទ្ធេហិ វណ្ណិតំ ។
តស្មា ហិ បណ្ឌិតោ បោសោ សម្បស្សំ អត្ថមត្តនោ
វិហារេ ការយេ រម្មេ វាសយេត្ថ ពហុស្សុតេ ។

តេសំ អន្នញ្ច បានញ្ច វត្ថសេនាសនានិ ច
ទទេយ្យ ឧជុភូតេសុ វិប្បសន្នេន ចេតសា
តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខាបនូទនំ
យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតិ អនាសវោ ។

( វិហារ គឺទីអាវាស ឬសេនាសនៈជាទីនៅនៃសង្ឃទាំងឡាយ ) រមែងការពារត្រជាក់ផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូចនិងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់និងកម្តៅថ្ងៃដ៏ក្លាខ្លាំង ដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះ ៗ ។ វិហារទាន គឺការឲ្យទីលំនៅ ( ដែលបុគ្គលបានឲ្យហើយ ) ដល់សង្ឃ ដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចំរើនវិបស្សនាផង ព្រះពុទ្ធទាំងឡាយ តែងត្រាស់សរសើរថា ជាទានដ៏ប្រសើរ ។ ព្រោះហេតុនោះឯង បុរសស្រ្តីជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន គប្បីកសាងវិហារ គឺអាវាសឬសេនាសនៈទាំងឡាយ ដ៏ជាទីគួររីករាយ ហើយគួរនិមន្តលោកដែលជាពហុស្សូត គឺលោកអ្នកចេះដឹងច្រើនទាំងឡាយ ដែលមានចិត្តដ៏ត្រង់ ហើយប្រគេនបាយ ទឹក សំពត់ និងសេនាសនៈទាំងឡាយ ដល់លោកទាំងនោះចុះ ។ លោកទាំងនោះ រមែងសំដែងធម៌ជាគ្រឿងបន្ទោបង់

ឲ្យឃាតខាតទុក្ខគ្រប់ប្រការដល់អ្នកនោះ លុះអ្នកនោះ បានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វាន ។

កាលដែលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់អនុមោទនាចំពោះគហបតីសេដ្ឋី ដោយគាថាទាំងឡាយនេះរួចហើយ ព្រះអង្គក៏ទ្រង់ក្រោកចាកអាសនៈ យាងចៀសចេញទៅ ។ គ្រាខាងក្រោយពីនោះមកទៀត មនុស្សទាំងឡាយ បានឮដំណឹងថា ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតវិហារសំរាប់ភិក្ខុសង្ឃហើយ ក៏នាំគ្នាយកចិត្តទុកដាក់កសាងវិហារ ក្នុងស្រុកនិគមជនបទផ្សេង ៗ ដើម្បីឧទ្ទិសចំពោះភិក្ខុសង្ឃ ក្នុងព្រះពុទ្ធសាសនា ដរាបមក ។ សម័យនោះឯង ភិក្ខុទាំងឡាយ នៅក្នុងអារាមដែលពុំទាន់មានឧបដ្ឋានសាលានៅឡើយ នាំគ្នាឆាន់អាហារក្នុងទីវាល រមែងមានការលំបាកដោយត្រជាក់ខ្លះ ដោយកំដៅថ្ងៃខ្លះ ។ ភិក្ខុទាំងនោះក្រាបបង្គំទូលរឿងនោះ ចំពោះព្រះមានព្រះភាគ, ព្រះអង្គទ្រង់ត្រាស់ថា អនុជានាមិ ភិក្ខវេ ឧបដ្ឋានសាលំ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឧបដ្ឋានសាលា ( សាលាដែលឧបាសក-ឧបាសិកាផ្គត់ផ្គង់ដោយអាហារភោជន បំរើភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ) ។ គ្រានោះ មនុស្សទាំងឡាយ អ្នកមានសទ្ធាជ្រះថ្លា ក៏នាំគ្នាកសាងឧបដ្ឋានសាលាឡើង សំរាប់បំរើភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ជាប់ជាប្រពៃណីរហូតមកដល់បច្ចុប្បន្នសម័យនេះ ។ល។ (នៅមានត)

# យោបល់ឯកឧត្តម យឹម-ទិត ផ្ញើជូនសហ. សម-ហាំង

ឯ ឧ. យឹម-ទិត បានយកលិខិតមួយរបស់លោកដែលផ្ញើទៅសហ. សម-ហាំង ដើម្បីថ្លែងយោបល់លោកព្រមទាំងមានចំណារអក្សរល្អិត របស់ព្រះសាសនមុនី ពិម-ពូ ភ្ជាប់ជាមួយផង។

ភ្នំពេញ ថ្ងៃទី ១៦ មិថុនា ១៩៦៧

ជំរាបមកលោក សម ហាំង

សូមជ្រាប ។

ខ្ញុំបានទទួលសៀវភៅធម៌ ដែលជាស្នាព្រះហស្តសម្តេចក្រុមព្រះមុនីវេត ទ្រង់ព្រះរាជនិពន្ធជាភាសាបារាំង ហើយលោកជាអ្នកប្រែមកជាភាសាខ្មែរ ។ ខ្ញុំបានអានសៀវភៅនេះខ្លះហើយ ដោយមានចាប់អារម្មណ៍ជាច្រើន ដូចជាសម្តេចទ្រង់ព្រះតម្រិះថា ឲ្យអ្នកកាន់ព្រះពុទ្ធសាសនា ត្រិះរិះរកសេចក្តីពិតខ្លួនឯងផង ។ ត្រង់នេះជាការត្រូវពិតណាស់ ពីព្រោះខ្ញុំធ្លាប់បានអានសៀវភៅអ្នកនិពន្ធជាតិយើង បានរៀបរៀងអំពីព្រះពុទ្ធសាសនា គឺព្រះសូត្រក្តី ព្រះវិន័យក្តី ព្រះអភិធម្មក្តី ដោយដកស្រង់យកពីគម្ពីរ

អហេតុកចិត្ត ក្នុងទីនេះប្រែថា ចិត្តគ្មានហេតុ ឧទាហរណ៍ ដូចបុគ្គលបើកភ្នែក ក្រឡេកទៅឃើញរូបអ្វីជាដំបូង នៅមិនទាន់មានវិតក្កៈវិចារៈ ដែលជាហេតុឲ្យកើតសោមនស្ស ទោមនស្ស ទៅលើរូបនោះនៅឡើយទេ ក្នុងខណៈនោះ ចិត្តនេះ ហៅ អហេតុកចិត្ត ព្រោះមិនទាន់ចាត់ជាចិត្តបុណ្យ ឬ បាបនៅឡើយ ។

ផ្សេងៗមានគម្ពីរទីឃនិកាយ អង្គុត្តរនិកាយជាដើម ខ្ញុំបានសំគាល់ឃើញ ក្នុងអត្ថបទទាំងនោះ ដែលអ្នកនិពន្ធដកស្រង់ពីគម្ពីរមកហើយ គ្មានអធិប្បាយអ្វីក្រៅ ជាសេចក្តីយល់ឃើញរបស់អ្នកនិពន្ធ គឺឃើញនៅត្រឹមត្រូវទាំងអស់ តែមានអ្នកនិពន្ធខ្លះបើមានសេចក្តីយល់ឃើញផ្ទាល់ខ្លួន ច្រើនតែមានទក័ន្តច្រឡំ ។ ឧទាហរណ៍ដូចអភិធម្មអំពីផ្លូវចិត្ត មានអហេតុកចិត្តជាដើម ។ អហេតុកចិត្តនេះ ជាចិត្តមួយផ្នែកដែលមានសុទ្ធតែជាឧបេក្ខា គឺជាចិត្តដែលឥតហេតុ គឺហេតុទាំង ៦ មានលោភ ទោស មោហ និង អលោភ អទោស អមោហ ។ ចិត្តនេះជាតួវិបាក គឺជាផលរបស់កម្មដែលយើងបានធ្វើមកពីអតីតជាតិ ។ អ្នកនិពន្ធខ្លះឲ្យមានឧទាហរណ៍ថា អហេតុកចិត្តនេះ ជាឧបេក្ខាបើធ្វើបុណ្យក៏បានតិច បើធ្វើបាបក៏បានតិច ។ យល់នេះខុសទាំងស្រុង ។

ឆន្ទ (បំណង) បើបំណងកើតឡើងហើយ ត្រូវឲ្យមានវីរិយៈ (សេចក្ដីព្យាយាម, សេចក្ដីប្រឹងប្រែងឈានទៅមុខមិនឈប់) បើវីរិយៈកើតឡើង ត្រូវឲ្យមានចិត្តៈ (សេចក្ដីត្រិះរិះ, សតិ) បើចិត្តៈកើតឡើងហើយ ត្រូវឲ្យមានវីមំសា (ប្រាជ្ញា) ការយល់ឃើញហេតុការណ៍ទូលំទូលាយ, កិច្ចការអ្វីខាងផ្លូវលោកក្ដី គុណវិសេសខាងផ្លូវធម៌ មានឈានសមាបត្តិជាដើមក្ដី ដែលនឹងសម្រេចទៅបាន អាស្រ័យដោយឥទ្ធិបាទធម៌ទាំងអស់; សមដូចយោបល់ របស់ឯកឧត្ដមដែលយល់នោះដែរ ។

មួយទៀត មានធម៌ខ្លះ ដូចជាឥទ្ធិបាទធម៌ ដែលព្រះពុទ្ធទ្រង់បានសម្ដែងមកថាជាធម៌មានខ្លឹមសារ អាចជាធម៌ធ្វើឲ្យមានឫទ្ធិយ៉ាងខ្លាំង បើតាមខ្ញុំមើលទៅមានមនុស្សជាច្រើន ពុំទាន់យល់អស់អំពីអត្ថន័យនៃធម៌នេះទេ ។ យើងយល់ថា : ឥទ្ធិបាទដែលជាធម៌ សម្រាប់ប្រព្រឹត្តឲ្យបានខាងផ្លូវលោកុត្តរ ។ ឯធម៌នេះ ត្រូវតែយកមកអនុវត្តក្នុងផ្លូវលោកិយផង ឧទាហរណ៍ ដូចចរិយាដែលមានចែកជាបំផែក ក្នុងនេះ ខ្ញុំយកតែចរិយាសិក្សាមកអធិប្បាយ ។ ចរិយាសិក្សាត្រូវប្រកបទៅនឹងឥទ្ធិបាទ ទើបបានសម្រេចផលដ៏បរិបូណ៌ ។ ដូចលោកជ្រាបស្រាប់ហើយ ឥទ្ធិបាទមានអង្គបួនគឺ ឆន្ទៈ វិរិយៈ ចិត្តៈ និង វិមំសា ។ យើងធ្វើអ្វីក៏ដោយ បើគ្មានឆន្ទៈទេ មិនបានសម្រេចតាមបំណងឡើយ ។ បើមានឆន្ទៈហើយត្រូវឲ្យមានវិរិយៈជួយគាំទ្រផង ត្រង់ពាក្យវិរិយៈនេះ ដែល

ប្រែមកជាភាសាខ្មែរថា ប្រឹងប្រែង មិនពេញ
សព្វទេ គឺប្រឹងប្រែងប្រកបដោយថាមពល ។
ឧទាហរណ៍ដូចជាព្រះពុទ្ធ កាលទ្រង់ប្ដេជ្ញានៅ
ពេលដែលព្រះអង្គធ្វើសមាធិ ក្រោមដើម
និគ្រោធព្រឹក្សនៅពុទ្ធគយាថា៖ ប្រសិនបើមិន
បាន ត្រាស់ដឹងនៅពេលនេះទេ ព្រះអង្គមិន
រំសាយព្រះភ្នែនឡើយ ។ ឯ វិមំសា វិញ ខ្ញុំគឺ
យល់ថាសព្វថ្ងៃនេះ យើងយល់ពាក្យនេះមិន
ច្បាស់លាស់ដែរ វិមំសា ប្រែមកជាខ្មែរថា
ពិនិត្យប្រឡង ពិសោធ យ៉ាងណាមិញ ដូច
និស្សិតដែលបានរៀនវិជ្ជាអ្វីមួយចប់ វិជ្ជានេះ
កាលណាគ្រូល្បងមើលតើសិស្សរបស់ខ្លួនចេះ
ចាំមេរៀននេះហើយឬនៅ "ឲ្យប្រឡង" ដូច
ជារឿងកុមារពេទ្យទៅរៀន នៅសាលាទិសា-
បាមោក្ខនគរតក្កសិលាគ្រប់ ៧ ឆ្នាំហើយ កុមារ
នេះបានទៅសួរគ្រូថា : ការរៀនរបស់ខ្ញុំ តើ
ចប់ហើយឬនៅ គ្រូតបថា បើចង់ដឹងដូច្នេះ
ត្រូវកុមារឯងយកចបមួយទៅជីកយកឫសឈើ

សតិជាគូនឹងសម្បជញ្ញៈ ហៅថា ពហុការធម៌ ធម៌មានឧបការច្រើន ។ បុគ្គលធ្វើការអ្វីក៏ដោយ ត្រូវតែមានសតិសម្បជញ្ញៈ គ្រប់ឥរិយាបថទាំងអស់ ទើបការដែលធ្វើនោះមិនខុសភ្លាត់, ចំណែកខាងការប្រតិបត្តិធម៌ ថ្នាក់ណាក៏ដោយ ត្រូវតែប្រើសតិសម្បជញ្ញៈ ឲ្យកើតមានគ្រប់វេលាទាំងអស់ ទើបសេចក្តីប្រតិបត្តិនោះ ត្រង់ទៅរកសេចក្តីពិតបាន បើគ្មានសតិសម្បជញ្ញៈ ក្នុងការដែលខ្លួនធ្វើនោះទេ ទុកជាខុស ប្រើការពុំបានឡើយ សមដូចឯកឧត្តមយល់នោះដែរ ។

ដែលមានផ្ទះនៅជុំវិញក្រុងតក្កសិលា ហើយពិនិត្យពិសោធមើល តើមានឈើណាខ្លះដែលមិនមែនជាថ្នាំ ។ កុមារពេទ្យបានធ្វើតាមបញ្ជាគ្រូ ហើយក៏មកជំរាបគ្រូវិញថា ក្នុងចំណោមឈើ ដែលខ្ញុំបានពិនិត្យមើលហើយនេះ គ្មានឈើអ្វីដែលមិនមែនជាថ្នាំនោះទេ ។ គ្រូនឹកក្នុងចិត្តថា កុមារពេទ្យរៀនបានចប់សព្វគ្រប់ហើយ ។ នេះហើយដែលហៅថាវិមំសា ។

មានឧទាហរណ៍មួយទៀតអំពីផ្លូវអភិធម្ម ខ្ញុំបានអានសៀវភៅ ដែលអ្នកនិពន្ធជាតិយើងបានថែងអំពីសមាធិ ។ ក្នុងសៀវភៅទាំងនោះ អ្នកនិពន្ធបានដកស្រង់ពីគម្ពីរព្រះអភិធម្ម មានសមាធិនិទ្ទេសជាដើម ក្នុងគម្ពីរវិសុទ្ធិមគ្គបានរៀបរាប់ពីសេចក្តីដែលត្រូវធ្វើសមាធិនោះ ដូចម្តេចខ្លះ តែមានខ្លះគោលធំបំផុតក្នុងពេលដែលព្រះអង្គបានបញ្ញត្តក្នុងសមាធិការនោះ គឺមហាសតិបដ្ឋានសូត្រ បើគ្មានសតិទេ តើធ្វើសមាធិកើតឬទេ ? ។

ការដែលខ្ញុំបានសាសព្ទទាំងប៉ុន្មាននេះ ជាសេចក្ដីយល់ឃើញផ្ទាល់ខ្លួនរបស់ខ្ញុំទេ ការយល់ឃើញនេះ ខ្ញុំមិនអាចអះអាងថា ខ្ញុំយល់ត្រូវឡើយ ប៉ុន្តែសុំឲ្យលោកដែលជាអ្នកប្រាជ្ញខាងពុទ្ធសាសនាពិនិត្យថែមទៀតចុះ ឬពិគ្រោះសួរទាំងអស់លោកណា ដែលស្ទាត់ជំនាញក្នុងព្រះពុទ្ធសាសនានេះទៀតផង ។

មុនទាំងបញ្ចប់ ខ្ញុំសូមអរគុណលោកដែលបានផ្ញើសៀវភៅ ដែលបានថែងរួចហើយមកឲ្យខ្ញុំ ហើយខ្ញុំសូមជូនមកលោកវិញនូវសៀវភៅមួយស្ដីអំពីព្រះពុទ្ធសាសនា ដែលខ្ញុំដាក់ឈ្មោះថា "ព្រះពុទ្ធសាសនាជាផ្លូវទៅកាន់សន្តិភាព" និងអត្ថបទមួយទៀតដែលមានឈ្មោះថា "ប្រវត្តិប្រទេសខ្មែរ នៅបច្ចុប្បន្នមួយផ្នែក" ។

សូមលោកទទួលនូវសេចក្ដីរាប់អាន
របស់ខ្ញុំដោយស្មោះបំពោះ ។

ឃឹម·ធិត

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មាំ
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

## ពិចារណាដើម្បីយល់តក្កវិជ្ជា

(ត)

លោក ហ៊ុន គិមសៀ រៀបរៀង

### ប- ការទាក់ទងរវាងទស្សនិយម (Concept)

*សត្វ, លោក, បាតុភូត ( Phénomène ) ទាំងអស់ ដែលកើតមានឡើង សុទ្ធតែមានការទាក់ទងគ្នាទៅវិញទៅមក ។ ទស្សនៈរបស់មនុស្ស គឺជារូបញ្ចាំងសាកលលោកខាងក្រៅ ដែលឆ្លុះចូលទៅក្នុងខួរក្បាលមនុស្ស ដូច្នេះ ទស្សនៈក៏មានការទាក់ទងគ្នាដូច្នោះដែរ ។*

*រវាងទស្សនៈ វាមានការទាក់ទងគ្នាដល់ទៅ ៦ យ៉ាង បើអ្នកណាធ្លាប់រៀនតក្កវិជ្ជា គេអាចយល់ច្បាស់រឿងនេះ ។*

១- *ទាក់ទងស្មើគ្នា* ( Rapport identique ) *មានទស្សនៈមួយចំនួន បើយើងយកលក្ខណៈឯកឯង ( ផ្ទាល់ ) មកពិចារណា*

យើងឃើញថា : ក៏មានកន្លែងខុសគ្នាច្រើន ប៉ុន្តែទស្សនៈនោះ គឺមានកម្រិតតែមួយទេ ។

ឧទាហរណ៍ : " រមគីន ,, និង " អ្នកនិពន្ធរឿងសុផាត ,, ខាងលើនេះ ជាទស្សនៈពីរ ប៉ុន្តែបង្អុលកម្រិតតែមួយ ។ លក្ខណៈឯកឯង ( ផ្ទាល់ ) នៃពាក្យ " រម - គីន ,, ក៏ខុសគ្នាពីពាក្យ " អ្នកនិពន្ធរឿងសុផាត ,, ប៉ុន្តែបើនិយាយអំពីមនុស្សវិញ គឺតែមួយ ប៉ុន្តែ ពាក្យថា " រម-គីន " ក៏ទូលាយជាងពាក្យថា : " អ្នកនិពន្ធរឿងសូផាត " ។ ដូច្នេះ ពីត្រឹមនេះទៅ យើងហៅថា "ទាក់ទងស្មើគ្នា" ដូចមានគំនូខាងក្រោមនេះ ។

ក និង ១ មានតម្លៃ

ស្មើគ្នា




រូបទី ១

២- ទាក់ទងក្រោមបង្គាប់ (Rapport dépendent) ក្នុងករណីនេះ គឺការទាក់ទងរវាងទស្សនៈមួយដែលមានលក្ខណៈមិនសូវទូទៅ មិនសូវទូលាយនិងទស្សនៈមួយទៀតដែលមានលក្ខណៈទូទៅឬទូលាយជាង ។

ឧទាហរណ៍ : " ដើមឈើ " និង " ដើមស្វាយ " ។

ដើមស្វាយថា ឈើម្យ៉ាងនៅក្នុងពួកដើមឈើ ។ ដូច្នេះ ពាក្យថា « ដើមស្វាយក៏ចង្អៀតជាងពាក្យថា : « ដើមឈើ » ។




យើងឃើញមានលក្ខណៈ ដើមឈើ ក៏ទូលាយទូទៅ ជាងលក្ខណៈដើមស្វាយ ។

រូបទី ២

៣- ទាក់ទងសមមាត្រ Rappot égal ទាក់ទងសមមាត្រគឺជាការទាក់ទងរវាងទស្សនៈក្រោមបន្ទាប់ដែលមានជំពូកតែមួយដូចគ្នាទាំងអស់ ។

ឧទាហរណ៍ : ទស្សនៈ « ផ្លែ » ( ក ) គឺទស្សនៈជំពូកមួយ ដែលរួមមានប្រភេទផ្លែស្វាយ ( ខ ) ប្រភេទផ្លែ « ខ្នុរ » (គ) ផ្លែ « ល្មុត » ( ឃ ) ។

ទស្សនៈ ៣ ខាងក្រោយនេះ គឺ : ស្វាយ, ខ្នុរ, ល្មុត មានតម្លៃស្មើគ្នាទាំងអស់ ។




"ក" (ផ្លែ) បង្អួលទស្សនៈ ជំពូក ។ រង្វង់តូចៗ ៣ ទៀត គឺ ខ គ ឃ បង្អួលទស្សនៈប្រភេទ ដែលមានតម្លៃស្មើគ្នាទាំងអស់ ។

៤- ពាក់ទងជាន់លើគ្នា ពាក់ទងជាន់គ្នាបានសេចក្ដីថា : ទស្សនៈពីរដែលមានលក្ខណៈទូទៅ ប៉ះគ្នាឬជាជាន់លើគ្នាក៏បាន ។

ឧទាហរណ៍ : យុវជននិងសាស្ត្រាចារ្យ ។ មានយុវជនខ្លះ ធ្វើជាសាស្ត្រាចារ្យ មានសាស្ត្រាចារ្យខ្លះធ្វើជាយុវជន ។ ឧទាហរណ៍ ដូចជាពលរដ្ឋភ្នំពេញ ខ្លះជាកម្មករ ។ កម្មករ នៅភ្នំពេញ ជាពលរដ្ឋ ។




វាមានលក្ខណៈទូទៅ ជាន់លើគ្នា ។

រូបទី ៤

៥– ពាក់ទងប្រឆាំងគ្នា : គឺជា ការពាក់ទងម្យ៉ាងដែលមានលក្ខណៈឯកឯង ( Carractère privé ) ខុសគ្នា ប៉ុន្តែ ទស្សនៈនោះ នៅគង់លក្ខណៈទូទៅដូចគ្នា ។

ឧទាហរណ៍ : “ ក្រហម ,, និង “ ខៀវ ,, ។ “ ក្រហម ,, វាជាពណ៌មួយខុសពីពណ៌ “ ខៀវ ,, ប៉ុន្តែ ទាំងពីរនេះ វានៅគង់លក្ខណៈទូទៅមួយគឺ “ ពណ៌ ” ។

ឧទាហរណ៍ : “ កុសល ,, និង „ អកុសល ” ពិតមែនតែពាក្យទាំងពីរនេះ មានលក្ខណៈឯកឯងខុសគ្នា ប៉ុន្តែមានលក្ខណៈទូទៅដូចគ្នាគឺ : កុសលក៏ជាមេរៀន; អកុសលក៏ជាមេរៀន ។

ខ្មៅ និង ស មានលក្ខណៈ ឯកឯងខុសគ្នា ប៉ុន្តែ មានលក្ខណៈទូទៅ ដូចគ្នា គឺ ពណ៌




រូបទី ៥

៦– ទាក់ទងផ្ទុយគ្នា (Rapport contradictoire) គឺជាការទាក់ទងម្យ៉ាងដែលមានទស្សនៈពីរ ហើយទស្សនៈនីមួយ ៗ ក៏ផ្ទុយគ្នា ប៉ុន្តែ ជាពិសេស លក្ខណៈឯកឯង នៃទស្សនៈទី ២ ក៏មិនលេចចេញមកឲ្យច្បាស់ទេ ។

ឧទាហរណ៍ : “ ខ្មែរ ,, និង „ មិនមែនខ្មែរ ,, ។ ពាក្យថា “ មិនមែនខ្មែរ ,, ក៏ផ្ទុយនឹងពាក្យថា “ ខ្មែរ ” ប៉ុន្តែ ក៏មិនបញ្ជាក់ឲ្យច្បាស់ថា តើយួន ឬ ចិន ឬ អ្វី ?

ឧទាហរណ៍: “ ស ” និង “ មិនមែនស ” ។ ( ប៉ុន្តែ

កុំប្រឡំនឹងករណី "ស្រី" និង "មិនមែនស្រី" ពីព្រោះមនុស្សយើងមាន តែប្រុសនឹងស្រី ។ ចំណែកឯខ្ទើយយើងមិននិយាយដល់ )

ឧទាហរណ៍ : « ក្ដៅ » និង "មិនមែនក្ដៅ" ។




សូមមិត្តអ្នកអាន ពិចារណាជំពូក « ការពាក់ទងនេះ » ឲ្យច្បាស់ លាស់ ពីព្រោះប្រការនេះសំខាន់ណាស់ ក្នុងការបង្វិលសំដី លេងពាក្យ ក្នុងសង្គ្រាមសំដី ឬ សង្គ្រាមប៉ាកកា ។ (នៅមានត)

---

អន្វេក្សណា  នបុំ.  កិរិយាត្រួតត្រា ។

អន្វេក្សា  ស្ត្រី. កិរិយាពិចារណា ។ -អន្វេក្សិត គុ. ដែលត្រួតត្រាមើល។

អន្វប្ដកា  ស្ត្រី.  ថ្ងៃតពីអប្ដកា ។

អន្វហ៑  ធាតុ.  ហៅបន្ទាប់, ហៅតាមលំដាប់ ។

អន្វាក្រម៑  ធាតុ.  ដើរមើលតាមក្រោយ ។

អន្វាគម៑  ធាតុ  ទៅតាមក្រោយ, ជូន ។ -អន្វាគត គុ. ដែលទៅតាម, ដែលជូន ។

អន្វាបរ៑  ធាតុ.  ធ្វើគ្រាប់ ។

អន្វាទ្រុ  ធាតុ  ដេញតាម, រត់តាម ។

អន្វាជា  ធាតុ  ដាក់បន្ថែម, បន្ថែមខស ។

អន្វាធេយ  នបុំ.  អន្វាធេយ, ទ្រព្យគឺស្ត្រីរៀបការហើយ បានទទួលពីត្រកូលស្វាមី ។

អន្វាគី ធាតុ. នាំទៅ ។

អន្វាយត្ត គុ. ដែលចងជាមួយ, ដែលអាស្រ័យដោយ, ដែលពឹងផ្អែក ។

អន្វារភិ ធាតុ. ប្រារព្ធតាម ។

អន្វារុហ៍ ធាតុ. ឡើងតាម, វាយលុកតាមដណ្ដើម ។

អន្វាលភ៑ ធាតុ. បានស្រេច, បានដល់ដៃ ។

អន្វាលម្ភន នបុ. ក្ដាប់, មួយចិប ។

អន្វាវិត៑ ធាតុ. កាន់កាប់, ប្រតិបត្តិតាម ។

អន្វាវ្ឫត៑ ធាតុ. ដេញតាម ។

អន្វាគ្រិត គុ. ដែលអាស្រ័យតាម ។

អន្វាស ធាតុ. អង្គុយជិត, រស់នៅជិត, គោរព ។

អន្វាសន នបុ. កិរិយាបំរើ ។

អន្វាហាយ៌ នបុ. អន្វាហាយ៌, ភោជនដែលឧទ្ទិសចំពោះអ្នកស្លាប់, មតកភត្ត ។

—បចន ប៉ុ. ភ្លើងវេទីទិសខាងត្បូងដើម្បីអន្វាហាយ៌ ។

**អន្វិ** ធាតុ. ទៅតាម, ដើរតាម, ស្វែងរក, ដល់គោលបំណង, បេះ ។ –**អន្វិត** គុ. ដែលទៅតាម, ដែលហែហម, ដែលប្រកប, ដែលធ្វើត្រាប់ ។ **អន្វីត** ដូចគ្នា ។

**អន្វិឞ** ធាតុ. ប្រាថ្នា, ស្វែងរក, ដេញតាម ។ –**អន្វិឞ្ដ** គុ. ដែលស្វែងរក ។

**អន្វីក្ស** ធាតុ. ក្រឡេកមើល ។

**អន្វីក្សក** គុ. ដែលបារម្ភ ។

**អន្វីក្សា** ស្ត្រី. កិរិយារមិលមើល, កិរិយាសំឡឹង, ការបារម្ភ ។

**អន្វេឞ** បុំ. កិរិយាស្វែងរក, កិរិយាស្វែងរកម៉ឺងម៉ាត់ ។

**អន្វេឞក** គុ. អ្នករកម៉ឺងម៉ាត់ ។ –**អន្វេឞិន** គុ. **អន្វេឞ្ដ្ឫ** ការក. អ្នកស្វែងរកកិត ។

**អន្វេឞណ** បុំ., **អន្វេឞណា** ស្ត្រី. កិរិយាស្វែងរក ។

**អប** ស្ត្រី ពហុ. (អាបស៍ អបស អទ្ភិស ...) ទឹក, ព្រះអាបោ ។

_ចរ បុំ. សត្វទឹក ។ –បតិ ព្រះវរុណ ។ –អគ្និ គុ. ភ្លើងក្រោមសមុទ្រ ។ _ជ គុ. ដែលកើតក្នុងទឹក ។ បុំ. ឈូក, ព្រះព្រហ្ម ។ –ជនាភ បុំ. ព្រះវិស្ណុ ។ _ជភូ បុំ. ព្រះព្រហ្ម ។ _ជសម្ភវ បុំ. ព្រះព្រហ្ម ។ _ជិនី ស្រី. ដើមឈូក ។ _ជិនីបតិ បុំ. ព្រះអាទិត្យ ។ –ទុគ៌ គុ ដែលទៅមិនបានព្រោះទឹក ។ _ធិ បុំ. ទីតម្កល់ទឹក, សមុទ្រ ។ _ធិកន្យា ស្រ្តី. នាងលក្ស្មី ។ _ធិជីវិន៍ បុំ អ្នកនេសាទ, ប្រមង់ ។ _ធិតនយ បុំ. វត្ថុដែលត្រូវបាន ។ –អគ្និ ទាំងពីរ ។ _ពិន្ទុ បុំ. ដំណក់ទឹក ។ _ភវ ឬ ភូ បុំ. ព្រះព្រហ្ម ។ _អបាម _តរតម បុំ. នាមអ្នកសិទ្ធ ។

អប បុព្វបទ, សេចក្តីថា តិច, ឥត, ថោកថយ ។

អប មកពី អប ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ញូ - គាង

ប្រែ-រៀបរៀង

(ក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន<br>នឹងបេះខបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ<br>យូរ—អ៊ុន |

## សាមកុក ខ្សែ ៦៤

តាំងពីចូភីលើកខ្លួនជាព្រះចៅវុយអង ជំនួសចូជូជាបិតា ហែហ៊្វិទុនឈឺស្លាប់របូតទៅ ផល់ហាមកៀងនិងទៀវតាត់លបកាត់ក្បាលទៀវហ៊ុយស្លាប់នាំរត់ទៅស្រុកកាំងតាំង ។

ឯចូភីនោះ លុះបានឡើងយសជាស្ដេចសម្រេចរាជការហើយ ក៏តាំងខ្លួនជាព្រះចៅវុយអងជំនួសបិតា បើករង្វាន់បំណាច់ឲ្យខុនរាជការទាំងឡាយតាមគុណានុរូបនិងបណ្ដាស័ក្តិ ហើយឲ្យកេណ្ឌទាហានបាន ៣០ ម៉ឺន លើកចេញអំពីទីក្រុងតម្រង់ទៅស្រុកបៀវគួនក្នុងដែនខែត្រផៃកុក ដែលធ្លាប់នៅពីដើមនោះ ប្រយោជន៍នឹងក្រសាលឲ្យសប្បាយផង លុះលើកទៅដល់ស្រុកផៃកុក ក៏សំដែងយសដ៏ខ្ពង់ខ្ពស់អស្ចារ្យ ។

អស់បណ្ដាអ្នកស្រុកទាំងពួង ក៏មកប្រជុំគាល់ដោយសេចក្ដីត្រេកអរសាទរសប្បាយណាស់ ខ្លះក៏តែងគ្រឿងបណ្ណាការមកថ្វាយដោយច្រើន ក្នុងខណៈនោះ មានមនុស្សបំរើស៊ើបការនាំអាថ៌សេចក្ដីទៅក្រាបទូលព្រះ

ទៅវ៉ុយអង់ថា ហៃហ៊្វូទុនមានជម្ងឺឈឺធ្ងន់ណាស់ មើលទៅឃើញច្បាស់ថាជម្ងឺនោះ គង់នឹងស្លាប់ជាប្រាកដ វ៉ុយអង់ឮដូច្នោះក៏ស្លុតព្រះទ័យដោយសេចក្តីអាល័យពប់អាន ស្តាយហៃហ៊្វូទុនណាស់ ក៏លើកទ័ពត្រឡប់វិលមកវិញ ល្មមដល់ស្រុកនៀបកុនវេលាណា ហៃហ៊្វូទុន ក៏ធ្វើកាលកិរិយា វ៉ុយអង់ក៏តាក់តែងរៀបសំស្ការសពតាមទំលាប់ប្រពៃណី ទីនាយទាហានឯក ហើយហៃទៅបញ្ចុះទុកតាមធម្មតា ។

កាលចូកឡើងជាទីវ៉ុយអង់ជួសបិតាជាអម្ចង់តមកប្រហែល ៦ ឆ្នាំ ក្នុងខែកក្រទបទ មានហង្សហើរទៅស្រែកយំនៅត្រង់ស្រុកសេងសឹក ហើយនិងមានកកសីហ៍ ចូលមកដើរត្រេច ក្នុងស្រុកលិមទោ រួចត្រឡប់បាត់ទៅវិញ មហាជនទាំងឡាយក៏នាំយកហេតុនោះទៅទូលវ៉ុយអង់ រួចអំពីនោះ មានមករពណ៌លឿង មានសក្តានុភាពណាស់ មកសំដែងឫទ្ធីអណ្តែតនៅលើអាកាសជាអស្ចារ្យធំ មហាជនទាំងពួងក៏ក្រឡេកឃើញចូក ក៏ឃើញច្បាស់ទាំងអស់គ្នា ។

វ៉ុយអង់ឃើញហេតុទាំង ៣ ប្រការដូច្នេះ ជាអស្ចារ្យណាស់ ទើបឲ្យហៅលីតុក ខៅជី ដែលជាមន្ត្រីធំ ហើយជាចាស់ទុំជាងគេ នូវអស់នាម៉ឺនឯទៀតមកប្រជុំប្រឹក្សាហើយត្រាស់សួរថា ៖ អាភេទទាំង ៣ ប្រការនេះ ឃើញចំឡែកអស្ចារ្យនៅក្នុងស្រុកយើង តើនឹងល្អឬអាក្រក់យ៉ាងណា ៗ លីតុកនិងខៅជី ក្រាបទូលថា ៖ កើតអស្ចារ្យប្រាកដក្នុងស្រុកយើង

ដូច្នេះជាមង្គលប្រសើរណាស់ គឺទឹងឲ្យចំរើនសួស្តីមង្គលដល់ទ្រង់ទឹងឲ្យបានគង់ព្រះកិត្តិយសជាទីវុយអង់មិនតែប៉ុណ្ណោះក៏ទេ ក្នុងបច្ចុប្បន្នជាតិនេះ បុណ្យទឹងចំរើនឲ្យលឿនទីឡើងទៀត គឺទ្រង់ទឹងបានសោយរាជសម្បត្តិជាមហាក្សត្រិយ៍គ្រប់គ្រងផែនដីនេះ ទើបបណ្ដាលចៃដន្យចិត្តនៃមហាជនទាំងប្រុសស្រីឲ្យមានសេចក្ដីស្នេហាស្រឡាញ់ ព្រះបរមពោធិ-សម្ភារបារមី ចង់ឲ្យទ្រង់ឡើងជាម្ចាស់ផែនដីតទៅ ។

ខណៈនោះអស់នាម៉ឺនមុខមន្ត្រីធំតូចក៏ប្រឹក្សាយល់ព្រមគ្នាថា យើងត្រូវក្រាបទូលព្រះចៅហៀនគេ សុំឲ្យប្រគល់រាជសម្បត្តិថ្វាយមកព្រះចៅចូភី លុះប្រឹក្សាយល់ព្រម ទើបចាត់ឲ្យហ្លួហុំម អង់ឡង់ ស៊ុនលៀក កាសៀង គាត់កៀវ គាន់កុន គេងកៃ នូវអស់មន្ត្រីធំ ៗ ហើយទិងនាយទាហានប្រមាណ ៤០ នាក់ នាំគ្នាចូលទៅក្រុងហ្លួគោ ហើយក៏ចូលទៅគាល់ព្រះចៅហៀនគេ ។ ហ្លួហុំមទូលថា ៖ ចូភីជាទីវុយអង់ធំនួសបូជួនោះ មានបុណ្យសម្ភារបារមីច្រើនណាស់ មានទាំងសតិបញ្ញាជ្រៅជ្រះឆ្លាសវៃ មានព្រះទ័យអាណិតអាណាប្រជានុរាស្ត្រ ទូទាំងផែនដីរាស្ត្រទាំងប្រុសស្រី ក៏បានសេចក្ដីសុខក្សេមក្សាន្ត ។ មុខមន្ត្រីទាំងប៉ុន្មានក៏ប្រឹក្សាយល់ព្រមគ្នាទាំងនាយទាហានទិងរាស្ត្រប្រជា យើញថា វេលានេះជាឱកាសដ៏សមគួរ ដែលនឹងឧបត្ថម្ភទំនុកបំរុងផែនដី បានចំរើនតទៅ សូមព្រះអង្គទ្រង់ប្រគល់នូវរាជសម្បត្តិខត្តិយរាជឲ្យចូភីពេញ

ទីជាព្រះមហាក្សត្រិយ៍ចុះ ព្រះអង្គក៏នឹងបានគង់ជាសុខក្សេមក្សាន្តយឺនយូរតទៅ ។

ព្រះចៅហៀនគេ ទ្រង់ព្រះសណ្ដាប់សព្វគ្រប់ ក៏ឲ្យស្មុគរទ្ធត់ក្នុងព្រះទ័យស្មៀមនៅមួយស្របក់ ហើយក្រឡេកមើលមុខនាម៉ឺនទាំងពួងក៏ទ្រង់ព្រះកន្សែងសោកាត្រាស់ថា យើងនឹកគិតគាណិតទៅដល់បុពណក្សត្រិយ៍ មានព្រះចៅហាន់កោះបាជាដើម ព្រះបរមវង្សវង្សយើងពេកណាស់ អំណើះតមកក៏មានព្រះកវង្សអង្គក្សត្រិយ៍ បានសោយកជសម្បត្តិជាលំដាប់គ្នាជាយូរប្រមាណ ៤០០ - ៥០០ ឆ្នាំមកហើយ ជាទីបំផុតត្រឹមអង្គយើង ។ នេះនៅក្មេងសោចក្ដីគម្រិះប្រាជ្ញាក៏មែន តែថាបានទទួលកជសម្បត្តិផ្លាល់ពីព្រះវរកជបិតា ដោយសារសេនាបតីនាម៉ឺនសព្វមុខមន្ត្រីជំនុំយល់ព្រម យើងក៏បានអនុលោមទទួលរក្សាកជសម្បត្តិដោយសត្យានុធម៌តរៀងមកដល់សម័យនេះ យើងក៏មិនមានប្រព្រឹត្តឲ្យខុសខាតពីសណ្ដាប់ច្បាប់បុកណកជប្រវេណីឯណាឡើយ ម្ដេចហើយអស់អ្នកទាំងឡាយ មកនិយាយឲ្យយើងលើកយកកជសម្បត្តិរបស់យើងឲ្យទៅអ្នកដទៃវិញដូច្នោះ យើងពឹងទៅឃើញខុសអំពីយុត្តិធម៌ច្បាប់ សុំឲ្យអស់អ្នកក្រឡាប់វិលទៅប្រឹក្សាគ្នាម្ដងទៀតសិនចុះ ។

ហ្លួហ៊ុម ឮដូច្នោះក៏ចេញទៅ នាំយក លីតុក ខៅជី ជានាម៉ឺនចាស់ទុំចូលទៅគាល់ព្រះចៅហៀនគេហើយទូលថា ៖ ព្រះអង្គ ចូរទ្រង់ប្រឹក្សាពីគ្រោះនឹងអ្នកចាស់ទុំ ២ នាក់នេះចុះ តោះបីគួរពុំគួរប្រការម្ដេច ក៏

ល្មមទ្រង់នឹងជឿស្តាប់បាន សិតុកក៏ទូលថា តាំងពីចូកឡើងទីជាំ វុយអង ជំនួសបិតាវៀងមក ទូលបង្គំបានឃើញស្រុកទេសក៏រាបទាប សប្បាយ បណ្តារាស្ត្រទាំងឡាយក៏បានសេចក្តីសុខក្សេមក្សាន្តគ្រប់គ្នា ចំណីអាហារក៏កើតឡើងបរិបូណ៌ គ្មានខ្វះកន្ទះអ្វីសោះ មានហង្សសត្វ ដែលរូបល្អស្រស់ក៏ហើរចូលមកក្នុងស្រុក រាជសីហ៍ក៏ចូលមកដើរត្រេក សព្វទីកន្លែងខេត្រខណ្ឌព័ទ្ធសីមា ស្តេចមករដែលមានរិទ្ធិក្លា ក៏អណ្តែត ត្រសែតមកនៅលើអាកាស សំដែងរិទ្ធិភាសរុងរឿងកណ្តាលស្រុក ទេស អាភេទទាំង ៣ ប្រការនេះ ជាទីអស្ចារ្យប្លែកណាស់ ទូល បង្គំយល់ច្បាស់ថា ចូកទឹងមានបុណ្យកុសល គួរដល់នូវរាជសម្បត្តិ ជាព្រះមហាក្សត្រិយ៍តទៅ ពោធ៍ទូលថា ពេលកណ្តាលយប់ស្ងាត់ ទូលបង្គំបានឃើញផ្កាយនក្ខត្តឫក្សអនឡាស្រុក ដែលប្រចាំបុណ្យរបស់ព្រះ អង្គ មានរស្មីសៅហ្មងវិប្បរិត្តខុសអំពីធម្មតា សំដែងអាការឲ្យឃើញ ថា ព្រះអង្គនឹងអស់បុណ្យក្នុងជាន់នេះហើយ ឯផ្កាយដែលប្រចាំបុណ្យ ចូកនោះ មានដួងធំអស្ចារ្យ រស្មីភ្លឺថ្លាបរិសុទ្ធណាស់ សំដែងហេតុ ឲ្យឃើញច្បាស់ថា ចូកទឹងមានបុណ្យបារមីថ្លៃថ្លា ទាំងមនុស្សនិង ទេវតា ក៏និយមសរសើរពប់អានចូកណាស់ បានជាបណ្តាលឲ្យ ឃើញអាភេទច្បាស់ទាំង ៣ ប្រការ ជាទីប្រាកដដល់ភ្នែកអ្នកទាំងពួង ហេតុនេះ សមគួរឲ្យព្រះអង្គទ្រង់លើករាជសម្បត្តិឲ្យ ចូកគ្រប់គ្រងជា ម្ចាស់ផែនដីតទៅចុះ ។

ព្រះចៅហៀនគេត្រាស់តបថា ដែលអស់អ្នកមកនិយាយដូច្នេះ ជាការមិនសមគួរនឹងជឿទេ ព្រោះមិនបានឃើញចំពោះនឹងភ្នែកយ៉ាងណា ហើយនៅកំណត់ក្នុងចិត្តថា មិនគួរនឹងឲ្យលើករាជសម្បត្តិ ដែលជាព្រះកេរ្តិ៍របស់ព្រះបរមក្សត្រិយ៍អំពីបុរាណឲ្យទៅអ្នកដទៃសោះ អង្គឡុងទូលថា ការទាំងនេះជាប្រវេណីមានមកអំពីបុរាណ មានល្អហើយក៏គង់ត្រឡប់ទៅជាអាក្រក់ ។ មានហើយក៏គង់នឹងត្រឡប់ទៅជាល្អវិញបាន យ៉ាងដូចប្រទេសស្រុកនីមួយ ៗ ធ្លាប់គង់នៅមាំមួនបរិបូណ៌ហើយ ក៏កើតជាសឹកសង្គ្រាមជ័យ ឲ្យវិនាសខ្ទេចខ្ទីអស់ទៅ លុះខ្ទេចខ្ទីទៅហើយក៏ត្រឡប់បានចំរើនមាំមួនឡើងជាធម្មតា ឯសម្បត្តិទ្រព្យសព្វសារពើទឹកដី ដែលព្រះអង្គទ្រង់ទទួលអំពីព្រះបរមរាជវង្ស ច្រើនផែនដីមកហើយ ប្រមាណ ៤០០ ឬ ៥០០ ឆ្នាំនោះ ទូលបង្គំយល់ឃើញថា វង្សរបស់ព្រះអង្គនឹងត្រូវផុតរលត់ក្នុងសម័យនេះជាពិត ហេតុនេះសុំឲ្យព្រះអង្គពិនិត្យលះបង់រាជសម្បត្តិនោះប្រគល់ឲ្យប៉ុកប៉ុះ បើព្រះអង្គនៅតែរឹងទទឹងដូច្នោះ មុខជានឹងមានសេចក្ដីភ័យអន្តរាយមកដល់ព្រះអង្គពុំខាន ។

ព្រះចៅហៀនគេ បានទ្រង់ព្រះសណ្ដាប់សព្វគ្រប់ប្រការ ក៏អាក់អួលព្រះទ័យទ្រង់ព្រះកន្សែងពិលាប ហើយក៏យាងចូលទៅក្នុងក្រឡាព្រះបន្ទំ អស់មន្ត្រីតូចធំក៏នាំគ្នាសើចទ្រហ៊ឹងអឺងកង រួចនាំគ្នាដើរចេញត្រសងមកព្រះរាជវាំង លុះព្រឹកឡើង អស់នាម៉ឺនទាំងនោះ ក៏នាំគ្នាចូលទៅគាល់

នៅទីព្រះរាជវាំងម្ដងទៀត ហើយប្រើពួកខន្ទីឲ្យចូលទៅ អញ្ជើញស្ដេចឲ្យយាងចេញមក ព្រះចៅហៀនតក៏ទ្រង់នឹងខ្លាចមិនអាចចេញមកសោះ នោះនាងចូហៅដែលជាប្អូនចូក៏ ជាទីព្រះអគ្គមហេសីមានសេចក្ដីធ្ងល់ក៏ក្រាបទូលសួរថា អស់មុខមន្ត្រីឲ្យបំរើចូលមកអញ្ជើញស្ដេចចេញទៅក្រៅ ហេតុអ្វីព្រះអង្គមិនទ្រង់ចេញទៅដូច្នោះ ព្រះចៅហៀនតក៏តែតែទ្រង់ព្រះកន្សែងសោក ហើយមានព្រះរាជឱង្ការត្រាស់ប្រាប់ព្រះមហេសីតាមសេចក្ដីដែលបង្កើតឡើងថា បងប្រុសរបស់ប្អូនឯងឲ្យបំរើមកក៏ហែងបង បងនឹងដណ្ដើមយករាជសម្បត្តិ បានជាពួកនាម៉ឺនទាំងនេះគិតគប់គ្នានឹងកំចាត់យើង ឲ្យយើងលើកស្វេតច្ឆត្រប្រគល់ឲ្យចូក៏ដោយបង្ខំ ហេតុនេះបានជាបងនៅសម្ងំមិនចេញទៅ ។

ព្រះនាងចូហៅបានឮដូច្នោះ ក៏ខឹងខ្លាំងណាស់ថា បងខ្ញុំម្ចាស់ហេតុម្ដេចបានជាមកគិតក្បត់ដូច្នោះ ព្រះនាងថាមិនទាន់ផុតពីមាត់ ស្រាប់តែចូហាង និង ចូហ៊ាំ សៀតគ្រប់ចូលទៅទូលអញ្ជើញស្ដេចឲ្យចេញទៅ ព្រះនាងចូហៅក៏ស្រែកដេរថា អាពួកក្បត់ទាំងអស់នេះវាមានសក្ដិយសពីព្រោះនរណា ឥឡូវហេតុម្ដេចវានាំគ្នាមកធ្វើជាសត្រូវក្បត់គិតប្រទុស្ត-រ៉ាយនឹងម្ចាស់ផែនដីវិញ កាលគ្រាបិតាអញនៅរស់ក៏បានធ្វើសេចក្ដីគាប់ប្រសើរ ទុកឈ្មោះគ្មាននរណាស្មើបាន ហើយបានរៀបចំស្រុកទេសទាំងប៉ុន្មានឲ្យរាបទាបស្រួលបួលទាំងអស់ បណ្ដាក្សត្រក៏ស្មគ្រស្មោះនិយម

កប់សានស្រឡាញ់ពេញទាំងផែនដី អស់ទាំងនាម៉ឺនមុខមន្ត្រីធំតូចក៏កោតក្រែងអំណាចខ្លាចគ្រប់គ្នា ស្ដេចបិតាអញមិនមានចិត្តគិតពុះពារទទឹងដណ្ដើមយករាជសម្បត្តិម្ចាស់ផែនដី ឥឡូវហេតុអ្វីបងអញដែលបានស្ដីការជំនួសបិតាប៉ុណ្ណោះ មកបេះប្រែចិត្តគិតប្រទុស្តរ៉ាយទទឹងដណ្ដើមយករាជសម្បត្តិដូច្នេះ មនុស្សយ៉ាងនេះមិនមានចំរើនប៉ុន្មាន ទេពតាសព្វហាន់ក៏មិនជួយឲ្យពរសព្ទសាធុការទេ ថាហើយក៏ទូញយំដំរីត្រឡប់យាត្រាចូលទៅក្នុងវិញ អស់បណ្ដាស្រីស្នំក្រមការ ដែលនៅក្នុងវាំងនោះមិញ ក៏សឹងជាទុក្ខទោមនេញទូញយំទាំងអស់គ្នាទ្រហឹងអឹងកង ។

ឯចូហ៊ីវនិងចូហាង ក៏បង្ខំព្រះចៅហៀនតេ ស្ដេចចេញទៅទីព្រះរាជរោងរម្យជួបជុំនាម៉ឺនមុខមន្ត្រីទាំងពួង ព្រះចៅហៀនតេទទឹងពុំបាន ក៏ដោះព្រះសុក័តយ៉ាងខ្ពស់មានរូបមករដែលធ្លាប់ទ្រង់ចេញប្រជុំមុខមន្ត្រីនោះចេញពីព្រះអង្គ ហើយក៏ទ្រង់ធ្វងព្រះអង្គយ៉ាងថោកទាបចេញទៅ ។ ហ៊ួហ៊ឹមទូលថា ព្រះអង្គទឹងព្រមប្រគល់រាជសម្បត្តិឲ្យចូភីតាមសេចក្ដីជំនុំ នាម៉ឺនមុខមន្ត្រីក្រាបទូលថ្វាយទេ បើព្រះអង្គទ្រង់ព្រមប្រគល់ហើយក៏ជាសិរីសុវត្ថិមង្គលប្រពៃមិនមានភ័យអន្តរាយឡើយ ព្រះចៅហៀនតេទ្រង់ព្រះសណ្ដាប់ហើយក៏ទ្រង់ព្រះកន្សែងសោកាត្រាស់ថា នាម៉ឺនពីបុរាណ ក៏បានយសស័ក្តិនិងប្រាក់បៀវត្សរ៍ដែលព្រះមហាក្សត្រិយ៍អម្បូរព្រះរាជវង្សរបស់យើង ទ្រង់ប្រទានប្រោសបានតកូនចៅរៀងមកដល់វេលានេះ ហេតុអ្វីឡើយក៏មិន

មានត្រិះរិះគិតគតញ្ញូដល់ព្រះតេជះព្រះគុណខ្លះសោះ នាំគ្នាមកប្រទុស្តរ៉ាយ
ដូច្នេះ ៗ

ហ្លួហ៊ុមទូលថា បើព្រះអង្គមិនធ្វើតាមពាក្យមុខមន្ត្រីប្រឹក្សា ក្នុង
ថ្ងៃនេះឬថ្ងៃស្អែក នឹងមានអន្តរាយប្លែក ៗ មកដល់ព្រះអង្គមិនខានឡើយ
ពាក្យនេះទូលបង្គំនឹងបានក្រាបទូលព្រះអង្គដោយទុច្ចរិតមុសាក៏ទេ ព្រះចៅ
ហៀនគេត្រាស់ថា បើអស់លោកអ្នកទាំងឡាយកល់គ្នាមិនបានគិតអាក្រក់
នឹងយើងទេ នរណានឹងមកប្រទុស្តរ៉ាយនឹងយើងសោត ៗ ហ្លួហ៊ុមស្រែក
គំហកដោយសំឡេងខ្លាំងថា បណ្តាក្រស្ត្រទាំងអស់គ្នាឃើញថា ព្រះ
អង្គលង់ខ្លៅមិនស្ងួវមានគម្រិះប្រាជ្ញាចេះរក្សាផែនដី ទិងមិនចេះដឹងសេចក្តី
ដែលនឹងគ្រប់គ្រងរាជសម្បត្តិ បានជាកើតចោរដើរស្កាត់ខ្ទាត់លួចប្លន់គ្រប់
ដំបន់នានា ក្រស្ត្រប្រជាក៏កើតក្តៅក្រហាយគ្រប់ស្រុក កើតកន្ទួល
កលិយុគខ្ទេចខ្ទីវិនាសច្រើនណាស់ គ្រានេះ ពួកជាទីពឹងពំនាក់បាន
ជួយទុក្ខធុរៈអាណាប្រជានុក្រស្ត្រតាសករទាំងឡាយ ហើយចំនួលខ្វាយ
ជួយទំនុកបំរុងព្រះអង្គឲ្យគង់ជាសុខមកយូរហើយ មិនមែននឹងក្បួនគំចាត់
ព្រះអង្គឡើយ គួរហើយព្រះអង្គនឹងដឹងគុណូបការ ពួកដែលព្រះអង្គ
នៅរឹងមិនព្រមសាមគ្គីប្រគល់ផែនដីឲ្យដូច្នេះ នឹងចង់ឲ្យបណ្តាក្រស្ត្របះ
បោរចលាចលឲ្យកើតអំពល់ដល់ព្រះអង្គឬ? ៗ ព្រះចៅហៀនគេឮដូច្នោះ
ក៏ភ័យស្លាំងកាំង ទ្រង់ក្រោកយាងចូលទៅក្នុងវិញ ៗ

អងឡូងក៏ញាក់មុខឲ្យហ្លួហ៊ុម ៗ ស្ទុះក្រោកដើរបន្ទាន់តាមទៅចាប់

ហើយក៏ចាប់ជាប់ទូវជាយព្រះសុភ័គព្រះចៅហៀនគេទុក ហើយធ្វើទឹកមុខ
ជាខឹងខ្លាំងណាស់ថា ប្រឹក្សាការផែនដីមិនទាន់បានសេចក្តីយ៉ាងម្តេច
ស្តេចមិនត្រូវក្រោកទៅណាទេ ទឹងព្រមប្រគល់រាជសម្បត្តិ ឬមិនព្រម
ជាមកចុះ? ព្រះចៅហៀនគេភ័យណាស់ទឹងត្រាស់តបក៏មិនរួច ខ្លាច
ញ័រអស់ព្រះអង្គ ៗ ចូហានទឹងចូហ៊ីវក៏ហូតគ្រីបត្រីវលើកឡើងហើយ
ស្រែកថា ត្រាព្រះរលញ្ចាករសម្រាប់រាជ្យនៅឯណា ចូបឹតឆ្លើយថា
ត្រាព្រះរលញ្ចករខ្ញុំរក្សាទុកឯង ចូហានថា បើត្រាសម្រាប់រាជ្យនៅលើ
អ្នកឯង ចូរទៅយកមកឲ្យយើងឲ្យឆាប់ ៗ ចូបឹតថា ត្រាសម្រាប់រាជ្យ
នេះជារបស់ព្រះមហាក្សត្រិយ៍ ព្រះអង្គមិនទាន់មានព្រះតម្រាស់ថាឲ្យ ១
ឯងទេ ៗ ចូហានខឹងខ្លាំងណាស់ ក៏បង្គាប់ទាហានឲ្យចាប់ចូបឹតនាំយក
ទៅសម្លាប់ ចូបឹតឥតតក់ស្លុតខ្នើត់ខ្លាចនឹងសេចក្តីស្លាប់សោះ បេះតែ
ស្រែកជេរចូហានទាល់តែគេសម្លាប់ ៗ

ព្រះចៅហៀនគេទតឃើញដូច្នោះ ក៏តក់ស្លុតញ័រអស់ព្រះអង្គមិន
បាត់ឡើយ ហើយក្រឡេកទៅឃើញទាហានប្រមាណ ៥០០ នាក់
គ្រឿងសស្ត្រាវុធគ្រប់ដៃ សុទ្ធតែពួកចូភីទាំងអស់ មិនឃើញមាន
ពួកព្រះអង្គសោះឡើយ គិតហើយក៏បញ្ចេញព្រះសូរសៀងថា យើង
ព្រមប្រគល់រាជសម្បត្តិឲ្យហើយ សុំតែជីវិតយើងទុកចុះ កាសៀងថា
បើព្រះអង្គព្រមប្រគល់ឲ្យហើយ ទូលបង្គំឃើញថាចូភីទឹងថ្វាយជីវិត

ទុកតទៅ មិនបានធ្វើអន្តរាយដល់ព្រះអង្គទេ ត្រូវព្រះអង្គធ្វើព្រះចុតហ្វាយប្រគល់រាជសម្បត្តិឲ្យចូកីចុះ ។

ព្រះចៅហៀនគេបានឮដូច្នោះ ក៏ត្រាស់បង្គាប់តាន់កុយឲ្យតែងព្រះចុតហ្វាយប្រគល់រាជសម្បត្តិសេចក្តីថា យើងបានសោយរាជសម្បត្តិគ្រប់គ្រងផែនដីរក្សាសេចក្តីសុខអស់អាណាប្រជានុកស្ត្រមក ជាយូរយារគណ. នាកប់ជាប់ ៣២ ឆ្នាំហើយ ឥឡូវផ្កាយប្រចាំព្រះអង្គយើងសៅហ្មងសន្តានចិត្តនាម៉ឺនមុខមន្ត្រីផងនឹងអស់អាណាប្រជានុកស្ត្រទាំងឡាយ ក៏ឃើញថា រូបកាយនៃយើងមិនសមគួរនៅគ្រងរាជសម្បត្តិឡើយ ហើយឃើញថាផ្កាយប្រចាំខ្លួនចូកីជាទីរុងរឿងស្វាងត្រចះ បុណ្យតេជះរបស់គេក៏គួរដល់នូវរាជសម្បត្តិពេញបរិបូណ៌ នាម៉ឺនទិងស្រុកក្នុងនគរក៏សាទរស្រឡាញ់រាប់អាន ឲ្យចូកីបានឋានពីកតពគ្រប់គ្រងរាជសម្បត្តិ ជាព្រះមហាក្សត្រាធិរាជ យើងក៏ព្រមប្រគល់អំណាចរាជសម្បត្តិនេះឲ្យចូកីតាមទីប្រាថ្នាមហាជនចុះ លុះធ្វើរួចក៏ប្រគល់ឲ្យហ្លួហឹមនឹងអស់នាម៉ឺនទាំងពួងនាំយកទៅជាមួយនឹងត្រាសម្រាប់រាជ្យ ដើម្បីប្រគល់ឲ្យចូកី ។

ឯចូកីនោះ លុះបានឃើញព្រះចុតហ្វាយនិងត្រាព្រះរាជលញ្ឆករសម្រាប់រាជ្យ ក៏មានចិត្តត្រេកអរសោទរពេកប្រមាណ គិតចង់បានទទួលយកក្នុងខណៈនោះ តែថាគិតមោះមាយាធ្វើជារេកសៀមទៅ ៗ សុ-មាអ៊ី ក៏ទូលថាស់ឃាត់ថា ទ្រង់កុំអាលទទួលយកឡើយ រឿងនេះ

ហើយត្រូវតែទ្រង់ធ្វើរឿងកាវថ្វាយត្រានេះទៅវិញសិនទើបគួរសម ដើម្បីនឹងបំបាត់នូវពាក្យគេហានិន្ទាផង ចូគីយល់ឃើញត្រូវចំនង់ ទើបចាត់ប្រើអង់ឡង់ឲ្យនែងចុកហ្វាយ ១ ច្បាប់កប់រៀបសេចក្តីថា ទូលបង្គំចូគីទីវ៉ុយអង់សូមថ្វាយត្រាព្រះវលញ្ញករសម្រាប់រាជ្យមកទ្រង់វិញ ព្រោះទូលបង្គំជាអ្នកមានសតិបញ្ញាតិចណាស់ នឹងហើសទទួលយករាជសម្បត្តិតាមសព្វព្រះទ័យនៃម្តងពុំបាន ការនេះគួរតែទ្រង់គិតគានពីគ្រោះពិចារណាជ្រើសរើសរកអ្នកល្អ ដែលមានតម្រិះប្រាជ្ញាជាជាងទូលបង្គំ ដែលគួរនឹងគ្រប់គ្រងមហាជនក្នុងផែនដីនេះបាន សូមឲ្យទ្រង់ព្រះរាជទានសម្បត្តិទៅអ្នកនោះទើបគួរ ហើយចាត់ប្រើអង់ឡង់និងមន្ត្រីទាំងពួង ឲ្យអញ្ជើញត្រាសម្រាប់រាជ្យនោះទៅថ្វាយព្រះចៅហៀនគេជាមួយនឹងចុកហ្វាយ ។

ព្រះចៅហៀនគេ បានឃើញសំបុត្រនឹងត្រា ក៏ឲ្យព្រួយព្រះចិន្តាគិតម្តងទៀត ទើបប្រឹក្សានឹងឋណ្តាំរាជការទាំងពួងថា ហេតុអ្វីបានជាចូគីបង្វិលត្រាមកឲ្យយើងវិញ ហ្ស៊ីហ៊ុមទូលថា កាលព្រះអង្គតាំង ទ្រង់ជាទីវ៉ុយ-អង់ ចូចូក៏មិនព្រមទទួលដល់ ៣ ដង ឯក្រោយទើបចូចូព្រមទទួល ត្រានេះត្រូវតែព្រះអង្គតាំងទៅទៀតទើបចូគីព្រមទទួល ព្រះចៅហៀនគេ នឹកគ្នាន់ក្នុងព្រះទ័យអាល័យរាជសម្បត្តិណាស់ តែថាត្រូវការដោយសេចក្តីខ្លាចគេ ទើបបង្គាប់ឲ្យហាងកែតែងព្រះរាជតម្រាស់សេចក្តីថា ចូគីនេះសមគួរណាស់ ហើយដែលនឹងត្រូវទទួលរាជសម្បត្តិជំនួសយើងបាន ។

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( គ )

**បំណងដើង :** *" សាស្ត្រា កុមារភណា "* (១)

**អ្នកនិពន្ធ :** *សុវណ្ណបញ្ញា (ប្រហែលនាមធាយា?) ។*

**កាលបរិច្ឆេទ :** *ថ្ងៃព្រហស្បតិ៍ ២ កើត ខែបុស្ស ឆ្នាំថោះសប្តស័ក*

*ព.ស. .. ? ។*

**របៀបនិពន្ធ :** *ពាក្យកាព្យ បទកាកគតិ – ពំនោល – ព្រហ្មគីត –*

*មណ្ឌូកគតិ និង បទឥន្ទ្រវិជិត ។*

**ប្រភពរឿង :** *រឿងព្រេង ។*

**លក្ខណៈឯកសារ :** *សាស្ត្រាស្លឹករឹត មាន ១៣ ខ្សែបច់ ។*

---

១ – សាស្ត្រាកុមារភណាគនេះ កវីតាំងចិត្ត រៀបរៀងជារឿងជាតក ១ ដូចសេចក្តីផ្តើមរបស់កវី ប៉ុន្តែខ្វះអត្ថបទបញ្ចប់ ដោយការសជាតិ ។ ឯកសារមានចំនួនដល់ ១៣ ខ្សែ តែមិនចប់ ត្រូវកវីបញ្ចប់ដោយបង្ខំ ទើបអត្ថបទបញ្ចប់របស់កវី មិនសូវសមហេតុសមផលទេ? ។

អត្ថបទក្នុងផ្ទៃរឿង គ្មានលក្ខណៈដូចជារឿងជាតកទេ បែរជាមានអត្ថន័យទាក់ទង និងទំនៀមទម្លាប់ ពិធីបុណ្យទានផ្សេងៗ និងជំនឿផ្សេងៗរបស់ខ្មែរ កាលពីសម័យព្រេងនាយ ។ គួរកត់សំគាល់ថា សេចក្តីរៀបរៀងរបស់កវីនេះ មិនសូវរៀបរាយទេ ទាំងពាក្យកាព្យសោត ទៀត ក៏មិនសូវល្អ ទាំងមានតក់ច្រើនផង ។

ខ្សែទី ១ មានសន្ទឹក ៣៦, ទី ២ មានសន្ទឹក ៣៦,
ទី ៣ មានសន្ទឹក ២៩, ទី ៤ មានសន្ទឹក ៣១,
ទី ៥ មានសន្ទឹក ៣៣, ទី ៦ មានសន្ទឹក ៣១,
ទី ៧ មានសន្ទឹក ៣១, ទី ៨ មានសន្ទឹក ៣១,
ទី ៩ មានសន្ទឹក ៣៥, ទី ១០ មានសន្ទឹក ៣៨,
ទី ១១ មានសន្ទឹក ៣៥, ទី ១២ មានសន្ទឹក ២៤,
ទី ១៣ មានសន្ទឹក ២២ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានច្បាប់ដើមមកពីវត្តសត្បូរ ចុះលេខសាស្ត្រា ១៣៩៣ ។

**អត្ថបទដើម:** នេះគឺបទព្រហ្មគីត ខ្ញុំលើកហត្ថលុតជង្គង់ បង្គំឆ្ពោះតម្រង់ ទៅព្រះអង្គត្រាស់វិញ្ញាណ ។ ព្រះស្រីកែវរត្នត្រៃ បវរថ្លៃ ព្រះកម្មដ្ឋាន ព្រះវិបស្សនាមាន ព្រះអភិធម្មនាំរូបា ។ ព្រះនពលោកុត្តរ ធម៌បវរប្រាំបួនណា ព្រះត្រៃលក្ខណញាណជា នូវព្រះត្រៃសរណគមន៍ ។ ...

អហំនាមនៃ លោកស្រដីមកនេះជា នាមសុវណ្ណបញ្ញា ចិត្តបច្ចាទិករិះរេ ។ ឆ្នាំជោះសប្តស័ក នោះទៀងជាក់ខែបុស្ស ថ្ងៃព្រហស្បតិ៍ឯងឯង ពីរកើតខែនេះឯងហោង ។

អត្ថបទបញ្ចប់: បើលោកណាប្រាជ្ញផង មើលហើយហោងគុំទិន្នា

ជួយតម្រង់ឲ្យជា ត្រូវពណ៌នាឡើងបរិយាយ ។

ទិតានរនេះទៀតទេ កាព្យបន្ទំកអតិប្រាយ

បរិបូណ៌ចប់បរិយាយ អស់អម្បាលណោះហើយនៃ ។

ទិតានតាមបរិយាយ រឿងនិយាយកយសំដី

សូមចប់ណោះខ្ញី អស់មេុះនៃបរិបូណ៌ហោង ។

X X X

បំណងជើង : " សាស្ត្រា ចន្ទឃាត(១) "

អ្នកនិពន្ធ : មាន ៣ រូប គឺចៅពញាកជាកត្ត៍, ចៅពញាដំទិត-ក្សត្រ៍ និង ចៅពញាស្រីអញ្ជិត ។

កាលបរិច្ឆេទ : ផ្តើមនិពន្ធនៅថ្ងៃព្រហស្បតិ៍ ៨ កើតខែជេស្ឋ ឆ្នាំមមី ព.ស. ២៤០១ (គ.ស. ១៨៥៨) ។

---

១ ពាក្យថា "ចន្ទឃាធ" ឬ "ចន្ទឃាតក៍" តាមរូបស័ព្ទ មានន័យមិនស្របតាមដំណើររឿងនេះទេ ព្រោះឈ្មោះតួអង្គសំខាន់ ដែលជាតួឯកក្នុងផ្ទៃរឿង មានតាមថ្លៃប្លេះ ព្រោះតួអង្គនេះកើតលើថ្ងៃដែលមានរាហូចាប់ចន្ទដែលហៅថា "ចន្ទ្រគ្រាះ" ។ ថ្លៃប្លេះ តួអង្គនេះគួរសរសេរជា "ចន្ទ្រគ្រាះ" (សំ.) ឬ "ចន្ទគាហៈ" (បា) ថ្លៃប្លេះវិញ ទើបស្របតាមកំណើតរបស់តួអង្គនេះ។

តួអង្គ ១ ទៀត ដែលត្រូវជាបងប្អូនជាតួអង្គសំខាន់ទីពីរ មានតាមថា "សូរ្យឃាត" ក៏គួរសរសេរថា "សូរ្យគ្រាះ" ថ្លៃប្លេះវិញដែរ ទើបស្របតាមប្រវត្តិកំណើតរបស់ខ្លួន ព្រោះតួអង្គកើតក្នុងថ្ងៃដែលមានសូរ្យគ្រាះ (រាហូចាប់ព្រះអាទិត្យ) ឯច្បាប់បាលីដើម មានអក្ខរាវិរុទ្ធថ្លៃម្តេច ខ្ញុំមិនទាន់បានពិនិត្យប្រៀបធៀបមើលព្រោះគ្មានឯកសារជាភាសាបាលីនៅជិតដែរ ។ អ្នកចៅ

របៀបនិពន្ធ : ពាក្យកាព្យ (បទភាគគតិ -ពំនោល -ព្រហ្មគីត- កុដ្ឋលីលា ។

ប្រភពរឿង : មហាសិបជាតក៍ ឬ បញ្ញាសជាតក ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១០ វែ្យចប់ជុំជាតក៍ ។ វែ្យទី ១ មានសន្លឹក៣៨, ទី ២ មានសន្លឹក ៤៥, ទី ៣ មានសន្លឹក ៣៤,

---

ពញាជំនិតក្សត្រី បានចាប់ផ្តើមនិពន្ធអត្ថបទកំណាព្យនេះនៅថ្ងៃ ៥ ៗ ៧ ឆ្នាំមមី ព.ស. ២៤០១ បាននិពន្ធចប់ក្នុងថ្ងៃ ៤ ៗ ៩ ក្នុងឆ្នាំមមីដដែល អស់ថិរវេលាត្រឹម ៧០ ថ្ងៃ (២ខែ ១០ ថ្ងៃ) ។

ឯកសារនេះ មានចំនួនសន្លឹកសាស្ត្រាដល់ ៤៥៩ សន្លឹក គប្បីចាត់ទុកជាមហាកំណាព្យយ៉ាងវែងមួយ ហើយកវីបាននិពន្ធអស់ថិរវេលាដ៏ខ្លីជាងពីរខែប៉ុណ្ណោះ ក៏បានចប់គ្រប់ ហើយជើងកាព្យសោតទៀត ក៏មិនសូវមានគក់ទេ ដែលមានគក់ខ្លះ ដោយសារភ្លាំងភ្លាត់នៅពេលចារចម្លងតៗគ្នាមក ។

បើទុកជាកវីបានបញ្ជាក់ថា ខ្លួនបានអញ្ជើញកវីពីររូបទៀតឲ្យជួយតែងផងក៏ដោយ ក៏នៅតែគួរស្ងើចសរសើរដល់ស្នាដៃតែងកំណាព្យយ៉ាងវែងនេះដែរ ។

ឯកសារនេះ ពិតមែនតែជារឿងជាតក តែអត្ថន័យ នៃរឿងទូទៅ លេចចេញមកអំពីឥទ្ធិពលនៃគោលនិយមផ្សេងៗលាយចម្រុះគ្នា ។

តួអង្គសំខាន់ ដែលកវីបានទុកដាក់ជាតួអង្គពោធិសត្វនោះ បានបំពេញសកម្មភាពផ្សេងៗស្របតាមលក្ខណៈមនុស្សនិយម ដូចជារក្សាការយុត្តិធម៌ គោរពប្រពៃណី កាន់ទំនៀមទម្លាប់ជាអាទិ ។ តួឯកក្នុងផ្ទៃរឿង បានបំពេញសកម្មភាព បង្ក្រាបសភាវៈអាក្រក់ផ្សេងៗ ដូចជាព្រះរាមដែរ តែមិនឃោរឃៅទេ គឺមានលក្ខណៈទន់ភ្លន់ស្របតាមគតិយុត្តិធម៌ច្រើន ជាពិសេសស្របតាមគតិបណ្ឌិត មិនលុះដោយលោភៈ ទោសៈ ឬព្រេវព្រោនឥតពិចារណាទេ ។

នៅទីបំផុត កវីបានបញ្ជាក់អំពីឥទ្ធិពលនៃកម្មផល នៃតួអង្គផ្សេង ៗ កាលអំពីអតីតជាតិដែលតួអង្គនីមួយៗត្រូវទទួលផលវិបាកជាចាំបាច់ ដូចមានរឿងបញ្ជាក់ក្នុងផ្ទៃរឿងស្រាប់ ។

ទី ៤ មានសទ្ទឹក ៣៦, ទី ៥ មានសទ្ទឹក ៤៣, ទី ៦ មានសទ្ទឹក ៤៦, ទី ៧ មានសទ្ទឹក ៤០, ទី ៨ មានសទ្ទឹក ៥៨, ទី ៩ មានសទ្ទឹក ៥៦, ទី ១០ មានសទ្ទឹក ៤៩ ។ បូករួមទាំងអស់ត្រូវជា ៤៥៥ សទ្ទឹកស្ទឹកកែ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានច្បាប់អំពីវត្តសំរោង ស្រុកកៀនស្វាយ ខេត្តកណ្ដាល យកមកចារចម្លងរក្សាទុកកាលពី គ.ស. ១៩៤៤ ចុះលេខសាស្ត្រា ។

អត្ថបទដើម កាកបទា អតិទុក្ខេក បឋមបទំ មមបញ្ញោ អកោសលំ
ធិរ៉មាមំ គរហិតា ។ មយ៉ាវន្ទេ មសម្ពុទ្ធេ សិរសាសត
ទសង្គុលិ បតិដ្ឋិតា អវបាទា លោកនាថោ ៖

ម៉យំដើមបទ យើងខ្ញុំលំអុត ទុនអង្គអភី ផ្គួបផ្គុំតាំង
បញ្ចង្គប្រតី ក្រាបក្រោមបាទវី- សេសសុទ្ធសាស្ដា ។ ព្រះអង្គ
គ្រូគ្រប់ ត្រាណាត្រើយត្រៃភព ឯកអង្គនាថា ប្រោសប្រាណ
ប្រែប្រាស លាកលះលេងលា ទុកចៀសពោលអា- បាយ
បាបបង់ទៅ ។ . . . ។ល។

អត្ថបទបញ្ចប់ ចន្ទឃាដជា- តកនិដ្ឋិតា និទានព្រះបាទ ចន្ទឃាដថ្ងៃថ្វា
កន្ធហាសិបជាតក៍ នៅក្នុងនិបាត ចែងចប់សេចក្ដី ។ និទាន
កាព្យ នេះនាមចៅពញា ដំនិតក្សត្រ លើកជាល្បើកថ្វាយ

បរិយាយសេចក្តី ដោយបទបាលី ជុំជាតកសព្វគ្រប់ ។ ជាតកសេចក្តី នេះខ្ញុំតាំងបី តែងតាំងថ្ងៃយប់ ដោយប្រាជ្ញាខ្មៅ ពុំសូវប្រសប់ តែងតៅតាំងថប់ ជួបចប់និទាន ។ ថ្ងៃពុធប្រាំបី កើតស្រាពណ៍មាសី ឆ្នាំមមីបាន សកពជសាសនា ព្រះអនាវ-រញ្ញាណ ឯខែនោះបាន ចតុមាសា ។ ថ្ងៃបានកំណត់ ប្រាំពីរថ្ងៃគត់ ឯឆ្នាំគណនា ពីរពាន់បួនរយ និងមួយវស្សា សង្ខេបគាថា សូរេចម្ល៉េះហោង ។

×××

ចំណងជើង : " សាស្ត្រា សុបិនតូច "

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ ( បទកាកគតិ និង បទពំនោល ) ។

ប្រភពរឿង : រឿងព្រេងខ្មែរ ?

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ខ្សែមាន ១៨ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តខ្វង់ ខេត្តកំពង់ចាម ចុះលេខសាស្ត្រា ៦៦៧ ។

សាស្ត្រាប្រភេទនេះ មានច្រើននៅតាមវត្តទាំងឡាយ ។ ព្រោះ ..

កាលជំនាន់ដើម គេនិយមឲ្យក្មេង ៗ នៅវត្តហាត់រៀនអាន សាស្ត្រានេះ ជាដំបូងជាមួយសាស្ត្រាច្បាប់ផ្សេង ៗ ។

អត្ថបទផ្ដើម: នេះបទកាកគតិ ។ ប្រណម្យជូលី ដាក់លើសិរសី ក្រាបក្រោមបាទា ព្រះបាទសម្ដេច សារពេជ្ញសាស្តា ថ្វាយវរវន្ទា នៃព្រះគុណនាថ ។ ព្រះអង្គត្រាស់ត្រេច សាងសម្ភារស្រេច ផ្ដាច់វត្តសង្សារ លើសលែងត្រៃភព សាយសព្វពិស្តារ ស្ដេចផ្ចាញ់ក្រុងមារ រួចដល់និព្វាន . . . ។ល។ . . .

អត្ថបទបញ្ចប់ : សាធុសម្ចាយ ចូរស្ដាប់អភិប្រាយ ជាបរិយោសាន រួមសេអាថ៌ធម៌ ជាច្បាប់សព្វប្រាណ ទុកតែងទូន្មាន អាត្មាសព្វថ្ងៃ ។ អស់ភិក្ខុសាមណេរ ចូរចាំដំណែល នេះឯងប្រពៃ បានបួសជាសង្ឃ ទ្រង់ដោយធម៌ថ្លៃ បានបរិបូណ៌ក្រៃ សម្បត្តិនិព្វាន ។ គួរតែសទ្ធា គួរតែឧស្សាហ៍ សន្សំឲ្យបាន គួរតែសូត្ររៀន ធម៌ជាប្រធាន នាំខ្លួនឲ្យបាន និព្វាននាយហោង ។

សុបិនជាតក ព្រះអ្នកថ្លែងទុក ( ជាបណ្ដាំផង ) គួរចាំគួរចាប់ គួរស្ដាប់គួររង ធម៌នេះឯងហោង បរិបូណ៌ថែងចប់ ។

បំណងជើង : « សាស្ត្រាច្បាប់ស្រីធំ »

អ្នកនិពន្ធ : គេមិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ ( បទកុជ្ឈលីលា )

ប្រភពរឿង : សីលធម៌ និង ប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ផ្ចុំ មាន ៨ សន្លឹក ។

ឯកសារនេះ បានមកពីវត្តខ្ចង់ ខេត្តកំពង់ចាម លេខសាស្ត្រា ៦៦៧ ។ សាស្ត្រាប្រភេទនេះ មានផ្សាយទូទៅ នៅតាមវត្តទាំងឡាយ ។

អត្ថបទដើម: នេះបទកំណត់ចង់ជា កុជ្ឈលីលា ចង់ជាច្បាប់ស្រី ។ កាលនាងអរុន្ធតី ចរចាកតាមប្ដី បណ្ដកយក្សា ។ នាងវិមលា ជាព្រះមាតា បើកបន្ទូលថា ហៃកូនពិសី ។ នាងនឹងត្រេចត្រង់តាមប្ដី ចេញចាកអំពី ពិភពនាគនេះ ។ . . .

. . . . . ។ល។ . . . . .

អត្ថបទបញ្ចប់ : ច្បាប់នេះឧត្ដមថ្លៃថ្លា បើស្រីឯណា បានរៀនបានស្ដាប់ . . . . ( បាត់ )

ហៅមហាកំព្ធក្រៃកន្ទង់ ជាលាភណាស់ហោង បានស្ដាប់ប្រពៃ ។ . . . ( បាត់ )

ហើយចូរចាំចង់គ្រប់គ្នា ស្ដាប់ច្បាប់នេះណា ប្រសើរពេកក្រៃ ។
ចូរចាំកុំភ្លេចឡើយនៃ ចរចាអស់ឮ ថែងចប់សេចក្ដី ។ ច្បាប់
នេះឧត្ដមប្រពៃ ជាច្បាប់អស់ស្រី បរិបូណ៌ចប់ហោង (១) ។

×××

បំណងជើង : « សាស្ត្រា ក្មួនចៅពាក្យចាស់(២)»

អ្នកនិពន្ធ : រកមិនបានឃើញ

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ ( បទកាកគតិ និងព្រហ្មគីត ) ។

ប្រភពរឿង : ច្បាប់សីលធម៌និងប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ផ្លូវ មាន ៧ សន្លឹកកន្ទុះ ។

ឯកសារនេះ បានមកពីវត្តខ្ទង់ ខេត្តកំពង់ចាម លេខសាស្ត្រា ៣៦៧ ។

---

១– ច្បាប់នេះ មានវិបត្តិ ជើងកាព្យ និងរំលងឃ្លាល្បះច្រើនអន្លើ ដោយការចារ បម្លងត ៗ គ្នា ។

២– ច្បាប់នេះ នៅអត្ថបទខាងដើម ប្រើបទកាកគតិ រៀបរាប់សរសើរគុណម្ដាយ និងលក្ខណៈទារកដែលមកចាប់កំណើតក្នុងផ្ទៃម្ដាយ ។ ខាងចុងប្រើបទព្រហ្មគីត គឺជាច្បាប់ពាក្យចាស់តាមធម្មតា ដូចមានពាក្យផ្ដើមថា : បទព្រហ្មគីត ។

ពាក្យចាស់ពាក្យពីព្រេង ទោសខ្លួនឯងមើលមិនយល់ ទោសគេតូចសោតសល់ រមិលយល់ប៉ុនទាំងភ្នំ ។

អត្ថបទផ្តើម : កូនអើយបាស្តាប់ អាពុកទឹនប្រាប់ ដោយបទគាថា

ព្រះស្រីសារពេជ្ញ ស្តែនស្តេចទេសនា សរសើរគុណមា-តា

ដោយគម្ពីរ ។ សណ្តាប់ប្រាជ្ញផង ដោយទូវគន្ធ អាថ៌

ព្រះបាលី ច្បាស់ច្បាប់សួស្តី នរប្រុសស្រី ចងចាំគ្រប់ប្រាណ

. . . ។ល។ . . . .

អត្ថបទបញ្ចប់ : ( បទព្រហ្មគីត ) រីឯអ្នកផង ឲ្យចាំចងប្រសើរពិត

កុំធ្វើឥតបើគិត គេមិនរាប់ជាមនុស្សឡើយ ។

ច្បាប់នេះប្រសើរគាប់ ជួបជុំចប់ជាតកហើយ ទៅឆ្ងាយល្វើន

ល្វើយឡប់ខ្សែឡាត់សួរបេហោន ។

×××

បំណងជើង : " សាស្ត្រា ច្បាប់ក្រម "

អ្នកនិពន្ធ : គេមិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ ( បទកាកគតិ )

ប្រភពរឿង : ច្បាប់សីលធម៌និងប្រពៃណីនិយម។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៣ សន្លឹកកន្ទុះ ។

ឯកសារនេះ បានមកពីវត្តខ្ទឹង ខេត្តកំពង់ចាម លេខសាស្ត្រា

៦៦៧ ។ សាស្ត្រាច្បាប់នេះ សម្បូរណាស់តាមវត្តទាំងឡាយ ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ នេះគឺច្បាប់ក្រម ប្រសើរឧត្តម ទូន្មានអ្នកផង ប្រើទទួលទោនកុំបីមានធ្គង ប្រាជ្ញាបុណ្យផង កើតដោយប្រណិបត្តិ ។ . . . . .

. . . . . . . ។ល។ . . .

អត្ថបទបញ្ចប់ : នរអ្នកណា ទីងនាំអាត្មា សង្វាហ៍អធ្យោគ ស្វែងធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហាធាតុមោក្ខ គឺនិព្វានហោង ។

×××

បំណងដើម : „ សាស្ត្រាក្រមច្បាប់ „

អ្នកនិពន្ធ : ក៏មិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ។

ប្រភពរឿង : ចំនៀមចំលាប់ទីងប្រពៃណីនិយមក្នុងព្រះពុទ្ធសាសនា ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៥ សន្លឹកចប់ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តខ្ញុំ កំពង់ចាម ចុះលេខសាស្ត្រា ៦៦៧ ។

អត្ថបទផ្ដើមៈ បទកាកគតិ ។ នេះគឺក្រមច្បាប់ ព្រះលោកបង្គាប់

ទូន្មានអ្នកផង កើតនាលោកិយ ដែនដីនេះហោង ឲ្យបាន

បួសសង គុណព្រះមាតា ។ បួសហើយលំអុត ចាំសីល

ស្រគត់ ចម្រើនភាវនា សង្វាតសូត្ររៀន រៀនអាត្មា ខ្មី

ឃ្មាតរក្ស កុំខ្ជិលឡើយហោង ។ . . . ។ល។ . . .

អត្ថបទបញ្ចប់ៈ ច្បាប់នេះប្រពៃ ប្រសើរថ្កាថ្លៃ លែងក្រមច្បាប់ផង

ចូរចាំចូរចាប់ ដោយច្បាប់ធម៌ផង ចូរគ្រាប់ចូរគ្រង ចូរ

រៀនចាំចង ទុកនៅអាត្មា ។ បើអ្នកណាចាំ អស់អាថ៌

កិច្ចកម្ម ដោយព្រះគាថា អ្នកនោះឯងបាន ដូចក្តីប្រាថ្នា

សូរេបបកាក និច្ចំតចប់ហោង ។

XXX

ចំណងជើង : " សាស្ត្រា សេចក្តីក្រមច្បាប់ ,,

អ្នកនិពន្ធ : គេមិនទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ។

ប្រភពរឿង : សុជីវធម៌ និងសីលធម៌ តាមប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ ៧ សន្លឹក ។

ពុទ្ធសាសនបណ្ឌិត្យ បានថតចម្លងអំពីវត្តខ្ទង់ ខេត្តកំពង់ចាម

ចុះលេខ ៦៦៧ ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ ក្រមច្បាប់នេះគិត លើកតាម

សុចរិត គន្ធមាត្រា តែងជាបរិយាយ ទុកឲ្យអស់មហា-ជន

ផងនានា គ្រាន់មើលតទៅ ។ ច្បាប់នេះជាល្បើក ទើប

និងរៀនលើក ពុំដឹងខុសត្រូវ ដ្បិតក្មេងសេចក្ដី ប្រាជ្ញា

ខ្វីខ្វៅ ពុំចាក់ជាក់នៅ អស់អាចិទនង ។

. . . . . . . ។ល។ . . . .

អត្ថបទបញ្ចប់ : អស់អាចិកាព្យកិច្ច ពាក្យល្បើកសេចក្រេច នូវពាក្យ

សច្ចា សូមឲ្យទៀងទាត់ កុំឃ្លាតឡើយណា សូរេចបកាព

និដ្ឋិតចប់ហោង ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ត)

លោក ឌឹក-គាម ប្រមូលរៀបរៀង

សេចក្ដីដំណាលពីរឿងភិក្ខុមួយរូប : ព្រះមហា ប៉ុណ្ណ-សម្អាជ ទ.ក. ៨, ទំព័រ ៤៣៦, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

សេចក្ដីដំណាលអំពីទេវបុត្តមារនិងព្រះថេរឧបគុត្ត : ព្រះមហា ប៉ុណ្ណ-សម្អាជ ទ.ក. ៦, ទំព័រ ៣៣០, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

សេចក្ដីថ្លែងការណ៍ សារពត៌មាន របស់ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត : ទ.ក ៨, ទំព័រ ៩៥០, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

សេចក្ដីថ្លែងគុណព្រះមហាវិមលធម្មថោង : ព្រះគ្រូសំឃវិជ្ជា ហ-គាត ទ.ក. ២, ទំព័រ ៣៩, ឆ្នាំ ១៩២៧, (ម.៥២/២) ។

សេចក្ដីបង្ហាញប្រយោជន៍ : អ្នកឧកញ៉ាពិទិត្យវោហារ ជួន-ហ៊ិល ទ.ក. ៤, ទំព័រ ៨៧, ឆ្នាំ ១៩២៦-២៧, (ម.៥២/១) ។

សេចក្ដីបង្ហាញប្រយោជន៍នៃទស្សនាវដ្ដីកម្ពុជសុរិយា

ដល់សាធារណជន : ព្រះអង្គម្ចាស់ក្រុមព្រះ នរោត្តម ភាណុវង្ស ទ.ក. ១, ទំព័រ ១៥, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីបរិសុទ្ធិនៅឯណា : ព្រះទេពសត្ថា គឹម-តួរ ទ.ក. ៩, ៦៤៣, ឆ្នាំ ១៩៥៥, (ម.៥២/២៤) ។ ទ.ក ៨, ទំព័រ ទំព័រ ៨៥១, ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

សេចក្ដីប្រកាសបដិការ របស់ ព្រះមហាវិមលធម្ម ថោង : ព្រះគ្រូសំសត្ថា ជ. ណាត ទ.ក. ២, ទំព័រ ៥១ ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីប្លែក ៗ : ទ.ក. ៣, ទំព័រ ២១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

សេចក្ដីផ្សាយតទល់នឹងការឃោសនា : ទ.ក. ៥, ទំព័រ ៨, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្ដីពណ៌នា កិត្តិគុណ របស់ព្រះមហាវិមលធម្ម-ថោង ព្រះញាណារិយឡុង ទ.ក. ២, ទំព័រ ១០៥, ឆ្នាំ ១៩២៧, (ម.៥២/៦) ។

សេចក្ដីពណ៌នាតាមគោលខ្ទះអំពីក្បាច់អលង្ការ ក្នុងប្រទេសឥណ្ឌូចិន : លោក ល្វី-ហ្វីណូត៍ ទ.ក ៤, ទំព័រ ៣៩, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីពណ៌នាមរណកិច្ច របស់ព្រះមហាវិមលធម្ម-ថោង : ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ ខ.ក. ២, ទំព័រ ៩៧ ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីពណ៌នា អំពីគុណ របស់ ព្រះមហាវិមលធម្ម-ថោង : លោក លី-ហ៊ីណុក ខ.ក. ៣, ទំព័រ ៣, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្ដីពន្យល់អំពីពាក្យខ្មែរខ្លះ ( ក្នុងសេចក្ដីរាយការណ៍ជាភាសាចិនក្នុងសតវត្សទី ១៣ : (លោកសីវេស ) ហ្វូននិពន្ធមន្ត្រី ញ៉ុក-ថែម ខ.ក. ១២, ទំព័រ ៦១៩, ឆ្នាំ ១៩៤៤ (ម.៥២/៩៦) ។

សេចក្ដីពិចារណានៃពុទ្ធសាសនិកជនម្នាក់ : លោក ប៉ាយ-ប៊ុក ខ.ក. ១១, ទំព័រ ៩៨០, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សេចក្ដីមួយ និយាយអំពីពង្សាវតារសង្ខេប របស់ប្រទេសកម្ពុជា : ខ.ក. ១៤, ទំព័រ ៩៣, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

សេចក្ដីយល់ឃើញអំពីប្រាសាទនគរវត្ត : លោក ព្រពុស្គី ខ.ក. ៧-៨-៩, ទំព័រ ៩៧, ឆ្នាំ ១៩៣៦, (ម.៥២/៨) ។

សេចក្តីយុត្តិធម៌ និង ប្រាក់ : លោក ក៏យ · ប៊ុក ទ.ក.
៦, ទំព័រ ៦៦៧; ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សេចក្តីរាយការណ៍អំពីពួកតំណាងខេត្តកំពត នាំប្រាក់ចំនួន ១.០០០ មកជូនព្រះរាជបណ្ណាល័យ :
ទ.ក. ១១ ទំព័រ ១០១ ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្តីរំលឹកគុណ លោករេស៊ីដង់ ស៊ុប៉េរីយ៉េរ ម្ង. ឡាំង : ទ.ក. ៧, ទំព័រ ៣ ឆ្នាំ ១៩២៦-២៧ (ម.៥២/១) ។

សេចក្តីរំលឹកជាសំនៀង (កាព្យ) : ព្រះភិរម្យភាសាអ៊ូ
ទ.ក. ៧·១២, ទំព័រ ៩៧, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

សេចក្តីល្អ សេចក្តីអាក្រក់ : លោក ស៊ុន · ហ៊ាន ទ.ក.
៤, ទំព័រ ២៥៩ ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

សេចក្តីសង្ខេបនៃគម្ពីរបញ្ចតន្ត្រៈ : ទ.ក. ១៩ - ២០
ទំព័រ ២៦, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

សេចក្តីសង្គ្រោះ : លោក ថេង · ជើរ ទ.ក. ២ ទំព័រ
១៧៧ ឆ្នាំ ១៩៦៣ (ម.៥២/៣៥) ។

សេចក្តីសន្និដ្ឋានមួយអំពីការគាស់ព្រះកែវមរកត:
ទ.ក. ១៦ ទំព័រ ១០ ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្ដីសាមគ្គីជាពិសេស និង ខ្មែរ : ទ.ក. ១០, ទំព័រ ៦, ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្ដីសុខ និងសេចក្ដីចំរើន របស់ប្រទេស តែង ប្រព្រឹត្តទៅជាមួយនឹងវប្បធម៌ : លោក ពយ-ប៊ុក ទ.ក. ៨, ទំព័រ ៧៣៣, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

សេចក្ដីស្ងួតរំលឹកគុណានុទិសនដល់ ចំពោះព្រះមហាវិមលធម្មបោង : ទ.ក ២, ទំព័រ ១៨៥, ឆ្នាំ ១៩២៧, (ម.៥២/២) ។

សេចក្ដីសំខាន់ ៗ ក្នុងសៀវភៅមួយ របស់ប្រទេស ជប៉ុន : ទ.ក. ៨, ទំព័រ ៨, ឆ្នាំ ១៩៤១, (ម.៥២/១៣ )

សេចក្ដីសំគាល់អំពីរូបព្រះមេត្រិយពោធិសត្វដែលតាំង នៅក្នុងព្រះរាជបណ្ណាល័យ : គាប៊ីឡេស ទ.ក. ១, ទំព័រ ១៩, ឆ្នាំ ១៩២៧, (ម.៥២/២) ។

សេចក្ដីស្រងំធម៌ទេសនាយ៉ាងសង្ខេប : លោកកំម៉ង់ដុក្ត ទ.ក. ៨, ទំព័រ ៩៣, (ម.៥២/៣) ។

សេចក្ដីស្រង់ពីពាក្យ (លោកអាំងស្ប៉ិកទ័រត្រួតសាលាបឋមវិជ្ជានៅកម្ពុជាក្រោម ) : ទ.ក. ៤ - ៥ - ៦, ទំព័រ ១២, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

សេចក្តីស្រង់អំពីរៀនមួយនិយាយអំពីការសិក្សា : គ-ច- ដេមាដេក្ត ទ.ក. ៩, ទំព័រ ៨; ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

សេចក្តីអធិប្បាយពីពិធីសាងប្រាសាទនគរវត្ត : លោក ហ-ម៉ារ្សាស ទ.ក. ៤ ៥-៦, ទំព័រ ៧៥, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

សេចក្តីអធិប្បាយរបស់ជាតិហុល្លង់ដេស់ម្នាក់ អំពីការពឹងពាក់ប្រាស្រ័យនៅស្រុកខ្មែរ : ថីគិម-ហាក់ ទ.ក. ២, ទំព័រ ៣, ឆ្នាំ ១៩៤០, (ម.៥២/១២) ។

សេចក្តីអធិប្បាយពន្យល់ធៀនរស្ព : ការប៉ឺឡេស ទ.ក. ៧, ទំព័រ ៣, ឆ្នាំ ១៩២៧ (ម.៥២/៦) ។

សេចក្តីអធិប្បាយសង្ខេបអំពីបឋមសាសនៈ : អ្នកអង្គម្ចាស់វឌ្ឍឆាយាវង្ស ទ.ក. ៣, ទំព័រ ៨៧, ឆ្នាំ ១៩២៦-២៧, (ម.៥២/១) ។

សេចក្តីអធិប្បាយអំពីជើងថ្ម ដែលឆ្លាក់ជារូបព្រះពុទ្ធបរិនិព្វាន : ការប៉ឺឡេស ទ.ក. ៣, ទំព័រ ១៥, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សេចក្តីអធិប្បាយអំពីរូបបុរាណសុភាសិត : អ្នកអាចារ្យ
ផត-ប៊ុន ទ.ក. ៨, ទំព័រ ៤៤១, ឆ្នាំ ១៩៤៣,
(ម.៥២/១៥ ) ។

សេចក្តីអធិប្បាយអំពីបុរាណវត្ថុ នៅជិតពិពិធភណ្ឌវត្ត
ពោធិកល : លោក ហ-ប៉ាម៉ង់ទេរ និង លោក ក.ផ៉ាលេត៍ ទ.ក.
១-២-៣, ទំព័រ ១០៧, ឆ្នាំ១៩៣៦ (ម.៥២/៨) ។

សេចក្តីអធិប្បាយអំពីរូបព្រះពោធិសត្វអវលោកិតេស្វរ
ព អង្គ នៅក្នុងព្រះបរមរាជវាំងក្រុងភ្នំពេញ : ការប៉ឺ-
ឡេស ទ.ក. ៣, ទំព័រ ១, ឆ្នាំ ១៩៣០, (ម.៥២/៣)។

សេចក្តីអធិប្បាយអំពីរូបសំរិទ្ធ ព ដែលមានមុខ ៤
និងដៃ ៤ : ការប៉ឺឡេស ទ.ក. ២, ទំព័រ ១, ឆ្នាំ ១៩៣០
(ម.៥២/៣) ។

សេដ្ឋីឆាត់ (រឿងព្រេង) : ទ.ក. ៣, ទំព័រ ២៦,
ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

សេរីភាព : លោក ផេង - ជ្រើ ទ.ក. ១២; ទំព័រ ១២៥២
ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

សេះពណាហា (រឿង) : លោក វិកទ័រ-គោលូបេហ៍ ទ.ក.

៣ - ៦, ទំព័រ ៧៥, ឆ្នាំ ១៩៣១, (ម.៥២/៤) ។

សែងក្មេងបេចាចាស់ទុំ : ទ.ក. ១០-១១-១២, ទំព័រ ១២៣, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

សោវសោយ (រឿង) : ព្រះមហាឧត្តមវិជ្ជា ប៊ុន-ម៉ម ទ.ក. ៥, ទំព័រ ៣៥១, ឆ្នាំ ១៩៥៤ (ម.៥២/២៥) ។

សំបុត្ររបស់លោកជេហាវុទៅបុត្រី : លោក ឈន-អៀម ទ.ក. ៦, ទំព័រ ៦៣៣, ឆ្នាំ ១៩៦៥

សំលៀកបំពាក់ខ្មែរ : ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ទ.ក. ៣, ទំព័រ ២២៤, ឆ្នាំ ១៩៥២, (ម.៥២/១៤) ។

សំភសកថា និយាយអំពីគូសំភស ៤ ពួក : មហា ថៃម ទ.ក. ៧-៨-៩, ទំព័រ ១៩៣, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

សំវេគកថា : លោក ស្រ៊-អ៊ូ ទ.ក. ១០, ទំព័រ ៨៩៧, ឆ្នាំ ១៩៤៧ (ម.៥២/២៩) ។

ស្ពឺប៉ែនហឺរ និង ព្រះពុទ្ធសាសនា : ទ.ក. ៧-៨-៩, ទំព័រ ៥, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

ស្តូបរបស់ព្រះចានធម្មាសោក : លោក ប៉ូល-មុស ទ.ក.

៩, ទំព័រ ៣, ឆ្នាំ ១៩៤០, (ម.៥២/១២) ។

ស្តេចក្រុងចិន (រឿងព្រេង) : ទ.ក. ៤ - ៥ - ៦,
ទំព័រ ១២៣, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

ស្តេចត្រី (រឿង) : លោក ផេង ជ្រីវ ទ.ក. ១១, ទំព័រ
៨.៣១, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

ស្តេចចាយស្ការ : លោក ញ៉ែម-ខឹម ទ.ក. ១២, ទំព័រ ១៣៨៦,
ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

ស្តេចឧនេង : ក្រុមការ ជុំ-មៅ ទ.ក. ៧ - ៨ - ៩, ទំព័រ
២៩, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

ស្ពានរបស់ព្រះគគក់ (តាមយោបល់របស់ហីនយាន-
មហាយាន) : ទ.ក. ១៦, ទំព័រ ៧, ឆ្នាំ ១៩៤១,
(ម.៥២/១៣) ។

ស្ទឹងគង្គាជាស្ទឹងសក្តិសិទ្ធិ : ទ.ក. ២២; ទំព័រ ៩,
ឆ្នាំ ១៩៤១ (ម.៥២/១៣) ។

ស្នាដៃឪពុក : លោក ស៊ុន - ផូ ទ.ក. ៨, ទំព័រ ៩២០
ឆ្នាំ ១៩៦០, (ម.៥២/៣២) ។

ស្នេហាជាតិ (រឿង) : លោក គង់ - លិម ទ.ក. ១០,

ទំព័រ ៣៦៦, ឆ្នាំ ១៩៤៩, (ម.៥២/២៤) ។

ស្នេង (អំពី) : លោក ថៃ-ឈុនអេង ទ.ក. ៥, ទំព័រ ៤៣, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

ស្រីក្បាកមាស (រឿងព្រេង) : ទ.ក. ១, ទំព័រ ៧៩, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

ស្រីគ្រប់លក្ខណ៍ : យុគ វិធីរ ទ.ក. ៨, ទំព័រ ៩២០; ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

ស្រីពីរនាក់ដណ្ដើមក្ខងគ្នា (រឿងព្រេង) : ទ.ក. ១, ទំព័រ ៤៩, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

ស្រីស្មោះត្រង់និងស្វាមី : ទ.ក. ១.៧ - ១៨ ទំព័រ ៦២, ឆ្នាំ ១៩៤២, (ម.៥២/២៤) ។

ស្រុកកំពង់ធំពីដើម : ទ.ក. ៤ - ៥ - ៦, ទំព័រ ១១២, ឆ្នាំ ១៩៣៥, (ម.៥២/២៤) ។

ស្លាប់ព្រោះជាតិ (រឿង) : លោក គង់-លឹម ទ.ក. ១០, ទំព័រ ៣៦៦, ឆ្នាំ ១៩៤៩ (ម.៥២/២៤) ។

ស្វាលួចមកុដស្ដេច (រឿងព្រេង) : ទ.ក. ៤, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

ហង្សយន្ត : ទ.ក. ៤, ទំព័រ ៤៣៦, ឆ្នាំ ១៩៥៩,
(ម.៥២/៣១) ។

ហិតោបទេស : ក្រមការ ជុំ-ម៉ៅ ទ.ក. ១-៦ ទំព័រ ៦៤,
ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

ហុល្លង់ដេស៍នៅស្រុកខ្មែរក្នុងសម័យលង្វែក : ទ.ក.
២៤, ទំព័រ ៩, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

ហេតុដូច ម្តេចបានជាព្រះពុទ្ធសាសនា ផុតរលត់ទៅពី
ប្រទេសឥណ្ឌា : ខេមររង្សី ទ.ក. ៣, ទំព័រ ១៩,
ឆ្នាំ ១៩៤០ (ម.៥២/១២) ។

ហោរាសាស្ត្រ និង ពុទ្ធសាសនា : ទ.ក. ៥, ទំព័រ ៣,
ឆ្នាំ ១៩៤០, (ម.៥២/១២) ។

ហ្លួចាត : ម.រឿងហ្លួចាត ។

ហ្វង់ព្រះបាទ (ក្បួនហែព្រះរាជទ្រព្យ កាំពុងហែចូល
ទៅវត្តបាណា) : ទ.ក. ៧, ទំព័រ ១, ឆ្នាំ ១៩៤១,
(ម.៥២/១៣) ។

(នៅមានត)

# សេចក្ដីជូនដំណឹង

## អំពីលទ្ធផល នៃ ការប្រឡងប្រជែង ខាង ទំនៀមទម្លាប់ខ្មែរ

(ឆមាសទី ១ ឆ្នាំ ១៩៦៧)

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ មានសេចក្ដីរីករាយនឹងផ្សាយដំណឹងចំពោះព្រះតេជព្រះគុណ អស់លោក-អ្នក ជាសមាជិកឆ្លើយឆ្លង និង បេក្ខជនទូទៅថា : នៅក្នុងឆមាសទី ១ នៃឆ្នាំ ១៩៦៧ គឺពីខែមករាដល់ខែមិថុនា ១៩៦៧ នេះ ក្រុមជំនុំបានបើកការប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ ពីរមុខ គឺ :

១– អំពីគ្រឿងសាស្ត្រាវុធ

២ – អំពីការបូជាសត្វសែនចំពោះវត្ថុស័ក្ដិសិទ្ធិ

ដើម្បីប្រមូលឯកសារ មកតំកល់ទុក សម្រាប់ធ្វើជាគោលចារិក នៃប្រពៃណីផ្នែកនេះ ទុកជាសម្បត្តិជាតិតរៀងទៅ ។ តាំងពីបានបើកឧកាសប្រឡងមក មានបេក្ខជនជាច្រើនទាំងព្រះសង្ឃ ទាំងគ្រហស្ថ ជាសមាជិកឆ្លើយឆ្លងខ្លះ ពុំមែនជាសមាជិកខ្លះ បានផ្ញើអត្ថបទមកចូលប្រឡងប្រជែង ។ ក្រុមជំនុំក៏បានប្រជុំពិនិត្យនូវវិញ្ញាសាទាំងនោះយ៉ាងហ្មត់ចត់ ដោយបានសម្រេចជាលទ្ធផលដូចតទៅ :

## ក- ផ្នែកគ្រឿងសាស្ត្រាវុធ

រង្វាន់លេខ ១: សហ. ភ័ណ-គួ នៅសង្កាត់អង្គតាសោម ស្រុកត្រាំកក់
ខេត្តតាកែវ បានរង្វាន់ . . . ១០០០៛០០

រង្វាន់លេខ១២ : សហ. កែវ-កុល នៅភូមិព្រៃយោង សង្កាត់អង្គ-
តាសោម ស្រុកត្រាំកក់ ខេត្តតាកែវ
បានរង្វាន់ . . . . . . . ៨០០៛០០

រង្វាន់លេខ១៣ : សហ. សេក សែព នៅសង្កាត់តាំងក្រសាំង
ស្រុកសន្ទុក ខេត្តកំពង់ធំ បានរង្វាន់ . . . ៦ ០៛០០

រង្វាន់លេខ ១៤ : សហ. យ៉េម-ត្រមម នៅការិយាល័យភូមិបាល
ស្រុកបាទី ខេត្តតាកែវ បានរង្វាន់ . . . ៤០០៛០០

ព្រមទាំងអ្នកបានរង្វាន់លើកទឹកចិត្ត ៤ រូបទៀត គឺ :

- សហ. ម៉ម យី គ្រូបង្រៀននៅសាលាសុគន្ធបញ្ញា សង្កាត់
ព្រែកស្ងួន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល
បានរង្វាន់ . . . . . . . ២០០៛០០
- សហ. កៅ យី នៅសង្កាត់បឹងត្រាញ់ ស្រុកសំរោង ខេត្ត
តាកែវ បានរង្វាន់ . . . . . . . ២០០៛០០
- សហ. សាន-ឌុយហៅ កែវ សានឌី នៅសៀមរាបក្រុង ២០០៛
- សហ. បាយ សេរី ធ្វើការនៅសាលាខេត្តពោធិ៍សាត់
បានរង្វាន់ — . . . . . . . ២០០៛០០

## ១- ផ្នែកបូជាសត្វរស់ចំពោះវត្ថុស័ក្តិសិទ្ធិ

ដោយឯកសារស្តីពីផ្នែកទី ២ នេះ មានចំនួនតិចពេក ហើយសរសេរពុំសូវប្រកបដោយខ្លឹមសារច្បាស់លាស់ផងនោះ ក្រុមជំនុំសម្រេចជ្រើសបានល្អគួរសមតែពីរវិញ្ញាសា ដោយឲ្យជារង្វាន់លើកទឹកចិត្ត គឺ:

– ព្រះភិក្ខុ ឃៃ ឈុន គង់នៅវត្តបទុមគង្គា សង្កាត់បាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល បានរង្វាន់ ៣០០៛០០

– លោក អ៊ុំ-ឈុំ នៅសង្កាត់កុមាររាជា ស្រុកបាទី ខេត្តតាកែវ បានរង្វាន់. . . . . . ៣០០៛០០

រង្វាន់ទាំងនេះ ក្រុមជំនុំចាត់ផ្ញើទៅជូនសាមីជន ក្នុងពេលយ៉ាងឆាប់ខាងមុខនេះ តាមរយៈប្រៃសណីយ៍ ។ ម្យ៉ាងទៀត នៅក្នុងឆមាសទី ២ នៃឆ្នាំ ១៩៦៧ នេះ ក្រុមជំនុំបានប្រកាសប្រឡងប្រជែង ២ មុខទៀត គឺ :

១– អំពីឧសថខ្មែរបុរាណ

២– អំពីភាសាសាស្ត្របុរាណខ្មែរ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះតេជព្រះគុណ អស់លោក-អ្នក ដែលបានយកព្រះទ័យ យកចិត្តទុកដាក់ជួយរក្សាកេរ្តិ៍ដំណែលរបស់ជាតិដ៏ថ្លៃថ្លាទាំងនេះ ជាតិយោគភាព ។

# ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

## ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៧

នៅឆមាសទី ២ គឺតាំងពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៧ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសរើសយកឯកសារ ដោយបើកការប្រឡងប្រជែង ២ មុខគឺ :

១– អំពីពិធីរបស់ខ្មែរបុរាណ

២– អំពីភាសាសាស្ត្របុរាណខ្មែរ

*ដូច្នេះ អស់លោក អ្នកចេះដឹងទាំងឡាយ ជាស្ត្រី ជាបុរស ឬ បព្វជិតក្តី ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងអត្ថបទ តាមគោលបញ្ហាដូចរៀបរាប់ខាងមុខ ហើយសរសេរ* ឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែវិច្ឆិកា ឆ្នាំ ១៩៦៧ ។

ការប្រឡងប្រជែងនេះ មានរង្វាន់ ៤ ថ្នាក់ :

| | |
|---|---|
| លេខ ១ ... ១០០០៛០០ | លេខ ៣ ... ៦០០៛០០ |
| លេខ ២ ... ៨០០៛០០ | លេខ ៤ ... ៤០០៛០០ |

បើអស់លោក-អ្នកត្រូវការសរសេរអត្ថបទ ដូចខាងលើនេះ ទៅដាក់ប្រឡង សូមសរសេរលើសៀវភៅ កុំសរសេរលើក្រដាសតែ ១ សន្លឹក ឬ ២ សន្លឹកឡើយ ហើយសូមសរសេរនាម និងទីលំនៅរបស់ខ្លួន ឲ្យច្បាស់លាស់លើក្រដាស ១ សន្លឹកដោយឡែក ដាក់ក្នុងស្រោមជាមួយនឹងអត្ថបទនោះ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួនក៏បាន ផ្ញើទៅតាមប្រៃសណីយ៍ក៏បាន ដោយកាន់សំបុត្រថា :

ពុទ្ធសាសនបណ្ឌិត្យ

ការិយាល័យទំនៀមទម្លាប់ - ភ្នំពេញ

គោលបញ្ហានៃការប្រឡង

## ១. អំពីឱសថខ្មែរបុរាណ

ដែលហៅថា « ឱសថខ្មែរបុរាណ » គឺយើងសំដៅយកថ្នាំតែភេទគ្រប់បែប ដែលតម្រាបុរាណខ្មែរយើងបានកំណត់ឲ្យផ្សំដោយស្លឹកឈើ, ដើមឈើ, មើមឈើ, ឬស ស្បែក ស្លាបសត្វ ឬ វត្ថុដទៃ ៗ ទៀត ជាដើម ៗ ជួនកាល គ្រឿងផ្សំថ្នាំខ្មែរយើង បេះចាំដោយក ៗ គ្នាមកក៏មាន ដូច្នេះសូមសរសេររៀបរាប់អំពីឱសថទាំងនោះ យ៉ាងតិចណាស់ ក៏ឲ្យបាន ឱសថ ៥ មុខ ដែរ ហើយសូមសរសេរ

កប់របៀបឲ្យត្រូវតាមសំនួរហូរហែខាងក្រោម បើប្រសិនត្រង់ចំណុចណា ពុំបានដឹង ក៏សូមរំលង ទៅចុះ :

### ក_ ឈ្មោះឱសថ

– តើឱសថនេះឈ្មោះអ្វី? ឈ្មោះនេះគេហៅតាមឈ្មោះពេគ ឬ តាម ឈ្មោះរបៀបប្រើ? នរណាជាអ្នករកឃើញ បង្កើតឱសថនេះឡើង បើស្គាល់ឈ្មោះ ឬ ប្រវត្តិដើមយ៉ាងណា ក៏សូមប្រាប់មកផង ។

### ខ- អំពីគ្រឿងផ្សំ

– តើមានអ្វីខ្លះជាគ្រឿងផ្សំ សូមកប់ឈ្មោះវត្ថុសំកប់ផ្សំនោះ ឲ្យបានគ្រប់ឈ្មោះ ។ ចំពោះរុក្ខជាតិ ឬ ធម្មជាតិអ្វីមួយដែលត្រូវយកមកផ្សំនោះ សូមប្រាប់ពីរូបពន៌ភិនភាគរបស់វា ទីកន្លែងដែលមានរបស់ទាំងនោះផង ។

– ក្នុងការស្វែងរកគ្រឿងផ្សំទាំងនោះ តើគេមានប្រកាន់ក្រណម ឬ និយមតាមទំនៀមបែបណាខ្លះ សូមកប់របៀបពីក្រណមទិងទំនៀមនោះ ឲ្យច្បាស់លាស់ ទាំងរបៀបធ្វើ ទាំងគ្រឿងប្រដាប់ដែលប្រើក្នុងពេលរកវត្ថុនោះ ។

### គ –អំពីវិធីផ្សំ

– សូមកប់របៀបពីរបៀបកាប់ចិញ្ច្រាំ ឬ ចិត ឬ កោសគ្រឿងផ្សំនោះ មួយមុខម្តង ៗ ។

– ការផ្សំ សូមនិយាយបញ្ជាក់ពីចំនួនដោយប៉ាន់ទំហំ ឬកំណត់តាមក្បួនថ្លឹង នូវគ្រឿងផ្សំទាំងនោះមួយមុខ ៗ ។

– របៀបញ្ចូលគ្នានេះ, តើគេបញ្ចូលដោយបុកឲ្យល្អិតលាយគ្នា ឬ កាប់ឲ្យតូច ៗ ដាក់ក្នុងឆ្នាំង ក្នុងដបជាមួយគ្នា ឬ មួយកោសយកកំទេចច្របល់គ្នា ហើយគេត្រូវយកទៅស្ងោរ, ត្រាំស្រា, ដុតយកចំហាយ ឬ មូរជក់ជាបារី ។ល។ ក៏សូមពន្យល់ឲ្យច្បាស់លាស់ អំពីរបៀបផ្សំថ្នាំនោះ ។

– ក្នុងពេលផ្សំ មានត្រូវសូត្រមន្តអាគមគាថាយ៉ាងណាដែរ ? បើមានក៏សូមប្រាប់ផង ឬ បើមានធ្វើអ្វីផ្សេងទៀតតាមជំនឿក៏សូមកប់រៀបផងដែរ ដូចមានបាយសិង្សាដក់ជាដើម ។

ឃ - វិធីប្រើ ឱសថនេះត្រូវប្រើតាមវិធីណា ដូចជាត្រូវផឹក, ត្រូវលេប, ត្រូវហាល-ធ្នង់, លាប, ត្រាំងូត ឬ ធ្វើបែបណា ៗ សូមបញ្ជាក់របៀបប្រើនោះ និង សូមប្រាប់ពីកំណត់ដែលត្រូវប្រើនោះផង ដូចជាត្រូវប្រើប៉ុន្មានដងក្នុង ១ ថ្ងៃ ជាដើម ។

ង- ត្រណមផ្សេង ៗ

– ក្នុងពេលដែលប្រើឱសថនោះ មានតាន់ត្រណមដូចម្តេចខ្លះ ? (ដូចជា គេមិនឲ្យបរិភោគអ្វីខ្លះ តាន់កិរិយាបែបណា អស់រយៈពេលប៉ុន្មានទើបផុត) ។

– តើរៀបរណ្តាប់ថ្វាយគ្រូ ឬគ្រាស់គ្រូដូចម្តេច មានអ្វីខ្លះ? ។

## ២ អំពីភាសាសាស្ត្របុរាណខ្មែរ

សូមបញ្ជាក់ថា " ភាសាសាស្ត្រ " ក្នុងទីនេះ សំដៅយក លំនាំបែបបទនៃពាក្យសំដីដែលយើងប្រើប្រាស់ ឬ ថាទំនុកទំនើបបែបផែន ឬ វិជ្ជា ដែលវេទនាភាសា ពោលគឺពាក្យសំដី ដែលយើងនិយាយស្ដីប្រស្រ័យគ្នា ឲ្យដឹង ឲ្យយល់ថា ដូច្នេះដូច្នោះនេះឯង ។ ព្រោះថា ទោះបីជាជាតិតែមួយ ប្រទេសតែមួយ ក៏គង់តែមានរបៀបនិយាយស្ដី ប្រើពាក្យពេចន៍ និង ការឡើងន័យ ឬ សំនួនវោហារ ដោយឡែក ៗ ពីគ្នា អាចឲ្យសំគាល់បានថា នេះជាសំដីអ្នកស្រុកនេះ នេះជាសំដីអ្នកស្រុកនោះ ឬថា អ្នកនេះ ជាអ្នកមានកំណើតដើម ពីសញ្ជាតិណា ៗ ជាដើម ។

ដើម្បីឲ្យងាយក្នុងការសរសេរពន្យល់ទៅក្រុមជំនុំវិញ សូមលោកអ្នកពិនិត្យតាមសំនួរហូរហែ ខាងក្រោមនេះ ៖

### ក- អំពីសូរសំនៀងនៃការប្រើពាក្យសំដី

តាមធម្មតា អ្នកស្រុក អាន ឬ និយាយចេញជាពាក្យសំដីមិនមែនមានសូរសំនៀងដូចគ្នាទេ តែងតែល្អៀងពីគ្នាបន្តិច ៗ ឬ សឹងតែស្ដាប់គ្នាពុំបានសោះក៏មាន ហេតុនេះ សូមពន្យល់ថា :

– តើសំដីភាសាអ្នកស្រុកណា ដែលលោក-អ្នកសរសេរនោះ មានសំឡេងទន់, ធ្ងន់, យាវវែង ឬក៏ វែង, កញ្ចក់ ៗ, កំបុត ៗ

សូមឲ្យឧទាហរណ៍ជាសំដីមួយឃ្លា ឬ ច្រើនឃ្លា ដើម្បីបង្ហាញឲ្យឃើញជាសភាពភាសា តាមភូមិតាមស្រុក ។

— បើប្រសិនជាអាចធ្វើជាតារាងមួយប្រៀបធៀបសំឡេង គាន ពាក្យមួយម៉ាត់ ៗ ដែលប្លែកគ្នាបាន ក៏សូមធ្វើតាមទំនងគំរូ តារាងខាងក្រោមនេះ :

| ឈ្មោះភូមិភាគ | សំឡេងអ្នកភ្នំពេញ | សំឡេងអ្នកភូមិភាគ | សេចក្ដីសង្កេត |
|---|---|---|---|
| | | | |

## ខ - អំពីន័យរបស់ពាក្យ ឬ ការប្រើពាក្យប្លែកគ្នា

ប្រទេសខ្មែរយើង គ្មានគ្រាមភាសា(Dialecte) ទេ, យើងមានតែពាក្យប្លែកគ្នាខ្លះ ៗ តាមភូមិភាគតែប៉ុណ្ណោះគឺ ជាជួនកាលរបស់តែមួយ តែអ្នកស្រុកហៅឈ្មោះផ្សេងពីគ្នា ដូចជាកាំបិត អ្នកកំពតហៅគី, ក្រមាអ្នកបាត់ដំបងហៅកន្សែង, ចានស្រាក់អ្នកកំពង់ចាមហៅកាតូ ។ល។ ជួនកាលផ្ទុយពីនេះទៅវិញ គឺពាក្យតែមួយសោះ ហើយអ្នកស្រុកឲ្យន័យប្លែកគ្នាដូចពាក្យ រអែង (ក្រែងខ្លាច) អ្នកបាត់ដំបងថាឧស្សាហ៍; សោ អ្នកសៀមរាប អ្នកបាត់ដំបងឲ្យន័យថា ហត់នឿយ, អាក្រក់ ។ល។

បើគេឃើញច្រើនក៏សូមធ្វើជាតារាងមួយដែរ ។

## គ– ដើមកំណើតពាក្យ

ពាក្យទីមួយ ៗ សុទ្ធតែមានដើមកំណើតចេញមកពីប្រភពផ្សេង ៗ ប៉ុន្តែយើងលើកយកមកក្នុងពេលនេះ តែចំពោះពាក្យដែលមានដើមកំណើតពីមនុស្សដើមដែលធ្លាប់រស់នៅលើស្រុកយើងតែប៉ុណ្ណោះ ដូចជាពួកកុលសម្ព័ន្ធ ព្នង, ស្ទៀង, កួយ, ស្អូច, ព័រ ជាដើម តើមានពាក្យណាខ្លះក្លាយមកពីភាសាអ្នកអស់នោះ សូមធ្វើជាបញ្ជី រាយពាក្យទាំងនោះ ហើយប្រាប់ថាក្លាយពីកុលសម្ព័ន្ធណា? សព្វថ្ងៃគេមានដូចម្តេច ផង ៗ

ចំណែកពាក្យខ្លះដែលទាក់ទងពីភាសាជាតិនានាដូចជា មន ម៉ាឡាយូ ជ្វា លាវ ។ល។ ដែលធ្លាប់ទាក់ទងយើងពីបុរាណកាល ក៏សូមរាប់រៀបផងដែរ (ចំពោះកំណើតពាក្យពីភាសាបាលី–សំស្រ្កឹតពុំបាច់និយាយទេ)។

**សេចក្តីបញ្ជាក់–** អត្ថបទដែលបេក្ខជនសរសេរទៅដាក់ប្រឡង ទោះជាប់ក្តី មិនជាប់ក្តី ត្រូវទុកជាសម្បត្តិរបស់ក្រសួងតទៅ មិនបង្វិលឲ្យសាមីខ្លួនវិញទេ ។

សូមផ្ញើរូបថតសាមីខ្លួនលោក-អ្នកដែលសរសេរអត្ថបទប្រឡង បីសន្លឹកមកជាមួយផង គឺរូបមួយកំណាត់ខ្លួន ទំហំ ៤×៦ លើកលែងតែរបស់លោកណាដែលបានផ្ញើពីលើកមុនរួចមកហើយ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

យើងបានទទួលដំណឹងថា សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់បានថ្វាយសៀវភៅ ព្រះរាជសុន្ទរកថា ក្នុងឱកាសថ្វាយសញ្ញាប័ត្រ បណ្ឌិតអក្សរសាស្ត្រ, ចំពោះសម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ចំនួន ៣០១ ច្បាប់ ។ ក្រោយដែលទ្រង់បានទទួលហើយ សម្តេចព្រះសង្ឃរាជជាអម្ចាស់ ទ្រង់ថ្លែងព្រះបុគហ្វាយ ថ្លែងអំណរព្រះមហាករុណាទិគុណ និង ព្រះពរសិរីមង្គល ថ្វាយចំពោះ សម្តេចព្រះប្រមុខរដ្ឋវិញ ដូចមានសេចក្តីទាំងស្រុងតទៅនេះ ...

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងព្រះសង្ឃរាជគណៈមហានិកាយ

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

សូមថ្វាយព្រះពរ សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាអក្សរសាស្ត្រជាតិ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតនៃអាត្មាភាព

សូមទ្រង់ជ្រាប ។

នៅថ្ងៃទី ៦ កក្កដា ១៩៦៧ នេះ អាត្មាភាពបានទទួលអំពីលោក អ៊ុក-ម៉ុត អនុរដ្ឋលេខាធិការក្រសួងធម្មការ ជាព្រះរាជបំរើនៃព្រះអង្គ នូវសៀវភៅព្រះរាជសុន្ទរកថា នៃសម្តេចជាអម្ចាស់ចំនួន ៣០០ ច្បាប់ ជា ៣០១ ច្បាប់នឹងសៀវភៅដដែលនេះ ដែលចងក្រងពិសេស មាន ព្រះរាជចំណារ និង ព្រះហស្តលេខា ជាអនុស្សាវរីយ ទៅក្នុងអនាគត ពុំអាចជនណានឹងក្លែងក្លាយ ។ អាត្មាភាពសូមទទួលដោយគោរពយ៉ាង --

ខ្ពង់ខ្ពស់ក្រៃលែង ទូលព្រះរាជអំណោយដ៏ថ្លៃក្រៃនេះ ហើយនឹងចែក សៀវភៅនោះដល់ភិក្ខុសង្ឃ និង គ្រហស្ថដែលគួរចែក ដើម្បីរក្សាទុកជាអនុស្សរណៈជាទីរលឹក និង ជាទិដ្ឋានុគតិ គឺជាគម្រាប់ឲ្យកុលបុត្រកុលធីតាជាកូនចៅទាំងឡាយ ពេញចិត្តចំពោះអក្សរសាស្ត្រជាតិតរៀងទៅ ។

សូមថ្វាយព្រះពរ

តាំងពីក្រោយដែលសម្តេចជាអម្ចាស់ ទ្រង់ព្រះមេត្តាប្រោសព្រះរាជទាន សញ្ញាបត្របណ្ឌិតខាងអក្សរសាស្ត្រខ្មែរ ដល់អាត្មាភាពនោះរៀងរហូតមកដល់សព្វថ្ងៃនេះ វចនានុក្រមខ្មែរទាំង ២ ភាគ ក៏ហាក់ដូចជាមានព្រលឹងព្រលះជាងពីដើមច្រើនណាស់ ដោយសារព្រះតេជះដ៏ខ្ពង់ខ្ពស់បំផុតនៃសម្តេចជាអម្ចាស់ ។ អាត្មាភាព មានអំណរច្រើនណាស់ ចំពោះព្រះមហាករុណាធិគុណដ៏លើសលន់ពន់ប្រមាណនេះ ។ ព្រះរាជយោបល់ដ៏ជ្រាលជ្រៅក្រៃអាចនឹងស្មឹងបាន និង ព្រះរាជសុន្ទរកថាដែលទ្រង់ព្រះមេត្តាប្រោសឲ្យបោះពុម្ពជាអក្សរខ្មែរ និងអក្សរបារាំងផ្សាយនេះ ជាឧសថទិព្វពូកែផុតគាប់ ញុំាងអក្សរសាស្ត្រខ្មែរ ដែលមានកំឡាំងខ្សោយ ឲ្យមានកម្លាំងរឹងប៉ឹងឡើង ញុំាងវចនានុក្រមខ្មែរ ដែលស្គមកំព្រឹងកំព្រយ ទទួលព្រះរាជទានដំណេកជ្រលៀក ដូចជាសន្ទប់នោះឲ្យមានស្មារតី និងកម្លាំងក្រោកឡើង ឲ្យមានសាច់ មានឈាម មានព្រលឹងរឹងប៉ឹងអាចស្ទុះស្ទាពេញទំហឹងបាន ។

ដែលអាត្មាភាពមានអំណរឥតប្រៀបគណនា ចំពោះព្រះមហាករុណាធិគុណនេះ គឺដោយហេតុដូចបានថ្វាយព្រះពរដោយសង្ខេបខាងលើនេះ ដែលកម្រនឹងបានជួបប្រទះ ទោះបីរាប់កប្បសកកប្បដ៏យូរ ក៏កម្រនឹងបានជួប ដូចក្នុងសម័យសម្តេចព្រះប្រមុខរដ្ឋ ជាអម្ចាស់នេះឡើយ ។ ដែលអាត្មាភាពថ្វាយព្រះពរនេះ ដោយសុទ្ធចិត្តពិតត្រង់ ពុំមែនដោយចេះតែបញ្ជោរលើកព្រះបាទាព្រះអង្គឡើយ ។

អាត្មាភាពសូមថ្វាយព្រះពរ សូមព្រះអង្គទ្រង់ប្រកបដោយព្រះមហាតេជះឈ្នះអស់មារសត្រូវ គ្រប់ទិសទី គ្រប់កាលវេលា សូមព្រះអង្គមានព្រះសុខភាពដ៏បរិបូណ៌ជានិច្ច សូមព្រះអង្គមានព្រះជន្មាយុវែងឆ្ងាយក្រៃលែងជាងរយវស្សា ។

គួរពុំគួរ សូមទ្រង់ព្រះករុណាប្រោស

សូមថ្វាយព្រះពរ នៅថ្ងៃទី ៧ កក្កដា ១៩៦៧

អាត្មាភាព

សម្តេចព្រះសង្ឃរាជ

គណៈមហានិកាយ

( ព្រះហស្តលេខា : ) ជួន-ណាត

# ព្រះរាជសុន្ទរកថានៃសម្ដេចព្រះប្រមុខរដ្ឋ
# ក្នុងឱកាសពិធីថ្វាយសញ្ញាប័ត្របណ្ឌិតខាងអក្សរសាស្ត្រ
# ចំពោះសម្ដេចព្រះសង្ឃរាជ ថ្នាក់ទី ១

## ជួន-ណាត

*សម្ដេចជាអម្ចាស់ ជាទីសក្ការៈ*

*ព្រះថេរានុថេរៈ ជាទីគោរព*

*ឯកឧត្តម - អស់លោក*

*ជនរួមជាតិជាទីស្នេហា*

*ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ មានបីតិសោមនស្សណាស់ ដោយបានមកជាអធិបតីក្នុងពិធីដ៏មហោឡារិកនេះ ។ មានសេចក្ដីរីករាយសប្បាយជាខ្លាំង ចំពោះភូមិន្ទសកលវិទ្យាល័យយើង ដែលបានសម្រេចលើកតម្កល់ព្រះអង្គសម្ដេចព្រះសង្ឃរាជ ជាឋានៈអ្នកប្រាជ្ញទី ១ របស់យើងផ្នែកខាងអក្សរសាស្ត្រខ្មែរ ។ ទូលព្រះបង្គំ – ខ្ញុំព្រះករុណា ខ្ញុំ សូមសរសើរ ហើយថ្លែងអំណរគុណលោកសកលវិទ្យាធិការ លោកមហាវិទ្យាធិការ និង សាស្ត្រាទាំងអស់ ដែលបានសម្រេចថ្វាយព្រះកិត្តិយស និងគារវកិច្ច ចំពោះសម្ដេចព្រះសង្ឃរាជជាអម្ចាស់ ដែលព្រះអង្គមានព្រះកិត្តិនាមល្បីល្បាញតាំងពីយូរមកហើយ គឺសម្ដេចព្រះ*

សង្ឃរាជព្រះអង្គមាននាទីផ្ដាច់គេក្នុងវិស័យចំណេះវិជ្ជា និងស្នាព្រះហស្ដ ៗ គឺដោយសារសម្ដេចនេះហើយ ទើបអក្សរសាស្ត្រយើងមានទម្រង់ទាន់សម័យ ៗ ព្រះអង្គទ្រង់បានកំណត់ក្បួនវេយ្យាករណ៍ខ្មែរ ឲ្យត្រឹមត្រូវ ទាំងខាងពាក្យសម្ពន្ធ ដ៏ដូចជាខាងការអានឲ្យច្បាស់លាស់ ៗ ហើយចំណែកខាងស្នាព្រះហស្ដព្រះអង្គផ្នែកគរុកោសល្យ និង អក្សរសាស្ត្រ ក៏មានសារប្រយោជន៍លេខ ១ ៗ គឺព្រះអង្គសម្ដេចព្រះសង្ឃរាជនេះហើយ ដែលជាឫសគល់នៃវឌ្ឍនភាពរបស់ភាសាខ្មែរ ដែលឥឡូវសម្បូណ៌ទៅដោយពាក្យពេចន៍ប្រើប្រាស់ ប្រកបទៅតាមការចាំបាច់នៃសម័យថ្មី ៗ សម្ដេចព្រះអង្គបានជួយស្រោចស្រង់ភាសាខ្មែរយើងឲ្យចៀសវាងបាននូវការតាំងដំណើររបស់ភាសាបុរាណជាច្រើន ៗ ដូច្នេះព្រះនាមៈជាមហាបណ្ឌិតខាងអក្សរសាស្ត្រ ដែលបានប្រគល់ថ្វាយក្នុងពេលនេះ គឺជាសក្ខីភាព នៃកតញ្ញូតាធម៌ ចំពោះព្រះអង្គ ក្នុងវិស័យពហុវិជ្ជា ៗ គឺព្រះអង្គមានចំពោះជាតិមាតុភូមិ នូវមហាគុណូបការដែលគ្មាននរណាប្រកែកកើត ៗ

អក្សរសាស្ត្រខ្មែរ ផ្នែកទូទៅហើយនិងផ្នែកសាសនា ផុសឡើងវិញហើយ អំពីកត្រីកាលដ៏អាប់អួរមួយ ដ៏យូរលង់ៗការលួចបន់ និងដុតបំផ្លាញរាជធានីអង្គរ ដែលសៀមបានធ្វើ ជាហេតុមួយបណ្ដាលឲ្យខ្មែរបានពើបប្រទះនូវមហន្តរាយ ដែលមានទំហំធំលើសមហន្តរាយនៃអារ្យប្រទេសជាតិដទៃក្នុងប្រវត្តិសាស្ត្រ ៗ កងទ័ពឈ្លានពាន រាបានភគត្យាគត័ទ្ធព័ន្ធ

ប្រទេសខ្មែរស៊ីវិល័យ ហើយក៏បានបំផ្លាញគ្រប់បែបយ៉ាង នូវសៀវភៅ និងក្បួនខ្នាត ដែលបុព្វបុរសយើង បានតាក់តែងយ៉ាងអំណត់ មកតាំងពីច្រើនសតវត្សហើយៗឯកសារទាំងនេះគឺជាឃ្លាំងនៃប្រវត្តិសាស្ត្រ, អក្សរសាស្ត្រ និង វិទ្យាសាស្ត្រ ។ ពួកប្អូនទឹកដីនៃខ្មែរក្នុងសម័យនោះ ក៏ជាអនក្ខរជន ក៏ប្រណៃណនយ៉ាងខ្លាំង ចំពោះជាតិសាសន៍ខ្មែរ ក៏ទឹងសម្បារនឹងការលូតលាស់ចំរើននៃអារ្យធម៌ខ្មែរយើង ។

ប្រាកដណាស់ សៀមក៏ដណ្ដើមបន់យកអស់ទាំងអ្វីដែលជាតម្លៃរបស់ជាតិយើង ក៏ចម្លងលក្ខណៈអក្សរយើង ក៏ផ្ដិតយកបែបរដ្ឋបាលសម័យអង្គរយើង ហើយក៏បំផ្លិចនូវសំណល់រឿងឯកសារនៃអក្សរសាស្ត្រយើងដែលមិនខេះខេលាយ ធ្វើទៅជារបស់ក៏ ។ ស្របជាមួយនឹងការណ៍នេះហើយរហូតមកដល់សតវត្សទី ១៧ សៀមបានដុតបំផ្លាញនូវបណ្ណាល័យដែលបានរៀបចំរួចក្នុងសម័យលង្វែកទៅទល់នឹងសម័យឧដុង្គ ។សៀមក៏មានចំណង់ផ្ដាច់ខ្មែរអំពីអតីតកាលដ៏ថ្កើងរុងរឿងនៃខ្លួន ។ យើងអាចរក្សាទុកបាននូវអារ្យធម៌ខ្មែរក្នុងសម័យដើមនោះ ដោយសារតែសិលាចារឹកនៅលើផែនថ្ម ហើយនិងការបេះចម្លងក្បួនតម្រាតៗគ្នា ដោយមាត់ទទេ ។

បន្ទាប់ពីសៀមមក ពួកយួនបានចិត្តចំធ្វើបាបខ្មែរ ប៉ុន្តែ ក៏ពុំអាចបញ្ចូលបាននូវវប្បធម៌របស់ក៏ មកក្នុងប្រទេសយើងឡើយ ។ រហូតមកដល់សតវត្សទី ១៩ កដបល្ល័ង្កដែលជាអគ្គការការពារ ហើយលើកទឹកចិត្តជួយ

សិល្បៈ និង អក្សរសាស្ត្រ, ទស្សនវិជ្ជា និងសាសនាជានិច្ចរៀងមក ត្រូវតែប្រទះនូវអភ័ព្វគ្រប់បែបយ៉ាង ដែលធ្វើឲ្យអស់នូវលទ្ធភាព ចម្រើនវប្បធម៌ជាតិ ដោយខ្លួនរវល់តែផ្លាស់កន្លែងពីនេះទៅនោះ ។ ក្នុងគ្រាដ៏លំបាកនោះ ខ្មែរយើងខ្វះនូវអ្នកកត់ត្រាប្រវត្តិសាស្ត្រកវី-អ្នកនិពន្ធ ដើម្បីសរសេរទុកឲ្យបានគង់វង្សនូវរឿងរ៉ាវ ឬនូវចម្រៀង ដែលបង្ហាញអំពីវិភាព របស់ខ្មែរក្នុងសម័យរងទុក្ខវេទនា ។ រីឯព្រះពុទ្ធសាសនាយើង ក៏ត្រូវចុះអន់ថយ ហើយមានវិវត្តន៍ទៅតាមជំនឿឆ្វេង ជំនឿក្រៅសាសនា ដែលឆ្ងាយអំពីទ្រឹស្តីបរិសុទ្ធ នៃព្រះបរមគ្រូ ។ ការប៉ុនប៉ងរៀបចំទម្រង់ថ្មីឡើងវិញ ចាប់ផ្ដើមនៅក្នុងរជ្ជកាលនៃព្រះករុណាព្រះបាទសម្ដេចព្រះហរិរក្ស-រាមាធិបតីព្រះអង្គឌួង ។ ប៉ុន្តែ ចំបាំងថ្មីទៀតជាមួយសៀម និង យួន នាំឲ្យរំខានដល់ការខិតខំផ្ដួចផ្ដើមនេះ ។

អាណាព្យាបាលបារាំងសែស បាននាំមកឲ្យយើង នូវសន្តិភាព និងស្ថិរភាពខ្លះដែរ ។ ប៉ុន្តែ ពួកអាណាព្យាបាលនេះ គេគ្មានផលប្រយោជន៍អ្វីនឹងរៀបចំនូវវប្បធម៌ជាតិរបស់យើងឡើយ ។ ជាកុសល សម័យនោះ មានអ្នកស្នេហាជាតិយើងមួយក្រុម ចេះរួបរួមគ្នាសម្រេចចិត្តពញាក់ស្មារតីជាតិឲ្យភ្ញាក់រឭក គិតទៅដល់ការចុះអន់ថយនៃអក្សរសាស្ត្រ និងដល់តម្លៃនៃសាសនាយើង ។ ក្នុងចំណោមវរជនទាំងនោះ មានព្រះរាជអយ្យកោខាងបិតារបស់ទូលព្រះបង្គំ-ខ្ញុំ គឺសម្ដេចវរចក្ររណារិទ្ធិសុទ្ធារស

ដែលព្រះអង្គត្រូវកាត់ខានបានសោយរាជសម្បត្តិ ព្រោះតែអាណានិគមបារាំង មិនសប្បាយចិត្តនឹងសកម្មភាពរបស់ព្រះអង្គ ដែលជាអ្នកការពារឧត្តមប្រយោជន៍ និង កិត្តិយសជាតិ ។

ក្នុងសម័យនោះ សម្តេច ជួន-ណាត និង ហួត-តាត ព្រះអង្គមានយុវភាពនៅឡើយ ។ ប៉ុន្តែព្រះអង្គមានសមត្ថភាពពេញទីដើរជួរមុខនៃចលនាស្រោចស្រង់និងលើកតម្លៃវប្បធម៌ជាតិ ដើម្បីបើកនិងត្រាយផ្លូវនៃការលូតលាស់ចំរើន ដ៏ពិតប្រាកដ នៃបុនភព(renaissance) របស់វប្បធម៌ខ្មែរ ដែលបន្តដំណើរជានិច្ចមកដល់សព្វថ្ងៃនេះ ។ មុខការដែលត្រូវបំពេញមានទំហំធំធេងណាស់ ។ បណ្ឌិតសន្និបាតមួយប្រកបដោយអ្នកប្រាជ្ញមានសទ្ធាជ្រះថ្លាដ៏ឧត្តម មានចិត្តក្លាហាន ធ្វើការយ៉ាងសកម្ម ហើយតាមរបៀបបែបផែនវិទ្យាសាស្ត្រនិងបច្ចេកទេសផង បានពុះពារនឹងមុខការនេះ ។ ព្រះអង្គខ្លះ ដូចជាព្រះអយ្យកោទូលព្រះបង្គំខ្ញុំ សម្តេចល្វី-ឯម និងអ្នកប្រាជ្ញច្រើនទៀត បានអនិច្ចកម្មទៅ កំពុងបំពេញសកម្មភាព ។ សព្វថ្ងៃនេះ ក្រុមអ្នកប្រាជ្ញជំនាន់នោះ ពិសេស គឺសម្តេច ជួន-ណាត និង ហួត-តាត ព្រះអង្គនៅតែបន្តការនេះគ្មានឆាករេ ព្រះអង្គយាងត្រង់តាមមាគ៌ាដែលបានដៅទុកមក ។

វឌ្ឍនភាពយ៉ាងធំមួយ បានសំរេចហើយ ក្នុងការសំរិតសំរាំងពាក្យដែលត្រូវខ្ចីឬត្រូវប្រែមកពីបរទេស ហើយក្នុងការសំដែងស្វែងរកឲ្យបាន

ត្រឹមត្រូវតាមព្រះធម៌ និងព្រះវិន័យរបស់ព្រះពុទ្ធជាម្ចាស់ ។ ក្នុងករណីនេះ គួរសរសើរចំពោះការបកប្រែ ការបោះពុម្ពនិងការផ្សាយព្រះត្រៃបិដកដែលមានដំណើរលឿនលឿនទៅមុខយ៉ាងទៀងទាត់ឥតខ្ចោះ ។ អ្នកខ្លះនិយាយខុសទាំងស្រុងថា នៅក្នុងសាសនាយើង មានធម៌ថ្មី-ធម៌ចាស់ ។ តាមការពិត យើងពុំមានធម៌ពីរទេ ។ មានតែមួយគត់ ។ ដែលនិយាយថាធម៌ថ្មីនោះ គឺការដែលខំសំរិតសំរាំងព្រះសាសនាឲ្យផុតអំពីជំនឿខុស អំពីការយល់ហួសហេតុផល និងអំពើទម្លាប់ខុស គឺពុំមែនធ្វើឲ្យពុទ្ធសាសនាទៅជាបែបថ្មីទេ ។ ការពិត គឺធ្វើឲ្យព្រះសាសនាត្រឡប់ទៅរកប្រភពដើម ដ៏ត្រឹមត្រូវល្អវិញតែប៉ុណ្ណោះ ។

o × o

ជាមួយនឹងឯកភាពជាតិ ភាសាជាតិត្រូវមាននាទីដ៏ធំ ហើយបំពេញមុខងារដ៏ខ្ពង់ខ្ពស់ ។ ខ្មែរយើងក៏បានរៀបចំភាសាជាតិឲ្យទៅជាឧបករណ៍សំរាប់ប្រើឲ្យសមទៅតាមការចាំបាច់នៃឯកភាពជាតិ ។ សម្ដេចជាអម្ចាស់ព្រះអង្គបានដឹកនាំប្រជាជាតិក្នុងការប្រើពាក្យនីមួយៗឲ្យចំន័យល្អត្រឹមត្រូវ ។ ព្រះអង្គព្រះរាជបញ្ជាឲ្យចៀសវាងនូវការប្រឡំ ក្នុងការជ្រើសរើសពាក្យ ហើយនិងការប្រើពាក្យផ្ទុយខុសអំពីគំនិត ។ ព្រះអង្គបានដឹកនាំឲ្យបំពេញនូវការកំណត់ក្បួនវេយ្យាករណ៍និងវាក្យសម្ពន្ធ នូវការបង្កើតពាក្យដើម្បីប្រើប្រាស់ក្នុងវិទ្យាសាស្ត្រ បច្ចេកទេស នយោបាយ និង អក្សរសាស្ត្រ ។

សម្តេចព្រះសង្ឃរាជទ្រង់គង់នៅជាប្រមុខ នៃចលនារៀបចំបែបថ្មីឲ្យស្រប តាមកាលសម័យនៃវប្បធម៌រីកចំរើននេះ ។ ទូលព្រះបង្គំ ខ្ញុំ សូមបន្ថែមថា ព្រោះបើព្រះអង្គមានវ័យចាស់ក៏ដោយ ក៏សម្តេចព្រះសង្ឃរាជ ទ្រង់នៅមាន សកម្មភាពណាស់ ។ ទ្រង់បានបង្កើតសមិទ្ធិច្រើនអនេកប្បការគឺព្រះអង្គនៅ មានភាពជាយុវវ័យនៅឡើយ ៗដ៏ពិតណាស់វរជន-អ្នកប្រាជ្ញក្មេងៗក៏ពុំអាច មានថាមភាពនិងប្រសិទ្ធិភាពស្មើនឹងព្រះអង្គបានឡើយ ។ នៅក្នុងពុទ្ធិក-វិទ្យាល័យ និងពុទ្ធិកមហាវិទ្យាល័យ នៅក្នុងគណៈកម្មការនានានិងអង្គការ ផ្សេង ៗ ខាងអក្សរសាស្ត្រ សម្តេចព្រះសង្ឃរាជទ្រង់ជាសាស្តា និងជា អ្នកចាត់ចែងដឹកនាំឧបត្ថម្ភជានិច្ច ៗជាងនេះទៅទៀតការងារដ៏ធ្ងន់ក្រៃលែង នេះពុំមែនតម្កល់ព្រះអង្គត្រឹមតែជាអ្នកនិពន្ធពហុផលប៉ុណ្ណោះទេ ពិសេស ព្រះអង្គជាកវីដែលក្រៅអំពីស្នាព្រះហស្តទាំងឡាយ គឺមានពាក្យពេចន៍ បទចម្រៀង "នគររាជ" ដែលទ្រង់និពន្ធនៅដើមរាជ្យរបស់ទូលបង្គំ ខ្ញុំ គឺក្នុងឆ្នាំ ១៩៤១ ។

អក្សរសាស្ត្រខ្មែរយើង ផ្នែកសាសនា, ទស្សនវិជ្ជា, វិទ្យាសាស្ត្រ និរុត្តិសាស្ត្រជាបាលីនិងជាសំស្ក្រឹត មានតម្លៃ មានឋានៈដ៏ខ្ពស់ឧត្តុង្គឧត្តម ណាស់នៅលើផ្ទៃពបអន្តរជាតិ និងក្នុងចំណោមនៃអត្ថបទនានាដ៏មានតម្លៃ នៃវប្បធម៌សកលលោក ។ ប៉ុន្តែ យើងមានសេចក្តីស្តាយចំពោះសភាព ទន់ខ្សោយនៃអក្សរសាស្ត្រផ្នែករឿងរ៉ាវធម្មតា ដូចជាប្រលោមលោក

ទុកជា ។ល។ បុព្វហេតុនៃសភាពទន់ខ្សោយនេះ គឺបណ្ដាលមកតែអំពីសម្ដេចនិងព្រះភិក្ខុសង្ឃជាអ្នកចេះដឹងយើង ព្រះអង្គពុំអាចចូលរួមបានក្នុងចលនាបែបនេះ ពីព្រោះខ្វះនូវវិន័យរបស់ព្រះអង្គ ។

អ្នកទទួលខុសត្រូវក្នុងវិស័យអក្សរសាស្ត្របែបធម្មតានេះ ច្រើនតែធ្លាក់ទៅក្នុងនយោបាយ ឬមនោគមវិជ្ជា ឬមួយជាអ្នកគិតតែពីរឿងរកចំណេញលុយ ដែលជាហេតុដឹកនាំគេ ឲ្យធ្លាក់ទៅក្នុងផ្លូវផ្ទុយនឹងសីលវិជ្ជា ឬមួយផ្លូវថោកទាប ។ ចំណែកឯជនរួមជាតិយើង ដែលមានគំនិតវិជ្ជាអន្តរជាតិ ឬ មួយមិនប្រសប់ប្រើនូវភាសាជាតិ ដោយពុំយល់ជ្រៅជ្រះ ឬ មួយជាប់រវល់នឹងមុខងារខាងនយោបាយ ឬ ក្នុងមុខក្រសួងរដ្ឋការវិញ ក៏ជាឧបសគ្គរារាំងពុំឲ្យគេចូលមកជួយលើកតម្កើងអក្សរ-សាស្ត្រជាតិរបស់ខ្លួនបានៗតែក្នុងខណៈនេះ ស្នាព្រះហស្តដ៏ល្អលើសលុបនិងមិនចេះសាបសូន្យនៃសម្ដេចព្រះសង្ឃរាជ ជួន ណាត តែមួយព្រះអង្គនេះ ក៏គ្រប់គ្រាន់បរិបូណ៌នឹងបញ្ចាំងនូវរស្មីចែងចាំង នៃអក្សរសាស្ត្ររបស់ប្រទេសជាតិយើងទាំងមូល ទៅលើឆាកអន្តរជាតិ ។ គឺជាកិត្តិសំណាងធំអស្ចារ្យរបស់យើង ដែលមានព្រះអង្គសម្ដេចជាបុត្រនៃកម្ពុជរដ្ឋ ។ រួចមកហើយ សម្ដេចព្រះអង្គជា "ព្រះពជា,, នៃព្រះសាសនាដ៏វិសិដ្ឋរបស់យើង, ហើយពិសេសទៅទៀត ប្រវត្តិសាស្ត្រច្បាស់ជាទទួលកត់ត្រាទុកព្រះអង្គជា "ព្រះពជា" នៃអក្សរសាស្ត្រខ្មែរជាប្រាកដ ។

៨

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៩ ខែ សីហា

ព.ស. ២៥១០ គ.ស. ១៩៦៧

– ភ្នំពេញ –

ÉCOLE FRANÇAISE D'EXTRÊME-ORIENT BIBLIOTHÈQUE F.205 P.C.

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

ទំព័រ

## ផ្នែកសាសនា


១ – បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . ៧៧៩

២ – សម្ដែងអំពីសុខនិងទុក្ខ ដែលកើតអំពីកម្ម ព្រះសាសនមុនី កិម-ទូ រៀបរៀង . ៧៨៩


## ផ្នែកអក្សរសាស្ត្រ


៣ – ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ិន-គីមសៀ រៀបរៀង (ត) . . . ៨០៤

៤ – វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង–ខាត់ រៀបរៀង (ត) . . . . . ៨១២

៥ – បណ្ដាំកសិករខ្មែរ ដោយសហ. អ៊ុង-ស៊ុមន៍ . . . . . . . . . ៨១៦

៦ – ឯកសារ សាស្ត្រាស៊ីកវិតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . ៨២៥

៧ – រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៨៣៦

៨ – ឯកសារកម្ពុជសុរិយា លោក ឱ.គាម ប្រមូលរៀបរៀង (ត) . . . . . . ៨៤៤

៩ - ជីវប្រវត្តិ ព្រះមុនីកោសល សួរ-ហាយ ចៅអធិការវត្តទីពោធិវង្ស អធិបតីរង
ក្រុមជំនុំព្រះត្រៃបិដក . . . . . . . . . . . . . . . . ៨៥៨

## ផ្នែកកំណត់ និង ប្រវត្តិការណ៍


១០ - សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ ក្នុងខែមិថុនា និង កក្កដា ១៩៦៧ . . . . . ៨៨២

១១ - ពិធីប្រគល់បរិញ្ញាប័ត្រនៃពុទ្ធិកមហាវិទ្យាល័យ . . . . . . . . . . ៨៨៥

– សុន្ទរកថា របស់សហជីវិនអគ្គលេខាធិការ ពុទ្ធិកមហាវិទ្យាល័យ . . . . ៨៨៦

– សុន្ទរកថា ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ. . . . . . . ៨៩៨



មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជារ ២៣០៛០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុសខាត់ចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ថាំង ប្រែ - រៀបរៀង

ប្ញ. ចូរអ្នកនាំឧទាហរណ៍ជាសំអាងបន្តិចមកមើល?

វិ. (មានកាលថ្ងៃមួយ) ព្រះអានន្ទត្រាច់ទៅដិតអណ្ដូងទឹកមួយមានការស្រេកទឹក ក៏បិណ្ឌបាតទឹកនាងប្រក្រតី ដែលជាធីតានៃជនចណ្ឌាល ។ នាងនោះ ក៏ទូលតបទៅព្រះអានន្ទវិញថា ខ្ញុំម្ចាស់ជាកូនចណ្ឌាល ថោកទាបណាស់ លោកម្ចាស់ឆាន់ទឹកដែលខ្ញុំម្ចាស់នឹងប្រគេននេះ សេចក្ដីសៅហ្មងនឹងឆ្លងជិតជាមដល់លោកម្ចាស់ពុំខាន ។ ព្រះអានន្ទតបទៅវិញថា "អាត្មាពុំបានបិណ្ឌបាតវណ្ណៈទេ គឺសុំទឹកឆាន់ទេតើ" ។ នាងនោះក៏មានបត្តិកករាយ ហើយប្រគេនទឹកដល់ព្រះអានន្ទ ។ ព្រះពុទ្ធជាម្ចាស់ជ្រាបហើយ ក៏ទទួលអនុមោទនា ។

ប្រ. ក្នុងសេលសូត្រ ព្រះបរមគ្រូទ្រង់សំដែងអំពីមនុស្សម្នាក់ក្នុងពួក "បរិយសោបាក" ថា ដូចម្តេច?

វិ. ថា ដោយការបំពេញកុសលធម៌ បុរសនោះក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញទូទៅ, ថា ពួកក្សត្រិយ៍និងព្រាហ្មណ៍ សឹងនាំគ្នាចូលទៅបំរើ លុះរំលាងខន្ធទៅ បុរសនោះនឹងបានទៅកើតក្នុងព្រហ្មលោក; ឯពួកព្រាហ្មណ៍ទាំងឡាយ នឹងធ្លាក់ទៅក្នុងនរក ដោយអកុសលកម្មរបស់ខ្លួន ។

ប្រ. ព្រះពុទ្ធសាសនាប្រដៅថាដួងព្រលឹងនឹងមិនចេះរលត់ឬ ?

វិ. ពាក្យថាព្រលឹង ដែលអ្នកលង់ខ្លៅប្រើនោះ ព្រះពុទ្ធសាសនាសំគាល់ថាជាគំនិតខុស ។ កាលបើវត្ថុ ឬ ធម្មជាតិទាំងអស់ប្រែប្រួលហើយ មនុស្សក៏ដូច្នោះដែរ សរីរៈរាងកាយក៏សឹងតែប្រែក្លាយគ្មានសល់ទាំងអស់ - វត្ថុដែលលុះដោយសេចក្តីបរិត ប្រែប្រួលហើយគ្មានខ្លឹមអ្វីទេ, ហេតុដូច្នេះ គ្មានវត្ថុអ្វីមួយដែលតាំងនៅជានិច្ចថិតថេរសោះឡើយ ។

ប្រ. ហេតុដូចម្តេចក៏មានទំនាស់នឹងពាក្យថាព្រលឹងនេះ?

វិ. សព្ទនេះ នាំឲ្យយល់ថាមនុស្សជាភាគមួយ ដែលឃ្លាតចេញអំពីភាគដទៃ ហើយជាចំណែកនៃភពទាំងមូលផង ។ គំនិតនេះមិនឈ្មោះថាត្រឹមត្រូវឡើយ ទោះបីក្នុងវិទ្យាសាស្ត្រ ក៏ពុំមានគ្រឿងអាងដែរ ។

ប្រ. បើដូច្នោះ គ្មានពាក្យថា "ខ្ញុំ" ដោយឡែក ឬ យើងនឹងហៅរបស់នេះនោះថា"ជារបស់ខ្ញុំ"ដូច្នេះ ពុំបានទេឬ?

វិ. ពិតមែនហើយ, មានតែជាគុម្ពានទេ យើងនិងសត្វទាំងពួងនិងវត្ថុទាំងអស់ គ្រាន់តែជាចំណែកប៉ុណ្ណោះ ។

ប្រ. បើត្រង់ដែលថា មនុស្សមាន "ព្រលឹង" នៅដោយឡែកពីប្រាណនោះ ត្រូវបដិសេធទៅហើយ ចុះអ្វីដែលនាំឲ្យមនុស្សម្នាក់ ៗ ដឹងថាខ្លួនមានអត្តភាពតាំងនៅបិតថេរនោះ ?

វិ. គឺតណ្ហា ឬ សេចក្តីប្រាថ្នា ចំពោះការរស់នៅជាមនុស្សក្នុងលោកនេះ ។ សត្វណាដែលត្រូវបានទទួលផលបុណ្យ ឬ ផលបាប បើនៅមានសេចក្តីប្រាថ្នានេះ នឹងមានជាតិជាថ្មីទៀតតាមយថាកម្មរបស់ខ្លួន ។

ប្រ. ចុះអ្វីដែលនាំឲ្យមានបដិសន្ធិ?

វិ. គឺវិញ្ញាណក្ខន្ធ ឬ ដួងវិញ្ញាណ ដែលកើតឡើងអំពចិត្តគំនិតជាក្រោយបង្អស់ របស់បុគ្គលដែលជិតដល់នូវមរណកាល ។

ប្រ. ខន្ធមានប៉ុន្មានយ៉ាង?

វិ. មាន ៥ យ៉ាង ។

ប្រ. ចូររាប់មកមើល?

វិ. រូប, វេទនា, សញ្ញា, សង្ខារ និង វិញ្ញាណ ។

ប្រ. ចូរអធិប្បាយពីខន្ធនីមួយៗ មកមើល?

វិ. រូបជាគ្រោងកាយខាងក្រៅ, វេទនាជាការសោយ ឬទទួលនូវអារម្មណ៍, សញ្ញាជាធម្មជាតិដែលសំគាល់នូវអារម្មណ៍, សង្ខារជាសភាវៈដែលគុបតែងបង្កើតជានេះជានោះ, វិញ្ញាណជាធម្មជាតដឹងនូវអារម្មណ៍ ឬមនោ ។ កងកាយរបស់យើង ត្រូវប្រកបព្រមដោយខន្ធទាំងនេះ ចំពោះខ្លួនយើង ដែលប្រព្រឹត្តទៅក្នុងការរស់នៅ ត្រូវពឹងប្រាស្រ័យនឹងរបស់ដែលនៅជុំវិញយើង ដោយសារបញ្ចក្ខន្ធនេះ ។

ឬ. ហេតុម្តេច បានជាមនុស្សយើងមានរូបខុសគ្នា ប៉ើមានខន្ធប្រាំដូចគ្នាទេ?

វិ. ដោយកម្មនៃបុគ្គលនីមួយៗ ដែលបានបំពេញអំពីអតីតជាតិ ។

ឬ. ធម្មជាតិអ្វី ដែលនាំឲ្យកម្មមានកម្លាំង មានអានុភាព អាចនាំសត្វឲ្យមានជាតិកំណើតជាថ្មី?

វិ. គឺសេចក្តីប្រាថ្នាឲ្យជីវិតតាំងនៅ ។

ឬ. ដែលថា សត្វស្លាប់កើតវិញនោះ តើអាងដល់ធម៌ណា?

វិ. អាងដល់កុសលនិងអកុសលមួយ ដែលជាគ្រឿងទ្រទ្រង់ នឹងបដិច្ចសមុប្បាទធម៌ ដែលមានអវិជ្ជាជាបច្ច័យឲ្យកើតឡើង ។ ពួកពុទ្ធមាមកជនមិនជឿថា ជីវិតរបស់មនុស្ស ទុកជារស់នៅប្រមាណ ៥០០ ឆ្នាំ ឬកំលើសពីនេះនោះ ដើម្បីនឹងទទួលផ្សេង ឬទណ្ឌកម្មផ្ទាល់ខ្លួនដូច្នេះទេ គឺបុគ្គលនីមួយៗ ដែលអន្ទោលទៅមកក្នុងសង្សារវដ្ត ដោយយឺតយូរ ឬ

ដាប់រហ័សនោះ មកពីកម្លាំងផលបុណ្យបាប ដែលខ្លួនបានប្រព្រឹត្តក្នុងភពនោះ ។ ៕

ប្រ. បញ្ចក្ខន្ធ ឬ រូបកាយមនុស្សថ្មីនេះ ជារូបដដែលពីក្នុងជាតិមុន ដោយតណ្ហានាំមកបង្កើត ឬ ដូចម្តេច?

វិ. មិនមែនជារូបដដែលទេ ទាំងជារូបដទៃក៏មិនមែនដែរ ។ នៅក្នុងជាតិនេះ ខន្ធទាំង ៥ ក៏សឹងប្រែប្រួលជាដរាប ឧបមាដូចជា មនុស្សម្នាក់ឈ្មោះក អាយុ ៤០ ឆ្នាំ ជាអ្នកដែលនៅមានរូបរាងកាយដូចមាណពឈ្មោះក កាលនៅក្មេងអាយុ ១៨ ឆ្នាំដោយពិត តែដោយសេចក្តីចាស់គ្រាំគ្រាប្រែប្រួលគ្មានឈប់ឈរនៃរូបកាយ ដោយការផ្លាស់ប្តូរចរិតចិត្តគំនិតនិងកិរិយាប្រព្រឹត្តជាលំដាប់មក ក៏ត្រឡប់ទៅជាបុគ្គលដទៃ ពីកាលមុនស្រឡះ ។ កាលបើសេចក្តីចាស់ជរាមកដល់ហើយ ឈ្មោះក ក៏ត្រូវទទួលផលកម្ម បុណ្យទោសទុក្ខលំបាក ដែលកើតមកអំពីចិត្តគំនិត និងអំពើកម្មអាក្រក់ ដែលខ្លួនបានប្រព្រឹត្តជាលំដាប់មកក្នុងជីវិតរបស់ខ្លួន ។ ហេតុនេះ បុគ្គលដែលកើតថ្មីទៀតនោះ គឺជាបុគ្គលដដែលពីមុន គ្រាន់តែផ្លាស់ទ្រង់ទ្រាយរាងកាយនិងខន្ធ ជាថ្មីប៉ុណ្ណោះ ហើយជាអ្នកទទួលកម្រៃផលដែលកើតពីចិត្តគំនិតនិងកម្ម ពីជាតិមុននោះឯង ៕

ប្រ. មនុស្សចាស់-ជរា អាចនឹករឭកឃើញហេតុភេទ ដែលខ្លួនបានជួបប្រទះកាលនៅពីក្មេងនោះ ទោះបីសរីរៈរាងកាយនិងស្មារតី ប្រែ

ប្រលះទៅកំណើតដោយ សឹងអាចចាំបានទាំងអស់ តែហេតុម្តេច ក៏ក្នុងជាតិនេះ យើងពុំដឹងនូវជាតិកំណើតរបស់ខ្លួនពីមុនមកផង?

វិ. ព្រោះស្មារតី ក៏អាស្រ័យនឹងខន្ធដែរ, កាលបើបញ្ចក្ខន្ធនេះបានប្រែប្រួលបដិសន្ធិក្នុងបច្ចុប្បន្នជាតិនេះទៅហើយ ស្មារតីថ្មីក៏ត្រូវកើតមានវិញដែរ ។ តែទោះយ៉ាងណា ក៏គង់នៅមានអ្នកនឹកឃើញហេតុការណ៍ពីជាតិមុនមកដែរ ដូចយ៉ាងព្រះសិទ្ធត្ថបរមពោធិសត្វ កាលទ្រង់បានត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធហើយ, ព្រះអង្គក៏ជ្រាបច្បាស់គ្មានសល់ចនោះអំពីជាតិមុនៗមក, ប្រសិនបើហេតុការណ៍ទាំងនោះ គ្មានសល់ស្មារតីខ្លួនទេ, ព្រះអង្គក៏ពុំអាចជ្រាបច្បាស់បានឡើយ ។ បុគ្គលណាដែលបានសម្រេចចតុត្ថជ្ឈាន នឹងអាចនឹកឃើញហេតុការណ៍ក្នុងបុព្វជាតិរបស់ខ្លួនបានដោយពិត ។

ប្ញ. ការផ្លាស់ប្តូរនៃខន្ធនេះ នឹងមានទីបំផុតត្រឹមណា?

វិ. ត្រឹមព្រះនិព្វាន ។

ប្ញ. ព្រះពុទ្ធសាសនា មានប្រដៅថា ត្រូវតែឲ្យយើងធ្វើអំពើល្អដើម្បីបានសម្រេចព្រះនិព្វាន ឬដូចម្តេច?

វិ ទេ. ប្រសិនបើសេចក្តីប្រាថ្នានេះ ចំពោះទៅតែការចង់បានមាសប្រាក់ រាជសម្បត្តិ ឬ សេចក្តីត្រេកក្នុងកាមគុណនោះ គឺជាកិច្ចបំពេញតណ្ហាទេ ។ ព្រះនិព្វាន ពុំមែនសម្រេចដោយសេចក្តីប្រាថ្នាយ៉ាងនេះទេ

ហើយអ្នកដែលធ្វើដូច្នេះ នឹងជួបប្រទះតែសេចក្ដីទោមនស្សៈ [illegible]

ប្រ. ចូរអ្នកអធិប្បាយពន្យល់រឿងនេះ ឲ្យពិស្ដារបន្តិចមកមើល?

វិ. ពាក្យថា ព្រះនិព្វាន ជាគូគាប់នឹងការបូលះបង់ដំរែក [illegible] មនុញ្ញាណ ។ មនុស្សល្ងង់ខ្លៅ ច្រើនច្រឡំថាបែកសេចក្ដីសុខក្នុងព្រះនិព្វាន គ្មានគិតថា ព្រះនិព្វាននោះ យ៉ាងដូចម្ដេចទេ ។ ការគ្មានចិត្តអស្សុប្បសេចព្រះនិព្វាន, ការប្រព្រឹត្តធ្វើអំពើល្អ ដើម្បីជាប្រយោជន៍នៃខ្លួន ឬ បួសជាតាបស ដោយមានបំណងចង់បានសេចក្ដីរីករាយសប្បាយក្នុងឋានសួគ៌ គុំមែនជាផ្លូវនៃព្រះនិព្វាន ដែលព្រះបរមគ្រូទ្រង់ត្រាស់សំដែងទេ ។ ការសេពនៅនៃព្រះអរិយៈទាំងឡាយ ប្រពៃពន់ពេកណាស់, លោកគ្មានបំណងចង់បានសេចក្ដីសុខក្នុងភពទាំងបីនេះទេ ។ បុគ្គល អាចបានសំរេចផ្លូវព្រះនិព្វានក្នុងលោកនេះដោយពិត ។

ប្រ. ចូរអ្នករៀបរាប់អំពីចំណងដែលរតែរសត្វ មិនឲ្យបានសេចក្ដីចម្រើន ១០ ប្រការ ដែលលោកហៅថា «សំយោជនៈ» នោះមកមើល?

វិ. គឺសេចក្ដីប្រកាន់ខ្ជាប់ថា រូបកាយជារបស់ខ្លួន (សក្កាយទិដ្ឋិ), សេចក្ដីសង្ស័យ (វិចិកិច្ឆា), ការប្រកាន់ជឿស៊ប់មន្ដអាគមនិងវត្តប្រតិបត្តិផ្សេង ( សីលព្វតបរាមាស ), តម្រេកក្នុងកាមគុណ ( កាម ), សេចក្ដីចងគំនុំអន់ចិត្ត ( បដិឃ ), ការពេញចិត្តនឹងរូបភព ( រូបរាគៈ ), ការពេញចិត្តនឹងអរូបភព ( អរូបរាគៈ ), អំនួតវឹងឫក ( មានៈ ), ចិត្តរវើ-

វាយកយមាយ, (ទុក្ខៈ) សេចក្តីល្ងង់ខ្លៅ (អវិជ្ជា) ។

ប្រ. ដើម្បីឲ្យបានដល់នូវព្រះអរហត្ត គេត្រូវកំចាត់ចោលចំណងនេះប៉ុន្មាន?

វិ. ត្រូវកំចាត់ចោលទាំងអស់ ។

ប្រ. ធម៌ជាគ្រឿងរាំងខ្ទាំងខ្ទប់ទាំងប្រាំប្រការ ដែលលោកហៅថា "នីវរណៈ" គឺអ្វីខ្លះ?

វិ. គឺកាមច្ឆន្ទៈ, ព្យាបាទ, ថីនមិទ្ធៈ, ឧទ្ធច្ចៈ, កុក្កុច្ចៈ និង វិចិកិច្ឆា ។

ប្រ. ហេតុដូចម្តេច ក៏ពាក្យប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ ខាងផ្លូវចិត្តចេតសិក សុទ្ធតែប្រកបដោយចំណែកល្អិតល្អន់ខ្លាំងម្ល៉េះ? ហេតុនេះនឹងនាំឲ្យអាចកបុគ្គលសេមរសោមគំនិត ដោយពិតឬ?

វិ. ដើម្បីជាជំនួយដល់យើង ឲ្យដឹងស្គាល់នូវអត្តភាពរបស់ខ្លួន ឲ្យគំនិតយើងមានទម្លាប់ស្គាល់ហេតុនីមួយៗឲ្យបានគ្រប់ប្រការ ។ ដោយការគិតរំពឹងនេះ យើងនឹងអាចដឹងស្គាល់នូវធម៌ដោយជាក់ស្តែង ។ អាចារ្យទាំងពួងក្នុងព្រះពុទ្ធសាសនា តែងណែនាំឲ្យចម្រើនផ្លូវបញ្ញាតាមគន្លងនេះឯង ។

ប្រ. បណ្តាសាវ័កទាំងអស់ របស់ព្រះបរមគ្រូ មានប៉ុន្មានអង្គ ដែលមានកិត្តិស័ព្ទល្បីល្បាញក្នុងផ្លូវវិជ្ជាផ្សេងៗ ។

វិ. មាន ៨០ ព្រះអង្គ គេសន្មតហៅថា "ព្រះអសីតិមហាសាវ័ក" ។

ប្រ. ព្រះពុទ្ធជាម្ចាស់ ព្រះអង្គត្រាស់ដឹងអ្វីខ្លះ?

វិ ព្រះអង្គជ្រាបច្បាស់ នូវត្រៃលោក, វិជ្ជានិងអវិជ្ជា. ហេតុជាកុសលនិងអកុសល, ចិត្តគំនិតរបស់អ្នកដទៃ, ការសោយអារម្មណ៍ និងផ្លូវកំចាត់បង់នូវតណ្ហា, ព្រះអង្គជ្រាបច្បាស់ នូវចុតិនិងបដិសន្ធិរបស់សត្វនិងហេតុដទៃទៀតជាអនេក ។

ឫ. ធម៌ជាប្រធាននៃពាក្យប្រៀនប្រដៅ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ គេហៅថាដូចម្ដេច?

វិ. ហៅថា បដិច្ចសមុប្បាទធម៌ ។

ឫ. ចុះធម៌នេះ ងាយយល់ងាយចូលចិត្តឬទេ?

វិ. ធម៌នេះ ជ្រៅ ពិបាកយល់ណាស់ គឺមានអត្ថដ៏ជ្រាលជ្រៅធំទូលាយក្រៃពេក ហួសវិស័យនៃអ្នកដែលពុំបានបំពេញផ្លូវបញ្ញាយល់ចាក់ធ្លុះបាន ។

ឫ. ព្រះពុទ្ធឃោសាចារ្យ ដែលជាអដ្ឋកថាចារ្យយ៉ាងឯក នោះលោកយល់ដូចម្ដេច ក្នុងធម៌នេះ?

វិ. លោកពោលត្អូញត្អែរថា ពុំអាចយល់សព្វគ្រប់ក្នុងធម៌ដ៏ជ្រាលជ្រៅនេះដែរ ហាក់ដូចជាមនុស្សសាត់អណ្ដែតក្នុងទឹកមហាសមុទ្ររកគោះត្រើយពុំឃើញ ។

ឫ. ហេតុដូចម្ដេច ក៏ក្នុងមហាបរិនិព្វានសូត្រ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងថា " ធម៌វិន័យរបស់តថាគត ។ គ្មានលាក់ទុកដូចសាសនា

ដទៃ ដែលមានវត្តកាប់ទុកក្នុងដៃនោះទេ, បើព្រះធម៌ទាំងមូលរបស់ព្រះអង្គសឹងជាវិស័យនៃបុគ្គលទាំងពួង ហេតុម្តេចក៏ព្រះពុទ្ធឃោសាចារ្យ ដែលជាអ្នកប្រាជ្ញយ៉ាងធ្ងន់ នៅពោលថា ពិបាកយល់ជាក់បានដូច្នេះ?

វិ. ព្រះពុទ្ធជាម្ចាស់ សំដៅសេចក្តីថា ព្រះអង្គបានត្រាស់សំដែងប្រាប់សព្វគ្រប់ទាំងអស់ គ្មានសល់លាក់ទុកនៃណាទេ ។ ឯអត្ថរសរបស់ព្រះធម៌នេះ អ្នកមានប្រាជ្ញាចម្រើនក្លៃ អាចយល់ចាក់ធ្លុះបានដោយងាយ ពុំកំបាំងឡើយ ។ ចំណែកខាងអ្នកដែលនៅមានសេចក្តីល្ងង់ ទើបកំបាំងមិនយល់មែន ។

ព្រ. ចុះដំណើរដែលព្រះបរមគ្រូទ្រង់ប្រៀនប្រដៅ ដល់វេនេយ្យ-សត្វនោះ ទ្រង់សំដែងបញ្ជាក់សេចក្តីនេះឬទេ?

វិ. ព្រះអង្គទាញយកអតីតនិទាន និងយកសេចក្តីងាយៗមកពន្យល់ដល់សត្វដែលនៅងឹតល្ងង់, សត្វណាដែលដឹងគ្រាន់បើ ព្រះអង្គប្រៀនប្រដៅសុត្តន្តបិដក, ព្រះអង្គបញ្ញត្តិវិនយបិដក ដើម្បីគ្រប់គ្រងពួកភិក្ខុ និងឧបាសក, ឯចំណែកអភិធម្មបិដក ដែលជាផ្លូវបរមត្ថ ព្រះអង្គប្រោសសំដែងតែដល់បុគ្គលអ្នកមានប្រាជ្ញាចាស់ក្លាហើយ ។

(នៅមានត)

## សម្ដែងអំពី

# សុខ និង ទុក្ខ

ដែលកើតអំពី

# កម្ម

(គ)

ព្រះសាសនមុនី កិម-ទួរ ក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

## អនាថបិណ្ឌិកសេដ្ឋី កសាងវត្តជេតពន

*ក្នុងផ្ទៃរឿងនេះ មានសេចក្ដីពិស្ដារវែង ប៉ុន្តែក្នុងទីនេះ សូមពណ៌នាដោយសង្ខេបថា អនាថបិណ្ឌិកសេដ្ឋី ទៅកាន់ក្រុងរាជគ្រឹះ ដោយមានករណីយកិច្ចអ្វីមួយ ក៏បានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ ៗ ក្នុងខណៈនោះ ព្រះអង្គទ្រង់សំដែងអនុបុព្វីកថា គឺ ទានកថា ( និយាយពីការឲ្យទាន ) ១ សីលកថា ( និយាយពីការរក្សាសីល ) ១ សគ្គកថា ( និយាយពីឋានសួគ៌ ) ១ កាមាទីនវកថា ( និយាយពីទោសនៃកាម ) ១ នេក្ខម្មានិសំសកថា ( និយាយពីអានិសង្សនៃការចេញចាកកាម ឬ ការចេញកសាងផ្នួស ) ១ ចំពោះអនាថបិណ្ឌិកសេដ្ឋី ៗ ព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់ថា កាលណាអនាថបិណ្ឌិកសេដ្ឋី មានចិត្តទន់ស្រួល មាន*

ចិត្តប្រាសចាកនីវរណធម៌ មានចិត្តរីករាយជ្រះថ្លា, ក៏ធម្មទេសនាណា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង ព្រះអង្គក៏ទ្រង់ប្រកាសនូវធម្មទេសនានោះ គឺសច្ចៈទាំង ៤ គឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច និង មគ្គសច្ច ក្នុងកាលណោះ ៗ ប្រៀបដូចសំពត់ដ៏ស្អាត ដែលមិនទាន់មានពណ៌ទៅ តែងទទួលយកនូវទឹកជ្រលក់ដោយប្រពៃ យ៉ាងណាមិញ, ក៏ដូចជាធម្មចក្ខុ គឺសោតាបត្តិផល មានធូលីទៅប្រាសហើយ មានមន្ទិលទៅប្រាសហើយ ក៏បានកើតឡើងដល់អនាថបិណ្ឌិកសេដ្ឋី លើអាសនៈនោះ ដូច្នេះថា ធម្មជាតណាមួយ មានសភាពកើតឡើងហើយជាធម្មតា ធម្មជាតទាំងអស់នោះ មានសភាពរលត់ទៅវិញជាធម្មតា ។

គ្រានោះ អនាថបិណ្ឌិកសេដ្ឋី បានឃើញធម៌ហើយ មានចិត្តចុះកាន់ធម៌ស៊ប់ហើយ ឆ្លងចាកសេចក្ដីសង្ស័យហើយ ដល់នូវសេចក្ដីក្លៀវក្លា លែងជឿនូវពាក្យនៃជនដទៃក្នុងសាសនារបស់ព្រះបរមសាស្ដា ហើយក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា អភិក្កន្តំ ភន្តេ បពិត្រព្រះអង្គដ៏ចំរើន, ពីរោះពេកណាស់ ! ធម៌ដែលព្រះអង្គទ្រង់សំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ភ្លឺច្បាស់ណាស់ គួរនាដូចជាមនុស្សបើកវត្ថុដែលគេផ្កាប់ឲ្យផ្ងារឡើង ឬដូចជាមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំងទុក ពុំនោះសោត ដូចគេប្រាប់ផ្លូវដល់មនុស្សវង្វេង

ឬដូចជាគេកាន់ចង្កៀងក្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែក នឹងមើលឃើញនូវរូបទាំងឡាយបាន ។ លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋី បានប្រកាសប្រគល់ខ្លួនជាឧបាសក ដល់នូវត្រៃសរណគមន៍ថា ឯសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរឭក សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់ហើយនូវព្រះត្រៃសរណគមន៍ស្មើដោយជីវិត ចាប់ដើមតាំងអំពីថ្ងៃនេះជាដើមរៀងទៅ ។

មួយយ៉ាងទៀត បពិត្រព្រះអង្គដ៏ចំរើន, សូមព្រះមានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃ ទទួលនិមន្តរបស់ខ្ញុំព្រះអង្គ ដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីបានដឹងច្បាស់ថា ព្រះអង្គទ្រង់ទទួលនិមន្តហើយ ក៏ថ្វាយបង្គំលាព្រះមានព្រះភាគក្រោកចាកអាសនៈ ធ្វើប្រទក្សិណ រួចថយចេញទៅ ។ កាលរាត្រីនោះកន្លងទៅហើយ អនាថបិណ្ឌិកសេដ្ឋី ក៏ឲ្យជនទាំងឡាយតាក់តែងខាទនីយភោជនីយាហារដ៏ឧត្តម ក្នុងគេហដ្ឋានរបស់រាជគហសេដ្ឋីជាបងថ្លៃ រួចហើយក៏ប្រើគេឲ្យទៅក្រាបបង្គំទូលភត្ត-

កាលចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន, កាលគួរហើយ ភត្តកិច្ចសម្រេចហើយ ។ នៅក្នុងវេលាបុព្វណ្ហសម័យ ព្រះសម្ពុទ្ធទ្រង់ពុទ្ធដំណើរទៅកាន់លំនៅរបស់កឌគហសេដ្ឋី ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ជាមួយនឹងភិក្ខុសង្ឃ ។ អនាថបិណ្ឌិកសេដ្ឋី បានអង្គាសថ្វាយខាទនីយភោជនីយាហារដ៏មានរសឆ្ងាញ់ពិសាដោយដៃខ្លួនឯងចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន, លុះដល់ទីបំផុតនៃភត្តកិច្ចហើយ ទើបក្រាបបង្គំទូលពាក្យនេះនឹងព្រះមានព្រះភាគថា អធិវាសេតុ មេ ភន្តេ ភគវា សាវត្ថិយំ វស្សាវាសំ សទ្ធឹ ភិក្ខុសង្ឃេន បពិត្រព្រះអង្គដ៏ចំរើន, សូមព្រះមានព្រះភាគជាមួយនឹងភិក្ខុសង្ឃ ទទួលនិមន្តគង់ចាំវស្សាក្នុងក្រុងសាវត្ថីរបស់យើងខ្ញុំព្រះអង្គ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតី ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុងលំនៅដ៏ស្ងប់ស្ងាត់តែម្យ៉ាង ។ អនាថបិណ្ឌិកសេដ្ឋី ក៏ក្រាបបង្គំទូលតបថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានយល់ច្បាស់ហើយ ។ ទើបព្រះមានព្រះភាគទ្រង់ពន្យល់អនាថបិណ្ឌិកសេដ្ឋីឲ្យឃើញព្រម ឲ្យកាន់យកព្រម ឲ្យទស្សាហ៍ព្រម ឲ្យរីករាយព្រម ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ទ្រង់ពុទ្ធដំណើរចេញទៅ ។

សម័យនោះឯង អនាថបិណ្ឌិកសេដ្ឋី ជាអ្នកមានមិត្តច្រើន មានសម្លាញ់ច្រើន មានពាក្យគួរឲ្យអ្នកផងកាន់យក លុះបានចាត់ចែងកិច្ចការ

របស់ខ្លួនដែលគួរធ្វើនោះ ក្នុងក្រុងរាជគ្រឹះរួចហើយ ក៏ត្រឡប់មកឯក្រុង
សាវត្ថីវិញ ។ កាលដល់ពាក់កណ្ដាលផ្លូវ អនាថបិណ្ឌិកសេដ្ឋី បាន
ប្រកាសប្រាប់មនុស្សទាំងឡាយថា ម្នាលអ្នកទាំងឡាយ ចូរអ្នករាល់គ្នា
ធ្វើអារាម សាងវិហារ ផ្ដើមធ្វើទានទៅ! ដ្បិតឥឡូវនេះ ព្រះពុទ្ធបាន
ត្រាស់ឡើងក្នុងលោកហើយ, ឯព្រះពុទ្ធអង្គនោះសោត ខ្ញុំក៏បាននិមន្ត
ហើយ ព្រះអង្គនឹងទ្រង់ពុទ្ធដំណើរមកតាមផ្លូវនេះឯង ។ គ្រានោះ
មនុស្សទាំងឡាយ ដែលអនាថបិណ្ឌិកសេដ្ឋីប្រកាសប្រាប់នោះ ក៏បាន
នាំគ្នាធ្វើអារាម សាងវិហារ និងផ្ដើមធ្វើទាន ។ វេលាដែលអនាថ-
បិណ្ឌិកសេដ្ឋីទៅដល់ក្រុងសាវត្ថីហើយ ក៏គយគន់រកមើលទីកន្លែងគ្រប់អន្លើ
ក្នុងក្រុងសាវត្ថី ដោយគិតថា ព្រះមានព្រះភាគ សមនឹងគង់នៅក្នុងទី
ណាហ្ន៎! ទីណាដែលមិនជិតពេក មិនឆ្ងាយពេកអំពីស្រុក ជាទីល្មមទៅ
ល្មមមកបានដោយស្រួល ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍
ងាយនឹងទៅមក ហើយជាទីមិនច្របូកច្របល់ក្នុងវេលាថ្ងៃ មានសំឡេង
តិច ឥតមានសំឡេងគឹកកង ជាទីមានខ្យល់បក់ស្រួល គួរដល់ការ
ពួនសម្ងំនៅនៃមនុស្សទាំងឡាយ ។ អនាថបិណ្ឌិកសេដ្ឋី បានឃើញ
ឧទ្យានរបស់ព្រះរាជកុមារព្រះនាម ជេត ជាទីមិនឆ្ងាយពេក មិនជិតពេក
អំពីស្រុក ល្មមពួកមនុស្សដែលត្រូវការដោយប្រយោជន៍អាចទៅមកបាន
ដោយងាយ, លុះបានឃើញដូច្នេះហើយ ក៏ចូលទៅរកព្រះរាជកុមារ

ជេត ថា បពិត្រព្រះអង្គម្ចាស់, សូមព្រះអង្គប្រទានឧទ្យានមកខ្ញុំព្រះអង្គ
ដើម្បីនឹងធ្វើអារាម ។ ព្រះអង្គម្ចាស់ជេត ឆ្លើយថា ម្នាលគហបតី
ឧទ្យានខ្ញុំឲ្យទៅអ្នកទទេពុំបានទេ លុះតែអ្នកឲ្យថ្លៃ គឺក្រាលដោយកោដិ
នៃកហាបណៈពេញទាំងអស់ ទើបឲ្យបាន ។ អនាថបិណ្ឌិកសេដ្ឋី
ឆ្លើយថា បពិត្រព្រះអង្គម្ចាស់, ឧទ្យាន ខ្ញុំព្រះអង្គប្រាកដជានឹងយក
ហើយ, ក៏ចាត់ចែងឲ្យគេផ្ទុកប្រាក់ដឹកដោយរទេះទាំងឡាយ មកចាក់
ក្រាលតម្រៀបដោយកហាបណៈក្នុងឧទ្យានរបស់ព្រះអង្គម្ចាស់ជេត ។
ប្រាក់ដែលដឹកនាំយកមកតែម្ដងប៉ុណ្ណោះមិនគ្រប់គ្រាន់ នៅសល់ទី
ឱកាសបន្តិច គ្រង់ជុំវិញក្លោងទ្វារ ទើបអនាថបិណ្ឌិកសេដ្ឋីបង្គាប់ឲ្យគេ
ទៅនាំយកប្រាក់មកថែមទៀត ដើម្បីនឹងក្រាលត្រង់ឱកាសនោះ ។
គ្រានោះ ព្រះអង្គម្ចាស់ជេត មានសេចក្ដីត្រិះរិះដូច្នេះថា គហបតីនេះ
ចំណាយប្រាក់ច្រើនដល់ម្លោះ ចំពោះកិច្ចណា កិច្ចនោះ មិនមែនជារបស់
ថោកទាបទេ, ហើយក៏និយាយនឹងអនាថបិណ្ឌិកសេដ្ឋីថា ណ្ហើយ
គហបតី, អ្នកកុំក្រាលត្រង់ទីឱកាសនោះឡើយ អ្នកចូរឲ្យទីឱកាសនោះ
ដល់ខ្ញុំ ទីដីនោះ ខ្ញុំទុកជាទានរបស់ខ្ញុំ រួមជាមួយនឹងអ្នកផង ។

និយមួយទៀត មានសេចក្ដីពណ៌នាក្នុងគម្ពីរបបញ្ចសូទនី អដ្ឋកថា
មជ្ឈិមនិកាយថា ទីដីនោះ គឺព្រះអង្គម្ចាស់ជេត បានដាំដើមឈើធំ-
តូច ថែទាំធ្វើជាព្រៃសួនឧទ្យាន មានលំអគួរជាទីរីករាយសប្បាយ សព្វ

ទ្រង់យាងទៅក្រសាលកំសាន្តមួយដងមួយកាល ហើយទ្រង់ត្រូវជាម្ចាស់ឧទ្យាននោះផង ព្រោះហេតុនោះ បានជាគេហៅ ឧទ្យាននោះថា ជេតវន ។ អនាថបិណ្ឌិកសេដ្ឋីចំណាយអស់ប្រាក់ ១៨ កោដិទិញដីឧទ្យាននោះអំពីព្រះអង្គម្ចាស់ជេត លុះបានដីឧទ្យាននោះហើយ ក៏ចំណាយប្រាក់ ១៨ កោដិទៀត ចាត់ការរៀបចំសាងសេនាសនៈផ្សេង ៗ ជាច្រើន មានគន្ធកុដិធំមួយ ប្រកបដោយលំអរុងរឿង ជាទីសម្រាប់ព្រះសម្មាសម្ពុទ្ធគង់ ជាដើម, លុះចាត់ចែងធ្វើអារាម ព្រមទាំងសេនាសនៈរួចសព្វគ្រប់ហើយ ក៏ចំណាយប្រាក់ ១៨ កោដិទៀត ធ្វើបុណ្យសម្ពោធឆ្លង ។ រួមការចំណាយទាំង ៣ លើក គឺចំណាយទិញដី, ចំណាយទិញគ្រឿងឧបសម្ភារៈធ្វើសេនាសនៈ, ចំណាយទិញរណ្តាប់បុណ្យ មានចីវរនិងខាទនីយភោជនីយាហារជាដើម ត្រូវជា ៥៤ កោដិប្រាក់ រួចហើយក៏វេរទីអារាមព្រមទាំងសេនាសនៈទាំងមូល ថ្វាយដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រោះហេតុនោះ បានជាព្រះគន្ថរចនាចារ្យទាំងឡាយ ចារឹកឈ្មោះនៃជនទាំងនោះទុកក្នុងខាងដើមនៃសូត្រជាច្រើន មានមង្គលសូត្រជាដើមថា ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ប្រែថា សម័យមួយព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិក-សេដ្ឋី ជិតក្រុងសាវត្ថី ។ ត្រង់ពាក្យថា ជេតវនេ នេះ គេចារឹក

ឈ្មោះអ្នកម្ចាស់ដើម គឺព្រះអង្គម្ចាស់ជេត ជាម្ចាស់ដីឧទ្យាន, ត្រង់ពាក្យថា អនាថបិណ្ឌិកស្ស អារាមោ នេះ គេហៅឈ្មោះអ្នកម្ចាស់ខាងក្រោយ គឺអនាថបិណ្ឌិកសេដ្ឋី ដែលបានទិញហើយចាត់ការកសាងអារាម ៗ បើមានពាក្យពោលសួរថា ការហៅឈ្មោះនៃជនទាំងនោះទុកដូច្នេះ នឹងមានផលប្រយោជន៍ដូចម្ដេច? ឆ្លើយថា មានប្រយោជន៍យ៉ាងសំខាន់ គឺហៅទុកជាពស្តុតាងឲ្យបច្ឆាជនទាំងឡាយ អ្នកប្រាថ្នាបុណ្យ បានឃើញហើយនឹងយកជាគម្រូតាមតទៅក្នុងអនាគត ៗ

## នាងវិសាខា កសាងវត្តបុព្វារាម

ថ្ងៃមួយ ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រមើលមើលសត្វលោក ក្នុងបច្ចូសសម័យ បានឃើញនូវសម្បត្តិ គឺឧបនិស្ស័យនៃសេដ្ឋីបុត្រម្នាក់ឈ្មោះ ភទ្ទិយៈ ដែលច្យុតចាកទេវលោកមកកើតក្នុងត្រកូលនៃសេដ្ឋីក្នុងភទ្ទិយនគរ, ព្រះអង្គទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះនៃអនាថបិណ្ឌិកសេដ្ឋីរួចហើយ ទ្រង់បែរព្រះភក្ត្រយាងទៅតាមទ្វារទិសខាងជើង ដើម្បីទៅសំដែងធម៌ប្រោសសេដ្ឋីបុត្រនោះឯង ៗ តាមប្រក្រតី ព្រះបរមសាស្ដា បើទ្រង់ទទួលភិក្ខាហារក្នុងផ្ទះនៃនាងវិសាខារួចហើយ ទ្រង់យាងចេញតាមទ្វារខាងត្បូងទៅគង់ក្នុងវត្តជេតពន, បើទ្រង់ទទួលនូវភិក្ខាហារក្នុងផ្ទះនៃអនាថបិណ្ឌិកសេដ្ឋីរួចហើយ ទ្រង់យាងចេញតាមទ្វារខាងកើតទៅគង់ក្នុងវត្ត

បុញ្ញកម ។ មនុស្សទាំងឡាយ កាលបើបានឃើញព្រះតថាគត ទ្រង់យាងសំដៅទៅកាន់ទ្វារទិសខាងជើង ហើយរមែងដឹងបានថា ព្រះអង្គទ្រង់ពុទ្ធដំណើរចេញទៅកាន់ចារិកជនបទខាងក្រៅ ។ ក្នុងថ្ងៃនោះ នាងវិសាខា គ្រាន់តែបានព្រដំណឹងថា ព្រះបរមសាស្តា ទ្រង់យាងចេញទៅតាមទ្វារខាងជើងហើយ ក៏ស្ទុះមីម្នាតាមទៅក្រាបថ្វាយបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, ខ្ញុំព្រះករុណាម្ចាស់ បានបរិច្ចាគទ្រព្យចំនួនប្រើនឲ្យគេសាងវិហារមួយថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះមេត្តាយាងត្រឡប់វិញ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវិសាខា, ដំណើរដែលតថាគតទៅនេះ ជាដំណើរមិនត្រឡប់វិញទេ ។ នាងវិសាខា ជាស្ត្រីមានប្រាជ្ញាឈ្លាសវៃ គិតឃើញថា ព្រះតថាគតទ្រង់ឃើញជនណាមួយដែលមានឧបនិស្ស័យគួរបានសម្រេចមគ្គផលដោយពិតហើយ បានជាព្រះអង្គមិនទ្រង់ត្រឡប់វិញ, ទើបនាងក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោសបើដូច្នោះសូមព្រះអង្គទ្រង់ចាត់ភិក្ខុមួយរូបដែលជាអ្នកចេះដឹងយល់ការគួរធ្វើនិងការពុំគួរធ្វើ ឲ្យដល់ខ្ញុំម្ចាស់ ហើយសឹមព្រះអង្គយាងទៅចុះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលវិសាខា, ការនេះសម្រេចនៅលើនាងចុះ បើនាងពេញចិត្តនឹងភិក្ខុណា ចូរទទួលបាត្ររបស់ភិក្ខុនោះទៅ ។ នាងវិសាខាធ្លាប់ស្រឡាញ់រាប់អានព្រះអានន្ទត្ថេរ ជាយូរមកហើយក៏ពិតមែន ប៉ុន្តែ នាងគិតថា ព្រះមហាមោគ្គល្លានត្ថេរ មានឥទ្ធានុភាពច្រើន បើបានលោក

មកជួយមើលការកសាងរបស់អាត្មាអញ ការនោះមុខជានឹងបានសម្រេចឆាប់ពុំខាន, លុះគិតឃើញដូច្នោះហើយ ក៏ទទួលយកបាត្រនិមន្តព្រះមហាមោគ្គល្លានទៅ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន, អ្នកចូរនាំយកភិក្ខុ ៥០០ រូបជាបរិវាររបស់អ្នក ត្រឡប់ទៅវិញចុះ ។ ព្រះមហាមោគ្គល្លាន ក៏បានថ្វាយបង្គំលាព្រះមានព្រះភាគ ហើយនិមន្តទៅកាន់ទីកន្លែងដែលនាងវិសាខាកសាងវិហារនោះឯង ។ ដោយអានុភាពនៃព្រះមហាមោគ្គល្លានត្រូវជាអ្នកចាត់ការ មនុស្សទាំងឡាយ ទៅនាំយកឈើនិងថ្មធំៗជាច្រើន ដោយរទេះ អំពីព្រៃ ចម្ងាយផ្លូវ ៥០ យោជន៍ខ្លះ ៦០ យោជន៍ខ្លះ បានមកដោយសុខស្រួល ឥតមានលំបាក ឬគ្រោះថ្នាក់បាក់កៀករទេះឡើយ ។ ការកសាងនោះ មិនយូរប៉ុន្មាន ក៏បានធ្វើប្រាសាទមួយមានជាន់ពីរហើយស្រេច, ជាន់ខាងក្រោមមានបន្ទប់ ៥០០, ជាន់ខាងលើ មានបន្ទប់ ៥០០ រួមជាប្រាសាទប្រដាប់ដោយបន្ទប់ ១.០០០ ។ នាងវិសាខា យល់ឃើញថា បើមានតែប្រាសាទមួយពេលតែឯងយ៉ាងនេះ ពុំសូវសមល្អឡើយ, នាងក៏បានបង្គាប់ឲ្យគេធ្វើប្រាសាទជាប្រធាន ៥០០ ប្រាសាទតូច ៥០០ និងសាលាវែង ៥០០ ទៀត បិតនៅព័ទ្ធជុំវិញប្រាសាទធំពីរជាន់នោះឯង, ឯកំពូលប្រាសាទនីមួយៗ នាងបង្គាប់ឲ្យគេធ្វើដោយជុំមាសទាំងអស់ ៕

គ្រានោះ ព្រះបរមសាស្តា ដែលទ្រង់យាងទៅកាន់ចារិកជនបទ

អស់ ៩ ខែ ហើយយាងត្រឡប់មកក្រុងសាវត្ថីវិញ ទ្រង់គង់ក្នុងមហាវិហារជេតពន ៗ ការកសាងប្រាសាទរបស់នាងវិសាខា បានប្រព្រឹត្តទៅអស់ ៩ ខែដែរ ទើបបានសម្រេច, នាងឮថា ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់យាងមកដល់វត្តជេតពនហើយ នាងក៏ទៅធ្វើបច្ចុគ្គមនាការទទួលព្រះអង្គ ហើយក៏អារាធនានិមន្តព្រះអង្គយាងមកឯវត្តរបស់ខ្លួន ហើយក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស, សូមព្រះអង្គនាំភិក្ខុសង្ឃមកគង់ក្នុងវត្តបុព្វារាមនេះ អស់កំណត់កាល ៤ ខែនេះ ខ្ញុំម្ចាស់នឹងធ្វើបុណ្យសម្ពោធឆ្លងប្រាសាទថ្មីដែលទើបនឹងកសាងហើយនេះ ៗ ព្រះសម្មាសម្ពុទ្ធ ទ្រង់ទទួលដោយតុណ្ហីភាព ៗ ចាប់ដើមពីថ្ងៃនោះតទៅ នាងវិសាខា បានចាត់ចែងធ្វើទានថ្វាយចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានក្នុងវត្ត ជានិច្ចរាល់ថ្ងៃ ៗ គ្រានោះ មានស្ត្រីម្នាក់ជាសំឡាញ់នឹងនាងវិសាខា បាននាំយកសំពត់មួយមានតម្លៃមួយពាន់កហាបណៈ បំរុងនឹងក្រាលក្នុងប្រាសាទនោះដែរ ប៉ុន្តែបានឃើញប្រាសាទពេញដោយកម្រាលទាំងអស់ស្រេច ក៏មកនិយាយនឹងនាងវិសាខាថា នែសំឡាញ់! ខ្ញុំចង់បកកម្រាលខ្លះក្នុងប្រាសាទរបស់នាងចេញ ហើយយកសំពត់នេះក្រាលជាជំនួសត្រង់កន្លែងនោះវិញ សូមនាងមេត្តាប្រាប់កន្លែងកម្រាលដែលគួរបកយកចេញនោះដល់ខ្ញុំ ៗ នាងវិសាខាឆ្លើយថា ល្អហើយសំឡាញ់! នាងចូរដើរគន់មើលក្នុងប្រាសាទទាំងពីរជាន់ នឹងបន្ទប់ទាំង

១.០០០ ឲ្យសព្វគ្រប់ដោយខ្លួនឯងចុះ បើឃើញកម្រាលត្រង់កន្លែងណាមិនល្អ ចូរនាងបកកម្រាលត្រង់នោះចេញ ហើយយកសំពត់នាងទៅក្រាលជាជំនួសវិញចុះ ។ នាងនោះ បានកាន់សំពត់តម្លៃមួយពាន់កហាបណៈនោះ ដើរពិនិត្យសព្វកន្លែងក្នុងប្រាសាទទាំងពីរជាន់ មិនឃើញកម្រាលណាដែលមានតម្លៃថោកអន់ថយជាងសំពត់ខ្លួនសោះ, នាងគិតថា ឱ! អាត្មាអញ ខានបានចំណែកបុណ្យក្នុងប្រាសាទនេះហើយតើ, លុះគិតឃើញដូច្នោះហើយ ក៏អាក់អន់តូចចិត្ត ទៅឈរយំក្នុងទីមួយតែម្នាក់ឯង ។ គ្រានោះ ព្រះអានន្ទត្ថេរ បានឃើញនាងនោះឈរយំ ក៏សួរថា ព្រោះហេតុអ្វី បានជានាងយំ? ។ នាងនោះក៏បានទូលសេចក្តីនោះសព្វគ្រប់ ។ ព្រះអានន្ទត្ថេរប្រាប់ថា នាងកុំគិតឡើយ! មក, អាត្មានឹងប្រាប់កន្លែងឲ្យនាងក្រាល, នាងចូរក្រាលត្រង់កន្លែងនេះចុះ ព្រោះភិក្ខុទាំងឡាយគ្រប់អង្គដែលលាងជើងរួចហើយ តែងមកឈរជូតជើងនៅកន្លែងក្បែរជណ្តើរឡើងនេះមុនគេ ហើយទើបនិមន្តចូលទៅខាងក្នុង, កន្លែងនេះ សំខាន់ណាស់ ទោះភិក្ខុណាក៏ដោយដែលនិមន្តមក គង់តែជាន់ត្រង់ទីនេះមិនខាន, ចូរនាងក្រាលត្រង់កន្លែងនេះទៅ, នាងនឹងបានបុណ្យច្រើនជាងកន្លែងឯទៀត ព្រោះកន្លែងនេះនាងវិសាខាពុំបានជាចាប់ភ្លឹក នឹកពុំឃើញឡើយ ។ នាងនោះ បានយកសំពត់របស់ខ្លួនទៅក្រាលត្រង់កន្លែងដែលព្រះអានន្ទបង្ហាញរួចហើយ ក៏

មានសេចក្ដីត្រេកអរសប្បាយរីករាយ ។

នាងវិសាខា បានធ្វើទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់ ៤ ខែក្នុងវត្តបុព្វារាម ក្នុងឱកាសដែលសម្ពោធឆ្លងប្រាសាទថ្មី លុះដល់ថ្ងៃទីបំផុតបុណ្យ នាងបានប្រគេនសាដកសំពត់ធ្វើចីវរមានចំនួនច្រើនដល់ភិក្ខុសង្ឃ ព្រមទាំងបច្ច័យដទៃទៀត មានភេសជ្ជបច្ច័យផង ។ នាងបានបរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនា កសាងសមិទ្ធផ្សេង ៗ អស់ចំនួនជាច្រើន គឺបរិច្ចាគទ្រព្យទិញដីកសាងវត្តបុព្វារាម អស់ ៩ កោដិកហាបណៈ, បរិច្ចាគទ្រព្យទិញទព្វសម្ភារៈធ្វើសេនាសនៈផ្សេង ៗ មានប្រាសាទជាដើម អស់ ៩ កោដិកហាបណៈ, រួមការបរិច្ចាគទាំងអស់ត្រូវជា ២៧ កោដិកហាបណៈ ។

គួរឲ្យស្ញើចសរសើរចំពោះនាងវិសាខា ដែលជាអ្នកមានប្រាជ្ញាឈ្លាសវៃ សូម្បីនាងឋិតនៅក្នុងភេទជាស្ត្រី មានស្វាមីហើយមកនៅក្នុងផ្ទះនៃមិគារសេដ្ឋីជាឪពុកក្មេកដែលជាមនុស្សមិច្ឆាទិដ្ឋិ មិនជឿកាន់ព្រះពុទ្ធសាសនាសោះ នាងបេះធ្វើឧបាយផ្ចាញ់ទូន្មានឪពុកក្មេក ដកបង់ឪពុកបានលះបង់គំនិតដែលយល់ខុសនោះចេញ ហើយងាកមកជឿកាន់ព្រះពុទ្ធសាសនាវិញ មិនតែប៉ុណ្ណោះឡើយ នាងបានបរិច្ចាគទ្រព្យសម្បត្តិជាច្រើន តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ពុំមានស្ត្រីដទៃណាមួយដូចនាងវិសាខាបានឡើយ ។

ក្នុងថ្ងៃដែលសម្ដេចធ្វើវិហាររួចស្រេចហើយ, វេលាថ្ងៃរសៀលល្ងាច នាងវិសាខាដោយមានកូននិងចៅជាបរិវារហែហមផង នាងបានគិតថា កិច្ចការណាដែលអាត្មាអញបានផ្ដងទុកពីមុនមក កិច្ចការទាំងអស់នោះក៏បានសម្រេចចប់សព្វគ្រប់អស់ហើយ នាងដើរក្រឡឹងជុំវិញប្រាសាទថ្មីដែលទើបនឹងធ្វើហើយ ដោយមានសេចក្ដីត្រេកអររីករាយខ្លាំង ក៏បន្លឺឧទានវាចា ដោយសំឡេងដ៏ពីរោះ ៥ បទថា :

១– សេចក្ដីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានកសាងប្រាសាទថ្មីដែលបូកលាបដោយកំបោរ ឲ្យជាវិហារទាន គំនិតនោះ អាត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

២- សេចក្ដីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានធ្វើគ្រែ តាំង ពូក និងខ្នើយ ឲ្យជាសេនាសនភណ្ឌ, គំនិតនោះអាត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

៣– សេចក្ដីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានតាក់តែងនូវសលាកភត្តដែលលាយដោយសាច់ដ៏ស្អាត ឲ្យជាភោជនទាន, គំនិតនោះ អាត្មាអញ ក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

៤- សេចក្ដីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎! អាត្មាអញនឹងបានឲ្យសំពត់ដែលនាំមកអំពីដែនកាសី, សំពត់ដែលធ្វើអំពីសរសៃ

សំបកឈើ និងសំពត់ដែលធ្វើអំពីកប្បាស ឲ្យជា ចីវរទាន, គំនិតនោះ អាត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

៥– សេចក្តីត្រិះរិះដែលបានគិតទុកថា កាលណាហ្ន៎ អាត្មាអញនឹងបានឲ្យទឹកដោះថ្លា ទឹកឃ្មុំ ប្រេង និងទឹកអំពៅ ឲ្យជាភេសជ្ជទាន, គំនិតនោះ អាត្មាអញក៏បានបំពេញគ្រប់គ្រាន់អស់ហើយ ។

ភិក្ខុទាំងឡាយ បានឮសំឡេងនៃនាងវិសាខានោះហើយ ក៏នាំគ្នាទៅក្រាបបង្គំទូលព្រះបរមសាស្តាថា សូមទ្រង់ព្រះមេត្តាប្រោស, អស់កាលជាយូរមកហើយ, ខ្ញុំព្រះអង្គទាំងឡាយ ពុំដែលធ្លាប់បានឮនាងវិសាខាច្រៀងឡើយ, ទើបតែក្នុងថ្ងៃនេះ នាងវិសាខា ដែលមានកូននិងចៅចោមរោមជាបរិវារ ច្រៀងដើរក្រឡឹងព័ទ្ធជុំវិញប្រាសាទ, ក្រែងនាងវិសាខាកំរើកប្រមាត់ទៅជាឆ្កួតទេដឹង? ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ; នាងវិសាខាជាធីតានៃតថាគត មិនមែនច្រៀងទេ, អធ្យាស្រ័យរបស់នាងវិសាខា បរិបូណ៌ដោយការបំពេញកុសលបានច្រើនយ៉ាង, នាងមានសេចក្តីសប្បាយចិត្ត ព្រោះបានឃើញសេចក្តីប្រាថ្នាដែលខ្លួនបានតម្កល់ទុកមកទាំងប៉ុន្មាន ក៏បានសម្រេចដោយសព្វគ្រប់ ទើបបន្លឺឧទានពាក្យយ៉ាងនេះឯង ។

ព្រះបរមសាស្តា ទ្រង់មានបន្ទូលចំពោះភិក្ខុទាំងឡាយនោះរួចហើយ ទើបទ្រង់សំដែងធម៌គាថាទៀតថា :

(តៅអាគត)

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព

# ពិចារណាដើម្បីយល់តក្កវិជ្ជា

( ៣ )

លោក ហ៊ុន គិមសៀ រៀបរៀង

## ការបែងចែកទស្សនៈ និង ការឲ្យន័យ

*ក– ឲ្យន័យបានសេចក្តីថា វែកញែកនូវលក្ខណៈឯកឯងនៃទស្សនៈ*

*ខ– ឲ្យន័យយ៉ាងណា ទើបបានត្រឹមត្រូវ?*

*គ– អត្ថន័យនៃការឲ្យន័យ*

*ឃ– បែងចែកទស្សនៈ*

*ង– វិធាននៃការបែងចែក*

*ច– រូបមន្តខ្លះៗ ក្នុងការបែងចែក ។*

### ក. យ៉ាងណាដែលហៅថា ការឲ្យន័យ? បានសេចក្តីថា វែកញែកនូវលក្ខណៈឯកឯង ( Privé ) នៃទស្សនៈ:-

*នៅក្នុងរឿងនេះ យើងចង់និយាយថា : តើយើងត្រូវធ្វើដូចម្តេច*

ដើម្បីរកឲ្យបានច្បាស់នូវលក្ខណៈឯកឯង (Caractère privé) និងលក្ខណៈទូទៅ (Caractère général) នៃទស្សនៈ? ជាបឋមយើងត្រូវអធិប្បាយអំពីរបៀបរកឃើញលក្ខណៈឯកឯង ។

ការរកឃើញកលក្ខណៈឯកឯងនៃទស្សនៈ (Concept) គឺជាការបង្ហាញនូវលក្ខណៈផ្ទាល់នៃវត្ថុនោះ ។ ឯវត្ថុនោះ គឺជាវត្ថុអ្វី? ។

ឧបមាដូចមនុស្សខ្លះ គេសួរយើងឲ្យពន្យល់ន័យអំពីមនុស្ស តើយើងត្រូវឲ្យន័យ (définir) យ៉ាងដូចម្តេច? ។ យើងមិនអាចឆ្លើយថា: "មនុស្សគឺជាសត្វចេះការប្រពន្ធ ដើម្បីបង្កើតជាគ្រួសារ, ចេះពាក់មួកក្នុងពេលដើរហាលថ្ងៃ... នោះទេ ។ ផ្ទុយទៅវិញ យើងត្រូវឲ្យន័យមនុស្សដូចតទៅទើបត្រឹមត្រូវ ៖ មនុស្សគឺសត្វលោកម្យ៉ាង ចេះបង្កើតឧបករណ៍សម្រាប់ប្រើ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការពិចារណា" ។

បើគេសួរយើងថា : "ទឹកគឺជាអ្វី? ហើយយើងឲ្យន័យថា ទឹកគឺជាវត្ថុរាវសម្រាប់ផឹក" កាលណាគេស្រេកទឹក គេចង់សើច ពីព្រោះការឲ្យន័យនេះរាំមិនត្រឹមត្រូវសោះ ។ ផ្ទុយទៅវិញ យើងត្រូវឲ្យន័យទៅតាមវិទ្យាសាស្ត្រដែលបង្រៀនយើងថា ទឹកគឺជាវត្ថុរាវ គ្មានពណ៌ គ្មានក្លិន គ្មានរសជាតិ ហើយថ្លាផង ។ អស់ទាំងនេះហើយដែលយើងហៅថា "ការឲ្យន័យ បានសេចក្តីថា ការរកឃើញកលក្ខណៈឯកឯង" នៃទស្សនៈ ។

យើងបានស្គាល់វត្ថុច្រើនណាស់ ប៉ុន្តែបើគេបង្គាប់ឲ្យយើងឲ្យន័យ

របស់វត្ថុទាំងនោះ យើងមានការពិបាកច្រើនដែរ ទោះបីអ្នកជាប់រៀនសូត្រច្រើនក៏ដោយ ។

## យើងសុំយកឧទាហរណ៍ក្នុងការឲ្យន័យអំពីទឹក

ទឹកគឺជាវត្ថុរាវ, គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិហើយថ្លា ។ តើយើងមានឃើញអ្វីខ្លះ? ។ យើងឃើញសមាសភាពនៃប្រយោគក្នុងការឲ្យន័យរួមមាន :

ទស្សនៈប្រភេទក៏ជិតបំផុតបូករួមនឹងលក្ខណៈផ្ទាល់របស់វត្ថុនោះ ។ ទឹកជាវត្ថុរាវ ។ វត្ថុរាវ គឺជាទស្សនៈប្រភេទរបស់ទឹក, ស្រា, ទឹកដោះ, ប្រេង... ។ ប្រេងខុសពីទឹក, ស្រាខុសពីទឹកដោះ ពីព្រោះជំពូកវាមានខុសគ្នា ប៉ុន្តែវាមានប្រភេទដូចគ្នា គឺវត្ថុរាវ ។ បើយើងឲ្យន័យថា ទឹកគឺជាវត្ថុ តើត្រូវឬទេ? ក៏ត្រូវដែរ ប៉ុន្តែវាមិនត្រឹមត្រូវដល់វត្ថុរាវទេ ពីព្រោះវត្ថុវាមានរឹង, ទន់, រាវ, ជ្រាយ ។ បើយើងថា វត្ថុរាវ ទើបវាត្រូវច្រើនជាង ។ ចំណែកឯលក្ខណៈ គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិ គឺជាលក្ខណៈពិសេសនៃពួកទឹក ក្រៅពីទឹកគឺគ្មាន ។ មកដល់ត្រឹមនេះ យើងទាំងអស់បានថា : ការឲ្យន័យ សំខាន់ណាស់ បើយើងឲ្យន័យផ្តេសផ្តាសចំពោះវត្ថុមួយ បានសេចក្តីថាយើងយល់វត្ថុនោះមិនទាន់ច្បាស់នៅឡើយទេ ។

សុំជូនឧទាហរណ៍មួយទៀត : ជនជាតិគឺជាអ្វី? ជនជាតិគឺពួក

មនុស្សមួយគ្រួសារធំដែលរស់នៅទាក់ទងគ្នា កើតឡើងក្នុងប្រវត្តិសាស្ត្រ មានការទាក់ទងខាងភាសា, សំដីនិយាយ, អាណាចក្រ, ជីវភាពខាងសេដ្ឋកិច្ច, ខាងការលូតលាស់ក្នុងផ្លូវចិត្ត ដែលរួបរួមគ្នាឲ្យបានទៅជាវប្បធម៌មួយ ។

## ១- ឲ្យន័យយ៉ាងណាទើបបានត្រឹមត្រូវ ?

យើងយកឧទាហរណ៍ «ពលកម្មគឺជាអ្វី?» ពលកម្មគឺជាការចលនាមានគោលបំណងរបស់មនុស្សក្នុងសង្គម ដោយប្រើឧបករណ៍កែប្រែធម្មជាតិ ។

បើនិយាយអំពីរបៀបសរសេរប្រយោគ (phraséologie) យើងយល់ឃើញថា ឃ្លានេះមានបីផ្នែក, ផ្នែកទី ១ គឺយកទស្សនៈមកឲ្យន័យ ផ្នែកទី ២ គឺប្រើទស្សនៈក្នុងការឲ្យន័យ ។ ផ្នែកទាំងពីរនេះភ្ជាប់គ្នាដោយពាក្យ «គឺជា» ។ ដូច្នេះយើងយកឧទាហរណ៍ពីរបីមកពិចារណាល្បងមើល?

— ជីវិត គឺជាសាលារៀន,

— ប្រពន្ធបងឯង គឺជាកសិករ... ។ល។ តាមឧទាហរណ៍នេះយើងយល់ថា មិនមែនជាការឲ្យន័យទេ ឬថាការឲ្យន័យមិនត្រឹមត្រូវ ។ តែកាលណាឲ្យន័យមិនត្រឹមត្រូវ យើងមិនអាចចាត់ថាជាការឲ្យន័យបានទេ ។

បើចង់ឲ្យន័យឲ្យបានត្រឹមត្រូវ យើងត្រូវស្គាល់ឲ្យច្បាស់នូវលក្ខណៈនៃវត្ថុ ដែលយើងត្រូវឲ្យន័យ ។ ដូចគ្នានឹងមនុស្សដែលមិនធ្លាប់ស្គាល់ផ្លែខ្នុរ គឺមិនអាចឲ្យន័យបានឡើយ ។ ដូចជាយើងមិនធ្លាប់ហាត់រៀនសម្ភារៈនិយមប្រវត្តិសាស្ត្រ យើងមិនអាចឲ្យន័យបាននូវសម្ភារៈនិយម ប្រវត្តិ-សាស្ត្របានឡើយ ។ ប៉ុន្តែបើយើងគ្រាន់តែស្គាល់វត្ថុ ដើម្បីឲ្យន័យហើយ យើងគ្មានចេះវិធីឲ្យន័យក៏មិនបានដែរ ។

វិធីឲ្យន័យមានបែបផែន ៤ យ៉ាង ហើយការឲ្យន័យណា ដែលមានសភាពប្រហែលៗ នឹងបែបផែនទាំង ៤ ខាងនេះ ទើបយើងចាត់ហៅថា ជាការឲ្យន័យបាន ។

វិធីទី ១– លក្ខណៈទូទៅនៃទស្សន ដែលយើងយកមកឲ្យន័យ និងលក្ខណៈទូទៅនៃទស្សនៈ ដែលយើងប្រើក្នុងការឲ្យន័យ ត្រូវមានតម្លៃស្មើគ្នា ដូចជាយើងឲ្យន័យអំពី "ទឹក" ថាទឹកគឺជាវត្ថុរាវ គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិ ហើយថ្លាដូច្នេះឯង ។ ការឲ្យន័យនេះរាប់ត្រឹមត្រូវ ពីព្រោះពាក្យនៃទឹកនិងវត្ថុរាវ គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិហើយថ្លារាប់ស្មើគ្នា មានលក្ខណៈទូទៅប៉ុនគ្នា ។

បើយើងចង់ដឹងថា តើទស្សនៈពីរនៃការឲ្យន័យ រាប់មានតម្លៃប៉ុនគ្នាឬទេ? យើងត្រូវប្តូរឃ្លានោះល្បងមើល ;

វត្ថុរាវ, គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិហើយថ្លា គឺវត្ថុអ្វី? ។

គ្មានអ្វីក្រៅពីទឹកទេ ។ យ៉ាងនេះ យើងយល់បានថា ការឲ្យន័យនេះ ក៏ត្រឹមត្រូវ ។

ផ្ទុយទៅវិញ យើងយកឧទាហរណ៍ថា :

" ប្រពន្ធបង គឺជាកសិករ" មកពិចារណា យើងឃើញថា មិនមែន "ការឲ្យន័យទេ" ។ យើងដូរឃ្លានេះល្បងមើល "កសិករ គឺជាប្រពន្ធបង" ។ ស្តាប់មិនបានសោះ ។ បើដូច្នេះ យើងហៅថា "ការឲ្យន័យមិនបាន" ។

វិធីទី ២– ទស្សនៈប្រភេទប្រើក្នុងការឲ្យន័យ មិនត្រូវឲ្យហួសលក្ខណៈវាទេ ។ ដូចជា "ទឹក" បើយើងថាតែ "វត្ថុ" គ្មានពណ៌, គ្មានក្លិន...មិនមែនទឹកទេ ពាក្យ "រាវ" ដ៏សំខាន់ណាស់ គឺជាពាក្យបញ្ជាក់លក្ខណៈដាច់ខាត ។ យើងពិនិត្យមើល "វត្ថុ, គ្មានពណ៌, គ្មានក្លិន, គ្មានរសជាតិ គឺកញ្ចក់" តែវត្ថុ "រាវគ្មានពណ៌...គឺទឹក" ។

វិធីទី ៣– បណ្តាលលក្ខណៈដែលយើងយកមកឲ្យន័យ ត្រូវឲ្យស្របនឹងប្រធាន (précis) ត្រូវឲ្យពិតហើយជាក់ ។ ប្រការនេះយើងងាយយល់ទេ ក្នុងការឲ្យន័យខាងប្រភេទ បើយើងប្រើពាក្យមិនចំ ឲ្យន័យមិនចំ គេអាចយល់ខុសទៅថាវត្ថុផ្សេងក្រៅអំពីប្រធាន ។

វិធីទី ៤– ការឲ្យន័យ មិនមែនជាការនិយាយផ្ទុយ បើយើងពន្យល់ដោយប្រើពាក្យផ្ទុយ គឺនាំឲ្យយើងគ្មានបានចេះដឹងអ្វីទាំងអស់ ។

ឧទាហរណ៍ "ដែលហៅថាក្របី គឺមិនមែនគោ, ដែលហៅថា មនុស្ស គឺមិនមែនឆ្កែ" បែបនេះហៅថា "ការឲ្យន័យម្តេចកើត" ។

វិធីទី ៤– "ការឲ្យន័យ" ត្រូវឲ្យគ្រប់គ្រាន់, ចំៗ, កុំប្រើពាក្យវិលវល់បត់បែនចុះឡើង ។ ឲ្យន័យត្រូវលើកយកតែលក្ខណៈសំខាន់ជាចាំបាច់ ។ ចុះបើយើងថា "មនុស្សមិនមែនជាឆ្កែ" ក៏ម្តេចកើត ។ ក៏នៅមាន ជ្រូក, មាន់, ទា, ឆ្មា ឯទៀតជាច្រើន ។

## គ- អត្ថន័យនៃការឲ្យន័យ

ការឲ្យន័យមានសារៈសំខាន់ណាស់ក្នុងរឿងជជែកយកចាញ់ឈ្នះ ។ គេត្រូវចេះបន្ថែមលក្ខណៈនៃប្រធាន ក្នុងការឲ្យន័យ ។

ឧទាហរណ៍ យើងយកឧទាហរណ៍ក្នុងអក្សរសាស្ត្រ មួយមកវែកញែក ។

ក–ស្នេហារវាងទុំនិងទាវ គឺជាស្នេហាដែលមានលក្ខណៈ អច្ឆរិយៈ, "អច្ឆរិយៈ គឺជាលក្ខណៈអស្ចារ្យ" ។ ប៉ុន្តែបើយើងចង់ទាត់ចោលយោបល់ខាងលើ យើងត្រូវថែមលក្ខណៈមួយទៀត គឺអស្ចារ្យហើយមនុស្សធ្វើមិនកើតផង ។ ដូច្នេះយើងបានចម្លើយថា "ស្នេហារវាងទុំនិងទាវ ជាស្នេហាដែលមានលក្ខណៈអច្ឆរិយៈម្តេចកើត បើអច្ឆរិយៈមានន័យថាអស្ចារ្យ មនុស្សធ្វើមិនកើត ។ ចុះបើទុំនិងទាវជាមនុស្សធ្វើកើតទៅហើយ តើស្នេហានេះ ហៅថា"អច្ឆរិយៈ" ដូចម្តេចបាន? ។

ដល់ត្រង់នេះ យើងទាំងអស់គ្នាយល់បានភ្លាមថា : ការឲ្យន័យមានសារៈសំខាន់ ហើយអនុលោមទៅតាមនិន្នាការថែមទៀតផង ។ ដូចថា : "ចក្រពត្តិ" បើតាមវចនានុក្រម គេពន្យល់ថា : "អំណាចជាធំជិះជាន់លើគេឯង" ប៉ុន្តែបើតាមពួកកុម្មុយនិស្តវិញ បន្ថែមលក្ខណៈ "ជិតស្លាប់" មួយថែមមកទៀត ពីព្រោះគេយល់ថា : តែជិះជាន់ឡើងថ្នាក់ចក្រពត្តិហើយ គឺ "ជិតស្លាប់" ហើយ ។

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

( ក )

*ព្រះមហា ចាន់-ខាត់ រៀបរៀង*

---

អបាករណ នបុ. កិរិយាបំបាត់, កិរិយាធ្វើឲ្យស្មើ ។

អបករុណ គុ. ដែលមានអាណិតតិច, កាច ។

អបកត៌ន នបុ. កិរិយាហែក, កិរិយាកាត់ ។

អបកត្ឫ ការក. អ្នកដេរ ។

អបកម៌ន៑ នបុ. កិរិយាប្រគល់ឲ្យ. កិរិយាសងបំណុល ·

អបកឞ៌ បុ. គុណវិបត្តិ, កិរិយាបំបាត់, កិរិយាខ្វះខាត, កិរិយាដាក់ចុះ ។ កិរិយាដំឡើង (ធ្នូ) ។ កិរិយាគិតអនាគត ។

អបកឞ៌ណ គុ. ដែលបន្ថយ ។ នបុ. កិរិយាញែកចេញ, កិរិយាលើកឡើង ។

អបកឞ៌ន៑ គុ ដែលបាញ់បន្ថែម ។

អបាកលង្ក គុ. ដែលមិនប្រឡាក់ ។

អបការ ប៉ុ. កិរិយាធ្វើឲ្យខុស, សេចក្ដីអន្តរាយ, កិរិយាមើលងាយ ។

-តា ស្ត្រី. ប្រទេច ។

អបការិន៑ គុ. ដែលធ្វើឲ្យខូចខាត, ដែលដេរប្រទេច ។

អបក្ឫ ធាតុ. ញែក, លើកឡើង, ធ្វើឲ្យខុស, ដេរ ។ –ក្ឫត គុ. ដែលធ្វើឲ្យខូចប្រយោជន៍, ញាំញី ។ នប៉ុ. កិរិយាប្រទេច, កិរិយាដេរប្រមាថ ។

អបក្ឫត ការក. អ្នកធ្វើឲ្យខូចប្រយោជន៍ ។

អបក្ឫតិ ស្ត្រី. កិរិយាដេរ ។

អបក្ឫត្យ នប៉ុ. កំហុស ។

អបក្ឫឞ៑ ធាតុ. ដក, ទាញ ។ យិត (ធ្នូ) ។ បន្ថយ ។ –ក្ឫឞ៑ ដែលធ្វើឲ្យទៅឆ្ងាយ, ទាប, អាក្រក់, បន្តិចបន្តួច ។

អបក្រម៑ ធាតុ. ចៀសចេញ, បើកឲ្យ ។ –ក្រាន្ត ដែលថយចេញ, ដែលកន្លងទៅហើយ ។

អបក្រម ប៉ុ. កិរិយាចរចេញ ។

អបក្រមណ នប៉ុ បកត្រា ។

អបក្រិយា ស្រ្តី. កំហុស, វិធីវិលខូច ។

អបក្រី ធាតុ. បានដោយប្រាក់, បាន ។

អបក្រុដ្ឋ គុ ដែលបន្ទោកបន្ទាប ។

អបក្វ គុ. ដែលមិនឆ្អិន ។

អបក្ស គុ. ដែលមិនមានបក្សពួក ។ លោប ឬ _សាទ

បុំ. (អ្នក) មិនបាត់ស្លាប ។

អបក្សិបិ ធាតុ. ញែកចេញ, បំបែកចេញ ។

អបក្សី ធាតុ. លិចបាត់ (ព្រះចន្ទ្រ) ។ _អបក្សិត គុ. ដែល

លិចបាត់ ។

អបគតិ ស្រ្តី អបគតិ, គតិអាក្រក់ ។

អបគមិ ធាតុ. គេចចេញ. បាត់ទៅ ។ _គត គុ ដែល

ចេញៈទៅបាត់ ។

អបគម បុំ. កិរិយាចៀសចេញ. កិរិយាចេញទៅ

អបគជិត គុ. ដែលមិនគម្រាម (ផ្គរ)

អបគុណ គុ. អបគុណ, ដែលឥតគុណ ។ កិរិយាបន្ទោស ។

អបគ្រហ  ធាតុ. លើកឡើងខ្ពស់, យកចេញ ។

អបឃន  គុ. ដែលមិនមានពពក ។ បុំ. ខ្លួន

អបប្បុណ  គុ. ដែលមិនមានសេចក្ដីអាណិត ។

អបង្គតា  ស្ត្រី  ភាពមិនមានភក់ ។

អបចយ  បុំ  អបច័យ, កិរិយាបន្ថយ, វិនាស, កិរិយាវាយរៀវ ។

អបចរ  ធាតុ. ខូចខាត, ធ្វើខុស ។ _ចរិត នបុំ. កំហុស, កិរិយាប្រមាថ ។

អបចាយិន  គុ  ដែលមិនគោរព, ដែលធ្វើខុស ។ _ចាយិត្វ នបុំ. ភាពនៃកិរិយាមិនគោរព ។

អបចារ  បុំ. កំហុស, កិរិយាប្រមាថ ។ អំពើអាក្រក់, កិរិយាមើលងាយ ៖ សេចក្ដីស្លាប់ ។ _ចារិន គុ. ដែលមិនមានភក្ដី ។

អបចិ  ធាតុ. បន្ថយ ។ _ចិត គុ ដែលបន្ថយ ។

អបចិ  ធាតុ  រាប់អាន ។ ចិត គុ. ដែលគួរគោរព, នបុំ. កិរិយាគោរព, កិរិយាសុំទោស ។

( នៅមានត )

# បណ្ដាំកសិករខ្មែរ

ដោយ អ៊ុង-ស៊ុមណ៍

ធ្វើការនៅអគ្គស្នងការដ្ឋានយុវជនរាជសង្គមនិយមខ្មែរ

ខ្ញុំបាទចាស់ហើយ រិះគិតមិនស្បើយ ទឹកស្ដាយអស្ចារ្យ
កាលវ័យនៅរៀន គ្មានចំសិក្សា ម្ល៉ោះហើយបញ្ញា
អន់ខ្សោយទន់ទៅ ។

ពាល់ក្រខ្លាំងណាស់ ចេះពុំជ្រៅជ្រះ ស្មើរល្ងិតល្ងង់ខ្លៅ
រស់ខ្វះវិជ្ជា ប្រដូចប្រៀបទៅ ស្មើខ្វាក់រស់នៅ
ក្នុងរណ្ដៅគរថ្ងង់ ។

ចំឆ្ងៀតសរសេរ នាពេលចំនេរ គ្រាន់កំចាត់បង់
មេរោគអវិជ្ជា ដែលតាញពាក់ចង់ ឲ្យលោកលិចលង់
ក្នុងវដ្ដសង្សារ ។

កូនខ្មែរចំរៀន តាមពាក្យខ្ញុំទាន ចាស់ទុំមេបា
គោរពប្រណិបត៌ គ្រូសាស្ត្រាចារ្យ ចប់ការសិក្សា
ធ្វើកសិករ ។

BIBLIOTHEQUE
P.P.
D'EXTREME ORIENT



កាប់គាស់ភនដី　　កូនខ្មែរប្រុសស្រី　　ពូជខ្មែរអង្គរ
ធ្វើស្រែចំការ　　សង់ផ្សារក្រុងល្អ　　ខ្មែរផុតពាល់ក្រ
ឡើងថ្នាក់អ្នកមាន ។

កាប់គាស់ជីកកាយ　　ទំនប់ប្រឡាយ　　ភាន់កម្លាំងមាន
នាំគ្នាដោះស្រាយ　　ជីកព្រែកសង់ស្ពាន　　ផ្លូវនាំយាន
ចែកជូនអ្នកក្រោយ ។

ធ្វើស្រែចំការ　　លក់ដូរផលា　　ខ្នះប្រែស្រួចហើយ
កុំនៅទំនេរ　　ដើរលេងប្រហើយ　　គិតមើលកុំឲ្យ
ខាតពេលវេលា ។

នៅជិតភូមិផ្ទះ　　ជីកអណ្តូងស្រះ　　ចែកទឹកគ្នីគ្នា
ដាំបេកអំពៅ　　ល្ហុងដូងម្នាស់　　ចិញ្ចឹមមាន់ទា
លក់យកប្រាក់កាស ។

ទំប្រឹងខ្លួនឯង　　កាប់គាស់លីសែង　　ដេរប៉ាក់ដុលប៉ះ
កើតមកក្នុងលោក　　ត្រូវចេះឲ្យច្បាស់　　វិជ្ជាសិល្បសាស្ត្រ
ទើបគេឯងគោត ។

ដើរតាមក្បួនច្បាប់　　កុំចេះចាប់　　ធ្វើតាមការដោត
ផ្សងព្រេងខាតពេល　　តាមចិត្តលោតលោត　　បើទង់ពិសោធ
នៅតាមក្បួនល្អ ។

មុនប្រាជ្ញសរសេរ ចងក្បួនទុកក្តើ លោកឃើញខ្មាស
សម្រឹតសម្រាំង សម្រួចពូជល្អ បណ្ដុះបន្ត
តាមសម័យលោក ។

រកស៊ីលោកមាន បើមិនស្ទូវបាន គង់រួចបរិភោគ
កុំធ្វើយមាយ ដាក់ខ្លួនតាមជោក ក្រលុកចូលមក
រកខ្ចីបុលគេ ។

គំនិតមិនល្អ កម្មកាយវណ្ណក ពុំប្រសើរទេ
ខ្ចីគេមួយតៅ ទៅសងគេទ្វេ គ្មានទ្រព្យផ្ទូរផ្ទេរ
ដោះគៃលែងរួច ។

ខំកាប់គាស់ដី កូនខ្មែរប្រុសស្រី ចៀសកងខិលខូច
អំពើអាក្រក់ ពាលឆក់ប្លន់លួច នាំក្តីអសោច
ពូជពង្សខេមរ ។

ខ្មែរស្លូតត្រង់ណាស់ គោរពធម៌ព្រះ– ពុទ្ធតាំងអស់គ្នា
ចៀសវាងវៀរបាប កម្មពៀរវេរា ប្រមូលគ្នាគ្នា
រកបានស្តុតិខ្មែរ ។

រៀនស៊ូខ្លួនឯង ខំប្រឹងស្រុះស្រួង រៀងរាល់ថ្ងៃខែ
ដាំតាមរដូវ ភោគផលផ្កាផ្លែ នេះឯងពូជខ្មែរ
លើកកសិករធំ ។

កូនខ្មែរជួយជាតិ បេះដោះទុកញាតិ ដាំច្រូតស្រូវដុំ
វេរយកដៃគ្នា ខ្មែរតែនិយម នៅតាមស្រុកភូមិ
រួបរួមគ្នាពិត ។

រកទទួលទាន គិតពីបានមាន គ្រប់រូបឆ្ងាយជិត
រស់សុខសប្បាយ ក្នុងកាយជីវិត បបួលគ្នាពិត
រកផ្លូវចំរើន ។

រាជរដ្ឋាភិបាល ចេញជួយគ្រប់កាល ឲ្យបានជឿនលឿន
គ្រប់ផ្នែកវិស័យ ផ្នែកជួយរាស្ត្រច្រើន កេនចក្រចំរើន
ទិញផលរាស្ត្រអស់ ។

រាស្ត្រគិតពីដាំ ជ្រើសផលដំណាំ ពូជល្អឥតខ្ចោះ
រាជការរកផ្សារ លក់ដូរលើកបោះ ឃើញប្រាក់ស្រស់ៗ
ហូរចូលជាតិខ្មែរ ។

កុំកាប់ដើមត្នោត ចូរខំដាំថោត តាមដងភ្លឺស្រែ
ត្នោតដុះយូរណាស់ ទំរាំផ្កាផ្លែ រាប់រយឆ្នាំខែ
ទើបហុចផលក្រោយ ។

កូនត្នោតតូចដុះ ហាមកូនស្រីប្រុស ឃាត់ក្មេងកុំឲ្យ
កាប់គាស់កំពឹង គ្មានគិតមុខក្រោយ ត្នោតធំដង្ហោយ
ឲ្យផលជាស្ករ ។

ដាក់ក្អមស្រាក់ប៉ោត បម្រាញ់ស្ករត្នោត ចេញជាស្ករស
ចក្រកំពង់ត្រាំ ធ្វៃប្រសិទ្ធល្អ ធ្វើបានស្ករស
ដូចដុំយ៉ាងស្អាត ។

លក់ចែកជូនជាតិ ថ្លៃថោកជូនញាតិ ចំណេញគ្មានខាត
ចំណាយចំណូល គត់ត្រាតាមខ្នាត ជាតិខ្មែរគ្មានខាត
រូបិយប័ណ្ណ ។

ដាំដើមក្រចៅ កប្បាសអំពៅ ខ្នុរស្វាយទៀបបាន
ម្រេចម្នាស់សារម៉ាវ ក្រូចគៀវសមាន់ កៅស៊ូសំខាន់
តាមដីដ៏ល្អ ។

ដីខ្មែរសម្បូរ ព្រៃភ្នំបឹងអូរ ទន្លេល្ហល្ហ
សល់ដីច្រើនណាស ជូនកសិករ ជួញមុខរបរ
ខាងកសិកម្ម ។

ហៃអស់ពលរដ្ឋ ជួយឲ្យហ្មត់ចត់ ពជបន្ទូលផ្តាំ
អង្គព្រះសីហនុ កូនចៅចងចាំ របរកសិកម្ម
ប្រសើរក្រៃលែង ។

ទៅចាប់ដីថ្មី រស់នៅធ្វើអ្វី ដីមួយកន្លែង
កើតពីជូនតា រីងរឹងហួតហែង ដីមួយកន្លែង
គ្នាមិនបប់ ។

កូនកើតបន្ត　　បួនប្រាំតំណ　　ថែរក្សមិនគ្រប់
ទាស់បងប្អូនឯង　　ខ្វែងគ្នាឈរឈប់　　ម្ដេចមិនគ្រឡប់

ទៅកនដីថ្មី ។

ព.បវដ្តតាំងអស់　　កុំភ្លេចឲ្យសោះ　　យើងរស់ទីងអ្វី
ធ្វើស្រែចំការ　　កងពស្ត្រមន្ត្រី　　ឧស្សាហកម្មថ្មី

ជោគជ័យជាតិយើង ។

កនដីបានធំ　　ខ្មែររស់ជួបជុំ　　ចិញ្ចឹមសត្វឡើង
សេះគោក្របី　　ត្រីមាន់ទាយើង　　ជួយលើកតំកើង

ដល់សេដ្ឋកិច្ចខ្មែរ ។

យន្តភ្ជួររាស់ដី　　សេះគោក្របី　　អត្តខាត់ហូរហែ
ចិញ្ចឹមសត្វឡើង　　តាមភ្នំភូមិស្រែ　　ហៃអស់កូនខ្មែរ

រុករត់ឃ្លាលសត្វ ។

ស្រែកច្រៀងច្ងន់ច្ងើយ　　សូរសម្លេងល្វើយ　　វង់ថ្វីមប្រមាត់
ខ្មែរច្រៀងឃ្លាលគោ　　ហួចហៅកសាក់　　តាមបំពង់មាត់

ទូរព្រៃរបោះ ។

សប្បាយឆ្នាំងណាស់　　ប្រុសស្រីក្មេងចាស់　　ខ្មែរយើងតាំងអស់
ប្រឹងចិញ្ចឹមសត្វ　　គ្រប់ច្រកកៀនកោះ　　ជួញយកប្រាក់ប្រោះ

ព្រំគ្រសារខ្មែរ ។

គួរកស៊ីយន្តចក្រ ប្រកបកាត់លើកដាក់ មិនគ្រប់គ្នាទេ
តាមស្ថានភាពដី គុំបការស្រែ ពលរដ្ឋក្រស្តខ្មែរ
ត្រូវការប្រើគោ ។

សេះឬក្របី ដឹកដល់ផ្ទះ ធ្វើរាល់កម្ពុរ
គួរកស៊ីដកដី ទឹមក្របីគោ ទិញដាក់លក់ដូរ
រហូតរៀងទៅ ។

ខ្វះប្រើយន្តចក្រ ខ្វះក្រអន់គ្ស គួរគិតឱ្យជ្រៅ
ប្រើគោក្របី បានការគ្រប់ផ្លូវ ចិញ្ចឹមសត្វទៅ
ជំនួយដល់ជាតិ ។

ភ្ជួរស្រែល្ហឹងល្ហើយ កុំនៅព្រងើយ អសខ្មែរសង្ខាត
ធៀតដាំកូនឈើ បង្កើនដីជាតិ សណ្តែកង្សាត
ក្រសាំងអង្កាញ់ ។

ម្លប់ឈើត្រជាក់ ទាញទឹកភ្លៀងធ្លាក់ ដីកើតជីខ្លាញ់
ដាំដំណាំល្អ កសិករគេសអញ យកផលចំកញ
មួយភាគយ៉ាងធំ ។

ពីកូនឈើស្រស់ ទន្ទ្រានទេត្តស្រស់ លាមកមូត្រជ្រាំ
ចំបើងកញ្ជ្រឹង កុំដុតចោលគម្ពុ ឆ្អឹងសត្វតូចធំ
ផ្សំផ្សំធ្វើជី ។

រិះគិតឲ្យគ្រប់ កុំតាមទម្លាប់ ដុតរាលខ្ទេចខ្ទី
ពេលរដូវប្រាំង ឃើញភ្លើងឆេះរី រាលពេញដីធ្លី
រាលដល់ព្រៃស្បាត ។

ភ្លើងឆេះរាលព្រៃ កូនឈើដុះក្បែរ រោលឆេះរលីស្អាត
ពីគល់ដល់ចុង ជាធ្យូងស្ងួតសាច តើនរណាខាត
គឺកសិករខ្មែរ ។

ប្រាជ្ញលោកពោលថា ដីដីអស្ចារ្យ តាមចំការស្រែ
ដាំដុះឈើស្រស់ ដីរស់វិញទេ ម្ដេចដុតរាលស្រែ
ដីហិលរលីខាត ។

នាយព្រានប្រមាញ់ កុំដើរបរបាញ់ រុករកតក្បាត
បង្ហិនសត្វព្រៃ ចតុ-ទ្វេបាទ នាំសត្វបង់ខាត
ព្រាត់គូស្រករ ។

ទន្សោងគោព្រៃ ល្បុសប្រើសគ្រប់ រមាំងខ្ទីងរលុំ
ទុកឲ្យគ្នារស ក្ដាន់ស្វានពានរ បាញ់ពាល់តែក្រ
ព្រឹក្សព្រៃខេមរ ។

កុំតាមសប្បាយ ត្រូវទាញចិត្តកាយ កុំដើរប្រហារ
សត្វស្លូតគ្មានពិស ម្ដេចមិនមេត្តា សីលប្រាំទៅណា
នាយព្រានកំហូច ។

ស្តាយសត្វស្រុកព្រៃ ទ្រព្យធម្មជាតិថ្លៃ គ្មានអ្វីប្រៀបដូច
បាញ់បំផ្លាញអស់ បានអ្វីតពូជ សូមកុំប្លន់លួច
វិនាសទ្រព្យជាតិ ៗ

តំណតទៅ ពាលខូចរឹងនៅ បំផ្លាញសត្វធាតុ
សត្វកាចពិសពុល គួរយេងពិឃាត សត្វស្លូតជាញាតិ
ទុកលំអព្រៃ ៗ

ប្រាប់ប្រាមកូនចៅ សត្វចង់រស់នៅ ចាកផុតទុក្ខភ័យ
ត្រូវមានមេត្តា ករុណាប្រណី កុំទៅប្រល័យ
ចងពៀរព្យាបាទ ៗ

រស់ជាខេមរា ក្រុងកម្ពុជា រស់រួមមិត្តញាតិ
កិច្ចធំបំផុត រស់បវរជាតិ សាសនាពុំឃ្លាត
ព្រះរាជបល្ល័ង្ក ៗ

ពន្លឺភ្លើងបន្ទុះនៅស្រុកស្រែ

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( ក )

**បំណងជើង :** „ សាស្ត្រា សេចក្តីអរិយសត្តា[១],,

**អ្នកនិពន្ធ :** ព្រះអរិយសត្តា (?) ។

**កាលបរិច្ឆេទ :** គ្មានបញ្ជាក់ក្នុងអត្ថបទ ។

**របៀបនិពន្ធ :** ពាក្យកាព្យ បទកាកគតិ ។

**ប្រភពរឿង :** ដូចសាស្ត្រាក្រមច្បាប់ ។

**លក្ខណៈឯកសារ :** សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣ សន្លឹកកន្លះ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកពីវត្តខ្វង កំពង់ចាម ចុះលេខសាស្ត្រា ៦៦៧ ។

**អត្ថបទផ្តើម :** បទកាកគតិ ៗ អរិយសត្តា គន់គិតថែងការ បង់ទុក

ជាច្បាប់ ឲ្យអស់សិស្សផង ត្រាប់ត្រង់សណ្តាប យកជាតម្រាប់

តម្រង់អាត្មា ។ ឲ្យមានប្រយោជន៍ ប្រយ័ត្នអសោចន៍

ភាពរូបអ្នកណា អម្បាលមករៀន រៀនសាស្ត្រា ប្រយ័ត្នអាត្មា

ការកើតលោកិយ ។ . . . ល។

---

១ កវីនេះ បានសន្មតយកគោរម្យងាររបស់ខ្លួន ធ្វើជាឈ្មោះអត្ថបទបំណងជើង ។ កវីនេះ ប្រហែលជាបព្វជិត មានឋានៈសក្តិ ទីរាជាគណៈ ងារជា «ព្រះអរិយសត្តា» ។

អត្ថបទបញ្ចប់ : អរិយសត្វា គន់គិតចែងចារ ចែងចប់សេចក្តី
តម្រង់តម្រាប់ ជាច្បាប់យ៉ាងថ្មី ជាសតៀនស្រដី លើសព្វប្រការៗ
កូនគិតរករៀន កិច្ចការរបៀន របស់ក្សត្រា តាមច្បាប់ទំពាន
ទូន្មានអាត្មា គ្រប់សិល្បសាស្ត្រា សូវរេចចប់ហោង ៗ

×××

បំណងជើង : " សេចក្តីគម្ពីរច្បាប់ក្រម[1] "

អ្នកនិពន្ធ : រកមិនទាន់ឃើញ ៗ

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ៗ

របៀបនិពន្ធ : ពាក្យកាព្យ (បទកាកគតិ) និង ពាក្យរាយ ពន្យល់ន័យក្នុងសាស្ត្រាច្បាប់ក្រម ៗ

ប្រភពរឿង : សុជីវធម៌ និង សីលធម៌ ៗ

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ៨ ស្សែ ស្សែ ១ មានសន្លឹក ៦, ទី ២ មានសន្លឹក ៩, ទី ៣ មានសន្លឹក ១០, ទី ៤ មានសន្លឹក ៩, ទី ៥ មានសន្លឹក ១៣, ទី ៦ មានសន្លឹក ១១, ទី ៧ មានសន្លឹក ១៦, ទី ៨ មានសន្លឹក ១៣ ៗ លេខសាស្ត្រា ១៣៧៧ ៗ

---

១ អត្ថបទពន្យល់ អធិប្បាយ សាស្ត្រាច្បាប់ក្រមនេះ ប្រហែលជាគេទើបនិពន្ធឡើងជាន់ក្រោយទេ ។ អត្ថបទនេះ មានវិបត្តិទាំងអក្ខរាវិរុទ្ធទាំងពាក្យពេចន៍ និង អត្ថន័យ ច្រើនអន្លើណាស់ គេមិនអាចស្តាប់តាប់យកសេចក្តីបានដូចម្តេចទេ ។

អត្ថបទផ្ដើម : នេះគឺច្បាប់ក្រម ប្រសើរឧត្ដម ទូន្មានអ្នកផង ប្រើទទួលគោរព កុំបីមានថ្នង ប្រាជ្ញបុណ្យផង កើតដោយប្រណិបតន៍ ។

ក្រមគឺស្រឡាញ់ មានអត្ថ ២ មានសេចក្ដីអធិប្បាយដូចម្ដេចខ្លះ ហ្ន៎អ្នក? . . . . . . . . ។ល។

អត្ថបទបញ្ចប់ : ស្វែងធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហាបាតិមោក្ខ គឺនិព្វានហោង ។

នេះដូចសត្វលោកយើងសព្វថ្ងៃ គណនាដូចសត្វបក្សីចាបបានកាប់សំបុកទុកកូនទៅ ។ លុះព្រឹកស្វាងកាលណាហើយក៏ហើរចរយាត្រា ទៅរកចំណីស៊ីចំអែតអាត្មា នាំអស់ផលាហារវិលចូលមកសំបុកវិញ ។ ខេមំ ។ គេរៀមក្សាន្តដោយអរិយមគ្គប្រាសចាកទុក្ខ ។ ទំស្វែងរកធម៌ជាផ្លូវ ទៅមកបានហើយទៅកាន់មហាបាតិមោក្ខ គឺចូលហើយចេញ ហើយចូលមកវិញ។ ពុំនោះសោតបីដូចរូបយើងទាំងឡាយពលគ្នា សព្វ (ថ្ងៃ) នេះមានតែព្រះនិព្វានធម៌នោះជាទីពឹង ព្រោះកើតហើយស្លាប់ ស្លាប់ហើយកើតឡើងវិញ មិនមានខ្លះអ្នកឯណាឡើយ ហៅថាព្រះនិព្វានហោង ។ អត្ថទី ១០ ឯរំ ចប់ដោយប្រការអម្បាលណោះហោង ។ ×

× ×

បំណងជើង : " សាស្ត្រា ទាវឯក "

អ្នកនិពន្ធ : រកពុំបានឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ ៧ (និង បទកាកគតិ បទពំនោល) ។

ប្រភពរឿង : ព្រឹត្តិការណ៍១ក្នុងសម័យលង្វែក (ចលនាខេរនិយម) ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត អក្សរជ្រៀង ទំព័រនីមួយ ៗ មាន ៥ បន្ទាត់ ១ខ្សែចប់ ចំនួនសន្លឹក ៣៤ ។ ឯកសារនេះមាន នៅវត្តព្រែកក្រើស ខេត្តកំពត ។

អត្ថបទផ្តើម : នេះនឹងថាថ្លែងពីនេនទុំ នៅខេត្តបាភ្នំដែនដីស្រែ
សង្កាត់សូត្ររៀនចប់អត្ថប្រែ ស្រុកស្រែល្បីគ្រប់សព្វដែនដី ។
បួសនេននៅវត្តវិហារធំ ចិន-ខ្មែរកុះករពាំងប្រុស-ស្រី រៀនសូត្រ
ធម៌អាថ៌សាស្ត្រាគម្ពីរ បទបែបបាលីសឹងបេះព្រម ។ មាននេន
មួយសោតឈ្មោះនេនពេជ្រ រៀនសព្វសេចក្រេបមានរូបឆោម
រឹងចំណោះបេះយ៉ាងល្អម រូបឆោមមុខល្អយ៉ាងកណ្តាល ។ . .
. . . . . . . . ។ល។

---

• ខុសចាប់ផ្តុំងចួន នៅចុងទី ៣ គួរ "ពាលពលស្រែក្រៅ,, ទើបអាចចាប់ចុងចួនបាន។ ការភ្លាំងភ្លាត់ ប្រហែលកើតឡើងដោយការចារចម្លងតៗគ្នា?

សូមជំរាបថា រឿងទុំទាវតែមួយ តែមានចំណងថា "ទាវឯក" ក៏មាន ថា "ទុំទាវ" ក៏មាន ប៉ុន្តែអត្ថន័យប្រហែលជាមានប្លែកៗពីគ្នាខ្លះៗ សូមប្រៀបធៀបមើល ។

អត្ថបទបញ្ចប់ : ជាចិត្តនេះមានះ ពះលោភពះ ពុំកោតបេស្ដា អាង តែអាពុក បានជាទុកញ៉ា អវជូននោះណា ជាស្ដេចគ្រាញ់ក្រៅៗ សម្ងាប់ឲ្យអស់ ក្រៅលែងពីនោះ ឲ្យមើលតែឈ្មោះ ដោយ ញាតិជិតឆ្ងាយ ញាតិជីដូនមួយ ពាលពលសង្រេក[1] ៗ អស់ ញាតិណា ៗ ដែលម្ចាស់មេត្តា ទុកជីវិតនៅ ស្ដេចឲ្យចូលជា អ្នកងារវិញទៅ ប៉ុន្មានដែលនៅ ខេត្តត្បូងឃ្មុំហោង ។

អ្នកកត់ចុចនូបទុម ចារចម្លងចប់ នៅថ្ងៃពុធ ៥ កេច ឆ្នាំមមី ឆស័ក ព.ស. ២៤៨១, ។

×××

បំណងរឿង : " សាស្ត្រា ច្បាប់ចាស់ ,,

អ្នកនិពន្ធ : ព្រះអង្គសត្ថា ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ បទកាកគតិ ។

ប្រភពរឿង : ធម្មសង្វេគ តាមគោលពុទ្ធនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ ៤ សន្លឹក ។ ពុទ្ធសាសនបណ្ឌិត្យ បានចារចម្លងអំពីវត្តក្រាយតូង ខេត្ត កំពង់ចាម ចុះលេខសាស្ត្រា ៦៣៩ ។

---

១ ពាក្យនេះមិនត្រឹមត្រូវសោះ តែច្បាប់ដើមដូច្នេះ ។

អត្ថបទផ្ដើម : នេះបទកាក ។ សូរ្យសែនរង្សី គ្រឡប់រស្មី ស្រយុត
ចាប់ទៅ ផះផិតជនក្ដ ស្រទំនិត្យនៅ រមិលមើលទៅ
ពពកសាត់ឆ្ងាយ ។

ទុះទុអនិច្ចា ព្រះសែនសូរ្យា ដូចរូបតាំងឡាយ រីឯពពក
សាត់ជ្រកទៅឆ្ងាយ បីដូចរូបកាយ វិញ្ញាណយើងឯង ។

. . . . . . . ។ល។ . . . .

អត្ថបទបញ្ចប់ : ធ្វើបុណ្យទុកទៅ ពាន់ខ្លួនរស់នៅ បែកចាយធនធាន
ជីវិតជាមនុស្ស រស់នៅវិញ្ញាណ ក្សោសីលតាម
សំរាប់ខ្លួនចាស់ ។

ព្រះអង្គសគ្គា គន់គិតថែងតារ ចងជាច្បាប់ច្បាស់
តាំងទុកសណ្ដាប់ សម្រាប់ក្មេងចាស់ ឲ្យដឹងជាក់ច្បាស់
ដោយច្បាប់នេះហោង ។

xxx

បំណាំងជើង : « សាស្ត្រា ចៅតាំព្រា »

អ្នកនិពន្ធ : រកមិនបានឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធន៍ : បទកាកគតិ ។

ប្រភពរឿង : ច្បាប់សីលធម៌-សុជីវធម៌តាមប្រពៃណីនិយម ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៧ សន្លឹក ។

ឯកសារនេះ គេចារជាតួអក្សរល្អិត ។ មាន ៤ បន្ទាត់ក្នុង ១ ទំព័រ ពុទ្ធសាសនបណ្ឌិត្យបានឯកសារនេះ អំពីវត្ត . . . . (រលំបាត់) ខេត្តបាសាក់ ( កូសាំងស៊ីន ) ចុះលេខសាស្ត្រា ៦១៨ ។

អត្ថបទផ្ដើម : នេះបទកាកគតិ ។ ទុកទៅក្រោយ ពន្ធកស្នួនភ្ញា សម្លាញ់អាពុក បណ្ដូលសាច់ត្រួយ តែមួយជាមុខ ការកើត ការស្រុក ស្រែភ្លឺសាច់ផៅ ។ អាពុកមានស្នួន ព្រលឹងខ្លួម ខ្លួន សង្ឃឹមតែទៅ ជាច្បងបង្អស់ អំណោះវង្សទៅ អាពុក កន្សៀវ ខ្លួនចាស់ហើយណា ។ . . . . ។ល។

អត្ថបទបញ្ចប់ : ច្បាប់នេះសូមរេច តែងចប់សេចក្រេច

អស់អាចិដំកល់ ទោះអ្នកឯណា

ប្រាជ្ញាឈ្មោះយល់ រំពឹងឆ្ងាយសល់

ប្រុងប្រាជ្ញាវៃ ។

ត្រិះរិះបំរុង ត្បិតកើតមកក្នុង

បច្ចុប្បន្ននេះនៃ ប្រែខុសជាគាប់

ក្រឡាប់ពេកក្រៃ    កើតក្នុងលោកិយ .
គួរតែអនិច្ចា ។
បើអ្នកណាបាន    ច្បាប់នេះទូន្មាន
ទុកខ្លួនហើយណា    អ្នកនោះនឹងបាន
រួចពីទុក្ខា    ទោសក្នុងលោកា
និរទោសនិរភ័យ ។
ប្រកបទូរទ្រព្យ    ធនធានគ្រាន់គ្រប់
ខ្ញុំប្រុសខ្ញុំស្រី    តាមគួរដោយធម៌
ធម៌ប្រធានថ្លៃ    បរិបូណ៌ស្រេចនៃ
ដល់និព្វានហោង ។

X X X

## បំណាងជើង : " សាស្ត្រា ពេជ្ជតា(១) "

---

១ រឿងពេជ្ជតានេះ មានដំណើរវង្វេងរឿងប្រហែលនឹងរឿងសព្វសិទ្ធិដែរ ។ រឿងនេះដំណាល ពីសត្វប្រពេចញី–ឈ្មោល កាច់សំបុកពង លើមែកព្រឹក្សា ភ្លើងព្រៃឆេះរោលរាលមក ប្រពេចញីសុខចិត្តស្លាប់ជាមួយនឹងពងអាត្មា ហើយមុនស្លាប់សច្ចាថាជាម្ដាប្រុស កុំឲ្យខ្លួននិយាយរកប្រុសណោះ ។ ឯប្រពេចឈ្មោលបានឮដូច្នេះ ក៏តាំងសច្ចាថា សុំឲ្យជួបគ្នាជាគូប្រចាំជីវិតតទៅមុខទៀត ហើយហក់ចូលទៅស្លាប់ទៅ ។

ប្រពេចញីបានទៅកើតជារាជបុត្រីក្សត្រាអង្គ តាំងពីកើតមកដល់ធំ ឥតនិយាយរកប្រុសណាសោះ សូម្បីព្រះវររាជបិតាព្រះនាងក៏មិននិយាយរកដែរ ។ ឯប្រពេចឈ្មោលបានទៅកើតជាបុត្រក្សត្រអង្គដែរ ប៉ុន្តែគូព្រេងតែងបិនព្រាត់ ។ នៅទីបំផុតតួអង្គប្រុស មានចំណេះវិជ្ជាខាងសិល្បសាស្ត្រ ព្រមទាំងបញ្ញាឈ្លាសវៃ ។ ធ្វើឲ្យព្រះនាងជាគូព្រេងនិយាយរកទាល់តែបាន ។ គូព្រេងនេះ ក៏ត្រូវបានអភិសេកជាប្ដីប្រពន្ធ រួមសុខរួមទុក្ខជាមួយគ្នាតទៅទៀត ។

អ្នកនិពន្ធ : ភិក្ខុធម្មបញ្ញា ម៉ែន

កាលបរិច្ឆេទ : ថ្ងៃអង្គារ ៥កើត ខែអាសាឍ ឆ្នាំមមែ ព.ស. ២៤០១

(គ.ស. ១៨៥៨) ។

របៀបនិពន្ធ : ពាក្យកាព្យ (បទកាកគតិ -ពំនោល -ព្រហ្មគីត -

ភុជង្គលីលា និង លោមនាង ។

ប្រភពរឿង : រឿងនេះមានចំនងជារឿងជាតកមួយដែរ ប៉ុន្តែគ្មាន

បញ្ជាក់អំពីការសេជាតិ ដូចជាជាតកនានាទេ ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣៦ សន្លឹក ។

ឯកសារនេះពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត កងតាណឹង

ខេត្តកំពង់ចាម ចុះលេខ សាស្ត្រា ៦១២ ។ ឯកសារនេះចាស់

គ្រាំគ្រាពេក ខូតស៊ុសន្លឹកស៊ឹករឹតអស់ច្រើន ។

អត្ថបទផ្តើម : នេះបទកាកគតិ ។ យើងខ្ញុំបង្គំ ក្រញូងក្រាបប្រណម្យ

ដោយដាក់សិរសា ឆ្ពោះឆ្ពោះតម្រង់ ព្រះអង្គគគរ់ ក្រញូងក្រាប

វន្ទា ប្រក្រតីសព្វថ្ងៃ ។ ត្បិតខ្ញុំនេះកាត់ ចិត្តខ្វាំងពេកក្កាត់

លាកលេសនៃ មកបួសសំណាក់ កងពុទ្ធញាណញោយ្យ

សេក្ខហ័សព្វថ្ងៃ តាមពុទ្ធវចនា . . . ។ល។

អត្ថបទបញ្ចប់ : ប្រពេចញ៉ីង គន់គិតដញ្ញីង សច្ចាផ្តេជា មិនឲ្យស្រដី ទីងប្រុសណា។ ដល់កើតជាតិជា មនុស្សប្រុសស្រដី ។ ប៉ុន្តែ ប្រពេច ឈ្មោលចិត្តមិនដាច់ ពីគ្នាឡើយនៃ សច្ចាឲ្យបាន ឈ្មះស្រីទីទៃ មើបបានមូលមៃ ជាគូគ្នាវិញ ។ ចប់មួយនិទាន លោកប្រើឲ្យបាន ដឹងអាថ៌នោះវិញ ទើបគិតលើកគ្នា លោក ប្រែថែងចេញ ចប់និទានមិញ និដ្ឋិតំសូរេច ។

×××

បំណងជើង : " សាស្ត្រាព្រះចានយសគេត្តិ "

អ្នកនិពន្ធ : រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ : គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ : ពាក្យកាព្យ - បទកាកគតិ - ពំនោល - ព្រហ្មគីតិ - កុជង្គលីលា ។

ប្រភពរឿង : រឿងជាតកមួយ (ប៉ុន្តែគ្មានបញ្ជាក់) ថាឋិតនៅក្នុងក្រុមជាតកណាទេ ។ ឯចលនារឿងមានកំសត់ ព្រាត់ប្រាស លទ្ធិកម្មផល ពៀរវេរា ដូចរឿងក្រុងសុភមិត្រដែរ ប៉ុន្តែសកម្មភាពរបស់តួអង្គប្លែកផ្សេងគ្នា ។

លក្ខណៈឯកសារ : សាស្ត្រាស្លឹករឹត ២ ខ្សែចប់ជុំជាតក់ ។ ខ្សែទី ១

មាន ៤៣ សន្លឹក, ខ្សែទី ២ មាន ២២ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តកំពោរព្រៃក្មេង ( អានដោយស្មាន អក្សរលុបអស់ច្រើន ) ខេត្តកំពង់ចាម លេខ ៦០៨ ។

អត្ថបទផ្តើម : នេះបទកាកគតិ ។ លុតលើកកំបង់. អញ្ជលីផ្គង់
ថ្វាត់ថ្វាយវន្ទា ព្រះអង្គត្រាស់ត្រេច សារពេជ្ញសាស្តា
បុណ្យបារមីតា លើសលើកពន្ត្រៃ ។ ព្រះអង្គឧត្តម
ខះខំសន្សំ ព្រះបារមីថ្លៃ ព្រះអង្គបានត្រាស់
ច្បង់ច្បាស់ញាណញ្ញេយ្យ ជាព្រះពុទ្ធថ្លៃ បុណ្យបារមីតា ។
ខ្ញុំសូមបង្គំ ព្រះធម៌ឧត្តម . . . . ។ល។

អត្ថបទបញ្ចប់ : ឯកជកុមារ អង្គអញ្ញតជា. គតឯងនោះនៃ
បានត្រាស់ប្រាជ្ញា សារពេជ្ញញាណញ្ញេយ្យ ជាព្រះពុទ្ធថ្លៃ
ប្រោសសព្វសត្វផង ។ ឯស្តេចវិលោ ចិត្តច្រើសលោភោ
រង់ស្រូកក្នុង ចេរវិលវិងមក យោនយកជាតិហោង
ទៅវត្តច្រើសឃ្លង ប្រមាថពុទ្ធអង្គ ។

ព្រះអង្គពេជ្ញញាណ ស្តេចនាំនិទាន កាលជាតិក្នុង
ឆ្ងាយទៅលង់ក្តាត់ ប្រមូលមកផ្គង់ ជុំជាតកហោង
សូត្រេចម៉េះណា ។ (ទៅមាតត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ងួ-តាង

ប្រែ-រៀបរៀង

(៣)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ—អ៊ុន

ព្រោះយើងគិតយល់គួរទៅដល់ប្អូនណាស់ ព្រោះពីដើមស្រុកទេសរាស្ត្រកើតបះបោរចលាចលពាល់តែខ្ទេចខ្ទីវិនាសអស់ បណ្តារាស្ត្រក៏រត់ទៅជ្រកកូនដោយព្រៃភ្នំក្រំថ្ម លុះតែប្អូនលើកទ័ពទៅប្រាបប្រាមសឹកសត្រូវ ទើបបានស្រុកភូមិរាបទាបដរាបមកដល់ឥឡូវនេះ គ្រានេះអស់បុណ្យប្អូនទៅហើយ បានប្អូនជំនួសទីបិតា មានសតិបញ្ញាអានុភាពលើសជាងបិតាទៅទៀត អាណាប្រជារាស្ត្រទាំងពួង ក៏និយមរាប់អានស្រឡាញ់ពេញចិត្តស្មគ្រ សុំឲ្យអ្នកឡើងសោយរាជសម្បត្តិជំនួសយើងចុះ លុះធ្វើរួចក៏ចាត់ប្រើចៀវអ៊ីម ឲ្យនាំព្រះរាជសារនិងត្រាសម្រាប់រាជ្យទៅប្រគល់ឲ្យប្អូន ។

ប្អូនបានឃើញព្រះរាជបន្ទូលដូច្នោះ ក៏មានអំណរណាស់ ទើបនិយាយនឹងការសៀងថា៖ ព្រះចៅបៀនគេ ប្រគល់ត្រាសម្រាប់រាជ្យមកឲ្យយើងដល់២ដងហើយ បើនឹងទទួលយកវេលានេះ ក៏មិនទាន់ផុតអស់

សេចក្តីទិន្នា កាសៀនឆ្លើយថា បើទ្រង់នៅបារម្ភពុំអស់ព្រះទ័យ ត្រូវត្រាស់ប្រើទៀវអ៊ុមឲ្យនាំយកត្រាទៅថ្វាយវិញម្តងទៀត ឲ្យទៀវអ៊ុមនិយាយនឹងហ៊ួហ៊ុម ឲ្យទូលព្រះចៅហៀនគេថា៖ បើព្រះអង្គទ្រង់ព្រមប្រគល់រាជសម្បត្តិឲ្យចូគីប្រាកដហើយ. ចូរឲ្យចាត់ការសង់រោងពិធីអភិសេកឲ្យខ្ពស់មានថ្នាក់៣ជាន់ ប្រដាប់ទះរាំនៅតាមរបៀបមទ់ ទង់ ឆត្រនានា តាមបូរាណរាជប្រវេណីធម្មតាឲ្យសព្វគ្រប់ លុះបានឫក្សពារពេលាល្អ ក៏ត្រូវឲ្យប្រជុំនាម៉ឺនសព្វមុខមន្ត្រីតូចធំឲ្យព្រមគ្នា ទៅប្រជុំក្នុងរោងរាជពិធី ហើយឲ្យចូគីឡើងអង្គុយលើមហាបុស្បកដែលខ្ពស់ អស់នាម៉ឺនក្រៅពីនោះ ឲ្យក្រាបថ្វាយបង្គំដុំពីក្រោមរាជបល្ល័ង្ក ហើយត្រូវព្រះចៅហៀនគេ ទ្រង់ស្រោចទឹកស័ង្ខប្រគល់ព្រះខ័នទិងត្រាសម្រាប់រាជ្យថ្វាយព្រះចៅចូគី ជាទីរាជាភិសេកឯកក្សត្រិយ៍សោយរាជសម្បត្តិតទៅ បើព្រះចៅហៀនគេធ្វើតាមដូច្នេះហើយ ទ្រង់ក៏នឹងអស់សេចក្តីគរហានិន្ទា ។

ចូគីបានឮកាសៀនទូលដូច្នោះ ក៏ពេញព្រះទ័យណាស់ ទើបត្រាស់ប្រើទៀវអ៊ុមឲ្យនាំត្រាទៅថ្វាយព្រះចៅហៀនគេទៀត ឲ្យហ៊ួហ៊ុមនាំឡើងទៅទូលតាមពាក្យកាសៀនគ្រប់ប្រការ ព្រះចៅហៀនគេ ទ្រង់សួរអស់នាម៉ឺនទាំងពួងការថា ហេតុម្តេចបានជាចូគីនៅមិនព្រមទទួលរាជសម្បត្តិឲ្យផុតទៅតែម្តង ហ៊ួហ៊ុមទូលថា ដែលចូគីនៅមិនទាន់ទទួលនោះ ព្រោះឃើញថា ព្រះអង្គប្រគល់រាជសម្បត្តិខុសអំពីទម្លាប់ច្បាប់រាជប្រវេណីបុរាណ

ច្រើនប្រការ ហ្លួងហ៊ឹមក៏ពណ៌នាតាមសំដីការសៀនឲ្យទិយាយនោះ ទូល
ព្រះចៅហៀនគេគ្រប់ប្រការហើយទូលថា បើព្រះអង្គនឹងប្រគល់រាជសម្បត្តិ
ឲ្យបូកីនោះ ត្រូវតាត់ការធ្វើឲ្យបានដូចសេចក្តីដែលទូលបង្គំទូលនេះ ទើប
បូកីព្រមទទួលជាប្រាកដ នោះទាំងខ្លួនព្រះអង្គនិងព្រះញាតិវង្សរបស់ព្រះ
អង្គ ក៏នឹងបានពឹងបុណ្យបូកីជាសុខតទៅ ។

ព្រះចៅហៀនគេបានទ្រង់ព្រះសណ្តាប់ ក៏គ្រវីព្រះកេសាហើយដក
ដង្ហើមធំ ទើបបង្គាប់ឲ្យថៃសៀនជាមេការទៅតាក់តែងកេងពិធីតាមទំនៀម
បុណ្យរាជាភិសេកស្រេចហើយ លុះដល់ខែកត្តិកថ្ងៃ ៩ កើត ជាប្ញក្សជោគ
ជ័យល្អ លុះព្រឹកព្រាងស្វាងព្រះទិនករ ក៏អញ្ជើញបូកីឲ្យឡើងគង់លើ
បល្ល័ង្កបុស្បុក អស់ពួកនាម៉ឺនមុខមន្ត្រីតូចធំមកប្រជុំគ្នាប្រហែល ៤០០ ចូល
ទៅគង់គាល់ជុំវិញកេងរាជពិធីជាមហោឡារិក មានទាហានទាំងពួកជើង
គោកជើងទឹកប្រមាណ ១០ ម៉ឺន កាន់នូវគ្រឿងសាស្ត្រាវុធ ព័ទ្ធជាច្រើន
ជាន់ដើម្បីការពារអន្តរាយផ្សេងៗ ។

ខណៈនោះ ព្រះចៅហៀនគេ ក៏តាំងព្រះទ័យមានៈស្ទុះក្រោកកាន់
ព្រះសែងគ្របនិងត្រាសម្រាប់រាជ្យ ហើយនឹងព្រះបន្ទូលសញ្ញា ឡើងទៅ
លើមហាបុស្បក ក៏ហុចប្រគល់ទៅឲ្យបូកី ។ ក៏ទទួលយកហើយហុច
ព្រះតម្រាស់នោះទៅអាលក្ខណ៍សូត្រប្រកាសប្រាប់អស់នាម៉ឺនមុខមន្ត្រី នូវ
អស់អាណាប្រជានុរាស្ត្រទាសករទាំងឡាយ សឹងថ្វាយសព្ទសាធុការពរ

ÉCOLE FRANÇAISE
BIBLIOTHÈQUE
P.P.

ជាកោលាហលអើកក្រើកមហិមា សន្មតថ្វាយព្រះនាមថា ព្រះចៅអ៊ួយប៉ូចូគីកំតាំងនៅក្នុងទីសម្មតិក្សត្រិយ៍ទក្តយពងតាំងពីនោះមក (ព.ស.៧៦៣) ព្រះចៅចូគីកំតាំងទីក្រុងហ៊ូគោ ប្រែជាក្រុងតៃវុយកុក ហើយត្រាស់ឲ្យលើកលែងយកពន្ធសួយសារអាករអំពីពស្ត្រប្រជាគំរប់ ៣ ឆ្នាំ និងឲ្យបើកលែងមនុស្សទោសក្នុងគុក ហើយឲ្យតាំងអក្សរនៅទីអនុស្សាវរីយ៍ ដែលបញ្ចុះសពបិតាជាថ្មី ហៅថាព្រះចៅថៃឡហ៊ូហង់តេ ហ៊ួហ៊ីមនាំយកសេចក្តីក្រាបទូលថា ប្រវេណីបូរាណលោកមិនដែលឲ្យមានម្ចាស់ផែនដីដល់ ២ ព្រះអង្គគង់នៅក្នុងនគរជាមួយគ្នាទេ ដែលទ្រង់នឹងឲ្យព្រះចៅហៀនតេទៅគង់នៅទីដំបន់ណា ឬប្រការម្តេចក៏ត្រូវសម្រេចឲ្យឆាប់ប្រញាប់ទៅ ហើយហ៊ីមបង្គាប់ឲ្យព្រះចៅហៀនតេម៉បស្តាប់ព្រះតម្រាស់ព្រះចៅចូគី ១ ក៏តាំងព្រះចៅហៀនតេឡើងជាទីវិសេស ហៅថាសាន់អៀងកុង ហើយឲ្យទៅនៅដំបន់សាន់អៀង ទីនោះមិនត្រូវឲ្យមានដំណែងគាល់ហៅឡើយ ឯបៀវត្សសម្រាប់ឆ្នាំក៏មិនត្រូវឲ្យមាន នោះសាន់អៀងកុងក៏លាចេញទៅ ហ៊ួហ៊ីមហ៊ូតគ្របឡើងកាន់ហើយស្រែកថា ជាទំនៀមប្រវេណីផែនដីវៀងមក បើមួយអង្គទ្រង់ពងសម្បត្តិហើយ ត្រូវកំចាត់មួយអង្គចេញ ព្រះចៅចូគីប្រោសប្រណីទ្រង់ណាស់ ហើយបានជាទុកព្រះជន្មប៉ុណ្ណេះ ថែមតាំងជាទីសាន់អៀងកុងទៀត ជាព្រះតេជះព្រះគុណគ្មានទីបំផុតទេ អំណើះពីនេះទៅ បើមិនមានព្រះតម្រាស់ឲ្យហៅទ្រង់ចូលមកគាល់ទេ នឹងចូល

មកពុំបានជាដាច់ខាត សាន់អៀងកុងទ្រង់ព្រះវិយោគ ក៏ក្រោកលាចេញទៅ ហើយឡើងគង់លើសេះនាំអស់គ្រប់គ្រួទៅទៅឯជំរំអៀង ខណៈនោះអស់បណ្ដាជនទាំងឡាយ ឃើញសាន់អៀងកុងត្រូវនិរទេសដូច្នោះ ទាំងអស់គ្នាក៏មានសេចក្ដីអាណិតអាសូរពន់ប្រមាណណាស់ សឹងតែយំស្រណោះអាលោះអាល័យក្រៃពេក ។

ឯព្រះចៅចូកពេញទីជាក្សត្រិយ៍ខត្តិយកង មានរិទ្ធិអំណាចលើសលុប ទ្រង់ប្រារព្ធនឹងអស់មន្ត្រីទាំងពួងថា : ការដែលយើងធ្វើទាំងអម្បាលនេះ ត្រូវតាមច្បាប់ទំនៀមបូរាណហើយឬម្ដេច? អស់នាម៉ឺនខ្ញុំរាជការសឹងក្រាបទូលថា ដែលព្រះអង្គទ្រង់តម្រិះដូច្នេះ ជាត្រឹមត្រូវតាមបូរាណរាជប្រវេណីណាស់ហើយៗ ក៏នាំគ្នាសរសើរព្រះសតិបញ្ញាជាអនេកប្បការផ្សេងៗ ហើយថាគួរព្រះអង្គនឹងតាក់តែងគ្រឿងសក្ការបូជាពលីការទេពតាអារក្សដែលស័ក្ដិសិទ្ធិ បំរើនបុញ្ញារិទ្ធិឲ្យថ្កើងរុងរឿងឡើងទៀត ព្រះចៅចូកទ្រង់យល់ឃើញផង ក៏ត្រាស់ឲ្យភ្នាក់ងាររៀបតាក់តែងគ្រឿងសែនព្រេនតាមទំនៀម កាលព្រះចៅចូកចេញទៅរៀបសែនព្រេននៅទីពិធីនោះ ក៏បណ្ដាលឲ្យកើតជាព្យុះខ្យល់ខ្លាំងធំអស្ចារ្យ បណ្ដាគ្រឿងអាមិសពលីការជាធូបទៀនទាំងឡាយ ក៏រលំរលត់ខ្ចាត់ខ្ចាយទៅអស់ ផ្គរបន្ទោរក៏ឃាលប្រវាត់ព័ទ្ធពេញអាកាស ដុំថ្មក៏ប្រឡាសខ្ទាតឡើងទង្គិចគ្នាជាកោលាហល ខ្យល់ក៏បក់ផាត់ងងឹតអស់ទិសទី មេឃមួររលឹមធ្លាក់មក មនុស្សម្នាក៏គិត

ភ័យរត់ជ្រកពួនសព្វស្ថាននានា ទីងមើលគ្នាក៏ពុំឃើញពុំយល់សោះឡើយ ។

ព្រះចៅចូក៏ភ័យតក់ស្លុតរន្ធត់ស្មារតីដួលសន្លប់ទៅ លុះអស់ព្យុះខ្យល់ស្ងប់ស្ងាប់វេលាណា បណ្ដានាម៉ឺនមុខមន្ត្រី ក៏ក្រឡេកឃើញព្រះចៅចូក៏ដួលសន្លប់ដូច្នោះ ក៏នាំគ្នាស្ទុះទៅលើកគ្រាហ៍ឡើងបានមួយស្របក់ ទើបព្រាកដឹងព្រះអង្គ នាម៉ឺនទាំងពួងក៏អញ្ជើញស្ដេចចូលទៅក្នុងព្រះរាជវាំង ព្រះចៅចូក៏ទ្រង់ប្រឈួនជាប់រាយូរថ្ងៃ មិនបានចេញស្ដីរាជការ លុះស្បើយព្រះឈួនកាលណាក៏ឧស្សាហ៍មានព្រះទ័យចេញទៅកាន់ទីព្រះរាជរោងរម្យ ទ្រង់និយមលើកសរសើរអស់ពួកខ្ញុំរាជការ ហើយឲ្យលៀងយសសក្ដាជាលំដាប់គ្រប់ៗគ្នាតាមគុណានុរូប ឯព្រះរោគនោះក៏មិនទាន់សះជា ព្រះចៅចូក៏មានព្រះទ័យសង្ស័យ ក្រែងខ្មោចព្រៃព្រាយបិសាចកាចខូចនៅក្នុងទីព្រះរាជវាំង ច្រើនណាស់មកពាល់ប៉ះធ្វើឲ្យព្រះអង្គទ្រង់អាពាធមិនសះជា ព្រះអង្គក៏ទ្រង់បន្ទាថា គួរនឹងប្រែទីឋានទៅរកវិមានប្រាសាទឯទីដទៃទៀតចុះ លុះគិតដូច្នោះ ក៏ត្រាស់បង្គាប់ភ្នាក់ងារឲ្យម៉ឺនទៅកសាងវាំងកំពែងឯទីស្រុកឡូកអៀងវិញ អស់ពួកភ្នាក់ងារនោះមិញក៏ចេញទៅចាត់ការកសាងព្រះរាជវាំងថ្មី នៅទីស្រុកឡូកអៀងហើយស្រេច ព្រះចៅចូក៏ស្ដេចទៅគង់នៅទីនោះ ខណៈនោះមានបំរើស៊ើបការនាំអាថ៌ពត៌មានទៅក្រាបទូលព្រះចៅឡៅពីថា ៖ តាមដំណឹងជាប្រាកដថា ចូកីប្រហារជីវិតព្រះចៅហៀនតេ ហើយដណ្ដើមយកបានរាជសម្បត្តិ ឡើង

សោយរាជ្យជាព្រះមហាក្សត្រិយ៍គង់នៅស្រុកឡុកអៀង ។

ព្រះចៅឡៅពីញ្ញដូចោះ ក៏ទ្រង់ព្រះកន្ទៀងកិលាបអាណិតអាណាថណាស់ ត្រាស់ឲ្យបង្គាប់សព្វមុខមន្ត្រី និងអាណាប្រជានុរាស្ត្រប្រុសស្រីស្លៀកពាក់សកាន់ទុក្ខ ហើយឲ្យគាត់តែងគ្រឿងសែនព្រះសពតាមទម្លាប់ទំនៀម ហើយឲ្យចារឹកព្រះនាមព្រះចៅហៀនគេថា ព្រះចៅហៅមិន-ហង់គេ ដាក់ក្នុងក្ការឈើក្រអូបតាំងទុកបូជា តាំងពីនោះមកព្រះចៅឡៅពីក៏ទូរទុកក្តៅក្រហាយពុំមានសប្បាយក្នុងព្រះទ័យសោះ ចាប់ព្រះរោគអាពាធសព្វអស់ព្រះកងកាយ នឹងចេញនិយាយជារាជការក៏ពុំបាន ទ្រង់ប្រទានមុខងារឲ្យខុងបេងចេញនិយាយរាជការជួសព្រះអង្គ ខុងបេងក៏ឲ្យហៅទៅចេង និងដៀវជីវ នូវអស់នាម៉ឺនទាំងពួងមកប្រឹក្សាថា វេលានេះចូភីវរំលាងព្រះចៅហៀនគេសាបសូន្យទៅហើយ គួរយើងលើកព្រះចៅឡៅពីឲ្យពេញទីជាព្រះមហាក្ស ត្រិយ៍ សោយរាជសម្បត្តិព្រះរាជវង្សព្រះចៅហៀនគេតទៅចុះ ។

ដៀវជីវថា ខ្ញុំបាទបានឃើញខណ្ឌសីមាស្រុកសែឈួន មានទីអស្ចារ្យដោយប្រការផ្សេងៗប្លែកច្រើនណាស់ បានឃើញច្បាស់ជាផ្កាយប្រចាំខ្លួនឡៅពីមានទីរុងរឿងដោយពន្លឺស្មើភ្លឺស្មើព្រះចន្ទ្រ ដែលយើងនឹងលើកឡៅពីឡើងកាន់ទីជាក្សត្រិយ៍ ក៏គិតឃើញគួរល្មមណាស់ ព្រោះឡៅពីជាព្រះរាជវង្សស្រាប់ អស់មុខមន្ត្រីទាំងឡាយបានស្តាប់ ក៏យល់

ឃើញត្រូវតាំងរកស៊ីគ្នា ទើបធ្វើរឿងរ៉ាវតាមច្បាប់ លើកឡើងពីជាទីក្សត្រិយ៍ឲ្យឡើងសោយរាជសម្បត្តិកុងផែនដី ក៏នាំសេចក្តីនោះយកទៅថ្វាយ ឡើងពីបានឃើញសេចក្តីចុតហ្មាយដូច្នោះ ក៏នឹកស្តូវនូវគត់ចិត្តគិតថា បណ្តាមន្ត្រីតាំងរកស៊ីនេះ ដែលមកនាំឲ្យយើងធ្វើដូច្នេះ ដើម្បីមិនឲ្យកាន់ចិត្តដោយស័ត្យនូវធម៌បាន គិតហើយក៏មានរាជាឆ្លើយប្រកែកកុំទទួល ខុងបេងក៏ក្រាបទូលទៅថា បណ្តាជាខ្ញុំទាំងឡាយដែលទំទូលខ្វាយគិតគ្នាតាំងម៉េះ ព្រោះយល់ឃើញថា ចូកីជាតួដណ្តើមយករាជសម្បត្តិជាតិលោហិតរបស់ព្រះអង្គ បានជាចង់លើកឲ្យទ្រង់គង់ជាម្ចាស់ផែនដីតទៅ ។

ឡើងពីថា បើយើងព្រមទទួលធ្វើជាម្ចាស់ផែនដីនេះហើយ ទោះបីបើយើងមិនបានដណ្តើមយករាជសម្បត្តិដូចគេ ក៏គង់មានគេថាដូចជាដណ្តើមរាជសម្បត្តិដូចអាសត្រូវនោះដែរ ថាតែប៉ុណ្ណោះក៏ក្រោកឡើងចូលទៅក្នុង លុះកន្លងមកពាំថ្ងៃ ខុងបេងឲ្យប្រជុំអស់នាម៉ឺនមុខមន្ត្រីចូលទៅគាល់ព្រមគ្នា ទៅបេងទូលថា បណ្តានាម៉ឺន និងបណ្តារាស្ត្រនានាសឹងមានសេចក្តីស្នេហាស្រឡាញ់ទ្រង់ បង់ឲ្យឡើងសោយរាជសម្បត្តិពិតណាស់ ទើបប្រជុំយកព្រមគ្នាលើកព្រះអង្គឡើងជាមហាក្សត្រិយ៍សោយរាជសម្បត្តិតទៅ ដើម្បីនឹងលើកទ័ពទៅកំចាត់អាសត្រូវចូកីឲ្យវិនាសចេញបំផ្លាញរាជនេះមិញ ជាទីសងសឹកជំនួសព្រះចៅហៀនគេឲ្យបាន ។

( នៅមានត )

# ឯកសារ កម្ពុជសុរិយា

(ក)

លោក ឌឹក-គាម ប្រមូលរៀបរៀង

អកតញ្ញូរបស់ហោកតម្មបុត្ត : ទ.ក. ១៥, ទំព័រ ៩, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

អក្សរសាស្ត្រខ្មែរសង្ខេប : លោក ប៉យ-ប៊ុក ទ.ក.៩, ទំព័រ ៨២៨, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

អក្សរសាស្ត្រខ្មែរក្រោយសម័យអង្គរ : លោក ស៊ិន ហ៊ិន ទ.ក ៤, ទំព័រ ៣៩៧, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

អង្គរកេរ្តិ៍ដំណែលខ្មែរ : លោក ប៉េ-ប៊ុក ទ.ក. ៣, ទំព័រ ១៨៤, ឆ្នាំ ១៩៥០, (ម ៥២/២២) ។

អង្គរក្នុងសតវត្សទី ១៣ : យុទ្ធទិពន្ធមន្ត្រី ញ៉ុក-ថែម ទ.ក. ១, ទំព័រ ១៥, ឆ្នាំ ១៩៤៤, (ម.៥២/១៦) ។

អង្គរ និង សម័យអង្គរ : លោក ផេង-ជ្រី ទ.ក. ៧, ទំព័រ ៨២០, ឆ្នាំ ១៩៦២ (ម.៥២/៣៤) ។

អង្គរវត្តក្នុងសតវត្សទី១៦-១៧: ហ្លួងទិពន្ធមន្ត្រី ញ៉ុក-ថែម ក.ទ. ១១, ទំព័រ ៥៦១ ឆ្នាំ ១៩៤៦, (ម.៥២/១៨) ។

អង្គុជ្ជរកុមារ : លោក លាង-ហ័បអាន ទ.ក. ៣, ទំព័រ ២០៩,
ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

អជ្ជដិកាមក្ក : អ្នកឧកញ៉ា ព-សាន ទ.ក. ៦, ទំព័រ ៥០៣,
ឆ្នាំ ៩៦២ (ម.៥២/៣៤) ។

អណ្ដើកនិងស្វា : ទ.ក. ៧ ៨-៩, ទំព័រ ១៥២, ឆ្នាំ ១៩៣៣,
(ម.៥២/៦) ។

អណ្ដើកមាស : លោក លី-ធាមតេង ទ.ក ៨, ទំព័រ ៧៤៧,
ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អតិចារិណីយក្ខិនី : លោក ឈឿង-កុល ទ.ក. ៩, ទំព័រ ៦៤១,
ឆ្នាំ ១៩៤៩, (ម.៥២/២១) ។

អត្តកថា ព្រះមហា សៅរ៍-យ៉យ ទ.ក. ២, ទំព័រ ៨៣, ឆ្នាំ
១៩៥៤. (ម.៥២/២៦) ។

អត្តជាតសុខកថា : ព្រះមហា អ៊ុក-អ៊ុន ទ.ក. ១១, ទំព័រ ៩៦៩,
ឆ្នាំ ១៩៥៨ (ម ៥២/៣០) ។

អត្តនោកម្មការណកថា : ព្រះមហា អ៊ុក-អ៊ុន ទ.ក. ៩, ទំព័រ
៧៨៧, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

អត្តបេមកថា : ព្រះមហា ឡេ-ឡាប ទ.ក. ៤, ទំព័រ ២៤៤,
ឆ្នាំ ១៩៥៣, (ម.៥២/២៥) ។

អត្តានុទិដ្ឋិ : ទេកញ៉ សំ-ស៊ុន ទ.ក. ៣, ទំព័រ ១៧៦; ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

អត្តានុរក្ខកថា : ព្រះអាចារ្យ ផេង-សុខុំ ទ.ក. ៥, ទំព័រ ៣៣១, ឆ្នាំ ១៩៥៥; (ម.៥២/២២) ។

អត្តទ្វារកថា : ព្រះទេពាលិវង្ស សួរ-ហាយ ទ.ក. ៧, ទំព័រ ៦១០, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

អត្ថន័យនៃការសិក្សា : លោក សុន-ហ៊ិន ទ.ក. ៣, ទំព័រ ២៨៤, ឆ្នាំ ១៩៥៩, (ម.៥២/៥) ។

អធិបតេយ្យកថា ៣ យ៉ាង : ព្រះសាសនមុនី កិម គួរ ទ.ក. ១១, ទំព័រ ១០៨៣, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

អធិប្បាយច្បាប់កេរ្តិ៍កាល (កាព្យ) : លោក ស្រ៊-អ៊ូ ទ.ក. ៨, ទំព័រ ៧២៦, ឆ្នាំ ១៩៥៨, (ម.៥២/៣ ) ។

អធិប្បាយពុទ្ធភាសិត : លោក លី-ធាមតេង ទ.ក. ៩, ទំព័រ ៧៩៦, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អធិប្បាយសុភាសិត: យុនទត្តមប្រីជា តាប ពិន ទ.ក ៣, ទំព័រ ១២៩; ទ.ក. ៤, ទំព័រ ១៦៩, ឆ្នាំ ១៩៤៥. (ម.៥២/១៧) ។ ស្តើង-គួរ ទ.ក. ១០, ទំព័រ ១១៦៦, ឆ្នាំ ១៩៦០, (ម.៥២/៣២) ។

អធិប្បាយសុភាសិតខ្លះ (ពាក្យ : លោក ចាប-ពិន ខ.ក.៤,
ទំព័រ ៣៦៧, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

អជាមគតជមិ : យុនសុវត្ថិទៅ យូរ អ៊ុន ខ.ក.៧, ទំព័រ ៦១២,
ឆ្នាំ ១៩៥៧, (ម.៥៦/២៩) ។

អនាមយកថា : ខេមរវេជ្ជ ខ.ក.៣, ទំព័រ២៧, ឆ្នាំ ១៩៤ ,
(ម.៤២/១៣) ។

អនិច្ចកម្មនៃព្រះមហា ឈឹម-ឧដ៏ : ខ.ក.៨, ទំព័រ ៩១៨,
ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

អនិច្ចកម្មនៃព្រះធតមុនិ យូរ-ប៊ុណ្ណ : ព្រះទេពសត្ថា ស្វរ-ហាយ
ខ.ក.១១, ទំព័រ ៨៧១, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

អនិច្ចកម្មនៃព្រះអហោ មាស-សុវណ្ណ : ខ.ក.១០, ទំព័រ
១១៣១, ឆ្នាំ ១៩៦៤, (ម.៥២/១៦) ។

អនិច្ចកម្មនៃសម្តេចព្រះសង្ឃរាជនាយកគណៈធម្មយុត្តិក.
និកាយ ខ.ក.២, ទំព័រ ១៨៨, ឆ្នាំ១៩៥៦ (ម.៥២/២៨) ។

អនុត្តរិយសុត្ត : ព្រះវេជ្ជមាស់ សុធារស ខ.ក.១, ទំព័រ ២៧,
ឆ្នាំ ១៩២៧, (ម.៥២/២)

អនុមោទនវិធី : អាចារ្យ ប៉ែន-សុខ ខ.ក.១០, ទំព័រ ៩, ឆ្នាំ
១៩៣០ (ម.៥២/៣) ។

អនុស្សាវរីយចំពោះព្រះអាទសម្តេចព្រះនរោត្តម សីហនុ

វគ្គ : លោក អ៊ុង-ស៊ុមន៍ ទ.ក. ៣, ទំព័រ ២១២, ឆ្នាំ ១៩៥៥, (ម.៥២/២២) ។

អនុសិរក្ខរមហាសន្និបាតនៃមន្ត្រីសង្ឃ : ទី ៧ ទ.ក. ២, ទំព័រ១៥១, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។ ទី ១០ ទ.ក. ៣, ទំព័រ ២៣៥, ឆ្នាំ ១៩៥៤ (ម.៥២/២៦) ។ ទី ១១ ទ.ក. ២, ឆ្នាំ ១៩៥៥, (ម.៥២/២៧) · ទី ១២ ទ.ក. ១, ទំព័រ ៨៩, ឆ្នាំ ១៩៥៦, (ម.៥២/២៧) ។ ទី ១៣ ឯនបង់ ទ.ក. ៦, ទំព័រ ១៧៧, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។ ទី ១៥ ទ.ក. ១, ទំព័រ ៩៧, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។ ទី ១៦ ទ.ក. ១, លោក ជង-វង ទំព័រ ៩៨, ឆ្នាំ ១៩៦០, (ម.៥២/៣២) ។ ទី ១៩ ឆ្នាំ ១៩៦២, ទ.ក. ១, ទំព័រ ១០៧, ឆ្នាំ ១៩៦៣, (ម.៥២/៣៥)។ ទី ២០ ទ.ក. ១, ទំព័រ ៩៦, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។ ទី ២១ ទ.ក. ១, ទំព័រ ៧៨, ឆ្នាំ១៩៦៥, (ម.៥២/៣៧) ។

អត្ថាយរិត្តិនៃសត្វអស្សត្ថ : អ្នកទកញ៉ា ឥស្សរាជ្យ ស៊ំ-ស៊ុន ទ.ក. ២, ទំព័រ ៨៩, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

អនន្តរិយកម្ម : ព្រះទេពសត្ថា គឹម គូរ ទ.ក. ៩, ទំព័រ ៨០៣, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

អបរិហានិយធម៌ : លោក ប៊ុ-ប៊ូ ទ.ក. ៩, ទំព័រ ៩២៩, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

អប្បមាទកថា : ព្រះទេពសត្ថា គឹម-គូរ ទ.ក. ៣, ទំព័រ ២០៣, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អប្បមាទធម៌ : លោក ទ្រឹញ-ក៉ញ ទ.ក. ១០, ទំព័រ ៨៧៩, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អបាយមុខ : ព្រះគ្រូសិរីសោភ័ណ គឹម គូរ ទ.ក. ៧, ទំព័រ ៤៩៧, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

អភយទានពិសេស : ព្រះឧបាលិវង្ស សូ-ហាយ ទ.ក. ២, ទំព័រ ៨៧, ឆ្នាំ ១៩៥៥, (ម.៥២/២២) ។

អភិធម្មវិភាគ : ព្រះញាណបវរវិជ្ជា អែម .ក. ៨, ទំព័រ ១ ; ឆ្នាំ ១៩២៧, (ម.៥២/២) ។

អភិធម្មត្ថសង្គហ : ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូ ទ.ក. ២, ទំព័រ ១៩, ឆ្នាំ ១៩២៦-២៧, (ម.៥២/១) ។

អភិនវភាសិត : លោកគ្រូអាចារ្យ អ៊ុក-ជា ទ.ក. ៩, ទំព័រ ១២, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

អត្តជាគារ : ឃុនបណ្ឌិតក្បួ ប៊ូ-ប៉ូ ទ.ក. ៨, ទំព័រ ១៤៥, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

អរិយសច្ចកថា : ព្រះចៅបាលីវង្ស សួ-ហាយ ទ.ក. ៦, ទំព័រ ៥០៣, ឆ្នាំ ១៩៤៧, (ម.៥២/២៩) ។

អរិយសច្ចជាតុក្កភាសិត : លោកគ្រូអាចារ្យ ប៉ាង-ខាត់ ទ.ក. ១, ទំព័រ ៥២, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

អរិដ្ឋា : លោក ផេង-ដើរ ទ.ក. ២, ទំព័រ ១២១, ឆ្នាំ ១៩៥២, (ម.៥២/៣៤) ។

អរិដ្ឋា និង រិដ្ឋា : ព្រះញាណបវរវិជ្ជា អែម ទ.ក. ៣, ទំព័រ ៣៥, ឆ្នាំ ១៩៤៧, (ម.៥២/២) ។

អសារតារសូត្រ : ឧកញ៉ាភក្តីកជា យ៉ុង ទ.ក. ១-២-៣, ទំព័រ ៦៣, ឆ្នាំ ១៩៣៧, (ម.៥២/៦) ។

អាជ្ញាកាំអាចិន ( រឿងព្រេង ) : ទ.ក. ៤-៥-៦, ទំព័រ ១៤៣, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

អាជីវកម្មគឺអ្វី? : ខេមរវង្ស ទ.ក. ៥, ទំព័រ ៣, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

អាទួទឹង (រឿង) : អ្នកឧកញ៉ាសុត្តន្តប្រីជា ស់-ស៊ុខ ទ.ក. ១០, ទំព័រ ៥៤៣, ឆ្នាំ ១៩៤៣, (ម.៥២/១៩) ។

អាចោរចិត្តជា : ទកញ្ញាបញ្ញាធិបតី យិន ទ.ក ១-២-៣, ទំព័រ

១៦២ ឆ្នាំ ១៩៣៣, (ម.៥២/៦) ។

អាជីវកម្មចាំផ្ទៃរបស់ព្រះពុទ្ធសាសនា : លោក ប៊ូ ប៊ូ ទ.ក. ៧,

ទំព័រ ៨០. ឆ្នាំ ៩៦៣ (ម.៥២/៣៥) ។

អាណុភាពនៃខ្មែរអតីត : លោក ក៉យ-ប៊ុក ទ.ក. ៩, ទំព័រ

៨០៦, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អាប៊ូលហ្វាអ៊ូរិស : លោក ក៉យ-លុត ទ.ក. ១, ទំព័រ ៤៣,

ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

អាពុកក្មេកកើសក្ខ ប្រសារ : ទ.ក.១ - ២ - ៣, ទំព័រ

១២៥, ឆ្នាំ១៩៣៦ (ម.៥២/៨) ។

អាមាត្យក្រក្សាថ្ងៃផ្ទៀតព្រះរាជទ្រព្យ (រឿងព្រេង) : ទ.ក.

១៧-១៨, ទំព័រ ៦៦, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

អាយុសម័យនៃពុទ្ធរូប មន-ខ្មែរ-ថៃ : ទ.ក. ២, ទំព័រ ១៩,

ឆ្នាំ ១៩៤០. (ម.៥២/១២) ។

អារោគធាតុទាចាស់ : សាស្ត្រាចារ្យ ផេន-ជ្រើ ទ.ក. ១២,

ទំព័រ ៩១៤, ឆ្នាំ ១៩៥៧ (ម.៥២/២៣) ។

អារក្សថ្ងៃផ្ទៃរឿងថ្លៃត្រី (រឿង) : លោក សាំង-សាពត ទ.ក.

៣, ទំព័រ ៥៤៦, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

សោយរាជ្យជាព្រះមហាក្សត្រិយ៍គង់នៅស្រុកឡុកអៀង ។

ព្រះចៅឡៅពីឮដូច្នោះ ក៏ទ្រង់ព្រះកន្សែងកិលាបអាណិតអាណាថណាស់ ត្រាស់ឲ្យបង្គាប់សព្វមុខមន្ត្រី និងអាណាប្រជានុរាស្ត្រប្រុសស្រីស្លៀកពាក់សកាន់ទុក្ខ ហើយឲ្យកាត់តែងគ្រឿងសែនព្រះសពតាមទម្លាប់ទំនៀម ហើយឲ្យចារឹកព្រះនាមព្រះចៅហៀនគេថា ព្រះចៅហៅម៉ែន-ហង់គេ ដាក់ក្នុងក្អារឈើក្រអូបតាំងទុកបូជា តាំងពីនោះមកព្រះចៅឡៅពីក៏ខ្វល់ខ្វាយក្តៅក្រហាយពុំមានសប្បាយក្នុងព្រះទ័យសោះ ចាប់ព្រះរោគអាពាធសព្វអស់ព្រះអង្គកាយ និងចេញនិយាយរាជការក៏ពុំបាន ទ្រង់ប្រទានមុខងារឲ្យខុនបេងចេញនិយាយរាជការជួសព្រះអង្គ ខុនបេងក៏ឲ្យហៅទៅចេង និងដៀវដ៉ៃ នូវអស់នាម៉ឺនទាំងពួងមកប្រឹក្សាថា វេលានេះចូគីរាំណាងព្រះចៅហៀនគេសាបសូន្យទៅហើយ គួរយើងលើកព្រះចៅឡៅពីឲ្យពេញទីជាព្រះមហាក្សត្រិយ៍ សោយរាជសម្បត្តិតព្រះរាជវង្សព្រះចៅហៀនគេតទៅចុះ ។

ដៀវដ៉ៃថា ខ្ញុំបាទបានឃើញខបខ័ណ្ឌសីមាស្រុកសៃឈួន មានទីអស្ចារ្យដោយប្រការផ្សេងៗប្លែកច្រើនណាស់ បានឃើញច្បាស់ជាផ្កាយប្រចាំខ្លួនឡៅពីមានទីរុងរឿងដោយពន្លឺស្មើភ្លឺស្មើព្រះចន្ទ្រ ដែលយើងនឹងលើកឡៅពីឡើងកាន់ទីជាក្សត្រិយ៍ ក៏គិតឃើញគួរល្មមណាស់ ព្រោះឡៅពីជាព្រះរាជវង្សស្រាប់ អស់មុខមន្ត្រីទាំងឡាយបានស្តាប់ ក៏យល់

ឃើញត្រូវតាំងរស់គ្នា ទើបធ្វើរឿងរ៉ាវតាមប្រាជ្ញា លើកឡើងជាទី
ក្សត្រិយ៍ឲ្យឡើងសោយរាជសម្បត្តិក្នុងផែនដី គំនិតសេចក្តីនោះយកទៅ
ថ្វាយ ទៀតបានឃើញសេចក្តីចុតហ្មាយដូច្នោះ ក៏នឹកស្មុគខ្ទប់ចិត្តគិត
ថា បណ្តាមន្ត្រីតាំងរស់នេះ ដែលមកនាំឲ្យយើងធ្វើដូច្នេះ ដើម្បីមិន
ឲ្យកាន់ចិត្តដោយស័ត្យទូរធម៌បាន គិតហើយក៏មានវាចាឆ្លើយប្រកែកកុំ
ទទួល ខ្ញុំបេងក៏ក្រាបទូលទៅថា បណ្តាជាខ្ញុំទាំងឡាយដែលទំនុល
ខ្វាយគិតគ្នាទាំងម៉្លេះ ព្រោះយល់ឃើញថា ចុកជាតួដណ្តើមយករាជ
សម្បត្តិធាតុលោហិតរបស់ព្រះអង្គ បានជាចង់លើកឲ្យទ្រង់គង់ជាម្ចាស់
ផែនដីតទៅ ។

ទៀតថា បើយើងព្រមទទួលធ្វើជាម្ចាស់ផែនដីនេះហើយ តែះបី
បើយើងមិនបានដណ្តើមយករាជសម្បត្តិដូចគេ ក៏គង់មានគេថាដូចជា
ដណ្តើមរាជសម្បត្តិដូចអាសត្រូវនោះដែរ ថាតែប៉ុណ្ណោះក៏ក្រោកឡើងចូល
ទៅក្នុង លុះគន្លងមកពាក់ថ្ងៃ ខ្ញុំបេងឲ្យប្រជុំអស់នាម៉ឺនមុខមន្ត្រីចូលទៅ
គាល់ព្រមគ្នា ទៅបេងទូលថា បណ្តានាម៉ឺន និងបណ្តាក្សត្រនានាសឹង
មានសេចក្តីស្នេហាស្រឡាញ់ស្រង់ ចង់ឲ្យឡើងសោយរាជសម្បត្តិពិត
ណាស់ ទើបប្រជុំយល់ព្រមគ្នាលើកព្រះអង្គឡើងជាមហាក្សត្រិយ៍សោយ
រាជសម្បត្តិតទៅ ដើម្បីនឹងលើកទ័ពទៅកំចាត់អាសត្រូវចុកឲ្យវិនាសចេញ
បំផ្លាញរាជនោះមិញ ជាទីសងសឹកជំនួសព្រះចៅហៀនតេឲ្យបាន ។

(ទៅមុខ)

ឧប្បត្តិកាជា វិត្តកបញ្ហា និង មលគរបញ្ហា : ព្រះសិរីសម្មតិវង្ស ឯម ទ.ក. ៧.១២; ទំព័រ ១២៤, ឆ្នាំ ១៩៧១, (ម.៥២/៩) ។

ឧស្សាហកម្មជាគ្រឿងបេះដូងនៃសេដ្ឋកិច្ច : ខេមរវង្ស ទ.ក. ៩, ទំព័រ ៣, ឆ្នាំ ១៩៤០, (ម ៥២/១២) ។

អូបុងជាបុណ្យព្រលឹងខ្មោច ដែលស្លាប់ទៅតាំងប៉ុន្មាន (ជប៉ុន) ក្រមការ ជុំ-មៅ ទ.ក. ១៦, ទំព័រ ២១៦, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

ឯកភាពនៃមិលិន្ទបញ្ហា : ឃុនទិពន្ធមន្ត្រី ញ៉ុក-ថែម ទ.ក. ៣, ទំព័រ ១៦៥, ឆ្នាំ ១៩៤៤, ម.៥២/១៦) ។

ឯកពិធានជាភាគ : អាចារ្យហ៊ឹម ទ.ក. ១-២-៣, ទំព័រ ៤៦, ឆ្នាំ ១៩៣៣, (ម.៥២/៦) ។ ទ.ក. ៤-៥-៦; ទំព័រ ៨១; (ម.៥២/៦) ។ ទ.ក. ១០-១១-១២; ទំព័រ ៤៥, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

ឯក.មហាគ្រូកគ្រី ភាគ : ១៣ ឃុនសុន្ទរមេធី ញ៉ួង-សៀង ទ.ក. ៣, ទំព័រ ១១៣; ឆ្នាំ ១៩៤៧ (ម.៥៥/១៩) ភាគ ១៤ ឃុនសុន្ទរមេធី ញ៉ួង-សៀង ទ.ក. ៨; ទំព័រ ៤១១; ឆ្នាំ ១៩៤៧

(ម.៥២/១៩) ។ ភាគ ១២ លោក ធុយ ប៊ុនស៊ូ ទ.ក. ៩, ទំព័រ ៤៦៦, ឆ្នាំ ១៩៤៦, (ម ៥២/១៨) ។ ភាគ ១១ យុទ្ធសុន្ទរមេធី ញូង-សៀង ទ.ក. ៥, ទំព័រ ៤២៥, ឆ្នាំ ១៩៤៦ (ម ៥២/១៨) ។ ភាគ ១០ ហ្វូងទិពន្ធមន្ត្រី ញ៉ុក ថែម ទ.ក. ១, ទំព័រ ១៦, ឆ្នាំ ១៩៤៦, (ម.៥២/១៨) ។ ភាគ ១៥ យុទ្ធសុន្ទរមេធី ញូង-សៀង ទ.ក. ២, ទំព័រ ១១៩, ឆ្នាំ ១៩៤៨ (ម.៥២/២០) ។ ភាគ ៤ ក្រមការ ជុំ-មៅ ទ.ក. ១-២-៣, ទំព័រ ១ ៧, ឆ្នាំ ១៩៣៣, (ម.៥២/៦) ។

ឃាតកសារសាស្ត្រាស្រីការីតជិតក្រាំង : លោក ញ៉ុក-ថែម ទ.ក. ៨, ទំព័រ ៨១៦, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

ឃាតកអង្គក្សត្រ : ម. រឿងឯកអង្គក្សត្រ ។

ជីវិតមហាត្មៈគន្ធី : លោកប៉ាយ ប៊ុក ទ.ក ៣, ទំព័រ ១៦១, ឆ្នាំ ១៩៥០, (ម ៥២/២២) ។

ទុក្ខមាតា : ព្រះមហាឡឿក អមរ៍ ទ.ក. ៧, ទំព័រ ៦៥១, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

ធុញការម្ដាយមានទុក្ខការុណាលើកូនមែនឬមិនមែន : លោក ផេង-ជ្រីវ ទ.ក ៦, ទំព័រ ៥៩៤, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

អ្នកកន្ទាលពៀមស្លូតត្រង់ និង ព្រះរាជនីតា . លោក ផេង-ជ្រីវ ទ.ក. ១២. ទំព័រ ១០៦៩, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

អ្នកជម្ទីរស់នៅប្រែកតែឯង : លោក ឌួច-គីឡេន ទ.ក. ៣, ទំព័រ ២៩៧, ឆ្នាំ ១៩៦០, (ម.៥២/៣២) ។

អ្នកជាតិនិយម : លោក ផេង-ជ្រីវ ទ.ក. ៩, ទំព័រ ៩៣៤, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

អ្នកដំណើរតែរណាត់ : ទ.ក. ៤-៥-៦, ទំព័រ ១៦៥, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

អ្នកតាឃុំនមៀង (រឿងព្រេង) : ទ.ក. ១, ទំព័រ ២៤, ឆ្នាំ ១៩៤១, (ម ៥២/១៣)

អ្នកតំណាងខេត្តកំពង់ចាម ដង្ហែគម្ពីរ និង វត្ថុផ្សេងៗ ចូលមកព្រះរាជបណ្ណាល័យ : ទ.ក. ៣. ទំព័រ ១១៥, ឆ្នាំ ១៩២៧ (ម.៥២/២) ។

អ្នកនៅផ្ទះភូមិជិតគ្នា (រឿងព្រេង : ទ.ក. ១០-១១ ១២, ទំព័រ ១៤៩, ឆ្នាំ ១៩៣៦, (ម.៥២/៨) ។

អ្នកបរិភោគកោម ១៦ ពួក : ទ.ក. ១២. ទំព័រ ១៤៤២, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

អ្នកមានគុណ : លោក ហេង-សំអាន ទ.ក. ៣, ទំព័រ ៦៤៩,

ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

អ្នករៀនដើម្បីជាតិ : លោក អាំង ហួន ទ.ក. ៧, ទំព័រ ៨២៥,

ឆ្នាំ ១៩៦២, (ម.៥២/៣ ) ។

អ្នកស្នេហាជាតិ-សាសនា-មហាក្សត្រ : យុនបណ្ណាឌិត្យ

ប៊ុ ប៉ុ ទ.ក. ៣, ទំព័រ ២២៨, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

អ្វីជាទ្រព្យរបស់ មនុស្ស : ភិក្ខុ ឡាយ-គ្រី ទ.ក. ៩, ទំព័រ ៩៣៦,

ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

សូមជំរាបថា ៖ ឯកសារបែបនេះ
ពុំទាន់អស់សព្វគ្រប់នៅឡើយទេ
ត្បិតមានអត្ថបទចុះផ្សាយបន្ទាប់ទៅ
ជាច្រើនទៀត ដែលយើងនឹងបង
ក្រងផ្សាយទៅអនាគត ។

# ជីវប្រវត្តិ

## នៃព្រះមុនីកោសល ស្ងួរ-ហាយ

ចៅអធិការ វត្តនិរោធរង្សី, អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

យើងខ្ញុំជាសិស្ស ទាំងពីររូប ដូចមានឈ្មោះ ក្នុងទីបំផុត ជាអ្នកសរសេររៀបរៀងជីវប្រវត្តិ នៃព្រះតេជព្រះគុណ ជាព្រះឧបសម្បទាចារ្យ ដោយការចែកបរិច្ឆេទនៃជីវប្រវត្តិនេះ មាន ៨ បរិច្ឆេទ ដើម្បីឲ្យងាយមើលចំណាំក្នុងបរិច្ឆេទមួយៗ តាមរយៈកាលនៃជីវភាព និងករណីយកិច្ច របស់លោក ព្រមទាំងងាយស្រួល ក្នុងការសរសេររៀបសេចក្ដីដូចតទៅនេះ៖

១– ជាតិបរិច្ឆេទ កំណត់អំពីការកើត

២– កុមារបរិច្ឆេទ កំណត់អំពីកាលនៅជាកុមារ

៣– បព្វជ្ជាបរិច្ឆេទ កំណត់អំពីបព្វជ្ជា

៤– ឧបសម្បទាបរិច្ឆេទ កំណត់អំពីឧបសម្បទា

៥– សិក្ខាបរិច្ឆេទ កំណត់អំពីការសិក្សា

៦– ឋានន្តរបរិច្ឆេទ កំណត់អំពីការទទួលឋានន្តរសក្តិ

៧– ពុទ្ធវឌ្ឍិបរិច្ឆេទ កំណត់អំពីការធ្វើសេចក្ដីចម្រើនក្នុងព្រះពុទ្ធសាសនា

៨- សេនាសនភណ្ឌបរិច្ឆេទ កំណត់អំពីការ កសាងសេនាសនភណ្ឌ ទុកបម្រើព្រះពុទ្ធសាសនា ។



ព្រះមុនីកោសល ស្វូរ-ហាយ

អធិបតីរងក្រុមជំនុំព្រះត្រៃបិដក

## សេចក្តីរាយការណ៍នៃបរិច្ឆេទមួយៗ ដូចតទៅនេះ ៖

### ១ ជាតិបរិច្ឆេទ កំណត់អំពីការកើត ។

ព្រះមុនីកោសល សួរ-ហាយ កើតក្នុងភូមិតូចមួយ ឈ្មោះ ភូមិឫស្សីជួរ ក្នុងសង្កាត់ក្រាលគោ ឋិតនៅក្នុងទិសខាងលិចវត្តចិនរ៉ៃ ចំនួនជាង ២ គ.ម. ក្នុងកាលណោះ ភូមិនោះមានផ្ទះចំនួនតែ ៩ ខ្នង ។ មាតារបស់លោក ឈ្មោះ ម៉ុង-ទុក ជាស្ត្រីមានសីលតាំងពីក្មេង, បិតា ឈ្មោះ សៅ-សួរ មានលំនៅដើមឈ្មោះភូមិកន្ទួតប្រាង សង្កាត់ស្វាយជ្រុំ ស្រុក ខេត្ត ស្វាយរៀង ។ មាតាបិតានៃព្រះមុនីកោសល មានរបរអាជីវៈខាងកសិកម្មជាក់មធ្យម ។ ទារក សួរ-ហាយ កើតនៅថ្ងៃព្រហស្បតិ៍ ៨ កើត ខែពិសាខ ឆ្នាំរោងឆស័ក ព.ស. ២៤៤៨ គ.ស. ១៩០៤ មានបងប្អូន ៦ នាក់ គឺស្រី ៤ នាក់ ប្រុស ២ នាក់ ។

ស្រី ៤ នាក់នោះគឺ ១– សួរ-នួន ២- សួរ-យួន ៣ សួរ-ជៅ ៤– សួរ ឡុត ។ ប្រុស ២ នាក់គឺ ១– សួរ ហុង, ២– សួរ-ហាយ ។ ទារក សួរ-ហាយ ជាកូនពៅរបស់មាតាបិតា ដែលបានទទួលការសង្គ្រោះថ្នាក់ថ្នមអំពីមាតាបិតាជាងបងៗទាំងអស់ ។

### ២– កុមារបរិច្ឆេទ កំណត់អំពីកាលនៅជាកុមារ ។

កុមារ សួរ-ហាយ មានអាយុ១០ឆ្នាំ ទើបមាតាបិតាបាននាំយកទៅឲ្យសិក្សាអក្សរសាស្ត្រជាតិ តាមប្រពៃណីឯវត្តចិនរ៉ៃ ក្នុងសំណាក់លោក

គ្រូសូត្រនាម ទេព-យ៉ិន ក្នុងលោកគ្រូសូត្រ ទេព-យ៉ិន ណាភាកសិក្សា-បរៈពាក់ជាគ្រូហាស្ត្រ ក៏មកនៅរៀន គង់សំណាក់លោកគ្រូនាយ សុខ-ហាម ទៀត លុះដល់អាយុ១៣ ឆ្នាំ បានចូលរៀនសិក្សាអក្សរសាស្ត្របរទេសផង សម អាចមើលបានសរសេរកើត ទើបត្រឡប់មកនៅឯផ្ទះវិញ ដើម្បីជួយបំពេញកិច្ចការបន្តិចបន្តួចរបស់មាតាបិតា តាមទំនៀមនៃត្រកូលកសិករ ។

៣- បព្វជ្ជាបរិច្ឆេទ កំណត់អំពីបព្វជ្ជា ។

កុមារ ស្វរ-ហាយ លុះដល់អាយុ ១៧ ឆ្នាំ ក៏ត្រឡប់ទៅសិក្សាធម៌វិន័យឯវត្តបឹងវ៉ែងវិញ ដើម្បីនឹងបួសជាសាមណេរ ដោយនិមន្តលោកគ្រូធៀមអធិការនាម កែវ-ទិត ជាព្រះឧបជ្ឈាយ៍ បួសក្នុងថ្ងៃ ៨កើត ខែពិសាខ ព.ស. ២៤៦៦ គ.ស. ១៩២២ លុះបានទទួលផ្នួសជាសាមណេរគោព នៅក្នុងវត្តនោះតែ ១ វស្សា ក៏សូមលាព្រះឧបជ្ឈាយ៍ចេញអំពីវត្តបឹងវ៉ែ មកនៅរៀនវេទ្ទញមេសូត្រ តាមសម័យនោះឯវត្តបរិសាគរ កំណត់ត្រឹមបែក បានចំនួន ២ ខែ រួចទៅកុំពីវត្តសិរីសាគរ មកនៅរៀនវត្តព្រែកឬាម ក្នុងស្រុកកាមរក់ ខេត្តព្រៃវែង គង់សំណាក់លោកគ្រូរាជបាលខាយ ប៉ុត ។ បានរៀនប្រែមូលកច្ចាយនៈសម្ពន្ធិសូរនាម ចំនួន ២ ខែ ក៏ចេញអំពីទីនោះមកនៅរៀនឯវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩២២ នៅក្នុងក្រុមលោកគ្រូព្រះបុរោ ហាម-ណុន អតីតចៅអធិការវត្តឧណ្ណាលោម ។

កាលនៅសិក្សា នាវត្តឧណ្ណាលោមក្នុងសម័យនោះ រៀនប្រែមូល

កច្ចាយនៈ ក្នុងសំណាក់លោកគ្រូព្រះមហា សោម-ឈុន និង លោកគ្រូអាចារ្យ ម៉ៅ-នុត នៅរៀនអស់ពីរឆ្នាំ ទើបចប់មូលកច្ចាយនៈ ។ បន្ទាប់មកពេលដែលគ្រូទាញជាខ្មន់ ត្រឡប់ទៅ វត្តកំណើតដើមវិញ ដើម្បីព្យាបាលគ្រូអាពាធជាង ១ ខែ ទើបជាសះស្បើយ រួចក៏ទៅនៅរៀនវត្តស្វាយព្រៃកូត ក្នុងសង្កាត់គោកព្រីង ស្រុក—ខេត្ត ស្វាយរៀង ក្នុងសំណាក់លោកគ្រូអាចារ្យ ទាម ទៀង បាន ១ វស្សាគត់ ក៏វិលត្រឡប់មកវត្តខណ្ឌលោម ក្រុងភ្នំពេញវិញ នៅក្នុងកុដិក្នុងក្រុមដដែលដូចមុន បានសូមរៀនប្រែគម្ពីរធម្មបទដ្ឋកថាបុព្វភាគ ក្នុងសំណាក់ លោកគ្រូព្រះមហា សោម-ឈុន និងលោកគ្រូអាចារ្យ ម៉ៅ នុត ដរាបដល់អាយុ ២១ ឆ្នាំ ទើបត្រឡប់ទៅបំពេញឧបសម្បទា ជាភិក្ខុ ឯវត្តបឹងរ៉ៃ ជាវត្តដើមកំណើតរបស់ខ្លួនវិញ ។ សាមណេរ សួរ-ហាយ ជាបុគ្គលមានចិត្តស្មោះស្ម័គ្រ ហើយមកនៅដល់ក្រុងភ្នំពេញ ព្រោះសម័យនោះ ពុំមានសាមណេរណាមួយនៃខេត្តស្វាយរៀងមកនៅវត្តខណ្ឌលោម ក្រុងភ្នំពេញទេ ។ ជីវិតក្នុងការព្យាយាមនៃសាមណេរ សួរ-ហាយ ឃើញថាពិបាករស់រាល់អណ្តឹតអណ្តក កំសត់រកាសរដែរ ទទឹមទឹងបានស្រួល ត្រូវគ្រាប់ផ្លាត់ សាបុះសាឡើង អស់ប្រើប្រឡប់ ។

៤– ឧបសម្បទាបរិច្ឆេទ កំណត់អំពីឧបសម្បទា ។

មុនឧបសម្បទា សាមណេរ សួរ-ហាយ មានជម្ងឺឫសដូងបាត

នៅពេលនោះ បានលាព្រះឧបជ្ឈាយ៍ចាកសិក្ខាបទទៅជាគ្រហស្ថ ដើម្បីព្យាបាលរោគឫសដូងបាត ក្នុងសំណាក់គ្រូម៉ា នៅភូមិដំណាក់ត្នោត ក្នុងសង្កាត់ស្វាយយារ ចំនួន ១ខែ លុះជាសះស្បើយចាករោគនោះហើយ ទើបមកសូមឧបសម្បទាឯវត្តបឹងវៃ ក្នុងថ្ងៃ ៨កើត ខែជេស្ឋ ឆ្នាំខាលសប្តស័ក ព.ស. ២៤៦៩ គ.ស. ១៩២៥ មានលោកគ្រូចៅអធិការ កែវ-ទិត ជាព្រះឧបជ្ឈាយ៍ លោកគ្រូសូត្រ សុខ ហែម និង លោកគ្រូស្មូត្រ ងួន-ស៊ិន ជាព្រះឧបសម្បទាចារ្យ លុះបានទទួលឧបសម្បទាជាភិក្ខុហើយ ក៏ត្រឡប់វិលមករៀនឯវត្តឧណ្ណាលោមវិញ នៅក្នុងកុដិក្នុងក្រុមជំដែល ។

## ៤– សិក្ខាបរិច្ឆេទ កំណត់អំពីការសិក្សា ។

ភិក្ខុ ស្វរ-ហាវេ បានសិក្សាព្រះបរិយត្តិធម៌ជាប់មាំមួនដោយមានសុខភាពបរិបូណ៌ តាំងអំពីកាលដែលបានទទួលឧបសម្បទាជាភិក្ខុមក លុះដល់ គ.ស. ១៩២៧ បានទៅរៀនឯវត្តជយនាវីចុងកោះសំពេង ខេត្តកំពង់ចាម អស់ ១ វស្សា ក្នុងសំណាក់លោកគ្រូអាចារ្យនាម ប៉ែន-សុខ សព្វថ្ងៃលោកមហាសមណសក្តិ ជាព្រះបិដកសោភ័ណ " រាជាគណៈពិសេស " ។

ការសិក្សាព្រះបរិយត្តិធម៌ក្នុងសម័យនោះ នៅជារបៀបទម្រង់ចាស់នៅឡើយ ពុទ្ធិកវិទ្យាល័យក្នុងជំនាន់នោះហៅថា សាលាបាលីជាន់ខ្ពស់ មានព្រះតេជព្រះគុណ ព្រះមហាវិមលធម្មព្រះនាម ថោង ជាចាងហ្វាង

មានលោកគ្រូបង្រៀនប្រចាំថ្នាក់ច្រើនរូប មានសម្តេចព្រះសង្ឃរាជជាដើម កាលនៅជាព្រះគ្រូសង្ឃសត្ថា ។ ការសិក្សានៅសម័យនោះ មានកម្មវិធីសិក្សាមិនច្រើនល្អិតហ្មត់ចត់ដូចសម័យសព្វថ្ងៃនេះទេ ។ កាលបើភិក្ខុ-សាមណៈប្រឡងប្រផែនចូលជាប់ ត្រូវរៀនតាមកំណត់ច្បាប់សាលា ក្នុងសម័យនោះអស់ប្រាំឆ្នាំទើបប្រឡងចេញ ។ ភិក្ខុ សួរ-ហាយ ជាភិក្ខុ-សាមណៈមួយរូប បានចូលប្រឡងប្រផែនក្នុងឆ្នាំ ១៩២៩ បានជាប់ជាសិស្សស្នង ពីព្រោះកាលនោះ រាជការកំណត់សិស្សប្រឡងជាប់តែចំនួន ២៥ រូបប៉ុណ្ណោះ ហើយបន្ថែមសិស្សស្តាប់ ៥ រូបទៀត ។

ការសិក្សាព្រះបរិយត្តិធម៌នៃភិក្ខុ សួរ-ហាយ មានជោគជ័យល្អគួរសមដែរ គឺថាចេះតែមានសុខភាពបរិបូណ៌ ពុំដែលមានជម្ងឺកាត់អ្វីឡើយ រហូតដល់ឆ្នាំ ១៩៣៣ ទើបប្រឡងចេញ ។ តាមលេខរៀងនៃលោកអ្នកប្រឡងជាប់បានពិន្ទុគ្រប់វិញ្ញាសានៃការប្រឡងនោះ ភិក្ខុ សួរ-ហាយ បានជាប់លេខ ៣ ។

លុះភិក្ខុ សួរ-ហាយ បានប្រឡងចេញជាប់ហើយ សម្តេចព្រះសង្ឃរាជ កាលព្រះអង្គនៅជាព្រះសាសនសោភ័ណ បានចាត់ឲ្យទៅធ្វើអាចារ្យបង្រៀនសាលាបាលីរង ឯវត្តបរិវាស សង្កាត់សំរោង ស្រុកបន្ទាយមាស ខេត្តកំពត អស់ ៥ ខែ គឺតាំងពីខែជេស្ឋ រហូតដល់ចុងនៃខែអស្សុជ ក៏ត្រឡប់មកវត្តឧណ្ណាលោម ក្រុងភ្នំពេញវិញ ដោយពុទ្ធសាសនបណ្ឌិត្យ

តម្រាវិមន្តមកធ្វើជាក្រុមជំនុំព្រះត្រៃបិដក ក្នុងខែតុលា ១៩៣៣ ពីព្រោះបានប្រឡងជាប់ជាក្រុមជំនុំព្រះត្រៃបិដកនោះ តាំងពីខែកញ្ញា ប៉ុន្តែពេលនោះនៅក្នុងស្រុកនៅឡើយ លុះបវារណាចេញវស្សាហើយ ទើបមកភ្នំពេញ ចូលធ្វើការក្នុងក្រុមជំនុំព្រះត្រៃបិដកតាំងពីកាលណោះដរាបមក ។

៦ ឋានន្តរបរិច្ឆេទ គំណត់អំពីការទទួលឋានន្តរស័ក្តិ ។

ភិក្ខុមហា ស្វរ.បាយ បានទទួលនាទីជាព្រះបាឡាត់ពុទ្ធញាណជាបាឡាត់នៃព្រះពុទ្ធវង្ស សោម ឈុន ក្នុង ព.ស. ២៤៨១ គ.ស. ១៩៣៧ ។

—បានទទួលនាទីជាព្រះគ្រូ ប៉ុណ្ណញាណ ក្នុង គ.ស. ១៩៤២ ។

—បានទទួលនាទីជាព្រះទេពសត្ថា រាជាគណៈថ្នាក់ទី ៤ ដោយព្រះរាជក្រឹត្យលេខ ៩៣ ប.រ. ចុះថ្ងៃទី ២៦ ឧសភា ឆ្នាំ ១៩៤៨ ។

—បានទទួលនាទីជាព្រះ[illegible]បាលិវង្ស រាជាគណៈថ្នាក់ទី ៣ ដោយព្រះរាជក្រឹត្យលេខ ៥ ប.រ. ចុះថ្ងៃ ២១ ខែមករា ឆ្នាំ ១៩៥៤ ។

—បានទទួលនាទីជាព្រះមុនីកោសល រាជាគណៈថ្នាក់ទី ២ ដោយព្រះរាជក្រឹត្យលេខ ២៣ ន.រ. ចុះថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ១៩៦០ ។

—បានចូលជាសមាជិកនៃគណៈកម្មការវប្បធម៌ខ្មែរ ដោយព្រះរាជក្រមលេខ ៣៩៣ ន.ស. ចុះថ្ងៃទី ២១ វិច្ឆិកា ឆ្នាំ ១៩៤៧ ។

—បានចូលជាសមាជិកថេរសភា ដោយព្រះរាជក្រឹត្យលេខ ១១១៣ ប.រ. ចុះថ្ងៃទី៩ កញ្ញា ឆ្នាំ ១៩៥៨ ។

—បានទទួលនាទីជាអធិបតីរង នៃក្រុមជំនុំព្រះត្រៃបិដក ដោយព្រះសង្ឃដីកានៃសម្តេចព្រះពោធិវង្ស លេខ ១៨៥ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ១៩៥៩ ។

—បានទទួលនាទីជាចៅអធិការ វត្តទិពោធិវង្ស ដោយសញ្ញាបត្រ លេខ ៣៩៧ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៩៦១ ។

៧– ពុទ្ធិវិធីប្រើប្រាស់ កំណត់ការធ្វើសេចក្តីចម្រើនក្នុងព្រះពុទ្ធសាសនា ។

ព្រះមុនី កោសល ស្វរៈ-ហាយ បានធ្វើមប្រយោជន៍នៃការប្រឡងសមណសិស្ស យកវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា, សមណសិស្សប្រឡងចូលពុទ្ធិកវិទ្យាល័យ ព្រមទាំងសមណសិស្ស ប្រឡងយកសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទៀងរាល់ឆ្នាំ តាំងពី ព.ស. ២៤៧៨ គ.ស. ១៩៣៤ ដរាបមកដល់សព្វថ្ងៃនេះ ។

—បានធ្វើជាគ្រូបង្រៀនសាលាបាលីរង វត្តបរិកេស ស្រុកបន្ទាយមាស ខេត្តកំពត ពីឆ្នាំ ១៩៣៣ ។

—បានប្រឡងជាប់ជាទីក្រុមជំនុំព្រះត្រៃបិដកពីឆ្នាំ ១៩៣៣ ។

—បានធ្វើជាប្រធានគណៈកម្មការសង្ឃ វត្តឧណ្ណាលោម ជាជំនួសក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃរាជ ។

—បានធ្វើជាគ្រូបង្រៀនសមណសិស្សវត្តឧណ្ណាលោម ដែលបម្រុងប្រឡងប្រជែងចូលរៀនក្នុងពុទ្ធិកវិទ្យាល័យ ។

-បានធ្វើជាសមាជិកគណៈកម្មការរៀបរៀងធម៌វិន័យ ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជ ។

-បានធ្វើជាសមាជិកគណៈប្រតិភូជាមួយនឹងសម្តេចព្រះសង្ឃរាជទៅក្រុងរង្គូន ប្រទេសភូមា ដើម្បីធ្វើឆដ្ឋសង្គាយនាពុទ្ធសាសនាពីឆ្នាំ ១៩៥៤ ។

-បានធ្វើជាប្រធានគណៈកម្មការ ពិនិត្យអត្ថបទធម៌ បោះពុម្ពចែកជាធម្មទានក្នុងឱកាសបុណ្យឆ្លងកន្លះពុទ្ធសាសនា ២៥០០ វស្សា ។

-បានចូលជា ជនសមាជិក នៃពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ តាំងពីការបង្កើតជាដំបូងរៀងមក ។

-បានធ្វើជាសមាជិកតែងអត្ថបទបោះពុម្ពដាក់ក្នុងទស្សនាវដ្តី កម្ពុជសុរិយា និង ពន្លឺពុទ្ធចក្រ ។

-បានធ្វើសន្និសីទអំពីសីលធម៌អប់រំយុវជន វត្តឧណ្ណាលោម ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃរាជ ។

-បានចូលជាសមាជិកនៃសមាគមគិលានុបដ្ឋានព្រះមហាក្សត្រិយានី «ពេទ្យព្រះសង្ឃ» ។

-បានធ្វើកឋិនទាន ដង្ហែទៅវត្តបឹងរៃ ១១ ដង គឺតាំងពីឆ្នាំ ១៩៥៧ រហូតដល់ឆ្នាំ ១៩៦៧ ។

-បានធ្វើកឋិនទានដង្ហែទៅវត្តឈើទាល ស្រុកស្វាយរៀងពីរដង ។

-បានធ្វើកឋិនទានជាមួយពុទ្ធបរិស័ទ ដង្ហែទៅវត្តសិរីសាគរ កំពង់ត្របែកម្តង ។

—បានចូលជាសមាជិកសមាគមមិត្តពុទ្ធិកវិទ្យាល័យ តាំងពីដំបូន ។

—បានចូលជាសមាជិកនៃសមាគម មគ្គសង្គ្រោះកងក្រុមពុទ្ធបរិស័ទ សាលាសន្សុំខ សង្កាត់លេខ៤ ក្រុងភ្នំពេញ ។

## ឈ្មោះសៀវភៅធម៌ដែលព្រះមុនីកោសលបានរៀបរៀង

១- វិសុទ្ធិកថា

២. បទពិចារណាពុទ្ធាភិសេក

៣- បទពិចារណាធម៌វិន័យ

៤- អធិប្បាយប្រជុំកង់ធម៌ ភាគ ១ ភាគ ២ ថ្នាក់ទោ

៥- អធិប្បាយចតុប្បារិសុទ្ធិសីល

៦- ពុទ្ធបារមីកថា

៧- គិហិសមណសុខកថា

៨- ញាទសកម្មកថា

៩- កាលិកវិនយកថា

១០- សីលធម៌របស់មនុស្ស

១១- សាមគ្គីកថា

១២- សិប្បកថា

១៣- អរិយសច្ចកថាសង្ខេប

១៤. ពុទ្ធោវាទកថា

១៥- ជីវិតធម្មកថា

១៦- កតញ្ញូកតវេទិកថា

១៧- ព្រហ្មវិហារធម្មកថា

១៨- សាសនាប្រៀបធៀប ។

អត្ថបទធម៌ភាយផ្សេងៗ ដែលបោះពុម្ពក្នុងទស្សនាវដ្ដីកម្ពុជសុរិយា និងពន្លឺពុទ្ធចក្រ ក៏មានច្រើន ស្ទើរតែគ្រប់សៀវភៅ ។

៨-សេវាសង្គមក្នុងបរិច្ឆេទ កំណត់អំពីការកសាងសេវាសង្គម ទុកបម្រើជាតិ, ព្រះពុទ្ធសាសនា ។

ព្រះមុនីកោសល ឡុង-ហាយ បានបបួលសិស្សគណកសាងកុដិ ១ ខ្នង មានពីរជាន់ ដោយគ្រឿងបេតុងអារម៉េ ក្នុងវត្តឧណ្ណាលោមជាកុដិលេខ ៣៨ មានបណ្ដោយ ១៨ ម. ទទឹង ៨ ម. ពី គ.ស. ១៩៥៦ អស់បច្ច័យផ្ទាល់ខ្លួនចំនួន ៣០ ម៉ឺនរៀល បច្ច័យសិស្សគណ, ពុទ្ធបរិស័ទចំនួន ៤៦ ម៉ឺនរៀល បូករួមជា ៥៦០ ០០០៛០០ ។

- បានជួយរំទុកបម្រុងកសាងសាលាបឋមសិក្សា សង្កាត់ក្រោលគោ តាំងពីឆ្នាំ ១៩៥៧ មក អស់ចំនួន ៣០.០០០៛០០ ។

- បានចូលកសាងមហាកុដិ វត្តឧណ្ណាលោម សម្រាប់សម្ដេចព្រះសង្ឃរាជគង់នៅ អស់ចំនួន ១០ ០០០៛០០ ។

- បានចូលកសាងវិហារវត្តឧណ្ណាលោម អស់ចំនួន ១៥.០០០៛០០ ។

-បានចូលកសាងវិហារវត្តព្រៃគុម្ព ខេត្តកំពត ជាមួយនិងលោកវរៈសេនីយឯក ស្រី-សាម៉ន ចំនួន ៦.០០០៛០០ ។

-បានកសាងឧបដ្ឋានសាលាវត្តបឹងរៃ ជាវត្តកើតដំណែល (ស្វាយ-រៀង) ១ ខ្នងដោយគ្រឿងបេតុងអារម៉េ ជាមួយនិងពុទ្ធបរិស័ទជើងវត្ត អស់បច្ច័យផ្ទាល់ខ្លួនចំនួនជាង ២០០.០០០៛ (២០ម៉ឺន) ។

-បានជួយកសាងកុដិ ១ ខ្នង មាន ២ ជាន់ សម្រាប់លោកគ្រូចៅអធិការវត្តបឹងរៃ អស់បច្ច័យចំនួន ៣០.០០០៛០០ ។

-បានចាប់កសាងវិហារវត្តបឹងរៃ ជាមួយនិងពុទ្ធបរិស័ទជើងវត្ត ពីឆ្នាំ ១៩៦៦ អស់បច្ច័យផ្ទាល់ខ្លួនរួចហើយចំនួន ១៥០.០០០៛០០ ។ ប៉ុន្តែវិហារនោះពុំទាន់ហើយនៅឡើយ ជិតរួចដែរហើយ ។

-បានចូលជួយកសាងអនុវិទ្យាល័យ ស្វាយជ្រំ ស្រុកខេត្តស្វាយរៀង ក្នុង ១ ឆ្នាំចំនួន ២ ពាន់រៀល ឥឡូវនេះបាន ៤ ឆ្នាំហើយ ត្រូវជា ៨ ពាន់រៀល សន្យាថានឹងចូលជួយជាប់ទាល់តែហើយស្រេចទើបឈប់អស់ចំនួនបច្ច័យ ១៥.០០០៛០០ ។ ស្វាយជ្រំនេះជាលំនៅជាតិភូមិនៃញោមប្រុស ។

-បានចូលជួយកសាងមន្ទីរពេទ្យព្រះសង្ឃនៅទីក្រុងស្វាយរៀងអស់បច្ច័យចំនួន ៤.១០០៛០០ ។ ចូលជួយកសាងវត្តសាមគ្គីរង្សី ៣៧០០៛០០។

-បានដឹកនាំលោកអ្នកឧកញ៉ា ឧត្តមភោគី លឹម-ហួត ឲ្យកសាងកិលានដ្ឋាន និងផ្សារក្រោលគោ ស្រុកស្វាយរៀង ហើយធានា

ក៏បានកសាងសម្ភារៈផ្សេងៗ មានគ្រែ តុ ជាដើមសម្រាប់គិលានដ្ឋាន នៃលោកអ្នកឧកញ៉ា ឧត្តមភោគី អស់ចំនួន ៤៥.១០០ រៀល ។

-បានបរិច្ចាគបច្ច័យប្រចាំខែ ៩០០ រៀលសម្រាប់ចិញ្ចឹមភិក្ខុសាមណេរ និងក្មេងនៅក្នុងកុដិលេខ ៣៨ ក្នុងវត្តឧណ្ណាលោម តាំងពីឆ្នាំ ១៩៦៣ ដែលលោកមកគង់នៅឯវត្តនិរោធរង្សី ដល់មកឆ្នាំ ១៩៦៦ បន្ថយមកវិញ នៅតែ ៧៥០ រៀលវិញ ព្រោះភិក្ខុសាមណេរនិងក្មេងក្នុងកុដិនោះ ក៏មានចំនួនតិចជាងមុនដែរ ។

-បានជំនុំផ្ដើមកសាងអនុវិទ្យាល័យរស្មីសម្ដេចឪ នៅជិតវត្តព្រែកឯង ស្រុកកៀនស្វាយ ហើយបានចូលបច្ច័យក្នុង ១ ឆ្នាំ ១០០០ រៀលៗ ដរាបដល់តែហើយស្រេច ឥឡូវនេះបានចូលអស់បីឆ្នាំហើយ ព្រមទាំងបច្ច័យជាភោគទាន ដែលកើតអំពីធម៌ទេសនាជាច្រើនដង រួចចូលបន្ថែមទៀត ត្រូវជាប្រាក់ ៤០០០ រៀលហើយ ។

-បានកសាងកុដិឈើប្រក់ក្បឿង ១ ខ្នងអស់បច្ច័យ ៥០.០០០៛០០ (៥ ម៉ឺនរៀល) ក្នុងវត្តនិរោធរង្សី ។

-បានកសាងបង្ហើយវិហារវត្តនិរោធរង្សី ដោយបច្ច័យនៃពុទ្ធបរិស័ទអ្នកជាប់ជ្រះថ្លា មានលោកជំទាវ ឧត្តមសេនីយ លន់-ណុល ជាដើមអស់បច្ច័យចំនួន ២៥ ម៉ឺនរៀល (២៥០.០០០៛០០) ។

-បានកសាងកុដិឈើ ១ ខ្នង នៅវត្តបូស្សីស្រស់ សម្រាប់លោក

អាចារ្យបង្រៀនពុទ្ធិកបឋមសិក្សា អស់បច្ច័យចំនួន ៤ មុឺន ៨ រយហាសិប រៀល (៤០.៨៥០៛០០) ។

-បានចូលកសាងអនុវិទ្យាល័យ កំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្ដាល ក្នុងមួយឆ្នាំ ១០០០៛០០ សន្យាថា ចូល ១០០០៛០០ ក្នុងមួយឆ្នាំ ដកបតាល់តែហើយស្រេច ។

-បានជួលគេជីកអណ្ដូង ១ ក្នុងវត្តនិរោធរង្សី អស់បច្ច័យចំនួន ៦.០០០ រៀល ។

ព្រះមុនីកោសល បានទាក់ទងនិងគហបតី លី ប៊ុន រួចគំគហបតីបាន កសាងបណ្ណាល័យ ១ ខ្នង សម្រាប់តម្កល់គម្ពីរក្នុងវត្តនិរោធរង្សី អស់បច្ច័យ ៤០០.០០០៛០០០ ។

-បានចូលជួយទិញស៊ីម៉ង់, ឥដ្ឋ, ក្រួស, ខ្សាច់ ធ្វើឧបដ្ឋានសាលាវត្តនិរោធរង្សីអស់បច្ច័យចំនួន ៣០.០០០៛០០ ។

-បានទិញក្រួសក្រហមសម្រាប់ក្រាលជុំវិញវិហារវត្តនិរោធរង្សី អស់បច្ច័យចំនួន ៣៤.០០០ រៀល តែពុំទាន់ហើយទេ នៅពុំទាន់ដឹងថាអស់ប៉ុន្មានទៀតទេ ដែលជួលកម្មករប្រចាំខែឲ្យកាប់គាស់ស្មៅ ព្រមទាំងក្រាលក្រួសក្រហមនោះ ។

## ឥស្សរិយយសនៃព្រះមុនីកោសល

១ មេដាយ អស្សរិទ្ធិមុនីសារគ័ណ្ឌ ដោយគុណបំណាច់នៃការប្រែព្រះត្រៃបិដក បោះពុម្ពព្រះត្រៃបិដក ។

២– មេដាយព្រះរាជាណាចក្រជាទីសេនា (Officier de l'ordre royale du comboge) ដោយគុណបំណាច់នៃការសាងគិលានដ្ឋាន និង អនុវិទ្យាល័យ ។

៣– មេដាយស្ថាបនាជាតិ ៣ ទៀត ដោយចេញតម្លៃមួយៗ ៣៥០ រៀល ។

ចប់ ជីវប្រវត្តិតែប៉ុណ្ណោះ ។

# ទស្សនៈនៃខ្ញុំករុណាលើប្រវត្តិនេះ

ខ្ញុំករុណា ខ្ញុំបាទ «ភ្លួច តៅឡេង» ជាសិស្សនៃព្រះតេជព្រះគុណ ព្រះមុនីកោសល សូមរៀបរាប់វែកញែកប្រវត្តិ នៃព្រះតេជព្រះគុណអង្គនេះ តាមទស្សនៈ (ការយល់ឃើញ) របស់ខ្ញុំដោយឡែកទៀត ដូចតទៅនេះ ៖

ខ្ញុំករុណា ខ្ញុំបាទ កាលនៅជាបណ្ឌិត កំពុងរៀបចំដំណើរទៅរៀនឯប្រទេសឥណ្ឌា ដោយសម្តេចព្រះសង្ឃរាជជ្រើសរើសរកលោក ដែលប្រឡងចេញពីសាលាបាលីជាន់ខ្ពស់ថ្មីៗ មានសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សា ហើយឲ្យរៀនអក្សរអង់គ្លេស ដើម្បីអប់រំឲ្យចេះដឹងគួរសម និងបញ្ជូនទៅរៀនប្រទេសឥណ្ឌា ។ ក្នុងសម័យនោះ សម្តេចព្រះសង្ឃរាជ ខ្នះខ្នែងចាត់ចែងខ្លាំងណាស់ ដោយព្រះរាជហឫទ័យចង់ឲ្យសមណនិស្សិតជាតិខ្មែរ បានទៅរៀនប្រទេសឥណ្ឌា ទ្រង់បានធ្វើព្រះសង្ឃដីកាចាត់ចែង និងព្រះរាជរដ្ឋាភិបាល ព្រមទាំងទូតឥណ្ឌា ទាល់តែបានសម្រេចសព្វគ្រប់ដូចបំណង ។

ក្នុងដំណើរចេញទៅប្រទេសឥណ្ឌា ជាលើកដំបូងបង្អស់នោះ ត្រូវលើខ្ញុំករុណា ខ្ញុំបាទ និងព្រះមហា ឆាយ-កេន ជាសិស្សនៃព្រះតេជព្រះគុណព្រះមុនីកោសល ព្រោះកាលណោះ លោកដែលបានប្រឡងចេញថ្មីៗ មានសញ្ញាប័ត្រពុទ្ធិកមធ្យមសិក្សានៃសាលាបាលីជាន់ខ្ពស់ ជាសិស្សនៃព្រះមុនីកោសលនោះមាន ៤ អង្គ សុទ្ធតែនៅក្នុងសំណាក់

កុដិលេខ ៣៨ ជាមួយគ្នា ជាសិស្សនៃព្រះមុនីកោសល ឃើញថាកុដិនេះមានលេខរៀង ៣៨ ត្រូវគ្នានឹងមង្គល ៣៨ ប្រការ ព្រោះហេតុដូច្នេះទើបនឹងបានជាកុដិនេះមានជោគជ័យសិរីមង្គលគ្រាន់បើ ទាំងពួកក្មេងក្នុងកុដិនេះដែលរៀនអក្សរសាស្ត្រជាតិក្នុងសាលាខាងអាណាចក្រ ក៏បានការច្រើននាក់ដែរ ។ លុះដល់សម្តេចព្រះសង្ឃរាជ ជ្រើសរើសគេសមណនិស្សិតដើម្បីឲ្យទៅប្រទេសឥណ្ឌានោះ រើសបានទាំង ៤ អង្គ គឺ ១– ខ្ញុំករុណា ខ្ញុំបាទ "គួច.គីឡេង", ២– មហា ឆាយ-ផន, ៣– មហា អ៊ុង-មាន ៤– មហា សោម ឆន ។ ប៉ុន្តែនៅសម័យនោះ លោកដែលបានទៅឥណ្ឌាលើកដំបូងនោះតែពីររូបសិន គឺ គួច-គីឡេង ១, ឆាយ-ផន ១, ក្រៅពីនេះចាំទៅលើកក្រោយទៀត ។

នៅឱកាសដ៏ខ្លីមុនពេលចេញដំណើរទៅប្រទេសឥណ្ឌា ៣ ថ្ងៃ ព្រះតេជព្រះគុណព្រះមុនីកោសល បានឲ្យឱវាទជាខ្លឹមសារល្អៗណាស់ ព្រមទាំងឲ្យពរចំពោះខ្ញុំករុណា ខ្ញុំបាទ ជាសិស្សកាលនៅជាបព្វជិត ជាពិសេសត្រង់ឱវាទខាងចុងថា : „លោក កាលបើបានរៀនវិជ្ជាណាមួយសម្រេចហើយ ត្រឡប់មកប្រទេសយើងវិញ លោកកុំសឹក លោកត្រូវប្រើគំនិតឲ្យវែងឆ្ងាយ កុំបណ្តោយគំនិតឲ្យគិតខុសគិតខ្លី គួរនៅជាបព្វជិតបម្រើព្រះពុទ្ធសាសនា ទើបប្រសើរជាងការបម្រើកាមគុណ ព្រោះថាគ្រហស្ថអ្នកបម្រើកាមគុណមានច្រើននាក់ណាស់ហើយ មិនខ្វះទេ” ប៉ុណ្ណោះជាដើម។

ការវែកញែកក្នុងជីវប្រវត្តិនៃព្រះតេជព្រះគុណ ព្រះមុនីកោសលអគ្គនេះ ឃើញថាមានស្នាមគំនូសល្អច្រើនណាស់ ដូចយ៉ាងការគ្រប់គ្រងកិច្ចសាមណេរនិងពួកក្មេងអ្នករៀនក្តី ការឧបត្ថម្ភចិញ្ចឹម ដោយស្បៀងអាហារក្តី សុទ្ធតែប្រព្រឹត្តទៅដោយស្រួលល្អទាំងអស់ គឺថាព្រះថេរៈអង្គនេះមានហឫទ័យធូរទូលាយ ទទួលដឹងសុខទុក្ខរបស់សិស្សគណដោយសេចក្តីស្រឡាញ់រាប់រកស្មើល្អណាស់ ជាព្រះថេរៈប្រកបដោយការឈ្លាសវៃប៉ិនប្រសប់ដោយការស្គាល់យល់ចរិតអធ្យាស្រ័យរបស់សិស្សគណ ។

ក្នុងកាលដែលខ្ញុំករុណា ខ្ញុំបាទ នៅកំពុងរៀនសូត្រឯប្រទេសឥណ្ឌា ព្រះតេជព្រះគុណអង្គនេះ បានផ្ញើស្បៀងជាបច្ច័យទៅឱ្យជារឿយ ៗ ជាពិសេសគ្រង់សំបុត្រស្នាមសួរសុខទុក្ខចំពោះខ្ញុំករុណា ខ្ញុំបាទ ក៏លោកផ្ញើទៅជាញឹកញយ ហើយច្រើនតែដាស់តឿនឱ្យយកចិត្តទុកដាក់ក្នុងការរៀន ទាំងខ្លួនទានរំលឹកប្រាប់ហេតុផលថា លោក ខំតែរៀនឱ្យមែនទែនទៅចុះ ខ្ញុំនៅឯណេះនឹងធ្វើកុដិបម្រុងទុកឱ្យលោកនៅ លុះធ្វើកុដិរួចហើយ ខ្ញុំនឹងធ្វើគ្រែដេកឱ្យមានកន្ទេលខ្នើយមុងទុកបម្រុងឱ្យលោកសព្វគ្រប់ ។ លុះខ្ញុំករុណា ខ្ញុំបាទវិលត្រឡប់អំពីប្រទេសឥណ្ឌាមកវិញ គឺមានកុដិថ្មី គ្រែ កន្ទេល ខ្នើយ មុងថ្មីៗ រៀបឱ្យពិតប្រាកដមែន ។ ព្រះថេរៈអង្គនេះដឹងសុខទុក្ខនិងករណីយកិច្ចរបស់សិស្សគណដោយពិត សមគួរដល់ឋានៈជាគ្រូអាចារ្យរបស់ខ្ញុំករុណា ខ្ញុំបាទគ្រប់ភាគរយឥតខ្វះចន្លោះឡើយ ។

ក្នុងការស្ថាបនានូវសំណង់សេនាសនៈ សម្រាប់ជ្រកកោននៅអា-ស្រ័យ ទុកបម្រើជាតិ សាសនា នោះឃើញថា ព្រះតេជព្រះគុណអង្គនេះ ផ្តួចផ្តើមកសាងបានច្រើនណាស់អស់ប្រាក់រាប់លានរៀល ដូចក្នុងជីវប្រវត្តិ ត្រង់បរិច្ឆេទទី ៨ ស្រាប់ គួរឲ្យគោរពសរសើរក្រៃលែង គួរជាទិដ្ឋានុគតិ យកជាគម្រាប់បាននៃបុគ្គលអ្នកត្រូវការពហានទៅមុខ ដើម្បីសេចក្ដីចំរើន លូតលាស់របស់ប្រទេសជាតិ សាសនា ជាពិតប្រាកដ ។ ជីវិតនៃព្រះ តេជព្រះគុណអង្គនេះ ពាក់ទងដោយបេសកកម្ម មានប្រយោជន៍ទាំងខាង ផ្លូវលោក ទាំងខាងផ្លូវសាសនា ឈ្មោះថាជាជីវិតទទួលបម្រើដោយគោរព ឥតសំចៃ ឥតលាក់លៀមចំពោះជាតិសាសនា និង ព្រះពុទ្ធបរិស័ទ ដើម្បី វឌ្ឍនភាពជាស្ថាពរ យូរអង្វែងតទៅអនាគត ។

អ្នកតែងសេចក្ដីជីវប្រវត្តិ និង ទស្សនៈនៃខ្ញុំ "គួច គីឡេង"

មហា គួច-គីឡេង

មហា អ៊ុង-មាន

# សុន្ទរកថា

នៃភិក្ខុមហា ម៉ា-សុន្ទរ៍ ថ្លែងក្នុងឱកាសបុណ្យចំរើនជន្មាយុ
នៃព្រះមុនីកោសល សួរ-ហាយ ថ្ងៃទី ១៨-១៩ កុម្ភៈ ១៩៦៧

បពិត្រសម្តេចព្រះពោធិវង្ស!

ព្រះករុណា ទាំងឡាយគ្រប់ព្រះអង្គ!

អស់លោកអ្នកពុទ្ធបរិស័ទទាំងឡាយ!

នៅឱកាសបុណ្យចំរើនជន្មាយុ នៃព្រះតេជព្រះគុណព្រះមុនីកោសល ជាចៅអធិការវត្តខិះរោធវង្សនេះ ខ្ញុំព្រះករុណា អាត្មាភាព ក្នុងនាមនៃគណៈកម្មការសមាគមវត្ត មានលោកតំណាងរាស្ត្រ តាន់ ឈាងលឹម ជាដើម ក្នុងនាមនៃពុទ្ធបរិស័ទជើងវត្តមានលោកអាចារ្យវត្តជាដើម សូមប្រកាសទទួលអំណរអរសប្បាយក្រៃលែង ចំពោះសម្តេច ដែលមានព្រះហឫទ័យទទួលនិមន្តមកប្រទានធម្មទេសនា ទាំងសម្តេចព្រះសង្ឃរាជ ក៏ទ្រង់ព្រះមេត្តាប្រោសទទួលយាងជាព្រះរាជាធិបតី ស្រោចស្រប់ទឹកសុគន្ធ-វារីក្នុងថ្ងៃស្អែកដែរ ដើម្បីសុភមង្គលដល់ព្រះតេជព្រះគុណព្រះមុនីកោ-សលផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង ចំពោះព្រះករុណាគ្រប់ព្រះអង្គ មានព្រះតេជព្រះគុណមេគណ ខេត្តកណ្តាលជាដើម និងអស់លោកអ្នកសប្បុរសទាំងឡាយ ដែលបាននិមន្ត អញ្ជើញមកជួយបំពេញកិច្ចអនុ-មោទនាបុណ្យ ជួយលើកកិត្តិយសនៃបុណ្យកុសលចំរើនជន្មាយុ នៃព្រះ

តេជព្រះគុណព្រះមុនីកោសលនេះ នាំឲ្យខ្ញុំព្រះករុណា អាត្មាភាព មាន បីតិសោមនស្ស រីករាយចិត្តអស្ចារ្យណាស់ ។

ខ្ញុំព្រះករុណា អាត្មាភាព ជាតំណាងនាមនៃពុទ្ធបរិស័ទអ្នកផ្ដើមបុណ្យ ដែលព្រមព្រៀងគ្នាជាមួយគ្នានិងសិស្សគណ ញាតិមិត្តសាលោហិតរបស់ព្រះតេជព្រះគុណព្រះមុនីកោសល ខ្ញុំព្រះករុណា អាត្មាភាព សូមធ្វៀតឱកាសបន្តិច ដើម្បីថ្លែងសុន្ទរកថា រៀបរាប់អំពីមូលហេតុនៃបុណ្យនេះ ប្រគេនជូនជាសង្ខេបដោយសេចក្ដីយ៉ាងខ្លីដូចតទៅនេះ :

១ តាមប្រពៃណីនិយមនៃយើងអ្នកកាន់ព្រះពុទ្ធសាសនា កាលបើព្រះថេរៈអង្គណាមួយ បានទទួលនាទីជាចៅអធិការ មានសញ្ញាប័ត្រតាមផ្លូវការហើយ គេតែងនាំគ្នាធ្វើបុណ្យប្រសិទ្ធិពរ ចំពោះព្រះថេរៈអង្គនោះ មានកិច្ចស្រោចស្រប់ស្រង់ទឹកជាដើម ចំពោះចៅអធិការថ្មី ដើម្បីឲ្យលោកបានទទួលប្រសិទ្ធិភាពអំពីផលានិសង្សបុណ្យកុសល ដែលទុកជាជាវិភាគទានមួយដ៏ប្រសើរ ។ ឥឡូវនេះព្រះមហាថេរអង្គនេះ បានទទួលឋានៈជាចៅអធិការតាំងពីឆ្នាំ ១៩៤១ ប៉ុន្តែមកគង់ជាប់នៅវត្តនេះ ពីឆ្នាំ ១៩៦៣ បើគិតអំពីឆ្នាំដែលបានទទួលសញ្ញាប័ត្រចៅអធិការចំនួន ៦ ឆ្នាំហើយ ប៉ុន្តែពុទ្ធបរិស័ទ សិស្ស គណ ពុំទាន់បានធ្វើកិច្ចកុសលណាមួយប្រគេននៅឡើយ ។

អាស្រ័យហេតុដូចរៀបរាប់មកនេះ ទើបខ្ញុំព្រះករុណាទាំងឡាយ

បានជំនុំព្រមព្រៀងគ្នាផ្ដើមធ្វើបុណ្យក្នុងឱកាសនេះ ដើម្បីជាសក្ខីភាពនៃសេចក្ដីគោរពសេចក្ដីជ្រះថ្លាចំពោះលោក ៗ កាលជំនុំអំពីបុណ្យនេះមុនដំបូង មូលមតិគ្នាជាឯកច្ឆន្ទហើយ ទើបបានចូលមកពិតលោកអំពីកិច្ចបុណ្យចំរើនជន្មាយុនេះ លោកបានឃាត់យើងកុំគ្នាអស់រលីងដែរ ប៉ុន្តែយើងខ្ញុំចេះតែទទូចអង្វរព្រះម័យទាល់តែលោកព្រមដោយតុណ្ហីភាព ៗ

២ – សកម្មភាពនៃព្រះតេជព្រះគុណយើងឃើញថា មានការចំរើនលូតលាស់ក្នុងវត្តគួរសមណាស់ហើយ ដែលតាំងពីលោកមកគង់វត្តនេះ យើងខ្ញុំពុំទាន់បានបំពេញករណីយកិច្ចជាកុសល ចំពោះលោកសោះ ដើម្បីជាកិច្ចកតញ្ញូកតវេទិតា តាមប្រពៃណីដែលយើងធ្លាប់អនុវត្តមកហើយ ហៅថាបុណ្យចម្រើនជន្មាយុចំពោះព្រះមហាថេរ ដែលយើងគួរគោរព ៗ ព្រះតេជព្រះគុណអង្គនេះ មានសកម្មភាពល្អ ជឿនលឿនឈានទៅមុខជាដរាប ចំពោះកិច្ចស្ថាបនាតាំងកិច្ចគ្រប់គ្រងវត្តអារាម និងភិក្ខុសាមណេរ ៗ

ក្នុងករណីដូចថ្លែងមកនេះ បណ្ដាលឲ្យយើងខ្ញុំជាពុទ្ធបរិស័ទសិស្សគណ បបួលគ្នាផ្ដើមធ្វើបុណ្យចម្រើនព្រះជន្មាយុ ចំពោះព្រះមហាថេរអង្គនេះ ឲ្យសមគួរដល់កិត្តិយសនៃលោក ពីព្រោះកាលអំណើះព្រះតេជព្រះគុណព្រះមុនីកោសល សោម-ឈុន ដែលទទួលអនិច្ចធម្មទៅ ក្នុងកាលខាងក្រោយដែលបូជាព្រះសពរួចហើយ យើងខ្ញុំបានសូមនិមន្តធ្វើជាចៅអធិការនោះ ព្រះតេជព្រះគុណអង្គនេះ ចេះតែប្រកែកជាច្រើនដង លុះ

តែយើងខ្ញុំបបួលគ្នាទៅឯវត្តខណ្ឌលោម ថ្វាយបង្គំគាល់សម្តេចព្រះសង្ឃ-រាជ ហាក់ដូចជាបាតុកម្ម ទ្រង់ក៏បានជួយឧបត្ថម្ភដោយព្រះឧបាយដ៏ប្រពៃ ទាល់តែបានសម្រេចដូចបំណង ។

៣- ព្រះតេជព្រះគុណមហាថេរអង្គនេះ ដែលយើងដឹងមកថា តាំងពីលោកចូលធ្វើការនៅក្នុងក្រុមជំនុំព្រះត្រៃបិដក ពុទ្ធសាសនបណ្ឌិត្យ ពីឆ្នាំ ១៩៣៣ មេះតែមានសុខភាពកាយស្រួលល្អណាស់ ពុំដែលឮថា លោកមានជម្ងឺជម្ងាត់ណាមួយឡើយ បើគិតអំពីឆ្នាំនោះមកដល់ឆ្នាំនេះ ៣៤ ឆ្នាំហើយ ពុំដែលឃើញថាលោកមានអាពាធ ដល់ថ្នាក់សិងពេទ្យនោះទេ ទើបតែឥឡូវនេះ រវាងជិត ១ ឆ្នាំហើយ ស្រាប់តែមានអាពាធដ៏ចម្លែក គឺរោគរលាកចំពង់ក បានឲ្យគ្រូពេទ្យពិនិត្យមើលថារោគនេះ តាមពាក្យបារាំងហៅថា អ៊ុលសេរ៍ (រោគរលាក) រាប់ថាជារោគក្រមួយដែរ បើមិនប្រញាប់ព្យាបាលមែនទែន នឹងអាចក្លាយទៅជារោគកង់សេរ "រោគមហារីក" បានដែរ ។ រោគក្នុងកាយនៃព្រះតេជព្រះគុណអង្គនេះ នាំឲ្យយើងខ្ញុំមានសេចក្តីទុក្ខព្រួយរមែជាមួយណាស់ បានព្យាបាលដោយឱសថដ៏វិសេសច្រើនមុខអស់រវាង ៣ ខែមកហើយ ឥឡូវនេះបានធូរស្រាលគ្រាន់បើដែរហើយ ។

ហេតុការណ៍ដូចរៀបរាប់ប្រគេនជូនមកនេះ បានជាយើងខ្ញុំពុំដឹងរកមធ្យោបាយណាមួយដែលប្រសើរវិសេសជាងការព្យាបាលរោគ និងការធ្វើ

បុណ្យនេះឯ ។ ការធ្វើបុណ្យនេះ ទុកថាជាកិច្ចសម្បូរសម្រួលប្រសិទ្ធិពរ ប្រគេនចំពោះព្រះមុនីកោសល សូមតេជាពលក្ខណកាយ ព្រះតេជព្រះគុណនេះ បានជាសះស្បើយល្ហើយជ្រះស្រឡះ តាំងពីពេលនេះតទៅ ដោយអំណាចគុណព្រះរតនត្រ័យ និងបុណ្យកុសលនេះ!

សម្តេចព្រះពោធិវង្ស ព្រះករុណាទាំងឡាយ លោកអ្នកពុទ្ធបរិស័ទទាំងឡាយ សូមជួយតាំងព្រះទ័យ តាំងចិត្តប្រសិទ្ធិពរ ប្រគេនជោគជ័យសិរីមង្គលចំពោះព្រះមុនីកោសល ដោយព្រះទ័យដោយចិត្តដ៏បរិសុទ្ធគ្រប់អង្គ គ្រប់ៗគ្នា ដើម្បីរម្ងាប់ពេគនៃព្រះតេជព្រះគុណព្រះមុនីកោសល ឲ្យជាសះស្បើយផុតពាប់រលួសកន់ ឲ្យមានសុខភាពបរិបូណ៌ឡើងវិញ អំពីពេលនេះតវៃទៅអនាគតទៅ! សូមសម្តេច សូមព្រះករុណាគ្រប់ព្រះអង្គ សូមលោក-អ្នកទាំងឡាយ ជួយបញ្ចេញក្រសែដួងចិត្តដ៏បរិសុទ្ធ ឲ្យជោគជៅត្រង់ឆ្ពោះទៅរកព្រះតេជព្រះគុណព្រះមុនីកោសល ដែលកំពុងមានពេគរលាកបំពង់ក ឲ្យបានជាស្រាកស្រាន្តធូរស្រាលសះស្បើយ ដោយអំណាចតេជះគុណព្រះរតនត្រ័យ និងអានុភាពនៃចិត្តដ៏បរិសុទ្ធគង់បុណ្យកុសលនេះកុំបីឃ្លៀងឃ្លាត!

សុន្ទរកថានៃខ្ញុំព្រះករុណា អាត្មាភាព ដែលថ្លែងមកនេះ កាលបើលោកអ្នកពុទ្ធិកជនមានសេចក្តីពេញចិត្តជូនបំណងប្រាថ្នានេះហើយ សូមតាំងសច្ចាធិដ្ឋានដោយចិត្តស្មោះត្រង់ ហើយបន្លឺនូវវាចាជាពីសុភាពថា សាធុបីដងឲ្យព្រមៗគ្នាទៅហោង! ចប់ ។

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ
## ក្នុងខែ មិថុនា និង កក្កដា ១៩៦៧

១– ចលនាបុគ្គលិក.–

សហ. គុយ-សូត្រ បានចូលនិវត្តន៍តាំងពីថ្ងៃ ២១–៦ ៦៧ តាមអំណាចប្រកាសក្រសួងមហាផ្ទៃលេខ ១៣៣៨ ចុះថ្ងៃទី ៣-៦-៦៧ ។

សហ. ទិម សួរ អ្នកនិពន្ធតែងសេចក្តី ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ បានត្រូវតែងតាំងជាបេឡាធិការ ជំនួស សហ. គុយ-សូត្រ តាមអំណាចប្រកាសក្រសួងហេរញ្ញវត្ថុ លេខ ១៧៣៤ ចុះថ្ងៃ ២១-៦-៦៧ ។

សហ. លឹម-លាងជិន អត្តលេខ ៤១៧៤ គ្រូបង្រៀនថ្នាក់បំពេញវិជ្ជា ថ្នាក់លេខ ១ ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ត្រូវបានច្បាប់ឈប់សម្រាកពិសេសចំនួនពីរខែ តាមសេចក្តីសុំរបស់សាមីខ្លួន ដើម្បីទៅឈរឈ្មោះជាបេក្ខជនបោះឆ្នោតរើសតំណាងរាស្ត្រ; តាមលិខិតអនុញ្ញាតនៃក្រសួងធម្មការ លេខ ១១ ប. ចុះថ្ងៃ ២៩-៧-៦៧ ។

២– ការទាក់ទងផ្សេងៗ.–

ក្រៅពីការទាក់ទងសំបុត្រស្នាមជាមួយក្រសួង និង ក្រុមរាជការនានា វិជ្ជាឋានបានធ្វើអំណោយសៀវភៅព្រះត្រៃបិដកមួយចប់ ទៅតម្កល់ទុកនៅ

ក្រុងប៉ៃរឡាំង តាមសេចក្ដីស្នើសុំនៃឯកអគ្គរាជទូតយើង ប្រចាំក្រុងមូស្គូ ហើយដែលក្រសួងការបរទេសបានស្នើបន្តមក ។

បានប្រគេនតាមសេចក្ដីសុំនូវ សៀវភៅធម៌ផ្សេងៗ ចំនួន ១០០០ ក្បាល ចំពោះសម្ដេចព្រះសង្ឃនាយក ដើម្បីព្រះអង្គចែកទៅតាមវត្តនានាដែលព្រះអង្គនិមន្តទៅតាំងមេគណ-អនុគណ ខាងគណៈធម្មយុត្តិកនិកាយ ។

៣- ខាងផ្នែកបោះពុម្ពផ្សាយ.-

បានបើកការដេញថ្លៃបោះពុម្ពព្រះត្រៃបិដក តាំងពីភាគ ៩១ ដល់ភាគ ១០១ ។ សព្វថ្ងៃការបោះពុម្ពនេះ កំពុងប្រព្រឹត្តទៅយ៉ាងទៀងទាត់ ដើម្បីសេចក្ដីត្រេកអរនៃពុទ្ធសាសនិកយើង ដែលតែងរង់ចាំឲ្យបោះពុម្ពឲ្យបានចប់ឆាប់ៗ ព្រោះពីដើមមក ក្នុងមួយឆ្នាំបោះបានតែ ២ ឬ ៣ ភាគប៉ុណ្ណោះ ។

ក្រៅពីព្រះត្រៃបិដកជាប់ភាគនេះ វិជ្ជាឋានបានចាត់ការបោះឡើងវិញនូវសៀវភៅផ្សេងៗ ចំនួន ៦ មុខទៀត ដែលបោះពីលើកមុនហើយលក់អស់ទៅ គឺសៀវភៅប្រជុំរឿងព្រេងភាគ ១-ភាគ ៦, រឿងក្រុងសុភមិត្រ, ពន្លឺអាស៊ីទ្វីប, ពិធីទ្វាទសមាសជាភាសាបារាំង និង គិហិបដិបត្តិ ។

៤- បណ្ណាល័យ.-

ក្នុងរយៈពីរខែនេះ បណ្ណាល័យបានទទួលសៀវភៅថ្មីមកទៀតចំនួន

១៩១ ។ មានអ្នកចូលមកអានចំនួន ៦៣៨ និងអ្នកមកខ្ចីសៀវភៅឯកសារផ្សេងៗ ៦១ នាក់ ។

៥– ការទទួលភ្ញៀវបរទេស.–

ក្នុងពេលពីរខែនេះ វិជ្ជាឋានបានទទួលភ្ញៀវបរទេសពីរដងគឺ :

ពីថ្ងៃ ២៩ មិថុនា ១៩៦៧ បានទទួលលោក ហ្វា-វ៉ាន់ ក្វាង និង លោក ង្វៀន-វ៉ាន់ ម៉ាយ ជាតំណាងទីភ្នាក់ងារយ៉ាយហ្វុង ធ្វើការនៅស្ថានតំណាងរណសិរ្សសេរីការជាតិវៀតណាមខាងត្បូងប្រចាំក្រុងភ្នំពេញ ដែលអញ្ជើញមកជួបគួរសម និង ស្រង់យកពត៌មាន ខាងវប្បធម៌ និង អរិយធម៌ខ្មែរ ។

ថ្ងៃ ៣១ កក្កដា ១៩៦៧ បានទទួលលោក វ៉ាំងសង់-ម៉ុងតី នាយកវិជ្ជាឋានខាងគោលនិយមអាហ្វ្រិកខ្មៅ នៅប្រទេសសេណេហ្កាល់ ដែលលោកត្រូវធ្វើទស្សនកិច្ចជាផ្លូវការនៅប្រទេសកម្ពុជាយើង ។

# ពិធីប្រគល់បរិញ្ញាបត្រនៃពុទ្ធិកមហាវិទ្យាល័យ

សេចក្ដីរាយការណ៍របស់ សហ. លី-ឆាយគេង

ថ្ងៃទី ១៩ សីហា ១៩៥៧ វេលាម៉ោង ៨ ព្រឹក នៅក្នុងបណ្ណាល័យនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ មានការជួបជុំគ្នានូវមន្ត្រីសង្ឃរាជា-គណៈឋានានុក្រមព្រមទាំងសាស្ត្រាចារ្យ បព្វជិតនិងគ្រហស្ថ, ឥស្សរជនស៊ីវិលជាច្រើនរូបដែលបាននិមន្ត និង អញ្ជើញមកជួបជុំក្នុងពិធីប្រគល់បរិញ្ញាបត្រនៃពុទ្ធិកមហាវិទ្យាល័យជាលើកដំបូង ចំពោះសមណនិស្សិតដែលទើបប្រឡងជាប់ចំនួន ៨ រូប ។ ពិធីនេះ បានប្រព្រឹត្តទៅ នៅក្រោមអធិបតីភាព នៃសម្ដេចព្រះពោធិវង្ស និង សហជីវិនទេសរដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងធម្មការ ។

នៅម៉ោង ៨ កន្លះ ភ្ញៀវកិត្តិយសបាននិមន្ត អញ្ជើញមកជួបជុំក្នុងកន្លែងប្រារព្ធពិធី ដែលគេសង្កេតឃើញផ្នែកខាងព្រះសង្ឃ មានៈ ព្រះរាជតំណាងសម្ដេចព្រះសង្ឃរាជ ព្រះតំណាងសម្ដេចព្រះសង្ឃនាយក, សម្ដេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាព្រមទាំងព្រះសង្ឃរាជាគណៈ-ឋានានុក្រម និងព្រះសង្ឃជាសាស្ត្រាចារ្យច្រើនព្រះអង្គ ផ្នែកខាងគ្រហស្ថ មានជាអាទិ៍ សហជីវិន អ៊ុង-ហ៊ុងសាធ ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ, សហជីវិន ចៅ សេង ទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងសេដ្ឋកិច្ចជាតិ និង ជាអធិបតីនៃពុទ្ធិកមហាវិទ្យាល័យ, សហជីវិនវណ្ណា-មូលីវណ្ណា រដ្ឋមន្ត្រីក្រសួងអប់រំជាតិ, សហជីវិន គឹង-គុន

មហាវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទ, សហជីវិន អ៊ុត-ម៉ូត អនុរដ្ឋលេខាធិការក្រសួងធម្មការ, អស់លោកសាស្ត្រាចារ្យសំខាន់ ៗ មន្ត្រីអ្នករាជការខ្លះ នៅក្រសួងធម្មការ ព្រមទាំងអស់លោក ជាភ្ញៀវកិត្តិយសច្រើនទៀត ដែលយើងសុំអភ័យទោស ដោយកប់ទាមមិនបាន អស់នៅក្នុងពេលនេះ ។

ពិធីនេះផ្តើមឡើង គឺមានសហជីវិន កែ-ម៉េងហាប់ ជាអគ្គលេខាធិការ នៃពុទ្ធិកមហាវិទ្យាល័យ ថ្លែងសុន្ទរកថាមួយ ហើយបន្ទាប់មកសហជីវិនទេសរដ្ឋមន្ត្រី ក៏បានថ្លែងឆ្លើយតបវិញ ។ សុន្ទរកថាទាំងពីរនេះ មានសេចក្តីដូចតទៅ ៖

សុន្ទរកថារបស់សហជីវិន អគ្គលេខាធិការ
ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ថ្លែងក្នុងឱកាសពិធី
ប្រគល់បរិញ្ញាប័ត្រ ចំពោះនិស្សិត ពុទ្ធិកវិទ្យាល័យ ព្រះសីហនុរាជ

សូមប្រណិបតន៍សហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ
សូមក្រាបថ្វាយបង្គំព្រះរាជតំណាងសម្តេចព្រះសង្ឃរាជ, ព្រះតំណាងសម្តេចព្រះសង្ឃនាយក, សម្តេចព្រះពោធិវង្ស
ព្រមទាំងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ
សូមគោរព សហជីវិន សហជីវិនី,

ថ្ងៃសៅរ៍ ១៩ ខែសីហា គ.ស. ១៩៦៧ នេះ ជាទិវាមួយប្រកប

ដោយនក្ខត្តឫក្សជោគជ័យសិរីមង្គល ចំពោះពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ព្រោះជាថ្ងៃដែលសមណនិស្សិត ពុទ្ធិកមហាវិទ្យាល័យ ផ្នែកទុតិយភូមិ ត្រូវទទួលជាឧឡារិកនូវបរិញ្ញាបត្រដែលជា ជោគជ័យនៃជំហានទី ២ របស់ពុទ្ធិកមហាវិទ្យាល័យ បន្ទាប់ពីជោគជ័យនៃជំហានទី ១ ដែលពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ បានទទួលកាលពីឆ្នាំ ១៩៦២ ក្នុងឱកាសធ្វើពិធីប្រគល់សញ្ញាបត្រ ពុទ្ធិកឧត្តមសិក្សា បឋមភូមិ ។

តាងនាមនៃពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងយ៉ាងស្មោះស្ម័គ្របំផុត ជូនចំពោះសហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ ដែលបានអញ្ជើញមកជាអធិបតី ក្នុងពិធីប្រគល់បរិញ្ញាបត្រជាគ្រាដំបូង ចំពោះសមណនិស្សិតនៃពុទ្ធិកមហាវិទ្យាល័យ ញុំាងពិធីនេះ ឲ្យរឹងរឹតតែមានភាពឧឡារិកឡើង ព្រមទាំងថ្លែងនូវអំណរគុណប្រគេន-ជូនចំពោះព្រះថេរានុត្ថេរៈ សហជីវិនី សហជីវិន គ្រប់ព្រះអង្គ គ្រប់រូប ដែលបាននិមន្ត អញ្ជើញមកជាកិត្តិយសទទួលអបអរសាទរក្នុងពិធីនេះ ដែលជានិមិត្តនៃជោគជ័យថ្មីមួយទៀតរបស់ពុទ្ធិកមហាវិទ្យាល័យ ។

បន្ទាប់ពីនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុញ្ញាតអំពីសហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ ដើម្បីថ្លែងដោយសង្ខេបនូវដំណើរការណ៍ នៃការសិក្សារបស់ពុទ្ធិកមហាវិទ្យាល័យ ដំណើរការណ៍ដែលបានប្រព្រឹត្តទៅដោយជោគជ័យសិរីមង្គល ។

កាលពីឆ្នាំ ១៩៥៣ សម្ដេចព្រះពោធិវង្ស កាលមានសមណសក្ដិជាព្រះពោធិវង្ស បានទទួលព្រះបរមអនុញ្ញាត ពីព្រះករុណា, ព្រះបាទសម្ដេចព្រះនរោត្តម សីហនុ គឺសម្ដេចព្រះប្រមុខរដ្ឋ កាលព្រះអង្គទ្រង់គង់នៅក្នុងព្រះរាជសម្បត្តិនៅឡើយ ឲ្យទៅពិនិត្យមើលការសិក្សា ខាងព្រះពុទ្ធសាសនា នៅបរទេសអស់រយៈកាល ១ខែ ។ លុះត្រឡប់មកវិញ សម្ដេចព្រះពោធិវង្សបានធ្វើសេចក្ដីរាយការណ៍ យ៉ាងពិស្ដារថ្វាយព្រះករុណាជាម្ចាស់ជីវិត ដើម្បីទ្រង់ជ្រាប ។ ព្រះករុណាជាម្ចាស់ជីវិត លុះទ្រង់បានជ្រាបសេចក្ដីរាយការណ៍នោះហើយ ទ្រង់បានព្រះរាជបញ្ជាទៅក្រសួងធម្មការ ឲ្យចាត់ការបង្កើតគណៈកម្មការ ជំនុំពិនិត្យដោយរួសរាន់ ។ គណៈកម្មការនោះបានជំនុំពិគ្រោះគ្នារួចហើយ បានធ្វើសេចក្ដីរាយការណ៍ថ្វាយព្រះករុណាជាម្ចាស់ជីវិត ដោយស្នើសុំបង្កើតពុទ្ធិកមហាវិទ្យាល័យខាងព្រះពុទ្ធសាសនា ។ ព្រះករុណាជាម្ចាស់ជីវិត ព្រះបាទ នរោត្តម សីហនុ កាលទ្រង់បានជ្រាបសេចក្ដីរាយការណ៍របស់គណៈកម្មការសព្វគ្រប់ហើយ ទ្រង់សព្វព្រះរាជហឫទ័យសម្រេចឲ្យបង្កើតពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ដោយព្រះរាជក្រមលេខ ៨៧៩ ន.ស. ចុះថ្ងៃទី ១ ខែកក្កដា គ.ស. ១៩៥៤ ។ ដោយខ្វះអគារសិក្សា ដោយមិនទាន់មានកម្មវិធីសិក្សា និងដោយមិនទាន់មានសមណនិស្សិតដែលមានចំណេះវិជ្ជាអាចចូលមកសិក្សាបាននៅឡើយ លុះដល់មក គ.ស. ១៩៥៩ ទើបពុទ្ធិកមហាវិទ្យាល័យ បានបើកទ្វារទទួល

សមណនិស្សិតជាលើកដំបូង ។ ចាប់តាំងពី គ.ស.១៩៥៩ នោះមក ពុទ្ធិកមហាវិទ្យាល័យបានចំរើនលូតលាស់ជាដរាបរៀងមក ។

នៅឆ្នាំសិក្សា ១៩៥៩-៦០ មាននិស្សិត ចំនួន ៤០ រូប

– ១៩៦០-៦១ . . . . ៨០ –

– ១៩៦១-៦២ . . . . ១០៧ -

នៅដំណាច់ឆ្នាំសិក្សា ១៩៦១-៦២ សមណនិស្សិតជំនាន់ទី ១ បានសិក្សាចប់ថ្នាក់ផ្នែកបឋមភូមិ ហើយបានប្រឡងជាប់សញ្ញាប័ត្រ ពុទ្ធិកឧត្តមសិក្សាបឋមភូមិបានចំនួន ២៤ រូប ។ ក្នុងឆ្នាំនោះ ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ បានរៀបចំធ្វើពិធីប្រគល់សញ្ញាប័ត្រជាឧឡារិកម្ដង ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់នៃសម្ដេចព្រះប្រមុខរដ្ឋ ដែលជានិមិត្តរូបនៃជោគជ័យទី ១ របស់ពុទ្ធិកមហាវិទ្យាល័យ ក្នុងដំណើរការសិក្សារបស់ខ្លួន ។ សមណនិស្សិតជំនាន់ក្រោយបន្តមកទៀត បាននាំគ្នាសិក្សាជាលំដាប់លំដោយរៀងរាល់ឆ្នាំមក ដែលជាហេតុនាំឲ្យមានសមណនិស្សិតថ្មីៗ ទៀត បានប្រឡងជាប់សញ្ញាប័ត្រ ពុទ្ធិកឧត្តមសិក្សាបឋមភូមិ រៀងរាល់ឆ្នាំជាបន្តបន្ទាប់មក ដូចតទៅនេះ ៖

ឆ្នាំ ១៩៦៣ ប្រឡងជាប់បាន ៣២ រូប

– ១៩៦៤ . . . . ៣៦ –

– ១៩៦៥ . . . . ២៥ –

ឆ្នាំ ១៩៦៦ ប្រឡងជាប់ ២៧ រូប

— ១៩៦៧ . . . . ២៥ —

បូករួមតាំងអស់មកដល់ឆ្នាំ ១៩៦៧ នេះ សមណនិស្សិតដែលបាន ប្រឡងជាប់សញ្ញាបត្រ ពុទ្ធិកឧត្តមសិក្សា បឋមភូមិ មានចំនួន១៦៥ រូបៗ

សមណនិស្សិត ដែលបានប្រឡងជាប់សញ្ញាបត្រ ពុទ្ធិកបឋមភូមិ ខ្លះ បានសុំចុះឈ្មោះបន្តការសិក្សាខាងផ្នែកទុតិយភូមិទៀត ។ ស្ថិតិ និស្សិតផ្នែកទុតិយភូមិ មានដូចតទៅនេះ ៖

ឆ្នាំសិក្សា ១៩៦២ ៦៣ មានចំនួន ១២ រូប

— ១៩៦៣–៦៤ . . . ១៥ —

— ១៩៦៤–៦៥ . . . ២១ —

— ១៩៦៥–៦៦ . . . ៣២ —

— ១៩៦៦–៦៧ . . . ៤៤ —

— ១៩៦៧–៦៨ . . . ៤៨ —

ការសិក្សានៅផ្នែកទុតិយភូមិនេះ មានការចែកជាបរិញ្ញាផ្សេងៗ គ្នា តាមឯកទេសភាពនៃវិជ្ជានីមួយៗ ។ ដើម្បីឲ្យបានសញ្ញាបត្រ នៃផ្នែក ទុតិយភូមិនេះ សមណនិស្សិតត្រូវសិក្សា ៤ ឆ្នាំយ៉ាងតិច គឺត្រូវប្រឡង ជាប់វិញ្ញាបនបត្រឧត្តមសិក្សាចំនួនតាំងអស់ ៤ ។ និស្សិតតាំង ៨ រូប ដែលបានប្រឡងជាប់បរិញ្ញាមុនគេ ហើយដែលមានកិត្តិយសនឹងបានទទួល

យកសញ្ញាប័ត្រក្នុងពេលបន្តិចទៀតនេះ សុទ្ធតែជ្រើសរើសយកបរិញ្ញាខាងទស្សនវិជ្ជា ។

ដូច្នេះ សមណនិស្សិតទាំង ៨រូប បានប្រឡងជាប់វិញ្ញាបនប័ត្រ ឧត្តមសិក្សាចំនួន ៤ គឺ:

- វិញ្ញាបនប័ត្រ ឧត្តមសិក្សា ទស្សនវិជ្ជាទូទៅ
- វិញ្ញាបនប័ត្រ ឧត្តមសិក្សា ទស្សនវិជ្ជាបស្ចិមប្រទេស
- វិញ្ញាបនប័ត្រ ឧត្តមសិក្សា ទស្សនវិជ្ជាបូព៌ាប្រទេស
- វិញ្ញាបនប័ត្រ ឧត្តមសិក្សា សាសនាប្រៀបធៀប ។

សមណនិស្សិតខ្លះទៀត បានជ្រើសរើសយកបរិញ្ញា ខាងវិជ្ជាដទៃៗទៀត ដូចបរិញ្ញាខាងបូរាណភាសាជាដើម ។ ក៏ប៉ុន្តែ សមណនិស្សិតទាំងនោះ ពុំទាន់ដល់គំរប់ឆ្នាំនឹងប្រឡងយកវិញ្ញាបនប័ត្រ នៅឡើយ ។ ជាសង្ខេបទៅ ឃើញថា តាំងពីបានចាប់បដិសន្ធិឡើង នៅឆ្នាំ ១៩៥៩ រហូតមកដល់ឆ្នាំ ១៩៦៧ នេះ ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ បានបញ្ចេញសញ្ញាប័ត្រ ពុទ្ធិកឧត្តមសិក្សា បឋមភូមិ បានចំនួនទាំងអស់១៦៥, សញ្ញាប័ត្រទុតិយភូមិ គឺបរិញ្ញាប័ត្របានចំនួន ៨ ។ សមណនិស្សិតខ្លះ ដែលបានប្រឡងជាប់បរិញ្ញាប័ត្រ មានបំណងនឹងបន្តការសិក្សាទៅខាងផ្នែកតតិយភូមិទៀត គឺថ្នាក់បណ្ឌិត ។ ដូច្នេះ ក្នុងអនាគតកាលដ៏ខ្លីខាងមុខនេះ ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ មានសេចក្ដីសង្ឃឹមថា នឹង

បានបញ្ចេញសញ្ញាប័ត្រតតិយភូមិ គឺសញ្ញាប័ត្របណ្ឌិត តទៅទៀត ។ ម្ល៉ោះហើយ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមសន្និដ្ឋានទុកជាមុនថា សហជីវិនទេសរដ្ឋមន្ត្រីមុខជានឹងបានអញ្ជើញមកជាអធិបតីនៃពិធីប្រគល់សញ្ញាប័ត្រថ្នាក់បណ្ឌិត របស់ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ក្នុងពេលដ៏ខ្លីខាងមុខនេះទៀត ជាពុំខានឡើយ ។

បើគិតទៅតាមកាលបរិច្ឆេទ ជោគជ័យនៃជំហានទី ១ ក្តី ជោគជ័យនៃជំហានទី ២ ដែលយើងរៀបចំធ្វើពិធីនេះជានិមិត្តរូបក្នុងពេលនេះក្តី ជាជោគជ័យដែលបានកើតឡើង ក្រោយពីប្រទេសខ្មែរយើងបានឯករាជ្យដ៏បរិបូណ៌ ដោយស្នាព្រះហស្តនៃសម្តេចព្រះនរោត្តម-សីហនុ ហើយជាពិសេស ក្នុងសម័យដែលប្រទេសយើងឋិតនៅក្រោមការដឹកនាំ របស់ចលនាសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះប្រមុខរដ្ឋ ជាព្រះប្រធាន ។

ដូច្នេះ ជោគជ័យទាំងអស់នេះ ជាជោគជ័យរបស់សង្គមរាស្ត្រនិយម ដែលយើងត្រូវកប់បញ្ចូលទៅក្នុងសមិទ្ធិដ៏ច្រើនឥតគណនា របស់សង្គម-រាស្ត្រនិយម ក្នុងការស្ថាបនាជាតិឲ្យបានទៅជាអារ្យប្រទេស ។

ក្នុងសម័យសង្គមរាស្ត្រនិយម ពុទ្ធិកសិក្សា តាំងពីថ្នាក់តូច រហូតដល់ឧត្តមសិក្សា បានកែរៀបចំឲ្យមានទម្រង់ថ្មីស្របតាមកាលៈទេសៈហើយ ។ គួរកត់សំគាល់ថា ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ជាពុទ្ធសាកលវិទ្យាល័យ បានកើតឡើងមុខគេបង្អស់ក្នុងចំណោមសាកលវិទ្យាល័យទាំង

ឡាយ នៃព្រះរាជាណាចក្រកម្ពុជាយើង ។ ដោយព្រះតម្រិះរបស់សម្ដេចព្រះពោធិវង្ស ពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ តាំងតែពីបានកើតឡើង បានយកភាសាខ្មែរមកធ្វើជាភាសា យានក្នុងការបង្ហាត់បង្រៀន ។ ក្នុងសម័យនេះ ដែលក្រសួងអប់រំជាតិ ត្រូវរៀបចំធ្វើខេមរយានកម្មក្នុងការសិក្សាស្របតាមសេចក្ដីសម្រេចនៃសមាជជាតិ ពុទ្ធិកមហាវិទ្យាល័យ បានក្លាយទៅជាទីពន្សូចក្នុងចលនាខេមរយានកម្មនេះ ពីព្រោះសាស្ត្រាចារ្យទាំងឡាយ ដែលធ្លាប់មានការពិសោធន៍ក្នុងបញ្ហានេះ ខាងពុទ្ធិកសិក្សា បានយកការពិសោធន៍របស់ខ្លួន ទៅអនុវត្តធ្វើសហប្រតិបត្តិការយ៉ាងពេញទំហឹង ក្នុងចលនាជាតិនៃខេមរយានកម្ម ដោយសាស្ត្រាចារ្យខ្លះ បានចូលជាសមាជិករបស់គណៈកម្មាធិការជាតិ សាស្ត្រាចារ្យខ្លះទៀត ធ្វើជាប្រធានឬសមាជិករបស់គណៈកម្មការបច្ចេកទេស នៃខេមរយានកម្ម ដែលក្រសួងអប់រំជាតិ កំពុងតាក់តែងប្រតិបត្តិការ ដើម្បីធ្វើការអនុវត្តឲ្យបានទាន់នៅបរិវេសនកាលខាងមុខនេះ ។

ម្យ៉ាងវិញទៀត ចាប់តាំងពីពេលដែលពុទ្ធិកមហាវិទ្យាល័យ បានបញ្ចេញសញ្ញាបត្រនេះមក ពុទ្ធិកមហាវិទ្យាល័យ មានសេចក្ដីរីករាយពេញចិត្តនឹងជោគជ័យរបស់ខ្លួនជាអនេក ពីព្រោះពុទ្ធិកមហាវិទ្យាល័យ បានបំពេញបេសកកម្មខ្លួនយ៉ាងហ្មត់ចត់ ស្រេះទៅតាមព្រះរាជបំណងរបស់ព្រះអគ្គមគ្គុទ្ទេសក៍របស់ខ្លួន ដែលមានព្រះរាជបន្ទូលក្នុងសុន្ទរកថារបស់ព្រះអង្គក្នុងឱកាសសម្ភោធពុទ្ធិកមហាវិទ្យាល័យ ថា :

ការដែលប្រទេសកម្ពុជាយើង បានបង្កើតឲ្យមានពុទ្ធិកមហាវិទ្យាល័យនេះ ជាការដ៏ប្រសើរមួយ ដែលត្រូវតែត្រាទុកក្នុងប្រវត្តិសាស្ត្រនៃជាតិយើង នៃប្រទេសយើង ដែលអំណោះតទៅសាកលលោកសន្មតបាន ថា មានវឌ្ឍនធម៌ខ្ពង់ខ្ពស់ក្នុងពុទ្ធិកសិក្សា ស្មើហ៊ាននឹងអារ្យប្រទេសឯទៀត ដែលកាន់លទ្ធិសាសនាដូចគ្នា ។

ជាការពិតណាស់ អំណោះតទៅ ជាមួយនឹងបរិញ្ញាបត្រ ដែលសហជីវិនទេសរដ្ឋមន្ត្រី នឹងប្រគល់ចំពោះទៅនិស្សិតក្នុងពេលបន្តិចទៀតនេះ ពុទ្ធិកមហាវិទ្យាល័យ បានក្លាយខ្លួនទៅជាគ្រឹះស្ថានឧត្តមសិក្សាមួយពេញលក្ខណៈ ដែលនឹងធ្វើឲ្យប្រទេសយើង ដែលតំកល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ មិនខ្មាសប្រទេសឯទៀត ដែលកាន់ព្រះពុទ្ធសាសនាដូចយើង ហើយថែមទាំងធ្វើឲ្យប្រទេសយើងរឹងរឹតតែមានកិត្យានុភាពខ្ពង់ខ្ពស់ឡើងទៀតៗ

ជោគជ័យរបស់ពុទ្ធិកមហាវិទ្យាល័យ បានបញ្ជាក់ឲ្យឃើញម្យ៉ាងទៀតថា នៅក្នុងកម្ពុជរដ្ឋយើង ពុទ្ធចក្របានវិលយ៉ាងលឿនស្របគ្នានឹងអាណាចក្រ ។ នេះជាភស្តុតាងមួយបង្ហាញយ៉ាងច្បាស់លាស់ថា សង្គមរាស្ត្រនិយម ក្រោមការដឹកនាំយ៉ាងវាងវៃរបស់សម្តេចព្រះនរោត្តម-សីហនុ ពុំបានភ្លេចក្នុងវិស័យណាមួយទេ ក្នុងការកសាងជាតិ ក្នុងវិស័យពុទ្ធចក្រ ក៏ដូចជាក្នុងវិស័យអាណាចក្រដែរ ។

គឺដោយសារការណែនាំ និង ការឧបត្ថម្ភគ្រប់បែបយ៉ាង របស់សង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះប្រមុខរដ្ឋ ជាព្រះប្រធាននេះ ហើយ ដែលនាំឲ្យសមណនិស្សិតបានខំប្រឹងប្រែងព្យាយាមយកចិត្តទុកដាក់ក្នុងការសិក្សារៀនសូត្រ ដែលនាំឲ្យអស់លោកសាស្ត្រាចារ្យ ទាំងបណ្ឌិត ទាំងគ្រហស្ថ ព្រមទាំងបុគ្គលិកនៃមន្ទីរចាត់ការពុទ្ធិកវិទ្យាល័យ ខំប្រឹងប្រែងបង្ហាត់បង្រៀន និង ខំប្រឹងប្រែងបំពេញកិច្ចការផ្សេង ៗ យ៉ាងហ្មត់ចត់ នាំឲ្យពុទ្ធិកមហាវិទ្យាល័យ បានស្គាល់នូវជោគជ័យដ៏ប្រសើរ ដែលខ្ញុំព្រះករុណា ខ្ញុំបាទ បានរៀបរាប់ដោយសង្ខេបអម្បាញ់មិញនេះ ។ អាស្រ័យហេតុនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុញ្ញាតអំពីសហជីវិនទេសរដ្ឋមន្ត្រី ដើម្បីឆ្លៀតឱកាសនេះ ថ្លែងនូវអំណរគុណយ៉ាងស្មោះស្ម័គ្រ និងសេចក្តីសរសើរយ៉ាងកក់ក្តៅចំពោះសមណនិស្សិត ចំពោះអស់លោកសាស្ត្រាចារ្យ និងចំពោះបុគ្គលិកនៃមន្ទីរចាត់ការ ដែលបានបំពេញពលកម្មគ្រប់បែបយ៉ាង ក្នុងការបំរើពុទ្ធិកសិក្សាឲ្យបានជោគជ័យ ដូចបានបញ្ជាក់ប្រគេន-ជូន រួចមកហើយ ។

ម្យ៉ាងវិញទៀត ជោគជ័យរបស់ពុទ្ធិកមហាវិទ្យាល័យ បានកើតមកពីការជ្រោមជ្រែងជួយឧបត្ថម្ភរបស់ពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ ដូចជាការឧបត្ថម្ភរបស់គហបតី ប៉េ.យាន ជាដើម ដែលបានកសាងអគារសិក្សាមួយខ្នងយ៉ាងធំ ទុកជាសម្បត្តិរបស់រដ្ឋ នៅក្នុងបរិវេណនៃពុទ្ធិកមហាវិទ្យាល័យ

ដើម្បីជាអនុស្សាវរីយ៍របស់លោក ក្នុងការស្ទួយព្រះពុទ្ធសាសនាឲ្យបានរុងរឿងឡើង មួយផ្នែកទៀត ដោយសារការទំប្រឹងប្រែងឥតឈប់ឈររបស់សម្ដេចព្រះពោធិវង្ស . អគ្គាធិការ ពុទ្ធិកសិក្សា ដែលព្រះអង្គបានបរិច្ចាគឥតសំច័យនូវកម្លាំងព្រះកាយ និង កម្លាំងព្រះទ័យ ទុកណាជាព្រះអង្គមានព្រះជន្មវស្សាគ្រាស់ក្រៃលណាស់ទៅហើយក៏ដោយ ហើយជាពិសេសបំផុតគឺដោយសារព្រះបរមរាជូបត្ថម្ភគ្រប់កាលៈទេសៈ ទាំងខាងផ្លូវចិត្តនិងខាងផ្លូវសម្ភារៈ នៃព្រះករុណាព្រះមហាកាញ្ចនកោដ្ឋ សម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះប្រមុខរដ្ឋ ដែលព្រះអង្គយកព្រះទ័យទុកដាក់ជាពិសេសចំពោះពុទ្ធិកសិក្សានេះ ។

ដើម្បីជាកិច្ចតបស្នងសងព្រះមហាករុណាធិគុណដ៏ធ្ងន់នេះ ខ្ញុំព្រះករុណា ខ្ញុំបាទ ក្នុងនាមនៃពុទ្ធបរិស័ទទាំងអស់ ទាំងបព្វជិត ទាំងគ្រហស្ថ សូមបួងសួងចំពោះវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាស្វេតច្ឆត្រជាដើម សូមជួយទ្រទ្រង់អភិបាលសម្ដេចព្រះមហាក្សត្រិយានី និងសម្ដេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានប្រកបដោយព្រះសុខភាពបរិបូណ៌ ឈ្នះអស់មារសត្រូវគ្រប់ទិសទី មានព្រះជន្មាយុយឺនយូរពេញវ័យព្រះវស្សា ដើម្បីបានជាម្លប់ដ៏ត្រជាក់នៃកូនចៅរបស់ព្រះអង្គតរៀងទៅ ។ មួយចំណែកទៀត សូមឲ្យវត្ថុស័ក្តិសិទ្ធិទាំងនោះ ជួយទ្រទ្រង់ពុទ្ធបរិស័ទទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ទាំងបព្វជិត ទាំងគ្រហស្ថ ឲ្យបានប្រកប

ដោយពុទ្ធពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សេចក្ដីគួរពុំគួរ សូមសហជីវិនទេសរដ្ឋមន្ត្រី សូមសម្ដេចជាអម្ចាស់ សូមព្រះថេរានុត្ថេរ សូមសហជីវិនី សហជីវិន មេត្តាប្រោសប្រណី ។

---

# សុន្ទរកថា

សហជីវិនទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ

សូមនមស្ការ ដោយគោរព ចំពោះសម្ដេចព្រះពោធិវង្ស

សូមនមស្ការ ចំពោះព្រះថេរានុត្ថេរ

សូមគោរព ចំពោះសហជីវិនទាំងអស់

ក្នុងឱកាសនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ ក្នុងឋានៈជាទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការ មានសោមនស្សរីករាយណាស់ ដោយបានទទួលនូវកិត្តិយសដ៏ខ្ពង់ខ្ពស់ ក្នុងឋានៈជាអធិបតី នៃពិធីប្រគេន ជូន នូវបរិញ្ញាប័ត្រចំពោះអស់លោកនិស្សិត ជាបព្វជិតខ្លះ ជាគ្រហស្ថខ្លះ ដែលបានសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ នេះ ហើយបានទទួលនូវលទ្ធផលដ៏ប្រសើរ ។

មុននឹងប្រគេន ជូន នូវបរិញ្ញាប័ត្រ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមភនឱកាសបន្តិច ដើម្បីថ្លែងពតិមានសង្ខេបដែលទាក់ទងនឹងពុទ្ធិកសិក្សានេះ ។

អម្បាញ់មិញនេះ សហជីវិន អគ្គលេខាធិការនៃពុទ្ធិកមហាវិទ្យាល័យ បានថ្លែងសុន្ទរកថាយ៉ាងក្បោះក្បាយ អំពីមូលហេតុដែលនាំឲ្យពុទ្ធិកមហាវិទ្យាល័យ បានកើតឡើងអំពីការប្រព្រឹត្តទៅនៃពុទ្ធិកសិក្សាតាំងពីបឋមសិក្សា រហូតដល់ឧត្តមសិក្សា ដែលបានប្រកបដោយសុវត្ថិភាព និងប្រកបដោយជោគជ័យជាដរាបរៀងមក ។

សេចក្តីថ្លែងរបស់សហជីវិនអគ្គលេខាធិការនេះ បានមកដាស់ស្មារតីខ្ញុំឲ្យភ្ញាក់រលឹកឃើញឥតមានសល់ ព្រោះខ្លួនខ្ញុំនេះមិនមែនឋិតនៅឆ្ងាយអំពីពុទ្ធិកសិក្សានេះទេ គឺខ្លួនខ្ញុំបានធ្លាប់បំរើពុទ្ធិកសិក្សានេះច្រើនដងហើយ ដោយហេតុថា ខ្លួនខ្ញុំនេះធ្លាប់ធ្វើជាលេខាធិការផ្ទាល់ នៃរដ្ឋមន្ត្រីក្រសួងធម្មការមួង តមកទៀត បានធ្វើជារដ្ឋលេខាធិការក្រសួងធម្មការពីរដង ឥឡូវបានធ្វើជាទេសរដ្ឋមន្ត្រីទទួលបន្ទុកក្រសួងធម្មការទៀត គឺខ្ញុំមានភ័ព្វសំណាងបានចូលរួមក្នុងពិធីបញ្ចុះបឋមសិលា ខាងពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ព្រមទាំងកម្មវិធីខាងការសិក្សាទៀតផង ។ ដោយហេតុនេះ ខ្ញុំសូមបញ្ជាក់ថា សេចក្តីថ្លែងរបស់សហជីវិនជាការពិតមែនទាំងអស់ ហើយសូមបន្ថែមថាការប្រព្រឹត្តទៅនៃពុទ្ធិកសិក្សាគ្រប់ផ្នែក ខ្លួនខ្ញុំក្តី របស់លោកទាំងឡាយឯទៀតក្តី ពុំអាចនឹងបំភ្លេចបានឡើយ នូវការខំប្រឹងប្រែងព្យាយាមនិងការតស៊ូស្វិតស្វាញជាទីបំផុត នៃសម្តេចព្រះពោធិវង្ស ដើម្បីឲ្យពុទ្ធិកសិក្សាបីផ្នែកបានកើតឡើង ដោយមានរបៀបរបបត្រឹមត្រូវ ក្រោម

ព្រះបរមរាជូបត្ថម្ភ ដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ។

លំដាប់តទៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមសរសើរដោយស្មោះ ចំពោះអស់លោកជាសាស្ត្រាចារ្យ ដែលបានខំបង្ហាត់បង្រៀនដោយយកព្រះទ័យ យកចិត្តទុកដាក់ដល់សមណនិស្សិតគ្រប់រូប សូមសរសើរចំពោះអស់លោកជានិស្សិតគ្រប់រូប ដែលបានខំប្រឹងព្យាយាមតស៊ូក្នុងការសិក្សា នូវចំណេះវិជ្ជា ទាំងខាងផ្លូវព្រះពុទ្ធសាសនា ទាំងខាងផ្លូវលោក អស់រយៈកាលច្រើនឆ្នាំ រហូតដល់បានសម្រេចផលដ៏ប្រសើរ គឺត្រូវបានទទួលនូវបរិញ្ញាបត្រជាគ្រាដំបូងបំផុតនេះ ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណា ខ្ញុំបាទ សូមថ្លែងបញ្ជាក់ថា អស់លោកនិស្សិតដែលបានទទួលបរិញ្ញាបត្រ អំពីពុទ្ធិកមហាវិទ្យាល័យនេះ ត្រូវចាត់ទុកថាជាអ្នកមានចំណេះវិជ្ជាដ៏ខ្ពង់ខ្ពស់ ទាំងខាងផ្លូវព្រះពុទ្ធសាសនា ទាំងខាងផ្លូវលោក សមជាវិញ្ញូកុលបុត្រ ឬវិញ្ញូជន នៃប្រទេសកម្ពុជា សម័យថ្មី ដែលបានទទួលយកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

នៅអវសាននេះ ខ្ញុំព្រះករុណា ខ្ញុំបាទ សូមប្រគេន-ជូន ពរសព្ទសាធុការ ចំពោះអស់លោកជានិស្សិតទាំងអស់ សូមឲ្យបានប្រកបដោយពរទាំង ៥ ប្រការ គឺអាយុៈ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ គ្រប់ទិវារាត្រី កុំបីឃ្លៀងឃ្លាតឡើយ ។

×

បន្ទាប់ពីសុន្ទរកថាទាំងពីរនេះមក ព្រះភិក្ខុ ប៉ាង-ខាត់ សាស្ត្រាចារ្យ និមន្តឡើងហៅនាមបេក្ខសមណៈ ដែលត្រូវមកទទួលបរិញ្ញាប័ត្រនេះមួយម្តងៗ តាមលំដាប់ថ្នាក់ គឺមាននាមដូចតទៅ ៖

១— ទុំ.ថៃ្ល

២. ពាវ-ឆៃសុក

៣ អេង-ប៊ិន

៤. ជា-ហ៊ាង

៥ ឆោម-ប្អាន

៦— គិម.កៀង

៧— លី.សុវ៉ា

៨ ពុទ្ធ-សំអុល

តពីនេះមកទៀត សម្តេចព្រះពោធិវង្ស អគ្គាធិការនៃពុទ្ធិកសិក្សាកុកនមូជវដ្ត និងជាស្ថាបត្យករដើមខាងពុទ្ធិកសិក្សារបស់ខ្មែរយើង ព្រះអង្គទ្រង់មានព្រះថេរដីកា ផ្តាំផ្ញើ ប្រៀនប្រដៅចំពោះអ្នកដែលទទួលសញ្ញាប័ត្រដ៏ឧត្តមទាំងនេះ ដោយព្រះកន្រ្តញញឹម ព្រះពក្តមួយៗ តែប្រកបដោយខ្លឹមសារ ពោរពេញដោយគតិបណ្ឌិត ដែលយើងសូមដកស្រង់តែខ្លះ ដូចតទៅ ៖

ជាបឋម សម្តេចទ្រង់ថ្លែងព្រះអំណរចំពោះកៀរតិ៍គុណយស ជាពិសេស

គឺវរជនសំខាន់ៗ ដែលបានអញ្ជើញមកក្នុងពិធីនេះ ដែលធ្វើឲ្យទឹកព្រះទ័យព្រះអង្គសប្បាយដោយសារកិត្តិយសនេះពន់ប្រមាណ ។ សម្តេចទ្រង់រាប់រៀបអំពីការលំបាកខ្លះ ដែលកើតមានក្នុងជីវភាពសមណនិស្សិត ដែលបានទំពុះពារមកតាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សា ក្នុងរយៈកាលមួយយ៉ាងវែង ។

បន្ទាប់មក ទ្រង់បែរព្រះភក្ត្រទៅផ្តាំផ្ញើចំពោះឧត្តមសិស្សរបស់ព្រះអង្គ ទាំង ៨ រូប មាន ៣ ខ សំខាន់ គឺ៖

១ - តម្លៃនៃបរិញ្ញាបត្រ.— ព្រះអង្គទ្រង់ដៅបញ្ជាក់ថា៖ នេះជាសន្ទឹកមួយបញ្ជាក់ឲ្យស្គាល់ ច្បាស់នូវកំពស់ចំណេះវិជ្ជាដែលយើងមានដែលជាលទ្ធផលដ៏ស្និតស្នាញ នៃពុទ្ធិកមហាវិទ្យាល័យយើង ជាត្រាដំបូង ។ ដូច្នេះ អស់លោកដែលបានទទួល ក៏ត្រូវតែរក្សាតម្លៃនេះឲ្យបានហ្មត់ចត់ល្អតទៅ ។

២- អំពីសារៈប្រយោជន៍.- ព្រះអង្គទ្រង់ផ្តាំបន្តថា : បើយើងបានទទួលសញ្ញាបត្រដ៏ខ្ពង់ខ្ពស់ដូច្នេះហើយ យើងពុំខិតខំត្រិះរិះរៀនសូត្របន្ថែមវិជ្ជា ឬផ្សព្វផ្សាយឲ្យបានល្អនូវចំណេះដែលយើងមានមកហើយទេ នោះបរិញ្ញាបត្រយើង ក៏បាត់គ្មានតម្លៃអ្វីដែរ ។ ហេតុនេះ គួរតែប្រកាន់ខ្ជាប់នូវការព្យាយាមស្វែងវិជ្ជាបន្ថែម និងប្រើការនូវវិជ្ជានេះ ឲ្យបានត្រឹមត្រូវ ហើយបានសាយភាយទូលំទូលាយផង ។

៣– អំពីគុណសម្ប័ទរៀងខ្លួន.– បើយើងមានវិជ្ជាខ្ពង់ខ្ពស់ហើយ យើងតោងតែរក្សាចរិយារបស់យើងឲ្យសមរម្យជាអ្នករៀនសូត្រ ជ្រៅជ្រះខាងព្រះពុទ្ធសាសនា ចំជៀសកងឲ្យផុតពីពាក្យនិន្ទា ដែលអាចកើតមានពេលណាដែលៈយើងភ្លេចខ្លួន ។ បើមានចរិយាប្រពៃជាទីគោរពរាប់អានបែបនេះ គេក្តីឈ្មោះយើងក៏ល្អ បរិញ្ញាបត្រនោះក៏រឹតតែលេចនូវគុណសម្ប័ទពិសេសមួយថែមឡើងទៀត ។

ពិធីនេះបានចប់សព្វគ្រប់នៅម៉ោង ៩ កន្លះ ប្រកបដោយបរិយាកាសយ៉ាងរីករាយក្រៃលែង ។

---